# របត់នយោបាយ

## សីហនុ ~ លន់ នល់ ~ ប៉ុល ពត ~ ហ៊ុន សែន




ឈឹម សេរីធួន



# របត់នយោបាយ

## សីហនុ ~ លន់ នល់ ~ ប៉ុល ពត ~ ហ៊ុន សែន

ភាគ ៣

ហាមថតចម្លង

ស្នាដៃនេះត្រូវបានចុះបញ្ជីលេខ Ⓡ ៦៨៣/២១ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២១ នៅនាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល នៃក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ។

***-ទីប្រឹក្សា និងពិនិត្យអក្ខរាវិរុទ្ធ៖***

វេជ្ជបណ្ឌិត អ៊ុន សុវណ្ណា

***-ការីកុំព្យូទ័រ***

ហែម សុជា

ឈឹម មករា

ប៉ោ កុសល

ចាន់ ពិសុទ្ធ

រក្សាសិទ្ធិ© ឈឹម សេរីភួន គ.ស.២០២២

ISBN-13 : 978-9924-969-808

# ឧទ្ទិសកថា

ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៩ គឺក្នុងរយៈពេលតែ៩ឆ្នាំប៉ុណ្ណោះ ប្រជាជាតិខ្មែរយើងបានឆ្លងកាត់របត់នយោបាយ ក្លាយជារដ្ឋប្រហារ ជាភ្លើងសង្គ្រាមបង្ហូរឈាមខ្មែរគ្នាឯង ហើយទឹកដីប្រទេសកម្ពុជាយើង បានក្លាយជាវាលពិឃាតដ៏មហាព្រៃផ្សៃ បន្សល់ទុកគំនរភ្នំឆ្អឹង ស្ទឹងទឹកភ្នែក ទុកជាដានប្រវត្តិសាស្ត្រឈឺចាប់បំផុតដែលក្នុងប្រវត្តិសាស្ត្រមនុស្សជាតិមិនធ្លាប់ជួបប្រទះកន្លងមក។

ប្រាកដណាស់ ប្រជាជាតិយើងពិតជាមិនចង់ដើរជាន់ដានប្រវត្តិសាស្ត្រគួរឲ្យឈឺចាប់វេទនាខ្លោចផ្សារនេះ ជាថ្មីម្តងទៀតឡើយ ហើយប្រជាជាតិយើងគ្មានប្រាថ្នាអ្វីក្រៅពីស្រុកទេសសុខសន្តិភាពនោះទេ។

ដូច្នេះ សូមអ្នកនយោបាយខ្មែរគ្រប់និន្នាការទាំងអស់ មេត្តាបោះបង់ចោលនូវមហិច្ឆតាដណ្តើមអំណាចគ្នា បង្កជាជម្លោះបែកបាក់ធ្វើឱ្យសង្គមជាតិយើងធ្លាក់ចូលទៅក្នុងភ្លើងសង្គ្រាមបង្ហូរឈាមសម្លាប់តែខ្មែរគ្នាឯង ដូចសម័យមុនៗទៀតទៅ។

សង្គមជាតិមួយដែលមានតែជម្លោះបែកបាក់មិនឈប់ឈរនោះ លទ្ធផល គឺគ្មានអ្វីក្រៅពីការបង្កើតឱ្យមានចលាចល វឹកវរ បង្កអសន្តិសុខ និងការបង្ហូរឈាមខ្មែរគ្នាឯងតែប៉ុណ្ណោះ។

សូមឧទ្ទិសបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក ជួយតាមថែរក្សាប្រជាជាតិមាតុភូមិខ្មែរ ពិសេស សូមអ្នកនយោបាយខ្មែរគ្រប់និន្នាការកុំគិតមហិច្ឆតាដណ្តើមអំណាចគ្នាជាធំសំខាន់គឺសុខសន្តិភាពរបស់ប្រទេសជាតិ ដើម្បីប្រជាពលរដ្ឋរស់នៅដោយសុខសាន្តត្រាណមានសុភមង្គល និងមានឱកាសកសាងអភិវឌ្ឍប្រទេសឲ្យបានរីកចម្រើនថ្កុំថ្កើងរុងរឿងដូចនៅបណ្តាអារ្យប្រទេសនានានៅលើសាកលលោក។

ថ្ងៃពុធ ១២កើត ខែភទ្របទ ឆ្នាំខាលចត្វាស័ក ព.ស២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២២

**អ្នកសិក្សាស្រាវជ្រាវ**

# អារម្ភកថា

ជាបឋម ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **សម្តេច ក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ជាមេដឹកនាំប្រកបដោយគតិបណ្ឌិត ដែលបានជួយឧបត្ថម្ភគាំទ្រទាំងស្រុងក្នុងការបោះពុម្ពសៀវភៅនេះ ដើម្បីទុកជាឯកសារប្រវត្តិសាស្ត្រសំខាន់មួយសម្រាប់សង្គមជាតិ។ បើគ្មានការជួយឧបត្ថម្ភគាំទ្រពី**សម្តេច ក្រឡាហោម** ទេ ក៏គ្មានវត្តមានសៀវភៅនេះដែរ។

រឿងរ៉ាវពិតនៃប្រវត្តិសាស្ត្រមួយចំនួន ត្រូវបានពួកអ្នកនយោបាយខ្លះយកមកកែច្នៃ បំភ្លៃបំប៉ោងប្រាសចាកពីការពិតទាំងស្រុង ដើម្បីបោកបញ្ឆោតប្រជាពលរដ្ឋខ្មែរយើងមួយចំនួន លង់គំនិតជឿតាម ដោយគ្មានការពិចារណារកហេតុផលឬសគល់ឱ្យបានគ្រប់ជ្រុងជ្រោយ បង្កជាការសម្អប់ ការរើសអើង ការចោទប្រកាន់ ការលាបពណ៌ ការប្រមាថមាក់ងាយទៅលើមេដឹកនាំប្រទេស និងឥស្សរជនសម័យមុនៗ ក៏ដូចជាសម័យបច្ចុប្បន្ន ផងដែរ។

ដូច្នេះ ខ្ញុំបាទបានព្យាយាមសិក្សាស្រាវជ្រាវឯកសាររឿងរ៉ាវពិតនៃប្រវត្តិសាស្ត្រខ្មែរ អស់រយៈពេលជាច្រើនឆ្នាំ ទម្រាំចងក្រងបានជា **សៀវភៅរបត់នយោបាយ សីហនុ - លន់ នល់ - ប៉ុល ពត - ហ៊ុន សែន** នេះឡើង ដើម្បីទុកជាពន្លឺខ្លះៗនៅក្នុងការសិក្សាពិចារណារកហេតុផល និងឫសគល់ពិតនៃព្រឹត្តិការណ៍នយោបាយសំខាន់ៗដែលកើតមានឡើងតាំងពីសម័យមុនៗ រហូតដល់សម័យបច្ចុប្បន្ននេះ សម្រាប់ប្រជាពល-រដ្ឋខ្មែរ ពិសេសយុវវ័យសម័យនេះនិងសម័យក្រោយៗទៀត សិក្សាពិចារណាតាមការគួរ។ ការស្វែងយល់ពីប្រវត្តិសាស្ត្រពិត គឺជាការបណ្តុះគំនិតយុត្តិធម៌ មិនឈ្លក់វង្វេងតាមការឃោសនារបស់ពួកអ្នកនយោបាយបោកប្រាស់ ហើយកាន់តែយល់ច្បាស់ពីរបត់នយោបាយពីរបបគ្រប់- គ្រងមួយ ទៅរបបមួយ របស់សង្គមជាតិយើង។

ជាមួយគ្នានេះដែរ ប្រសិនបើមានការខ្វះខាតខុសឆ្គងលើសលោះត្រង់ចំណុចណាមួយ ក៏សូមមេត្តាខន្តីអភ័យទោស ដោយក្ដីអនុគ្រោះ៕

ថ្ងៃពុធ ១២កើត ខែភទ្របទ ឆ្នាំខាលចត្វាស័ក ព.ស២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២២

**អ្នកសិក្សាស្រាវជ្រាវ**

**ឈឹម សេរីវុទ្ធន**

# មាតិកា

●៩៧ សម្តេចសីហនុ ទទួលជំនួយពីចិន ......................................................................1

●៩៨ សាឡុត ស ពង្រីកឥទ្ធិពលរបស់ខ្លួន នៅក្នុងជួរមេដឹកនាំបក្ស........................10

●៩៩ ដាប ឈួន ហៅ ឈួន ម្ជុលពេជ្រ ឡើងតំណែងជាទេសរដ្ឋមន្ត្រី 13

●១០០ ង៉ូ ឱញយៀម បង្ខំសម្តេចសីហនុ ប្រគល់កោះខ្មែរមួយចំនួនទៅឱ្យខ្លួន......... 20

●១០១ ព្រះមហាក្សត្រតែងតាំងសម សារី ជាទីប្រឹក្សារាជរដ្ឋាភិបាល ..................... 25

●១០២ ចលនាយុវជនសង្គមរាស្ត្រនិយមខ្មែរ ....................................................29

●១០៣ ប៉ុល ពត, អៀង សារី, សុន សេន និងប្រពន្ធពួកគាត់ សុទ្ធតែជាសាស្ត្រាចារ្យ 31

●១០៤ ហ៊ូ យន់, ហ៊ូ នឹម និងថៅ សេង និស្សិតឆ្វេងនិយម

ក្លាយជាសមាជិកគណៈរដ្ឋមន្ត្រី ..................................................................36

●១០៥ សម្តេចសីហនុ យាងទៅបំពេញទស្សនកិច្ចនៅអាមេរិក .............................41

●១០៦ សម្តេចសីហនុ ធ្វើមេអណ្តើកឱ្យចិន អាមេរិកថា

ព្រះអង្គមិនដឹងអ្វីបន្តិចសោះ .......................................................................46

●១០៧ ឡឹក សំអឿន ចេញពីក្រុងបាងកក ទៅរកការងារធ្វើនៅក្រុងវៀងចន្ទ .......... 52

●១០៨ សម សារី បង្ករឿងអាស្រូវនៅក្រុងឡុងដ៍..............................................58

●១០៩ សម សារី បង្កើតគណបក្សប្រឆាំង......................................................67

●១១០ អាមេរិក រៀបចំផែនការផ្តួលរំលំសម្តេចសីហនុ ........................................72

●១១១ យួនខាងត្បូង និងថៃ ឱ្យសឺង ង៉ុកថាញ់ សហការជាមួយសម សារី

និងដាប ឈួន ..............................................................................................78

●១១២ សឺង ង៉ុកថាញ់ រៀបចំមូលដ្ឋានយោធាខ្មែរសេរី នៅព្រំដែនយួន និងថៃ ........86

●១១៣ សម សារី រត់គេចខ្លួន មុនពេលកងកម្លាំងចុះបង្ក្រាប...............................93

●១១៤ ដាប ឈួន មានផែនការដាក់ប្រទេស ចូលជាសមាជិកអង្គការសេអាតូ .........98

●១១៥ លន់ នល់ នាំកងទ័ពទៅបង្ក្រាបដាប ឈួន .........................................102

●១១៦ សេអ៊ីអា និងផែនការក្បត់របស់សម សារី និងដាប ឈួន ........................110
●១១៧ វៀតណាមខាងត្បូង និងសេអ៊ីអា រៀបចំផែនការ ផ្តួលរំលំសម្តេចសីហនុ
តាំងពីឆ្នាំ១៩៥៦ ........................................................................119
●១១៨ សម សារី មិនព្រមស្តាប់តាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃថៃ .......125
●១១៩ នរណាផ្ញើគ្រាប់បែក មកថ្វាយសម្តេចសីហនុ និងព្រះមាតាបិតា? ............133
●១២០ គ្រួសារសម សារី រងគ្រោះ ព្រោះរឿងបំផ្ទុះគ្រាប់បែក ...........................138
●១២១ ទំនាក់ទំនងរវាងសហរដ្ឋអាមេរិក និងកម្ពុជា ពីឆ្នាំ១៩៥២ ដល់ឆ្នាំ១៩៥៩ .144
●១២២ សម្តេចសីហនុ រៀបរាប់ពីអំពើក្បត់របស់ សម សារី និងសឺង ង៉ុកថាញ់ ......154
●១២៣ សម សារី និងសឺង ង៉ុកថាញ់ ថា នយោបាយអព្យាក្រឹត
ជានយោបាយទាល់ច្រក ...................................................................160
●១២៤ សម្តេចសីហនុ ផ្តាំទៅសម សារី ថា កុំខ្លាចកុម្មុយនិស្ត
ជាងព្រះអង្គដែលជាស្តេច ..................................................................164
●១២៥ សម សារី ថា៖ សីហនុ ជាជនផ្តាច់ការ បំបាត់លទ្ធិប្រជាធិបតេយ្យ ...........170
●១២៦ សម្តេចសីហនុ មានបន្ទូលពីរឿងអាស្រូវរបស់សម សារី .........................176
●១២៧ សម សារី និងសឺង ង៉ុកថាញ់ ថា៖ សីហនុ ដឹកនាំប្រទេស
លម្អៀងទៅរកកុម្មុយនិស្ត ..................................................................182
●១២៨ សឺង ង៉ុកថាញ់ ជាអ្នកស្នេហាជាតិ ឬជាអ្នកបំផ្លាញជាតិ? ........................187
●១២៩ សម សារី មិនចង់ធ្វើទីប្រឹក្សារាជរដ្ឋាភិបាល
ព្រោះមិនមានអំណាចដូចនាយករដ្ឋមន្ត្រី ...................................................193
●១៣០ សម្តេចសីហនុ ថា៖ សម សារី និងសឺង ង៉ុកថាញ់ ជាជនក្បត់ជាតិ ...........197
●១៣១ ខៀវ សំផន កំពុងជិះកង់តាមផ្លូវ ត្រូវគេស្ទាក់វាយសម្រាតខោអាវ............ 203
●១៣២ អាកប្បកិរិយា និងអត្តចរិតរបស់សម សារី ........................................ 208
●១៣៣ មូលហេតុព្រះមហាក្សត្រនរោត្តម សុរាម្រិត ចូលទិវង្គត .........................212

●១៣៤ សម្តេចសីហនុ ក្លាយជាព្រះប្រមុខរដ្ឋ មានឋានៈស្មើព្រះមហាក្សត្រ ...........216
●១៣៥ គ្រូស្ចូឆេវ មេដឹកនាំសូវៀត មានបំណងចែចង់អ្នកម្នាងម៉ូនិក .................. 223
●១៣៦ បក្សប្រជាជនបដិវត្តន៍ខ្មែរ ដូរឈ្មោះជាបក្សពលករកម្ពុជា វិញ .................227
●១៣៧ សម្តេចសីហនុ យាងទៅជួបទីតូ និងចន កេណ្ណឌី ............................... 230
●១៣៨ តុលាការក្រុងឡាអេ ៖ ប្រាសាទព្រះវិហារជារបស់ខ្មែរ............................236
●១៣៩ ឡឹក សំអឿន លែងហ៊ានបង្រៀនសិស្សថៃ..........................................243
●១៤០ ជីវិតប្រពន្ធ និងកូនៗ ក្រោយពេលសម សារី រត់គេចខ្លួនទៅក្រៅប្រទេស....246
●១៤១ នរណាជាអ្នកសម្លាប់ទូ សាមុត? .................................................... 252
●១៤២ ចៅសែន កុសលឈុំ ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រី........................254
●១៤៣ ខៀវ សំផន ត្រូវបានតែងតាំងរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម.............258
●១៤៤ នរណាសម្លាប់សម សម សារី? .......................................................263
●១៤៥ បាតុកម្មនៅខេត្តសៀមរាប សិស្សម្នាក់
ស្លាប់នៅក្នុងប៉ុស្តិ៍ប៉ូលិសសម្តេចសីហនុ បន្ទោសកេង វ៉ាន់សាក់ និងសុន សេន ......269
●១៤៦ មហាសន្និបាតលើកទី៣ របស់បក្សពលករកម្ពុជា.................................272
●១៤៧ សាឡុត ស និងអៀង សារី បាត់ខ្លួនពីក្រុងភ្នំពេញ ................................276
●១៤៨ ង៉ូ ឌិញយៀម កាន់សាសនាកាតូលិក ជាន់ឈ្លីសាសនាព្រះពុទ្ធ............... 280
●១៤៩ ព្រះសង្ឃស្រោចប្រេងសាំងបូជាកាយ ដើម្បីសេរីភាពពុទ្ធសាសនា ............284
●១៥០ ប្រពន្ធង៉ូ ឌិញញូ និយាយបញ្ឈឺថា ៖
បើសង្ឃណាចង់ដុតខ្លួនទៀត គាត់នឹងជួយផ្តល់ប្រេងសាំង ..............................291

# ៩៧
# សម្តេចសីហនុ ទទួលជំនួយពីចិន



**សម្តេចសីហនុ និងមេដឹកនាំកំពូលរបស់ប្រទេសចិន ម៉ៅ សេទុង**

បន្ទាប់ពីយាងទៅបំពេញព្រះរាជទស្សនកិច្ច នៅប្រទេសហ្វីលីពីន នៅដើមខែកុម្ភៈ ឆ្នាំ១៩៥៦នោះ សម្តេចសីហនុ បានយាងទៅបំពេញទស្សនកិច្ចនៅទីក្រុងតូក្យូ ជាបន្តទៀត។ នៅទីនោះ ព្រះអង្គបានចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការជាមួយប្រទេសជប៉ុន ផងដែរ។ ជាមួយគ្នានោះ ព្រះអង្គក៏បានប្រកាសមិនទទួលយកសំណងពីប្រទេសជប៉ុន ដែលបានបង្កឱ្យមានការខូចខាតដល់ប្រទេសកម្ពុជា កាលក្នុងសម័យសង្គ្រាមលោកលើកទី២ ទៀតផង ។

សមាជិកសភាជប៉ុន ក៏បានទះដៃយ៉ាងកងរំពង ដើម្បីអបអរសាទរចំពោះព្រះរាជកាយវិការយោគយល់ គួរឱ្យកោតសរសើរនេះ។ រីឯព្រះចៅអធិរាជ ហ៊ីរ៉ូ ហ៊ីតូ និងព្រះអគ្គមហេសី ក៏បានរៀបចំព្រះរាជពិធីលៀងភោជនាហារថ្ងៃត្រង់ នៅក្នុងព្រះបរមរាជវាំង ថ្វាយ

របត់នយោបាយ

ជាព្រះរាជកិត្តិយស ដើម្បីជាការថ្លែងអំណរព្រះគុណចំពោះព្រះអង្គ ក្នុងការមិនទទួលយកសំណងពីប្រទេសជប៉ុននោះ ដោយទឹកព្រះទ័យសប្បុរស និងមិត្តភាពដ៏ជ្រាលជ្រៅបំផុត។

ជាមួយគ្នានោះ រាជរដ្ឋាភិបាលជប៉ុន ក៏បានសន្យាថា នឹងជួយសាងសង់មជ្ឈមណ្ឌលចិញ្ចឹមសត្វគោជ្រូកមាន់ទា ដ៏ទំនើបមួយ និងកសាងមជ្ឈមណ្ឌលស្រាវជ្រាវក្សេត្រសាស្ត្រមួយ ព្រមទាំងជួយសាងសង់មន្ទីរពេទ្យគំរូមួយទៀត ដល់ប្រទេសកម្ពុជា វិញដែរ។

នៅថ្ងៃទី១៣ ដល់ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ១៩៥៦ សម្តេចសីហនុ បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់មួយក្រុម ទៅបំពេញព្រះរាជទស្សនកិច្ចនៅសាធារណរដ្ឋប្រជាមានិតចិន។

ពេលនោះ មេដឹកនាំកំពូលរបស់ចិន គឺអគ្គលេខាបក្សកុម្មុយនិស្តចិន ម៉ៅ សេទុង និងនាយករដ្ឋមន្ត្រី ជូ អេនឡាយបានរៀបចំធ្វើពិធីបដិសណ្ឋារកិច្ចថ្វាយព្រះអង្គយ៉ាងអធិកអធម ជាងកាលព្រះអង្គយាងទៅបំពេញព្រះរាជទស្សនកិច្ច នៅប្រទេសហ្វីលីពីន កាលពីដើមខែកុម្ភៈនោះទៅទៀត។

នាយករដ្ឋមន្ត្រី ជូ អេនឡាយ បានលើកសរសើរចំពោះការប្រកាន់យកគោលនយោបាយអព្យាក្រឹតរបស់សម្តេច

សីហនុ ថា កាលនៅក្នុងសន្និសីទបណ្តាប្រទេសអាហ្វ្រិក-អាស៊ី នៅទីក្រុងបានឌុង គណៈប្រតិភូកម្ពុជា ដឹកនាំផ្ទាល់ដោយសម្តេច បានបញ្ជាក់យ៉ាងច្បាស់ថា ប្រទេសកម្ពុជានឹងប្រកាន់ខ្ជាប់នូវគោលនយោបាយអព្យាក្រឹតរបស់ខ្លួនជាប់ជានិច្ច ដោយមិនព្រមដាក់ប្រទេសឱ្យក្លាយទៅជាមូលដ្ឋានយោធានៃការឈ្លានពានរបស់ប្រទេសណាមួយឡើយ ហើយក្នុងពេលសន្ទនាជាមួយយើងខ្ញុំ សម្តេចបានថ្លែងពីការគោលនយោបាយរក្សាឯករាជ្យរបស់ប្រទេសព្រះអង្គ និងសន្តិភាពនៅឥណ្ឌូចិននោះ ធ្វើឱ្យយើងខ្ញុំមានការចាប់អារម្មណ៍ចំពោះព្រះអង្គជាខ្លាំង តាំងពីពេលនោះមក។

ជូ អេនឡាយ បន្តថា គោលនយោបាយអព្យាក្រឹត និងសន្តិភាពរបស់ប្រទេសកម្ពុជា ទទួលបាននូវការគោរព កោតសរសើរពីសំណាក់មហាជនទូទៅ និងពីសំណាក់បណ្តាប្រទេសជាច្រើននៅលើសកលលោក ព្រមទាំងធ្វើឱ្យព្រះរាជាណាចក្រកម្ពុជា កាន់តែដើរតួនាទីសំខាន់



**ជូ អេនឡាយ មកទទួលស្វាគមន៍សម្តេចសីហនុ នៅអាកាសយានដ្ឋាន**
**(រូបថតកាសែតចិន)**

ឡើងៗផងដែរ ។

ពេលនោះដែរ ប្រធានម៉ៅ (ម៉ៅ សេទុង) ក៏បានទទួលជួបសន្ទនាជាមួយព្រះអង្គក្នុងបរិយាកាសរីករាយស្និទ្ធស្នាលបំផុត ចំនួន៣លើកទៀតផង។

ប្រធានម៉ៅ បានលើកឡើងពីបញ្ហាទាំងឡាយទាក់ទងជាមួយប្រទេសកម្ពុជា យ៉ាងស៊ីជម្រៅ និងបានពិភាក្សាជាមួយព្រះអង្គពីបញ្ហាអន្តរជាតិសំខាន់ៗផងដែរ។ ប្រធានម៉ៅបញ្ជាក់ប្រាប់សម្តេចសីហនុ ថា គាត់ជាកូនរបស់ប្រជាជន មានដើមកំណើតជាកសិករ ហើយគាត់ជាជនកុម្មុយនិស្តដ៏ផ្តាច់ប្តូរម្នាក់ដែរ ប៉ុន្តែគាត់ចាត់ទុកថា នេះជាមហាកិត្តិយសមួយដោយសារគាត់មានមិត្តភក្តិម្នាក់ជាព្រះមហាក្សត្រមួយអង្គប្រកបដោយលក្ខណៈសម្បត្តិគួរឱ្យកោតសរសើរដូចព្រះអង្គនេះ។

នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៥៦ ជូ អេនឡាយ នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន និងសម្តេចសីហនុ បានចុះហត្ថលេខាលើសេចក្តីប្រកាសរួមមួយ មានខ្លឹមសារ

## របត់នយោបាយ

ជាអាទិថា ភាគីចិន និងកម្ពុជា ចាត់ទុកថា គោលការណ៍បញ្ចសិលាជាវិធានការច្បាប់ក្នុងការអនុវត្តទំនាក់ទំនងរវាងប្រទេសទាំង២។ គោលការណ៍នេះ មិនត្រឹមតែផ្តល់ផលប្រយោជន៍ដល់ប្រជាជននៃប្រទេសទាំងពីរប៉ុណ្ណោះទេ គឺថែមទាំងផ្តល់នូវផលប្រយោជន៍ ចំពោះការរក្សាសន្តិភាពនៅអាស៊ី និងនៅពិភពលោកទាំងមូល ផងដែរ។ រដ្ឋាភិបាលនៃប្រទេសទាំង២នឹងបន្តខិតខំប្រឹងប្រែង ដើម្បីធ្វើឱ្យទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការជាមួយគ្នាឱ្យកាន់តែល្អប្រសើរថែមទៀត។

នៅពេលបំពេញព្រះរាជទស្សនកិច្ចនោះ រាជរដ្ឋាភិបាលកម្ពុជា បានទទួលជំនួយដោយគ្មានលក្ខខណ្ឌពីរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន នូវទឹកប្រាក់ចំនួន២២,៤លានដុល្លារសហរដ្ឋអាមេរិក។ បន្ទាប់មកទៀត រាជរដ្ឋាភិបាលកម្ពុជា ក៏បានទទួលជំនួយរោងចក្រតម្បាញ, រោងចក្រផលិតកង់នៅភ្នំពេញ, រោងចក្រកៅស៊ូក្រែបនៅខេត្តកំពង់ចាម, រោងចក្រផលិតស៊ីម៉ងត៍នៅចក្រីទីងនៅខេត្តកំពត, រោងចក្រផលិតក្រដាសនៅឆ្លូង ក្នុងខេត្តក្រចេះ, រោងចក្រក្តារបន្ទះនៅដីឥដ្ឋ ក្នុងស្រុកកៀនស្វាយ ខេត្តកណ្តាល ជាដើម។

សម្តេចសីហនុ សង្ឃឹមថា ដោយសារជំនួយសេដ្ឋកិច្ចដ៏ច្រើនសន្ធឹកសន្ធាប់នេះ ព្រះអង្គអាចមានលទ្ធភាពក្នុងការកសាងប្រទេសជាតិរបស់ព្រះអង្គ ឱ្យបានរីកចម្រើនមួយចំណែកធំ ហើយដោយសារឥទ្ធិពលរបស់មហាអំណាចចិន នេះដែរ ព្រះអង្គសង្ឃឹមថា អាចបង្អាក់រាល់សកម្មភាពរំលោភឈ្លានពានមកលើអធិបតេយ្យភាពកម្ពុជា ជារឿយៗរបស់ប្រទេសថៃ និងវៀតណាមខាងត្បូង ផងដែរ។ ចំណែកមេដឹកនាំចិន ចាត់ទុកថា កម្ពុជា គឺជាទីតាំងយុទ្ធសាស្ត្រដ៏សំខាន់មួយរបស់ខ្លួន ហើយនយោបាយអព្យាក្រឹតរបស់សម្តេចសីហនុ ក៏រឹតតែសំខាន់ទៅទៀត ក្នុងការជួយឱ្យសាធារណរដ្ឋប្រជាមានិតចិន គេចផុតពីការហ៊ុមព័ទ្ធបានមួយកម្រិតទៀត។

ក្រោយពីយាងត្រលប់មកដល់មាតុប្រទេសវិញភ្លាម សម្តេចសីហនុ បានបន្តរិះគន់យ៉ាងចាស់ដៃទៅលើអង្គការសេអាតូ (SEATO) ហើយរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយមរបស់ព្រះអង្គ ក៏បានប្រកាសបដិសេធថា ប្រទេសកម្ពុជា គ្មានទំនាក់ទំនងដោយផ្ទាល់ ឬដោយ

ប្រយោលជាមួយអង្គការសេអាតូ(SEATO) នោះឡើយ។

ការរិះគន់ និងការប្រកាសជំហរនយោបាយបែបនេះ បានធ្វើឱ្យសហរដ្ឋអាមេរិក និងបណ្ដាប្រទេសជាសមាជិកអង្គការសេអាតូ (SEATO) ពិសេសគឺប្រទេសថៃ និងប្រទេសវៀតណាមខាងត្បូង កាន់តែខឹងសម្បា និងធ្វើសកម្មភាពប្រឆាំងនឹងប្រទេសកម្ពុជា កាន់តែខ្លាំងក្លាថែមទៀត។ ក្រោយពីសម្ដេចសីហនុ ឡាយព្រះហស្ដលេខាលើកិច្ចព្រមព្រៀងទទួលជំនួយពីរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន ក្នុងពេលយាងបំពេញព្រះរាជទស្សនកិច្ចនៅទីក្រុងប៉េកាំង កាលពីខែកុម្ភៈ ឆ្នាំ១៩៥៦ នោះមក រដ្ឋាភិបាលសហរដ្ឋអាមេរិក ក៏បានសម្រេចផ្អាកការផ្ដល់ជំនួយយោធាមកឱ្យរាជរដ្ឋាភិបាលកម្ពុជា ជាបណ្ដោះអាសន្ន ក្នុងគោលបំណងបង្ហាញនូវការមិនពេញចិត្តរបស់ខ្លួនមកលើសម្ដេចសីហនុ ។

តែទោះបីយ៉ាងនេះក៏ដោយ ក៏នៅថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៥៦ រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំធ្វើពិធីទទួលជំនួយរបស់សាធារណរដ្ឋប្រជាមានិតចិន យ៉ាងអធិកអធមនៅរាជធានីភ្នំពេញ ដែរ។ ចំណែករដ្ឋាភិបាលសហរដ្ឋអាមេរិក ក៏បានសហការជាមួយរាជ-រដ្ឋាភិបាលថៃ ដឹកនាំដោយសេនាប្រមុខសារិត ថាណារ៉ាត (Sarit Thanarat) និងរដ្ឋាភិបាលវៀតណាមខាងត្បូង ដឹកនាំដោយ ង៉ូ ឌិញយៀម (Ngo Dinh Diem) ហ៊ុមព័ទ្ធសេដ្ឋកិច្ច ប្រឆាំងនឹងរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយមរបស់សម្ដេចសីហនុ មិនឱ្យដកដង្ហើមរួច។ មិនតែប៉ុណ្ណោះ រាជរដ្ឋាភិបាលថៃ និងរដ្ឋាភិបាលវៀតណាមខាងត្បូង បាននាំគ្នាចល័តកងទ័ពនៅតាមបណ្ដោយព្រំដែនភាគខាងត្បូង និងខាងកើត ព្រមទាំងភាគខាងលិចប្រទេសកម្ពុជា ក្នុងគោលបំណងបង្ករឿងគ្រប់បែបយ៉ាងមកលើប្រទេសកម្ពុជា ទៀតផង។

ដើម្បីចៀសវាងនូវការចោទប្រកាន់ថា រដ្ឋាភិបាលសហរដ្ឋអាមេរិក ជាអ្នកញុះញង់ និងជាអ្នកនៅពីក្រោយខ្នងសកម្មភាពប្រទូសរ៉ាយរបស់ប្រទេសថៃ និងប្រទេសវៀតណាមខាងត្បូង រដ្ឋមន្ត្រីការបរទេសអាមេរិក ចន ហ្វូស្ទ័រ ឌុល្លេស (John Foster Dulles) បានផ្ញើលិខិតជាផ្លូវការមួយច្បាប់ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៥៦ មកឱ្យរដ្ឋមន្ត្រីក្រសួងការ-បរទេសកម្ពុជា តាមរយៈនង គីមនី ឯកអគ្គរាជទូតកម្ពុជា ប្រចាំសហរដ្ឋអាមេរិក។ លិខិតជា

ផ្លូវការនោះ មានខ្លឹមសារថា៖ លោករដ្ឋមន្ត្រី! ខ្ញុំមានសេចក្តីព្រួយបារម្ភជាខ្លាំង ដោយនៅពេលថ្មីៗនេះ មានមជ្ឈដ្ឋានជាច្រើនបានលើកឡើងថា សហរដ្ឋអាមេរិក បានប៉ុនប៉ងបង្ខំប្រទេសកម្ពុជា ឱ្យយល់ព្រមនៅក្រោមឆត្រការពាររបស់អង្គការសេអាតូ (SEATO)។ តែប្រទេសកម្ពុជាមិនព្រម ក៏ត្រូវសហរដ្ឋអាមេរិកផ្តាច់ជំនួយសេដ្ឋកិច្ច និងយោធាវិញ។

ទន្ទឹមគ្នានោះ ក៏លេចឮដែរថា សហរដ្ឋអាមេរិក បានបញ្ជាឲ្យប្រទេសវៀតណាមខាងត្បូង និងប្រទេសថៃ ជាសម្ព័ន្ធមិត្តធ្វើវិទ្ធង្សនាសេដ្ឋកិច្ច ដើម្បីគាបសង្កត់ប្រទេសកម្ពុជា។ ជាមួយគ្នានេះដែរ នៅទីក្រុងភ្នំពេញ ស្ថានទូតអាមេរិកប្រចាំកម្ពុជា បានថ្វាយដំណឹងជាផ្លូវការចំពោះព្រះមហាក្សត្រខ្មែរ ហើយថា សហរដ្ឋអាមេរិក ពុំដែលបានថ្លែងការណ៍ស្តីពីបញ្ហានយោបាយក្រៅប្រទេសរបស់កម្ពុជា ម្តងណាដែរ ។

លិខិតជាផ្លូវការរបស់រដ្ឋមន្ត្រីការបរទេសអាមេរិក បានបន្តថា នយោបាយរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ចំពោះប្រទេសកម្ពុជា គឺបានធ្វើឡើងតាមរយៈកម្មវិធីផ្តល់ជំនួយយោធារបស់ខ្លួន តាមសេចក្តីស្នើសុំជំនួយសេដ្ឋកិច្ច ជាផ្លូវការរបស់ប្រទេសកម្ពុជា ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៥៤ និងជំនួយយោធាចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៥៤ ដើម្បីការពារប្រទេសកម្ពុជា ដោយខ្លួនឯង តទល់នឹងអំពើឈ្លានពានរបស់ពួកកុម្មុយនិស្ត ឬអំពើវិទ្ធង្សនាណាមួយមកលើឯករាជ្យរបស់ខ្លួនតែប៉ុណ្ណោះ។ សហរដ្ឋអាមេរិក គោរពជានិច្ច ប្រសិនបើប្រទេសណាមួយមានជំនឿលើខ្លួនឯងថា អាចរក្សាឯករាជ្យរបស់ខ្លួនបានល្អប្រសើរ ជាងការអនុវត្តនូវគោលគំនិតនៃការរក្សាសន្តិសុខរួមគ្នានេះ។

ក្នុងអំឡុងពេលនោះដែរ នាយករដ្ឋមន្ត្រី អ៊ុម ឈាងស៊ុន ដឹកនាំរាជរដ្ឋាភិបាល មិនបានពីរខែផង(ពីថ្ងៃទី០៥ ខែមករា ដល់ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៥៦) ត្រូវបានប្រកាសរំសាយចោល។ នៅថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៥៦ សម្តេចសីហនុ ក្នុងនាមប្រធានចលនាសង្គមរាស្ត្រនិយមបានរៀបចំសមាសភាពរាជរដ្ឋាភិបាលថ្មីមួយទៀត ដោយមានព្រះអង្គផ្ទាល់ជានាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីការបរទេស និងមហាផ្ទៃ, ឃឹម ទិត ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីសន្តិសុខជាតិ រដ្ឋមន្ត្រីទទួលបន្ទុកចាត់ការខាងបច្ចេកទេសនៃការិយាល័យ និងក្រុមជំនាញ

នៅទីស្តីការនាយករដ្ឋមន្ត្រី, ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ជារដ្ឋមន្ត្រីការពារជាតិ និងសិក្សាធិការជាតិ, ជួប សំឡុត ជារដ្ឋមន្ត្រីយុត្តិធម៌, ម៉ៅ សាយ (ទើបបញ្ចប់ការសិក្សាមកពីប្រទេសបារាំង) ជារដ្ឋមន្ត្រីហិរញ្ញវត្ថុ និងកិច្ចការសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្ម, ហួត សម្អាត ជារដ្ឋមន្ត្រីសាធារណការ ទូរគមនាគមន៍ និងផែនការ, គួ រុន ជារដ្ឋមន្ត្រីសុខាភិបាល, ជា ជិនកុក ជារដ្ឋលេខាធិការបរទេស និងមហាផ្ទៃ, ហឿ ឡាយអ៊ីន ជារដ្ឋលេខាធិការកសិកម្ម កិច្ចការអ្នកស្រែចម្ការ សង្គមកិច្ច និងរកមុខរបរឱ្យប្រជារាស្ត្រធ្វើ, ហួត សម្បត្តិ ជារដ្ឋលេខាធិការសិក្សាធិការជាតិ និងទ្រិញ វ៉ាញ ជារដ្ឋលេខាធិការធម្មការ និងសាសនា។



**នាយករដ្ឋមន្ត្រីយឹម ទិត**

ក្រោយពីបង្កើតរាជរដ្ឋាភិបាលនេះ បាន១ថ្ងៃ នាយករដ្ឋមន្ត្រីថៃ សេនាប្រមុខ ភិប៊ូន សុង្គ្រាម បានចោទប្រកាន់ថា កម្ពុជា បានរំលោភបំពានធ្វើបាបប្រជារាស្ត្រថៃ នៅតាមបណ្តាព្រំដែន។ ចំណែកភាគីកម្ពុជា ក៏បានតវ៉ាអំពីការរំលោភកាន់កាប់ប្រាសាទព្រះវិហារ ពីសំណាក់កងទ័ពថៃ និងតវ៉ាទៅនាយករដ្ឋមន្ត្រីថៃ ពីរឿងអនុញ្ញាតឱ្យចលនាតស៊ូរបស់សឺង ង៉ុកថាញ់ បោះទីតាំងនៅលើដីថៃ វិញដែរ។

ពេលនោះ សម្តេចសីហនុ ជានាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីការបរទេស និងមហាផ្ទៃ បានប្រកាសបដិសេធមិនចូលរួមក្នុងអង្គការកតិកាសន្ធិសញ្ញាអាស៊ីអាគ្នេយ៍ (SEATO=សេអាតូ) ជាដាច់ខាត ហើយព្រះអង្គនៅតែប្រកាន់យកនយោបាយអាព្យាក្រឹតមកដឹកនាំប្រទេសដដែល។

នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៥៦ វិទ្យុក្រុងហាណូយ ក៏បានប្រកាសថា កលល្បិច

របត់នយោបាយ

របស់ចក្រពត្តិអាមេរិក ដែលចង់អូសទាញប្រទេសកម្ពុជា ឱ្យចូលទៅក្នុងនយោបាយឈ្លានពានរបស់ខ្លួននោះត្រូវបរាជ័យហើយ។

ការប្រកាសដូច្នេះ បង្ហាញឱ្យឃើញថា រដ្ឋាភិបាលក្រុងហាណូយ មានបំណងគាំទ្រនយោបាយអាព្យាក្រឹតរបស់សម្តេចសីហនុ យ៉ាងពិតប្រាកដ។

ថ្ងៃទី២១ និង២២ ខែមេសា ឆ្នាំ១៩៥៦ សមាជជាតិលើកទី៣ បានសម្រេចគាំទ្រជាឯកច្ឆន្ទ ចំពោះសម្តេចសីហនុ ដែលមិនព្រមចូលរួមជាមួយអង្គការសេអាតូ(SEATO) និងគាំទ្រគោលនយោបាយអព្យាក្រឹតរបស់ព្រះអង្គទាំងស្រុង។

ក្នុងសមាជជាតិលើកទី៣នោះដែរ នង សួន មេដឹកនាំគណបក្សប្រជាជន ចាញ់ឆ្នោតកាលពីថ្ងៃទី១១ខែកញ្ញា ឆ្នាំ១៩៥៥ បានឡើងប្រកាសសុំចុះចូលជាមួយចលនាសង្គមរាស្ត្រនិយម និងស្នើសុំឱ្យសម្តេចសីហនុ បង្កើតរាជរដ្ឋាភិបាលចម្រុះមួយ រួមមានគណបក្សប្រជាជន និងគណបក្សផ្សេងៗទៀតផងដែរ ប៉ុន្តែសម្តេចសីហនុ បដិសេធ។

ក្រោយពីកាន់តំណែងជានាយករដ្ឋមន្ត្រី បានរយៈពេលតែ១ខែ សម្តេចសីហនុ បានលាចេញតំណែងម្តងទៀត។ នៅថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៥៦ ព្រះមហាក្សត្រនរោត្តម សុរាម្រិត ក៏បានចេញព្រះរាជក្រឹត្យ តែងតាំងសមាសភាពរាជរដ្ឋាភិបាលថ្មីមួយទៀត ដោយបានតែងតាំង ឃឹម ទិត ដែលជាឧបនាយករដ្ឋមន្ត្រី ឱ្យឡើងជានាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីផែនការ និងបោសសម្អាត, នង គីមនី ជាឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីការបរទេស, ទ្រង់ស៊ីសុវត្ថិ សិរិមតៈ ជារដ្ឋមន្ត្រីការពារជាតិ, ជា ជិនកុក ជារដ្ឋមន្ត្រីមហាផ្ទៃ, ជួប សំឡុត ជារដ្ឋមន្ត្រីយុត្តិធម៌ អប់រំជាតិ វិចិត្រសិល្បៈ យុវជន និងកីឡា, ម៉ៅ សាយ ជារដ្ឋមន្ត្រីកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ហួត សម្អាត ជារដ្ឋមន្ត្រីសាធារណការ និងទូរគមនាគមន៍, គូ រុន ជារដ្ឋមន្ត្រីសាធារណសុខាភិបាល, ផ្លែក ភឺន ជារដ្ឋលេខាធិការអមទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកផែនការ និងដឹកនាំកិច្ចការទូទៅនៅទីស្តីការគណៈរដ្ឋមន្ត្រី, ហឿ ឡាយអ៊ីន ជារដ្ឋលេខាធិការកសិកម្ម សង្គមកិច្ច និងការងារ, ហួត សម្បត្តិ ជារដ្ឋលេខាធិការអប់រំជាតិ វិចិត្រសិល្បៈ យុវជន និងកីឡា និងទ្រិញ វ៉ាញ ជារដ្ឋលេខាធិការធម្មការ និងព័ត៌មាន។

ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៥៦ រាជរដ្ឋាភិបាលដែលមានឈឹម ទិត ជានាយករដ្ឋមន្ត្រី បានបង្កើតអង្គការឥណទានមួយសម្រាប់រឹតត្បិតអំពីមហន្តរាយដែលកើតមានពីការយកពន្ធច្រើនពេកពីទំនិញនាំចូលមកពីប្រទេសចិន។

# ៥៨
# សាឡុត ស ពង្រីកឥទ្ធិពលរបស់ខ្លួន នៅក្នុងជួរមេដឹកនាំបក្ស



**ចលនាតស៊ូខ្មែរឥស្សរៈកាលដើមទសវត្សរ៍ឆ្នាំ១៩៥០**

មកដល់ខែឧសភា ឆ្នាំ១៩៥៦ សកម្មភាពបង្ក្រាបអ្នកនយោបាយប្រឆាំង ពីសំណាក់អាជ្ញាធរនៃរបបសង្គមរាស្ត្រនិយម ហាក់ដូចជាមានការស្ងប់ស្ងាត់បន្តិច។ ពេលនោះ នង សួន, កែវ មាស និងណុប បូផាន់ មេដឹកនាំគណបក្សប្រជាជន មានឱកាសចេញផ្សាយកាសែតឈ្មោះប្រជាជនរបស់ពួកគេឡើងវិញ ដោយចេញផ្សាយ១លេខក្នុងមួយសប្តាហ៍។ ឯកាសែតវត្តភ្នំ មាននិន្នាការកណ្តាលនិយម ក៏បានចេញផ្សាយ១លេខក្នុងមួយសប្តាហ៍ ដូចកាសែតប្រជាជន ដែរ។

ក្រៅពីនេះ មានកាសែតមួយទៀត គឺកាសែតមាតុភូមិ មាន សឹង កឿកថ ជានិពន្ធនាយក។ ហ៊ូ យន់ ទើបបញ្ចប់ការសិក្សានៅប្រទេសបារាំង ហើយវិលត្រលប់មកកម្ពុជាវិញ ក្នុងខែមករា ឆ្នាំ១៩៥៦ និងតូច កឿន (ដែលក្រោយមក ជារដ្ឋមន្ត្រីក្រសួងសាធារណការ

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ) ព្រមទាំង សាឡុត ឆាយ ជាបងប្រុសរបស់សាឡុត ស ទើបចេញពីពន្ធនាគារ ក៏បានចូលរួមជាអ្នកនិពន្ធរបស់កាសែតមាតុភូមិ នេះដែរ ។ កាសែត នេះចេញផ្សាយក្នុងរយៈពេលពាសប្តាហ៍ តែមួយលេខប៉ុណ្ណោះ ។

ហ៊ូ យន់ បានយកនិក្ខេបបទជាភាសាបារាំងមួយ ដែលគាត់ស្រាវជ្រាវ ដើម្បីប្រលង យកសញ្ញាបត្រថ្នាក់បណ្ឌិតសេដ្ឋកិច្ច នៅប្រទេសបារាំង មានចំណងជើងថា បញ្ហាសហករណ៍ (និយាយពីបញ្ហាសង្គមនិយម និងបញ្ហាកសិករ)នោះ មកបកប្រែជាភាសាខ្មែរ យកចុះផ្សាយ នៅលើទំព័រកាសែតមាតុភូមិ នោះ ផងដែរ។

ចំណែក នង សួន និងកែវ មាស វិញ មិនយូរប៉ុន្មាន ក៏ចាប់ផ្តើមលែងទុកចិត្តទៅលើ ប៉ែន យុទ្ធ ជានិពន្ធនាយកកាសែតប្រជាជន ជាអ្នកតស៊ូជិតស្និទ្ធនឹងគ្នាបំផុតនោះ ដោយសារ តែ ប៉ែន យុទ្ធ បែកគំនិតផឹកស៊ី មានស្រីញី ហើយនិពន្ធអត្ថបទ ដែលមើលទៅ មិនគួរឱ្យគេ ចាប់អារម្មណ៍ មកចុះផ្សាយលើទំព័រកាសែតប្រជាជន ជាបន្តបន្ទាប់។

ក្នុងខែខែឧសភា ឆ្នាំ១៩៥៦ នោះ សុន សេន បានបញ្ចប់ការសិក្សា នៅប្រទេស បារាំង ហើយវិលត្រលប់មកមាតុប្រទេសវិញ។

ជាមួយគ្នានោះ មាននិស្សិតម្នាក់ទៀត ទើបមកពីប្រទេសបារាំង ឈ្មោះ សុខ ខ្នុល បានចូលរួមតស៊ូជាមួយចលនាតស៊ូដឹកនាំដោយ សឺង ង៉ុកមិញ និងទូ សាមុត ដែរ តែ ក្រោយពីមានកិច្ចព្រមព្រៀង នៅក្រុងហ្សឺណែវ គាត់បានរត់ទៅចូលរួមជាមួយចលនាតស៊ូ របស់សឺង ង៉ុកថាញ់ ដើម្បីប្រឆាំងនឹងសម្តេចសីហនុ បន្តទៀតនោះ ក៏ត្រូវបានសាឡុត ស អូសទាញឱ្យមកចូលរួមក្នុងចលនាតស៊ូសម្ងាត់របស់គាត់វិញដែរ។

នៅក្នុងសម័យសង្គ្រាមតស៊ូរបស់ខ្មែរក្រហម ឆ្នាំ១៩៧០ សុខ ខ្នុល មានឈ្មោះ បដិវត្តថា សមមិត្ត ពាម មានតួនាទីជាប្រធានមន្ទីរភូមិភាគបូព៌ា ជួយដល់កិច្ចការរដ្ឋបាល ទាំងឡាយដល់ សោ ភឹម ជាលេខាបក្សភូមិភាគបូព៌ា ដែលមានកម្រិតវប្បធម៌ទាប។ នៅ ពាក់កណ្តាលឆ្នាំ១៩៥៦ បក្សប្រជាជនបដិវត្តន៍ខ្មែរ រៀបចំឱ្យមានគណៈកម្មាធិការបក្សជន បទមួយ មានស៊ីវ ហេង ជាលេខា។ ចំណែកគណៈកម្មាធិការបក្សទីក្រុងភ្នំពេញ មានទូ សាមុត

## របត់នយោបាយ

ជាលេខា និងជាអ្នកទទួលខុសត្រូវលើចលនាតស៊ូទាំងសម្ងាត់ និងចំហ នៅទូទាំងប្រទេសផងដែរ។ ប៉ុន្តែ ទូ សាមុត និងស៊ីវ ហេង បានគេចខ្លួនទៅស្នាក់នៅក្នុងតំបន់ព្រៃក្រាស់មួយក្នុងស្រុករមាសហែក ខេត្តស្វាយរៀង ជាប់នឹងខេត្តតៃនិញ របស់ប្រទេសវៀតណាមខាងត្បូង។ ពេលនោះ សាឡុត ស ជាសមាជិកនៅក្នុងជួរគណៈកម្មាធិការបក្សក្រុងភ្នំពេញនេះ ម្នាក់ដែរ ក៏មានឱកាសដឹកនាំចលនាបដិវត្តន៍ និងពង្រីកឥទ្ធិពលរបស់ខ្លួន នៅក្នុងជួរមេដឹកនាំបក្សបន្តិចម្តងៗ។

ចំណែក នង សួន (ជ័យ សួន) និងកែវ មាស ជាអ្នកចេញមុខធ្វើសកម្មភាពស្របច្បាប់នៅក្នុងទីក្រុងភ្នំពេញ តាមកិច្ចព្រមព្រៀងក្រុងហ្សឺណែវ ក៏ជាសមាជិកសម្ងាត់របស់គណៈកម្មាធិការបក្សក្រុងភ្នំពេញ នោះដែរ ហើយយូរៗម្តង ពួកគាត់ទាំង២នាក់ តែងតែធ្វើដំណើរទៅខេត្តស្វាយរៀង ជួប ទូ សាមុត និងស៊ីវ ហេង ដើម្បីរាយការណ៍ពីសភាពការណ៍នយោបាយ នៅទីក្រុងភ្នំពេញ។

គណៈកម្មាធិការបក្សក្រុងភ្នំពេញ មានទូ សាមុត ជាលេខា មានតែឈ្មោះនោះ ហាក់ដូចជាបានក្លាយទៅជាគណៈកម្មាធិការមជ្ឈិមបក្ស ទៅហើយ ព្រោះគណៈកម្មាធិការបក្សនេះ ជាអ្នកចាត់ចែង និងដឹកនាំការងារបក្ស ស្ទើរតែទាំងស្រុងទៅហើយ បើទោះបីគណៈកម្មាធិការបក្សជនបទ មានសមាជិកច្រើនលើសលប់ជាងក៏ដោយ។ ដោយសារឃើញថា បញ្ហាសុវត្ថិភាពកាន់តែមានភាពល្អប្រសើរឡើងៗ នង សួន ក៏បានរាយការណ៍ទៅប្រាប់ស៊ីវ ហេង និងទូ សាមុត កំពុងលាក់ខ្លួននៅក្នុងតំបន់ព្រៃក្រាស់មួយ ក្នុងខេត្តស្វាយរៀង ក្បែរព្រំដែនប្រទេសវៀតណាមខាងត្បូងនោះ ឱ្យនាំគ្នាមករស់នៅក្នុងទីក្រុងភ្នំពេញ វិញ ដើម្បីងាយស្រួលក្នុងការទាក់ទងគ្នា ព្រោះពេលនោះ មានផ្ទះមួយអាចស្នាក់នៅលាក់ខ្លួនបាន ហើយកម្លាំងសមត្ថកិច្ច ក៏មិនសូវតាមដាន តឹងតែងដូចមុនៗដែរ។

# ៩៩
# ដាប ឈួន ហៅ ឈួន ម្ចុលពេជ្រ
# ឡើងតំណែងជាទេសរដ្ឋមន្ត្រី



**ឈួន ម្ចុលពេជ្រ ឡើងឋានៈ ជាទេសរដ្ឋមន្ត្រី**

ក្រោយពីសមាគមនិស្សិតខ្មែរ មាន ហ៊ូ យន់ ជាប្រធាន ត្រូវរដ្ឋាភិបាលបារាំងប្រកាសរំលាយចោល លែងឱ្យមានតទៅទៀត ចាប់ពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៥៣ តាមព្រះរាជសំណើរបស់សម្តេចសីហនុ អស់រយៈពេល២ឆ្នាំមក នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៥៥ នៅទីក្រុងប៉ារីស ពួកនិស្សិតខ្មែរមាននិន្នាការមិនមែនកុម្មុយនិស្ត បាននាំគ្នាបង្កើតសមាគមមួយមានឈ្មោះ សមាគមខ្មែរ( AK = Association Khmère ) ដោយមាន ចៅ សេងអ៊ួ ជាប្រធាន ។ ចំណែក ជួន មុម្ម ដែលបានរត់គេចខ្លួន ចេញពីប្រទេសកម្ពុជា ទៅរស់នៅជាមួយប្រពន្ធជាជនជាតិបារាំង នៅក្រុងប៉ារីសវិញនោះ នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៥៦ គាត់បានរួបរួមគ្នាជាមួយ អៀង សារី, ខៀវ សំផន ព្រមទាំងពួកនិស្សិតមាននិន្នាការឆ្វេងនិយមមួយ

ចំនួនទៀត បង្កើតសមាគមមួយឈ្មោះ សហភាពនិស្សិតខ្មែរ ( UEK=Union des étudiants Khmère )។

លុះដល់ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៥៦ អ៊ិន សូកាន ត្រូវបានជ្រើសរើសឱ្យធ្វើជាប្រធានសហភាពនិស្សិតខ្មែរ(UEK)។ ពេលនោះ សមាគមខ្មែរ(AK) មិនមែនជាពួកកុម្មុយនិស្ត និងសហភាពនិស្សិតខ្មែរ (UEK) មាននិន្នាការឆ្វេងនិយម (និន្នាការទៅរកកុម្មុយនិស្ត) បានប្រជែងគ្នាប្រមែប្រមូលពួកនិស្សិតខ្មែរ កំពុងសិក្សានៅប្រទេសបារាំង ឱ្យមកចូលជាសមាជិករបស់សមាគមតែរៀងៗខ្លួន រហូតដល់មេដឹកនាំសមាគមទាំងពីរនេះ មានទំនាស់នឹងគ្នាទៀតផង។

នៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៥៧ សម្តេចសីហនុ បានយាងទៅសម្ពោធអគារសម្រាប់និស្សិតខ្មែរស្នាក់នៅ ហៅថា ផ្ទះកម្ពុជា( Pavillion du Cambodge ) សាងសង់នៅក្នុងបុរីសាកលវិទ្យាល័យក្រុងប៉ារីស។

តាមការយាងរបស់សេនាប្រមុខយ៉ូសិប ប្រូស ទីតូ ( Josip Broz Tito ) នៅចុងឆ្នាំ១៩៥៦ សម្តេចសីហនុ បានយាងទៅបំពេញព្រះរាជទស្សនកិច្ចនៅសាធារណរដ្ឋសង្គមនិយមសហព័ន្ធយូហ្គោស្លាវី ។

បន្ទាប់ពីយាងទស្សនាទីក្រុងបែលក្រាដ ( Belgrad )មក ព្រះអង្គ និងអ្នកអមដំណើរបានជិះរថភ្លើងទៅទស្សនាវិមានដ៏ប្រណីតបំផុតរបស់សេនាប្រមុខទីតូ នៅប្រីអូនី ( Brioni ) ស្ថិតនៅជាប់ឆ្នេរសមុទ្រអាឌ្រីយ៉ាកទិក ខណៈ ហ្កាម៉ាល់ អាប់ដែល ណាស៊ែរ ( Gamal Abdel Nasser ) ប្រធានាធិបតីនៃប្រទេសអេហ្ស៊ីប និងហ្យាវ៉ា ហារឡាល់ នេរុហ៍ ( Jawa harlal Nehru ) នាយករដ្ឋមន្ត្រីឥណ្ឌា ដែលព្រះអង្គចាត់ទុកជាគ្រូរបស់ព្រះអង្គនោះ ទើបនឹងចេញផុតពីវិមាននោះ មុននេះបន្តិច។

សម្តេចសីហនុ បានចុះហត្ថលេខាជាមួយសេនាប្រមុខ ទីតូ លើសេចក្តីថ្លែងការណ៍រួមស្តីពីការមិនចូលបក្សសម្ព័ន្ធ ដូចដែលព្រះអង្គបានចូលរួមក្នុងសន្និសីទនៅក្រុងបានឌុង កន្លងមក ដែរ។ ប៉ុន្តែប៉ុន្មានថ្ងៃក្រោយមក ពួកប្រវត្តិវិទូ ក៏បានប្រកាសឈ្មោះមេដឹកនាំប្រទេស




អគារសម្រាប់និស្សិតខ្មែរស្នាក់នៅ ពេលកំពុងសាងសង់ (រូបថត Maison du Cambodge)




អគារសម្រាប់និស្សិតខ្មែរស្នាក់នៅ ពេលសាងសង់រួច (រូបថត Maison du Cambodge)

មួយចំនួន ដូចជា ហ្សាវ៉ា ហារឡាល់ នេហរុហ៍ (Jawa harlap Nehru), ហ្គាម៉ាល់ អាប់ដែល ណាសែរ (Gamal Abdel Nasser), ហ្សូសិប ប្រូស ទីតូ (Josip Broz Tito), ស៊ូការណូ (Sukarno) និងមេដឹកនាំប្រទេសហ្គាណា ម្នាក់ទៀតថា ជាសហស្ថាបនិករបស់ចលនាមិនចូលបក្សសម្ព័ន្ធ ដោយមិនមានព្រះនាមសម្ដេចសីហនុ នោះទេ ព្រោះពួកប្រវត្តិវិទូទាំងនោះចាត់ទុកថា ព្រះអង្គគ្រាន់តែជាមេដឹកនាំប្រទេសតូចមួយប៉ុណ្ណោះ។ តែទោះបីយ៉ាងណាក៏សេនាប្រមុខ ទីតូ បានផ្ដល់សច្ចធម៌ និងយុត្តិធម៌ដល់ព្រះអង្គពីបញ្ហានេះ ដោយចាត់ទុកព្រះអង្គជាសហស្ថាបនិករបស់ចលនាមិនចូលបក្សសម្ព័ន្ធ មួយអង្គដែរ។

ក្រោយពីបំពេញទស្សនកិច្ច នៅសាធារណរដ្ឋសង្គមនិយមសហព័ន្ធយូហ្គោស្លាវី មកក្នុងឋានៈជាមេដឹកនាំប្រទេសមួយដែលប្រកាន់យកគោលនយោបាយអព្យាក្រឹតមក សម្ដេចសីហនុ ត្រូវបានមេដឹកនាំបណ្ដាប្រទេសនានា ដូចជា ប្រទេសអេស្ប៉ាញ, អូទ្រីស, សហភាពសូវៀត, ប៉ូឡូញ, ឆេកូស្លូវ៉ាគី, សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់, រ៉ូម៉ានី, ហុងគ្រី, ប៊ុលហ្គារី និងប្រទេសមួយចំនួនទៀត បានសុំយាងព្រះអង្គទៅបំពេញទស្សនកិច្ច នៅប្រទេសរបស់ពួកគេ ជាបន្តបន្ទាប់។

ថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៥៦ សម្ដេចសីហនុ បានផ្សារទំនាក់ទំនងការទូតជាមួយសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត (ស.ស.ស.ស)។ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៥៦ ឃីម ទិត លាលែងពីតំណែងនាយករដ្ឋមន្ត្រី សម្ដេចសីហនុ ក៏បានរៀបចំរាជរដ្ឋាភិបាលថ្មីមួយទៀត ដោយមានព្រះអង្គផ្ទាល់ជានាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីការបរទេស, ទ្រង់ស៊ីសុវត្ថិ មុនីរ៉េត ជាទេសរដ្ឋមន្ត្រីទទួលបន្ទុកការពារជាតិ និងបោសសម្អាត, ដាប ឈួន ហៅ ឈួន ម្ចុលពេជ្រ ជារដ្ឋមន្ត្រីសន្តិសុខ និងធម្មការ, កុល ឈឿន ជារដ្ឋមន្ត្រីយុត្តិធម៌, ហួត សម្អាត ជារដ្ឋមន្ត្រីហិរញ្ញវត្ថុ ផែនការ និងទូរគមនាគមន៍, ផ្លែក ភឺន ជារដ្ឋមន្ត្រីសាធារណការ កសិកម្ម និងទូរគមនាគមន៍, ហួត សម្បត្តិ ជារដ្ឋលេខាធិការសាធារណសិក្សា អប់រំមូលដ្ឋាន និងវិចិត្រសិល្បៈ, ឃឹម ឱត ជារដ្ឋលេខាធិការព័ត៌មានយុវជន និងកីឡា, កុច សាន ជារដ្ឋលេខាធិការពាណិជ្ជកម្ម និងឧស្សាហកម្ម, ញ៉ែម សុផល

រដ្ឋលេខាធិការសាធារណសុខាភិបាល, ទូច គីម ជារដ្ឋលេខាធិការពាណិជ្ជកម្ម ការងារ សង្គមកិច្ច ការសិក្សា និងការកែទម្រង់, សឹង គៀកថ ( និពន្ធនាយកកាសែតមាតុភូមិ ) ជារដ្ឋលេខាធិការអមទីស្តីការគណៈរដ្ឋមន្ត្រីទទួលបន្ទុកកីឡា យុវជន និងសារព័ត៌មាន, ទ្បៅ ប៊ុនប៉ា ជារដ្ឋលេខាធិការកសិកម្ម ទទួលបន្ទុករាជមន្ទីរសហករណ៍, រឿម សុផុន ជារដ្ឋលេខាធិការការងារ និងសង្គមកិច្ច ទទួលបន្ទុកការតាំងទីលំនៅ, អ៊ុក ឈុំ ជាអនុរដ្ឋលេខាធិការមហាផ្ទៃ និង ធុយ ប៊ុនសូ ជាអនុរដ្ឋលេខាធិការសាធារណសិក្សាធិការ។

សមាសភាពនៅក្នុងជួររាជរដ្ឋាភិបាលនេះ ធ្វើឱ្យសាធារណមតិជាច្រើនមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ព្រោះឈួន ម្ជុលពេជ្រ ពីមុនឈ្មោះ ដាប ឈួន ជាអតីតមេខ្មែរឥស្សរៈល្បីថា ជាមនុស្សកំណាចឃោរឃៅនៅខេត្តសៀមរាប គ្រាន់តែចេះអាន និងសរសេរអក្សរខ្មែរបន្តិចបន្តួចប៉ុណ្ណោះនោះ ត្រូវបានសម្តេចសីហនុ តែងតាំងឱ្យធ្វើជារដ្ឋមន្ត្រីក្រសួងសន្តិសុខជាតិ និងធម្មការ។

អ្វីដែលធ្វើឱ្យចាប់អារម្មណ៍ដែរនោះ គឺរាជរដ្ឋាភិបាលនេះ មិនមានតំណែងឧបនាយករដ្ឋមន្ត្រីទេ គឺមានតែទ្រង់ស៊ីសុវត្ថិ មុនីរ៉េត ជាទេសរដ្ឋមន្ត្រីទទួលបន្ទុកការពារជាតិ និងបោសសម្អាតទូទៅ និងមានរដ្ឋមន្ត្រីតែ៤រូបប៉ុណ្ណោះ ក្រៅពីនោះ មានឋានៈត្រឹមតែរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការប៉ុណ្ណោះ។ ក្រសួងបោសសំអាតទូទៅ ជាអ្នករៀបចំឱ្យមានប្រព័ន្ធយុត្តិធម៌ឯករាជ្យមួយសម្រាប់ត្រួតពិនិត្យឯកសារដែលជាប់ទាក់ទងទៅនឹងពួកមន្ត្រីរាជការនៅក្នុងជួរកងទ័ព និងជួរក្រុបខណ្ឌស៊ីវិល ជាជនជាប់សង្ស័យក្នុងអំពើពុករលួយ។

ប៉ុន្តែ រាជរដ្ឋាភិបាល មានសម្តេចសីហនុ ជានាយករដ្ឋមន្ត្រីនេះ មានរយៈពេលមិនដល់មួយខែកន្លះផង ព្រះអង្គក៏ប្រកាសរំលាយចោល ហើយរៀបចំសមាសភាពរាជរដ្ឋាភិបាលថ្មីមួយទៀត ដោយបានតែងតាំង សាន យុន ជានាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីមហាផ្ទៃ រដ្ឋមន្ត្រីការបរទេស រដ្ឋមន្ត្រីការពារជាតិ និងរដ្ឋមន្ត្រីបោសសម្អាតអំពើពុករលួយ, ឈួន ម្ជុលពេជ្រ ( ដាប ឈួន )នៅតែជារដ្ឋមន្ត្រីសន្តិសុខ និងធម្មការ ដដែល, សៅ អួន ជារដ្ឋមន្ត្រីយុត្តិធម៌, ហួត សម្បត្តិ ជារដ្ឋមន្ត្រី ហិរញ្ញវត្ថុ ផែនការ និងឧស្សាហូបនីយកម្ម, ផ្លែក ភឺន ជារដ្ឋមន្ត្រី

សាធារណការ កសិកម្ម និងទូរគមនាគមន៍, ហួត សម្អាត ជារដ្ឋលេខាធិការការងារ និងព័ត៌មាន, កុច សាន ជារដ្ឋលេខាធិការពាណិជ្ជកម្ម និងឧស្សាហកម្ម, យឹម ឱត ជារដ្ឋលេខាធិការអប់រំជាតិ កីឡា និងវិចិត្រ សិល្បៈ, ញ៉ែម សុផល ជារដ្ឋលេខាធិការសាធារណសុខាភិបាល និងសង្គមកិច្ច, ទូច គីម ជារដ្ឋលេខាធិការអមទីស្ដីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកសម្របសម្រួលការសិក្សា និងការកែទម្រង់, សឹង គឿកថ ជារដ្ឋលេខាធិការអមទីស្ដីការគណៈរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការវប្បធម៌ និងសារព័ត៌មាន, សាក់ ស៊ុតសាខន ជារដ្ឋលេខាធិការការពារជាតិ, ឡៅ ប៊ុនប៉ា ជាអនុរដ្ឋលេខាធិការកសិកម្ម ទទួលបន្ទុករាជមន្ទីរសហករណ៍, រឿម សុផុន ជាអនុរដ្ឋលេខាធិការ ការងារ សង្គមកិច្ច ទទួលបន្ទុកតាំងទីលំនៅ និងកិច្ចការកសិករ, អ៊ុក ឈុំ ជាអនុរដ្ឋលេខាធិការមហាផ្ទៃ និងធុយ ប៊ុនសូ ជាអនុរដ្ឋលេខាធិការសាធា រណសិក្សាធិការ។

គួរកត់សម្គាល់ថា ក្នុងរចនាសម្ព័ន្ធរាជរដ្ឋាភិបាលថ្មីនេះ ក្រសួងបោសសម្អាតទូទៅ ពុំសូវមានប្រសិទ្ធភាពប៉ុន្មាននោះ សម្ដេចសីហនុ ក៏បានរំលាយក្រសួងនេះចោលវិញ។

ពីថ្ងៃទី២២ ដល់ ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៥៦ នាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ បានធ្វើដំណើរមកបំពេញទស្សនកិច្ចនៅកម្ពុជា ដើម្បីរឹតចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការ ប្រទេសទាំង២ឱ្យកាន់តែរឹងមាំថែមទៀត និងបានចុះហត្ថលេខាលើសេចក្ដីថ្លែងការណ៍រួម ស្ដីពីការប្រកាន់ភ្ជាប់នូវគោលនយោបាយមិនឈ្លានពានគ្នា និងគោរពអធិបតេយ្យភាពគ្នា ទៅវិញទៅមក។

អតីតលេខាផ្ទាល់សម្ដេចសីហនុ ឈ្មោះហ្ស៊ុយលីយ៉ូ ហ្សែលជ្រេស( Julio Jeldres) បានសរសេរនៅក្នុងអត្ថបទមួយនៅក្នុងឆ្នាំ២០១២ថា ព្រះបាទ នរោត្តម សីហនុ សព្វព្រះទ័យយ៉ាងខ្លាំងជាមួយនាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ ព្រោះថ្នាក់ដឹកនាំប្រទេសមហាអំណាចរូបនេះ ចេះដាក់ខ្លួន ឱនលំទោនគោរពព្រះអង្គ។ គារវកិច្ចដ៏ទន់ភ្លន់របស់ជូ អេនឡាយ បានធ្វើឲ្យព្រះអង្គឈ្វេងយល់ថា ប្រទេសមហាអំណាចចិន បានផ្ដល់តម្លៃស្មើមុខស្មើមាត់ដល់ព្រះអង្គ និងប្រទេសកម្ពុជា។

នៅថ្ងៃទី០៣ ខែមករា ឆ្នាំ១៩៥៧ នាយករដ្ឋមន្ត្រីសាន យុន បានធ្វើការកែសម្រួល ផ្លាស់ប្តូរសមាសភាពសមាជិកគណៈរដ្ឋមន្ត្រីរបស់គាត់មួយចំនួន។ សាន យុន ជានាយក រដ្ឋមន្ត្រីទទួលបន្ទុកបោសសម្អាតទូទៅ ដដែល និងជារដ្ឋមន្ត្រីការបរទេស កិច្ចការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ការពារជាតិ និងមហាផ្ទៃ ទៀតផង, ឈួន ម្ចុលពេជ្រ (ដាប ឈួន) ឡើងឋានៈ ជាទេសរដ្ឋមន្ត្រី ទទួលបន្ទុកសន្តិសុខជាតិ និងធម្មការ, សៅ អួន ជារដ្ឋមន្ត្រីយុត្តិធម៌ ដដែល, ជា ជិនកុក ជារដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកសម្របសម្រួលការសិក្សា និងការ កែទម្រង់, ផ្លែក ភីន ជារដ្ឋមន្ត្រីកសិកម្ម ផែនការ និងឧស្សាហូបនីយកម្ម, ហួត សម្បត្តិ ធ្លាក់ ពីរដ្ឋមន្ត្រី មកជារដ្ឋលេខាធិការព័ត៌មាន និងការងារ, យឹម ឌិត ជារដ្ឋលេខាធិការអប់រំជាតិ កីឡា យុវជន និងវិចិត្រសិល្បៈ ដដែល, ទូច គីម ជារដ្ឋលេខាធិការសេដ្ឋកិច្ច, ញ៉ែម សុផល ជារដ្ឋលេខាធិការសាធារណសុខាភិបាល និងសង្គមកិច្ច, សឹង គៀកថ រដ្ឋលេខាធិការថវិកា, សាក់ ស៊ុតសាខន រដ្ឋលេខាធិការការពារជាតិ, ផ្លែក ឆាត រដ្ឋលេខាធិការសាធារណការ និង ទូរគមនាគមន៍, ឡៅ ប៊ុនប៉ា ជារដ្ឋលេខាធិការកសិកម្ម ទទួលបន្ទុករាជមន្ទីរសហករណ៍, អ៊ុក ឈុំ អនុរដ្ឋលេខាធិការមហាផ្ទៃ,ធុយ ប៊ុនសូ ជាអនុរដ្ឋលេខាធិការអប់រំជាតិ និង អ៊ឹង ក្រពុំផ្កា ជាអនុរដ្ឋលេខាធិការសាធារណសុខាភិបាល និងសង្គមកិច្ច ទទួលបន្ទុកតាំងទីលំនៅ និងកិច្ចការកសិករ។

# ១០០
# ង៉ូ ឌិញយៀម បង្ខំសម្ដេចសីហនុ ប្រគល់កោះខ្មែរមួយចំនួនទៅឱ្យខ្លួន



**ង៉ូ ឌិញយៀម** (**រូបថត** fickr)

ការពិតទៅ ប្រទេសវៀតណាមត្រូវបានពុះចែកជាពីរ តាំងពីនៅក្នុងឆ្នាំ១៩៤៩ គឺបារាំង ជាអ្នកផ្ដួចផ្ដើមគំនិតបង្កើតរដ្ឋាភិបាលវៀតណាមខាងត្បូង ក្រោមការដឹកនាំរបស់ព្រះចៅបាវដាយ អតីតអធិរាជនៃនគរអណ្ណាម ដោយនៅពេលនោះ បារាំង ក៏មានការគាំទ្រពីសហរដ្ឋអាមេរិក ផងដែរ។ ក្នុងឆ្នាំ១៩៤៩នោះ បារាំង បានយកព្រះចៅបាវដាយ ដែលរត់គៀសខ្លួនទៅក្រុងហុងកុង ឱ្យមកដឹកនាំរដ្ឋវៀតណាម (វៀតណាមខាងត្បូង)វិញ និងបានតែងតាំង ង៉ូ ឌិញយៀម ឱ្យធ្វើជានាយករដ្ឋមន្ត្រី។ ប៉ុន្តែ ក្រោយពីមានកិច្ចព្រមព្រៀងក្រុងហ្សឺណែវ នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៥៤ ង៉ូ ឌិញយៀម បានរៀបចំធ្វើរដ្ឋប្រហារស្រប ច្បាប់មួយ តាមរយៈការធ្វើប្រជាមតិ ដើម្បីឱ្យប្រជាជនវៀតណាមខាងត្បូង សម្រេច ចិត្តថាតើត្រូវរក្សាទុករបបរាជានិយម មានព្រះចៅបាវដាយ ជាតំណាងឱ្យនៅដដែល ឬមួយត្រូវបង្កើតរបបសាធារណរដ្ឋនិយម?។

លទ្ធផលនៃការធ្វើប្រជាមតិនៅពេលនោះ បានបង្ហាញថា ប្រជាជនវៀតណាមខាងត្បូង ប្រមាណ ៩៨ភាគរយ បានគាំទ្រ ឱ្យបង្កើតរបបសាធារណរដ្ឋ។

៣ខែ ក្រោយលទ្ធផលនៃការធ្វើប្រជាមតិនោះ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៥៥ ង៉ូ ឌិញយៀម បានប្រកាសខ្លួនឯងជាប្រធានាធិបតី និងប្រកាសប្រទេសរបស់គាត់ថា សាធារណរដ្ឋវៀតណាម។

ភ្លាមៗនោះ រដ្ឋាភិបាលអាមេរិក និងបារាំង ប្រកាសគាំទ្រ ង៉ូ ឌិញយៀម ពេញទំហឹង ដោយសាររដ្ឋាភិបាលប្រទេសទាំង២នេះ មើលឃើញថា ង៉ូ ឌិញយៀម ជាមេដឹកនាំប្រឆាំងនឹងចលនាតស៊ូរំដោះជាតិវៀតណាមខាងត្បូងជាពួកកុម្មុយនិស្ត ដែលហៅកាត់ថា ពួកវៀតកុង យ៉ាងប្តូរផ្តាច់បំផុត។

ប្រធានាធិបតី ង៉ូ ឌិញយៀម បានធ្វើការវាយប្រហារដោយពាក្យសម្តីគ្មានសំចៃមាត់ទៅលើពួកវៀតណាមកុម្មុយនិស្ត ហើយនរណាហ៊ានប្រឆាំងនឹងគាត់ ពិសេសឱ្យតែជាពួកកុម្មុយនិស្ត គាត់នឹងបញ្ជាឱ្យគេចាប់ទៅដាក់គុក ធ្វើទារុណកម្ម ឬសម្លាប់ចោលភ្លាមៗតែម្តង។ ង៉ូ ឌិញយៀម មិនត្រឹមតែជាមេដឹកនាំផ្តាច់ការប៉ុណ្ណោះទេ គឺថែមទាំងជាជនពុករលួយ និងគ្រួសារនិយម គួរឱ្យស្អប់ខ្ពើមបំផុត។

នៅក្នុងអំឡុងសង្គ្រាមលោកលើកទី២ សហរដ្ឋអាមេរិក ជាអ្នកគាំទ្រចលនាតស៊ូទាមទារឯករាជ្យរបស់វៀតណាម ដឹកនាំដោយហូជីមិញ ដើម្បីប្រឆាំងនឹងកងទ័ពជប៉ុន ហើយសហរដ្ឋអាមេរិក តែងតែប្រកាន់ជំហរប្រឆាំងនឹងនយោបាយអាណានិគមផងដែរ រួមទាំងអាណានិគមនៅឥណ្ឌូចិន ក៏ដូចជាអាណានិគមនៅបណ្តាប្រទេសផ្សេងៗទៀតនៅទូទាំងពិភពលោក។

ក៏ប៉ុន្តែ ក្រោយពីសង្គ្រាមលោកលើកទី២ត្រូវបានបញ្ចប់ ខណៈពិភពលោកត្រូវធ្លាក់ចូលទៅក្នុងសង្គ្រាមត្រជាក់ សហរដ្ឋអាមេរិក បែរជាទៅគាំទ្របារាំង ក្នុងការបង្ក្រាបចលនាទាមទារ ឯករាជ្យនៅវៀតណាម ទៅវិញ។ មូលហេតុនេះ គឺដោយសារតែបារាំង ជាសម្ព័ន្ធមិត្តដ៏សំខាន់ របស់អាមេរិក ចំណែកឯចលនាតស៊ូទាមទារឯករាជ្យវៀតណាម ដឹកនាំដោយហូ

ដីមិញ គឺជាចលនាកុម្មុយនិស្តគាំទ្រដោយសហភាពសូវៀត និងចិន។ មេដឹកនាំអាមេរិក បានក្បត់នឹងគោលនយោបាយប្រឆាំងនឹងពួកអាណានិគមរបស់ខ្លួន ព្រោះតែចង់បញ្ចៀសកុំឲ្យជ្រោយ ឥណ្ឌូចិន ត្រូវធ្លាក់ក្រោមការកាន់កាប់របស់ពួកកុម្មុយនិស្ត។

មេដឹកនាំអាមេរិក មានជំនឿថា ប្រសិនបើប្រទេសណាមួយ ធ្លាក់ចូលទៅក្នុងដៃកុម្មុយនិស្តហើយនោះ ប្រទេសផ្សេងៗទៀតដែលនៅក្បែរៗគ្នានោះ មិនយូរមិនឆាប់ ប្រាកដជានឹងក្លាយជាប្រទេសកុម្មុយនិស្តដែរជាមិនខាន គឺមិនខុសគ្នាពីបណ្ដាប្រទេសនៅអឺរ៉ុបខាងកើត បន្ទាប់ពីសង្គ្រាមលោកលើកទី២ ត្រូវបានបញ្ចប់នៅឆ្នាំ១៩៤៥។ ពិសេសសហរដ្ឋអាមេរិក ខ្លាចពួកកុម្មុយនិស្តដែលកំពុងដឹកនាំគ្រប់គ្រងប្រទេសវៀតណាមខាងជើង ដណ្ដើមកាន់កាប់វៀតណាមខាងត្បូង ហើយបន្ទាប់មកពង្រីកឥទ្ធិពលរបស់ខ្លួននៅពាសពេញអាស៊ីទាំងមូល។ ហេតុដូច្នេះហើយ បានជាអាមេរិក បានសម្រេចចិត្តផ្ដល់ជំនួយសេដ្ឋកិច្ច និងជំនួយយោធា ព្រមទាំងទីប្រឹក្សាផងដែរ ដើម្បីជួយទ្រទ្រង់រដ្ឋាភិបាលវៀតណាមខាងត្បូង ប្រឆាំងជាមួយពួកកុម្មុយនិស្តវៀតណាមខាងជើង។ តាមកិច្ចព្រមព្រៀងក្រុងហ្សឺណែវ ភាគីវៀតណាមខាងជើង និងវៀតណាមខាងត្បូង ត្រូវរក្សាស្ថានភាពឱ្យនៅដដែល និងរង់ចាំការបោះឆ្នោតសាកលមួយ គ្រោងធ្វើឡើង នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៥៦ ក្រោមការចាត់ចែងរបស់គណៈកម្មការត្រួតពិនិត្យអន្តរជាតិ (ICC)។

ចាប់ពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៥៧ ជនជាតិវៀតណាមជាជនកុម្មុយនិស្ត និងអ្នកកាន់ព្រះពុទ្ធសាសនាប្រមាណ១២០០០នាក់ ត្រូវបាន ង៉ូ ឌិញយៀម បញ្ជាឱ្យគេចាប់យកទៅសម្លាប់ចោល ព្រោះតែហ៊ានក្រោកឡើងប្រឆាំងនឹងគាត់ ។

ពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៥៧ នោះដែរ សហរដ្ឋអាមេរិក បានផ្ដល់ជំនួយដល់របបសាធារណរដ្ឋវៀតណាមខាងត្បូង ចំនួនជាទឹកប្រាក់ ៨០០លានដុល្លារអាមេរិក ក្នុងនោះមានជំនួយយោធា ៦៨ភាគរយ។

ទន្ទឹមនោះ កងទ័ពសហរដ្ឋអាមេរិក ចំនួន២០០០នាក់ ត្រូវបានបញ្ជូនមកដល់វៀតណាមខាងត្បូង រួចជាស្រេច ដូចអ្វីដែលរដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក ហ្វូស្ទ័រ



**កងទ័ពអាមេរិក នៅវៀតណាមខាងត្បូង ចាប់បានពួកវៀតកុង** (**រូបថត** pinterest)

ឌុល្លេស (Foster Dulles) បានថ្លែងតាំងពីថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៥៤ មុនពេលមានសន្និសីទនៅក្រុងហ្សឺណែវ ថា សហរដ្ឋអាមេរិក ត្រូវតែមានមូលដ្ឋានកងទ័ពពីរកន្លែង គឺមួយនៅប្រទេសកូរ៉េខាងត្បូង និងមួយទៀត នៅជ្រោយឥណ្ឌូចិន។

ថ្ងៃទី៣ ខែសីហា ឆ្នាំ១៩៥៩ សម្តេចសីហនុ ក៏បានយាងទៅកាន់ទីក្រុងព្រៃនគរ (ទីក្រុងសៃហ្គន) ប្រទេសវៀតណាមភាគខាងត្បូង ក្នុងបំណងរឹតចំណងមិត្តភាព ដើម្បីរួមរស់ជិតខាងគ្នាដោយសុខសន្តិភាព។ ប៉ុន្តែ នៅក្នុងអំឡុងពេលស្នាក់នៅរបស់ព្រះអង្គ នាទីក្រុងព្រៃនគរ ប្រធានាធិបតី ង៉ូ ឌិញយៀម បែរជានិយាយដោយឥតអៀនខ្មាសថា សុំឱ្យព្រះអង្គប្រគល់បណ្តាកោះទាំងឡាយ ដូចជាកោះកន្ទាយ នៅខាងមុខទីក្រុងកែប, កោះសេះ និងកោះពូលូវ៉ៃ ឲ្យទៅប្រទេសវៀតណាមខាងត្បូង វិញ។

សម្តេចសីហនុ បានឆ្លើយតបវិញ ដោយមិនខឹងប្រឡោតថា លោកនាយករដ្ឋមន្ត្រី! ព្រះរាជាណាចក្រកម្ពុជា មិនមានហេតុផលអ្វី ត្រូវប្រគល់បណ្តាកោះជាកម្មសិទ្ធិរបស់ខ្លួនតាំងពីការកើតទឹកដីកម្ពុជា មានអាយុរាប់ពាន់ឆ្នាំមកហើយនោះ ទៅឱ្យប្រទេសវៀតណាម

នោះទេ។

សម្ដេចសីហនុ បានបញ្ជាក់បន្ថែមទៅ ង៉ូ ឌិញយៀម ថា គឺកោះត្រល់ ដែលវៀតណាម ហៅថាកោះភូកុក នៅក្បែរឆ្នេរសមុទ្រខ្មែរ នោះទេ ដែលខ្ញុំត្រូវទាមទារយកមកវិញ ព្រោះពួកអាណានិគមបារាំង បានប្រគល់ឱ្យវៀតណាម ដោយអយុត្តិធម៌បំផុត។ ខ្ញុំសូមរម្លឹកលោកថា ទឹកដីកូសាំងស៊ីននោះទេ ដែលលោកត្រូវប្រគល់មកខ្មែរវិញ ព្រោះទឹកដីនោះ គឺជាទឹកដីកម្ពុជាក្រោម របស់យើង។

ដោយសារតែការទាមទារយកកោះខ្មែរ ដោយឥតអៀនខ្មាសរបស់ប្រធានាធិបតី ង៉ូ ឌិញយៀម ធ្វើឱ្យព្រះរាជទស្សនកិច្ចរបស់សម្ដេចសីហនុ នាទីក្រុងព្រៃនគរ ក្នុងបំណងរឹតចំណងមិត្តភាព ដើម្បីរួមរស់ជិតខាងគ្នា ដោយសុខសន្តិភាពនោះ ក្លាយទៅជាការឈ្លានពានរបស់វៀតណាមខាងត្បូង មកលើបូរណភាពទឹកដីកម្ពុជា ជាបន្តបន្ទាប់ចាប់តាំងពីពេលនោះមក។

# ១០១
# ព្រះមហាក្សត្រតែងតាំងសម សារី ជាទីប្រឹក្សារាជរដ្ឋាភិបាល



**សម សារី**

នៅថ្ងៃទី១២ ខែមករា ឆ្នាំ១៩៥៧ សមាជជាតិលើកទី៤ របស់ចលនាសង្គមរាស្ត្រនិយម បានអនុម័តសេចក្តីសម្រេចចិត្តប្រកាន់យកគោលជំហរអព្យាក្រឹត មកដឹកនាំប្រទេសដូចមុនដដែល ។

រាជរដ្ឋាភិបាល សាន យុន ដឹកនាំប្រទេសបានជាង៣ខែ ត្រូវពួកពាណិជ្ជករនាំគ្នារិះគន់ថា អសមត្ថភាព ព្រោះមិនអាចការពារផលិតផលក្នុងប្រទេសបាន ដូចមានចែងនៅក្នុងមាត្រា៩៥ នៃរដ្ឋធម្មនុញ្ញ ហើយគួបផ្សំរាជរដ្ឋាភិបាលនេះ មានបញ្ហាចម្រូងចម្រាសពីបញ្ហាថវិកាជាតិ ផងនោះ រដ្ឋសភាបានបើកអង្គប្រជុំ បោះឆ្នោតទម្លាក់រាជរដ្ឋាភិបាល សាន យុន នៅថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៥៧ រួចបោះឆ្នោតជ្រើសតាំងសម្តេចសីហនុ ជានាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីការបរទេស ឧស្សាហកម្ម និងផែនការ, ឈួន ម្ជុលពេជ្រ( ដាប ឈួន ) ជាទេសរដ្ឋមន្ត្រីសន្តិសុខជាតិ និងធម្មការដដែល, គូ រុន ជារដ្ឋមន្ត្រីសេដ្ឋកិច្ចជាតិ, ទ្រឿង កាង



**រាជរដ្ឋាភិបាលដែលមានសម សារី ជាទីប្រឹក្សា**

ជារដ្ឋមន្ត្រីហិរញ្ញវត្ថុ, លាន ថុង ជារដ្ឋមន្ត្រីយុត្តិធម៌, ម៉ៅ ចយ ជារដ្ឋមន្ត្រីការងារ និងសង្គមកិច្ច, ហួត សម្អាត ជារដ្ឋមន្ត្រីអប់រំជាតិ យុវជន និងបោសសម្អាតទូទៅ, សាក់ ស៊ុតសាខន ជារដ្ឋមន្ត្រីការពារជាតិ និងព័ត៌មាន, ទូច គីម ជារដ្ឋលេខាធិការសាធារណការ និងទូរគមនាគមន៍, ញ៉ែម សុផល ជារដ្ឋលេខាធិការសាធារណសុខាភិបាល, ភួង សាន ជារដ្ឋលេខាធិការអមទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកទំនាក់ទំនងសភា និងទឹម ដុង ជារដ្ឋលេខាធិការព័ត៌មាន និងទេសចរណ៍។

នៅថ្ងៃប្រកាសសមាសភាពគណៈរដ្ឋមន្ត្រីថ្មីនេះ ព្រះមហាក្សត្រនរោត្តម សុរាម្រិត ក៏បានចេញព្រះរាជក្រឹត្យ លេខ១៧៣ ន.ស ចុះថ្ងៃទី០៩ ខែមសា ឆ្នាំ១៩៥៧ តែងតាំង សម សារី (អតីតឧបនាយករដ្ឋមន្ត្រី) លែងមានឈ្មោះនៅក្នុងជួរគណៈរដ្ឋមន្ត្រី តាំងពីដើមឆ្នាំ១៩៥៦ មកនោះ ជាទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើនាយករដ្ឋមន្ត្រី បន្ថែមលើមុខតំណែងជាសមាជិកឧត្តមក្រុមប្រឹក្សាព្រះមហាក្សត្រ ។

នៅក្នុងព្រះរាជក្រឹត្យនោះ ព្រះមហាក្សត្រនរោត្តម សុរាម្រិត ក៏បានបញ្ជាក់ពីតួនាទី

និងសិទ្ធិអំណាចរបស់ ទីប្រឹក្សារាជរដ្ឋាភិបាលថា សម សារី មានសិទ្ធិចូលរួមក្នុងកិច្ចប្រជុំរបស់គណៈរដ្ឋមន្ត្រី ហើយជូនយោបល់ និងណែនាំគ្រប់កិច្ចការទាំងអស់ចំពោះគណៈរដ្ឋមន្ត្រី ដើម្បីពិភាក្សាគ្នា ធ្វើយ៉ាងណាឱ្យគោលនយោបាយរបស់រាជរដ្ឋាភិបាលប្រព្រឹត្តទៅដោយរលូន និងទទួលបានលទ្ធផលល្អប្រសើរ។

ជាមួយគ្នានេះ សម សារី ក៏មានសិទ្ធិសាកសួរព័ត៌មាន ឬសុំការបំភ្លឺបញ្ហាផ្សេងៗពីទីស្តីការរដ្ឋមន្ត្រីទាំងឡាយ ហើយធ្វើរបាយការណ៍ដាក់ថ្វាយសម្តេចសីហនុ និងគណៈរដ្ឋមន្ត្រីទាំងមូល ដើម្បីធ្វើការដោះស្រាយ។

នៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៥៧ ដោយសារស៊ូទ្រាំចំពោះការវាយប្រហាររិះគន់របស់មន្ត្រីជាន់ខ្ពស់គណបក្សប្រជាធិបតេយ្យ មកលើចលនាសង្គមរាស្ត្រនិយម និងព្រះអង្គមិនចេះអស់មិនចេះហើយនោះ សម្តេចសីហនុ ក៏បានបើកវេទិកាមួយ ដើម្បីតទល់គ្នាដោយផ្ទាល់ នៅក្នុងព្រះបរមរាជវាំង ជាមួយមន្ត្រីជាន់ខ្ពស់របស់គណបក្សប្រជាធិបតេយ្យ ចំនួន៥នាក់ ក្នុងនោះមានព្រះអង្គម្ចាស់នរោត្តម ភូរិស្សារ៉ា មួយអង្គផងដែរ ដោយវេទិកាតទល់គ្នានេះ មានការផ្សាយបន្តផ្ទាល់តាមវិទ្យុជាតិ ទៀតផង។

នៅក្នុងវេទិកានោះ ពួកមន្ត្រីជាន់ខ្ពស់គណបក្សប្រជាធិបតេយ្យ នៅតែមិនញញើតក្នុងការមានមតិរិះគន់ចំពោះព្រះអង្គដដែល។ ប៉ុន្តែ ក្រោយចេញពីវេទិកានោះមក មន្ត្រីជាន់ខ្ពស់របស់គណបក្សប្រជាធិបតេយ្យទាំង៥នាក់នោះ ត្រូវកងរក្សាព្រះអង្គវាយឱ្យរងរបួសធ្ងន់ និងរកចាប់ខ្លួនបន្តទៀត ធ្វើឱ្យពួកគេទាំង៥នាក់បាក់ស្បាត លែងហ៊ានធ្វើសកម្មភាពប្រឆាំងនឹងព្រះអង្គទៀត ចាប់ពីពេលនោះមក។

តែទោះបីមន្ត្រីគណបក្សប្រជាធិបតេយ្យ លែងហ៊ានធ្វើសកម្មភាពវាយប្រហាររិះគន់រាជរដ្ឋាភិបាល ដឹកនាំដោយសម្តេចសីហនុ ក៏ពិតមែន ក៏មជ្ឈដ្ឋានផ្សេងទៀត បានរិះគន់ថារាជរដ្ឋាភិបាលសម្តេចសីហនុ ពុំមានសមត្ថភាពក្នុងការបង្ក្រាបអំពើពុករលួយ និងបនល្បែងស៊ីសងឡើយ។

នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៥៧ សម្តេចសីហនុ សម្រេចព្រះទ័យចុះចេញពី



**នាយករដ្ឋមន្ត្រី ស៊ឹម វ៉ា**

តំណែងនាយករដ្ឋមន្ត្រី ហើយថ្ងៃនោះដែរ សមាសភាពគណៈរដ្ឋមន្ត្រីថ្មីមួយទៀត ត្រូវបានប្រកាសឡើង ដោយមាន ស៊ឹម វ៉ា ជានាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងផែនការ, ទេព ផន ជាឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកបោសសម្អាតទូទៅ និងសេដ្ឋកិច្ចជាតិ, ប៉ាល់ ជួន ជារដ្ឋមន្ត្រីមហាផ្ទៃ សន្តិសុខជាតិ និងធម្មការ (ជំនួស ឈួន ម្ជុលពេជ្រ), សៅ អួន ជារដ្ឋមន្ត្រីយុត្តិធម៌, ទ្រឿង កាង ជារដ្ឋមន្ត្រីហិរញ្ញវត្ថុ សង្គមកិច្ច, ម៉ៅ ចយ រដ្ឋមន្ត្រីការងារ និងសង្គម កិច្ច, ម៉ៅ សាយ រដ្ឋមន្ត្រីអប់រំជាតិ កីឡា និងយុវជន,ទ្រង់ស៊ីសុវត្ថិ សិរិមតៈ ជារដ្ឋមន្ត្រីការពារជាតិ ព័ត៌មាន និងទេសចរណ៍, ទូច គីម ជារដ្ឋមន្ត្រីសាធារណការ ទូរគមនាគមន៍ និងសាធារណសុខាភិបាល, ឡៅ ប៊ុនប៉ា ជារដ្ឋលេខាធិការសេដ្ឋកិច្ចជាតិ ទទួលបន្ទុកកសិកម្ម និងរាជមន្ទីរសហករណ៍, ទឹម ដុង ជាលេខាធិការព័ត៌មាន និងទេសចរណ៍, ភួង សាន ជារដ្ឋលេខាធិការអមទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកទំនាក់ទំនងរដ្ឋសភា, ជា ជិនកុក អនុរដ្ឋលេខាធិការមហាផ្ទៃ និងសន្តិសុខជាតិ, មាស យ៉ង់ ជាអនុរដ្ឋលេខាធិការធម្មការ, អ៊ុក ឈុំ ជាអនុរដ្ឋលេខាធិការការបរទេស, ធុយ ប៊ុនសូ ជាអនុរដ្ឋលេខាធិការការងារសង្គមកិច្ច ទទួលបន្ទុកតាំងលំនៅឋាន និងកសិដ្ឋានរដ្ឋ, អ៊ឹង ក្រពុំផ្កា ជាអនុរដ្ឋលេខាធិការសាធារណការ និងទូរគមនាគមន៍ ទទួលបន្ទុកប្រៃសណីយ៍ ទូរគមនាគមន៍ដឹកជញ្ជូន, សាប សុខុម ជាអនុរដ្ឋលេខាធិការសេដ្ឋកិច្ចជាតិ, យូ ហេង ជាអនុរដ្ឋលេខាធិការការពារ និងសង្គមកិច្ច ទទួលបន្ទុកការងារ និងកិច្ចការកសិករ និងពុង ប៉េងចេង ជាអនុរដ្ឋលេខាធិការអប់រំជាតិ។

# ១០២
# ចលនាយុវជនសង្គមរាស្ត្រនិយមខ្មែរ



ឯកសណ្ឋានចលនាយុវជនសង្គមរាស្ត្រនិយមខ្មែរ

នៅក្នុងឆ្នាំ១៩៣៤ អង្គការយុវជនមួយ ហៅថា អង្គការខេមរកាយរឹទ្ធិកម្ពុជា ត្រូវបានបង្កើតឡើង ក្រោមការដឹកនាំរបស់ព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉េត។ អង្គការយុវជននេះបានពង្រីកពីក្រុងភ្នំពេញទៅដល់ខេត្តចំនួន៨ទៀតដោយមានសមាជិកជាង១០០០នាក់។

នៅចុងឆ្នាំ១៩៣៧ អង្គការកាយរឹទ្ធិបារាំងបាន បញ្ជូនតំណាងម្នាក់ឈ្មោះរ៉ាយម៉ុង ស្លេម្ម័រ (Raymond Schlemmer) មកកាន់ប្រទេសទាំងបីនៅឥណ្ឌូចិន គឺកម្ពុជា ឡាវ វៀតណាម ដើម្បីរៀបចំបង្កើតសហព័ន្ធសមាគមកាយរឹទ្ធិឥណ្ឌូចិន (FIAS = Indochina Federating of Scouting Associations )។

នៅក្នុងអំឡុងឆ្នាំ ១៩៣៩ ដល់ឆ្នាំ ១៩៤៥ ដោយសារបារាំងជាប់ដៃ នៅក្នុងសង្គ្រាម

លោកលើកទី២ ស្របពេលប្រទេសកម្ពុជា មានចលនាខ្មែរឥស្សរៈជាច្រើននាំគ្នាតស៊ូ ដើម្បីទាមទារឯករាជ្យពីបារាំង ហើយប្រទេសជប៉ុន ចូលមកដណ្ដើមបារាំង ត្រួតត្រាកម្ពុជា ទៀតនោះ អង្គការខេមរកាយរឹទ្ធិ នៅក្នុងប្រទេសកម្ពុជា ឡាវ វៀតណាម ក៏បានផ្អាកសកម្មភាពដែរ។

នៅក្នុងឆ្នាំ១៩៥៥ កាយរឹទ្ធិកម្ពុជា បានចេញទៅចូលរួមក្នុងពិធីបោះជំរំកាយរឹទ្ធិពិភពលោក លើកទី៨ ដែលបានប្រព្រឹត្តទៅ នៅប្រទេសកាណាដា។

នៅក្នុងឆ្នាំ១៩៥៦ អង្គការខេមរកាយរឹទ្ធិ បានផ្លាស់ប្ដូរឈ្មោះទៅជាអង្គការខេមរកាយរឹទ្ធិមហាក្សត្រិយានី វិញ។ អង្គការខេមរកាយរឹទ្ធិ នេះ មានសមាជិកចំនួនជាង១២០០នាក់ ក្នុងនោះ ៥០០នាក់នៅក្នុងទីក្រុងភ្នំពេញ និងប្រមាណ៧០០នាក់ទៀតនៅតាមបណ្ដាខេត្ត។

នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ១៩៥៧ សម្ដេចសីហនុ បានបង្កើតចលនាយុវជនមួយឱ្យឈ្មោះថា"យុវជនរាជសង្គមរាស្ត្រនិយមខ្មែរ" (ភាសាបារាំង JSRK = Jeunesse socialiste royale Khmère)។

ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៦៤ ព្រះអង្គម្ចាស់ស៊ីសុវត្ថិ ឥស្សរ៉ា ជាប្រធានអង្គការខេមរកាយរឹទ្ធិមហាក្សត្រិយានី បានប្រកាសរំលាយសមាគមយុវជនកាយរឹទ្ធិកម្ពុជា (The Cambodian Boy Scout Association)ចោល ហើយឱ្យសមាជិកទាំងអស់ ចូលជាសមាជិករបស់ចលនាយុវជនសង្គមរាស្ត្រនិយមខ្មែរ ដែលសម្ដេចសីហនុ បានបង្កើតឡើងនោះ។

# ១០៣
# ប៉ុល ពត, អៀង សារី, សុន សេន
# និងប្រពន្ធពួកគាត់ សុទ្ធតែជាសាស្ត្រាចារ្យ



**ខៀវ ធីរិទ្ធ ប្រពន្ធអៀង សារី និង ខៀវ ប៉ុណ្ណារី ប្រពន្ធប៉ុល ពត កាលរៀននៅប្រទេសបារាំង**

នៅក្នុងខែកញ្ញា ឆ្នាំ១៩៥៧ នៅក្នុងស្រុកឈូក ខេត្តកំពត មានអ្នកភូមិ៤៨នាក់ បានមកប្តឹងតវ៉ាជាមួយគណៈកម្មការត្រួតពិនិត្យអន្តរជាតិ (ICC)ថា ពួកអាជ្ញាធរបានមករុកកួន ធ្វើបាបពួកគេជាអតីតអ្នកតស៊ូរបស់បក្សប្រជាជបដិវត្តន៍ខ្មែរ។ ទន្ទឹមនឹងនេះ អ្នកភូមិ៥៤នាក់ទៀត នៅស្រុកបន្ទាយមាស ក្នុងខេត្តកំពត នោះដែរ ក៏បានដាក់ពាក្យប្តឹងតវ៉ាទៅគណៈកម្មការត្រួតពិនិត្យអន្តរជាតិ (ICC) ពីរឿងអាជ្ញាធរធ្វើទុក្ខបុកម្នេញពួកខ្លួន និងបានសម្តែងពីការព្រួយបារម្ភ ចំពោះការរំលោភបំពាន នៅតាមបណ្តោយព្រំដែន ពីសំណាក់កងទ័ពវៀតណាមខាងត្បូង គាំទ្រដោយសហរដ្ឋអាមេរិក ផងដែរ។

## របត់នយោបាយ

ពេលនោះ សោ ភឹម ជាអតីតមេទ័ពខ្មែរឥស្សរៈបក្សប្រជាជបដិវត្តន៍ខ្មែរ ល្បីឈ្មោះនៅភូមិភាគបូព៌ា កំពុងធ្វើស្រែជាមួយប្រពន្ធ នៅក្នុងស្រុកកំចាយមារ ខេត្តព្រៃវែង ក្បែរព្រំដែនខេត្តតៃនិញ របស់ប្រទេសវៀតណាម ក៏ត្រូវអាជ្ញាធរស្រុក-ខេត្ត តាមស្រាវជ្រាវរកចាប់ខ្លួនដែរ។ តែគាត់បានគេចខ្លួនពីខេត្តព្រៃវែង ទៅសម្ងំលាក់ខ្លួននៅម្តុំទឹកល្អក់ ទីក្រុងភ្នំពេញ និងឆ្លៀតឱកាសប្រកបមុខរបរជាជាងធ្វើផ្ទះ(ផ្ទះឈើ)។ ក្រោយពីសភាពការណ៍ស្ងប់ស្ងាត់បន្តិច ទើបគាត់ហ៊ានត្រលប់ទៅជួបប្រពន្ធកូន នៅឯខេត្តព្រៃវែង វិញ។

ចំណែកនៅភូមិភាគពាយព្យ អតីតមេបញ្ជាការយោធាភូមិភាគរបស់ចលនាតស៊ូខ្មែរឥស្សរៈគណបក្សប្រជាជនបដិវត្តន៍ខ្មែរ ឈ្មោះរស់ ញឹម ហៅមូល សម្បត្តិ ទៅចាប់ដីមួយកន្លែងនៅភាគខាងត្បូង ខេត្តបាត់ដំបង ដើម្បីប្រកបរបរកសិកម្មនោះ បានបន្តធ្វើសកម្មភាពឃោសនាពីបញ្ហានយោបាយខ្លះៗប៉ុណ្ណោះ ដោយពុំបានធ្វើសកម្មភាពអ្វីធំដុំ គួរឱ្យកត់សម្គាល់ឡើយ។

រីឯ នៅភូមិភាគឧត្តរ មានអ្នកតស៊ូម្នាក់ ឈ្មោះ កែ វិន ចូលរួមជាមួយចលនាខ្មែរឥស្សរៈតាំងពីវ័យ១៥ឆ្នាំនោះ ក្រោយសន្និសីទក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ គាត់បានវិលត្រលប់ទៅរស់នៅជាមួយម្តាយឪពុករបស់គាត់ នៅក្នុងស្រុកបារាយណ៍ ខេត្តកំពង់ធំ ត្រូវអាជ្ញាធរចាប់បាន យកទៅដាក់គុកនៅខេត្តកំពង់ធំ រួចបញ្ជូនទៅដាក់គុកនៅទីក្រុងភ្នំពេញ រហូតដល់ឆ្នាំ១៩៥៧ ទើបដោះលែងឱ្យមករស់នៅជួបជុំគ្រួសារវិញ ហើយគាត់បានរៀបការជាមួយនារីក្រមុំម្នាក់ នៅភូមិក្បែរគ្នា។

ក្រោយមក កែ វិន បានដូរឈ្មោះមកជា កែ ពក (ឈ្មោះបដិវត្ត)។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចន្លោះពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៩ កែ ពក បានឡើងឋានៈជាលេខាបក្សភូមិភាគកណ្តាល (ពីមុនជាភូមិភាគឧត្តរ)។

នៅក្នុងឆ្នាំ១៩៥៧ ខៀវ ធីរិទ្ធ (អៀង ធីរិទ្ធ) បានបញ្ចប់ការសិក្សាផ្នែកអក្សរសាស្ត្រអង់គ្លេសនៅប្រទេសបារាំងហើយគាត់បានវិលត្រលប់មកមាតុភូមិវិញ តែគាត់មិនប្រាថ្នាស្វែងរកបុណ្យស័ក្តិអ្វីធំដុំនោះទេ។



**ទិដ្ឋភាពទីក្រុងភ្នំពេញ សម័យទសវត្សរ៍ឆ្នាំ១៩៥០**

រាជរដ្ឋាភិបាលបានផ្តល់ការងារដល់គាត់ជាសាស្ត្រាចារ្យនៅវិទ្យាល័យរដ្ឋដែរ តែគាត់និងអៀង សារី ជាប្តីដែលបានរៀបការជាមួយគ្នា នៅប្រទេសបារាំង តាំងពីឆ្នាំ១៩៥១នោះ បានសម្រេចចិត្តធ្វើជាសាស្ត្រាចារ្យនៅវិទ្យាល័យឯកជនវិញ។ ទោះបីធ្វើជាសាស្ត្រាចារ្យនៅវិទ្យាល័យឯកជនទទួលបានប្រាក់កម្រៃតិចតួចស្តួចស្តើងក៏ពិតមែន ប៉ុន្តែពួកគាត់មានឱកាសធ្វើសកម្មភាពបម្រើចលនាបដិវត្តន៍ជាសម្ងាត់ ងាយស្រួលជាងធ្វើជាសាស្ត្រាចារ្យនៅតាមវិទ្យាល័យរដ្ឋ។

កាលក្នុងអំឡុងពេលបោះឆ្នោតឆ្នាំ១៩៥៥ សាឡុត ស និងខៀវ ប៉ុណ្ណារី ដែលបានស្រលាញ់គ្នាតាំងពីនៅរៀនឯប្រទេសបារាំង បានចូលរួមយ៉ាងសកម្មជាមួយគណបក្សប្រជា



**សិស្សសាលាគរុកោសល្យ កំពង់កន្ទួត នៅស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល**

ធិបតេយ្យ ដឹកនាំដោយកេង វ៉ាន់សាក់ តែគាត់មិនបានឈរឈ្មោះជាបេក្ខជននៅមណ្ឌលបោះឆ្នោតណាមួយទេ។ នៅក្នុងឆ្នាំ១៩៥៦ ពួកគាត់បានរៀបការនឹងគ្នាតាមប្រពៃណី។

ក្រោយពេលពួកគាត់រៀបការរួច ជី គឹមអាន ជាចៅផែនទី(មន្ត្រីសុរិយោដី)នៅសាលាក្រុងភ្នំពេញ ធ្លាប់សិក្សានៅប្រទេសបារាំង ជាមួយគ្នា និងធន សុខុម (សម័យសាធារណរដ្ឋខ្មែរ បានឡើងជារដ្ឋមន្ត្រី)ត្រូវជាបងជីដូនមួយរបស់ខៀវ ប៉ុណ្ណារី ជាមន្ត្រីរាជការនៅសាលាក្រុងភ្នំពេញ បានជួយលៃលកដោះស្រាយ រកបានដីឡូត៍មួយកន្លែងនៅម៉ុំចម្ការមន ដើម្បីគ្រាន់ឱ្យសាឡុត ស និងខៀវ ប៉ុណ្ណារី សង់ផ្ទះស្នាក់នៅ។

ពេលនោះ ខៀវ ប៉ុណ្ណារី មានវ័យ៣៦ឆ្នាំ ឯសាឡុត ស មានវ័យ៣១ឆ្នាំ។ ខៀវ ប៉ុណ្ណារី ជាស្ត្រីខ្មែរដំបូងគេបង្អស់ ដែលបានប្រលងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិភាគ២ (បាក់ឌុប) និងទទួលសញ្ញាបត្រថ្នាក់បរិញ្ញាមកពីប្រទេសបារាំង។ គាត់បានបម្រើការងារជាសាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរ នៅវិទ្យាល័យព្រះស៊ីសុវត្ថិ ផង និងនៅអនុវិទ្យាល័យឯកជន

ចម្រើនវិជ្ជា ជាមួយសាឡុត ស ជាសាស្ត្រាចារ្យបង្រៀនមុខវិជ្ជាភាសាបារាំង ប្រវត្តិវិទ្យា ភូមិវិទ្យា និងពលរដ្ឋវិជ្ជា ផងដែរ។

ដោយសារបំពេញការងារជាសាស្ត្រាចារ្យបង្រៀន នៅអនុវិទ្យាល័យចម្រើនវិជ្ជានោះ សាឡុត ស ក៏មានឱកាសធ្វើសកម្មភាពឃោសនា និងអប់រំមនោគមវិជ្ជាកុម្មុយនិស្តនិយម ដល់សិស្សទាំងឡាយ ដែលចូលទៅសិក្សានៅទីនោះដោយមានប្រសិទ្ធភាពបំផុត។

នៃ សារ៉ាន់ (យ៉ា) ក៏បានចូលមករស់នៅក្នុងក្រុងភ្នំពេញ ដែរ។ គាត់បានចាប់មុខរបរ ជាសាស្ត្រាចារ្យ នៅអនុវិទ្យាល័យឯកជនចម្រើនវិជ្ជា ជាមួយ វន វ៉េត, សៀត ឆែ និងអ្នកតស៊ូធ្វើបដិវត្តន៍ផ្សេងៗទៀតជាច្រើន។

ចំណែក សុន សេន និងប្រពន្ធគាត់ឈ្មោះយន់ យ៉ាត បម្រើការងារជាសាស្ត្រាចារ្យ នៅវិទ្យាល័យព្រះស៊ីសុវត្ថិ។ ក្រោយមក សុន សេន បានឡើងឋានៈជាប្រធានការិយាល័យមួយ នៅសាលាគរុកោសល្យក្រុងភ្នំពេញ ដោយមានអតីតនិស្សិតមកពីប្រទេសបារាំង ដូចជា ថៅ សេង, អ៊ុច វ៉ែន និងរស់ ដេជ្ជថូ ក៏បម្រើការងារជាសាស្ត្រាចារ្យបង្រៀន នៅសាលាគរុកោសល្យ នោះដែរ។

បន្ទាប់មកទៀត សុន សេន ត្រូវបានគេផ្លាស់ឱ្យទៅធ្វើជានាយកសាលាគរុកោសល្យ នៅកំពង់កន្ទួត ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល។ សាលាគរុកោសល្យកំពង់កន្ទួត នេះ សហរដ្ឋអាមេរិក ជាអ្នកផ្ដល់ជំនួយក្នុងការសាងសង់។

ជួន ជឿន មានសញ្ញាបត្រវេជ្ជបណ្ឌិត មកពីប្រទេសបារាំង បម្រើការងារជាសាស្ត្រាចារ្យ នៅមហាវិទ្យាល័យភូមិន្ទវិជ្ជាពេទ្យនៅទីក្រុងភ្នំពេញ ។ ចំណែក ហ៊ូ យន់ ធ្វើជានាយកអនុវិទ្យាល័យកម្ពុជបុត្រ ជាសម្បុករបស់ពួកសាស្ត្រាចារ្យកុម្មុយនិស្តនិយម ផង និងជាអ្នកនិពន្ធអត្ថបទទាក់ទងនឹងរឿងនយោបាយឱ្យកាសែត មួយចំនួន។

ចំណែក នួន ជា ក៏បានចូលមករស់នៅទីក្រុងភ្នំពេញ នៅក្នុងឆ្នាំ១៩៥៧ និងបន្តធ្វើសកម្មភាពពង្រីកចលនាបដិវត្តន៍ដែរ។

# ១០៤
# ហ៊ូ យន់, ហ៊ូ នឹម និងចៅ សេង និស្សិតឆ្វេងនិយម ក្លាយជាសមាជិកគណៈរដ្ឋមន្ត្រី



**ចៅ សេង**

ក្រោយពីចលនាសង្គមរាស្ត្រនិយមឡើងកាន់អំណាច ប្រទេសបារាំង បានជួយកសាងកំពង់ផែមួយ នៅក្រុងព្រះសីហនុ ព្រមទាំងអាកាសយានដ្ឋានពោធិ៍ចិនតុង និងមន្ទីរពេទ្យកាល់ម៉ែត ផងដែរ។ ចំណែក សហរដ្ឋអាមេរិក ទោះបីមិនអាចបញ្ចុះបញ្ចូលឱ្យសម្តេចសីហនុបោះបង់គោលនយោបាយអព្យាក្រឹតចោល មកចូលរួមជាមួយអង្គការសេអាតូ(SEATO) ដូចបំណងរបស់ខ្លួន ក៏ដោយ ក៏ប្រទេសមហាអំណាចមួយនេះ បានជួយកសាងផ្លូវជាតិលេខ៤ ពីក្រុងភ្នំពេញ ទៅកំពង់ផែក្រុងព្រះសីហនុ ដែរ។

នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៥៧ សាធារណរដ្ឋសង្គមនិយមសហភាពសូវៀត បានជួយកសាងមន្ទីរពេទ្យដ៏ធំជាងគេមួយនៅតំបន់អាស៊ីអាគ្នេយ៍ ឱ្យប្រទេសកម្ពុជា គឺមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត (ពេទ្យរុស្ស៊ី) មានគ្រែសម្រាប់អ្នកជំងឺចំនួន៥០០គ្រែ និងបំពាក់

ឧបករណ៍បរិក្ខារគ្រប់បែបយ៉ាងទាំងស្រុង។

ប្រទេសប៉ូឡូញ បានជួយឧបត្ថម្ភគ្រឿងបរិក្ខារវះកាត់ទំនើបដល់មន្ទីរពេទ្យខេត្តកំពង់ចាម ខណៈប្រទេសឆេកូស្លូវ៉ាគី បានផ្តល់រោងចក្រអគ្គិសនីមួយ នៅចាក់អង្រែលើ។

នៅក្នុងខែធ្នូ ឆ្នាំ១៩៥៧ សហរដ្ឋអាមេរិក ផ្តល់រថយន្តហ្ស៊ីប ចំនួន១០គ្រឿង និងរថយន្តសម្រាប់បញ្ជាំងភាពយន្តចល័តមួយគ្រឿងទៀត។ បន្ទាប់មកទៀត សហភាពសូវៀតក៏បានផ្តល់ឧទ្ធម្ភាគចក្រ មួយគ្រឿងដែរ។

ដោយសារមានតំណាងរាស្ត្ររបស់ចលនាសង្គមរាស្ត្រនិយម មួយចំនួន គប់គិតគ្នាប្រព្រឹត្តអំពើពុករលួយ ក្នុងឆ្នាំ១៩៥៨ សម្តេចសីហនុ បានប្រកាសរំលាយសភា កើតចេញពីការបោះឆ្នោតកាលពីខែកញ្ញា ឆ្នាំ១៩៥៥នោះចោល ហើយរៀបចំឱ្យមានការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រម្តងទៀត ដោយមានការកាត់បន្ថយចំនួនអាសនៈនៅក្នុងសភាចំនួន៩១អាសនៈ មកនៅត្រឹម៦១អាសនៈប៉ុណ្ណោះ។ បេក្ខជនតំណាងរាស្ត្ររបស់ចលនាសង្គមរាស្ត្រនិយមទាំងអស់ សម្តេចសីហនុ ជាអ្នកតែងតាំង។ ពេលបោះឆ្នោតក្នុងឆ្នាំ១៩៥៨ នោះនៅសល់តែគណបក្សប្រជាជនមួយប៉ុណ្ណោះ ដែលហ៊ានចូលប្រកួតប្រជែងជាមួយចលនាសង្គមរាស្ត្រនិយម បន្តទៀត។

ចំណែកគណបក្សប្រជាធិបតេយ្យ ដ៏មានប្រជាប្រិយភាពបំផុត នៅក្នុងការបោះឆ្នោតតាំងពីឆ្នាំ១៩៤៧ តែនៅក្នុងការបោះឆ្នោតឆ្នាំ១៩៥៥ ត្រូវបរាជ័យ សូម្បីតែ១អាសនៈនៅក្នុងសភា ក៏មិនទទួលបានផងនោះ ត្រូវរលាយបាត់ស្រមោលពីឆាកនយោបាយ។

ពេលនោះ គណបក្សប្រជាជន បានដាក់បេក្ខជនរបស់ខ្លួននៅទូទាំងប្រទេស ចំនួនតែ៥នាក់ប៉ុណ្ណោះ គឺនៅក្នុងក្រុងភ្នំពេញម្នាក់, នៅខេត្តបាត់ដំបង ម្នាក់, នៅខេត្តកំពត ម្នាក់, នៅខេត្តស្វាយរៀង ម្នាក់ និងនៅខេត្តតាកែវ ម្នាក់ ហើយបេក្ខជនទាំង៥នាក់នេះ មិនហ៊ានបើកវេទិកាឃោសនារកសំឡេងឆ្នោត ដូចបេក្ខជនរបស់ចលនាសង្គមរាស្ត្រនិយម ឡើយ។

លទ្ធផលចុងក្រោយ នៅមណ្ឌលក្រុងភ្នំពេញ កែវ មាស មេដឹកនាំគណបក្សប្រជាជនដ៏មានប្រជាប្រិយភាពឈរឈ្មោះជាបេក្ខជននោះ ទទួលបានសំឡេងគាំទ្រតែ៣៦៩ សំឡេង


កែវ មាស

ប៉ុណ្ណោះ។ កែវ មាស មេដឹកនាំគណបក្សប្រជាជន ធ្វើនយោបាយស្របច្បាប់ តែមានតួនាទីសម្ងាត់ជាមេដឹកនាំគណៈកម្មាធិការបក្សប្រជាជនបដិវត្តន៍ខ្មែរ នៅទីក្រុងភ្នំពេញ ជំនួសមុខឱ្យទូ សាមុត ដែលបានគេចខ្លួនទៅរស់នៅក្នុងជំរំតស៊ូក្នុងព្រៃមួយ ។

បើទោះបី កែវ មាស មិនបានជាប់ឆ្នោតជាតំណាងរាស្ត្រ នៅពេលនោះ ក៏ដោយ ក៏គាត់ត្រូវប្រឈមនឹងគ្រោះថ្នាក់ពីការតាមព្យាបាទ ពីសំណាក់មេដឹកនាំចលនាសង្គមរាស្ត្រនិយមដែរ។ គាត់បានចាកចេញពីទីក្រុងភ្នំពេញ ទៅរស់នៅក្នុងជំរំតស៊ូក្នុងព្រៃ នៅខេត្ត ស្វាយរៀង ក្បែរព្រំប្រទល់ប្រទេសវៀតណាម។ បន្ទាប់មក គាត់ក៏សម្រេចចិត្តចាកចេញពីមាតុភូមិ ទៅរស់នៅទីក្រុងហាណូយ ជាមួយសឹង ង៉ុកមិញ និងអតីតអ្នកតស៊ូដែលស្និទ្ធនឹងពួកវៀតមិញ ប្រមាណជាង១០០០នាក់ ដែលបានចាកចេញពីមាតុប្រទេសកាលពីឆ្នាំ ១៩៥៤ នោះ តែម្តងទៅ។ ដូច្នេះ សាឡុត ស ក៏កាន់តែមានតួនាទីសំខាន់ក្នុងការដឹកនាំគណៈកម្មាធិការបក្សទីក្រុងភ្នំពេញ បន្តពី កែវ មាស ចាប់ពីពេលនោះមក។

លទ្ធផលនៃការបោះឆ្នោតថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៥៨នោះ ចលនាសង្គមរាស្ត្រនិយមឈ្នះឆ្នោតទទួលបានអាសនៈ៦១លើ៦១ នៅក្នុងរដ្ឋសភា។ ការបោះឆ្នោតនេះ គឺជាប្រវត្តិសាស្ត្រដំបូងបង្អស់ ដែលស្ត្រីម្នាក់ ឈ្មោះពុង ប៉េងចេង នាមដើម ស៊ីវ អេងតុង បានជាប់ឆ្នោតជាតំណាងរាស្ត្រ ។

បន្ទាប់មក ព្រះមហាក្សត្រនរោត្តម សុរាម្រិត បានចេញព្រះរាជក្រឹត្យមួយ ចុះថ្ងៃទី

២៤ ខែមេសា ឆ្នាំ១៩៥៨ តែងតាំងរាជរដ្ឋាភិបាលថ្មីមួយ ដោយមាន ស៊ឹម វ៉ា ជានាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារប្រទេស និងជារដ្ឋមន្ត្រីទទួលបន្ទុកបោសសម្អាតទូទៅ, ញឹក ជូឡុង ជាឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកសេដ្ឋកិច្ច និងផលិតផល រដ្ឋមន្ត្រីផែនការសាធារណការ ប្រៃយសណីយ៍ ទូរគមនាគមន៍ និងទេសចរណ៍, ផូ ព្រឿង រដ្ឋមន្ត្រីការងារ សង្គមកិច្ច និងទេសចរណ៍, ជា ជិនកុក រដ្ឋមន្ត្រីប្រតិភូអមទីស្តីការនាយករដ្ឋមន្ត្រី ទទួលបន្ទុកកំណែទម្រង់, ទូច គីម រដ្ឋមន្ត្រីហិរញ្ញវត្ថុ, ទ្រឿង កាង រដ្ឋមន្ត្រីការបរទេស, អ៊ុំ សម រដ្ឋមន្ត្រីយុត្តិធម៌, ទឹម ងួន រដ្ឋមន្ត្រីមហាផ្ទៃ និងការពារលើផ្ទៃប្រទេស, ញឹម សុផល រដ្ឋលេខាធិការសុខាភិបាល, ជួប ហែល រដ្ឋលេខាធិការកសិកម្ម, ផ្លែក ឆាត រដ្ឋលេខាធិការផែនការ សាធារណការ និងទេសចរណ៍, ទឹម ដុង រដ្ឋលេខាធិការឃោសនាការ, ចៅ សេង រដ្ឋលេខាធិការសិក្សាធិការជាតិ ,អ៊ឹង ហុងសាធ ជារដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ហ៊ូ យន់ រដ្ឋលេខាធិការឧស្សាហកម្ម និងពាណិជ្ជកម្ម និងហ៊ីង កន្ធែល រដ្ឋលេខាធិការការពារប្រទេស។



សហជីវិនី ពុង ប៉េងចេង

ក្នុងគណៈរដ្ឋមន្ត្រីនេះ គេសង្កេតឃើញនិស្សិតមាននិន្នាការឆ្វេងនិយម២នាក់ ទើបមកពីប្រទេសបារាំង គឺ ហ៊ូ យន់ បានចេញមុខជាលើកដំបូង ក្នុងតំណែងជារដ្ឋលេខាធិការឧស្សាហកម្ម និងពាណិជ្ជកម្ម និងចៅ សេង រដ្ឋលេខាធិការសិក្សាធិការជាតិ ។

នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ១៩៥៨ ង៉ូ ឌិញយៀម មេដឹកនាំផ្តាច់ការរបស់ប្រទេសវៀតណាមខាងត្បូង បានបញ្ជាឱ្យកងទ័ពមួយកងវរសេនាធំ ចូលលុកលុយឈ្លានពានមកលើបូរណភាពទឹកដីខ្មែរ នៅក្នុងខេត្តក្រចេះ ដោយបានចូលមកក្នុងជម្រៅ១៥គីឡូម៉ែត្រ ពី

ព្រំដែន ហើយបានឈរជើងនៅទីនោះ អស់រយៈពេលជាង២សប្តាហ៍ ទើបដកថយវិញ។

ក្រោយពី ស៊ឹម វ៉ា ជានាយករដ្ឋមន្ត្រី ដឹកនាំរាជរដ្ឋាភិបាល បាន២សប្តាហ៍ ព្រះមហាក្សត្រនរោត្តម សុរាម្រិត បានចេញព្រះរាជក្រឹត្យលេខ ៣១៣ ន.ស ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៥៨ ធ្វើការកែសម្រួលផ្លាស់ប្តូរសមាសភាពគណៈរដ្ឋមន្ត្រីនេះមួយចំនួន ដោយមាន ស៊ឹម វ៉ា ជានាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារប្រទេស និងជារដ្ឋមន្ត្រីបោសសម្អាតដដែល, ញឹក ជូឡុង ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកសេដ្ឋកិច្ច និងផលិតផល រដ្ឋមន្ត្រីផែនការ សាធារណការ ប្រៃសណីយ៍ ទូរគមនាគមន៍ និងទេសចរណ៍, ផូ ព្រឿង ជា រដ្ឋមន្ត្រីការងារ សង្គមកិច្ច ធម្មការ និងទំនាក់ទំនងសភា, ជា ជិនកុក ជារដ្ឋមន្ត្រីប្រតិភូអមទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកកំណែទម្រង់, ទូច គីម ជារដ្ឋមន្ត្រីហិរញ្ញវត្ថុ, ទ្រឿង កាង ជារដ្ឋមន្ត្រីការបរទេស, អ៊ុំ សម ជារដ្ឋមន្ត្រីយុត្តិធម៌, ទឹម ងួន ជារដ្ឋមន្ត្រីមហាផ្ទៃ និងការពារលើផ្ទៃប្រទេស, ជួប ហែល ជារដ្ឋលេខាធិការកសិកម្ម, អ៊ឹង ហុងសាធ ជារដ្ឋលេខាធិការប្រៃសណីយ៍ និងទូរគមនាគមន៍, ហ៊ូ យន់ ជារដ្ឋលេខាធិការ ឧស្សាហកម្ម និងពាណិជ្ជកម្ម, ហ៊ីងគន្ធែល រដ្ឋលេខាធិការក្រសួងការពារជាតិ, ហ៊ូ នឹម អនុរដ្ឋលេខាធិការអមទីស្តីការគណៈរដ្ឋមន្ត្រី, ឡុង បូរ៉េត ជាអនុរដ្ឋលេខាធិការការងារ និងសង្គមកិច្ច។ អ៊ី ទុយ ជាអនុរដ្ឋលេខាធិការមហាផ្ទៃ និងការពារលើផ្ទៃប្រទេស និងយូ គឹមយាន ជាអនុរដ្ឋលេខាធិការសាធារណសុខាភិបាល។

នៅក្នុងគណៈរដ្ឋមន្ត្រីនេះ គេសង្កេតឃើញអតីតនិស្សិតមាននិន្នាការឆ្វេងនិយមម្នាក់ទៀត ទើបមកពីប្រទេសបារាំង ដែរ គឺ ហ៊ូ នឹម ចាប់ផ្តើមចេញមុខ នៅក្នុងសមាសភាពគណៈរដ្ឋមន្ត្រីនេះ ក្នុងតួនាទីជាអនុរដ្ឋលេខាធិការអមទីស្តីការគណៈរដ្ឋមន្ត្រី។ ប៉ុន្តែគណៈ រដ្ឋមន្ត្រីនេះ ដំណើរការបានប្រហែល៤ខែ នៅដើមខែកក្កដា ឆ្នាំ១៩៥៨ នាយករដ្ឋមន្ត្រី ស៊ឹម វ៉ា ក៏បានស្នើសុំលាលែងពីតំណែង ។

# ១០៥
# សម្តេចសីហនុ យាងទៅបំពេញទស្សនកិច្ចនៅអាមេរិក



**សម្តេចសីហនុ និងប្រធានាធិបតី ដ្វៃត៍ ឌី. អៃសិនហាវើរ**

នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៥៨ សម្តេចសីហនុ យល់ព្រមតាមការសុំលាលែងពីតំណែង របស់នាយករដ្ឋមន្ត្រី ស៊ឹម វ៉ា ហើយព្រះអង្គក៏បានរៀបចំសមាសភាពរាជរដ្ឋាភិបាលថ្មី មួយទៀត ដោយមានព្រះអង្គផ្ទាល់ ជានាយករដ្ឋមន្ត្រី, សឺន សាន ជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេស, ជា ជិនកុក ជាទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីប្រតិភូទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកការសម្របសម្រួល និងកំណែទម្រង់, ផូ ព្រឿង ជាទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីមហាផ្ទៃ ធម្មការ និងទំនាក់ទំនងសភា, ម៉ៅ សាយ ជារដ្ឋមន្ត្រីឃោសនាការ និងផែនការ, ទូច គីម ជា រដ្ឋមន្ត្រីសេដ្ឋកិច្ច ហិរញ្ញវត្ថុ, ទឹម ងួន ជារដ្ឋមន្ត្រីការពារជាតិ ការពារលើផ្ទៃប្រទេស និងសន្តិសុខ, អ៊ុំ សម ជារដ្ឋមន្ត្រីកសិកម្ម, ផ្លែក ឆាត ជារដ្ឋមន្ត្រីសាធារណការ និងទូរគមនា



**សម្តេចសីហនុ ពេលយាងទៅសហរដ្ឋអាមេរិក**

គមន៍, លឹម គ្រី ជារដ្ឋមន្ត្រីយុត្តិធម៌ និងបោសសម្អាតទូទៅ, ញឹម សុផល ជារដ្ឋលេខាធិការពាណិជ្ជ កម្ម និងឧស្សាហកម្ម, ទឹម ដុង ជារដ្ឋលេខាធិការឃោសនាការ និងទេសចរណ៍, ចៅ សេង ជា រដ្ឋលេខាធិការសិក្សាធិការជាតិ, យឹម ឌិត ជារដ្ឋលេខាធិការសង្គមកិច្ច និងការងារ, ហ៊ូ យន់ រដ្ឋលេខាធិការផែនការ, អ៊ឹង ហុងសាធ ជារដ្ឋលេខាធិការសាធារណសុខាភិបាល, យូ គឹមយាន ជាអនុរដ្ឋលេខាធិការសាធារណសុខាភិបាល, ហ៊ូ នឹម ជាអនុរដ្ឋលេខាធិការមហាផ្ទៃ ទទួលបន្ទុកទំនាក់ទំនងសភា, អ៊ុច វ៉ែន អនុរដ្ឋលេខាធិការធម្មការ និង ឌុក ប៉ាស៊ី ជាអនុរដ្ឋលេខាធិការយុត្តិធម៌ បោសសម្អាត និងកំណែទម្រង់។

នៅក្នុងសមាសភាពរាជរដ្ឋាភិបាលនេះ ហ៊ូ យន់ ត្រូវបានប្តូរតំណែងពីរដ្ឋលេខាធិការឧស្សាហកម្ម និងពាណិជ្ជកម្ម មកជារដ្ឋលេខាធិការផែនការ វិញ ហើយ ហ៊ូ នឹម ក៏បានប្តូរតំណែងពីអនុរដ្ឋលេខាធិការអមទីស្តីការគណៈរដ្ឋមន្ត្រី ទៅកាន់តំណែងអនុរដ្ឋលេខាធិការមហាផ្ទៃ ទទួលបន្ទុកទំនាក់ទំនងសភា ផងដែរ។

ក្រោយពីបញ្ចប់ការសិក្សា នៅប្រទេសបារាំង ហ៊ូ នឹម វិលត្រលប់មកមាតុប្រទេស

វិញក្នុងឆ្នាំ១៩៥៧ បានចូលបម្រើការងារជាមន្ត្រីគយ ក្នុងការិយាល័យច្បាប់ អស់រយៈពេល៣ខែ ទើប ផ្លែក ភឹន នាំគាត់ឱ្យទៅជួប ម៉ៅ សាយ ពេលនោះ កំពុងកាន់តំណែងជារដ្ឋមន្ត្រីអប់រំ យុវជន និងកីឡា ហើយម៉ៅ សាយ ក៏ឱ្យ ហ៊ូ នឹម ជួយសរសេរកាសែតប្រជាសេរី ដោយមាន ស៊ឹម វ៉ា នាយករដ្ឋមន្ត្រី ជាអ្នកគ្រប់គ្រងកាសែតនោះ។

ជាមួយគ្នានោះ ម៉ៅ សាយ ក៏បានឱ្យ ហ៊ូ នឹម ជួយសរសេរកាសែតជាភាសាបារាំង រ៉េអាលីតេ កាំបូតហ្សេន ( Réalité Cambodgienne )មួយទៀតដែរ។

ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៥៨ សម្តេចសីហនុ ចាប់ផ្តើមភ្ជាប់ទំនាក់ទំនងការទូតជាមួយសាធារណរដ្ឋប្រជាមានិតចិន កាន់តែជិតស្និទ្ធឡើងៗ។

នៅថ្ងៃទី១៦ ខែសីហា កងទ័ពថៃ បង្ករឿងនៅប្រាសាទព្រះវិហារ កាន់តែខ្លាំងឡើងៗ ទោះបីតំណាងរាជរដ្ឋាភិបាលកម្ពុជា បានធ្វើដំណើរទៅទីក្រុងបាងកក ចរចាជាមួយរាជរដ្ឋាភិបាលថៃ ស្តីពីបញ្ហាប្រាសាទព្រះវិហារ ចាប់ពីថ្ងៃទី១៨ ខែសីហា រហូតដល់ថ្ងៃទី០៣ ខែកញ្ញា ក៏ដោយ ក៏នៅតែគ្មានដំណោះស្រាយ ដោយសារតែភាគីថៃ មិនព្រមទទួលស្គាល់ផែនទី ជាឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងបារាំង-សៀម ឆ្នាំ១៩០៧។

នៅថ្ងៃទី២៨ ខែវិច្ឆិកា សម្តេចសីហនុ ក៏សម្រេចប្រកាសផ្តាច់ទំនាក់ទំនងការទូតជាមួយប្រទេសថៃ តែម្តងទៅ។

នៅក្នុងខែសីហា ឆ្នាំ១៩៥៨ នង សួន (ជ័យ សួន) មេដឹកនាំគណបក្សប្រជាជន និងជាចាងហ្វាងកាសែតប្រជាជន ត្រូវបានគេជ្រើសរើសជាសមាជិកគណៈប្រតិភូអ្នកកាសែតកម្ពុជា ឱ្យទៅធ្វើទស្សនកិច្ច នៅសាធារណរដ្ឋប្រជាមានិតចិន, សាធារណរដ្ឋប្រជាធិបតេយ្យកូរ៉េ និងសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម រយៈពេល១ខែ។

ពេលគណៈប្រតិភូអ្នកកាសែតកម្ពុជា ជិះយន្តហោះចេញពីក្រុងភ្នំពេញ ទៅចុះសំចតនៅទីក្រុងហាណូយ នង សួន ក៏មានឱកាស បានជួប សឺង ង៉ុកមិញ សំណេះសំណាលគ្នាពីបញ្ហាធ្វើបដិវត្តន៍ និងបញ្ហាប្រទេសជាតិ ផងដែរ។

នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៥៨ តាមការយាងរបស់ប្រធានាធិបតី ដ្វៃត៍ ឌី. អៃសិនហាវ

វើរ ( Dwight D. Eisenhower ) សម្តេចសីហនុ និងមហេសី អ្នកម្នាងម៉ូនិក យាងទៅបំពេញព្រះរាជទស្សនកិច្ច នៅសហរដ្ឋអាមេរិក។

ព្រះអង្គត្រូវបានស្វាគមន៍ ដោយការបាញ់កាំភ្លើងធំ ចំនួន១៩ណាត់ និងមានការរៀបចំពិធីលៀងភោជនាហារថ្ងៃត្រង់ នៅក្នុងសេតវិមាន ដោយប្រធានាធិបតីសហរដ្ឋអាមេរិក បានថ្លែងសុន្ទរកថា កោតសរសើរចំពោះវីរភាពរបស់ព្រះអង្គ និងមានការប្រគំតន្ត្រីរបស់ក្រុមអង្គរក្សប្រធានាធិបតី ក្នុងឯកសណ្ឋានសមោសរថ្វាយជាព្រះកិត្តិយសទៀតផង។

ប្រធានាធិបតីអាមេរិក បានទូលសម្តេចសីហនុ ថា គាត់កាន់តែមានមនោសញ្ចេតនាមកលើព្រះអង្គ ថែមទៀត ដោយសារ ព្រះអង្គប្រសូតនៅក្នុងឆ្នាំ១៩២២ ដូចកូនរបស់គាត់ដែរ។

ក្នុងព្រះរាជទស្សនកិច្ចនៅសហរដ្ឋអាមេរិកនោះ ព្រះអង្គក៏បានយាងទៅទស្សនាទីក្រុងស៊ីកាហ្គោ ផងដែរ។ នៅក្នុងពិធីលៀងភោជនាហារថ្ងៃត្រង់ រៀបចំដោយអភិបាល ក្រុងនោះមិនដឹងជាចៅហ្វាយក្រុងស៊ីកាហ្គោនោះ មានចេតនាយ៉ាងណាទេ បានជាគាត់ឱ្យគេដាក់កៅអីមួយទុកសម្រាប់អ្នកកាសែតម្នាក់ ឱ្យមកអង្គុយក្បែរមហេសីព្រះអង្គ(អ្នកម្នាង ម៉ូនិក) ទៅវិញ ហើយអ្នកសែតរូបនោះ បានសម្តែងនូវការកោតសរសើរចំពោះរូបសម្រស់របស់មហេសីព្រះអង្គខ្ពស់កប់ពពកតែម្តង។

ក្រោយពីថ្លែងលើកសរសើរពីរូបសម្រស់របស់អ្នកម្នាងម៉ូនិក មក ស្រាប់តែ អ្នកកាសែតរូបនោះ ងាកមកសួរព្រះអង្គថា តើជាការពិតទេ ដែលថាព្រះអង្គមានមហេសី២អង្គ ក្នុងនោះ មានមួយអង្គកំពុងនៅឯទីក្រុងភ្នំពេញ និងមួយអង្គទៀត មានវ័យក្មេងស្រស់ស្អាត កំពុងមានវត្តមាននៅទីនេះដែរ ?។

សំណួរនេះមិនថាតែសម្តេចសីហនុ ទេ សូម្បីមហេសីព្រះអង្គ និងចៅហ្វាយក្រុងស៊ីកាហ្គោ ព្រមទាំងមន្ត្រីអាមេរិក ទាំងអស់ចូលរួមក្នុងពិធីនោះ ក៏មានការភ្ញាក់ផ្អើល និងស្រឡាំងកាំងគ្រប់ៗគ្នាដែរ។ តែព្រះអង្គមិនឆ្លើយតបនឹងសំណួរខាងលើនេះទេ ព្រះអង្គបែរជាមានបន្ទូលទៅកាន់ចៅហ្វាយក្រុងស៊ីកាហ្គោ អង្គុយនៅក្បែរព្រះអង្គថា៖ "តើលោក

អាចប្រាប់ទៅអ្នកកាសែតនោះ កុំឱ្យសួរសំណួរណា លក្ខណៈកកូរកកាយដល់ជីវិតឯកជនរបស់ខ្ញុំ បានឬទេ?"

ចៅហ្វាយក្រុងស៊ីកាហ្គោ មិនទាន់ឆ្លើយតបនឹងសំណូមពររបស់ព្រះអង្គថាយ៉ាងដូចម្ដេចផង ស្រាប់តែអ្នកកាសែតនោះ ក៏បានទូលព្រះអង្គភ្លាមថា មានតែបញ្ហាជីវិតឯកជនរបស់ព្រះអង្គប៉ុណ្ណោះ ធ្វើឱ្យសាធារណមតិអន្តរជាតិ មានការចាប់អារម្មណ៍ខ្លាំងបំផុតនោះ។

ដោយមិនអាចគេចផុតពីសំណួរនេះបាន ព្រះអង្គក៏សម្រេចព្រះទ័យ ធ្វើការបកស្រាយខ្លះៗ ជុំវិញបញ្ហាមហេសីពីរអង្គនោះ ឱ្យក្រុមអ្នកកាសែត បានដឹងតែម្ដងទៅ។

ស្អែកឡើង នៅទីក្រុងស៊ីកាហ្គោ កាសែតទាំងឡាយបាននាំគ្នាចេញផ្សាយនៅទំព័រមុខ ដោយដាក់ចំណងជើងធំៗថា "សម្ដេចសីហនុ សារភាពថា ព្រះអង្គមានមហេសីពីរអង្គ" និងសរសេរបរិយាយយ៉ាងវែង ពីជីវិតឯកជនរបស់ព្រះអង្គ ទៅតាមទេពកោសល្យអ្នកនិពន្ធរបស់កាសែតនីមួយៗ។

ការពិតអ្នកកាសែតអាមេរិកទាំងនោះ ប្រហែលជាមិនបានដឹងថា តាំងពីឡើងសោយ-រាជសម្បត្តិ ឆ្នាំ១៩៤១មក រហូតមកដល់ឆ្នាំ១៩៥៨នោះ សម្ដេចសីហនុ មានមហេសីដល់ទៅ ៦អង្គនោះទេ មើលទៅ ទើបបានជាសួរថា ព្រះអង្គមានមហេសី២ យ៉ាងដូច្នេះ?។

ក្រោយពីបំពេញទស្សនកិច្ច នៅក្រុងស៊ីកាហ្គោ សម្ដេចសីហនុ ក៏យាងទៅទស្សនាទីក្រុងសាន់ហ្វ្រាន់ស៊ីស្កូ បន្តទៀត។ នៅទីនោះ ព្រះអង្គបានធ្វើសន្និសីទកាសែតមួយ ដោយមានបន្ទូលជាភាសាអង់គ្លេសអំពីសភាពការណ៍របស់ប្រទេសកម្ពុជា ក្នុងពេលបច្ចុប្បន្ន ហើយត្រូវបានអ្នកកាសែតនាំគ្នាអបអរសាទរយ៉ាងខ្លាំង ដោយគ្មានអ្នកកាសែតណាម្នាក់សួរសំណួររុកកួនដល់ជីវិតឯកជនរបស់ព្រះអង្គ ដូចនៅទីក្រុងស៊ីកាហ្គោ នោះទៀតឡើយ។

បន្ទាប់មក ព្រះអង្គក៏បានយាងទៅទស្សនាស្ទូឌីយោរបស់ផលិតកម្មភាពយន្តហូលីវូដ និងបានភ្ជាប់ចំណងមិត្តភាពជាមួយសិល្បករក្រមាច់ក្រមើមដ៏ល្បីល្បាញម្នាក់ ឈ្មោះប៊ិមហ៊ិពផងដែរ។

# ១០៦
# សម្តេចសីហនុ ផ្ញើមេអណ្តើកឱ្យចិន អាមេរិកថា ព្រះអង្គមិនដឹងអ្វីបន្តិចសោះ



**រដ្ឋមន្ត្រីការបរទេស ហ្វូសស្ទ័រ ឌុលេស និងប្រធានាធិបតី អែសិនហាវថើរ**
(រូបថត politico)

បន្ទាប់មកទៀត ពេលយាងតាមយន្តហោះពីក្រុងញូវយ៉ក ទៅក្រុងវ៉ាស៊ីនតោន ព្រះអង្គបានជួបប្រទះរឿងគួរឱ្យហួសចិត្តមួយ ដោយនៅពេលយន្តហោះកំពុងហោះហើរនៅលើអាកាស ស្រាប់តែមេបញ្ជាការអាកាសយានិក បានចាកចេញពីកៅអីរបស់ខ្លួន រួចដើរតម្រង់មករកព្រះអង្គ ហើយនិយាយថា ភរិយារបស់លោកពិតជាស្អាតណាស់! ខ្ញុំចង់ជជែកគ្នាលេងជាមួយនាងបន្តិច ដោយមិនចង់ឱ្យមាននរណារំខាន។ ដូច្នេះ សូមលោកទៅអង្គុយនៅកៅអីទំនេរ នៅឆ្ងាយពីទីនេះបន្តិច ...។

នេះចាត់ទុកដូចជាការប្រមាថដ៏ព្រហើនមួយរបស់មេបញ្ជាការអាកាសយានិករូបនោះមកលើព្រះអង្គយ៉ាងដូច្នេះដែរ តែព្រះអង្គនៅតែធ្វើព្រះភក្ត្រញញឹម ដោយមិនហ៊ានបញ្ចេញកំហឹងណាមួយតបទៅមេបញ្ជាការអាកាសយានិក ដោយសារព្រះអង្គឈ្វេងយល់ថា មេបញ្ជា

ការនោះ ជាអ្នកកំណត់ជោគវាសនាព្រះជន្មរបស់ព្រះអង្គ នៅពេលកំពុងហោះហើរ ដូច្នេះ គ្មានអ្វី ក្រៅតែពីយល់ព្រមយាងចេញពីកៅអីរបស់ព្រះអង្គ ទៅអង្គុយនៅកៅអីទំនេរមួយ នៅឆ្ងាយបន្តិច ដើម្បីទុកឱកាសឱ្យមេបញ្ជាការបើកបរយន្តហោះដ៏ព្រហើននោះ មកអង្គុយ សាសងក្បែរមហេសីរបស់ព្រះអង្គ តាមបំណងប្រាថ្នារបស់គេ។

ប្រហែល១០នាទីក្រោយមក ទើបមេបញ្ជាការអាកាសយានិកនោះ ក្រោកចេញដើរ មករកព្រះអង្គ ហើយទូលព្រះអង្គថា៖ "នេះជាការហោះហើរ ដ៏សែនមនោរម្យបំផុត ក្នុង ឆាកជីវិតរបស់ខ្ញុំ។ ភរិយារបស់លោក ពិតជាស្រស់ស្អាតមែនទែន។ ឥឡូវនេះ ខ្ញុំត្រូវទៅ កន្លែងបើកបររបស់ខ្ញុំវិញហើយ សូមលោកអញ្ជើញទៅអង្គុយក្បែរភរិយារបស់លោកវិញ ចុះ..."។

អ្នកម្នាងម៉ូនិក ជាមហេសី បានទូលព្រះអង្គថា មេបញ្ជាការអាកាសយានិកនោះ ជា មនុស្សប្រកបដោយសមានចិត្តល្អទេ គ្រាន់តែជាមនុស្សរបិលរប៉ូចប៉ុណ្ណោះ។

សម្តេចសីហនុ ក៏ឈ្វេងយល់ថា មហេសីរបស់ព្រះអង្គ មិនបានចាប់អារម្មណ៍ចំពោះ កាយវិការចែចង់ដោយត្រង់ៗ និងរបិលរប៉ូចរបស់មេបញ្ជាការកំហូចនោះដែរ។

នៅលើយន្តហោះនោះ ក៏មានតារាភាពយន្តដ៏ល្បីម្នាក់ ឈ្មោះ ស្ទីវ៉ាត់ ហ្គ្រានហ្សឺរ ជា តួឯកក្នុងរឿង "អ្នកទោសនៃហ្សិនដា" រួមដំណើរជាមួយផងដែរ។

តារាភាពយន្តរូបនេះ ប្រហែលជាបានស្គាល់ព្រះអង្គ និងមហេសី តាមរយៈការចុះ ផ្សាយរបស់កាសែតអាមេរិកនានា ពីរឿងព្រះអង្គមានមហេសីពីរអង្គ កាលពីពេលថ្មីៗនេះ គាត់ បានឱនក្បាលសម្តែងការគួរសមចំពោះព្រះអង្គដោយសុភាពរាបសា។

ពេលមកដល់ទីក្រុងញូវយ៉កវិញ ហង់រី កាបូត៍ ឡូដ (Henry Cabot Lodge) ឯកអគ្គ រដ្ឋទូតសហរដ្ឋអាមេរិក ប្រចាំអង្គការសហប្រជាជាតិ បានរៀបចំពិធីលៀងភោជនាហារមួយ ថ្វាយជាព្រះកិត្តិយសចំពោះព្រះអង្គ និងមហេសី ដោយមានតារាភាពយន្ត អ៊ីរ៉ែន ឌូន តួឯកស្រី ក្នុងរឿង "នាង និងគេ" អង្គុយក្បែរព្រះអង្គ ផងដែរ។

នៅក្នុងឱកាសគង់នៅសហរដ្ឋអាមេរិកនោះ សម្តេចសីហនុ សង្កេតឃើញថា ប្រជា-



**ឯកអគ្គរដ្ឋទូតហាច់រី ភាបុត៍ ឡជ**
(រូបថតstate.com)

នាធិបតី ដ្វៃត៍ ឌី.អៃសិនហាវវើរ (Dwight D.Eisenhower) គឺជាមនុស្សគួរឱ្យគោរព និងរាប់អានបំផុត។ ប៉ុន្តែ ចំពោះហ្វូស្ទ័រ ឌុល្លេស (Foster Dulles) រដ្ឋមន្ត្រីការបរទេសជាមនុស្សមុខក្រញូវ និងប្រកាន់នយោបាយតឹងរ៉ឹង គឺគាត់ប្រឆាំងដាច់ខាតចំពោះលទ្ធិកុម្មុយ-និស្ត និងនយោបាយអព្យាក្រឹតរបស់ព្រះអង្គ ពិសេស ប្រឆាំងដាច់ខាតចំពោះសាធារណរដ្ឋប្រជាមានិតចិន ។

តែទោះបីយ៉ាងនេះក៏ដោយ ក៏សម្តេចសីហនុ បានឆ្លៀតឱកាសសាកល្បង មានបន្ទូលបញ្ចុះបញ្ចូលឱ្យរដ្ឋមន្ត្រីការបរទេសអាមេរិករូបនេះ ធ្វើយ៉ាងណាឱ្យទំនាក់ទំនងការទូតរវាងសហរដ្ឋអាមេរិក និងសាធារណរដ្ឋប្រជាមានិតចិន ។

ហ្វូសស្ទ័រ ឌុល្លេស ចេះនិយាយភាសាបារាំងយ៉ាងស្ទាត់ជំនាញនោះ បានបង្កលក្ខណៈងាយស្រួលបំផុតក្នុងកិច្ចសន្ទនាគ្នា ជាមួយព្រះអង្គ។

ព្រះអង្គមានបន្ទូលប្រាប់ទៅ ហ្វូសស្ទ័រ ឌុល្លេស(Foster Dulles) ថា អ្វីដែល ជាងកាយជៀក(Chiang KaiShek) មេដឹកនាំចិន កោះតៃវ៉ាន់ មានអំណួតអួតអាងថា អាចដណ្តើមយកទឹកដីចិនដីគោក បានមកវិញនោះ ព្រះអង្គជឿជាក់ថា មិនអាចទៅរួចទេ ហើយក៏មិនអាចផ្តួលរំលំរបបម៉ៅនិយមបានដែរ។ នៅក្នុងបរិបទនេះ ដើម្បីផលប្រយោជន៍របស់ខ្លួន មានតែសហរដ្ឋអាមេរិក ធ្វើឱ្យទំនាក់ទំនងជាមួយសាធារណរដ្ឋប្រជាមានិតចិន មានភាពប្រក្រតីឡើងវិញ ឱ្យបានឆាប់រហ័ស តាមរយៈជួបចរចាជាមួយនាយករដ្ឋមន្ត្រីជូ អេន-

ឡាយ ជាមេដឹកនាំមានគំនិតជឿនលឿន និងគួរឱ្យទុកចិត្តនោះ។

តែនៅពេលឮសម្តេចសីហនុ មានបន្ទូលពីមេដឹកនាំចិនកុម្មុយនិស្ត ភ្លាម ធ្វើឱ្យកែវភ្នែករបស់រដ្ឋមន្ត្រីការបរទេសអាមេរិករូបនោះ ឡើងក្រហមច្រាល ហើយមិនគ្រាន់តែទាត់ចោលនូវសំណូមពររបស់ព្រះអង្គប៉ុណ្ណោះទេ គឺហ្វូសស្ទ័រ ឌុល្លេស ថែមទាំងចាត់ទុកព្រះអង្គថា ជាអ្នកនយោបាយគ្មានព័ត៌មានគ្រប់គ្រាន់ និងគ្មានដឹងអ្វីបន្តិចទាល់តែសោះ ទៀតផង។

សូមបញ្ជាក់ថា ពេលសម្តេចសីហនុ យាងទៅបំពេញព្រះរាជទស្សនកិច្ចនៅសហរដ្ឋអាមេរិកនោះ បញ្ហាជម្លោះកោះម៉ូយ និងកោះម៉ាត់ស៊ុយ រវាងចិនតៃវ៉ាន់(ចិនសេរី) និងសាធារណរដ្ឋប្រជាមានិតចិន(ចិនកុម្មុយនិស្ត)កាន់តែមានភាពតានតឹងឡើងៗ។

មុនជំនួបជាមួយរដ្ឋមន្ត្រីការបរទេសអាមេរិក នេះ មួយថ្ងៃ ឯកអគ្គរដ្ឋទូតសហភាពសូវៀត ប្រចាំនៅ ក្រុងវ៉ាស៊ីនតោន បានប្រគល់លិខិតរបស់នាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ មួយច្បាប់មកថ្វាយព្រះអង្គ។

ខ្លឹមសារយ៉ាងវែងក្នុងលិខិតនោះ ជូ អេនឡាយ បានរៀបរាប់ទូលសម្តេចសីហនុ យ៉ាងក្បោះក្បាយពីបញ្ហាជម្លោះកោះម៉ូយ និងកោះម៉ាត់ស៊ុយ និងវិធានការទាំងឡាយ ដែល ជូ អេនឡាយ ត្រូវដោះស្រាយផងដែរ។ ប៉ុន្តែដោយសារ ជូ អេនឡាយ ចាត់ទុកថា សម្តេចសីហនុ ជាមិត្តដ៏ជិតស្និទ្ធ និងមានប្រជាប្រិយបំផុតនោះ គាត់ក៏បានស្នើសុំឱ្យព្រះអង្គជួយធ្វើជាអ្នកផ្សះផ្សាបញ្ហាជម្លោះរវាងប្លុកទាំងពីរ(ប្លុកសេរី និងប្លុកកុម្មុយនិស្ត) កំពុងគំរាមកំហែងយ៉ាងធ្ងន់ក្រៃលែងដល់សន្តិភាពពិភពលោក។

យោងតាមលិខិតរបស់ជូ អេនឡាយ នេះហើយ ទើបសម្តេចសីហនុ សម្រេចព្រះទ័យថា ត្រូវតែសាកល្បងនិយាយពីការផ្សះផ្សាបញ្ហានេះ ជាមួយរដ្ឋមន្ត្រីការបរទេសរបស់អាមេរិក ហ្វូសស្ទ័រ ឌុល្លេស(Foster Dulles) ។

តែយ៉ាងណា នៅចុងបញ្ចប់នៃការជួបសន្ទនាគ្នា ដោយមានវត្តមាន នង គីមនី ឯកអគ្គរាជទូតខ្មែរប្រចាំសហរដ្ឋអាមេរិក ផងដែរ ហ្វូសស្ទ័រ ឌុល្លេស ក៏បានថ្លែងអំណរគុណចំពោះព្រះរាជបំណងល្អរបស់សម្តេចសីហនុ ចង់ផ្សះផ្សាអាមេរិក និងចិន ឱ្យមានទំនាក់ទំនង



**ប្រធានាធិបតីជាង កាយជៀក និងប្រធានាធិបតី អែសិនហាវឌើរ**

(រូបថត defence pk)

ល្អនឹងគ្នាឡើងវិញ នោះដែរ។

ហ្វូសស្ទ័រ ឌុល្លេស (Foster Dulles) បញ្ជាក់ប្រាប់សម្ដេចសីហនុ ថា គាត់យល់ស្រប ទាំងស្រុង ចំពោះអ្វីដែលព្រះអង្គបានលើកឡើងថា ជាង កាយជៀក មេដឹកនាំចិនតៃវ៉ាន់ មិនអាចដណ្ដើមទឹកដីចិនដីគោក និងផ្ដួលរំលំរបបម៉ៅនិយមបាន ទោះបីសហរដ្ឋអាមេរិក ផ្ដល់ជំនួយដ៏ច្រើនសន្ធឹកសន្ធាប់យ៉ាងណា ក៏ដោយ។ ប៉ុន្តែ គាត់នៅតែជឿជាក់ថា នៅថ្ងៃណាមួយ របបកុម្មុយនិស្តម៉ៅនិយម ត្រូវតែដួលរលំ ព្រោះជាក់ស្ដែង ប្រជាជនចិន កំពុងរស់នៅវេទនា ដោយសារការគាបសង្កត់របស់ពួកកុម្មុយនិស្ត ហើយនៅពេលការគាបសង្កត់នេះ ឈានដល់កម្រិតកំពូល គឺប្រជាជនចិន ស៊ូទ្រាំលែងបានទៀតហើយ។ ដូច្នេះការរំដោះប្រទេសចិន នឹងមិនធ្វើឡើងតាមរយៈជាង កាយជៀក មេដឹកនាំចិនកោះតៃវ៉ាន់ ដូចព្រះអង្គមានបន្ទូលនោះ ពិតមែន តែការរំដោះប្រទេសចិន នឹងធ្វើឡើង ដោយប្រជាជនចិនខ្លួនឯង ដែលឆ្អែតឆ្អន់ និងឈឺចាប់ជាមួយម៉ៅ សេទុង។

សហការីរបស់ហ្វូសស្ទ័រ ឌុល្លេស ទាំងប៉ុន្មានចូលរួមក្នុងជំនួបនោះ ក៏បានសម្ដែងការជឿជាក់ និងគាំទ្រពាល់ការលើកឡើងរបស់ថ្នាក់ដឹកនាំរបស់ពួកគេទាំងស្រុង ខណៈសម្ដេច

សីហនុ មិនបានសម្តែងអ្វីមួយ ក្រៅពីញញឹមព្រះភក្ត្រនោះឡើយ។

ចុងបញ្ចប់នៃព្រះរាជទស្សនកិច្ច នៅសហរដ្ឋអាមេរិក សម្តេចសីហនុ ក្នុងនាមប្រជារាស្ត្រខ្មែរទាំងមូល ព្រះអង្គបានយកព្រះពុទ្ធបដិមាដ៏ល្អអស្ចារ្យមួយអង្គ តាំងពីសតវត្សរ៍ទី១២មកម្ល៉េះ ជូនជាវត្ថុអនុស្សាវរីយ៍ចំពោះប្រជាពលរដ្ឋអាមេរិក ផងដែរ។

ព្រះពុទ្ធបដិមានេះ ត្រូវបានគេយកទៅដាក់តាំងនៅក្នុងសារមន្ទីរនៅក្រុងវ៉ាស៊ីនតោន។ រដ្ឋាភិបាល ក៏ដូចជាកាសែតនានារបស់សហរដ្ឋអាមេរិក ក៏បានសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះវត្ថុអនុស្សាវរីយ៍ដ៏ថ្លៃថ្លានេះដែរ។

# ១០៧
# ឡឹក សំអឿន ចេញពីក្រុងបាងកក
# ទៅរកការងារធ្វើនៅក្រុងវៀងចន្ទ



**ក្រុងបាងកក ឆ្នាំ១៩៥៧**

ដើមខែមីនា ឆ្នាំ១៩៥៧ សឺង ង៉ុកថាញ់ បានសម្រេចចិត្ត ធ្វើដំណើរចាកចេញពីប្រទេសថៃ ទៅរស់នៅឯស្រុកកំណើតរបស់គាត់នៅឯកម្ពុជាក្រោម វិញ។

តាមប្រភពមួយបានអះអាងថា ដំបូង សឺង ង៉ុកថាញ់ បានធ្វើដំណើរចាកចេញពីប្រទេសថៃ ចូលទៅប្រទេសភូមា ទាក់ទងជាមួយមន្ត្រីស្ថានទូតជប៉ុន ប្រចាំនៅទីក្រុងរ៉ង់ហ្គូន រួចហើយមន្ត្រីស្ថានទូតជប៉ុន បានជួយឱ្យគាត់ធ្វើដំណើរតាមយន្តហោះទៅស្នាក់នៅទីក្រុងតូក្យូមួយរយៈខ្លី ទើបបន្តដំណើរមកប្រទេសវៀតណាមខាងត្បូង(កម្ពុជាក្រោម) ជាស្រុកកំណើតរបស់គាត់។

បន្ទាប់មក គាត់បានលក់កេរអាករមួយចំនួន យកទៅធ្វើជាដើមទុន និងនាំសហការី

៥នាក់ទៅរស់នៅជាមួយ នៅភូមិធំ ស្រុកឡុកនិញ ខេត្តវិញឡុង ដើម្បីប្រកបមុខរបរកាប់ធ្ការព្រៃធ្វើចម្ការ ដាំចេកល្ហុងម្នាស់ស្វាយ និងចិញ្ចឹមសត្វ ដូចពលរដ្ឋភាគតិចរស់នៅវៀតណាមខាងត្បូង ផ្សេងៗទៀតដែរ។ តែគាត់មិនភ្លេចតាមដានសភាពការណ៍នយោបាយស្រុកទេស និងជួយដោះស្រាយបញ្ហាទំនាស់ផ្សេងៗរវាងបងប្អូនខ្មែរកម្ពុជាក្រោម ជាមួយរដ្ឋការយួនខាងត្បូង ផងដែរ។

ចំណែកឡឹក សំអឿន ត្រូវរស់នៅក្នុងប្រទេសថៃ បន្តទៀត ដោយស្នាក់អាស្រ័យនៅជាមួយព្រះសង្ឃខ្មែរពីវត្តមួយ ទៅវត្តមួយ ជាអាទិស្នាក់អាស្រ័យនៅជាមួយ លោកគ្រូអាចារ្យចន្ទ នៅវត្តស៊ីសាកេត, លោកគ្រូអាចារ្យសួស គូ នៅវត្តចាងហ្វាងឱត, លោកគ្រូអាចារ្យសួង នៅវត្តចក្កវត្តិ ក្រុងបាងកក។

ពេលនោះ គាត់មានទំនាក់ទំនងស្គាល់រាប់អានគ្នាជាមួយសាមណសិស្សខ្មែរ មួយក្រុមដែលបានទទួលបានអាហារូបករណ៍ មកបន្តការសិក្សានៅមហាវិទ្យាល័យជុឡាឡុងកន ទីក្រុងបាងកក។

សាមណនិស្សិតទាំងនោះ រួមមាន៖ ព្រះភិក្ខុអ៊ុង មាន, ព្រះភិក្ខុឈឹម ផន, ព្រះភិក្ខុស៊ុន សារៀម នៅវត្តបញ្ចបរមពិត, ព្រះភិក្ខុប៉ា ផល នៅវត្តចាងហ្វាងឱត, ព្រះភិក្ខុសោម ងន នៅវត្តព្រះភិរុន្ទ្រេ, ព្រះភិក្ខុអាង សារ៉េន នៅវត្តចក្កវត្តិ។ សាមណនិស្សិតទាំងអស់នេះ ទើបតែបង្កើតសមាគមមួយ ឈ្មោះសមាគមសាមណនិស្សិតខ្មែរ មានទីចាត់ការ នៅក្នុងវត្តចក្កវត្តិ ក្នុងក្រុងបាងកក។

ការបង្កើតសមាគមសាមណនិស្សិតខ្មែរនេះឡើង គឺក្នុងគោលបំណងជួយដឹកនាំព្រះសង្ឃ ឲ្យខំប្រឹងប្រែងរៀនសូត្រ និងអ្នកភៀសខ្លួនខ្មែរទាំងឡាយឱ្យចេះរួបរួមសាមគ្គីជួយយកអាសាគ្នាទៅវិញទៅមក តែប៉ុណ្ណោះ។ លុះ២ឆ្នាំក្រោយមក ស្រាប់តែមានជនកំហូចម្នាក់ ឈ្មោះព្រាប សុខ បានរាយការណ៍ទៅឯកអគ្គរាជទូតខ្មែរប្រចាំប្រទេសថៃ ឈ្មោះទី គឹមសួរ ដោយមួលបង្កាច់ថា សមាគមសមណនិស្សិតខ្មែរនេះ ជាសមាគមគាំទ្រចលនាតស៊ូរបស់សឺង ង៉ុកថាញ់ ហើយសមាជិករបស់សមាគមទាំងអស់ សុទ្ធតែជាអ្នកប្រឆាំងនឹង



**សម្ដេចព្រះសង្ឃរាជហួត តាត និងជួន ណាត** (រូបថតវិទូ)

សម្ដេចសីហនុ និងជាអ្នកស្អប់ខ្ពើមរបបរាជាជានិយម។

ក្រោយពីមានរបាយការណ៍ ដូចខាងលើនេះ សម្ដេចសីហនុ ខ្វាល់ប្រទ្បោតតោគតួង ឲ្យគេកោះហៅសាមណនិស្សិតទាំងអស់នោះ ដើម្បីយកមកតទល់គ្នា នៅក្នុងសមាជជាតិទៀតផង។ ប៉ុន្តែ ដោយសារមានអន្តរាគមន៍ពីសម្ដេចព្រះសង្ឃរាជ ជួន ណាត និងសម្ដេចព្រះសង្ឃរាជ ហួត តាត ព្រះអង្គក៏អន់ខ្វាល់មួយរយៈ ប៉ុន្តែ នៅតែឱ្យភ្នាក់ងារសម្ងាត់ (គិញ) របស់ព្រះអង្គ តាមដានសមណនិស្សិតទាំងនោះ។

នៅពេលលោកអាចារ្យអាង សារ៉េន វិលត្រលប់ទៅក្រុងភ្នំពេញ វិញ គាត់បានចាកសិក្ខាបទ ទៅធ្វើការនៅស្ថានទូតអាមេរិក ក្នុងឆ្នាំ១៩៥៧ ។ តែគាត់ត្រូវបាត់ខ្លួនយ៉ាងអាថ៌កំបាំងបំផុត។ ប្រភពខ្លះថា គាត់ត្រូវភ្នាក់ងារសម្ងាត់ (គិញ) របស់សីហនុ ចាប់យកទៅប្រហារជីវិតចោល។

មុនបាត់ខ្លួនអាចារ្យអាង សារ៉េន នេះបន្តិច លោកអាចារ្យប្រុក គង់នៅកុដិព្រះគ្រូអាចារ្យប៉ាង ខាត់ ក្នុងវត្តឧណ្ណាលោម ក៏ត្រូវគេសង្ស័យថា ភ្នាក់ងារសម្ងាត់(គិញ) របស់សីហនុ ចាប់យកទៅប្រហារជីវិតស្ងាត់ៗ ដែរ។

ចំណែក ឡឹក សំអឿន ពេលរស់នៅក្នុងទីក្រុងបាងកកនោះ ក៏បានជួបមិត្តភក្តិម្នាក់ឈ្មោះ សារ៉ាក់ ខាន់ រត់ភៀសខ្លួនពីប្រទេសខ្មែរ ដោយសារភ្នាក់ងារសម្ងាត់(គិញ)របស់

សម្តេចសីហនុ តាមរកចាប់ខ្លួន។

សារ៉ាក់ ខាន់ បានមករកគាត់ដល់កុដិព្រះគ្រូសោម ងន នៅវត្តព្រះភិរេន្ទ្រ ក្រុងបាងកក ហើយបបួលគាត់ទៅរកការធ្វើនៅទីក្រុងវៀងចន្ទ ប្រទេសឡាវ។

នៅដើមខែមេសា ១៩៥៧ ឡឹក សំអឿន និងសារ៉ាក់ ខាន់ បានចេញដំណើរដោយរថភ្លើង នៅវេលាយប់ ពីក្រុងបាងកក ទៅកាន់ក្រុងណងខាយ (Nong Khai) ដោយពេលនោះ សារ៉ាក់ ខាន់ ត្រូវក្លែងខ្លួនធ្វើជាមនុស្សគ ព្រោះគាត់មិនចេះនិយាយភាសាថៃ។ ពេលទៅដល់ទីប្រជុំជនណងខាយ (Nong Khai) ទឹកដីថៃ ជាប់ព្រំដែនឡាវ ពួកគាត់បានស្នាក់អាស្រ័យនៅផ្ទះលោកអាចារ្យខៀវ ណយ (ជាប្អូនប្រុសរបស់ព្រះគ្រូអាចារ្យខៀវ ជុំ) មានមុខរបរជាអ្នកដឹកឈើហ៊ុប ពីព្រៃគុកឈៀងខាន មកទីប្រជុំជនណងខាយ (Nong Khai) (ទឹកដីថៃ)។

ប៉ុន្មានថ្ងៃក្រោយមក លោកអាចារ្យខៀវ ណយ ក៏បាននាំឡឹក សំអឿន និងសារ៉ាក់ ខាន់ ឱ្យចូលធ្វើកម្មករនៅក្រុមហ៊ុនដឹកជញ្ជូនឈើហ៊ុបនោះមួយរយៈ ដើម្បីរកប្រាក់ធ្វើសោហ៊ុយបន្តដំណើរទៅក្រុងវៀងចន្ទ ទៀត។

នៅទីនោះ ពួកគាត់ និងកម្មករព្រៃគុកទាំងអស់ តែងតែធ្វើដំណើរចេញចូលទៅទីប្រជុំជនឈៀងខាន នៅខាងទឹកដីឡាវ ជារៀងរាល់ថ្ងៃ ដើម្បីទិញម្ហូបអាហារ ពួកតម្រួតថៃ នៅទីនោះ ក៏បានចំណាំមុខគាត់ទាំងពីរនាក់ ថាជាកម្មករនៅក្រុមហ៊ុនព្រៃគុក នោះដែរ។ ឈៀងខាន ជាទីប្រជុំមួយតូច ស្ថិតនៅតាមដងទន្លេមេគង្គ ដោយមានទីក្រុងហ្លួងព្រះបាងនៅប៉ែកខាងលើ និងទីក្រុងវៀងចន្ទ នៅប៉ែកខាងក្រោមដងទន្លេ។ បន្ទាប់ពីបាន ដឹងថាមានកប៉ាល់ឈ្នួលចេញដំណើរ នៅវេលាម៉ោង៦ព្រឹក ជារៀងរាល់ថ្ងៃ ពីទីប្រជុំជន ឈៀងខាន (ខាងទឹកដីឡាវ) ទៅទីប្រជុំជនណងខាយ ដែលនៅសល់តែចម្ងាយ ១៥គីឡូ ម៉ែត្រទៀត នឹងទៅដល់ទីក្រុងវៀងចន្ទ ពួកគាត់ក៏បានធ្វើដំណើរតាមកប៉ាល់នោះ។

តែមុនពេលចេញដំណើរ លោកអាចារ្យខៀវ ណយ បានទាក់ទងជាមួយបងប្អូនខ្មែរកម្ពុជាក្រោមម្នាក់ ឈ្មោះថាច់ គឿង ជាគ្រូពេទ្យប្រចាំ នៅទីប្រជុំជនណងចាន់ ស្ថិតនៅចំពី

មុខក្រុងវៀងចន្ទ ឲ្យរង់ចាំទទួលពួកគាត់ ផងដែរ។

ថាច់ គឿង ពីមុនធ្លាប់រស់នៅខេត្តបាត់ដំបង ក្នុងសម័យថៃត្រួតត្រា និងមានតួនាទីជាគិលានុបដ្ឋាក។ តែក្រោយពេលថៃត្រូវដកចេញពីខេត្តបាត់ដំបង ក្នុងឆ្នាំ១៩៤៦ គាត់ក៏ជាអ្នកគាំទ្រចលនាតស៊ូខ្មែរឥស្សរៈយ៉ាងប្តូរផ្តាច់ម្នាក់ដែរ។

វេលាម៉ោង៥ល្ងាច កប៉ាល់បានចូលចតនៅផែតូចមួយ នៅពាក់កណ្តាលផ្លូវ ដើម្បីឈប់សម្រាកមួយយប់។ អ្នកដំណើរភាគច្រើន បាននាំគ្នាឡើងទៅទីផ្សារ ដើម្បីទទួលទានបាយពេលល្ងាច និងខ្លះទៀត ទៅជួលផ្ទះសំណាក់ដេក។

ដោយឡែកពួកគាត់ទាំងពីរនាក់ និងអ្នកដំណើរមួយចំនួនទៀត នាំគ្នាទទួលទានបាយកញ្ចប់ ដាក់មកជាមួយ ហើយទទួលទានដំណេក នៅលើកប៉ាល់នោះ តែម្តង។ លុះព្រឹកឡើងម៉ោង៦ កប៉ាល់ក៏បន្តដំណើរទៅមុខទៀត រហូតដល់ម៉ោង១០ ក៏បានចូលចតកំពង់ផែណងចាន់ ដែលមើលទៅត្រើយម្ខាងទៀត ឃើញក្រុងវៀងចន្ទ នៅចំពីមុខ។

ពេលនោះ ពួកគាត់ទាំងពីរនាក់ ក៏ជួបគ្រូពេទ្យថាច់ គឿង កំពុងរង់ចាំទទួលនៅមាត់ច្រាំង ហើយបាននាំពួកគាត់ទៅផ្ទះ ដើម្បីទទួលទានបាយ និងសំណេះសំណាលគ្នារហូតដល់ពេលល្ងាច គ្រូពេទ្យថាច់ គឿង ក៏បាននាំពួកគាត់ឆ្លងទៅក្រុងវៀងចន្ទ នៅត្រើយម្ខាង។ ដោយគ្រូពេទ្យថាច់ គឿង បានទាក់ទងឈ្មោះអ៊ុក ម៉ិល និយាយព្រមព្រៀងគ្នាពីមុនរួចមកហើយ។ ពេលទៅដល់ក្រុងវៀងចន្ទ គ្រូពេទ្យថាច់ គឿង បាននាំពួកគាត់ទៅដល់ផ្ទះរបស់ឈ្មោះអ៊ុក ម៉ិល នៅជាប់របងវត្តមួយ។ ម្ចាស់ផ្ទះ ក៏អនុញ្ញាតឲ្យពួកគាត់ស្នាក់ជាមួយបណ្តោះអាសន្នសិន។

ប្រហែលមួយអាទិត្យក្រោយមក ដោយសារ ឡឹក សំអឿន ចេះនិយាយភាសាបារាំង សៀម និងយួន ផងនោះ គាត់ក៏មានលទ្ធភាពរកការងារបានធ្វើ នៅក្រុមហ៊ុនឈើហ៊ុបរបស់សេដ្ឋីម្នាក់ ឈ្មោះសំប៊ូន ឥន្ទវង្ស ដោយមានតួនាទីជាគណនេយ្យផង និងជាអ្នកលក់អ្នកទិញឈើហ៊ុបផង និងបានប្រាក់ខែ ចំនួន៨ពាន់គីប ស្មើនឹង៨ពាន់រៀលលុយខ្មែរសម័យនោះ។

ពេលនោះ ប្រទេសខ្មែរយើង ពុំទាន់មានស្ថានទូតប្រចាំក្រុងវៀងចន្ទ នៅឡើយទេ កិច្ចការទំនាក់ទំនងរវាងប្រទេសខ្មែរ និងឡាវ គឺទូតបារាំង ជាអ្នកទទួលខុសត្រូវ ជំនួស។ ២ខែក្រោយមក ឡឹក សំអឿន និងសារ៉ាក់ ខាន់ ក៏បានសុំលាម្ចាស់ផ្ទះ ឈ្មោះអ៊ុក ម៉ិល ចេញទៅជួលផ្ទះមួយស្នាក់នៅជិតកន្លែងធ្វើការ នៅឯក្រុមហ៊ុនឈើហ៊ុបនោះវិញ។

ថ្ងៃមួយ សេដ្ឋីសំប៊ូន ឥន្ទវង្ស បានចុះមកពិនិត្យមើលការងារនៅក្រុមហ៊ុន ឃើញ ឡឹក សំអឿន ធ្វើការសកម្ម ហើយធ្វើការច្រើនមុខ ជាអ្នកកាន់បញ្ជីផង ជាអ្នកលក់ និងអ្នកទិញឈើផង សេដ្ឋីនោះ ក៏ឱ្យគាត់រកមនុស្សម្នាក់ទៀត មកជួយធ្វើការ ដោយឱ្យប្រាក់ខែ ចំនួន៦ពាន់គីប។ ពេលនោះ ឡឹក សំអឿន ក៏បាននាំ សារ៉ាក់ ខាន់ ជាមិត្តភក្តិឲ្យមកចូលធ្វើការជាមួយដែរ។

ចាប់ពីពេលនោះមក ឡឹក សំអឿន មិនត្រឹមតែមិនសូវមានការងាររវល់ច្រើន ដូចមុន ទៀតទេ គឺថែមទាំងមានឱកាសបានជួបប្រស្រ័យទាក់ទង រាប់អានជាមួយបងប្អូនខ្មែរផ្សេងៗ ទៀត នៅទីក្រុងវៀងចន្ទ នោះទៀតផង។

# ១០៨
# សម សារី បង្ករឿងអាស្រូវនៅក្រុងឡុងដ៍



**សម សារី ពេលមានតំណែងជាឯកអគ្គរាជទូត នៅប្រទេសអង់គ្លេស** (រូបថត Historic)

នៅដើមឆ្នាំ១៩៥៧ ដោយសារ សម សារី ជាទីប្រឹក្សារាជរដ្ឋាភិបាល ត្រូវបានមន្ត្រីក្នុងជួររាជរដ្ឋាភិបាលភាគច្រើននាំគ្នាប្រឆាំងជំទាស់គាំ រហូតដល់មានការដកចេញពីតំណែង។



**សម សារី ពេលសាងផ្នួស និងប៉ែន នុត**

ជាមួយគ្នានោះ គាត់ក៏មានទំនាស់យ៉ាងស្រួចស្រាវជាមួយ សឺន សាន អគ្គទេសាភិបាលធនាគារជាតិ ពីបញ្ហាដូរក្រដាសប្រាក់រៀល ផងដែរ ។

គាប់ជួនអំឡុងពេលដកចេញពីតំណែងនោះ ចំពេលប្រារព្ធធ្វើពិធីបុណ្យពាក់កណ្តាលសាសនា (គឺឆ្នាំ២៥០០នៃពុទ្ធសករាជ) យ៉ាងអធិកអធមក្រៃលែង រយៈពេល៧យប់ និង៧ថ្ងៃ គឺពីថ្ងៃទី១២ ដល់ថ្ងៃទី១៨ ខែឧសភាឆ្នាំ១៩៥៧ នៃគ្រិស្តសករាជ ដោយមានដង្ហែព្រះសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធ ពីប្រទេសស្រីលង្កា យកមកតម្កល់ទុក នៅក្នុងព្រះសក្យមុនីចេតិយនៅមុខស្ថានីយរថភ្លើង នៅទីក្រុងភ្នំពេញ ផងនោះ សម សារី បានសម្រេចចិត្តទៅសាងផ្នួសបួសជាព្រះសង្ឃនៅវត្តបទុមវតីរាជវរារាម មួយរយៈ។

ក្រោយពីចាកសិក្ខាបទមកវិញ គាត់បានសុំចូលគាល់សម្តេចសីហនុ សុំឱ្យព្រះអង្គប្រទានតំណែងណាមួយ មិនមានទំនាស់ជាមួយមន្ត្រីជាន់ផ្សេងៗទៀតដូចពីមុន។ ដើម្បី

ស្តារមុខមាត់របស់ សម សារី ឡើងវិញ និងដើម្បីបញ្ចៀសគាត់ កុំឱ្យបង្កជម្លោះជាមួយមន្ត្រីក្នុងជួររាជរដ្ឋាភិបាលផ្សេងៗទៀតនោះ នៅដើមឆ្នាំ១៩៥៨ សម្តេចសីហនុ ក៏បានតែងតាំង សម សារី ឱ្យទៅធ្វើជាឯកអគ្គរាជទូតខ្មែរ នៅក្រៅប្រទេស ដោយបើកសិទ្ធិឱ្យគាត់ជ្រើសរើសយកបណ្តាប្រទេសមួយចំនួន ដូចជា នៅក្រុងវ៉ាស៊ីនតោន សហរដ្ឋអាមេរិក, ក្រុងឡុងដ៍ ប្រទេសអង់គ្លេស, ក្រុងប៉ារីស ប្រទេសបារាំង ឬក្រុងកង់បេរ៉ា ប្រទេសអូស្ត្រាលី នៅប្រទេសណាមួយ ក៏បាន គឺតាមបំណងប្រាថ្នារបស់គាត់។

ដោយសារធ្លាប់បានទៅសិក្សា នៅប្រទេសបារាំង ដែរនោះ សម សារី បានសម្រេចចិត្តយកតំណែងឯកអគ្គរាជទូតខ្មែរ នៅប្រទេសបារាំង ហើយបាននាំក្រុមគ្រួសារចាកចេញពីភ្នំពេញ តាមយន្តហោះដ៏ទំនើបមួយ ទៅរស់នៅក្នុងសង្កាត់ទី១៧ ក្នុងក្រុងប៉ារីស។ ប៉ុន្តែការចូលកាន់តំណែងជាឯកអគ្គរាជទូតរបស់គាត់ ជាផ្លូវការ នៅក្រុងប៉ារីសនោះ ពិធីទទួលសារតាំងត្រូវបានខុទ្ទកាល័យប្រធានាធិបតី និងក្រសួងការបរទេសបារាំង ចេះតែពន្យារពេលជាបន្តបន្ទាប់ មិនដូចការតែងតាំងឯកអគ្គរាជទូតខ្មែរមុនៗនោះឡើយ។ តែទោះបីយ៉ាងនេះក៏ដោយ ក៏ សម សារី បានរកវិទ្យាល័យមួយ ដើម្បីឱ្យកូនធំៗរបស់គាត់ បានចូលរៀនជាបណ្តើរៗ សិនដែរ។ កូនប្រុសច្បងគាត់ឈ្មោះអេម៉ារ៉ា ចូលរៀននៅវិទ្យាល័យហ្សង់សុង ដឺ សៃយី (Janson de sailly) និងកូនស្រីឈ្មោះអេម៉ារ៉ាន ចូលរៀននៅវិទ្យាល័យម៉ូលីយ៉ែរ (Molière)។

មូលហេតុខុទ្ទកាល័យប្រធានាធិបតី និងក្រសួងការបរទេសបារាំង ចេះតែពន្យារពេលទទួលសារតាំងទទួលស្គាល់សម សារី ជាឯកអគ្គរាជទូតខ្មែរ ជាផ្លូវការនោះ អាចមកពីបញ្ហា សម សារី ធ្លាប់មានរឿងអាស្រូវជាច្រើនករណី ដូចជា កាលទៅចូលរួមក្នុងសន្និសីទចតុភាគី (បារាំង កម្ពុជា វៀតណាមខាងត្បូង លាវ) នៅប្រទេសបារាំង ក្នុងខែសីហា ឆ្នាំ១៩៥៤ ដើម្បីដោះស្រាយបញ្ហារូបិយវត្ថុនៅឥណ្ឌូចិន។ ពេលនោះ គាត់មានតួនាទីជាលេខាធិការរបស់គណៈប្រតិភូកម្ពុជា បានប្រើពាក្យសម្តីមិនគួរគប្បីទៅលើគណៈប្រតិភូប្រទេសផ្សេងទៀត ធ្វើឱ្យសន្និសីទនោះត្រូវផ្អាកការប្រជុំ រាប់ខែ។

រឿងអាស្រូវមួយទៀត កាលគាត់កាន់តំណែងជាឧបនាយករដ្ឋ-មន្ត្រី កាលពីចុងឆ្នាំ១៩៥៥ ក្នុងពិធីប្រគល់ជំនួយរបស់សហរដ្ឋអាមេរិក គាត់បានបង្កជម្លោះជាមួយឯកអគ្គរដ្ឋទូតអាមេរិក គ្លីនតុក (Clintock) រហូតដល់ឯកអគ្គរដ្ឋទូតអាមេរិក ប្រាប់ សឺន សាន ថា សម សារី បានយកកាំភ្លើងខ្លី មកភ្ជង់ក្បាលគាត់ទៀតផង ។

ទន្ទឹមនោះដែរ នៅក្រុងប៉ារីស មានជនជាតិខ្មែរ ពួកនិស្សិតខ្មែរ មាននិន្នាការឆ្វេងនិយម បាននាំគ្នាធ្វើបាតុកម្មប្រឆាំងមិនឱ្យគាត់មកធ្វើជាឯកអគ្គរាជទូតខ្មែរ នៅប្រទេសបារាំងនេះ ជាដាច់ខាត។



**នាងអ៊ីុង អេងសេង និងកូនប្រុសឈ្មោះ សេនារ័ត្ន អាវើរីល ពេលធំពេញវ័យ**

នៅទីបំផុត សម សារី សុខចិត្តចាកចេញពីប្រទេសបារាំង ទៅធ្វើជាឯកអគ្គរាជទូត នៅប្រទេសអង់គ្លេស វិញ។ គាត់បាននាំប្រពន្ធ និងកូន៥នាក់ ព្រមទាំងអតីតបវរកញ្ញាជ័យលាភីលេខ១វ័យក្មេង ក្នុងសម័យប្រលង ខែវិច្ឆិកា ឆ្នាំ១៩៥៥ ឈ្មោះ ទេព កន្នរី ជាភរិយាទី២ និងអតីតបវរកញ្ញាជ័យលាភីលេខ២ ឈ្មោះអ៊ីវ អេងសេង ជាស្រីកំណាន់ (តាមពិតដូចជាប្រពន្ធទី៣ ដែរ) ទៅជាមួយផង ដោយចុះឈ្មោះក្នុងបញ្ជីផ្លូវការថា ជាបុគ្គលិកស្ថានទូត និងជាអ្នកបម្រើ។

## របត់នយោបាយ



ស្ត្រីឈ្មោះ អ៊ីវ អេងសេង

សម សារី បានយកកញ្ញាដ៏ស្រស់ស្អាត ឈ្មោះ ទេព កិន្នរី ដែលទើបនឹងប្រលងជាប់ជាបវរកញ្ញា នៅក្នុងឆ្នាំ១៩៥៥ ជាធ្វើជាប្រពន្ធចុង ហើយថែមទាំងយកមករស់នៅផ្ទះជាមួយ ប្រពន្ធដើមទៀតផង។ ក្រោយមកទៀត គាត់ក៏បានយកបវរកញ្ញាម្នាក់ទៀត ឈ្មោះ អ៊ីវ អេងសេង មកធ្វើជាប្រពន្ធថែមម្នាក់ទៀត។

ប៉ុន្តែ ក្រោយពេលទៅបំពេញតួនាទីជាឯកអគ្គរាជទូត នៅទីក្រុងឡុងដ៍ បានរយៈពេលតែ៦ខែ ស្រាប់តែ សម សារី ក៏បង្កឱ្យមានរឿងអាស្រូវមួយទៀត ដោយគាត់បានវាយដំប្រពន្ធចុងម្នាក់ (ក្នុងបញ្ជីផ្លូវការដាក់ថាជាអ្នកបម្រើ) គឺអតីតបវរកញ្ញា ឈ្មោះ អ៊ីវ អេងសេង ទើបតែសម្រាលបានកូនប្រុសមួយ បណ្តាលឱ្យរងរបួសយ៉ាងធ្ងន់។

រឿងអាស្រូវនេះ មិនត្រឹមតែកាសែត និងទស្សនាវដ្តីរបស់ប្រទេសអង់គ្លេស នោះទេ សូម្បីទស្សនាវដ្តីថែម( Time )របស់អាមេរិក និងកាសែតនៅបណ្តាប្រទេសមួយចំនួនទៀតក៏បានចុះផ្សាយព្រោងព្រាតផងដែរ។

ទស្សនាវដ្តីថែម (Time) ដ៏ល្បីល្បាញរបស់សហរដ្ឋអាមេរិក បានចុះផ្សាយថា ស្ត្រីរងគ្រោះឈ្មោះអ៊ីវ អេងសេង បានបីទារក ទើបតែសម្រាលបានប្រហែល១ខែ រត់គេចចេញពីស្ថានទូតខ្មែរ ទៅប្តឹងសមត្ថកិច្ចប៉ូលិសថា ឯកអគ្គរាជទូត សម សារី បានវាយដំនាង

ឱ្យរងរបួសធ្ងន់ ដោយសារតែកំហុសបន្តិចបន្តួច។

នៅចំពោះមុខសមត្ថកិច្ចប៉ូលិសអង់គ្លេស សម សារី បានបញ្ជាក់ថា គាត់មិនបានវាយស្រីបម្រើនោះឱ្យមានរបួសអ្វីធ្ងន់ទេ គឺគាត់គ្រាន់តែប្រដៅនាង ដោយវាយនឹងរំពាត់បន្តិចបន្តួច ហើយគាត់មិនដែលវាយនាងលើមុខទេ គឺវាយតែនៅត្រង់ខ្នង និងនៅត្រង់ភ្លៅប៉ុណ្ណោះ។

លើសពីនេះទៅទៀត សម សារី បានតវ៉ាថា គាត់មានសិទ្ធិគ្រប់បែបយ៉ាង ក្នុងការវាយប្រដៅស្រីជាអ្នកបម្រើរបស់គាត់ តាមទំនៀមទម្លាប់ខ្មែរ ហើយការវាយប្រដៅនោះ ក៏គាត់ធ្វើឡើងនៅក្នុងស្ថានទូតខ្មែរ ជាទឹកដីរបស់កម្ពុជា នៅក្នុងទីក្រុងឡុងដ៍ នេះដែរ។

បន្ទាប់មក ឯកអគ្គរដ្ឋទូតសម សារី បានទៅតវ៉ាដល់ក្រសួងការបរទេសអង់គ្លេស ដើម្បីប្រឆាំងជំទាស់នឹងពាក្យបណ្តឹងរបស់ស្រីរងគ្រោះ ឈ្មោះអ៊ីវ អេងសេង ផងដែរ។ តែទោះបីយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាលនៅទីក្រុងភ្នំពេញ មាន ស៊ឹម វ៉ា ជានាយករដ្ឋមន្ត្រីចាត់ទុកថា ការដែលសម សារី បានវាយជំស្រី ឈ្មោះអ៊ីវ អេងសេង រួចហើយប្រាប់ពួកក្រុមអ្នកកាសែតបរទេសថា នៅស្រុកខ្មែរ ការវាយធ្វើបាបអ្នកបម្រើក្នុងផ្ទះ គឺជាទំនៀមទម្លាប់របស់ជនជាតិខ្មែរនោះ គឺជាការធ្វើឱ្យអាប់ឱនដល់កិត្តិយស មុខមាត់របស់ប្រទេសជាតិ ហើយអង់គ្លេស គេគិតថា យើងជាប្រទេសព្រៃផ្សៃ។

ទីបំផុត នៅថ្ងៃទី១៧ ខែមិថុនា ១៩៥៨ រាជរដ្ឋាភិបាលបានសម្រេចបញ្ចប់តំណែងឯកអគ្គរដ្ឋទូត ប្រចាំប្រទេសអង់គ្លេស ពីសម សារី រួចបញ្ជាឱ្យគាត់នាំក្រុមគ្រួសារវិលត្រលប់មកមាតុប្រទេស វិញភ្លាមៗតែម្តង។

ចំណែកស្ត្រីរងគ្រោះ ឈ្មោះ អ៊ីវ អេងសេង ពេលនោះ នាងមានវ័យ ២២ ឆ្នាំ មិនបានត្រលប់មកប្រទេសវិញទេ នាងបានដាក់ពាក្យសុំសិទ្ធិជ្រកកោន ទៅកាន់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអង់គ្លេស រីឆាដ អេ. បាត្ល័រ (Richard A. Butler)។ រដ្ឋាភិបាលប្រទេសអង់គ្លេស ក៏បានអនុញ្ញាត យល់ព្រមឱ្យនាង និងកូនប្រុសទើប អាយុជាង១ខែនោះ រស់នៅក្នុងទីក្រុងឡុងដ៍បន្តទៀត។

## របត់នយោបាយ

ក្រោយមក នាងអ៊ីវ អេងសេង បានយកប្តី ជាជនជាតិអង់គ្លេស ឈ្មោះចន អាវើរីល (John Averill) ហើយកូនប្រុសម្នាក់នោះ នាងបានដាក់ឈ្មោះ ដោយភ្ជាប់ជាមួយឈ្មោះប្តី ជាជនជាតិអង់គ្លេស នោះ គឺឈ្មោះសេនារ័ត្ន អាវើរីស(Senaroth Averill)។

រីឯ អតីតបវរកញ្ញា ជ័យលាភីលេខ១ ឈ្មោះទេព កន្នរី ជាកវិយាទី២ ក៏បានវិលត្រលប់មកមាតុប្រទេសវិញ ជាមួយគ្រួសារសម សារី ដែរ ។ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ នាងបានក្លាយជាតារាភាពយន្ត។ ក្រោយព្រឹត្តិការណ៍រដ្ឋប្រហារឆ្នាំ១៩៧០ ទេព កន្នរី បានចាកចេញពីប្រទេសកម្ពុជា ទៅរស់នៅប្រទេសបារាំង ហើយបានបន្តទៅរស់នៅសហរដ្ឋអាមេរិក រហូតដល់សព្វថ្ងៃ។

នៅទី១១ ខែសីហា ឆ្នាំ២០១៥ នៅក្នុងវេទិកាពិភាក្សាមួយដែលមានជនជាតិខ្មែររាប់រយនាក់រស់នៅក្រៅប្រទេសចូលរួមនោះ មានស្ត្រីម្នាក់ឈ្មោះណារី បានឡើងអះអាងថា ស្ត្រីឈ្មោះអ៊ីវ អេងសេង ត្រូវជាម្តាយមីងរបស់នាងបានបាត់ខ្លួននៅក្នុងប្រទេសកម្ពុជាក្នុងសម័យខ្មែរប៉ុលពត។ ចំណែកកូនប្រុសបង្កើតរបស់គាត់ឈ្មោះ សេនារ័ត្ន អេវើរីល (Senaroth Averill) ត្រូវជាបងប្អូនជីដូនមួយរបស់នាង។ លោកស្រី ណារី បានថ្លែងជាភាសាអង់គ្លេស ថា៖ សួស្តីអ្នកទាំងអស់គ្នា ។ ខ្ញុំជាជនជាតិខ្មែរសញ្ជាតិបារាំង ហើយខ្ញុំនិយាយភាសាអង់គ្លេសមិនសូវល្អទេ តែខ្ញុំសង្ឃឹមថាលោកអ្នកនឹងយល់ពីអ្វីដែលខ្ញុំនិយាយ។ ខ្ញុំសូមប្រកាសស្វែងរកឈ្មោះ សេនារ័ត្ន អេវើរីល(Senaroth Averill) ដែលជាកូនប្រុសបង្កើតរបស់ម្តាយមីងរបស់ខ្ញុំ(អ៊ីវ អេងសេង)ជាមួយសម សារី។

ម្តាយមីងរបស់ខ្ញុំ និងកូនប្រុសឈ្មោះសេនារ័ត្ន អេវើរីលរស់នៅអង់គ្លេស ហើយម្តាយមីងរបស់ខ្ញុំ បានបានយកប្តី ជាជនជាតិអង់គ្លេស ឈ្មោះចន អេវើរីល (John Averill) ។ ក្រោយមក ម្តាយមីងរបស់ខ្ញុំបានវិលត្រលប់មករស់នៅប្រទេសកម្ពុជាវិញ តែម្នាក់គាត់។ នៅក្នុងឆ្នាំ១៩៧៤ កូនប្រុសគាត់ឈ្មោះ សេនារ័ត្ន អេវើរីល បានទៅលេងម្តាយរបស់គេនៅប្រទេសកម្ពុជា ហើយគេត្រលប់ទៅប្រទេសអង់គ្លេសវិញ នៅឆ្នាំដើមឆ្នាំ១៩៧៥។ ពេលនេះយាយរបស់ខ្ញុំនៅប្រទេសបារាំង មានវ័យចាស់ជរាទៅហើយ តែងតែសួររកចន អេវើរីល

( John Averill ) ។ ដូច្នេះបើមានលោកអ្នកណាបានដឹងដំណឹងពីគាត់ សូមមេត្តាជួយប្រាប់ខ្ញុំផង។ អរគុណច្រើន ។

៤០ឆ្នាំក្រោយមក គឺនៅក្នុងឆ្នាំ១៩៩៨ សម រង្ស៊ី ជាកូនពៅរបស់សម សារី ដែលក្លាយខ្លួនជាមេដឹកនាំគណបក្សប្រឆាំងដ៏ល្បីឈ្មោះម្នាក់ បានអះអាងពីរឿងអាស្រូវ នៅទីក្រុងឡុងដ៍ ឆ្នាំ១៩៥៨នោះ ថា ល្ងាចថ្ងៃកើតហេតុនោះ មានស្ត្រីបម្រើការនៅក្នុងស្ថានទូតម្នាក់ ជិតស្និទ្ធនឹងឪពុកគាត់( សម សារី) ត្រូវបានគេវាយដំ។ ភ្លាមនោះ គាត់( ទើបមានអាយុ៩ឆ្នាំ )គិតថា ប្រហែលម្ដាយរបស់គាត់ជាអ្នកវាយស្ត្រីម្នាក់នោះ។

ចំណែក ស្ថានភាពមុខរបួស មានការលើកឡើងខុសៗគ្នា ដោយអ្នកខ្លះថា មានសភាពធ្ងន់ និងខ្លះទៀតថា រងរបួសបន្តិចបន្តួច ។ ក្រោយពេលកើតហេតុ គេបានដឹកស្ត្រីនោះ ទៅមន្ទីរពេទ្យ ហើយមិនយូរប៉ុន្មាន ក៏មានអាចារ្យប៉ាស្ទ័រ អង់គ្លេសម្នាក់ មកជួយយកអាសា និងមើលការខុសត្រូវ។

ប៉ុន្តែ រឿងនេះ វាមិនបញ្ចប់ទៅដោយងាយៗទេ ដំណឹងនេះក៏លេចឮសុះសាយដល់ពួកអ្នកកាសែត ហើយពួកនេះបាននាំគ្នាមកធ្វើសម្ភាសជាមួយស្រីនោះ និងបានយកបទសម្ភាសនោះ ទៅរៀបចំចងក្រងជាអត្ថបទមួយ យកទៅចុះផ្សាយលើទំព័រកាសែត ដ៏ល្បីល្បាញមួយរបស់អង់គ្លេស ឈ្មោះដេលី មីរ័រ ( Daily Mirror ) ដោយបានដាក់ចំណងជើងនៅលើទំព័រមុខថា មានរឿងអាស្រូវមួយ នៅក្នុងស្ថានទូតកម្ពុជា! ។

ឪពុកគាត់ឃើញដូច្នោះ ក៏ចេញមុខការពារម្ដាយរបស់គាត់ ដោយបញ្ជាក់ប្រាប់គេឯងថា គឺខ្លួនគាត់ផ្ទាល់តែម្ដង ជាអ្នកវាយតប់ស្រីនោះ។ តែដោយសារចង់ឲ្យរឿងរ៉ាវនេះស្ងប់ស្ងាត់ទៅវិញ កុំឲ្យរាលដាលវែងឆ្ងាយតទៅទៀត ឪពុករបស់គាត់ ក៏បានភ្លាំងភ្លាត់ ធ្វើឱ្យមានកំហុសឆ្គងមួយយ៉ាងធំ ដោយឪពុករបស់គាត់ បានបកស្រាយប្រាប់ពួកអ្នកកាសែតថា នៅស្រុកខ្មែរ ការវាយធ្វើបាបអ្នកបម្រើនៅក្នុងផ្ទះ គឺជារឿងធម្មតាមួយ គ្មានអ្វីចម្លែកទេ ម្យ៉ាងទៀត ស្ត្រីនោះក៏គ្មានរបួសស្នាមអ្វីដែរ ។

សម រង្ស៊ី យល់ថា ការដែលគេព្យាយាមយកស្រីរងរបួសបន្តិចបន្តួចនោះ ទៅកាន់

មន្ទីរពេទ្យ ក៏ជាល្បិចនយោបាយពង្រីករឿងនេះ ឱ្យកាន់ធំឡើងៗ ដើម្បីបំផ្លាញតំណែងឪពុករបស់គាត់ ជាឯកអគ្គរាជទូតខ្មែរ ប្រចាំនៅចក្រភពអង់គ្លេស នោះ តែប៉ុណ្ណោះ។

ក្រោយមក ឪពុករបស់គាត់ ក៏បានធ្វើលិខិតតវ៉ាមួយ ទៅក្រសួងការបរទេសអង់គ្លេស ប្រឆាំងនឹងអត្ថបទចុះផ្សាយនៅលើទំព័រកាសែតដេលី មីរ័រ ( Daily Mirror ) នោះ ផងដែរ។


EMBASSY GIRL ACCUSES ENVOY

VICE in LONDON

**កាសែត Daily Mirror**

សម រង្ស៊ី បានសម្តែងការសោកស្តាយថា ពេលនោះ ប្រសិនបើឪពុកគាត់ ប្រកាន់យកឥរិយាបថស្ងៀមស្ងាត់សិន កុំទាន់ឆេវឆាវខ្លាំងពេក ឪពុករបស់គាត់ ក៏មិនធ្លាក់ចូលក្នុងអន្ទាក់នយោបាយរបស់គេដែរ។

សម រង្ស៊ី បានបន្តថា ក្រោយពីត្រលប់មកដល់ទីក្រុងភ្នំពេញ វិញភ្លាម ឪពុករបស់គាត់បានព្យាយាមជាច្រើនថ្ងៃ ដើម្បីសុំរាជានុញ្ញាតចូលគាល់ព្រះមហាក្សត្រដែរ តែមិនបានសម្រេច។

ពេលនោះ ក៏មានការលេចឮពាក្យចចាមអារ៉ាមផ្សេងៗជាច្រើនបន្ថែមទៀត ធ្វើឲ្យរឿងនេះចេះតែរីកធំឡើងៗ ដោយអ្នកខ្លះនិយាយថា ស្រីបម្រើរូបនោះ មានផ្ទៃពោះជាមួយឪពុកគាត់ ហើយការវាយតប់នោះ ធ្វើឲ្យកូនក្នុងផ្ទៃពោះត្រូវរលូត គឺខុសស្រឡះ តែម្តង។ តាមការពិត ស្រីនោះបានសម្រាលកូនប្រហែលពីរខែរួចហើយ មុនពេលមានរឿងរ៉ាវនេះ។

សម រង្ស៊ី បានអះអាងថា គាត់គ្មានគំនិតចង់បន្ថយទម្ងន់នៃឧបទ្ទវហេតុនោះទេ ប៉ុន្តែគាត់ជឿជាក់ថា គេយករឿងរ៉ាវនេះជាលេស ដើម្បីកម្ចាត់ឪពុករបស់គាត់។

សម រង្ស៊ី យល់ឃើញថា ក្នុងសង្គមខ្មែរយើងជំនាន់នោះ រឿងរ៉ាវប៉ុណ្ណឹងៗគេអាចបំភ្លេច ឬអាចដោះស្រាយបានដោយគ្មានបញ្ហាអ្វីឡើយ។

# ១០៩
# សម សារី បង្កើតគណបក្សប្រឆាំង



**សម សារី**

ក្រោយពីវិលត្រលប់មកមាតុប្រទេសវិញ សម សារី សង្ឃឹមថា នឹងអាចចូលប្រឡូកក្នុងឆាកនយោបាយបន្តទៀត។ ប៉ុន្តែផ្ទុយទៅវិញ អ្វីៗវាមិនដូចការសង្ឃឹមទុករបស់គាត់នោះទេ ព្រោះសូម្បីតែមិត្តភក្តិជិតស្និទ្ធ និងកូនចៅជាមន្ត្រីរាជការ ធ្លាប់ធ្វើការនៅក្រោមឱវាទរបស់គាត់ កាលពីមុន ម្នាក់ៗចេះតែនាំគ្នាគេចមុខចេញ ធ្វើឱ្យគាត់មានកំហឹងកាន់តែខ្លាំងឡើងៗ។ សម រង្ស៊ី យល់ឃើញថា ពួកគេមិនទុកឱកាសឲ្យឪពុករបស់គាត់ មានលទ្ធភាពការពារខ្លួន ឲ្យបានសមរម្យតាមគតិយុត្តិធម៌ទេ។ ពួកគេមិនផ្តល់ឱកាសម្តងទៀត ឱ្យឪពុករបស់គាត់ទាល់តែសោះ ឬយ៉ាងហោចណាស់ ក៏គួរគិតដល់វីរភាពរបស់ឪពុករបស់គាត់កាលពីអតីតកាលដែរ។

ចំពោះភាពអយុត្តិធម៌បែបនេះ ធ្វើឱ្យឪពុករបស់គាត់ កាន់តែពុះកញ្ជ្រោលមួម៉ៅក្តៅ

ក្រហាយ និងបញ្ចេញកំហឹងឱ្យឃើញកាន់តែច្បាស់ថែមទៀត ដោយឪពុករបស់គាត់បានសរសេរសំបុត្រ ជាបន្តបន្ទាប់ ទៅថ្វាយសម្តេចសីហនុ និងព្រះមាតាព្រះអង្គ គឺសម្តេចព្រះមហាក្សត្រិយានីកុសមៈ ហើយនៅក្នុងខ្លឹមសារសំបុត្រទាំងនោះ ឪពុករបស់គាត់ បានប្រើពាក្យពេចន៍កាន់តែធ្ងន់ឡើងៗជាលំដាប់ ចំពោះសម្តេចសីហនុ និងព្រះមាតារបស់ព្រះអង្គ។

សម រង្ស៊ី បានរម្លឹកថា អស់រយៈពេលជាច្រើនថ្ងៃ ក្រោយមក ឪពុករបស់គាត់ត្រូវបានគេអនុញ្ញាតឲ្យចូលក្នុងព្រះបរមរាជវាំង ក្រាបបង្គំសម្តេចព្រះមហាក្សត្រិយានីកុសមៈ ដើម្បីទូលថ្វាយបំភ្លឺពីមូលហេតុ បង្កឱ្យមានរឿងអាស្រូវ នៅក្នុងស្ថានទូតខ្មែរ ប្រចាំនៅចក្រភពអង់គ្លេស នោះ។ តែទោះបី ឪពុករបស់គាត់ព្យាយាមពន្យល់ថា មានមន្ត្រីមួយចំនួនបានរួមគំនិតគ្នា ធ្វើបាបគាត់ ក្នុងរឿងនេះយ៉ាងណា ក៏ដោយ ក៏សម្តេចសីហនុ និងព្រះមាតារបស់ព្រះអង្គ មិនស្តាប់ឪពុករបស់គាត់ដែរ គឺមានតែចោទប្រកាន់ និងទម្លាក់កំហុសមកលើឪពុករបស់គាត់តែប៉ុណ្ណោះ។

ពេលនោះហើយ កាន់តែធ្វើឱ្យឪពុករបស់គាត់ខឹងច្រឡោត ហើយនិយាយខ្លាំងៗទៅកាន់សម្តេចសីហនុ និងព្រះមហាក្សត្រិយានីកុសមៈ ពោលគឺឪពុករបស់គាត់បានចាប់ផ្តើមធ្លាក់ចូលក្នុងស្ថានភាពវណ្ណ.ក កាន់តែធ្ងន់ទៅៗ។

នៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ១៩៥៨ សម សារី ត្រូវបានសម្តេចសីហនុ ដកចេញពីតំណែងសមាជិកក្រុមប្រឹក្សារាជបល្ល័ង្ក ជាបន្តទៀត។ តែគាត់បានសរសេរសំបុត្រសារភាពនូវទោសកំហុសមួយ ថ្វាយព្រះអង្គថា៖ ព្រះករុណាជាអម្ចាស់! ទូលបង្គំបានប្រព្រឹត្តកំហុស ពុំគួរអត់ឱនឲ្យទាល់តែសោះ ព្រោះមិនបានទប់កំហឹង បណ្តាលឲ្យទូលបង្គំ ប្រកាន់អាកប្បកិរិយាមួយ ដែលទូលបង្គំដឹងថា មិនសមស្របនឹងការគោរពកោតខ្លាច និងការគោរពស្រលាញ់របស់ទូលបង្គំ ធ្លាប់តែមានចំពោះព្រះមហាក្សត្រិយានី និងព្រះករុណាជាអម្ចាស់ ជាអ្នកមានគុណលើទូលបង្គំ...។ តែអ្វី ដែលសម សារី បានទទួលមកវិញ គឺចម្លើយមួយយ៉ាងខ្លី ពីមន្ត្រីម្នាក់នៅក្នុងព្រះបរមរាជវាំង ត្រឹមតែពីរបីបន្ទាត់ប៉ុណ្ណោះ។

ដោយការអស់សង្ឃឹម និងការធ្លាក់ទឹកចិត្តជាខ្លាំង នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៥៨

សម សារី បានសម្រេចចិត្តសរសេរសំបុត្រមួយទៀត ថ្វាយទៅព្រះមហាក្សត្រិយានីកុសុមៈ និងសម្ដេច សីហនុ ដើម្បីសារភាពនូវទោសកំហុស ជាថ្មីម្ដងទៀតដែរ តែគ្មានបានលទ្ធផលអ្វីដដែល ។

តែទោះបី យ៉ាងណា ក៏ក្រោយពីត្រូវដកហូតតំណែងជាឯកអគ្គរាជទូត នៅប្រទេសអង់គ្លេស និងដកហូតតំណែងជាសមាជិកក្រុមប្រឹក្សារាជបល្ល័ង្ក មក សម សារី ត្រូវបានរាជរដ្ឋាភិបាលតែងតាំង ឲ្យទៅធ្វើជាមន្ត្រីតូចតាចមួយ នៅឯខេត្តមួយ ឆ្ងាយដាច់ស្រយាល។ សម សារី តូចចិត្ត គិតថា ការតែងតាំងឱ្យគាត់ទៅធ្វើជាមន្ត្រីតូចតាច នៅខេត្តឆ្ងាយដាច់ស្រយាលបែបនេះ គឺគ្រាន់តែដើម្បីបំបាក់មុខមាត់របស់គាត់ និងជម្លៀសខ្លួនគាត់ ឲ្យចេញទៅឆ្ងាយពីទីក្រុងភ្នំពេញ ដើម្បីកុំឲ្យគាត់មានលទ្ធភាពធ្វើនយោបាយបន្តទៀតតែប៉ុណ្ណោះ ដូច្នេះគាត់មិនព្រមទទួលតំណែងនោះជាដាច់ខាត។

ពេលនោះហើយ ភ្នាក់ងារសេអ៊ីអា(CIA) របស់សហរដ្ឋអាមេរិក និងមន្ត្រីស្ថានទូតវៀតណាមខាងត្បូង បានចាប់ផ្ដើមទាក់ទង និងអូសទាញសម សារី បន្តិចម្ដងៗ ដើម្បីធ្វើជាកម្លាំងស្នូលមួយ ក្នុងផែនការផ្ដួលរំលំសម្ដេចសីហនុ ចេញពីអំណាច។

នៅក្នុងវីឡាដ៏ស្កឹមស្កៃរបស់សម សារី ស្ថិតនៅតាមបណ្ដោយវិថីត្រសក់ផ្អែម និងនៅមិនឆ្ងាយប៉ុន្មាន ពីខាងត្បូង ខ្លោងទ្វារខាងក្រោយវត្តកោះ គាត់បានប្រមូលសហការី នៅតែស្មោះស្ម័គ្រជាមួយគាត់ មួយចំនួន ពិសេសគឺ ចៅ បុរី ជាមន្ត្រីជាន់ខ្ពស់មួយរូប តែត្រូវរដ្ឋាភិបាលដកហូតតំណែងដែរនោះ និងពាណិជ្ជករម្នាក់ទៀត ឈ្មោះ នេត ចន្ថា ឱ្យមករួមប្រជុំពិភាក្សាគ្នាពីរឿងនយោបាយ ស្ទើរតែរៀងរាល់ថ្ងៃ។

មិនយូរប៉ុន្មាន គាត់បានរៀបចំនៅជាន់ក្រោមដី ដាក់ម៉ាស៊ីនបោះពុម្ពតូចមួយ សម្រាប់បោះពុម្ពផ្សាយខិត្តបណ្ណផ្សេងៗ ពិសេសបោះពុម្ពផ្សាយកាសែត គាត់ទើបបង្កើតថ្មីមួយឈ្មោះកាសែតព្រស្ត្រាធិបតេយ្យ ជាជំហានដំបូង និងមានគម្រោងបង្កើតគណបក្សនយោបាយថ្មីមួយ ឈ្មោះគណបក្សបង្រួបបង្រួមខ្មែរអ្នកប្រជាធិបតេយ្យ ដើម្បីប្រដែងអំណាចជាមួយចលនាសង្គមរាស្ត្រនិយម ដឹកនាំដោយសម្ដេចសីហនុ ទៀតផង។

## របត់នយោបាយ

នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៥៨ កាសែតរាស្ត្រាធិបតេយ្យ របស់សម សារី ដោយមានស្ត្រីម្នាក់ ឈ្មោះនួន ចន្ទ្រី ឈរឈ្មោះជាចាងហ្វាងការផ្សាយ បានចាប់ផ្តើមចេញផ្សាយ៣ដងក្នុងមួយសប្តាហ៍ ហើយអត្ថបទសំខាន់ៗ នៅលើទំព័រកាសែតនេះ គឺ សម សារី ជាអ្នកសរសេរផ្ទាល់ ទាំងភាសាបារាំង ទាំងភាសាខ្មែរ ដោយគាត់បានសរសេររិះគន់រាជរដ្ឋាភិបាល និងទិតៀនការប្រើអំណាចជ្រុលហួសហេតុរបស់សម្តេចសីហនុ ។

សម សារី ចង់ឲ្យប្រទេសកម្ពុជា មានលទ្ធិប្រជាធិបតេយ្យ តាមបែបសភានិយម និងជារបបរាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញ ដូចប្រទេសអង់គ្លេស។ គាត់ចង់ឲ្យព្រះមហាក្សត្រខ្មែរ ធ្វើដូចព្រះមហាក្សត្រថៃ ឬដូចស្តេចអង់គ្លេស ពោលគឺ មិនលូកលាន់ចូលកិច្ចការរបស់នយោបាយរបស់ប្រទេសជាតិ។

សម សារី បានសរសេរទិតៀនថា សម្តេចសីហនុ បង្កើតចលនាសង្គមរាស្ត្រនិយម ហើយបានប្រាប់គេឯងថា មិនមែនជាគណបក្សនយោបាយ តែជាចលនាបង្រួបបង្រួមជាតិមួយ និងការបង្កើតឲ្យមានសមាជជាតិ៦ខែម្តងនោះ គឺគ្រាន់តែដើម្បីកាត់បន្ថយអំណាចសភា តែប៉ុណ្ណោះ។

សម្តេចសីហនុ បានអនុវត្តនយោបាយសង្គមនិយមព្រះពុទ្ធសាសនា ដោយចាត់ទុកព្រះអង្គខ្លួនឯង ជាព្រះបិតាជាតិគ្រប់គ្រងអំណាចតែអង្គឯង មានសិទ្ធិសម្រេចអ្វីៗតាមទំនើងចិត្ត គឺជាការប្រាសចាកពីគោលនយោបាយសភានិយម ដើម្បីឆ្ពោះទៅរកអំណាចផ្តាច់ការប៉ុណ្ណោះ ហើយថា មូលហេតុសម្តេចសីហនុ កាន់តំណែងជានាយករដ្ឋមន្ត្រីផង ជាប្រមុខរដ្ឋផង គឺគ្មានអ្វីក្រៅតែពីការពង្រឹងអំណាចអង្គឯងនោះឡើយ។

សម សារី បានសរសេរទិតៀនសម្តេចសីហនុ ទៀតថា នៅក្នុងឆ្នាំ១៩៥៥ ពោលគឺមួយឆ្នាំ ក្រោយមានសន្និសីទក្រុងហ្សឺណែវ ព្រះអង្គមិនគោរពគោលនយោបាយអព្យាក្រឹតភាពនិងអធិបតេយ្យភាពកម្ពុជាទេ ព្រះអង្គបានយាងទៅចូលប្រជុំនៅក្នុងសន្និសីទបណ្តាប្រទេសមិនចូលបក្សសម្ព័ន្ធនៅក្រុងបានឌុង ប្រទេសឥណ្ឌូនេស៊ី និងបានជួបជាមួយនាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ ។ តាំងពីពេលនោះមក ទំនាក់ទំនងកម្ពុជា និងចិន ចេះតែជិតស្និទ្ធ

គ្នាជាលំដាប់ រហូតប្រទេសទាំងពីរឈានដល់ការផ្សារទំនាក់ទំនងការទូតជាផ្លូវការ ហើយប្រទេសចិន ក៏បានផ្តល់ជំនួយសេដ្ឋកិច្ចជាច្រើនដល់ប្រទេសកម្ពុជា។

ការខិតទៅជិតចិន ជាសម្ព័ន្ធមិត្តរបស់វៀតណាមខាងជើងនេះ អាចរុញច្រានប្រទេសខ្មែរយើង ឲ្យធ្លាក់ចូលក្នុងសង្គ្រាមនៅវៀតណាម ដោយចៀសមិនរួច...។

# ១១០
# អាមេរិក រៀបចំផែនការផ្តួលរំលំសម្តេចសីហនុ



**នាយកភ្នាក់ងារសេអ៊ីអេ អាល់ឡិន ឌុល្លេស** (រូបថត flickr)

ពេលសម្តេចសីហនុ ចេះតែបន្តរិះគន់ទៅលើអង្គការសេអាតូ (SEATO) និងនៅតែប្រកាសគោលជំហរអព្យាក្រឹត តែខិតចូលទៅរកប្រទេសចិនកុម្មុយនិស្តកាន់តែជិតស្និទ្ធឡើងៗនោះ សហរដ្ឋអាមេរិក មិនត្រឹមតែសម្រេចផ្អាកការផ្តល់ជំនួយយោធាដល់កម្ពុជា ប៉ុណ្ណោះទេ គឺថែមទាំងញុះញង់ប្រទេសថៃ និងវៀតណាមខាងត្បូង ហ៊ុមពទ្ធសេដ្ឋកិច្ចកម្ពុជា ដោយប្រទេសទាំង២នេះមិនអនុញ្ញាតឱ្យយន្តហោះដឹកទំនិញមកពីប្រទេសនានាផ្សេងៗទៀតហោះឆ្លងកាត់ដែនអាកាសរបស់ខ្លួន ពិសេសប្រទេសវៀតណាមខាងត្បូង បិទច្រកទន្លេមេគង្គ មិនឱ្យនាវាដឹកទំនិញបរទេសចូលមកកំពង់ផែភ្នំពេញ។

ជាមួយគ្នានេះដែរ ប្រទេសថៃ និងវៀតណាមខាងត្បូង បានឱ្យកងទ័ពចូលមករំលោភឈ្លានពានមកលើដែនអធិបតេយ្យកម្ពុជាទាំងដែនគោកទាំងដែនអាកាស តាមបណ្តោយព្រំដែនភាគខាងកើតខាងត្បូង និងខាងលិចប្រទេសទៀតផង។ មិនតែប៉ុណ្ណោះ ពួកគេបាន

បំភិតបំភ័យថា សង្គ្រាមប្រឆាំងកម្ពុជា នឹងផ្ទុះឡើងនាពេលឆាប់ៗនេះជាមិនខាន។

ចាប់ពីខែមករា ដល់ខែមិថុនា ឆ្នាំ១៩៥៨ ប្រធានាធិបតីវៀតណាមខាងត្បូង ង៉ូ ឌិញយៀម ( Ngo Dinh Diem ) បានបញ្ជាឱ្យកងទ័ពខ្លួនចូលមករំលោភក្នុងដែនអធិបតេយ្យកម្ពុជា ចំនួន២៩លើក។ បន្ទាប់មក នៅក្នុងខែកក្កដា ឆ្នាំ១៩៥៨ រដ្ឋាភិបាលក្រុងព្រៃនគរបានបញ្ជូនទាហានចំនួន ៣,០០០នាក់ទៀតឱ្យចូលមករំលោភឈ្លានពានក្នុងទឹកដីខេត្តស្ទឹងត្រែង ក្នុងជម្រៅចម្ងាយ១៥គីឡូម៉ែត្រពីខ្សែបន្ទាត់ព្រំដែនរបស់កម្ពុជា។

ក្នុងខែកក្កដា ឆ្នាំ១៩៥៨ សម្ដេចសីហនុបានផ្ញើលិខិតមួយច្បាប់ទៅនាយករដ្ឋមន្ត្រី ជូ អេនឡាយ ដោយស្នើឱ្យចិន ឱ្យមានទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរដល់ថ្នាក់ឯកអគ្គរដ្ឋទូត និងឯកអគ្គរាជទូត។ នាយករដ្ឋមន្ត្រីចិន បានឆ្លើយតប និងយល់ព្រមដោយរីករាយបំផុត ហើយប្រទេសទាំងពីរក៏កាន់មានទំនាក់ទំនងជិតស្និទ្ធនឹងគ្នាកាន់តែស្អិតរមួតឡើងៗជាលំដាប់។

ចំណែកនៅភាគខាងលិចប្រទេសវិញ ចន្លោះខែមីនា ដល់ខែឧសភា ឆ្នាំ១៩៥៨ រាជរដ្ឋាភិបាលក្រុងបាងកក ដែលមាន សារិត ថាណារ៉ាត់ (Sarit Thanarat) ជានាយករដ្ឋមន្ត្រី បានបញ្ជាឱ្យកងទ័ពខ្លួន ចូលមករំលោភឈ្លានពានក្នុងទឹកដីកម្ពុជា ចំនួន៦លើក។ មិនតែប៉ុណ្ណោះ ពួកអ្នកនយោបាយជ្រុលនិយមថៃ បានបំផុសបំផុលឱ្យមានការប្រឆាំងនឹងកម្ពុជា និងទាមទារឱ្យរាជរដ្ឋាភិបាលក្រុងបាងកក ធ្វើយ៉ាងណាយកខេត្តបាត់ដំបង និងខេត្តសៀមរាប របស់កម្ពុជា ឱ្យទៅជារបស់គេទាល់តែបាន។ ដោយសារការបះបោរទាមទាររបស់ពួកអ្នកនយោបាយជ្រុលនិយមថៃ កាន់តែរីករាលដាលខ្លាំងឡើងៗ រាជរដ្ឋាភិបាលក្រុងបាងកក បានប្រកាសបិទព្រំដែន និងដាក់ខេត្តជាប់ជាមួយព្រំដែនកម្ពុជា ចំនួន៦ ឱ្យស្ថិតនៅក្នុងភាពអាសន្ន។

នៅខែវិច្ឆិកា ឆ្នាំ១៩៥៨ ដោយសារតែមូលហេតុខាងលើនេះ កម្ពុជា ត្រូវបង្ខំចិត្តផ្ដាច់ទំនាក់ទំនងការទូតជាមួយប្រទេសថៃ ជាបណ្ដោះអាសន្ន។ ដើម្បីដោះស្រាយបញ្ហារំលោភឈ្លានពានមកលើអធិបតេយ្យភាពបូរណភាពទឹកដីកម្ពុជា យ៉ាងព្រហើនកោងកាចនេះ សម្ដេច



**ប្រធានាធិបតីវៀតណាមខាងត្បូង ង៉ូ ឌិញយៀម** (រូបថត flickr)

សីហនុ បានស្នើអាមេរិកឱ្យប្រើប្រាស់ឥទ្ធិពលរបស់ខ្លួនធ្វើយ៉ាងណាឱ្យប្រធានាធិបតីវៀតណាមខាងត្បូង ង៉ូ ឌិញយៀម (Ngo Dinh Diem) ជាសម្ព័ន្ធមិត្ររបស់ខ្លួន បញ្ឈប់សកម្មភាពរំលោភឈ្លានពានមកលើអធិបតេយ្យភាព បូរណភាពទឹកដីកម្ពុជា បន្តទៀត។ ប៉ុន្តែ ឯកអគ្គរដ្ឋទូតអាមេរិកខាល ស្ត្រូម (Carl W. Strom) បានឆ្លើយតបថា៖ «សហរដ្ឋអាមេរិក មិនអាចចូលជ្រៀតជ្រែកនៅក្នុងជម្លោះរវាងប្រទេសជិតខាងទាំងពីរ ដែលជាមិត្តរបស់ខ្លួនបានទេ» ហើយថា៖ «ជំនួយយោធាដែលអាមេរិកផ្តល់ឱ្យកម្ពុជា សម្រាប់តែប្រើប្រាស់ប្រឆាំងនឹងពួកកុម្មុយនិស្តតែប៉ុណ្ណោះ មិនត្រូវប្រើប្រាស់សម្រាប់ប្រឆាំងជាមួយប្រទេសជាសម្ព័ន្ធមិត្តរបស់អាមេរិក ឡើយ។ មិនតែប៉ុណ្ណោះ ឯកអគ្គរដ្ឋទូតអាមេរិករូបនេះ បានគំរាមថា៖ «ប្រសិនបើកងទ័ពកម្ពុជា យកគ្រាប់កាំភ្លើងជាជំនួយរបស់អាមេរិក តែមួយគ្រាប់ ទៅបាញ់លើកងទ័ពវៀតណាមខាងត្បូង ឬសូម្បីតែយករថយន្តតែមួយគ្រឿងជាជំនួយអាមេរិក ដឹកកងទ័ពទៅប្រយុទ្ធជាមួយកងទ័ពវៀតណាមខាងត្បូងនោះ អាមេរិកនឹងលុបចោលជំនួយទាំងអស់មិនខាន»។ សម្តេចសីហនុ បានវាយបកទៅវិញថា៖ «បើមិនឱ្យកម្ពុជា ប្រើប្រាស់អាវុធជំនួយដើម្បីប្រយុទ្ធនឹងសត្រូវ គឺមានន័យថា សហរដ្ឋអាមេរិក កំពុងជាន់ពន្លិចកម្ពុជា និងរុញច្រាន



**ទាហានវៀតណាមខាងត្បូង** (រូបថតវៀតណាម)

ប្រទេសព្រះអង្គឱ្យទៅក្នុងដៃពួកកុម្មុយនិសយ៉ាងពិតប្រាកដ »។

ខាល ស្ត្រូម (Carl W. Strom) មកទទួលតំណែងជាឯកអគ្គរដ្ឋទូតអាមេរិកប្រចាំកម្ពុជា ពីថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៥៦ ដល់ថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៥៩។

ក្នុងគោលបំណងផ្តួលរំលំសម្តេចសីហនុ មកនៅចុងឆ្នាំ១៩៥៨ សហរដ្ឋអាមេរិកបានបញ្ចុះបញ្ចូលឱ្យប្រធានាធិបតីវៀតណាមខាងត្បូង ង៉ូ ឌិញយៀម និងនាយកមន្ត្រីថៃ សារិត ថាណារ៉ាត ជួយគាំទ្រចលនា «ខ្មែរសេរី» ក្រោមការដឹកនាំរបស់ សឺង ង៉ុកថាញ់ តាមរយៈការផ្តល់ទីតាំងកសាងជំរំហ្វឹកហ្វឺនកងទ័ព និងបង្កើតឱ្យមានស្ថានីយវិទ្យុផ្សាយសំឡេងដើម្បីឃោសនាប្រឆាំងតបតនឹងនយោបាយរបស់សម្តេចសីហនុ តាមរលកធាតុអាកាសវិញ។ ផែនការផ្តួលរំលំសម្តេចសីហនុ នេះ មានពួកភ្នាក់ងារសម្ងាត់សេអ៊ីអា(CIA) មកសហការអនុវត្តផ្ទាល់តែម្តង។

នៅថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៥៩ សម្តេចសីហនុ បានទម្លាយការណ៍សម្ងាត់ថា

## របត់នយោបាយ



**នាយករដ្ឋមន្ត្រីថៃ សារិត ថាណារ៉ាត**
(រូបថត wikipedia)

ព្រះអង្គបានដឹងអំពីផែនការធ្វើរដ្ឋប្រហារទម្លាក់ព្រះអង្គ ដែលរៀបចំឡើងដោយនាយករដ្ឋមន្ត្រីថៃ សារិត ថាណារ៉ាត(Sarit Thanarat) ជាមួយនឹងពួកសេអ៊ីអារបស់អាមេរិក។

នៅព្រឹកថ្ងៃទី ២០ ខែមករា ឆ្នាំ ១៩៥៩ ក្នុងវេទិកាប្រជុំប្រជារាស្ត្រមួយ នៅខេត្តកំពង់ចាម ដោយមានចាក់ផ្សាយជាសាធារណៈតាមវិទ្យុជួចសព្វដងនោះ សម្តេចសីហនុ បានថ្លែងប្រកាសថា សម សារី រួមគំនិតជាមួយបរទេស ក្បត់ជាតិខ្លួនឯង។

ភ្លាមៗនោះដែរ រដ្ឋសភាក៏បានបើកកិច្ចប្រជុំបោះឆ្នោតជាឯកច្ឆន្ទថា សម្រេចឲ្យកម្លាំងសមត្ថកិច្ចតាមចាប់ខ្លួនសម សារី ជាជនក្បត់ជាតិ យកមកកាត់ទោសតាមច្បាប់។

នៅថ្ងៃទី២១ ខែមករា ឆ្នាំ១៩៥៩ ព្រះមហាក្សត្រនរោត្តម សុរាម្រិត មានបន្ទូលជាសាធារណៈ ប្រាប់ប្រជារាស្ត្រឱ្យបានដឹងពីផែនការក្បត់របស់ សម សារី ហើយព្រះអង្គបានអំពាវនាវឱ្យប្រជារាស្ត្រគ្រប់ស្រទាប់វណ្ណៈ រក្សាភាពស្ងៀមស្ងាត់ កុំឱ្យមានការជ្រួលច្របល់អ្វីឱ្យសោះ។

នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៥៩ ដោយមានការសម្របសម្រួលពីអង្គការសហប្រជាជាតិ សម្តេចសីហនុ ក៏យល់ព្រមផ្សារទំនាក់ទំនងការទូតជាមួយប្រទេសថៃ ឡើងវិញ ក្រោយពីទំនាក់ទំនងការទូតនេះ ត្រូវកាត់ផ្តាច់កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៥៨ ដោយសារការរំលោភបំពានរបស់ថៃ មកលើប្រាសាទព្រះវិហារ។

ប្រភពពីមន្ត្រីជាន់ខ្ពស់ម្នាក់ក្នុងសម័យនោះ បានអះអាងថា នៅថ្ងៃទី០៦ ខែមករា

ឆ្នាំ១៩៥៩ នៅពេលសម្តេចសីហនុ និងឧត្តមនាវីឯក ហ្វេលត៍(Felt) ជាមេបញ្ជាការកងទ័ពជើងទឹករបស់សហរដ្ឋអាមេរិក ប្រចាំមហាសមុទ្រប៉ាស៊ីហ្វិក កំពុងចូលរួមជាអធិបតី ក្នុងពិធីរម្លឹកខួបកំណើតថ្ងៃភ្ជាប់ទំនាក់ទំនងការទូត និងសហប្រតិបត្តិការនៃប្រទេសទាំងពីរ នៅលង្វែក ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ នៅក្រុងភ្នំពេញ ឯណោះ សម សារី បានទទួលជួបភារធារីស្ថានទូតអាមេរិក ឈ្មោះ វ៉ិចទ័រ ម៉ាត់ស៊ូ និងមេភ្នាក់ងារសេ.អ៊ី.អា(CIA) របស់សហរដ្ឋអាមេរិកម្នាក់ដែរនោះ នៅនឹងផ្ទះរបស់គាត់ផ្ទាល់ ដើម្បីរៀបចំផែនការសម្លាត់ផ្តួលរំលំសម្តេចសីហនុ។ ប៉ុន្តែ មិនបានប៉ុន្មានថ្ងៃផង ក៏មានមន្ត្រីការទូតចិន និងបារាំងប្រចាំនៅទីក្រុងភ្នំពេញ បានលួចផ្តល់ព័ត៌មានសម្ងាត់បំផុតនេះ ឱ្យសម្តេចសីហនុ បានដឹងជាមុន។

ភ្លាមៗនោះ សម្តេចសីហនុ ក៏បានបញ្ជាឱ្យកម្លាំងសមត្ថកិច្ចចម្រុះចុះទៅចាប់ សម សារី និងបក្ខពួកផ្សេងៗទៀត ប៉ុន្តែសម សារី និងសហការីជំនិតរបស់គាត់ម្នាក់ ឈ្មោះចៅ បូរី ត្រូវបានមន្ត្រីស្ថានទូតវៀតណាមខាងត្បូង ជួយធ្វើអន្តរាគមន៍ជម្លៀស យកចេញទៅប្រទេសវៀតណាមខាងត្បូង ដោយសុវត្ថិភាព។

# ១១១
# យួនខាងត្បូង និងថៃ ឱ្យសឹង ង៉ុកថាញ់ សហការជាមួយសម សារី និងដាប ឈួន



**នាយកត្ថាក់ខារសេអ៊ីអា អាល់ឡឺន ឌុល្លេស** (រូបថត flickr)

ក្នុងអំឡុងពេលពាក់កណ្ដាលឆ្នាំ១៩៥៨ ដោយដឹងថា សឹង ង៉ុកថាញ់ ជាមនុស្ស មានប្រជាប្រិយល្បីល្បាញក្នុងសង្គមខ្មែរ និងជាអ្នកប្រឆាំងសម្ដេចសីហនុ យ៉ាងប្ដូរផ្ដាច់ផង នោះ ប្រធានាធិបតីវៀតណាមខាងត្បូង ង៉ូ ឌិញយៀម បានបញ្ជូនតំណាងឲ្យមកទាក់ទង សឹង ង៉ុកថាញ់ កំពុងដឹកនាំសហការីរបស់គាត់ ៥នាក់ទៀត កាប់ឆ្ការព្រៃធ្វើចម្ការ នៅស្រុក ឡុកនិញ ខេត្តវិញឡុង ដើម្បីជួបពិភាក្សាគ្នាពីបញ្ហាសម្ងាត់មួយ ។

បន្ទាប់មក ប្រធានាធិបតីរូបនេះ ក៏បានអញ្ជើញសឹង ង៉ុកថាញ់ ឲ្យទៅជួបផ្ទាល់ នៅ វិមានដុកឡាប់(វិមានឯករាជ្យ)នៅទីក្រុងព្រៃនគរ ដើម្បីពិភាក្សាគ្នាពីផែនការសម្ងាត់មួយ

ស្តីពីការបង្កើតចលនាតស៊ូមួយប្រឆាំងនឹងការដឹកនាំប្រទេសកម្ពុជា របស់សម្តេចសីហនុ ដោយសហការជាមួយសម សារី ទើបដកតំណែងជាឯកអគ្គរាជទូតខ្មែរ នៅប្រទេសអង់គ្លេស ឱ្យមកក្រុងភ្នំពេញ វិញ និងដាប ឈួន ត្រូវបញ្ចុះតំណែងពីទេសរដ្ឋមន្ត្រី ឱ្យទៅជាព្រះរាជប្រតិភូទទួលបន្ទុកខេត្តសៀមរាបវិញ ដើម្បីផ្តួលរំលំសម្តេចសីហនុ ចេញពីអំណាច ។

ផែនការផ្តួលរំលំសម្តេចសីហនុ នេះ នៅខាងក្នុងប្រទេស មានឯកអគ្គរដ្ឋទូតយួនខាងត្បូង ប្រចាំនៅក្រុងភ្នំពេញ ឈ្មោះង៉ូ ត្រុងហៀវ ជាអ្នកជួយចាត់ចែងផ្ទាល់ជាមួយសម សារី ។ ចំណែក ដាប ឈួន នៅខេត្តសៀមរាប ក្រៅពីឯកអគ្គរដ្ឋទូតយួនខាងត្បូង ប្រចាំនៅក្រុងភ្នំពេញ ក៏មានរាជរដ្ឋាភិបាលថៃ ជាអ្នកជួយធ្វើអន្តរាគមន៍ផងដែរ។

ពេលនោះ សឺង ង៉ុកថាញ់ បានយល់ព្រមបង្កើតចលនាតស៊ូ ដើម្បីប្រឆាំងនឹងសម្តេចសីហនុ តែបញ្ជាឱ្យគាត់រួមសហការជាមួយសម សារី និងដាប ឈួន គាត់សុំយកបញ្ហានេះទៅពិចារណាជាមួយសហការីរបស់គាត់សិន ព្រោះគាត់មិនបានដឹងគម្រោងការនេះ ពីមុនផង ម្យ៉ាងទៀតគាត់ដឹងច្បាស់ថា សម សារី និងដាប ឈួន ជាមនុស្សជិតស្និទ្ធជាមួយសម្តេចសីហនុ និងធ្លាប់ចាត់វិធានការបង្ក្រាបមកលើចលនាតស៊ូរបស់គាត់ និងមន្ត្រីគណបក្សប្រជាធិបតេយ្យ ពិសេស ដាប ឈួន បានបញ្ជាឱ្យទាហាននៅក្រោមបញ្ជាទៅឱ្យបាញ់សម្លាប់កៅ តក់ ជាអតីតមេបញ្ជាការចលនាតស៊ូរបស់គាត់យ៉ាងព្រៃផ្សៃបំផុត។

មិនតែប៉ុណ្ណោះ ដាប ឈួន ក៏មានឈ្មោះអាក្រក់ថា ជាមេចោរប្លន់ និងចាប់រំលោភកូនក្រមុំអ្នកស្រុក តាមអំពើចិត្ត កាលពីសម័យគេធ្វើមេខ្មែរឥស្សរៈតស៊ូប្រឆាំងនឹងបារាំងមកដែរ។ តែយ៉ាងណា ក្នុងពេលជួបសន្ទនាគ្នានោះ សឺង ង៉ុកថាញ់ ឆ្លៀតឱកាសស្នើសុំប្រធានាធិបតី ង៉ូ ឌិញយៀម ឱ្យបញ្ឈប់ការធ្វើបាបគំរាមកំហែង បង្ខិតបង្ខំបងប្អូនខ្មែរកម្ពុជាក្រោម ឱ្យចូលសញ្ជាតិជាជនជាតិវៀតណាម ផងដែរ ព្រោះបើមិនដូច្នេះទេ បងប្អូនខ្មែរកម្ពុជាក្រោម នឹងនាំគ្នាងើបឡើងបះបោរប្រឆាំងតបតវិញ នឹងធ្វើឱ្យសភាពការណ៍នៅវៀតណាមខាងត្បូង កាន់លុបចេញតែរីករវថែមទៀត ជាមិនខាន។

ក្រោយពីមានការស្នើសុំរបស់សឺង ង៉ុកថាញ់ នោះមក រដ្ឋការវៀតណាមខាងត្បូង ក៏

បានអនុញ្ញាតឲ្យបងប្អូនខ្មែរកម្ពុជាក្រោម មានសិទ្ធិសេរីភាពក្នុងការធ្វើបុណ្យទានតាមវត្តអារាមនានា និងលែងសូវធ្វើបាបគំរាមកំហែង បង្ខិតបង្ខំបងប្អូនខ្មែរកម្ពុជាក្រោម ឱ្យចូលសញ្ជាតិជាជនជាតិវៀតណាម ដូច សឺង ង៉ុកថាញ់ បានស្នើសុំប្រធានាធិបតី ង៉ូ ឌិញយៀម នោះពិតមែន។

ទន្ទឹមនោះ ប្រធានាធិបតី ង៉ូ ឌិញយៀម បានចាត់តំណាងឲ្យមកជួបសឺង ង៉ុកថាញ់ មួយលើក ជាពីរលើកបន្តទៀត ព្រោះចង់បានចម្លើយថា តើគាត់យល់ព្រមសហការជាមួយសម សារី និងដាប ឈួន ដើម្បីផ្តួលរំលំសម្តេចសីហនុ ចេញពីអំណាច នោះហើយឬនៅ? តែសឺង ង៉ុកថាញ់ នៅតែឆ្លើយទៅវិញថា គាត់កំពុងធ្វើការពិចារណាឲ្យបានល្អិតល្អន់សិន មិនទាន់អាចសម្រេចចិត្តបាននៅឡើយទេ។

ការពន្យារពេលរបស់សឺង ង៉ុកថាញ់ ក្នុងការឆ្លើយយល់ព្រមតាមបំណងរបស់ប្រធានាធិបតី ង៉ូ ឌិញយៀម នេះ គាត់មានហេតុផល២ គឺ៖

ទី១. គាត់មិនចង់ប្រឡូកប្រឡាក់ក្នុងការផ្តួលរំលំសម្តេចសីហនុ ជាមួយសម សារី និងដាប ឈួន ព្រោះគាត់ក៏មិនចង់ទទួលថ្មបាក់ដែរ។

ទី២. គាត់ដឹងថា តំណាងរាជរដ្ឋាភិបាលថៃ ក៏មានបំណងចង់មកជួបចរចា ដើម្បីឱ្យគាត់សហការជាមួយដាប ឈួន ក្នុងផែនការផ្តួលរំលំសម្តេចសីហនុ នេះដែរ។ ដូច្នេះ គាត់ចង់ឱ្យតំណាងរាជរដ្ឋាភិបាលថៃ ជាអ្នកគាំទ្រដាប ឈួន មកជួបគាត់ដោយផ្ទាល់ ព្រោះដាប ឈួន ជាមនុស្សមិនគួរឱ្យទុកចិត្ត និងជាមនុស្សពិបាកធ្វើការជាមួយណាស់។ ហេតុនេះ នៅពេលតំណាងរាជរដ្ឋាភិបាលថៃ មកជួបចរចាជាមួយគាត់ នៅទីក្រុងព្រៃនគរ គាត់នឹងមានឱកាសដាក់លក្ខខណ្ឌមួយចំនួន ទៅរាជរដ្ឋាភិបាលថៃ ផងដែរ។

ក្រោយពីបានជួបពិភាក្សាជាមួយប្រធានាធិបតី ង៉ូ ឌិញយៀម នៅពាក់កណ្តាលឆ្នាំ ១៩៥៨ ស្តីពីការបង្កើតចលនាតស៊ូនោះ សឺង ង៉ុកថាញ់ ក៏បានផ្តល់ដំណឹងទៅឡឹក សំអឿន កំពុងធ្វើការនៅក្រុមហ៊ុនឈើហ៊ុប ក្នុងប្រទេសឡាវ ឲ្យត្រៀមខ្លួន ដើម្បីចាត់ចែងបង្កើតចលនាតស៊ូឡើងវិញ នៅភ្នំដងរែក ជាមូលដ្ឋានតស៊ូចាស់របស់ពួកគាត់ពីមុនមក

នោះ។

មិនយូរប៉ុន្មាន មានតំណាងរាជរដ្ឋាភិបាលថៃម្នាក់ បានទៅទាក់ទងឡឹក សំអឿន កំពុងធ្វើការ នៅក្រុមហ៊ុនឈើហ៊ុប នៅទីក្រុងវៀងចន្ទ ប្រទេសឡាវ ដើម្បីស្នើសុំឲ្យគាត់ជូនពួកគេទៅជួបសឺង ង៉ុកថាញ់ នៅឯកម្ពុជាក្រោម(វៀតណាមខាងត្បូង)។

ឡឹក សំអឿន ក៏យល់ព្រម និងបានសុំច្បាប់ពីប្រធានក្រុមហ៊ុនឈើហ៊ុបនោះ ចំនួនមួយសប្តាហ៍ ហើយបានធ្វើដំណើរជាមួយតំណាងរាជរដ្ឋាភិបាលថៃ ម្នាក់នោះ ទៅក្រុងបាងកក ក្នុងថ្ងៃដដែលនោះ។ លុះស្អែកឡើង គាត់បានបន្តដំណើរតាមយន្តហោះ ជាមួយតំណាងរាជរដ្ឋាភិបាលថៃ ពីររូប ចេញពីក្រុងបាងកក ឆ្ពោះទៅទីក្រុងព្រៃនគរ(ក្រុងសៃហ្គន) ប្រទេសវៀតណាមខាងត្បូង។

នៅអាកាសយានដ្ឋានតឺន សឺនញ៉ឹត ក្រុងព្រៃនគរ មានរថយន្តស្ថានទូតព្រះរាជាណាចក្រថៃ ប្រចាំសាធារណរដ្ឋវៀតណាមខាងត្បូង មករង់ចាំទទួលពួកគាត់ទាំងបីនាក់ យកទៅកាន់សណ្ឋាគារមួយ។ បន្ទាប់ពីទៅដល់សណ្ឋាគារ បានបន្តិច ឡឹក សំអឿន ក៏បានធ្វើដំណើរម្នាក់ឯង ទៅជួបសឺង ង៉ុកថាញ់ កំពុងស្ថិតនៅក្នុងគេហដ្ឋានរបស់គាត់ នៅជាយទីក្រុងព្រៃនគរ ដើម្បីជម្រាបពីគោលបំណង របស់តំណាងរាជរដ្ឋាភិបាលថៃ ត្រូវមកសុំជួបគាត់ ដោយបន្ទាន់បែបនេះ ព្រមទាំងសុំឱ្យគាត់ទៅជួបគ្នានៅសណ្ឋាគារនោះ និងបានពិភាក្សាជាមួយសឺង ង៉ុកថាញ់ ពីបញ្ហាសំខាន់ៗមួយចំនួនផងដែរ។

នៅពេលពិភាក្សាគ្នានោះ ទើប ឡឹក សំអឿន ដឹងថា តំណាងរាជរដ្ឋាភិបាលថៃ បានស្នើសុំជួប សឺង ង៉ុកថាញ់ ចំនួន២លើក រួចមកហើយ តែគាត់មិនព្រមឱ្យជួប។ មូលហេតុមិនព្រមជួបនេះ ដោយសារៈ

ទី១. សឺង ង៉ុកថាញ់ ចង់ឲ្យតំណាងរាជរដ្ឋាភិបាលថៃ ទាក់ទងជួបគាត់ (ឡឹក សំអឿន)ជាមុនសិន។

ទី២. សឺង ង៉ុកថាញ់ មិនចង់ឲ្យចលនាតស៊ូថ្មី ត្រូវបង្កើតឡើងនោះ ជាប់ពាក់ព័ន្ធជាមួយផែនការវៀតណាម និងថៃ ឱ្យសម សារី និងដាប ឈួន នៅក្នុងប្រទេស ផ្តួលរំលំ

សម្តេចសីហនុ ចេញពីអំណាច តាមបំណងរបស់ប្រធានាធិបតី ង៉ូ ឌិញយៀម នោះទេ។

ទី៣. សឹង ង៉ុកថាញ់ ចង់ពន្យារពេល ដើម្បីពិនិត្យស្រាវជ្រាវពីសកម្មភាពរបស់សម សារី និងដាប ឈួន ជាមនុស្សព្រហើនកោងកាច ដែលរដ្ឋាភិបាលវៀតណាមខាងត្បូង និងថៃ ជំរុញឱ្យផ្តួលរំលំសម្តេចសីហនុ ចេញពីអំណាចនោះ ថា តើទៅថ្ងៃក្រោយ ទាំង២នាក់នេះ អាចនឹងបង្កឲ្យមានគ្រោះថ្នាក់ដល់ចលនាតស៊ូរបស់គាត់ដែរឬទេ?

ទី៤. សឹង ង៉ុកថាញ់ ចង់ឱ្យតំណាងរដ្ឋាភិបាលវៀតណាមខាងត្បូង និងតំណាងរាជរដ្ឋាភិបាលថៃ ជាអ្នកឧបត្ថម្ភគាំទ្រ សម សារី មកជួបគាត់ ដើម្បីគាត់មានលទ្ធភាពក្នុងការដាក់លក្ខខណ្ឌមួយចំនួន ពិសេសគឺ ដាក់លក្ខខណ្ឌ កុំឱ្យវៀតណាមខាងត្បូង និងថៃ ចូលជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់ចលនាតស៊ូរបស់គាត់ នៅពេលអនុវត្តផែនការនោះ។ បន្ទាប់ពីប្រាប់ឡឹក សំអឿន ពីមូលហេតុទាំង៤ ខាងលើនេះមក សឹង ង៉ុកថាញ់ ក៏បានពន្យល់អំពីស្ថានការណ៍នយោបាយបច្ចុប្បន្ន ទាំងនៅក្នុង និងក្រៅប្រទេស ឱ្យឡឹក សំអឿន បានដឹង ព្រមទាំងដាក់ផែនការសំខាន់ៗមួយចំនួន ដើម្បីឱ្យឡឹក សំអឿន សហការជាមួយសម្ព័ន្ធមិត្តថៃ យកទៅអនុវត្ត ផងដែរ។

ជាមួយគ្នានោះ សឹង ង៉ុកថាញ់ បានលើកយកពាក្យកំណាព្យមួយ និពន្ធដោយព្រះរាជសម្ភារ ថា៖ «កុំទុកចិត្តបរទេស កុំទុកចិត្តអភិនេស្រ្តម៍ កុំទុកចិត្តអភិប្រាយ ប្រើទំលែងខ្ពស់ រំពឹងឱ្យឆ្ងាយ ស្តាប់ពាក្យបរិយាយ បណ្តាំមេដី» មានន័យថា កុំទុកចិត្តមនុស្សឱ្យសោះទោះបីក្នុងប្រភេទណាក៏ដោយ មកឱ្យឡឹក សំអឿន ធ្វើការពិចារណា។ សឹង ង៉ុកថាញ់ បញ្ជាក់បន្ថែមថា បរទេសជួយយើង ដើម្បីផលប្រយោជន៍គេ។ ចំណែកយើង ក៏ជួយគេដើម្បីផលប្រយោជន៍របស់យើងដែរ។ ប៉ុន្តែ យើងមិនត្រូវឲ្យគេលូកដល់ថ្លើមប្រមាត់បេះដូងរបស់យើង ជាដាច់ខាត។ ជាមួយគ្នានេះ យើងត្រូវតែព្យាយាមចៀសវាងការបង្ហូរឈាមខ្មែរគ្នាឯង ប្រសិនបើអាចចៀសរួច ព្រោះការសម្លាប់ខ្មែរគ្នាឯង មិនមែនជាវិធីដោះស្រាយបញ្ហាជាតិនោះឡើយ។

ក្រោយពីទទួលទានបាយល្ងាច ជាមួយក្រុមគ្រួសារសឹង ង៉ុកថាញ់ រួចមក ឡឹក សំ

អឿន ក៏លាត្រលប់មកសណ្ឋាគារវិញ ដើម្បីផ្តល់ដំណឹងឱ្យតំណាងរាជរដ្ឋាភិបាលថៃ ទាំងពីររូបនោះ បានដឹងថា សឺង ង៉ុកថាញ់ យល់ព្រមជួបពិភាក្សាគ្នានៅព្រឹកស្អែកនេះ។ លុះស្អែកឡើង វេលាម៉ោង១០ព្រឹក សឺង ង៉ុកថាញ់ ក៏បានអញ្ជើញមកដល់សណ្ឋាគារ ដែលតំណាងរាជរដ្ឋាភិបាលថៃ ស្នាក់នៅនោះ ហើយបានចូលប្រជុំក្នុងបន្ទប់តូចមួយ ដោយមន្ត្រីស្ថានទូតថៃ បានមករៀបចំទុករួចជាស្រេច។ តំណាងរាជរដ្ឋាភិបាលថៃ ប្រាប់សឺង ង៉ុកថាញ់ ថា ការអនុវត្តផែនការសម្ងាត់ក្នុងការកម្ចាត់សម្តេចសីហនុ ចេញពីអំណាចសម សារី និងដាប ឈួន នោះ មើលទៅដូចជាមានសភាពមិនស្រួលសោះ អាចនាំទៅដល់បែកការណ៍សម្ងាត់ទៀតផង។

តំណាងរាជរដ្ឋាភិបាលថៃ បន្ថែមថា បើដូច្នេះមែន រាជរដ្ឋាភិបាលថៃ និងរដ្ឋាភិបាលវៀតណាមខាងត្បូង ចាំបាច់ត្រូវតែជម្លៀសសម សារី និងដាប ឈួន ឱ្យចេញពីប្រទេសខ្មែរ។ ដូច្នេះ តំណាងរាជរដ្ឋាភិបាលថៃ ស្នើសុំឱ្យគាត់( សឺង ង៉ុកថាញ់ ) ទទួលអ្នកទាំងពីរនាក់នេះ ឱ្យមកចូលរួមជាមួយក្នុងចលនាតស៊ូនោះផង។

ពេលនោះ រាជរដ្ឋាភិបាលថៃ ក៏ដូចជារដ្ឋាភិបាលវៀតណាមខាងត្បូង ដែរ បានសន្យាថា នឹងជួយគាំទ្រចលនាតស៊ូ ដែលគាត់នឹងត្រូវបង្កើតឡើងនៅពេលខាងមុខនេះ រហូតដល់បានសម្រេចជោគជ័យ តាមគោលបំណង។

សឺង ង៉ុកថាញ់ តបទៅតំណាងរាជរដ្ឋាភិបាលថៃ វិញថា ចលនាតស៊ូរបស់គាត់ ទទួលស្វាគមន៍ប្រជាពលរដ្ឋខ្មែរទាំងអស់ ដោយមិនប្រកាន់ថា មានជីវប្រវត្តិ ឬនិន្នាការអ្វីឡើយ សំខាន់ឲ្យតែមានគំនិតប្រឆាំងនឹងនយោបាយរបស់សម្តេចសីហនុ និងមនោគមវិជ្ជាកុម្មុយនិស្ត ហើយចូលបម្រើចលនាតស៊ូរបស់គាត់ ដោយចិត្តស្មោះស្ម័គ្រ។

សឺង ង៉ុកថាញ់ បញ្ជាក់ថា បើនរណា បានចូលបម្រើចលនាតស៊ូរបស់គាត់ ត្រូវតែប្រតិបត្តិតាមគោលនយោបាយ និងក្រឹត្យវិន័យនៃចលនាតស៊ូរបស់គាត់ តែបើយល់ឃើញថា ខ្លួនមិនអាចដើរតាមគោលនយោបាយ និងក្រឹត្យវិន័យនោះ បានទេ ខ្លួនក៏អាចលាចេញពីសមាជិកភាពដោយសេរី តែក៏មិនត្រូវធ្វើវិទ្ធង្សនាណាមួយ ដើម្បីបំផ្លាញចលនាតស៊ូរបស់

គាត់ដែរ។

ដូច្នេះ បើខាងរាជរដ្ឋាភិបាលថៃ ព្រមទទួលខុសត្រូវលើអស់លោកទាំងពីរ(សម សារី និងដាប ឈួន)គាត់សូមទទួលស្វាគមន៍ ដោយរីករាយ។ សឺង ង៉ុកថាញ់ បញ្ជាក់បន្ថែមថា មូលហេតុ គាត់សុំឲ្យរាជរដ្ឋាភិបាលថៃ ទទួលខុសត្រូវចំពោះសម សារី និងដាប ឈួន នេះ ក៏ព្រោះតែគាត់ធ្លាប់ដឹងច្បាស់ជាយូរមកហើយ ពីចរិតអាកប្បកិរិយា ប្រឡើសបើស របស់អ្នកទាំងពីរនេះ ហើយនៅរឿងមួយទៀត គឺរាជរដ្ឋាភិបាលថៃ ជាអ្នកគាំទ្រចលនាតស៊ូរបស់គាត់ ក៏មិនត្រូវជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់ពួកគាត់ផងដែរ តែអាចផ្តល់យោបល់ក្នុងកិច្ចសហប្រតិបត្តិការបាន ឯសេចក្តីសម្រេចចិត្តពីបញ្ហាផ្សេងៗ គឺស្រេចលើពួកគាត់ ជាអ្នកសម្រេច។

ចុងបញ្ចប់ តំណាងរាជរដ្ឋាភិបាលថៃ បានស្នើសុំឱ្យអញ្ជើញ សឺង ង៉ុកថាញ់ ទៅក្រុងបាងកក ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀង ស្តីពីបញ្ហាបង្កើតចលនាតស៊ូ និងបញ្ហាសហការជាមួយសម សារី និងដាប ឈួន នេះ ជាមួយមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាលថៃនៅពេលខាងមុខ ដ៏ខ្លីនេះផងដែរ ព្រោះស្ថានការណ៍កាន់តែទំុដោរណាស់ទៅហើយ។ ក្រោយបញ្ចប់កិច្ចសន្ទនា នៅវេលាម៉ោង១១ និង៣០នាទី សឺង ង៉ុកថាញ់ ក៏បានអញ្ជើញតំណាងរាជរដ្ឋាភិបាលថៃ ទាំង២នាក់ ទៅទទួលទានអាហារ នៅសណ្ឋាគារបារាំងមួយស្ថិតនៅជិតនោះដែរ។

លុះទទួលទានអាហារថ្ងៃត្រង់រួច ឡឹក សំអឿន ក៏ជូនដំណើរសឺង ង៉ុកថាញ់ ទៅកាន់គេហដ្ឋានរបស់គាត់វិញ ដោយនៅតាមផ្លូវ រហូតទៅដល់គេហដ្ឋាន សឺង ង៉ុកថាញ់ បានណែនាំពន្យល់គាត់ជាថ្មីម្តងទៀត អំពីរបៀបរបបទាក់ទងជាមួយអ្នកទទួលខុសត្រូវថៃ ក្នុងកិច្ចសហប្រតិបត្តិការជាមួយគ្នា ទៅថ្ងៃមុខ ដោយមិនត្រូវឱ្យគេចូលជ្រៀតជ្រែកដល់កិច្ចការផ្ទៃក្នុងរបស់ពួកគាត់ ដើម្បីផលប្រយោជន៍របស់គេនោះឡើយ។

ជាមួយគ្នានោះ សឺង ង៉ុកថាញ់ បានដាស់តឿនគាត់ ឱ្យបណ្តុះស្មារតីជាតិនិយមចូលទៅក្នុងសាច់ឈាម ឆ្អឹងសរសៃដល់ពួកអ្នកតស៊ូគ្រប់លំដាប់ថ្នាក់ ពិសេសពួកអ្នកតស៊ូ

ជាថ្នាក់ដឹកនាំអ្នកទទួលខុសត្រូវបន្ទាប់ពីគាត់។ សឺង ង៉ុកថាញ់ មានជំនឿយ៉ាងមុតមាំថា ឡឹក សំអឿន ធ្លាប់មានបទពិសោធតាំងពីសម័យដឹកនាំតស៊ូទាមទារឯករាជ្យពីបារាំង ច្រើនឆ្នាំហើយនោះ នឹងធ្វើតាមការណែនាំរបស់គាត់ បានជាមិនខាន។

តែយ៉ាងណា សឺង ង៉ុកថាញ់ មានការព្រួយបារម្ភដែរ ពីបញ្ហាមេដឹកនាំវៀតណាមខាងត្បូង និងថៃ ត្រៀមយកសម សារី និងដាប ឈួន មកបញ្ចូលជាមួយពួកគាត់ ព្រោះបុគ្គលទាំង២នាក់នេះជាមនុស្សមានចរិតឆ្មើងឆ្មៃក្រអឺតក្រទមជាមនុស្សអាត្មានិយម ហើយគាត់សុំឲ្យឡឹក សំអឿន ប្រុងប្រយ័ត្នតាមដានជានិច្ច។

បន្ទាប់ពីទទួលទានបាយល្ងាចរួច ឡឹក សំអឿន ក៏ត្រលប់ទៅសណ្ឋាគារវិញ ព្រោះស្អែក ពេលព្រឹកព្រលឹម ត្រូវឡើងយន្តហោះពីក្រុងសៃហ្គន ត្រលប់ទៅក្រុងបាងកក វិញ។

# ១១២
# សឺង ង៉ុកថាញ់ រៀបចំមូលដ្ឋានយោធាខ្មែរសេរី នៅព្រំដែនយួន និងថៃ



សឺង ង៉ុកថាញ់

ពេលមកដល់ក្រុងបាងកក ឡឹក សំអឿន បានស្នាក់នៅចំនួន២ថ្ងៃ ដើម្បីដើរទាក់ទង អតីតសហការីជាអ្នកតស៊ូជាមួយគាត់ពីមុន នៅក្នុងក្រុងបាងកក នោះ បានមួយចំនួន រួច ចាត់ឱ្យពួកគេធ្វើដំណើរចេញទៅកាន់ខេត្តបុរីរ៉ាំ ខេត្តសុរិន្ទ និងខេត្តស៊ីសាកេត ស្រាវជ្រាវរក អតីតអ្នកតស៊ូប្រជាចលនាឥស្សរៈខ្មែរបម្រើជាតិ ទាំងប៉ុន្មាន ដើម្បីត្រៀមខ្លួនចូលរួមតស៊ូ ជាមួយគាត់ បន្តទៀត។

បន្ទាប់មក គាត់ក៏បន្តដំណើរទៅទីក្រុងវៀងចន្ទ ដើម្បីសុំឈប់ពីការងារ នៅក្រុមហ៊ុន ឈើហ៊ុបនោះ និងបាននាំជនជាតិខ្មែរ ដែលស្ម័គ្រចិត្តចូលបម្រើចលនាតស៊ូជាមួយគាត់

ចំនួន៩នាក់ មកក្រុងបាងកក ផងដែរ។ ពេលមកដល់ក្រុងបាងកក មន្ត្រីជាន់ខ្ពស់ថៃ ក៏បានរៀបចំផ្ទះមួយកន្លែង សម្រាប់ឱ្យពួកគាត់ស្នាក់នៅផង និងសម្រាប់ធ្វើការិយាល័យ ដើម្បីរៀបចំចលនាតស៊ូមួយ។ ជាការចាប់ផ្តើមដំបូង ឡឹក សំអឿន បានរៀបចំគម្រោងអនុវត្តនយោបាយសង្គ្រាមចិត្តសាស្ត្រ ដោយផ្សព្វផ្សាយព័ត៌មានតាមរយៈការត្រៀមបាចខិតប័ណ្ណដោយប្រើរហស្សនាមថា ក្រុមផ្កាយព្រឹក ដើម្បីបំភាន់ភ្នែករាជការសម្តេចសីហនុ ឱ្យច្រឡំថាមានចលានាតស៊ូផ្សេងមួយទៀត បានចេញមុខប្រឆាំងនឹងនយោបាយរបស់ព្រះអង្គហើយ។ ពេលកំពុងរៀបចំផែនការអនុវត្តនយោបាយសង្គ្រាមចិត្តសាស្ត្រនោះ មិនបានប៉ុន្មានថ្ងៃផង ក៏មានមន្ត្រីបារាំងម្នាក់ ជាតំណាងសាធារណរដ្ឋបារាំង ប្រចាំអង្គការសេអាតូ(SEATO) នៅទីក្រុងបាងកក បានមកជួបទាក់ទងជាមួយ ឡឹក សំអឿន ដោយមិនឲ្យភាគីថៃ ដឹងឡើយ សួរចង់ដឹងនូវគោលនយោបាយរបស់ចលនាតស៊ូ ដែលសឺង ង៉ុកថាញ់ បម្រុងបង្កើតឡើងនោះ។

ឡឹក សំអឿន បានឆ្លើយបញ្ជាក់ទៅតាមអ្វី ដែលសឺង ង៉ុកថាញ់ ធ្លាប់បានលើកឡើងថា គោលនយោបាយក្នុងប្រទេសរបស់ចលនាតស៊ូរបស់គាត់ គឺការផ្លាស់ប្តូររបបគ្រប់គ្រងពីរបបរាជានិយម ទៅជាសាធារណរដ្ឋនិយម។ ចំណែកគោលនយោបាយក្រៅប្រទេស គឺអនុវត្តឱ្យបានត្រឹមត្រូវនូវគោលមាគ៌ានយោបាយអព្យាក្រឹត ព្រមទាំងទប់ទល់នឹងពួកកុម្មុយនិស្តកំពុងវាតទីរំលោភបំពាន គ្មានឈប់ឈរមកលើទឹកដីខ្មែរកម្ពុជា។ គាប់ជួនពេលនោះ ឯកអគ្គរដ្ឋទូតគោចរបារាំង ឈ្មោះ អង់ដ្រេ ម៉ាល់រ៉ូ (Andre Malreau) មកបំពេញទស្សនកិច្ចជាផ្លូវការនៅចុងបូព៌ាប្រទេសផងដែរ មន្ត្រីតំណាងសាធារណរដ្ឋបារាំង ប្រចាំអង្គការសេអាតូ (SEATO) នៅក្រុងបាងកក រូបនោះ ក៏បានផ្ញើខ្លឹមសារគោលនយោបាយរបស់ចលនាតស៊ូដឹកនាំដោយសឺង ង៉ុកថាញ់ តាមរយៈឯកអគ្គរដ្ឋទូតគោចរនោះ ទៅជូនរដ្ឋាភិបាលបារាំងនៅក្រុងប៉ារីស ដើម្បីឱ្យជួយគាំទ្រ ដោយមានភ្ជាប់លិខិតគាំទ្ររបស់ខ្លួនទៅជាមួយ ផងដែរ។

ក្រោយពីបានទទួលលិខិតនោះភ្លាម រដ្ឋាភិបាលបារាំង បានបដិសេធមិនទទួលស្គាល់ចលនាតស៊ូដឹកនាំដោយសឺង ង៉ុកថាញ់ នោះទេ ហើយបង្គាប់មកឲ្យមន្ត្រីតំណាងប្រចាំអង្គការ

សេអាតូ(SEATO) នៅក្រុងបាងកករូបនោះ បញ្ឈប់ការទាក់ទងជាមួយចលនាតស៊ូនេះតទៅទៀត។

ទោះយ៉ាងណា មន្ត្រីបារាំងរូបនេះ នៅតែបន្តព្យាយាមទាក់ទង និងផ្តល់យោបល់ទៅរដ្ឋាភិបាលបារាំង ឱ្យជួយគាំទ្រចលនាតស៊ូនេះ ម្តងហើយម្តងទៀត រហូតរដ្ឋាភិបាលបារាំងបង្ខំចិត្តដកតំណែងគាត់ចេញពីអង្គការសេអាតូ(SEATO) នៅក្រុងបាងកក និងបញ្ជាឲ្យគាត់វិលត្រលប់ទៅប្រទេសបារាំង វិញ។ តែតំណាងបារាំងរូបនោះ មិនព្រមត្រលប់ទៅប្រទេសបារាំង វិញទេ គឺគាត់ស្ម័គ្រចិត្តនៅចូលរួមបម្រើចលនាតស៊ូនោះ ដោយផ្ទាល់តែម្តង។ ពេលនោះ ឡឹក សំអឿន នៅក្នុងក្រុងបាងកក ពុំអាចទាក់ទងទៅសឺង ង៉ុកថាញ់ នៅវៀតណាមខាងត្បូង ភ្លាមៗ ដើម្បីសុំឱ្យអ្នកតំណាងបារាំង រូបនោះ បានចូលមកបម្រើចលនាតស៊ូរបស់គាត់ដែរ បើសិនជាអាចធ្វើទៅបាន ព្រោះអ្នកតំណាងរូបនេះ ក៏ធ្លាប់ជាយុទ្ធជន នៅក្រោមបញ្ជាឧត្តមសេនីយ៍ ហ្សាល ដឺ ហ្គោល និងមានបទពិសោធច្រើន ក្នុងការប្រយុទ្ធវាយបណ្តេញពួកឈ្លានពានណាហ្ស៊ី អាល្លឺម៉ង់ ឱ្យចេញពីប្រទេសបារាំង កាលក្នុងសម័យសង្គ្រាមលោកលើកទី២ ផងដែរ។

ក្រោយពីជួបចរចាគ្នាជាមួយមន្ត្រីតំណាងរាជរដ្ឋាភិបាលថៃ នៅក្រុងព្រៃនគរ(ក្រុងសៃហ្គន) បាន២សប្តាហ៍ សឺង ង៉ុកថាញ់ ក៏បានធ្វើដំណើរមកដល់ក្រុងបាងកក តាមការអញ្ជើញរបស់តំណាងរាជរដ្ឋាភិបាលថៃ។ ពេលនោះ ឡឹក សំអឿន ក៏បានជម្រាបពីរឿងរ៉ាវរបស់អតីតមន្ត្រីតំណាងប្រទេសបារាំង ប្រចាំអង្គការសេអាតូ(SEATO) នៅក្រុងបាងកកនោះ ឱ្យសឺង ង៉ុកថាញ់ បានជ្រាប រួចហើយ បាននាំជនជាតិបារាំង នោះ ឱ្យទៅជួបពិភាក្សាគ្នាជាមួយ សឺង ង៉ុកថាញ់ ដោយមិនឱ្យភាគីថៃ ដឹងឡើយ ។

ក្នុងកិច្ចសន្ទនានោះ សឺង ង៉ុកថាញ់ បានថ្លែងអំណរគុណចំពោះជនជាតិបារាំង នោះដែលបានព្យាយាមគាំទ្រចលនាតស៊ូរបស់គាត់ យ៉ាងស្វិតស្វាញ ព្រមទាំងបានសម្តែងការសោកស្តាយ ចំពោះការបាត់បង់មុខតំណែងជាមន្ត្រីតំណាងប្រទេសបារាំង ប្រចាំអង្គការសេអាតូ(SEATO) របស់ជនជាតិបារាំង នោះ ផងដែរ។ តែយ៉ាងណា គាត់ក៏ពុំបានទទួល

ឲ្យជនជាតិបារាំង នោះ ចូលរួមក្នុងចលនាតស៊ូរបស់គាត់បានដែរ ដោយគាត់បានលើកហេតុផលថា នៅភ្នំដងរែក ចលនាតស៊ូរបស់គាត់ ពុំទាន់មានមូលដ្ឋានយោធា ពិតប្រាកដនៅឡើយ។

នៅទីបញ្ចប់នៃកិច្ចសន្ទនាគ្នានោះ សឺង ង៉ុកថាញ់ បានជូនពរឱ្យជនជាតិបារាំង នោះ វិលត្រលប់ទៅមាតុភូមិរបស់គេវិញ ប្រកបដោយសុវត្ថិភាព ហើយបើមានឱកាស សុំឲ្យគេជួយបកស្រាយបំភ្លឺដល់មេដឹកនាំបារាំង ឱ្យបានយល់ពីបុព្វហេតុតស៊ូរបស់គាត់ផង។ បន្ទាប់មក សឺង ង៉ុកថាញ់ បានជួបពិភាក្សាគ្នាលម្អិតជាមួយមន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាលថៃ ពីបញ្ហាបង្កើតចលនាតស៊ូ និងបញ្ហាសហការជាមួយ សម សារី និងដាប ឈួន អស់រយៈពេលជាច្រើនម៉ោង មុនមានការព្រមព្រៀងគ្នា ជាសម្ងាត់។

ក្រោយពីព្រមព្រៀងគ្នា ជាសម្ងាត់ជាមួយមន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាលថៃ ចប់សព្វគ្រប់មក សឺង ង៉ុកថាញ់ បានប្រគល់ភារកិច្ចឲ្យឡឹក សំអឿន សហការជាមួយសម្ព័នមិត្តថៃ ដើម្បីចាប់ផ្តើមរៀបចំមូលដ្ឋានយោធាមួយ នៅលើភ្នំដងរែក។ ចំណែករូបគាត់ ក៏ប្រញាប់ប្រញាល់ធ្វើដំណើរតាមយន្តហោះ វិលត្រលប់ទៅប្រទេសវៀតណាមខាងត្បូងវិញ ដើម្បីរៀបចំមូលដ្ឋានយោធា នៅតាមបណ្តោយព្រំដែនខ្មែរ ដែរ។

ដោយមានការជួយឧបត្ថម្ភគាំទ្រពីសំណាក់ពួកសេអ៊ីអា របស់សហរដ្ឋអាមេរិក ផង និងពីរដ្ឋការវៀតណាមខាងត្បូង ផង នៅទីបំផុត សឺង ង៉ុកថាញ់ បានសម្រេចចិត្តបង្កើតចលនាតស៊ូមួយ មានឈ្មោះថាចលនាខ្មែរសេរី ដោយគាត់បានបញ្ជាក់ពីមូលហេតុធំៗ ចំនួន៤ចំណុច គឺ ៖

១. ក្រោយពីប្រទេសកម្ពុជា ទទួលបានឯករាជ្យមក សម្តេចសីហនុ បានដឹកនាំនយោបាយផ្តេសផ្តាសជាច្រើន ដូចជាដឹកនាំនយោបាយអព្យាក្រឹត ម្តងលម្អៀងទៅខាងស្តាំ ម្តងលម្អៀងទៅឆ្វេង បង្កជម្លោះជាមួយប្រទេសជិតខាង។ គាត់មើលឃើញថា ជានយោបាយមិនច្បាស់លាស់ មិនច្រឡំគេ ហើយគ្មានបានផលប្រយោជន៍អ្វី ដល់ប្រទេសជាតិទាល់តែសោះ។

២. ចលនាសង្គមរាស្ត្រនិយម សម្តេចសីហនុ បានបង្កើតឡើង កាលពីឆ្នាំ១៩៥៥

នោះ ជាចលនាថោកទាប សម្រាប់បម្រើតែផលប្រយោជន៍ពពួករាជការពុករលួយ តែប៉ុណ្ណោះ។ អ្នកបានរៀនសូត្រចេះដឹង នឹងយល់ច្បាស់ថា នេះជាល្បែងប្រជាភិថុត បញ្ឆោតបញ្ឆៅ បោកប្រាស់ប្រជារាស្ត្រ នាំឱ្យប្រទេសជាតិខ្មែរទាំងមូល ធ្លាក់ចូលទៅក្នុងសេចក្ដីវិនាស នៅថ្ងៃណាមួយ ជាមិនខានឡើយ។

៣. មូលហេតុអាក្រក់បំផុត ធ្វើឱ្យគាត់ទ្រាំមិនបាននោះ គឺគំនិតល្ងង់ខ្លៅចោលម្សៀតរបស់សម្ដេចសីហនុ បណ្ដោយខ្លួន ឱ្យដើរចូលទៅក្នុងអង្គប់ដៃករបស់ពួកកុម្មុយនិស្តចិន និងយួន ដោយអនុញ្ញាតឱ្យយួនខាងជើង និងវៀតកុង ប្រើប្រាស់ទឹកដីខ្មែរ ធ្វើជាមូលដ្ឋានទ័ពរបស់គេ។

៤. ខ្មែរវៀតមិញក្ដី ខ្មែរឆ្វេងនិយមក្ដី សុទ្ធតែជាអ្នកបម្រើមនោគមវិជ្ជាកុម្មុយនិស្ត ជាក្រុមមនុស្សទាល់ច្រក សុខចិត្តឱនក្បាល ប្រគល់ជោគវាសនាប្រទេស ឱ្យយួនដឹកនាំ។ ដូច្នេះ គាត់យល់ឃើញថា ជាការចាំបាច់ ត្រូវតែរៀបចំបង្កើតចលនាខ្មែរសេរី នេះឡើង ក្នុងគោលបំណង ដំបូង គ្រាន់តែជួយជ្រោមជ្រែងតម្រែតម្រង់នយោបាយសម្ពឹករបស់សម្ដេចសីហនុ ឲ្យដឹងខុសដឹងត្រូវ ឡើងវិញ តែប៉ុណ្ណោះ ដើម្បីចៀសវាងកើតមានគ្រោះមហន្តរាយដល់ប្រទេសជាតិ បណ្ដាលមកពីមនោគមវិជ្ជាកុម្មុយនិស្ត និងគំនិតលេបទឹកដីរបស់ប្រទេសជិតខាង។

ក្នុងខែតុលា ឆ្នាំ១៩៥៨ សឹង ង៉ុកថាញ់ បានបង្កើតមូលដ្ឋានយោធាវាលកក់ នៅភូមិទ្រាំង ក្នុងខេត្តមាត់ជ្រូក(ខេត្តចូវដុក)នៅក្បែរព្រំដែនខ្មែរ មានសមាជិកចំនួន១៤០នាក់ ចាប់ផ្ដើមកាប់ឆ្ការព្រៃធ្វើស្រែចម្ការ និងចិញ្ចឹមសត្វ ព្រមទាំងរៀនសូត្រគោលនយោបាយផងដែរ។ បន្ទាប់មក គាត់បានបង្កើតមូលដ្ឋានមួយទៀត នៅចម្ងាយប្រហែល១៥ គីឡូម៉ែត្រពីភូមិធំ ជាកន្លែងដែលគាត់នាំសហការី៥នាក់ ទៅកាប់ឆ្ការព្រៃធ្វើចម្ការនោះ ដើម្បីហ្វឹកហ្វឺនក្បួនយុទ្ធសាស្ត្រ និងសង្គ្រាមចិត្តសាស្ត្រដល់យុទ្ធជនរបស់គាត់ថែមទៀត។

មិនយូរប៉ុន្មាន គាត់ក៏បានបញ្ជូនយុទ្ធជនមួយចំនួន ឱ្យទៅរៀនជំនាញខាងចារកិច្ច និងវិធីរៀបចំបណ្ដាញសម្ងាត់ នៅទីក្រុងព្រៃនគរ ដើម្បីចេញទៅឃោសនាប្រមូលកម្លាំង

បងប្អូនខ្មែរកម្ពុជាក្រោម នៅតាមបណ្ដាខេត្តនានា នៅក្នុងសាធារណរដ្ឋវៀតណាមខាងត្បូង ពិសេស នៅតាមខេត្ត ជាប់ព្រំដែនខ្មែរ ឱ្យចូលរួមក្នុងចលនាតស៊ូខ្មែរសេរី របស់គាត់។

ដោយមានជំនួយពីពួកសេអ៊ីអា និងរដ្ឋការវៀតណាមខាងត្បូង នៅដើមឆ្នាំ១៩៥៩ សឺង ង៉ុកថាញ់ បានបង្កើតទីតាំងប្រតិបត្តិការសឹកមួយនៅក្នុងខេត្តដាក់ឡាក់ ឲ្យឈ្មោះថា មូលដ្ឋានឦសានទិស ដើម្បីចូលទៅក្នុងខេត្តមណ្ឌលគិរី និងខេត្តរតនគិរី ក្នុងទឹកដីខ្មែរ ធ្វើសកម្មភាពឃោសនាផ្សព្វផ្សាយពីគោលនយោបាយរបស់ចលនាខ្មែរសេរី និងធ្វើសង្គ្រាមចិត្តសាស្ត្រ ដោយមានញឹក ញ៉ុក អតីតនាយទាហានជំនាន់ទី២ កាលពីសម័យតស៊ូ ឆ្នាំ ១៩៥២ នៅភ្នំដងរែក ជាមេដឹកនាំ។

ជាមួយគ្នានោះ គាត់បានផ្សព្វផ្សាយតាមខិតប័ណ្ណ និងតាមវិទ្យុខ្មែរសេរី ឱ្យប្រជារាស្ត្រខ្មែរយល់ថា សម្ដេចសីហនុ មិនត្រឹមតែចរចេសរីងរូស មិនព្រមលះបង់នយោបាយអព្យាក្រឹតប៉ុណ្ណោះទេ ព្រះអង្គថែមទាំងទៅចូលរួមប្រជុំសន្និសីទប្រជាជនឥណ្ឌូចិន រួចហើយធ្វើតាមឱវាទរបស់ពួកកុម្មុយនិស្តចិន និងយួន បើកវេទិកាបំផុសឱ្យប្រជារាស្ត្រខ្មែរប្រឆាំងនឹងសកម្មភាពតម្រែតម្រង់ រកផ្លូវត្រូវរបស់ចលនាតស៊ូរបស់គាត់ ទៅវិញ។

ដោយមានការជួយឧបត្ថម្ភគាំទ្រពេញទំហឹង ពីសហរដ្ឋអាមេរិក ព្រមទាំងសម្ព័ន្ធមិត្តវៀតណាមខាងត្បូង និងថៃ ចលនាខ្មែរសេរី ដឹកនាំដោយសឺង ង៉ុកថាញ់ បានឈានដល់បង្កើតមូលដ្ឋានយោធាធំៗចំនួន២កន្លែង គឺមូលដ្ឋានយោធាវាលកក់ ស្ថិតនៅព្រំដែនខ្មែរ-វៀតណាមខាងត្បូង និងមូលដ្ឋានយោធាភ្នំដងរែក ស្ថិតនៅព្រំប្រទល់ខ្មែរ-ថៃ។ មូលដ្ឋានយោធាវាលកក់ មានទីតាំងប្រតិបត្តិការ ២កន្លែងទៀត គឺ៖

១. ទីតាំងប្រតិបត្តិការឦសានទិស ត្រូវបើកប្រតិបត្តិការក្នុងខេត្តកំពង់ចាម, ខេត្តស្ទឹងត្រែង, ខេត្តក្រចេះ, ខេត្តមណ្ឌលគិរី និងខេត្តរតនគិរី,។

ទី២. ទីតាំងប្រតិបត្តិការពាយ័ព្យទិស ត្រូវបើកប្រតិបត្តិការក្នុងខេត្តព្រៃវែង, ខេត្តស្វាយរៀង, ខេត្តតាកែវ, ខេត្តកំពត, ខេត្តកំពង់សោម, ខេត្តកោះកុង និងខេត្តកណ្ដាល។

ចំណែកមូលដ្ឋានយោធាភ្នំដងរែក មានទីតាំងប្រតិបត្តិការ២កន្លែងដែរ គឺ៖

**របត់នយោបាយ**

ទី១. ទីតាំងប្រតិបត្តិការឧត្តរទិស ត្រូវបើកប្រតិបត្តិការក្នុងខេត្តឧត្តរមានជ័យ, ខេត្តព្រះវិហារ, ខេត្តសៀមរាប និងកំពង់ធំ។

ទី២. ទីតាំងប្រតិបត្តិការបស្ចិមទិស ត្រូវបើកប្រតិបត្តិការក្នុងខេត្តថ្មពួក, ខេត្តបាត់ដំបង, ខេត្តពោធិ៍សាត់, ខេត្តកំពង់ឆ្នាំង និងកំពង់ស្ពឺ ។

ទីតាំងប្រតិបត្តិការនីមួយៗចែកចេញជាជំរំប្រតិបត្តិការ បន្តទៀត ដោយមានចំនួនទៅតាមស្ថានភាពភូមិសាស្ត្រនិងយុទ្ធសាស្ត្រជាក់ស្តែង រួមមានៈ

១. ទីតាំងប្រតិបត្តិការឦសានទិស មានជំរំប្រតិបត្តិការឡុកនិញ, បូដូប, អន្លង់ស្វាយ, ត្រាំខ្នា ក្នុងខេត្តព្រះបាទជាន់ទុក (ខេត្តកៀកឡុង), ពន់ឌឹក, ឌឹកឡុក ក្នុងខេត្តទឹកផុស (ខេត្តក្វាងឌឹក), ទាន់ហាន់, បាជន, បន្ទាយប៉ុយត្រាង ក្នុងខេត្តលក្ខខណ្ឌ(ខេត្តដាក់ឡាក់)។

២. ទីតាំងប្រតិបត្តិការការពាយ័ព្យទិស មានជំរំវាលកក់ នៅភូមិទ្រាំង ក្នុងខេត្តមាត់ជ្រូក(ខេត្តចូវដុក), កំពង់ទូក ក្នុងខេត្តប្រាំល្វែង(ខេត្តទៀងថុង), ទន្លេចាម, ត្រពាំងរបង, ស្ទឹងថ្ម និងភ្នំនាគខ្មៅ ក្នុងខេត្តពេងជំរី(ខេត្តតៃនិញ)។

៣. ទីតាំងប្រតិបត្តិការឧត្តរទិស មានជំរំភ្នំស្រួច, ជំរំភ្នំត្រងិល, ជំរំបោកប៉ីស្រីស្រណោះនៅលើភ្នំដងរែក និងមានជំរំបណ្តោះអាសន្ន នៅគោករមៀត, ភ្នំស្រីស្នំ ក្នុងខេត្តបាត់ដំបង, ជំរំបណ្តោះអាសន្ន នៅអន្លង់វែង, វ៉ារិន, បន្ទាយស្រី ក្នុងខេត្តសៀមរាប, ជំរំបណ្តោះអាសន្ននៅជាំក្សាន្ត, រវៀង, ភ្នំគូលែន ក្នុងខេត្តព្រះវិហារ។

៤. ជំរំប្រតិបត្តិការបស្ចិមទិស មានជំរំភ្នំឆត្រ ជំរំអូរជ្រៅ ក្នុងខេត្តថ្មពួក, ជំរំម៉ាឡៃ, ជំរំបណ្តោះអាសន្ននៅភ្នំព្រឹក, កំរៀង បរតាំងស៊ូ ក្នុងខេត្តបាត់ដំបង។

តែទោះបីចលនាខ្មែរសេរី បានរៀបចំបង្កើតទីតាំងប្រតិបត្តិការជាច្រើនដូចខាងលើនេះ ពិតមែន តែពួកគេមិនមានលទ្ធភាពធ្វើសកម្មភាពចូលមកជ្រៅនៅក្នុងផ្ទៃប្រទេស គួរឱ្យកត់សម្គាល់ឡើយ។

# ១១៣
# សម សារី រត់គេចខ្លួន មុនពេលកងកម្លាំងចុះបង្ក្រាប



**សម សារី**

នាចុងខែធ្នូ ឆ្នាំ១៩៥៨ កាសែតរាស្ត្រាធិបតេយ្យរបស់សម សារី បានសេសេរិះគន់រាជរដ្ឋាភិបាលរបស់សម្តេចសីហនុ និងជេរជៀលបញ្ឆិតបញ្ឆៀងទៅលើព្រះមហាក្សត្រ និងរាជវង្សានុវង្ស កាន់តែខ្លាំងឡើងៗ និងបានប្រកាសបង្កើតគណបក្សប្រឆាំងមួយឈ្មោះ គណបក្សបង្រួបបង្រួមខ្មែរអ្នកប្រជាធិបតេយ្យផងដែរ ។

ប៉ុន្មានថ្ងៃក្រោយស្ត្រី ឈ្មោះនួន ចន្ទ្រី ជាចាងហ្វាងកាសែតរាស្ត្រាធិបតេយ្យ ត្រូវបានសមត្ថកិច្ចចាប់យកទៅឃុំឃាំង សម សារី បានបើកបររថយន្តចេញពីភូមិគ្រឹះទៅបាត់ ទំនងមានរឿងសំខាន់បំផុត ត្រូវទៅជួបមន្ត្រីទូតវៀតណាមខាងត្បូង។

រហូតដល់វេលាម៉ោងប្រហែល៦ល្ងាច ទើបគាត់ត្រលប់មកដល់ភូមិគ្រឹះវិញ ដោយមានទឹកមុខស្លេកស្លាំង ហើយប្រញាប់ប្រញាល់ឡើងទៅបន្ទប់ដេករបស់គាត់ ដើម្បីរៀបចំខោអាវ និងហឹបដែកតូចមួយ ពណ៌ស នៅក្នុងនោះ មានកាំភ្លើងខ្លីមួយដើម រួចគាត់បាន



**រថយន្តម៉ាកគ្រីស្លែរ** (Chrysler)

ឡើងទៅដាក់លើបង្អស់ លុតជង្គង់ថ្វាយបង្គំព្រះពុទ្ធបដិមា តាំងនៅលើអាសនៈធំមួយ។

បន្ទាប់មក គាត់ក៏បានរត់ចុះមកខាងក្រោមវិញ រួចបក់ដៃហៅប្រពន្ធឱ្យមកជិត ហើយឱនខ្សឹប ឱ្យហៅកូនប្រុសច្បងឈ្មោះអេម៉ារ៉ា ជូនគាត់ចេញទៅក្រៅ ប៉ុន្តែដោយសារកូនប្រុសច្បងនោះមិននៅ ដូច្នេះប្រពន្ធគាត់ ក៏ហៅកូនទី៣ ឈ្មោះអេម៉ារិទ្ធ ឱ្យទៅជំនួស។

សម សារី បានឡើងបើករថយន្តម៉ាកគ្រីស្លែរ(Chrysler) ដោយប្រពន្ធគាត់អង្គុយទន្ទឹមគ្នា នៅបាំងខាងមុខ និងអេម៉ារិទ្ធ អង្គុយនៅបាំងខាងក្រោយ ចាកចេញពីផ្ទះចេញទៅតាមបណ្ដាយផ្លូវស្រស់ផ្អែម ដោយគ្មានងាកក្រោយ ឬលើកដៃលាកូនៗផ្សេងទៀត កំពុងឈរមើល ដោយការងឿងឆ្ងល់នោះបន្តិចឡើយ ហើយគាត់ ក៏មិនប្រាប់ទិសដៅថា គាត់ត្រូវទៅទីណា? ឬ ថ្ងៃណាបានវិលមកវិញដែរ? ។

ក្រោយមក អេម៉ារិទ្ធ ជាកូនទី៣ របស់សម សារី បានរម្លឹកពីព្រឹត្តិការណ៍ខាងលើនេះថា ពេលនោះឪពុករបស់គាត់បានបើករថយន្តម៉ាកគ្រីស្លែរ(Chrysler) ឆ្លងស្ពានព្រះមុនីវង្ស ចុះតាមបណ្ដោយផ្លូវជាតិលេខ១ បានចម្ងាយប្រហែលជាង១០គីឡូម៉ែត្រ គាត់ឃើញរថយន្ត២គ្រឿងទៀត កំពុងចតនៅលើចិញ្ចើមផ្លូវម្ខាង។ ក្នុងចំណោមរថយន្តទាំង២គ្រឿងនោះ មានរថយន្ត១គ្រឿងផលិត នៅប្រទេសបារាំង ម៉ាកដេអេស(DS) ព៌ណខ្មៅ បើតាមគាត់ពិនិត្យមើលផ្លាកលេខ រថយន្តនេះជារថយន្តរបស់ស្ថានទូតវៀតណាមខាងត្បូង។ ឪពុក របស់គាត់ក៏បញ្ឈប់រថយន្ត ហើយចាប់ដៃលាម្ដាយរបស់គាត់ និងគាត់ក្នុងទឹកមុខក្រៀមក្រំ ខុសប្លែកពី

ធម្មតា តែឪពុករបស់គាត់ មិនបានប្រាប់ថា មានរឿងអ្វីកើតឡើងនោះទេ គឺគ្រាន់តែ ប្រាប់ម្ដាយរបស់គាត់ ឲ្យបើករថយន្តត្រលប់ទៅផ្ទះវិញ ដោយបើកវាងចុះឡើង ដូចបើកដើរ លេងលំហែកាយធម្មតា។

ប៉ុន្មានថ្ងៃក្រោយមកទៀត វេលាទៀបភ្លឺ ស្រាប់តែមានរថយន្តកាំមីញ៉ុង និងរថយន្តតូចៗ ប្រហែលជាង១០គ្រឿង ដឹកកម្លាំងចម្រុះ រួមមានប៉ូលិស ទាហានប៉ារ៉ា និងទាហានជើងគោកផ្សេងៗទៀតរាប់សិបនាក់មកឡោមព័ទ្ធ និងសម្រុកចូលភូមិគ្រឹះរបស់គាត់ចាប់ប្រមូលក្រុមគ្រួសាររបស់គាត់ និងអ្នករស់នៅក្នុងផ្ទះទាំងអស់ឲ្យមកនៅជុំគ្នាក្នុងបន្ទប់តែមួយ ហើយនាំគ្នាចុចភ្លើងពិលដើរឆែកឆេររុករកឪពុកគាត់ តាំងពីជាន់ក្រោមដល់ជាន់លើ គ្រប់កន្លៀតកៀនកោះទាំងអស់ និងនៅជាន់ក្រោមដី ឃើញតែម៉ាស៊ីនសម្រាប់បោះពុម្ពកាសែតប៉ុណ្ណោះ។

ទីបំផុត ពួកគេបានបិទត្រា នៅមាត់ទ្វារបន្ទប់របស់ឪពុកគាត់ មិនឱ្យនរណាម្នាក់បើកទ្វារចូលក្នុងបន្ទប់នេះដាដាច់ខាត រួចពួកគេនាំគ្នាចុះមកខាងក្រោម យកកូនសោមកចាក់បញ្ឆេះម៉ាស៊ីនរថយន្តទាំង២គ្រឿងរបស់ឪពុកម្ដាយគាត់ បើកចេញទៅក្រៅបរិវេណភូមិគ្រឹះ។

មុនពេលនាំគ្នាចាកចេញទៅវិញ ពួកគេបានប្រាប់ថា ទុករយៈពេលមួយម៉ោងសម្រាប់ឱ្យម្ដាយ និងពួកគាត់ជាកូនៗ រៀបចំអីវ៉ាន់ចាកចេញឱ្យផុតពីភូមិគ្រឹះនេះ។ ចុងក្រោយ រថយន្ត២គ្រឿង និងភូមិគ្រឹះរបស់ក្រុមគ្រួសារគាត់ ត្រូវរាជរដ្ឋាភិបាលរឹបអូសទុកជាសម្បត្តិរដ្ឋ។

បន្ទាប់មកទៀត ម្ដាយគាត់ (អ៊ិន អេម) ជាសាស្ត្រាចារ្យដែលសម្ដេចសីហនុ ធ្លាប់បានបញ្ជូនបុត្រីបុត្រា៣អង្គគឺម្ចាស់ក្សត្រីនរោត្តម បុប្ផាទេវី, ព្រះអង្គម្ចាស់នរោត្តម យុវនាថ និងព្រះអង្គម្ចាស់នរោត្តម ចក្រពង្ស ឱ្យមករៀនបំប៉នបន្ថែមក្រៅម៉ោងនៅផ្ទះរបស់គាត់នៅផ្លូវត្រសក់ផ្អែម ហើយចុងក្រោយនេះជានាយិកាអនុវិទ្យាល័យព្រះនរោត្តម ក៏ត្រូវគេបង្ខំឱ្យលាឈប់ពីតំណែងដែរ។ ចំណែក ជីតាគាត់(សម ញាណ) និងពូគាត់ម្នាក់ឈ្មោះសម សារុន ជាប្អូនប្រុសរបស់ឪពុកគាត់ ក៏ត្រូវគេបណ្ដេញចេញពីតំណែងសមាជិកក្រុមប្រឹក្សាព្រះរាជាណាចក្រ ផងដែរ។

## របត់នយោបាយ

សម រង្ស៊ី ជាកូនពៅរបស់សម សារី កាលនោះទើបមានអាយុ៩ឆ្នាំ បានឃើញហេតុការណ៍នោះផ្ទាល់ ក៏បានរម្លឹកដែរថា ពេលកម្លាំងសមត្ថកិច្ចចម្រុះចុះទៅឡោមពទ្ធផ្ទះ ដើម្បីរកចាប់ឪពុករបស់គាត់នោះ គាត់ចេះតែឆ្ងល់ថា ហេតុអ្វីបានជា ពួកគេយកហ្រ្វង់កា(ស្នែងសម្រាប់សែងអ្នកជំងឺ ឬសែងសាកសព)មកត្រៀមទុកចាំ នៅជាន់ខាងក្រោម?។

ក្រោយមក ទើបគាត់ដឹងថា មេប៉ូលិសឈ្មោះ គូ រុន ជាអ្នកដឹកនាំកម្លាំងប៉ូលិសទាហាន មករកចាប់ឪពុកគាត់នោះ បានគិតទុកជាមុនហើយថា ប្រសិនបើឪពុករបស់គាត់ហ៊ានតដៃ គេនឹងបញ្ជាឱ្យកម្លាំងប៉ូលិសទាហានទាំងនោះ បាញ់សម្លាប់ឪពុកគាត់ចោលភ្លាម ហើយលើកសាកសពដាក់លើហ្រ្វង់កានោះ យកចេញពីផ្ទះទៅបាត់តែម្តង។

ក្រោយកម្លាំងប៉ូលិសទាហាន ទៅឡោមព័ទ្ធចាប់សម សារី មិនបានសម្រេច និងទុករយៈពេលមួយម៉ោង សម្រាប់ឱ្យម្តាយគាត់ និងកូនៗ រៀបចំអីវ៉ាន់ ដើម្បីចាកចេញឱ្យផុតពីភូមិគ្រឹះមក មានតែបងប្អូនគាត់ម្នាក់មានផ្ទះនៅតាមដងទន្លេមេគង្គ ជាមន្រ្តីប៉ូលិសតូចតាចប៉ុណ្ណោះ ដែលបានហៅពួកគាត់ឲ្យទៅស្នាក់នៅជាមួយជាបណ្តោះអាសន្ន។ ផ្ទះរបស់បងប្អូនគាត់ជាមន្ត្រីប៉ូលិសតូចតាចនោះ ក៏ដូចជាផ្ទះនៅម្តុំនោះដែរ មានសសរជន្ទល់ខ្ពស់ៗ ពីដីដើម្បីការពារកុំឲ្យទឹកលិចនៅរដូវវស្សា។ ម្ចាស់ផ្ទះនេះ បានយកឈើបន្ទះមកវាយជាប់នឹងសសរគ្រោងខាងក្រោម ដើម្បីធ្វើជាកន្លែងសម្រាប់ឱ្យពួកគាត់ដេក ដោយសារកន្លែងដេកនេះទាបបន្តិច កូនធំៗត្រូវដើរឱនក្បាល បើមិនដូច្នេះទេ ប្រាកដជាប៉ះក្បាលនឹងធ្នឹមខាងលើជាមិនខាន។ នៅក្រោមកន្លែងពួកគាត់ដេកនោះ ពីមុនជាកន្លែងសម្រាប់ទុកឲ្យឆ្កែជ្រូក និងមាន់ ពួកគាត់ក្រាលកន្ទេល ដាក់តុ១ និងកៅអី ២-៣ ដើម្បីអង្គុយមើលសៀវភៅ។ អ្វីដែលលំបាកជាងនេះទៅទៀតនោះ ពេលកំពប់កន្ថោរម្ជូល្លា ដែលចាស់ៗនៅខាងលើមកម្តងៗ ធ្វើឱ្យទឹកមាត់ពណ៌ក្រហមក្លិនស្អុយធ្លាក់ស្រក់តាមចន្លោះរនាបស្រក់មកលើខោអាវចានបាយ ឬស្រក់ធ្លាក់មកលើក្បាលពួកគាត់តែម្តង។

ជាមួយគ្នានោះដែរ ជាញឹកញាប់ ពេលពួកគាត់ធ្វើដំណើរនៅតាមដងផ្លូវក្នុងក្រុងភ្នំពេញ ឃើញគេបើករថយន្តគ្រីស្លែរ ឬរថយន្តក័រវ៉ែត ជាកម្មសិទ្ធិរបស់ឪពុកម្តាយគាត់ពីមុន

ដោយរថយន្តទាំងពីរនេះត្រូវបានដាក់ផ្លាកថ្មី ជាអក្សរបារាំង ថា បេអេសតេ (BST) មានន័យថា ទ្រព្យសម្បត្តិរឹបអូសពីជនក្បត់។ សម រង្ស៊ី បានរម្លឹកថា សូម្បីពួកមន្ត្រីជាន់ខ្ពស់ម្នាក់ជាមិត្តភក្តិ និងអ្នកនៅក្រោមឱវាទរបស់ឪពុកគាត់ ពីមុនធ្លាប់តែលុតក្រាបឡែមឡឺមឱនក្បាលគោរពពួកគាត់ ជាកូនៗ ពេលឃើញមុខពួកគាត់ ពួកគេនាំគ្នាគេចវេះពីពួកគាត់ទាំងអស់ ហើយមានអ្នកខ្លះបានជេរប្រទេចពួកគាត់ទៀតផង។

ល្ងាចមួយ ម្ដាយគាត់បាននាំគាត់ទៅលេងគ្រួសារមន្ត្រីជាន់ខ្ពស់មួយធ្លាប់ជាសហការីជិតស្និទ្ធនឹងឪពុកគាត់ ដែលមានភូមិគ្រឹះនៅតាមបណ្ដោយផ្លូវព្រះនរោត្ដម។ ពេលទៅខាងមុខភូមិគ្រឹះ ក្មេងៗជាកូនម្ចាស់ផ្ទះដែលកំពុងរត់លេងនៅខាងក្នុងភូមិគ្រឹះនោះ ក៏រត់មកក្បែរមាត់របងសួរម្ដាយគាត់ថា តើមករកអី? ម្ដាយគាត់ឆ្លើយថា មករកឪពុកឯង។ ឮដូច្នោះក្មេងៗទាំងនោះ ក៏ស្រែកហៅរកអ្នកបម្រើឲ្យមកជួប ហើយអ្នកបម្រើនោះក៏ប្រាប់ម្ដាយគាត់ដោយទើសទាល់ថា ចៅហ្វាយរបស់គេចេញទៅក្រៅបាត់ហើយ ប្រហែលជាមិនត្រលប់មកផ្ទះវិញឆាប់ៗនោះទេ។ ឮដូច្នេះម្ដាយគាត់ និងគាត់ក៏បានដើរចេញពីមុខភូមិគ្រឹះនោះ ដើម្បីវិលត្រលប់មកផ្ទះវិញ។

ពេលដើរបានប្រមាណ១០ជំហាន ពួកគាត់បានងាកទៅក្រោយវិញព្រមគ្នា ស្រាប់តែឃើញមិត្តភក្តិឪពុកគាត់ពីរនាក់ប្ដីប្រពន្ធ ដែលម្ដាយគាត់ទៅរកនោះកំពុងឈរនៅក្នុងសួនច្បារខាងក្នុង ហើយខ្សែភ្នែកម្ដាយរបស់គាត់ និងមិត្តភក្តិប្ដីប្រពន្ធពីរនាក់នោះសម្លឹងរកគ្នាយ៉ាងយូរ តែពួកគេនៅស្ងៀមមិននិយាយស្ដីអ្វី សូម្បីមួយម៉ាត់ឡើយ។ លុះពួកគាត់ដើរទៅមុខទៀតបានបន្តិចទៀត ប្រហែលជាម្ចាស់ភូមិគ្រឹះជាចៅហ្វាយនោះប្រើហើយ ទើបបានជាអ្នកបម្រើដែលនិយាយកុហកនោះរត់មកសួរពួកគាត់ថា តើអ្នកស្រីមកនេះចង់ពឹងពាក់អ្វី? ឮដូច្នោះ ម្ដាយគាត់ឈឺចុកចាប់ខ្លាំង ក៏ឆ្លើយទាំងទឹកមុខក្រៀមក្រំទៅវិញថា យើងគ្រាន់តែចង់មកសួរសុខទុក្ខ និងសម្ដែងការគួរសមតែប៉ុណ្ណោះ គ្មានចង់ពឹងពាក់អ្វីទេ។ អ្នកបម្រើនោះក៏ឱនក្បាលគោរព ហើយប្រាប់ថាគេនឹងយកពាក្យនេះទៅប្រាប់ចៅហ្វាយរបស់គេវិញ។

# ១១៤
# ដាប ឈួន មានផែនការដាក់ប្រទេស ចូលជាសមាជិកអង្គការសេអាតូ



**ដាប ឈួន** (**ឈួន ម្ចុលពេជ្រ**)

ក្រោយពីផែនការផ្តួលរំលំសម្តេចសីហនុ របស់សម សារី ត្រូវបរាជ័យមក ផែនការក្បត់របស់វរសេនីយ៍ឯក ឈួន ម្ចុលពេជ្រ(ដាបឈួន) ក៏ត្រូវបែកធ្លាយទៀតដែរ ដោយឯកអគ្គរដ្ឋទូតប្រទេសបារាំង ប្រចាំនៅក្រុងភ្នំពេញ ឈ្មោះព្យែរ ហ្ស៊ក (Pierre Gorge) ជាអ្នកលួចទម្លាយរឿងនេះ ថ្វាយសម្តេចសីហនុ។

គេនៅចាំបានថា នៅដើមខែកក្កដាឆ្នាំ១៩៥៧ ដាប ឈួន កំពុងកាន់តំណែងទេសរដ្ឋមន្ត្រី ទទួលបន្ទុកសន្តិសុខជាតិ និងធម្មការ បានសម្តែងឃើញនូវការមិនពេញចិត្ត ចំពោះនយោបាយរបស់សម្តេចសីហនុ ពីបញ្ហាផ្សារទំនាក់ទំនងជាមួយប្រទេសចិនកុម្មុយនិស្ត។

ដោយសារបញ្ហានេះ គាត់ត្រូវបានសម្តេចសីហនុ ដកចេញពីតំណែងទេសរដ្ឋមន្ត្រីទទួលបន្ទុកសន្តិសុខ និងធម្មការ ឱ្យទៅកាន់តំណែងជាព្រះរាជប្រតិភូទទួលបន្ទុកជាអភិបាល

ខេត្តសៀមរាប និងកំពង់ធំ វិញ ពោលគឺពុំមែនជាអភិបាលខេត្តដូចធម្មតានោះទេ តែយ៉ាងណា តំណែងជាព្រះរាជប្រតិភូទទួលបន្ទុកជាអភិបាលខេត្តទាំង២នេះ មិនអាចប្រៀបផ្ទឹមជាមួយ តំណែងទេសរដ្ឋមន្ត្រី បានឡើយ។ បើតាមព្រឹទ្ធាចារ្យទូន ទេស ពេលនោះជាគ្រូបង្រៀន នៅក្នុងក្រុងសៀមរាប និងជាអ្នកតាមដានហេតុការណ៍នោះ បានឱ្យដឹងថា ពេលនោះដែរ រាជរដ្ឋាភិបាលបានបង្កើតមានកងវរសេនាតូច មួយទៀត គឺកងវរសេនាតូចលេខ១៥ មាន បញ្ជាការដ្ឋាននៅខេត្តកំពង់ធំ បន្ថែមលើកងវរសេនាតូចលេខ៧ នៅខេត្តសៀមរាប របស់ដាប ឈួន បានបង្កើតឡើង ក្រោយពេលគាត់បានចុះចូលក្នុងសង្គមជាតិ វិញ កាលពីខែតុលា ឆ្នាំ១៩៤៩ ថែមទៀត។ កងវរសេនាតូចលេខ៧ និងកងវរសេនាតូចលេខ១៥ ទាំង២អង្គភាព នេះ ក៏ស្ថិតនៅក្រោមបញ្ជាផ្ទាល់របស់ដាប ឈួន ក្នុងនាមជាព្រះរាជប្រតិភូនោះដែរ។

នៅសម័យនោះ នរណាក៏ល្បីថា ដាប ឈួន ជាមនុស្សកំណាចឃោរឃៅដែរ បើគាត់ ចាប់ចិត្តស្រលាញ់កូនក្រមុំគ្រួសារណាម្នាក់ហើយនោះ គឺគាត់ឱ្យកូនចៅរបស់គាត់ ទៅចាប់យក មកឱ្យគាត់ ទាល់តែបាន។ គាត់ហាមស្រីៗទាំងអស់ នៅក្នុងក្រុងសៀមរាប មិនឲ្យស្លៀកសារុង ទៅផ្សារជាដាច់ខាត បើហ៊ានល្មើសនឹងបម្រាមនេះ គាត់ឱ្យប៉ូលិសចាប់មក ឱ្យបង់ពិន័យប្រាក់ ៥រៀល។ ចំណែកប្រុសៗវិញ បើហ៊ានស្លៀកខោខ្លី អត់ពាក់អាវ ដើរតាមទីផ្សារ នឹងត្រូវបង់ពិន័យ ប្រាក់ ៥រៀលដែរ។ ពិសេសនៅពេលឮសូរសំឡេងសារ៉ែន ត្រូវគោរពទង់ជាតិ រាល់ព្រឹកម៉ោង ៧ អ្នកធ្វើដំណើរទាំងអស់ នៅក្នុងក្រុងសៀមរាប ទោះធ្វើដំណើរតាមរថយន្ត តាមម៉ូតូ តាមកង់ ឬថ្មើរជើងក្ដី ត្រូវតែឈប់ ហើយឈរឱ្យត្រង់ខ្លួន ដើម្បីគោរពទង់ជាតិ បើមិនដូច្នេះ ច្បាស់ជា ឱ្យប៉ូលិសផាកពិន័យ ឬរងនូវការធ្វើទារុណកម្មស្រាលៗ ជាមិនខាន។

ដាប ឈួន មានទំនាក់ទំនងជិតស្និទ្ធ និងមានភាគហ៊ុនជាមួយអ្នកជំនួញធំៗ ពិសេស អ្នកជំនួញម្នាក់ ឈ្មោះស ហួយ រកស៊ីដេញថ្លៃប្រមូលសំរាម ដេញថ្លៃធ្វើបាយដល់សិស្ស អាហារូបករណ៍ និងដេញថ្លៃភាស៊ីតាមផ្សារជាដើម ហើយ ស ហួយ នេះ ក៏មានតួនាទីជាស មាជិកគណៈកម្មការដឹកនាំចលនាសង្គមរាស្ត្រនិយម ប្រចាំខេត្តសៀមរាប ម្នាក់ដែរ។

ក្រោយពេលត្រូវបញ្ចុះតំណែងពីទេសរដ្ឋមន្ត្រី ទទួលបន្ទុកសន្តិសុខជាតិ និងធម្មការ

មកកាន់តំណែងជាព្រះរាជប្រតិភូ ទទួលបន្ទុកជាអភិបាលខេត្តសៀមរាប និងកំពង់ធំ នោះ ឈួន ក៏មានការអាក់អន់ស្រពន់ចិត្ត និងចាប់ផ្ដើមប្រឆាំងសម្ដេចសីហនុ បន្តិចម្ដងៗ រហូតមានគំនិតក្បត់ តាមការអូសទាញរបស់ប្អូនប្រុសគាត់ឈ្មោះស្លាត ពៅ ជាមន្ត្រីជាន់ខ្ពស់ម្នាក់ដែរ។

នៅក្នុងខែតុលា ឆ្នាំ១៩៥៨ ដាប ឈួន បានកោះហៅមន្ត្រីរាជការទាំងអស់ ក្នុងខេត្តសៀមរាប មករួមប្រជុំនៅខាងជើងសាលាខេត្ត ដោយគាត់បាននិយាយបញ្ឆិតបញ្ឆៀងថា បើយើងមិនធ្វើ ទុកឱ្យគេធ្វើទៅ...ហើយគាត់ត្អូញត្អែរថា កងទ័ពរបស់គាត់សព្វថ្ងៃនេះគ្មានកាំភ្លើងល្អប្រើប្រាស់ទេ មានតែកាំភ្លើងចាស់ៗ នៅសល់ពីសង្គ្រាមលោកលើកទី២ ដូច្នេះ បើយើងមិនធ្វើ ឱ្យគេធ្វើទៅ ដើម្បីបានកាំភ្លើងមកការពារទឹកដី។ គាត់ប្រហែលជាចង់និយាយថា បើសម្ដេចសីហនុ មិនព្រមដឹកនាំប្រទេស ចូលជាមួយអង្គការសេអាតូ (SEATO) ទេ ទុកឱ្យអ្នកផ្សេង គេដឹកនាំប្រទេសវិញទៅ ដើម្បីបានកាំភ្លើងមកការពារទឹកដី។ ពេលនោះដែរ គាត់បានប្រកាសប្រាប់អង្គប្រជុំថា នៅខែមេសា ឆ្នាំ១៩៥៩ ខាងមុខនេះ នឹងមានបើកសមយុទ្ធយោធាមួយ នៅភ្នំគូលែន ពេលនោះយើងទាំងអស់គ្នា ក៏ត្រូវតែចូលរួមក្នុងនាមជាជាកងជីវពលដែរ។

ព្រឹទ្ធាចារ្យទួន ទេស បានបញ្ជាក់ថា ការពិត ដាប ឈួន មានផែនការកែនកម្លាំងមន្ត្រីរាជការនៅក្នុងខេត្តសៀមរាបទាំងអស់ ឱ្យចូលរួមជាកម្លាំងក្នុងការផ្ដួលរំលំសម្ដេចសីហនុ កំពុងដឹកនាំប្រទេស លម្អៀងទៅរកប្រទេសចិនកុម្មុយនិស្ត ដើម្បីដណ្ដើមអំណាចមកដឹកនាំប្រទេសទៅចូលអង្គការសេអាតូ (SEATO) វិញ។ ប្រភពមួយបានឱ្យដឹងដែរថា នៅពេលណាគាត់ផ្ដួលរំលំសម្ដេចសីហនុ ទទួលជោគជ័យ បានឡើងកាន់អំណាច គាត់នឹងយកអ្នកជំនួញ ឈ្មោះស ហួយ ជាមនុស្សជិតស្និទ្ធនឹងគាត់ ឱ្យធ្វើជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច។

បន្ទាប់មក ពួកសេអ៊ីអា (CIA) អាមេរិក បានបញ្ជូនជនជាតិវៀតណាមខាងត្បូង ២ នាក់ ក្លែងខ្លួនជាជនជាតិចិន នាំយកគ្រឿងម៉ាស៊ីនថតភាពយន្ត ពីក្រុងហុងកុង មកទុកនៅភូមិគ្រឹះរបស់ដាប ឈួន ដើម្បីរៀបចំថតកុន នៅខេត្តសៀមរាប។ តែការពិត ជនជាតិវៀតណាមខាងត្បូង ២នាក់ មិនមែននាំគ្រឿងម៉ាស៊ីនថតភាពយន្តទេ គឺពួកគេបាននាំ

ឧបករណ៍វិទ្យុទាក់ទង មកដំឡើងនៅភូមិគ្រឹះរបស់ដាប ឈួន ដើម្បីទាក់ទងទៅប្រទេសថៃ និងប្រទេសវៀតណាមខាងត្បូង។

ពេលនោះ ង៉ូ ឌិញញូ ជាប្អូនប្រុស និងជាទីប្រឹក្សាជាន់ខ្ពស់របស់ប្រធានាធិបតីវៀតណាមខាងត្បូង ង៉ូ ឌិញយៀម បានបញ្ជូនមាស ចំនួន២៧០ដុំ មានទម្ងន់ស្មើនឹង ២៧០គីឡូក្រាម មកឲ្យដាបឈួន ដើម្បីសម្រាប់ចំណាយក្នុងការរៀបចំកម្លាំង រីឯមេដឹកនាំថៃ ក៏ជួយផ្គត់ផ្គង់អាវុធដល់កងកម្លាំងរបស់ដាប ឈួន ផងដែរ ដើម្បីវាយផ្តួលរំលំសម្តេចសីហនុ និងដាក់ប្រទេសឲ្យចូលជាសមាជិកអង្គការសេអាតូ (SEATO) ។

តាមប្រភពស៊ើបការណ៍របស់សម្តេចសីហនុ បានឱ្យដឹងថា ដាប ឈួន លួចទាក់ទងឧត្តមសេនីយ៍ អ៊ីហាតស្ហន(E.Hat-shorn) ប្រធានគណៈបេសកកម្មយោធាសហរដ្ឋអាមេរិក និងង៉ូ ត្រុងហៀវ (Ngo Trong Hieu)ជាឯកអគ្គរដ្ឋទូតប្រទេសវៀតណាមខាងត្បូង ប្រចាំកម្ពុជា ដើម្បីរៀបចំផែនការផ្តួលរំលំសម្តេចសីហនុ នេះ។

ជាមួយគ្នានោះ មេដឹកនាំប្រទេសវៀតណាមខាងត្បូង បានប្រជុំសម្ងាត់ជាមួយ សឺង ង៉ុកថាញ់ ឱ្យគាត់ត្រៀមបញ្ជូនកងទ័ពខ្មែរសេរី ខ្លះមកពីព្រំដែនថៃ ខ្លះទៀត មកពីតំបន់ឡុកនិញ ប្រទេសវៀតណាមខាងត្បូង ដើម្បីធ្វើរដ្ឋប្រហារផ្តួលរំលំសម្តេចសីហនុ និងលើកឱ្យដាប ឈួន ឡើងកាន់អំណាចដឹកនាំប្រទេស វិញម្តង។ តែសឺង ង៉ុកថាញ់ មិនព្រម ព្រោះគាត់យល់ថា គាត់ជាអ្នកចេះដឹងម្នាក់ដែរ រឿងអី ត្រូវបញ្ជូនកងទ័ពខ្មែរសេរី របស់គាត់ឱ្យទៅផ្តួលរំលំសម្តេចសីហនុ ដើម្បីលើក ដាប ឈួន ជាមនុស្សមិនចេះដឹង ឆេវឆាវ និងកាចសាហាវ ឱ្យឡើងកាន់អំណាចដឹកនាំប្រទេស នោះ?។

សម្តេចសីហនុ បានហៅផែនការក្បត់របស់ដាប ឈួន ថា៖ "ផែនការក្បត់ ក្រុងបាងកក" ព្រោះរាជរដ្ឋាភិបាលថៃ ដោយមានសេនាប្រមុខសារិត ថាណារ៉ាត (Sarit Thanarat) ជានាយករដ្ឋមន្ត្រី ជាអ្នកនៅពីក្រោយខ្នងដាប ឈួន ហើយពេលនោះ កងទ័ពថៃ ក៏កំពុងរំលោភបំពានមកលើប្រាសាទព្រះវិហារ យ៉ាងព្រហើនកោងកាចផងដែរ។

# ១១៥
# លន់ នល់ នាំកងទ័ពទៅបង្ក្រាបដាប ឈួន




**ឧត្តមសេនីយ៍លន់ នល់**

នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៥៩ ដោយមានការជួយសម្របសម្រួលពីសំណាក់អង្គការសហប្រជាជាតិ ព្រះរាជាណាចក្រកម្ពុជា ក៏បានភ្ជាប់ទំនាក់ទំនងការទូត ជាមួយព្រះរាជាណាចក្រថៃ ឡើងវិញ ។ ថ្ងៃទី២០ ខែកុម្ភៈនោះហើយ ជាថ្ងៃផែនការធ្វើរដ្ឋប្រហាររបស់ដាប ឈួន ដែលមានពួកសេអ៊ីអា និងរដ្ឋការវៀតណាមខាងត្បូង ព្រមទាំងថៃ នៅពីក្រោយខ្នង ត្រូវបែកការណ៍ ហើយសម្តេចសីហនុ បានបញ្ជាឱ្យលន់ នល់ ជាទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារប្រទេស ដឹកនាំកម្លាំងទាហានថ្មើរជើងចំនួនពីរកងវរសេនាតូច មានទាំងរថពាសដែកផង ទៅកាន់ក្រុងសៀមរាប ដើម្បីចាប់ឈួន ម្ចុលពេជ្រ យកមកកាត់ទោស។

លោកតាទួន ទេស ជាគ្រូបង្រៀននៅទីរួមខេត្តសៀមរាប និងជាមិត្តភក្តិរបស់ស្លាត ពៅ (ប្អូនដាប ឈួន) សម័យនោះ បានអះអាងព្រឹត្តិការណ៍ទៅឡោមព័ទ្ធចាប់ដាប ឈួន នៅក្រុងសៀមរាប នោះថា នៅយប់ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ១៩៥៩ ក្បួនរថយន្តរបស់កងទ័ពរាជរដ្ឋាភិបាល ដឹកនាំដោយ លន់ លន់ បានធ្វើដំណើរទៅដល់ទីរួមខេត្តកំពង់ធំ ចាប់មេបញ្ជាការកងវរសេនាតូចលេខ១៥ ក្រោមបញ្ជាការរបស់ដាប ឈួន ឲ្យអង្គុយលើក្បាល



**កងទ័ពឆត្រយោងសម័យសង្គមរាស្ត្រនិយម**

រថយន្ត នាំមុខចេញដំណើរសំដៅទៅរកបន្ទាយកងវរសេនាតូចលេខ៧ របស់ដាប ឈួន នៅទីរួមខេត្តសៀមរាប បន្តទៀត។

មូលហេតុលន់លន់បញ្ជាឱ្យពលទាហានរបស់គាត់ចាប់មេបញ្ជាការកងវរសេនាតូចលេខ១៥ នៅទីរួមខេត្តកំពង់ធំ ជាចំណាប់ខ្មាំង ឲ្យអង្គុយលើក្បាលរថយន្តនាំមុខនោះ គឺដើម្បីកាពារ កុំឲ្យកងទ័ពរបស់ដាប ឈួន នៅបន្ទាយកងវរសេនាតូចលេខ៧ នៅទីរួមខេត្តសៀមរាប បាញ់ប្រហារទៅលើពួកគាត់។ តែបើពួកគេហ៊ានបាញ់ ប្រាកដជាត្រូវមេបញ្ជាការកងវរសេនាតូចលេខ១៥ ដែលអង្គុយលើក្បាលរថយន្ត នាំមុខនោះ ជាមិនខាន។

នៅវេលាម៉ោង៨ព្រឹក ថ្ងៃអាទិត្យទី២២ ខែកុម្ភៈ ឆ្នាំ១៩៥៩ ក្បួនរថយន្តកងទ័ពរាជ-រដ្ឋាភិបាល បានចូលទៅដល់កណ្តាលទីរួមខេត្តសៀមរាប។ តែពេលនោះ ដាប ឈួន ដឹងខ្លួនមុន ក៏បានរត់គេចខ្លួនជាមួយកូនចៅជំនិត៧នាក់ទៀត ឆ្លងស្ទឹងទៅដល់ភូមិស្នាសង្គ្រាម ក្នុងឃុំបល្ល័ង្ក រួចទៅហើយ។ នៅពេលឈប់សម្រាកនៅភូមិស្នាសង្គ្រាមនោះ ដាប ឈួន ក៏ប្រើកូនចៅគាត់ឱ្យទៅហៅប្រពន្ធទី២របស់គាត់ ឈ្មោះចាន់ ឆោម ហៅយាយក្តុមស័ក្តិ រស់នៅ

## របត់នយោបាយ

ឯភូមិត្បែងខាងកើត ក្នុងឃុំត្បែង ឱ្យមកជួបគាត់នៅភូមិស្នាសង្គ្រាម ដើម្បីបន្តដំណើរទៅភ្នំគូលែន ទាំងអស់គ្នាបន្តទៀត។

ពេលនោះ ប្អូនប្រុសគាត់ឈ្មោះស្លាត ពៅ ក៏រត់គេចខ្លួនដែរ ដោយឱ្យកូនទាហានរបស់ដាប ឈួន ម្នាក់ឈ្មោះ វ៉ាត ជាអ្នកជូនផ្លូវ។ ពេលរត់ទៅដល់ឃុំពាក់ស្នែង ស្រុកអង្គរធំ ស្លាត ពៅ ក៏ត្រូវពួកទាហានលន់ នល់ ដេញតាមចាប់បាន នាំយកមកវិញ។ តែទាហានជាអ្នកជូនផ្លូវ ឈ្មោះ វ៉ាត នោះ ក៏ត្រូវគេបាញ់សម្លាប់ចោលដែរ។ ពេលនោះមេបញ្ជាការឈ្មោះចំរើន ស៊ិន បានបញ្ជាឱ្យស័ក្តិ៣ ហេង នាំកម្លាំងប្រមាណ៣០នាក់ទៅពួនស្ទាក់នៅវាលសារឿន។

នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៥៩ ដាប ឈួន និងយាយក្តុមស័ក្តិ ជាប្រពន្ធទី២ ព្រមទាំងកូនចៅជំនិត៧នាក់ រួមទាំងអ្នកជូនផ្លូវ ២នាក់ទៀត បានដើរចូលក្នុងអន្ទាក់របស់ក្រុមស័ក្តិ៣ ហេង កំពុងពួនស្ទាក់នៅវាលសារឿន នោះ។ ពេលនោះ ស័ក្តិ៣ ហេង បានស្រែកឱ្យដាប ឈួន ទម្លាក់អាវុធ តែគាត់មិនព្រម ពួកគេក៏បាញ់គាត់ត្រូវដៃឱ្យរងរបួសជាធ្ងន់ ហើយអ្នកនៅជាមួយគាត់ទាំងអស់ ក៏ត្រូវចាប់ខ្លួនបានដែរ។ បន្តិចក្រោយមក កូនទាហានជំនិតរបស់ដាប ឈួន ទាំង៧នាក់ ត្រូវស័ក្តិ៣ ហេង បញ្ជាឱ្យកូនទាហានរបស់គាត់យកទៅបាញ់សម្លាប់ចោល នៅប្រហែលចម្ងាយ៥០០ម៉ែត្រ ពីវត្តស្រែណូយ។

បន្ទាប់មក ស័ក្តិបី ហេង ក៏បានប្រមូលអ្នកភូមិបាន៨នាក់ឱ្យមកជួយសែង ដាប ឈួន ពីវាលសារឿន មកដាក់នៅផ្ទះប្រធានភូមិស្រែណូយ ក្នុងស្រុកវ៉ារិន ហើយប្រាប់ម្ចាស់ផ្ទះ ឱ្យចេញទៅឆ្ងាយអស់ ដើម្បីឱ្យមេបញ្ជាការបើកប្រតិបត្តិការនៅទីនោះសួរចម្លើយ រហូតដល់យប់ថ្ងៃទី២ ខែមីនា ឆ្នាំ១៩៥៩។ សម្តេចសីហនុ បានដាក់បញ្ជាឲ្យលន់ នល់ ថា ធ្វើយ៉ាងណាចាប់ដាប ឈួន ឲ្យបានទាំងរស់។ ពេលនោះ លន់ នល់ កំពុងតែស្ថិតនៅទីក្រុងសៀមរាប បាននិយាយតាមវិទ្យុទាក់ទងទៅមេបញ្ជាការជាអ្នកសួរចម្លើយដាប ឈួន នៅស្រែណូយនោះថា យ៉ាងម៉េចទៅហើយ? មេបញ្ជាការនោះ ឆ្លើយប្រាប់លន់ នល់ ថា ចាប់បានដាប ឈួន ហើយ តែបាញ់ឲ្យរបួសធ្ងន់ មិនដឹងថាស្លាប់ ឬយ៉ាងណានោះទេ។ ស្រាប់តែព្រឹក

ឡើងថ្ងៃ៣ ខែមីនា សាកសពគាត់ត្រូវគេដឹកតាមរថយន្តហ្សេអឹមសេ (GMC) មកដល់ទីក្រុងសៀមរាប។



**គឹម ស្រី កាលនៅពាក់ស័ក្តិ១**
(រូបថត Home et histore du Cambodge)

ដាប ឈួន រងរបួសដៃស្តាំជាទម្ងន់ ក្រោយពេលសួរចម្លើយអស់រយៈពេល៤ថ្ងៃមក ត្រូវបានគេសង្ស័យថា គាត់បានឆ្លើយដាក់មន្ត្រីជាន់ខ្ពស់នៅក្នុងជួររាជរដ្ឋាភិបាលមួយចំនួនទៀត បានចូលរួមក្នុងសកម្មភាពក្បត់ជាមួយគាត់ ដើម្បីផ្តួលរំលំសម្តេចសីហនុ ដែរ។ ដូច្នេះមេបញ្ជាការបើកប្រតិបត្តិការនៅស្រែណូយនោះ បានយកគាត់ទៅបាញ់សម្លាប់នៅមុខវត្តស្រែណូយ ក្នុងយប់ថ្ងៃទី២ ខែមីនា ដើម្បីបំបិទមាត់កុំឱ្យជាប់ពាក់ព័ន្ធដល់មន្ត្រីជាន់ខ្ពស់ផ្សេងៗ មួយចំនួនទៀត។

ពេលរថយន្តហ្សេអឹមសេ(GMC) ដឹកសាកសពដាប ឈួន យកមកទម្លាក់នៅខាងជើងសាលាខេត្តសៀមរាប នៅព្រឹកថ្ងៃ៣ ខែមីនានោះ ប្រជាពលរដ្ឋប្រុសស្រីក្មេងចាស់សិស្សានុសិស្ស នាំគ្នាមកចោមរោមមើលយ៉ាងច្រើនកុះករ។ សាកសពរបស់គាត់មានទាក់កនឹងខ្សែក្រវាត់មកស្រាប់ ត្រូវបានគេទាញអូសយកទៅដឹកដឹកប់នៅក្នុងរណ្តៅមួយ នៅមិនឆ្ងាយប៉ុន្មាន ពីសាលាខេត្ត។ ពេលនោះបងប្អូនរបស់ដាប ឈួន ពីរនាក់ទៀត គឺអនុសេនីយ៍ឯក គឹម ស្រី និងឈ្មោះគឹម ពេញ ជាអ្នករកស៊ីរត់ពន្ធអាវុធដ៏ល្បីល្បាញ ក៏ត្រូវចាប់ខ្លួនដែរ។

លោកតាទួន ទេស បានអះអាងបន្តថា ថ្ងៃទី៤ ខែមីនា ឆ្នាំ៩៥៩ សម្តេចសីហនុ បានយាងទៅដល់ទីក្រុងសៀមរាប ដើម្បីពិនិត្យមើលសភាពការណ៍នៃការបង្ក្រាបដាប ឈួន ដោយផ្ទាល់។

ពេលនោះ ស ហួយ ជាសមាជិកគណៈកម្មការដឹកនាំចលនាសង្គមរាស្ត្រនិយម ប្រចាំ

ខេត្តសៀមរាប និងជាបក្ខពួករកស៊ីជាមួយដាប ឈួន បានឡើងមានមតិសម្តែងនូវភាពស្មោះត្រង់របស់គាត់ ចំពោះព្រះភក្ត្រសម្តេចសីហនុ ថា គាត់បានរកស៊ីចូលហ៊ុនគ្នាមែន តែគាត់មិនបានចូលរួមសកម្មភាពក្បត់ជាមួយដាប ឈួន ទេ។ តែយ៉ាងណា ក្រោយពីឡើងមានមតិចប់ គាត់ត្រូវក្រុមប៉េអឹម ចាប់កៀកលើក ដាក់លើរថយន្តយកទៅបាត់។ មិនយូរប៉ុន្មានតុលាការសឹកនៅក្រុងភ្នំពេញ បានប្រកាសកាត់ទោសប្រហារជីវិត ស ហួយ។ តែគាត់ ត្រូវបានព្រះមហាក្សត្រ បន្ធូរបន្ថយទោស ឲ្យមកនៅត្រឹមជាប់ពន្ធនាគារអស់មួយជីវិតវិញ។

ក្រោយពីជាប់ពន្ធនាគារបាន៤ឆ្នាំ ស ហួយ ក៏ត្រូវបានព្រះមហាក្សត្រប្រោសប្រទានលើកលែងទោស ឱ្យមានសេរីភាពវិញ។ ចំណែក ស្លាត ពៅ (ប្អូនដាប ឈួន) ដែលត្រូវចាប់ខ្លួនបញ្ជូនទៅឱ្យតុលាការសឹកនៅក្រុងភ្នំពេញ បានសារភាពថា គាត់បានស្មគ្រចិត្តធ្វើជាភ្នាក់ងារសេ.អ៊ី.អា (CIA) របស់សហរដ្ឋអាមេរិក នៅពេលគាត់ត្រូវបានតែងតាំងជាសមាជិកគណៈប្រតិភូរបស់ប្រទេសកម្ពុជា អមព្រះរាជដំណើរសម្តេចសីហនុ ទៅចូលរួមក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក ក្នុងឆ្នាំ១៩៥៨។

ក្រោយពេលត្រលប់មកមាតុប្រទេសវិញ ភ្នាក់ងារសម្ងាត់សេអ៊ីអា របស់អាមេរិក ឈ្មោះវិចទ័រ ម៉ាត់ស៊ូ ជាជនជាតិជប៉ុន ចូលសញ្ជាតិអាមេរិក នៅស្ថានទូតអាមេរិក នៅក្រុងភ្នំពេញ បានទាក់ទងសម្ងាត់ជាមួយដាប ឈួន តាមរយៈស្លាត ពៅ នេះឯង។

ស្លាត ពៅ (គឹម ពៅ)និង គឹម ស្រី ជាប្អូនរបស់ដាប ឈួន (គឹម ឈួន) និងជនជាតិយួនខាងត្បូង២នាក់ទៀត ជាអ្នកមកជួយរៀបចំដំឡើងវិទ្យុទាក់ទងនៅផ្ទះដាប ឈួន ក៏ត្រូវតុលាការសឹកកាត់ទោសប្រហារជីវិតដែរ។

អ្នកទោសទាំង៤នាក់នេះ ត្រូវបានគេដឹកតាមរថយន្តពីក្រុងភ្នំពេញ យកមកចងផ្អោបនឹងបង្គោលសសរ៤ដើម ដែលគេរៀបចំទុកជាស្រេច នៅវាលត្រពាំងតាឡោ ជាយក្រុងសៀមរាប ។

មុនពេលបាញ់ប្រហារជីវិត តុលាការបានសូត្រសាលក្រម ឲ្យអ្នកទោសទាំង៤នាក់ស្តាប់ ហើយចាប់ផ្តើមយកក្រណាត់ខ្មៅមកចងរុំភ្នែក រួចលោកអាចារ្យឱ្យធម៌។ ពេលនោះ



**កាសែតមាតុភូមិ ឆ្នាំទី៧ លេខ២៦៤៧ ថ្ងៃទី៧ ខែមីនា ឆ្នាំ១៩៥៩**
**ចុះផ្សាយពីព្រឹត្តិការណ៍សម្លាប់ ដាប ឈួន ថ្ងៃទី២១ កុម្ភៈ ឆ្នាំ១៩៥៩** (រូបថត Ta Reak)

ស្លាត ៣៧ មានការតក់ស្លុត រហូតទន់ជង្គង់ ខណៈជនជាតិយួនម្នាក់ស្រែកថា បរាជ័យ សីហនុ។

លោកតាទួន ទេស បានអះអាងបន្តទៀតថា តាំងពីនៅជាមេដឹកនាំខ្មែរឥស្សរៈមក

ម៉្លេះ គាត់មានជំនឿថា បារមីព្រះអង្គចេក ព្រះអង្គចម ដែលនៅក្រោមដើមធ្លកធំមួយ នៅឃុំតៀង ស្រុកបន្ទាយស្រី តាមជួយថែរក្សាគាត់ ហើយគាត់បានស្បថសច្ចាថា ប្រសិនបើគាត់ក្បត់ជាតិ ក្បត់ព្រះមហាក្សត្រ សូមបារមីព្រះអង្គចេកព្រះអង្គចម ផ្តាច់ជីវិតគាត់ចុះ។

មុនពេល ដាប ឈួន សម្រេចចិត្តចូលរួមគំនិតក្បត់ជាមួយពួកបរទេស ប្រឆាំងនឹងសម្តេចសីហនុ គាត់ធ្លាប់បានទៅធ្វើពិធីបន់ស្រន់មួយ នៅមុខព្រះអង្គចម ក្នុងភូមិត្បែងខាងកើត ឃុំត្បែង ស្រុកបន្ទាយស្រី។ គាត់បានឱ្យគេលេងភ្លេងពិណពាទ្យ៣បទ រួចគាត់លើកកាំភ្លើងកាប៉ាប៊ីន ផ្សងសច្ចាថា បើគាត់បាញ់ទៅ គ្រាប់កាំភ្លើងមិនផ្ទុះ នឹងគ្មានអ្វីដែលនាំគាត់ក្បត់សម្តេចសីហនុ បានទេ។ ពេលបាញ់គ្រាប់ទី១ ឡើងទៅលើ គ្រាប់កាំភ្លើងមិនផ្ទុះទេ តែដល់ពេលគាត់បាញ់បន្ថែម ១គ្រាប់ទៀត គ្រាប់កាំភ្លើង ក៏ផ្ទុះ ផាំង គាត់គិតខ្លួនគាត់ថា គាត់ប្រហែលជាក្បត់ហើយ នៅពេលខាងមុខ។ តែមានពាក្យចចាមអារ៉ាមថា ពេល ដាប ឈួន រត់គេចខ្លួននោះ គាត់បានយកបដិមាព្រះអង្គចេកព្រះអង្គចម ដែលគាត់យកតម្កល់ទុកនៅក្នុងភូមិគ្រឹះរបស់គាត់ ដើម្បីថ្វាយបង្គំគោរពបូជានោះ ទៅជាមួយដែរ។ តែគាត់យកទៅមិនរួច ដោយសារគាត់ក្បត់នឹងពាក្យសច្ចានោះ។

លោកតាទួន ទេស ពេលនោះជាគ្រូបង្រៀននៅក្នុងក្រុងសៀមរាប បានអះអាងថាតាមពិតទៅ នៅពេលពួកទាហានដឹកនាំដោយលន់ នល់ មករកចាប់ដាប ឈួន នៅថ្ងៃទី២២ ខែកុម្ភៈនោះ បដិមាព្រះអង្គចម ស្ថិតនៅក្នុងភូមិត្បែងខាងកើត ឃុំត្បែង ឯបដិមាព្រះអង្គចេក ស្ថិតនៅភូមិមួយផ្សេងទៀត(ភូមិម្រាក់មា?) ឯណោះ។ មិនមែននៅក្នុងភូមិគ្រឹះរបស់គាត់ទេ។ នៅថ្ងៃដដែលនោះ ពួកទាហានក៏បានដឹកបដិមាព្រះអង្គចេកព្រះអង្គចម យកមកតម្កល់នៅទីរួមខេត្តសៀមរាប ដើម្បីទុកឱ្យប្រជារាស្ត្រគោរពបូជា រហូតដល់សព្វថ្ងៃ។

ដាប ឈួន មានឈ្មោះកំណើត គឹម ឈួន កើតនៅក្នុងឆ្នាំ១៩១២ នៅខេត្តសៀមរាប តែបានទៅរស់នៅឯខេត្តព្រៃវែង។ លុះពេលពេញវ័យ គាត់បានចូលបម្រើការងារជាទាហានកងរក្សាស្រុក ដែលប្រជារាស្ត្រសាមញ្ញ ហៅថាទាហានជើងខ្មៅ(ស្បែកជើងពណ៌ខ្មៅ) នៅខេត្តសៀមរាប មានឋានន្តរស័ក្តិជាពលបាលត្រី (ដោយ១ជាន់)។ ទាហានកងរក្សាស្រុកនេះ

មានតួនាទីជាអ្នកថែរក្សាសណ្តាប់ធ្នាប់ និងសន្តិសុខនៅតាមស្រុកខេត្តទូទាំងប្រទេស។

ក្រោយសង្គ្រាមលោកលើកទី២ ត្រូវបានបញ្ចប់ បារាំងទាមទារយកខេត្តបាត់ដំបង និងសៀមរាប ពីថៃមកឱ្យខ្មែរវិញ ថៃក៏បានបង្កើតចលនាខ្មែរឥស្សរៈជាច្រើនក្រុម ដើម្បីឱ្យតស៊ូប្រឆាំងនឹងបារាំង។ ពេលនោះ ថៃក៏បានអូសទាញ ដាប ឈួន ឱ្យចូលរួមក្នុងចលនាតស៊ូខ្មែរឥស្សរៈនោះដែរ ដោយសន្យាថា តំឡើងឋានន្តរស័ក្តិឱ្យគាត់ពីពលបាលត្រីឱ្យទៅជាព្រឹន្ទបាល។



**ស្លាត ពៅ ហៅ គឹម ពៅ**
(រូបថត Home et histore du Cambodge)

បន្ទាប់ពីបានចូលរួមក្នុងចលនាតស៊ូខ្មែរឥស្សរៈដែលបង្កើតឡើងដោយអាជ្ញាធរថៃ នោះមក គាត់ត្រូវបានគេហៅឈ្មោះថា ដាប ឈួនៗ ចាប់ពីពេលនោះមក។ លុះដល់ក្រោយ ពេលគាត់ចុះចូលជាមួយសម្តេចសីហនុ មកចូលរួមក្នុងសង្គមជាតិវិញក្នុងឆ្នាំ១៩៤៩ ហើយ បានឡើងឋានៈជាសមាជិកគណៈរដ្ឋមន្ត្រី នៅក្នុងឆ្នាំ ១៩៥៦មក គាត់ក៏បានដូរឈ្មោះជា ឈួន ម្ជុលពេជ្រ វិញ។

គេមិនដឹងច្បាស់ថា គាត់មានបងប្អូនប៉ុន្មាននាក់ទេ គ្រាន់តែដឹងថា ប្អូនប្រុសគាត់ម្នាក់ឈ្មោះ គឹម ពេញ ជាមេឈ្មួញជួញដូរអាវុធម្នាក់ទៀតឈ្មោះគឹម ស្រី ជាទាហានមានឋានន្តរស័ក្តិជាអនុសេនីយ៍ឯក(ស័ក្តិ៣)និងប្អូនប្រុសម្នាក់ទៀតឈ្មោះគឹម ពៅ ហៅស្លាត ពៅ ជាមន្ត្រីធ្វើការនៅក្រសួងការបរទេស ក្រោយ មកបានក្លាយជាសមាជិកគណៈកម្មាធិការចលនាសង្គមរាស្ត្រនិយមនៅខេត្តសៀមរាប។

# ១១៦
# សេអ៊ីអា និងផែនការក្បត់របស់សម សារី និងដាប ឈួន



**អាល់ឡិន ឌុល្លេស នាយកភ្នាក់ងារសេអ៊ីអា ពីឆ្នាំ១៩៥៣ ដល់១៩៦១**

នៅដើមឆ្នាំ២០០០ លោកយាយចាន់ ឆោម ដែលអ្នកស្រុកតែងហៅគាត់ថា យាយក្ដុមស័ក្ដិ ហើយគាត់កាន់តែមានវ័យចាស់ជរាទៅហើយនោះ បានឱ្យដឹងថា គាត់ប្រពន្ធទី២របស់ដាប ឈួន។ ចំណែកប្រពន្ធទី១ ឈ្មោះ តាំង អ៊ឹម។ កាលនៅជាមេដឹកនាំចលនាខ្មែរឥស្សរៈ នៅតំបន់ភ្នំគូលែន ដាប ឈួន ក៏បានយកគាត់ធ្វើជាប្រពន្ធទី២។ គាត់ក៏ជាស្រីល្បីថា ខ្លាំងពូកែ បាញ់មិនមុត ដុតមិនឆេះ។ ដោយសារគាត់មានសក់ជាញ់ នៅផ្នែកខាងក្រោម គាត់អាចជួយការពារដាប ឈួន ជាប្ដី បានទៀតផង។

លោកយាយចាន់ ឆោម ហៅក្ដុមស័ក្ដិ បានបញ្ជាក់ថា នៅពេលទាហានរបស់ លន់ នល់ មករកចាប់នោះ ប្ដីរបស់គាត់ (ឈួន ម្ចុលពេជ្រ) បានរត់គេចខ្លួន ហើយបានឱ្យកូនទាហាន ទៅយករូបគាត់ជាប្រពន្ធទី២ នៅក្នុងឃុំត្បែង ដើម្បីនាំរូបគាត់រត់គេចខ្លួនទៅប្រទេសថៃ បន្តទៀត។ ប៉ុន្តែ ពេលរត់មកដល់ឃុំស្រែណូយ ស្រុកវ៉ារិន ក៏ត្រូវពួកទាហានលន់ នល់ ស្ទាក់បាញ់នៅក្នុងព្រៃ ត្រូវប្ដីរបស់គាត់ ចំនួន២គ្រាប់ គាត់ក៏រត់ទៅឃំឱបប្ដី។ ពេលនោះ ប្ដី



**យាយក្តុមសក្តិ និងដាប ឈួន ជាមួយប្រពន្ធដើមឈ្មោះតាំង អ៊ឹម**

របស់គាត់ បានប្រាប់ឱ្យគាត់យកកាំភ្លើងខ្លី បាញ់បន្ថែមទៀត ដើម្បីបញ្ចប់ជីវិតតែម្តងទៅ តែគាត់មិនអាចលើកដៃ បាញ់សម្លាប់ប្តីបានទេ។ បន្តិចក្រោយមក ពួកទាហានលន់ នល់ ក៏ចូលមកដល់ ចាប់ទាញគាត់ចេញពីប្តី រួចបញ្ជូនគាត់ទៅឱ្យ លន់ នល់ ដើម្បីសួរចម្លើយ នៅទីក្រុងសៀមរាប។ តែក្រោយមក លន់ នល់ ក៏បានដោះលែងគាត់ ឱ្យត្រលប់ទៅផ្ទះសម្បែងវិញ ដោយមិនបានយកទោសពៃរ៍អ្វីឡើយ។

ចំណែកនៅក្នុងភូមិគ្រឹះរបស់ឈួន ម្ជុលពេជ្រ គេបានរកឃើញឯកសារជាច្រើនទាក់ទងនឹងការផ្តល់ជំនួយផ្សេងៗដល់ ឈួន ម្ជុលពេជ្រ ដើម្បីធ្វើរដ្ឋប្រហារផ្តួលរំលំសម្តេចសីហនុ ដោយនៅផ្នែកខាងលើនៃឯកសារសម្ងាត់ខ្លះ មានដាក់ផ្លាកសញ្ញាថា ស្ថានឯកអគ្គរដ្ឋទូតវៀតណាមខាងត្បូង និងចុះហត្ថលេខាដោយឯកអគ្គរដ្ឋទូតវៀតណាមខាងត្បូង ង៉ូ ត្រុងហៀវ។

នៅថ្ងៃទី២០ ខែមករាឆ្នាំ ១៩៥៩ ដោយសង្ស័យថាបានសមគំនិតក្នុងការប៉ុនប៉ងធ្វើរដ្ឋប្រហារនេះ ពួកអតីតអ្នកតស៊ូជាមួយសឺង ង៉ុកថាញ់ នៅភ្នំដងរែក ក៏ត្រូវសមត្ថកិច្ចចាប់ខ្លួនព្រមៗគ្នាតែម្តង ក្នុងនោះរួមមាន៖ អតីតអនុសេនីយ៍ទោដួង ចន្ទសាវ៉ាត បានទៅរកស៊ីលក់សាំងនៅទន្លេបិទខេត្តកំពង់ចាម ត្រូវជាប់ពន្ធនាគារ ៥ឆ្នាំ, អ៊ីវ យ៉ាង ធ្វើជាគ្រូបង្រៀនវិទ្យាល័យឯកជន និងធ្វើមេជាវីជាមួយជនជាតិក្លឹងម្នាក់ នៅក្រុងភ្នំពេញ ត្រូវតុលាការសឹក កាត់ទោសដាក់ពន្ធនាគារ ៧ឆ្នាំកន្លះ។ ឆាយ យ៉ត ត្រូវចាប់ខ្លួនជាមួយអ៊ីវ យ៉ាង ដែរ។ គាំ រ៉ែត



**សាង សាវាត**

ធ្វើការជាមួយក្រុមហ៊ុនជំនួញមហាបូព៌ាពាណិជ្ជកម្ម នៅខាងជើងផ្សារធំថ្មីខាងផ្នែកនាំទំនិញចេញចូល មានខ្សែរយៈទាក់ទងជិតស្និទ្ធជាមួយរាជវង្ស ជាប់ពន្ធនាគារ ៣ ឆ្នាំ, ហង្ស ធុនហាក់ ត្រូវរួចទោស ដោយសារគាត់ជាអ្នកដឹកនាំសិល្បៈរបាំព្រះរាជទ្រព្យនៅក្នុងព្រះបរមរាជវាំង ធ្វើឱ្យព្រះមហាក្សត្រិយានីកុសុមៈ ពេញព្រះទ័យ, ប៉ែន គិត បានរួចទោស ដោយសារចេះជំនាញជំឡើងស្ថានីយវិទ្យុ, អៀ ស៊ីចូវ បានរួចទោស ដោយសារព្រះមហាក្សត្រ នរោត្តម សុរាម្រិត ជួយធ្វើអន្តរាគមន៍។

ចំណែក សាង សាវ៉ាត ជាចាងហ្វាងសារព័ត៌មានខ្មែរថ្មី សារព័ត៌មានទៅមុខ សារព័ត៌មានឈាមខ្មែរ និងបាននិពន្ធប្រលោមលោកដ៏សែនជក់ចិត្ត គឺរឿងតេជោក្រហម និងរឿងមហាចោរនៅទល់ដែន ត្រូវស័ក្តិបី សេក សំអៀត ជាអ្នកទៅចាប់ផ្ទាល់ ដោយបានយកជើងទៅឈូសសំណៅនិពន្ធរបស់គាត់ឲ្យធ្លាក់រាយប៉ាយ។ គាត់ត្រូវបានដោះលែងវិញ តែក្រោយមកត្រូវឃាតករមិនស្គាល់មុខលួចសម្លាប់។

ជាមួយគ្នានោះ គេបានរកឃើញដុំមាសចំនួន២៧០ដុំ ក្នុងមួយដុំៗ មានទម្ងន់ ១គីឡូក្រាម និងមានបោះត្រាធនាគារជាតិវៀតណាមខាងត្បូង ព្រមទាំងឧបករណ៍វិទ្យុទាក់ទង និងអាវុធគ្រាប់រំសេវជាច្រើនទៀត។ នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៥៩ ភស្តុតាងទាំងអស់នេះ សម្តេចសីហនុ ទៅចូលរួមជាព្រះអធិបតី ក្នុងពិធីដាក់បង្ហាញចំពោះមុខអ្នកការទូតបរទេសទាំងអស់ និងគណៈកម្មការត្រួតពិនិត្យអន្តរជាតិ (ICC) រួមទាំងឯកអគ្គរដ្ឋទូតវៀតណាមឈ្មោះង៉ូ ត្រុងហៀវ នោះផងដែរ ឱ្យបានឃើញជាក់ស្តែង។

សម្តេចសីហនុ បានប្រកាសជាសាធារណៈថា ប្រធានភ្នាក់ងារសម្ងាត់សេ.អ៊ី.អា(-CIA) របស់សហរដ្ឋអាមេរិក ឈ្មោះ អាល់ឡិន ឌុល្លេស(Allan Dulles) ជាមេខ្លោងក្នុងការរៀបចំផែនការផ្តួលរំលំព្រះអង្គចេញពីអំណាច ដោយមានការចូលរួមពីរាជរដ្ឋាភិបាលក្រុង បាងកក និងរដ្ឋការក្រុងព្រៃនគរ ផងដែរ។ កាលពីឆ្នាំ១៩៥៥ អាល់ឡិន ឌុល្លេស (Allan Dulles) នេះ ជាប្អូនប្រុសរបស់រដ្ឋមន្ត្រីក្រសួងការបរទេស សហរដ្ឋអាមេរិក ហ្វូស្ទ័រ ឌុល្លេស (Foster Dulles) ធ្លាប់មកដល់ទីក្រុងភ្នំពេញ ដើម្បីព្យាយាមនិយាយបញ្ចុះបញ្ចូលសម្តេចសីហនុ ឱ្យដាក់ប្រទេសកម្ពុជា នៅក្រោមឆត្រការពាររបស់អង្គការសេអាតូ (SEATO) ម្តងរួចមកហើយ តែត្រូវសម្តេចសីហនុ បដិសេធ។

យោងតាមឯកសារនាយកផ្នែកចារកម្មនយោបាយរបស់ប្រធានាធិបតីវៀតណាមខាងត្បូង ង៉ូ ឌិញយៀម ឈ្មោះត្រាន គីមទ្វៀង(Tran Kim Tuyen) សរសេរនៅឆ្នាំ១៩៧០ បានឱ្យដឹងថា៖ "នៅក្នុងខែធ្នូ ឆ្នាំ១៩៥៨ ង៉ូ ឌិញញូ ជាទីប្រឹក្សា និងជាប្អូនប្រុសរបស់ប្រធានាធិបតីវៀតណាមខាងត្បូង ង៉ូ ឌិញយៀម បានបញ្ជាឱ្យឯកអគ្គរដ្ឋទូតវៀតណាមខាងត្បូងប្រចាំនៅទីក្រុងភ្នំពេញ ឈ្មោះ ង៉ូ ត្រុងហៀវ (Ngo Trong Hieu) ធ្វើយ៉ាងណាបញ្ចុះបញ្ចូលសម្តេចសីហនុ ឱ្យផ្លាស់ប្តូរគោលនយោបាយរបស់ព្រះអង្គ កុំឱ្យលម្អៀងទៅរកពួកកុម្មុយនិស្តខ្លាំងពេក។ តែឯកអគ្គរដ្ឋទូតវៀតណាមរូបនេះ បានផ្តល់យោបល់ជំនួសវិញថា យើងគួរតែរៀបចំផែនការរដ្ឋប្រហារមួយ ដើម្បីផ្តួលរំលំសីហនុ វិញប្រសើរជាង។ ពេលនោះប្រធានាធិបតីវៀតណាមខាងត្បូង ង៉ូ ឌិញយៀម និងប្អូនប្រុសឈ្មោះង៉ូ ឌិញញូ ក៏បានយល់ព្រម"។

នៅក្នុងកំឡុងឆ្នាំ១៩៥៨ នោះដែរ ទំនាក់ទំនងការទូតរវាងប្រទេសកម្ពុជា ជាមួយប្រទេសថៃ និងវៀតណាមខាងត្បូង បានធ្លាក់ចុះអាប់អួរ ដោយសារតែប្រទេសថៃ បានបង្កជម្លោះចូលមកជណ្តើមប្រាសាទព្រះវិហារ។ ឯវៀតណាមខាងត្បូង បានបង្កជម្លោះចូលឈ្លានពានទឹកដីកម្ពុជា នៅខេត្តស្ទឹងត្រែង(កាលនោះនៅពុំទាន់បង្កើតខេត្តរតនគិរី ផ្តាច់ចេញពីខេត្តស្ទឹងត្រែង នៅឡើយទេ)។ នាយករដ្ឋមន្ត្រីថៃ សារិត ថាណារ៉ាត និងប្រធានាធិបតីវៀតណាមខាងត្បូង ង៉ូ ឌិញយៀម មានការខឹងសម្បាយ៉ាងខ្លាំងចំពោះសម្តេចសីហនុ មិន

ព្រមចូលជាមួយអង្គការសេអាតូ (SEATO) និងតែងតែប្រកាសថា ព្រះអង្គប្រកាន់យកមាគ៌ានយោបាយអព្យាក្រឹត តែការពិតព្រះអង្គបានរឹតចំណងមិត្តភាព និងសហប្រតិបត្តិការជាមួយសាធារណរដ្ឋប្រជាមានិតចិន កាន់តែជិតស្និទ្ធឡើងៗ ដោយព្រះអង្គបានយាងទៅបំពេញព្រះរាជទស្សនកិច្ចផ្លូវរដ្ឋនៅសាធារណរដ្ឋប្រជាមានិតចិន ហើយត្រូវបានមេដឹកនាំចិន ម៉ៅ សេទុង និងជូ អេនឡាយ ធ្វើពិធីបដិសណ្ឋារកិច្ចចំពោះព្រះអង្គយ៉ាងអធិកអធមកក់ក្ដៅបំផុត។

ដោយសារមានការផ្ដល់យោបល់ពី ង៉ូ ត្រុងហៀវ (Ngo Trong Hieu) ឯកអគ្គរដ្ឋទូតវៀតណាមខាងត្បូងប្រចាំនៅទីក្រុងភ្នំពេញ ប្រធានាធិបតីវៀតណាមខាងត្បូង ង៉ូ ឌិញ យៀម និងង៉ូ ឌិញញូ ជាប្អូនប្រុស និងជាទីប្រឹក្សារបស់ខ្លួនបានរៀបចំផែនការសម្ងាត់មួយដើម្បីផ្ដួលរំលំសម្ដេចព្រះ សីហនុ និងបង្កើតរបបគ្រប់គ្រងថ្មីមួយជំនួសវិញ។ ពេលនោះ ពួកសេអ៊ីអា(CIA)របស់អាមេរិក និងឧត្ដមសេនីយ៍សារិត ថាណារ៉ាត នាយករដ្ឋមន្ត្រីថៃ ក៏បានចូលរួមផ្ដល់ការគាំទ្រគម្រោងធ្វើរដ្ឋប្រហារផ្ដួលរំលំសម្ដេចសីហនុ នេះដែរ។

មេដឹកនាំថៃ និងវៀតណាមខាងត្បូង បានទាក់ទងសឹង ង៉ុកថាញ់ ដែលកំពុងរស់នៅក្នុងទឹកដីវៀតណាមខាងត្បូង។ ជាមួយគ្នានោះមេដឹកនាំថៃ និងបានទាក់ទង ដាប ឈួន ជាព្រះរាជប្រតិភូទទួលបន្ទុកអភិបាលខេត្តសៀមរាប ហើយមេដឹកនាំវៀតណាមខាងត្បូងតាមរយៈឯកអគ្គរដ្ឋទូតវៀតណាមខាងត្បូងប្រចាំនៅទីក្រុងភ្នំពេញ ឈ្មោះ ង៉ូ ត្រុងហៀវ បានទាក់ទងសម សារី ដែលកំពុងមានការតូចចិត្តពីរឿងសម្ដេចសីហនុ ដកតំណែងឯកអគ្គរាជទូតរបស់គាត់ប្រចាំនៅប្រទេសអង់គ្លេស ឱ្យត្រលប់មកនៅក្រុងភ្នំពេញ វិញនោះ ដើម្បីឱ្យអនុវត្តផែនការធ្វើរដ្ឋប្រហារផ្ដួលរំលំសម្ដេចសីហនុ ។

នៅចុងឆ្នាំ១៩៥៨ គ្រូបង្រៀនជនជាតិអាមេរិកម្នាក់ ឈ្មោះ រីឆាដ ស៊ីម៉ា (Richard Cima) បានមកបង្រៀនភាសាអង់គ្លេសនៅខេត្តសៀមរាប។ គាត់គឺជាគ្រូបង្រៀនជនជាតិអាមេរិក តែម្នាក់គត់ដែលបង្រៀនភាសាអង់គ្លេសនៅក្នុងខេត្តសៀមរាបនោះ។ ក្រោយផែនការរដ្ឋប្រហារផ្ដួលរំលំសម្ដេចសីហនុ ត្រូវបរាជ័យ គ្រូបង្រៀនជនជាតិអាមេរិក ឈ្មោះរីឆាដ ស៊ីម៉ា (Richard Cima) បានឱ្យដឹងថា៖ " មុនពេលមានផែនការធ្វើរដ្ឋប្រហារ ដាប ឈួន

បានទាក់ទងរាប់អានរូបគាត់ជាជនជាតិអាមេរិក ខុសពីការទាក់ទងរាប់អានជាមួយគ្រូជាជនជាតិបារាំង និងខ្មែរ ផ្សេងៗទៀត។ ម្តងម្កាល ដាប ឈួន បានហៅគាត់ឱ្យទៅជួបនៅការិយាល័យ ដើម្បីជជែកគ្នាពីនេះពីនោះ ខណៈគ្រូជនជាតិបារាំង និងខ្មែរ ផ្សេងទៀត ដាប ឈួន មិនដែលហៅឱ្យទៅជួបនៅការិយាល័យគាត់បែបនេះទាល់តែសោះ»។

រីឆាដ ស៊ីម៉ា (Richard Cima) បានរម្លឹកថា៖" ល្ងាចមួយ ដាប ឈួន ហៅរូបគាត់ទៅជួបដើម្បីជជែកគ្នាពីរឿងនយោបាយ រួចបានសុំឱ្យរូបគាត់ទូរសព្ទទៅឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ខាល ស្រ្តូម (Carl W. Strom) នៅទីក្រុងភ្នំពេញ ឱ្យអញ្ជើញមកខេត្តសៀមរាប ដើម្បីជួបពិភាក្សាគ្នា។ ពេលនោះគាត់ក៏បានទូរស័ព្ទទៅស្ថានទូតសហរដ្ឋអាមេរិកនៅទីក្រុងភ្នំពេញ តាមសំណូមពររបស់ដាប ឈួន តែឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ខាល ស្រ្តូម (Carl W. Strom)មិនបានឆ្លើយតបមកវិញឡើយ"។ រីឆាដ ស៊ីម៉ា (Richard Cima) គិតថា នៅពេលនោះ គាត់ល្ងង់ណាស់ ព្រោះមិនដឹងថារឿងនេះវាអាចមានគ្រោះថ្នាក់ដល់ខ្លួន ព្រោះការហៅទូរស័ព្ទពីខេត្តសៀមរាប ទៅទីក្រុងភ្នំពេញ ត្រូវឆ្លងកាត់ការត្រួតពិនិត្យដោយភ្នាក់ងាររាជរដ្ឋាភិបាល"។

តែយ៉ាងណាក៏ដោយ ប៉ុន្មានថ្ងៃក្រោយមក អនុព័ន្ធយោធាប្រចាំស្ថានទូតអាមេរិកាំងដើមកំណើតជប៉ុនម្នាក់ ឈ្មោះ វិចទ័រ ម៉ាត់ស៊ូយ (Victor Matsui) នៅទីក្រុងភ្នំពេញ បានធ្វើដំណើរមកទស្សនកិច្ចខេត្តសៀមរាប មួយរយៈពេលខ្លី ដើម្បីឆ្លៀតឱកាសជួបជាមួយមិត្តភក្តិគាត់ម្នាក់ឈ្មោះ ស្លាត ពៅ ជាតំណាងរាស្រ្តមណ្ឌលសៀមរាប និងជាប្អូនប្រុសរបស់ដាប ឈួន។ ស្លាត ពៅ នេះ ក៏ដូច សម សារី ដែរ ត្រូវបានគេសង្ស័យថាត្រូវបានភ្នាក់ងារសេអ៊ីអា (CIA) របស់សហរដ្ឋអាមេរិក ទាក់ទងជាសម្ងាត់កាលពីឆ្នាំ១៩៥៦ ខណៈពួកគាត់ទាំងពីរនាក់បានដង្ហែសម្តេចសីហនុ យាងទៅចូលរួមមហាសន្និបាទអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក។

ពេលនោះ វិចទ័រ ម៉ាត់ស៊ូយ (Victor Matsui) មានដើមកំណើតជាជនជាតិជប៉ុន ជាអនុព័ន្ធយោធាប្រចាំស្ថានទូតអាមេរិក នៅទីក្រុងភ្នំពេញ និងជាភ្នាក់ងារសេអ៊ីអា(CIA)ម្នាក់ដែរ


វិចទ័រ ម៉ាត់ស៊ូយ និងភរិយា

បានចូលរួមសហការអនុវត្តផែនការធ្វើរដ្ឋប្រហារផ្តួលរំលំសម្តេចសីហនុ ដោយផ្ទាល់ផងដែរ។

ក្រោយផែនការរដ្ឋប្រហារត្រូវបរាជ័យ វិចទ័រ ម៉ាត់ស៊ូយ (Victor Matsui) ត្រូវបានផ្ទេរចេញពីប្រទេសកម្ពុជា យ៉ាងឆាប់រហ័សឱ្យទៅបំពេញការងារជាអនុព័ន្ធយោធាប្រចាំស្ថានទូត សហរដ្ឋអាមេរិក នៅប្រទេសអេហ្ស៊ីប និងប្រទេសប៉ាគីស្ថាន។ នៅក្នុងឆ្នាំ១៩៦៦ វិចទ័រ ម៉ាត់ស៊ូ ត្រូវបានបណ្តេញចេញពីប្រទេសប៉ាគីស្ថាន ម្តងទៀត ដោយសារតែគាត់ធ្វើសកម្មភាព មិនស័ក្តិសមជាអ្នកការទូត។ តែយ៉ាងណា គាត់នៅតែបន្តការងារជាអនុពន្ធយោធាប្រចាំស្ថានទូតសហរដ្ឋអាមេរិក នៅបណ្តាប្រទេសផ្សេងៗទៀត ដូចជាប្រទេសម៉ាដាហ្កាស្កា ប្រទេស កូតឌីវ័រ និងប្រទេសកុងហ្គោ រហូតដល់ឆ្នាំ១៩៨៥ ទើបគាត់ចូលនិវត្តន៍។ វិចទ័រ ម៉ាត់ស៊ូ បានទទួលមរណភាពនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១២ នៅក្រុងហុងកុង ក្នុងជន្មាយុ៨៩ ឆ្នាំ។

ប្រភពព័ត៌មានមួយ បានឱ្យដឹងថា នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៥៩ សម្តេចសីហនុ បានរៀបចំពិធីអាពាហ៍ពិពាហ៍ម្ចាស់ក្សត្រីនរោត្តម បុប្ផាទេវី ជាបុត្រីច្បងរបស់ព្រះអង្គជាមួយព្រះអង្គម្ចាស់នរោត្តម នរិន្ទរៈ ទេវង្ស។ ពេលនោះ មន្រ្តីជាន់ខ្ពស់គ្រប់លំដាប់ថ្នាក់ ចាប់ពីចៅហ្វាយខេត្ត សមាជិកសភា រដ្ឋមន្រ្តី រហូតដល់នាយករដ្ឋមន្រ្តី បានទៅចូលរួមក្នុងពិធីអាពាហ៍ពិពាហ៍ដ៏អធិកអធមនេះ។ ប៉ុន្តែមានតែ ដាប ឈួន ជាមន្រ្តីជាន់ខ្ពស់មានតួនាទីព្រះរាជប្រតិភូទទួលបន្ទុកជាអភិបាលខេត្តសៀមរាប ម្នាក់គត់ដែលមិនបានមកចូលរួម ដោយសារ

ពេលនោះ គាត់ដាប់រវល់ទទួលមាសចំនួន ២៧០គីឡូក្រាម (តម្លៃឆ្នាំ១៩៥៩ ប្រមាណ ៣០៣,៨៥៨ ដុល្លារ) ពីពួកសេអ៊ីអា និងរដ្ឋការវៀតណាមខាងត្បូង ដើម្បីរៀបចំកម្លាំងកងទ័ព និងចំណាយទៅលើកិច្ចការផ្សេងៗទៀត។

២ថ្ងៃពីបន្ទាប់ទៀត ង៉ូ ឌិញយៀម បានបញ្ជូនឧបករណ៍វិទ្យុទាក់ទង និងអ្នកបច្ចេកទេស ជាជនជាតិវៀតណាម ២នាក់ ឱ្យមកដំឡើងឧបករណ៍វិទ្យុទាក់ទងនេះ មកខេត្តសៀមរាប សម្រាប់ឱ្យដាប ឈួន ធ្វើការទាក់ទងគ្នាជាមួយប្រធានចារកម្មរបស់ប្រធានាធិតីវៀតណាមខាងត្បូង និងស្ថានទូតវៀតណាមខាងត្បូង នៅទីក្រុងភ្នំពេញ។

អតីតមន្ត្រីអាកាសយានដ្ឋាននៅខេត្តសៀបរាប ឈ្មោះសៀវ ឆេងអ៊ី បានរម្លឹកពីព្រឹត្តិការណ៍នោះថា៖ ពេលនោះ គាត់បានឃើញយន្តហោះធំមួយចុះចតនៅលើទីលាន។ ក្នុងយន្តហោះនោះមានតែមនុស្សជិះតែពីរនាក់ គឺជនជាតិវៀតណាមក្នុងសម្លៀកបំពាក់ស៊ីវិលពាក់អាវដៃខ្លី។ ភ្លាមនោះដែរ គាត់ឃើញរថយន្តម៉ែរសឺដេស (Mercedes) ពណ៌ស្វាយរបស់ដាប ឈួន បើកចូលមកក្បែរយន្តហោះនោះ។

ដាប ឈួន ចុះពីរថយន្ត ហើយស្រែកប្រាប់គាត់ដែលនៅក្បែរនោះថា៖ «ថ្ងៃនេះយើងសប្បាយចិត្តណាស់!" ហើយដើរបង្ហួសទៅចាប់ដៃជនជាតិវៀតណាម២នាក់ ដែលកំពុងចុះពីយន្តហោះនោះ។ ពេលនោះគាត់មិនហ៊ាននិយាយស្តីអ្វីទាំងអស់។

មួយសន្ទុះក្រោយមក គាត់ឃើញយន្តហោះតូចស្អាតមួយគ្រឿងដែលគាត់មិនធ្លាប់ឃើញពីមុនៗមកនោះ បានហោះក្រវែលពីលើទីលានពីរបីជុំ ក៏ចុះចតនៅក្បែរយន្តហោះធំនោះដែរ។ នៅក្នុងយន្តហោះតូចនោះ ក្រៅពីអ្នកបើកបរ គាត់ឃើញមានតែអ្នកដំណើរជាជនជាតិអាមេរិកម្នាក់ប៉ុណ្ណោះ។ គាត់មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ព្រោះឃើញយន្តហោះធំដំបូង មានជនជាតិវៀតណាមពីរនាក់ បន្ទាប់មកឃើញយន្តហោះតូចមួយគ្រឿងចុះមកទៀតមានជនជាតិអាមេរិកម្នាក់។ ពេលជនជាតិអាមេរិកនោះ បើកទ្វារចេញមកក្រៅ ដាប ឈួន បានដើរទៅចាប់ដៃស្វាគមន៍។ តែគាត់មិនដឹងថាគេនិយាយគ្នាពីរឿងអ្វីទេ?។

សៀវ ឆេងអ៊ី បានរម្លឹកបន្តថា៖ ក្រោយពីនិយាយគ្នាមួយភ្លែត ជនជាតិអាមេរិករូប




**អាកាសយានដ្ឋានអង្គរសម័យសង្គមរាស្ត្រនិយម**

នោះ ក៏បានឡើងយន្តហោះតូចរបស់គេវិញ ហើយហោះឡើងទៅវិញបាត់បន្តិច គាត់ក៏ឃើញរថយន្តហ្សេអឹមសេមួយគ្រឿងដឹកទាហានរបស់ដាប ឈួន ប្រហែល១៥នាក់ចូលមក ហើយនាំគ្នាលើកឡាំងឈើធំៗចេញពីលើយន្តហោះធំនោះដាក់លើរថយន្ត រួចបើកចេញទៅក្រៅអាកាសយានដ្ឋាន តែមិនមែនសំដៅទៅទីរួមខេត្តសៀមរាបទេ គឺឆ្ពោះទៅផ្ទះដាប ឈួន នៅផ្លូវទៅប្រាសាទអង្គរ។ គាត់មិនដឹងថាមានអ្វីនៅក្នុងឡាំងធំៗនោះទេ។

ទីបំផុត ដាប ឈួន បានស្រែកមករកគាត់ថា ៖ "អរគុណ!" រួចចូលទៅក្នុងរថយន្តមែរសីដេស (Mercedes) របស់គាត់ ហើយបើកចេញទៅបាត់។ ក្រោយមក ទើបគាត់ឮដំណឹងថា យន្តហោះនោះជាយន្តហោះដឹកឧបករណ៍វិទ្យុទាក់ទង និងអ្នកបច្ចេកទេសជាជនជាតិវៀតណាម ២នាក់ ពីប្រទេសវៀតណាមខាងត្បូង មកដំឡើងវិទ្យុទាក់ទងឱ្យដាប ឈួន។

# ១១៧
# វៀតណាមខាងត្បូង និងសេអ៊ីអា រៀបចំផែនការ ផ្តួលរំលំសម្តេចសីហនុ តាំងពីឆ្នាំ១៩៥៦



**អនុប្រធានាធិបតីវៀតណាមខាងត្បូង ង្វៀន ង៉ុកថឺ**

ទាក់ទងរឿងវៀតណាមខាងត្បូង និងសេអ៊ីអា រៀបចំផែនការផ្តួលរំលំសម្តេចសីហនុនេះ ប្រភពព័ត៌មានបរទេសមួយ បានចុះផ្សាយថា នៅក្នុងឆ្នាំ១៩៥៦ រដ្ឋការវៀតណាមខាងត្បូង និងរាជរដ្ឋាភិបាលកម្ពុជា បានសម្រេចផ្សារទំនាក់ទំនងការទូតជាមួយគ្នាក្នុងកម្រិតឯកអគ្គរដ្ឋទូត និងឯកអគ្គរាជទូត។ ពេលនោះ ប្រធានាធិបតីង៉ូ ឌិញយៀម និងប្អូនប្រុសគាត់ង៉ូ ឌិញញូ ជាទីប្រឹក្សា បានឱ្យអនុប្រធានាធិបតីរបស់គាត់ឈ្មោះ ង្វៀង ង៉ុកថឺ ( Nguyễn Ngọc Thơ ) ជ្រើសរើសមន្ត្រីណាម្នាក់ដែលអាចបំពេញមុខងារជាឯកអគ្គរដ្ឋទូតដំបូងរបស់ខ្លួននៅប្រទេសកម្ពុជា ។

ប្រធានាធិបតីង៉ូ ឌិញយៀម បានដាក់ចេញលក្ខខណ្ឌ៣ចំណុចក្នុងការជ្រើសរើសឯកអគ្គរដ្ឋទូតនោះ គឺទី១ជាមន្ត្រីឈ្លាសវៃ ពូកែក្នុងទំនាក់ទំនង និងចេះនិយាយភាសាបារាំងបានល្អ។ ទី២ ជាមន្ត្រីដែលយល់ដឹងពីស្ថានការណ៍របស់ប្រទេសកម្ពុជា និងទី៣ ជា

## របត់នយោបាយ

មន្ត្រីដែលធ្លាប់ស្គាល់ឥស្សរជនខ្មែរច្រើន រួមទាំងធ្លាប់មានទំនាក់ទំនងល្អជាមួយនឹងជនជាតិបារាំង អាមេរិក ជាពិសេសជាអ្នកដែលមានកលល្បិចច្រើនក្នុងរឿងនយោបាយធ្វើយ៉ាងណាឱ្យកម្ពុជា ងាកមករកអង្គការសេអាតូ( SEATO )។

ចំពោះមន្ត្រីដែលមានលក្ខណៈសម្បត្តិទាំង ៣ចំណុច ខាងលើនេះ គឺកម្ររកបានណាស់ តែអនុប្រធានាធិបតី ង្វៀង ង៉ុកថឺ សម្លឹងឃើញមិត្តដ៏ជិតស្និទរបស់គាត់ម្នាក់ឈ្មោះ ង៉ូ ត្រុងហៀវ ដែលធ្លាប់បានស្គាល់គ្នាជាយូរមកហើយ។ ង៉ូ ត្រុងហៀវ មិនត្រឹមតែមានគ្រប់លក្ខណៈសម្បត្តិស្របតាមលក្ខខណ្ឌទាំង៣ចំណុចដែលប្រធានាធិបតីង៉ូ ឌិញយៀម ចង់បាននោះទេ គឺគាត់ថែមទាំងចេះនិយាយភាសារខ្មែរយ៉ាងស្ទាត់ជំនាញទៀតផង ព្រោះគាត់ធ្លាប់បានធ្វើការនៅក្នុងរតនាគាររបស់បារាំង ជាច្រើនឆ្នាំនៅក្រុងភ្នំពេញ កាលសម័យកាលអាណានិគមបារាំង ផងដែរ ។ ដូច្នេះ អនុប្រធានាធិបតី ង្វៀង ង៉ុកថឺ បានសម្រេចជ្រើសរើសយកបេក្ខភាពរបស់ ង៉ូ ត្រុងហៀវ មកឱ្យប្រធានាធិបតីង៉ូ ឌិញយៀម ពិនិត្យ និងសម្រេច។

ប្រធានាធិបតីង៉ូ ឌិញយៀម និងប្អូនប្រុសគាត់ង៉ូ ឌិញញូ ជាទីប្រឹក្សា បានហៅង៉ូ ត្រុងហៀវ មកធ្វើតេស្តសាកល្បងនៅវិមានប្រធានាធិបតី ដើម្បីចង់ដឹងសមត្ថភាព និងលក្ខណៈ សម្បត្តិទាំង៣ចំណុច ដូចអនុប្រធានាធិបតី ង្វៀង ង៉ុកថឺ រាយការណ៍នោះដែរឬទេ? ក្រោយ ពីដឹងថា ង៉ូ ត្រុងហៀវ អាចមានសមត្ថភាពបញ្ចុះបញ្ចូលអូសទាញសូកប៉ាន់ពួកមន្ត្រីខ្មែរធ្វើឱ្យមានការផ្លាស់ប្តូរនយោបាយប្រទេសកម្ពុជាបាននោះ ប្រធានាធិបតីង៉ូ ឌិនញយៀម និងប្អូន ប្រុសគាត់ សប្បាយរីករាយយ៉ាងខ្លាំង ហើយបានតែងតាំងង៉ូ ត្រុងហៀវ ឱ្យធ្វើជាឯកអគ្គរដ្ឋទូតរបស់វៀតណាមខាងត្បូង ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ព្រមទាំងណែនាំង៉ូ ត្រុងហៀវ ថា ទោះបីត្រូវចំណាយអស់លុយប៉ុន្មាន ក៏បានដែរ តែត្រូវអូសទាញបញ្ចុះបញ្ចូលទិញទឹកចិត្តមេដឹកនាំខ្មែរឱ្យបាន។

នៅពេលមកបំពេញតួនាទីជាឯកអគ្គរដ្ឋទូតរបស់វៀតណាមខាងត្បូងនៅភ្នំពេញ ង៉ូ ត្រុងហៀវ បានចំណាយលុយកាក់ ស៊ីចាយហ៊ឺហាដូចមន្ត្រីទូតរបស់ពួកលោកខាងលិចដែរ។ ជាមួយគ្នានេះ គាត់រៀបចំពិធីជប់លៀងជូនដល់បណ្តាមន្ត្រីជាន់ខ្ពស់ក្នុងរាជរដ្ឋាភិបាល

កម្ពុជា ជាញឹកញាប់ រហូតបានស្គាល់ជិតស្និទ្ធជាមួយដាប ឈួន ដែលពេលនោះជាទេសរដ្ឋមន្ត្រីទទួលបន្ទុកសន្តិសុខជាតិ និងធម្មការ។ រហូតដល់ឆ្នាំ១៩៥៨ ឯកអគ្គរដ្ឋទូតសាធារណរដ្ឋវៀតណាមខាងត្បូង ង៉ូ ត្រុងហៀវ មិនត្រឹមតែមិនអាចអូសទាញសម្តេច សីហនុ ឱ្យងាកមករកអង្គការសេអាតូ (SEATO) បាននោះទេ គឺសម្តេចសីហនុ ថែមទាំងកាន់តែមានទំនាក់ទំនងជាមួយប្រទេសចិន និងបណ្តាប្រទេសកុម្មុយនិស្តផ្សេងៗទៀតកាន់ជិតស្និទ្ធឡើងៗ។ មិនតែប៉ុណ្ណោះ ព្រះអង្គថែមទាំងបានធ្វើការវាយប្រហារទៅលើអង្គការសេអាតូ (SEATO) ជាញឹកញាប់ទៀតផង។

ប្រធានាធិបតីង៉ូ ឌិញយៀម និងប្អូនប្រុសគាត់យល់ថា នេះជាការគំរាមកំហែងមួយដ៏ធំមកលើរបបសាធារណរដ្ឋវៀតណាមខាងត្បូង ហើយគាត់បានបញ្ជាឱ្យឯកអគ្គរដ្ឋទូតង៉ូ ត្រុងហៀវ ធ្វើដំណើរមកទីក្រុងព្រៃនគរ ដើម្បីជួបពិភាក្សាគ្នា។ ង៉ូ ត្រុងហៀវ បានផ្តល់យោបល់ទៅប្រធានាធិបតីង៉ូ ឌិញយៀម ថា មានតែទាក់ទងមន្ត្រីជាន់ខ្ពស់ខ្មែរណាដែលមាន និន្នាការស្អប់ខ្ពើមលទ្ធិកុម្មុយនិស្ត ដើម្បីធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុ ឲ្យបានប៉ុណ្ណោះ។ ង៉ូ ឌិញយៀម ក៏ឯកភាពទាំងស្រុងក្នុងការរៀបចំផែនការធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុ។ ពេលវិលមកដល់កម្ពុជាវិញ ឯកអគ្គរដ្ឋទូតង៉ូ ត្រុងហៀវ ក៏បានធ្វើដំណើរទៅជួប ដាប ឈួន ជាព្រះរាជប្រតិភូទទួលបន្ទុកជាអភិបាលខេត្តសៀមរាប ។

ក្នុងឱកាសដើរបរបាញ់សត្វតែ២នាក់នៅក្នុងព្រៃជ្រៅមួយនៅខាងជើងទីរួមខេត្តសៀមរាប ង៉ូ ត្រុងហៀវ ចាប់ផ្តើមធ្វើការស្ទាបស្ទង់ទឹកចិត្តរបស់ដាប ឈួន បន្តិចម្តងៗ ពីផែនការធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុ ខណៈ ដាប ឈួន កំពុងតូចចិត្តពីរឿងសម្តេចសីហនុ ដកចេញពីតំណែងទេសរដ្ឋមន្ត្រីទទួលបន្ទុកសន្តិសុខជាតិ និងធម្មការ ឱ្យមកធ្វើជាព្រះរាជប្រតិភូទទួលបន្ទុកជាអភិបាលខេត្តសៀមរាប ដូចពីមុនវិញផងដែរ។ ជាមួយគ្នានោះ ង៉ូ ត្រុងហៀវ ក៏មានទំនាក់ទំនងគ្នាជាសម្ងាត់ជាមួយស្លាត ពៅ (ឈ្មោះ ដើម គឹម ពៅ) ត្រូវជាប្អូនរបស់ដាប ឈួន ផងដែរ។

បន្ទាប់ពីឯកអគ្គរដ្ឋទូតង៉ូ ត្រុងហៀវ និយាយបញ្ចុះបញ្ចូលអូសទាញជាច្រើនដងមក

# របត់នយោបាយ

ដាប ឈួន ក៏យល់ព្រមធ្វើជាមេដឹកនាំក្នុងផែនការធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុ នោះ ។ តែគាត់បានសំណូមពរថា គាត់ត្រូវការលុយកាក់ច្រើនដើម្បីរៀបចំកងទ័ព និងចំណាយទៅលើកិច្ចការផ្សេងៗទៀត។

ក្រោយពីបញ្ចុះបញ្ចូលអូសទាញដាប ឈួន បានហើយ ង៉ូ ត្រុងហៀវ បានធ្វើដំណើរទៅព្រៃនគរ ដើម្បីប្រាប់ប្រធានាធិបតីង៉ូ ឌិញយៀម និងប្អូនប្រុសគាត់ឱ្យបានដឹង និងប្រាប់ពីសំណូមពររបស់ដាប ឈួន ដែលថាត្រូវការលុយកាក់ច្រើនដើម្បីរៀបចំកងទ័ពនោះ។ ង៉ូ ឌិនយៀម ប្រាប់ង៉ូ ត្រុងហៀវ វិញថាៈ អស់លុយកាក់ប៉ុន្មាន ក៏គ្មានបញ្ហាអ្វីដែរ សំខាន់ឲ្យតែសម្រេចជោគជ័យ ។ មួយសប្តាហ៍ក្រោយមក ប្រធានាធិបតីង៉ូ ឌិញយៀម បានបញ្ជូនមាសចំនួន២៧០គីឡូក្រាមរៀបចំដាក់ក្នុងកេសយ៉ាងស្អាតបញ្ជូនមកដល់ទីក្រុងភ្នំពេញ ហើយង៉ូ ត្រុងហៀវ បានដឹកមាសទាំងអស់នោះតាមរថយន្តស្ថានទូតរបស់គាត់យកទៅប្រគល់ជូន ដាប ឈួន ដោយផ្ទាល់តែម្តង។

ក្នុងពេលនោះដែរ ពួកសេអ៊ីអា និងពួកចារកម្មរបស់ទីស្តីការប្រធានាធិបតីង៉ូ ឌិញយៀម បានចាត់បញ្ជូនអ្នកជំនាញខាងវិទ្យុទាក់ទងពីរនាក់ឱ្យទៅដំឡើងវិទ្យុទាក់ទងមួយគ្រឿងនៅក្នុងបរិវេណភូមិគ្រឹះរបស់ដាប ឈួន ដើម្បីឱ្យគាត់ទាក់ទងដោយផ្ទាល់ជាមួយការិយាល័យចារកម្មរបស់ទីស្តីការប្រធានាធិបតីង៉ូ ឌិញយៀម នៅក្រុងព្រៃនគរ និងជាមួយស្ថានតំណាងរបស់វៀតណាមខាងត្បូងប្រចាំនៅភ្នំពេញ។

ក្នុងជំនួបចុងក្រោយ នៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៥៩នៅខេត្តសៀមរាប ដាប ឈួន បានប្រាប់ង៉ូ ត្រុងហៀវ ថា អ្វីៗកំពុងដំណើរការបានយ៉ាងល្អប្រសើរ ហើយគាត់រង់ចាំថ្ងៃកំណត់ផ្ទុះអាវុធប៉ុណ្ណោះ។ ប្រភពព័ត៌មានមួយបានចុះផ្សាយថា ពេលនោះ ដាប ឈួន មានកម្លាំងកងទ័ព៣០០០នាក់នៅក្នុងប្រទេស និងសឺង ង៉ុកថាញ់ មានកម្លាំងកងទ័ព១២០០នាក់នៅក្នុងប្រទេសវៀតណាមខាងត្បូង និងប្រទេសថៃ ត្រៀមក្បែរព្រំដែនខ្មែរជាស្រេច។

ជាមួយគ្នានោះ ប្រធានាធិបតីង៉ូ ឌិញយៀម បានបញ្ជូនកងកម្លាំងយោធភូមិភាគទី៥ និងកម្លាំងយោធភូមិភាគទី២ នៅក្នុងប្រទេសវៀតណាមខាងត្បូង មកឱ្យត្រៀមនៅក្បែរ



ង៉ូ ត្រុងហៀវ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
(អតីតឯកអគ្គរដ្ឋទូតវៀតណាមខាងត្បូង ប្រចាំកម្ពុជា)

ព្រំដែនកម្ពុជាខាងកើត និងឦសាន ដើម្បីត្រៀមជួយអន្តរាគមន៍ក្នុងការធ្វើរដ្ឋប្រហារនោះផងដែរ។ ង៉ូ ឌិញយៀម ពិភាក្សាជាមួយព្រឹង គីមទៀង ប្រធានការិយាល័យចារកម្មរបស់គាត់អំពីបញ្ហានាំយកសឺង ង៉ុកថាញ់ មកកាន់អំណាចនៅភ្នំពេញ ផងដែរ ក្រោយរដ្ឋប្រហារទទួលបានជោគជ័យ។ ប៉ុន្តែ ផែនការសម្ងាត់នៃការធ្វើរដ្ឋប្រហារនេះត្រូវបែកធ្លាយ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៥៩ ឯកអគ្គរដ្ឋទូតរបស់បារាំង និងសហភាពសូវៀត សុំចូលគាល់សម្តេចសីហនុ នៅក្នុងព្រះបរមរាជវាំង ហើយទូលថ្វាយដល់ព្រះអង្គពីរឿងដាប ឈួន រៀបចំផែនការធ្វើរដ្ឋប្រហារទម្លាក់ព្រះអង្គចេញពីអំណាចនេះ។ ក្រោយពីផែនការធ្វើរដ្ឋប្រហារត្រូវបរាជ័យ ដាប ឈួន ត្រូវបាញ់សម្លាប់មក កងទ័ពដឹកនាំដោយលន់ នល់ ប្រមូលបានភស្តុតាងជាក់ស្តែងគឺមាសទម្ងន់២៧០គីឡូក្រាម និងអាវុធយុទ្ធភណ្ឌជាច្រើនទៀត។

បន្ទាប់មក សម្តេចសីហនុ បានអញ្ជើញបណ្តាអគ្គទូតទាំងអស់ប្រចាំនៅភ្នំពេញ ទៅទីក្រុងសៀមរាប ដើម្បីពិនិត្យមើលភស្តុតាងទាំងអស់នោះឱ្យឃើញជាក់ស្តែង។ ឯកអគ្គរដ្ឋទូតវៀតណាមខាងត្បូង ង៉ូ ត្រុងហៀវ ក៏មានវត្តមានចូលរួមការពិនិត្យនោះដែរ។

## របត់នយោបាយ

ពេលនោះ សម្តេច សីហនុ បានងាកមកសួរង៉ូ ត្រុងហៀវ ថា៖ តើឯកឧត្តមយល់យ៉ាង ណា អំពីភស្តុតាងដ៏ជាក់ស្តែងទាំងអស់នេះ? ពេលនោះ ហៀវ ខំធ្វើទឹកមុខជម្មតាដូចជាមិនដឹងរឿងអ្វី រួចឆ្លើយថា៖ សម្តេច! ខ្ញុំមកទីនេះ គឺដើម្បីស្តាប់នូវការពន្យល់របស់ព្រះអង្គតែប៉ុណ្ណោះ គឺគ្មានមតិអ្វីដើម្បីឆ្លើយបកស្រាយនោះទេ។

សម្តេចសីហនុ បញ្ជាក់ថា មាស២៧០គីឡូក្រាម មានទាំងត្រារបស់រតនាគារវៀតណាមខាងត្បូងច្បាស់ក្រឡែតវិទ្យុទាក់ទង និងភ្នាក់ងារវិទ្យុទាក់ទងទាំងពីរនាក់មានលិខិតឆ្លងដែនវៀតណាមខាងត្បូងទៀតផង ជាភស្តុងតាងគ្រប់គ្រាន់បញ្ជាក់ថា នរណាជាមេខ្លោងនៃផែនការធ្វើរដ្ឋប្រហារនេះ?។

សម្តេចសីហនុ បានសំណូមពរឱ្យរដ្ឋាភិបាលង៉ូ ឌិញយៀម កោះហៅឯកអគ្គរដ្ឋទូតង៉ូត្រុងហៀវ ឱ្យវិលត្រលប់ទៅប្រទេសវៀតណាមខាងត្បូង វិញជាបន្ទាន់។ ប្រធានាធិបតីង៉ូឌិញយៀមក៏យល់ព្រមដកតំណែងឯកអគ្គរដ្ឋទូតវៀតណាមខាងត្បូងប្រចាំព្រះរាជាណាចក្រកម្ពុជា ពីង៉ូ ត្រុងហៀវ ដែរ។

ក្រោយពីវិលត្រឡប់ទៅប្រទេសវៀតណាមខាងត្បូង វិញ ង៉ូ ត្រុងហៀវ ត្រូវបានប្រធានាធិបតីង៉ូ ឌិញយៀម តែងតាំងជារដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

# ១១៨
# សម សារី មិនព្រមស្ដាប់តាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃថៃ



**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រ៉ះផាត ចារុសៈធៀន**

នៅពេលលន់ នល់ ដឹកនាំកម្លាំងចុះទៅបង្ក្រាបដាប ឈួន នោះ ឡឹក សំអឿន បានទទួលសារទូរលេខពីសឹង ង៉ុកថាញ់ ឱ្យចាត់កម្លាំងមួយចំនួនទៅទទួលដាប ឈួន នៅអន្លង់វែង។ ប៉ុន្តែប៉ុន្មានថ្ងៃក្រោយមក ស្រាប់តែឮវិទ្យុភ្នំពេញប្រកាសព័ត៌មានថា ដាប ឈួន ត្រូវកម្លាំងទាហានដឹកនាំដោយលន់ នល់ បានបាញ់សម្លាប់នៅភូមិស្រែណូយ ស្រុកវ៉ារិន ហើយ។

ក្រោយព្រឹត្តិការណ៍បាញ់សម្លាប់ដាប ឈួន បានមួយសប្ដាហ៍ មន្ត្រីជាន់ខ្ពស់ថៃដែលជាអ្នកទទួលខុសត្រូវលើចលនាខ្មែរ បានអញ្ជើញសម សារី និងឡឹក សំអឿន ហៅផ្កាយព្រឹក ទៅជួបរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រ៉ះផាត ចារុសៈធៀន នៅទីស្ដីការក្រសួង។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃថៃ រូបនេះ បានលើកឡើងថា ផែនការធ្វើរដ្ឋប្រហារផ្ដួលរំលំសម្ដេចសីហនុ ត្រូវបរាជ័យហើយ ដូច្នេះគេស្នើសុំឱ្យពួកគាត់ទាំងពីរនាក់បញ្ឈប់សកម្មភាពរបស់ចលនាតស៊ូខ្មែរសេរី

មួយរយៈសិន ដើម្បីកុំឱ្យមានការប៉ះពាល់ដល់ទំនាក់ទំនងការទូត រវាងប្រទេសថៃ និងកម្ពុជា។

ក្រោយពេលចេញពីក្រសួងមហាផ្ទៃថៃ មកវិញ សម សារី និងឡឹក សំអឿន បានបើកសម័យប្រជុំមួយនៅទីស្នាក់ការខ្មែរសេរី នៅក្នុងទីក្រុងបាងកក ដើម្បីពិភាក្សាគ្នារឿងបញ្ឈប់សកម្មភាពរបស់ចលនាតស៊ូខ្មែរសេរីនេះ។ នៅក្នុងអង្គប្រជុំ ឡឹក សំអឿន បានផ្តល់យោបល់ជូនអង្គប្រជុំថា យើងត្រូវតែផ្អាកសកម្មភាពទាំងអស់ តាមការស្នើសុំរបស់រាជរដ្ឋាភិបាលថៃ ហើយនៅស្ងៀមមួយរយៈសិន។



**នាយករដ្ឋមន្ត្រីថៃ សារិត ថាណារ៉ាត**

ដោយដឹងថា សម សារី នៅតែចចេសរឹងរូស មិនព្រមបញ្ឈប់សកម្មភាពរបស់ចលនាតស៊ូខ្មែរសេរី តាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃថៃនោះ ឡឹក សំអឿន បានសំណូមពរឱ្យអង្គប្រជុំធ្វើការពិចារណាឲ្យបានល្អិតល្អន់ និងថ្លឹងថ្លែងពីលទ្ធផលល្អ និងអាក្រក់ កុំចេះតែសម្រេចចិត្តទៅតាមចំណង់ដែលពោរពេញទៅដោយកំហឹងរបស់ខ្លួន ហើយក៏មិនត្រូវគិតយកប្រយោជន៍ខាងយើងតែឯងប៉ុណ្ណោះទេ គឺគួរតែគិតប្រយោជន៍ថៃ ជាម្ចាស់ផ្ទះ និងប្រយោជន៍ រួមផងដែរ។

ឡឹក សំអឿន បានរម្លឹកថា បន្ទាប់ពីបានស្តាប់យោបល់គាត់រួចមក សម សារី កាន់តែក្តៅក្រហាយខ្លាំងឡើងថែមទៀត ពីព្រោះយោបល់គាត់ផ្ទុយនឹងគំនិតរបស់សម សារី ជាមនុស្សអាត្មានិយម ដូចសម្តេចសីហនុ បេះបិទ។ សម សារី បានពោលទាំងអំណួតអួតអាង

ថា គេនឹងមិនធ្វើតាមសំណូមពររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃថៃនោះទេ គេនឹងរកច្រកចេញផ្សេងទៀត គឺត្រូវតែចាកចេញពីប្រទេសថៃ ទៅប្រទេសឡាវ ដើម្បីធ្វើសកម្មភាពតស៊ូបន្តទៀត ហើយសុំឲ្យគាត់ (ឡឹក សំអឿន) ជួយសម្រួលរឿងនេះឱ្យផង។

ដោយដឹងច្បាស់ថា សម សារី មិនព្រមស្តាប់តាមការស្នើសុំរបស់ ប្រ៉ះផាត ចារុសៈ-ធៀន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃថៃ គាត់ក៏បណ្តោយឱ្យសម សារី ធ្វើតាមទំនើងចិត្តគេទៅចុះ។

ពេលនោះ គាត់បានចាត់សហការីរបស់គាត់៤នាក់ ក្នុងចំណោមសហការីគាត់ចំនួន៩នាក់ ដែលគាត់នាំមកពីទីក្រុងវៀងចន្ទ កាលពីប៉ុន្មានឆ្នាំមុន ឱ្យជូនដំណើរសម សារី ទៅទៅទីប្រជុំជនប៉ាកសេ ខេត្តចំប៉ាសាក់ ប្រទេសឡាវ។ ឡឹក សំអឿន បានផ្តាំផ្ញើសហការីជាអ្នកស្ម័គ្រចិត្តជូនសម សារី ទៅប្រទេសឡាវ នោះថា ពេលទៅដល់ខេត្តចំប៉ាសាក់ បើឃើញថាមិនបានការអ្វីទេ ត្រូវត្រលប់ទៅរស់នៅឯក្រុងវៀងចន្ទ វិញ ព្រោះយើងត្រូវបំបែកគ្នាមួយរយៈសិន។

មុននឹងចាកចេញពីប្រទេសថៃ សម សារី ក៏បានសុំយោបល់ពីមន្ត្រីថៃ ដែរ ហើយគេក៏យល់ព្រមតាមសំណើរបស់សម សារី ដែរ។ ពេលនោះ គាត់បានប្រាប់សម សារី ថា បើលោកអញ្ជើញចេញពីស្រុកគេហើយ សូមកុំត្រលប់មកវិញ នាំឲ្យបាក់មុខខូចកិត្តិយស ហើយអាចនឹងមានបញ្ហាដល់អាយុជីវិតទៀតផង។

ក្រោយពី សម សារី ចេញដំណើរពីក្រុងបាងកក ទៅក្រុងប៉ាកសេ ប្រទេសឡាវ ឡឹក សំអឿន បានធ្វើរបាយការណ៍មួយផ្ញើទៅជូនសឺង ង៉ុកថាញ់ នៅឯប្រទេសវៀតណាមខាងត្បូង ដើម្បីឲ្យបានជ្រាបពីបញ្ហានេះដែរ។ ពេលនោះ សឺង ង៉ុកថាញ់ បានបញ្ជាមកគាត់វិញថា ឈប់ទាក់ទងជាមួយសម សារី ទៀត ហើយបើខាងថៃ ធ្វើយ៉ាងណាក៏ស្រេចតែគេទៅចុះ។

ពេលទៅដល់ខេត្តចំប៉ាសាក់ សម សារី បានបញ្ជូនសហការីស្ម័គ្រចិត្តរបស់គាត់៥នាក់ពីក្រុងប៉ាកសេ ឲ្យចូលទៅទីក្រុងភ្នំពេញ ទាក់ទងជាមួយកម្លាំងបង្កប់របស់គាត់នៅទីនោះ ដើម្បីធ្វើសកម្មភាពភេរវកម្ម។ ប៉ុន្តែត្រូវក្រុមប៉ូលិសសម្ងាត់(គិញ) របស់សម្តេចសីហនុ ចាប់យកទៅប្រហារជីវិតអស់៤នាក់ នៅសល់ម្នាក់ ក៏គៀសខ្លួនទៅរស់នៅឯកម្ពុជាក្រោមវិញ។



**ទីក្រុងវៀងចន្ទ កាលទសវត្សរ៍ឆ្នាំ១៩៥០**

ឯសហការីរបស់ឡឹក សំអឿន ៤នាក់ ជាអ្នកស្ម័គ្រចិត្តជូនដំណើរសម សារី ទៅខេត្តចំប៉ាសាក់ នោះ ក៏បានទៅរស់នៅឯក្រុងវៀងចន្ទ វិញ តាមបណ្តាំរបស់ឡឹក សំអឿន ។

ចំណែក សម សារី ត្រូវពួកមន្ត្រីថៃ ទៅទទួលយកពីក្រុងប៉ាកសេ ខេត្តចំប៉ាសាក់ មកកាន់ប្រទេសថៃវិញ ហើយពួកគេណែនាំសម សារី ថា ត្រូវនៅស្ងៀម កុំទាក់ទងអ្វីជាមួយនរណាឱ្យសោះ សូម្បីក្រុមឡឹក សំអឿន ក៏មិនត្រូវទាក់ទងដែរ។ តែសម សារី នៅតែចេះរឹងរូសមិនស្តាប់តាមការណែនាំរបស់ពួកមន្ត្រីថៃ ដោយគាត់ចេះតែសរសេរសំបុត្រសម្ងាត់លួចផ្ញើទៅទាក់ទងមិត្តភក្តិគាត់ផ្សេងៗទៀត នៅក្រៅប្រទេស ជាបន្តបន្ទាប់។ ប៉ុន្តែសំបុត្រទាំងអស់នោះត្រូវសមត្ថកិច្ចថៃ ចាប់បានទាំងអស់ ហើយបើទោះបីពួកមន្ត្រីថៃ ព្រមានមួយលើកជាពីរលើក ឱ្យឈប់សរសេរសំបុត្រសម្ងាត់លួចផ្ញើទៅក្រៅប្រទេសថៃទៀត ក៏សម សារី នៅតែមិនព្រម ហើយគាត់ទទូចសុំចេញទៅពីប្រទេសថៃ ទៅនៅក្រុងវៀងចន្ទ ប្រទេសឡាវ វិញ។

ដោយសម សារី ចេះតែទទូចសុំខ្លាំងពេក ពួកមន្ត្រីថៃ ក៏យល់ព្រមជូនដំណើរគាត់ចាកចេញពីក្រុងបាងកក ទៅក្រុងវៀងចន្ទ តាមបំណងរបស់គាត់។ ដោយដឹងថា ឡឹក សំអឿន ធ្លាប់រស់នៅក្រុងវៀងចន្ទ ព្រមទាំងមានមិត្តភក្តិទាំងខ្មែរទាំងឡាវច្រើននៅទីនោះ ពួកមន្ត្រីថៃ ក៏បានពឹងពាក់ឡឹក សំអឿន ឱ្យជួយជូនដំណើរសម សារី ទៅក្រុងវៀងចន្ទ និង

ជួយសម្រួលដល់កិច្ចការមួយចំនួនទៀត។ ពេលទៅដល់ទីប្រជុំជនណងខាយ ជាប់ព្រំដែនឡាវ ឡឹក សំអឿន និងសម សារី បានសម្រាកនៅទីនោះមួយយប់។ ព្រឹកឡើង ឡឹក សំអឿន បានឆ្លងព្រំដែនធ្វើដំណើរទៅក្រុងវៀងចន្ទ តែម្នាក់ឯង ដើម្បីរកមិត្តភក្តិគាត់ម្នាក់ឈ្មោះអ៊ុក ម៉ុល ឲ្យមកទទួលសម សារី ទៅក្រុងវៀងចន្ទ នៅល្ងាចថ្ងៃដដែលនោះ។

អ៊ុក ម៉ុល និងឡឹកសំអឿន បានយករថយន្តតូចមួយគ្រឿង មកទទួលសម សារី នៅត្រង់ភូមិមួយជាប់មាត់ទន្លេមេគង្គ នៅខាងប្រទេសឡាវ ស្ថិតនៅចំពីមុខទីប្រជុំជនណងខាយ របស់ថៃ ដើម្បីដឹកសម សារី ទៅក្រុងវៀងចន្ទ។ ពេលទៅដល់ក្រុងវៀងចន្ទ ដើម្បីកុំឲ្យគេដឹងថា សម សារី កំពុងស្ថិតនៅទីក្រុងនេះ ឡឹក សំអឿន ក៏បានរៀបចំឲ្យសម សារី ស្នាក់នៅផ្ទះរបស់អ៊ុក ម៉ុល ។ តែសម សារី មិនព្រមសម្រាកនៅផ្ទះរបស់អ៊ុក ម៉ុល ទេ គាត់ឱ្យឡឹក សំអឿន ជូនគាត់បានទៅសម្រាកនៅសណ្ឋាគារវិញ។

ឡឹក សំអឿន បានរម្លឹកថា នៅក្រុងវៀងចន្ទ មានសណ្ឋាគារធំតែមួយគត់ គឺសណ្ឋាគារសមប៊ូន ឥន្ទវង្ស ដែលជាកម្មសិទ្ធិរបស់ថៅកែក្រុមហ៊ុនឈើធំជាងគេនៅក្រុងវៀងចន្ទ ដែលគាត់ធ្លាប់ធ្វើការពីមុននោះ ហើយនៅក្នុងសណ្ឋាគារនោះ ប្រាកដជាមានអ្នកស្គាល់គាត់ច្បាស់ជាមិនខាន ដូច្នេះ គាត់មិនហ៊ានជូនសម សារី ទៅសណ្ឋាគារសមប៊ូន ឥន្ទវង្ស នោះទេ តែគាត់សុំឱ្យម្ចាស់ផ្ទះឈ្មោះអ៊ុក ម៉ុល ជាអ្នកចាត់ចែងក្នុងរឿងនេះ។

ល្ងាចថ្ងៃដដែលនោះ ឡឹក សំអឿន បានទៅជួបមិត្តភក្តិគាត់ម្នាក់ធ្វើការនៅក្រសួងការបរទេសឡាវ នៅផ្ទះរបស់គេផ្ទាល់ ដើម្បីឱ្យជួយនាំពាក្យទៅជម្រាបរដ្ឋមន្ត្រីក្រសួងការបរទេសឡាវ ឈ្មោះខាំ ប៉ាន់បញ្ញា ដែលសម សារី ប្រាប់ថា ធ្លាប់ស្គាល់រាប់អានគ្នាកាលនៅរៀនប្រទេសបារាំង។ ស្អែកឡើង ម៉ោង១១ មិត្តភក្តិធ្វើការនៅក្រសួងការបរទេសឡាវ នោះ ក៏បានមកជួបឡឹក សំអឿន ប្រាប់ថា រដ្ឋមន្ត្រីក្រសួងការបរទេសឡាវ នោះ យល់ព្រមឲ្យសម សារី ទៅជួបនៅគេហដ្ឋានរបស់គាត់ នៅវេលាម៉ោង៦ល្ងាច។

ពេលទៅដល់ផ្ទះរដ្ឋមន្ត្រីក្រសួងការបរទេសឡាវ នោះ បន្ទាប់ពីសួរសុខទុក្ខគ្នាប្រកបដោយភាតរភាពមក សម សារីក៏បានស្នើទៅរដ្ឋមន្ត្រីរូបនោះ ឲ្យជួយទាក់ទងជាមួយរាជរដ្ឋា

ភិបាលឡាវ សុំឱ្យគាត់មានសិទ្ធិរស់នៅក្នុងប្រទេសឡាវ ក្នុងឋានៈជាជនភៀសខ្លួនខាងនយោបាយផង ហើយរដ្ឋមន្ត្រីខាំ ប៉ាន់បញ្ញា បានសន្យាជាមួយសម សារី ថានឹងយករឿងនេះទៅដាក់ជូនគណៈរដ្ឋមន្ត្រីឡាវ ដើម្បីធ្វើការសម្រេច។ លុះស្អែកឡើង មិនទាន់ទាំងបានទទួលសេចក្តីសម្រេចពីគណៈរដ្ឋមន្ត្រីឡាវ នៅឡើយផង ស្រាប់តែពួកទាហានឡាវ បានយករថយន្តមកដឹកសម សារី និងឡឹក សំអឿន ឱ្យទៅស្នាក់នៅក្នុងបន្ទាយមួយនៅតំបន់ថាតហ្លួង ជាយក្រុងវៀងចន្ទ ដើម្បីការពារសន្តិសុខ។

មួយថ្ងៃក្រោយមក ស្រាប់តែនៅក្នុងសារព័ត៌មានខ្មែរផ្សាយជាភាសាបារាំង នៅទីក្រុងភ្នំពេញ ឈ្មោះរេអាលីតេ កាំបូហ្សែន (réalité cambodgienne) បានចុះអត្ថបទត្រង់ទំព័រមុខពីវត្តមានរបស់សម សារី នៅទីក្រុងវៀងចន្ទ ហើយសរសេរថា មានមេចោរដែលអ្នកផងបានស្គាល់ច្បាស់ គឺឈ្មោះឡឹក សំអឿន ហៅផ្កាយព្រឹក ជាអ្នកជូនដំណើរទៀតផង។ នៅល្ងាចថ្ងៃដដែលនោះ ឡឹក សំអឿន បានលាសម សារី ត្រលប់ទៅទីក្រុងបាងកកវិញ និងបានប្រកាសរំសាយគ្នា បិទទ្វារទីស្នាក់ការចលនាខ្មែរសេរី ហើយនាំគ្នាទៅរកការងារធ្វើរៀងៗខ្លួន។ តែខាងថៃ នៅតែជួយផ្តល់ជំនួយដល់ពួកគាត់ចំនួន៦នាក់ ដោយគេបានជួលផ្ទះមួយឱ្យពួកគាត់ស្នាក់នៅ ព្រមទាំងផ្តល់ថវិកាខ្លះសម្រាប់ផ្គត់ផ្គង់ម្ហូបអាហារប្រចាំថ្ងៃ ព្រមទាំងមានវរសេនីយ៍ឯកឆណះ សមុទ្ទផាណិជ ជាអ្នកទទួលខុសត្រូវក្នុងការការពារសន្តិសុខគ្រប់យ៉ាងដល់ពួកគាត់ទៀតផង។

ប៉ុន្មានថ្ងៃក្រោយមក ឡឹក សំអឿនក៏បានទទួលដំណឹងថា ពួកមន្ត្រីថៃ បានទៅទទួលយកសម សារី មកប្រទេសថៃវិញ ពីព្រោះគណៈរដ្ឋមន្ត្រីឡាវ មិនយល់ព្រមឲ្យសម សារី រស់នៅក្នុងប្រទេសគេក្នុងឋានៈជាជនភៀសខ្លួនឡើយ។ នៅទីក្រុងបាងកក វរសេនីយ៍ឯកឆណះ សមុទ្ទផាណិជ បានជួយឡឹក សំអឿន ឱ្យបានធ្វើជាគ្រូបង្រៀនភាសាបារាំង ដល់សិស្សថៃ ដែលរៀនថ្នាក់ត្រៀមនៅមហាវិទ្យាល័យជុឡា ឡុងកន គ្រាន់បានប្រាក់ខែដោះស្រាយជីវភាពផងដែរ។

ឡឹក សំអឿន ហៅផ្កាយព្រឹក បានរម្លឹកថា ល្ងាចមួយ វរសេនីយ៍ឯកឆណះ សមុទ្ទ-



**មហាវិទ្យាល័យជុំឡា ឡុងគន កសាងឡើងនៅឆ្នាំ១៩១៧**

ផាណិជ បានមកទទួលគាត់យកទៅឲ្យជួបពិភាក្សាគ្នាពីបញ្ហាសម សារី ជាមួយវរសេនីយ៍ឯកវៀតណាមខាងត្បូងម្នាក់ ជាអ្នកទទួលខុសត្រូវលើចលនាខ្មែរសេរីដែរនោះ នៅផ្ទះឯកអគ្គរដ្ឋទូតវៀតណាមខាងត្បូង ប្រចាំប្រទេសថៃ។ វរសេនីយ៍ឯកឆណៈ សមុទ្ទផាណិជ បានលើកឡើងថា គេគ្មានមធ្យោបាយអ្វីហាមឃាត់សម សារី ឱ្យឈប់ធ្វើការទាក់ទងជាមួយអ្នកផ្សេងៗ ទៀតទេ។ គេបន្តថា វៀតណាមខាងត្បូងជាអ្នកទទួលខុសត្រូវក្នុងរឿងនេះ ព្រោះជាអ្នកនាំយកសម សារី ចេញពីក្រុងភ្នំពេញ រួចបញ្ជូនមកប្រទេសថៃ។

វរសេនីយ៍ឯកវៀតណាមខាងត្បូង តបវិញថា សម សារី ជាសមាជិកចលនាខ្មែរសេរីគឺសឺង ង៉ុកថាញ់ ជាអ្នកស្នើឲ្យវៀតណាម បញ្ជូនគាត់មកប្រទេសថៃ ដើម្បីបម្រើចលនាខ្មែរសេរី នៅរណសិរ្សយោជាភ្នំដងរែក។ ពេលនោះ ឡឺក សំអឿន បានលើកហេតុផលថា សម សារី ជាសមាជិកចលនាខ្មែរសេរីពិតមែន ប៉ុន្តែរដ្ឋាភិបាលរបស់លោកទាំងពីរជាអ្នកជ្រើសរើសឱ្យមកធ្វើសហប្រតិបត្តិការក្នុងផែនការសម្ងាត់ ដើម្បីផ្តួលរំលំសម្តេចសីហនុ ហើយផែនការសម្ងាត់នេះ ចលនាខ្មែរសេរីមិនបានដឹងឮ ឬចូលរួមពីដើមទីមកនោះទេ។ លុះផែនការផ្តួលរំលំសម្តេចសីហនុ មិនបានសម្រេច រហូតបែកការណ៍ ទើបរដ្ឋាភិបាលរបស់លោកទាំងពីរ

## របត់នយោបាយ

ទាក់ទងជាមួយប្រមុខចលនាខ្មែរសេរី សឺង ង៉ុកថាញ់ ឲ្យទទួលយកសម សារី ជាសមាជិកចលនាខ្មែរសេរី។

ឡឹក សំអឿន បានបន្តថា បញ្ហាដែលរដ្ឋាភិបាលថៃ សុំឱ្យសម សារី បញ្ឈប់សកម្មភាពរបស់ខ្លួន តែសម សារី នៅតែចចេសសុំទៅរាជរដ្ឋាភិបាលថៃ មួយលើកជាពីរលើក ដើម្បីឱ្យគាត់បានទៅនៅប្រទេសឡាវនោះ គឺគាត់មិនបានឲ្យដំណឹង ឬពិគ្រោះយោបល់ជាមួយសឺង ង៉ុកថាញ់ ប្រមុខចលនាខ្មែរសេរីបន្តិចសោះឡើយ។  នេះសបញ្ជាក់ឱ្យឃើញថា សម សារី បានប្រព្រឹត្តរំលោភវិន័យ ហើយបានបាត់បង់សមាជិកភាពនៃចលនាខ្មែរសេរី រួចទៅហើយ។ ម៉្យាងទៀត រឿងនេះ ខ្ញុំបានរាយការណ៍ទៅជូនលោកប្រមុខសឺង ង៉ុកថាញ់ រួចហើយដែរ ហើយលោកប្រមុខបានប្រាប់ឲ្យខ្ញុំឈប់ទាក់ទង ឬដឹងឮពីរឿងសម សារី នេះទៀត គាត់ចង់ធ្វើអ្វី ក៏ស្រេចតែខ្លួនគាត់ និងរាជរដ្ឋាភិបាលថៃ ទៅចុះ។ ដូច្នេះតាមយោបល់ខ្ញុំ បញ្ហានេះស្រេចតែថៃ និងវៀតណាមខាងត្បូង ជាអ្នកដោះស្រាយចុះ។ នៅទីបំផុត តំណាងថៃ និងវៀតណាមខាងត្បូង ទាំង២នាក់ ក៏យល់ព្រមទទួលខុសត្រូវរឿងសម សារី នេះ ហើយចាប់ពីពេលនោះមក ជោគវាសនាអនាគតរបស់សម សារី ទៅជាយ៉ាងណា មេដឹកនាំចលនាខ្មែរសេរីពុំដឹងឮទៀតទេ។

# ១១៩
# នរណាផ្ញើគ្រាប់បែក មកថ្វាយសម្តេចសីហនុ និងព្រះមាតាបិតា ?



**សម្តេចសីហនុ និងព្រះមាតាបិតា**

នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៥៩ មានហេតុការណ៍ប៉ុនប៉ងធ្វើគត ទៅលើសម្តេចសីហនុ និងព្រះបិតា ព្រះមាតារបស់ព្រះអង្គ ដោយដាក់គ្រាប់បែកបង្កប់នៅក្នុងវ៉ាលិសមួយ។

នៅថ្ងៃកើតហេតុនោះ សឺន សាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស បានដឹកនាំគណៈប្រតិភូមួយក្រុមចូលក្រាបបង្គំគាល់ព្រះមហាក្សត្រនរោត្តម សុរាម្រិត និងព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ ដើម្បីសុំព្រះរាជឱវាទ មុនពេលចេញដំណើរទៅចូល

រួមមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី០២ ខែកញ្ញា។

ការចូលបង្គំគាល់នោះ ត្រូវកំណត់ធ្វើឡើង នៅម៉ោង១៥ រសៀល ប៉ុន្តែ ពេលនោះ ព្រះមហាក្សត្រិយានី កំពុងគង់ នៅឯអាកាសយានដ្ឋានពោធិ៍ចិនតុង នៅឡើយ។

រហូតដល់ម៉ោង១៨ព្រលប់ ទើបព្រះមហាក្សត្រិយានី យាងមកដល់ព្រះបរមរាជវាំង ដោយមានព្រះអង្គម្ចាស់វ៉ាគ្រី វណ្ណ ជានាយកពិធីការព្រះបរមរាជវាំង ជាអ្នកយួរវ៉ាលិសដាក់គ្រឿងតង្វាយ អមព្រះរាជដំណើរតាមពីក្រោយផង។

ពេលព្រះមហាក្សត្រិយានីកុសុមៈ យាងមកដល់ភ្លាម ក៏ប្រញាប់ប្រញាល់ចូលទៅយាងព្រះមហាក្សត្រសុរាម្រិត ចេញពីបន្ទប់ព្រះក្រឡាបន្ទំ មកជួបគណៈប្រតិភូរបស់សឺន សាន ភ្លាមៗដែរ ព្រោះគណៈប្រតិភូនេះ រង់ចាំយូរហើយ។

ឯព្រះអង្គម្ចាស់ វ៉ាគ្រីវណ្ណ ឆ្លៀតឱកាសរង់ចាំព្រះមហាក្សត្រ និងព្រះមហាក្សត្រិយានី យាងចេញទៅជួបគណៈប្រតិភូនៅមុខព្រះរាជបល្ល័ង្កនោះ ទ្រង់ក៏ចាប់ផ្ដើមបើកមើលវ៉ាលិសដាក់គ្រឿងតង្វាយនោះ។ នៅពេលព្រះមហាក្សត្រ និងព្រះមហាក្សត្រិយានី យាងផុតពីមាត់ទ្វារបន្ទប់ក្រឡាព្រះបន្ទំ ស្ថិតនៅខាងក្រោយព្រះរាជបល្ល័ង្កនោះ ស្រាប់តែស្នូរគ្រាប់បែកផ្ទុះឡើងលាន់កក្រើកប្រាសាទទេវាវិនិច្ឆ័យ បណ្ដាលឱ្យព្រះអង្គម្ចាស់វ៉ាគ្រី វណ្ណ នាយកពិធីការព្រះបរមរាជវាំង ត្រូវបាត់បង់ជីវិតភ្លាមៗ។ តែព្រះមហាក្សត្រ និងព្រះមហាក្សត្រិយានី ព្រមទាំងគណៈប្រតិភូរបស់សឺន សាន មិនបានរងរបួសអ្វីទេ គឺគ្រាន់តែមានការស្លុតរន្ធត់ប៉ុណ្ណោះ។

សឺន សាន, សារិន ឆាក និងសមាជិកគណៈប្រតិភូទាំងអស់ ក៏នាំគ្នាអមព្រះរាជដំណើររបស់ព្រះមហាក្សត្រសុរាម្រិត និងព្រះមហាក្សត្រិយានី ចេញពីប្រាសាទទេវាវិនិច្ឆ័យ ឱ្យទៅគង់នៅប្រាសាទខេមរិន្ទ វិញ។ ព្រះអង្គម្ចាស់វ៉ាគ្រី វណ្ណ មានមហេសី ព្រះនាមនរោត្តម ថាវេត នរលក្ខណ៍ ជាប្អូនជីដូនមួយរបស់សម្ដេចសីហនុ (ព្រះមាតា និងព្រះមាតាជាបងប្អូនបង្កើតនឹងគ្នា)ហើយទ្រង់ ក៏ជាមិត្តជិតស្និទ្ធជាមួយសម្ដេចសីហនុ ផងដែរ។ កាលនៅជាកំលោះ អ្នកអង្គម្ចាស់វ៉ាគ្រីវណ្ណ ខិលខូចពីរឿងស្រីញីខ្លាំងណាស់ ហើយទ្រង់បានពឹងពាក់ព្រះមហាក្សត្រសីហនុ ឱ្យជួយចែចូវបញ្ចុះបញ្ចូលម្ចាស់ក្សត្រីនរោត្តម ថាវេត នរលក្ខណ៍ និងមាតាព្រះនាង



**ព្រះបរមរាជវាំង ទសវត្សរ៍ឆ្នាំ១៩៥០**

ដើម្បីសុំរៀបអាពាហ៍ពិពាហ៍ ជាមួយ។

ក្រោយពីព្រះអង្គជួយបញ្ចុះបញ្ចូលលួងលោមមក ម្ចាស់ក្សត្រីនរលក្ខណ៍ និងមាតាព្រះនាង ក៏យល់ព្រម។ ប៉ុន្តែក្រោយពីរៀបអាពាហ៍ពិពាហ៍រួចមក ទ្រង់នៅតែខិលខូចពីរឿងស្រីញី ដដែល។ ដោយមិនអាចស៊ូទ្រាំនឹងការខូចខិលពីរឿងស្រីនេះបាន ម្ចាស់ក្សត្រីនរលក្ខណ៍ ក៏បានលែងលះគ្នាជាមួយអ្នកអង្គម្ចាស់រ៉ាគ្រីវណ្ណ នោះទៅ។ បន្ទាប់មក ម្ចាស់ក្សត្រីនរលក្ខណ៍




ម្ចាស់ក្សត្រីនរលក្ខណ៍

ក៏បានរៀបអភិសេកជាមួយព្រះមហាក្សត្រសីហនុ នៅក្នុងឆ្នាំ១៩៥៥ ដោយព្រះអង្គចាត់ទុកថា ព្រះនាងជាមហេសីផ្លូវការទី១ និងអ្នកម្នាង ម៉ូនិក ជាមហេសីផ្លូវការទី២។ សេចក្ដីស្នេហារបស់ព្រះអង្គចំពោះម្ចាស់ក្សត្រី នរលក្ខណ៍ និងអ្នកម្នាង ម៉ូនិក មានទំហំធំធេងណាស់។ ប៉ុន្តែ ម្ចាស់ក្សត្រី នរលក្ខណ៍ ជាមួយព្រះអង្គ មិនមានបុត្រម្នាក់ឡើយ។

នៅក្នុងឆ្នាំ១៩៥៦ ដោយសារជាមិត្តជិតស្និទ្ធផង សម្ដេចសីហនុ បានតែងតាំងព្រះអង្គ ម្ចាស់រ៉ាគ្រីវណ្ណ ជានាយកពិធីការប្រចាំព្រះបរមរាជវាំង។ ជាញឹកញាប់ ពេលព្រះអង្គយាងចេញទៅបំពេញព្រះរាជទស្សនកិច្ច នៅប្រទេសបារាំង និងប្រទេសផ្សេងៗទៀត ទ្រង់រ៉ាគ្រីវណ្ណ តែងតែដង្ហែព្រះរាជដំណើររបស់ព្រះអង្គ ជាប់ជានិច្ច។

ប៉ុន្តែមានមជ្ឈដ្ឋានមួយចំនួននិយាយបំផ្លើសថា ទ្រង់រ៉ាគ្រីវណ្ណ បានលក់ម្ចាស់ក្សត្រីនរលក្ខណ៍ មហេសីរបស់ទ្រង់ ឱ្យទៅសម្ដេចសីហនុ ដើម្បីជាថ្នូរនឹងលុយកាក់ និងការប្រគល់តំណែងជានាយកពិធីការព្រះបរមរាជវាំង នោះទៅវិញ។

ពាក់ព័ន្ធពីបញ្ហាចោទប្រកាន់នេះ សម្ដេចសីហនុ បានធ្វើការបកស្រាយថា ទ្រង់រ៉ាគ្រីវណ្ណ មិនត្រឹមតែជារាជវង្សមួយអង្គ ប្រកបដោយកិត្តិយសខ្ពង់ខ្ពស់ប៉ុណ្ណោះទេ គឺថែមទាំងជាអ្នកមានទ្រព្យសម្បត្តិសម្បូរហូរហៀរទៀតផង។ ដូច្នេះទ្រង់មិនចាំបាច់លក់មហេសី ដើម្បីលុយកាក់ និងចង់បានតំណែងត្រឹមនាយកពិធីការព្រះបរមរាជវាំងនោះទេ។ តាំងពីឆ្នាំ១៩៥៥

សម្តេចនរោត្តម សីហនុ និងម្ចាស់ក្សត្រីនរលក្ខណ៍ បានរួមរស់ជាមួយគ្នាយ៉ាងសុខសាន្ត រហូតដល់ឆ្នាំ១៩៦០ ក៏មានបញ្ហាថ្នាំងថ្នាក់នឹងគ្នា ដោយសារតែមានការប្រចណ្ឌច្រណែននឹងព្រះអង្គ ដែលស្រលាញ់អ្នកម្នាង ម៉ូនិក ច្រើនជាង ព្រះនាងក៏សម្រេចព្រះទ័យគង់នៅតែអង្គឯង ដោយមិនបានរករឿង បង្កឱ្យមានជម្លោះអ្វីឡើយ។

ក្រោយពីមានហេតុការណ៍ផ្ទុះគ្រាប់បែក នៅក្នុងប្រាសាទទេវាវិនិច្ឆ័យ នាព្រលប់ថ្ងៃទី៣១ ខែសីហា នោះមក សម្តេចសីហនុ បានបញ្ជាក់ថា នៅថ្ងៃកើតហេតុ វេលាម៉ោង១៨ព្រលប់នោះដែរ ព្រះអង្គ និងអ្នកម្នាងម៉ូនិក ជាមហេសី ក៏មានគម្រោងចូលបង្គំគាល់ព្រះមហាក្សត្រ និងព្រះមហាក្សត្រិយានី ជាព្រះបិតា និងព្រះមាតាដែរ ប៉ុន្តែដោយសារព្រះអង្គដឹងថា ព្រះបិតា និងព្រះមាតា ត្រូវជួបជាមួយគណៈប្រតិភូ ត្រូវទៅចូលរួមប្រជុំនៅអង្គការសហប្រជាជាតិ ដឹកនាំដោយសឺន សាន នោះ ព្រះអង្គសម្រេចព្រះទ័យពន្យារពេលវិញ។ ពេលនោះ ប្រសិនបើព្រះអង្គមិនមានការពន្យារពេលទេ ប្រហែលជាព្រះអង្គ និងមហេសីអាចនឹងជួបគ្រោះថ្នាក់ ក៏អាចថាបាន។

# ១២០
# គ្រួសារសម សារី រងគ្រោះ ព្រោះរឿងបំផ្ទុះគ្រាប់បែក



**អ៊ិន អេម ប្រពន្ធសម សារី និងកូនៗទាំង៥នាក់** (រូបថត សម រង្ស៊ី)

ក្រោយហេតុការណ៍បំផ្ទុះគ្រាប់បែកនៅក្នុងព្រះបរមរាជវាំង នោះភ្លាម សម្តេចសីហនុ ទ្រង់ព្រះពិរោធឥតឧបមា ព្រះអង្គជឿជាក់ថា គ្មាននរណា ក្រៅពីសម សារី ជាអ្នកផ្ញើតង្វាយគ្រាប់បែកមក ដើម្បីធ្វើគតព្រះអង្គ ព្រមទាំងព្រះមាតា និងព្រះបិតារបស់ព្រះអង្គ នោះទេ។

ប៉ុន្មានម៉ោងក្រោយមក ព្រះអង្គបានចេញព្រះរាជបញ្ជាឲ្យគេចាប់ខ្លួនមនុស្សជាង១០ នាក់ ក្នុងនោះមាន សម ញាណ អតីតរដ្ឋមន្ត្រីក្រសួងធម្មការ ជាឪពុករបស់សម សារី និងបងប្អូនបង្កើត បងប្អូនជីដូនមួយ ព្រមទាំងមនុស្សជំនិតជាមួយគ្រួសារសម សារី មួយចំនួនទៀត។ ប្អូនប្រុសសម សារី ឈ្មោះសម សារុន ត្រូវសម្តេចសីហនុ ឱ្យគេចាប់ដាក់ពន្ធនាគារជិត១ឆ្នាំ។

ចំណែក ប្រពន្ធសម សារី ឈ្មោះអ៊ិន អេម ត្រូវរដ្ឋមន្ត្រីក្រសួងសន្តិសុខជាតិ និង

ការពារលើផ្ទៃ កោះហៅឲ្យទៅជួបដើម្បីសាកសួរ។ ពេលនោះ អ៊ិន អេម ក៏បានយកកូនប្រុសម្នាក់ ឈ្មោះអេម៉ារិទ្ធ ទៅជាមួយដែរ។ រដ្ឋមន្ត្រីក្រសួងចាប់ចងនេះ ឈ្មោះគូ រុន ជាមនុស្សធ្លាប់រាប់អានគ្នា និងធ្លាប់មកលេងផ្ទះសម សារី ញឹកញាប់ផងដែរ កាលពីមុន។ ដោយរង់ចាំរដ្ឋមន្ត្រី គូ រុន យូរពេក អ៊ិន អេម ជាម្ដាយ ក៏បានឲ្យកូន ឈ្មោះអេម៉ារិទ្ធ វិលត្រលប់មកផ្ទះវិញមុន។



**គូ រុន រដ្ឋមន្ត្រីសន្តិសុខជាតិ**

ក្រោយពីអង្គុយរង់ចាំអស់រយៈពេលជាច្រើនម៉ោង រដ្ឋមន្ត្រី គូ រុន ក៏បានមកដល់ និងបាននិយាយសុំទោសដោយសារមកយឺតយ៉ាវនោះ ដើម្បីជាការគួរសមដែរ តែបន្តិចក្រោយមក គូ រុន ក៏បញ្ជាឱ្យគេចាប់ប្រពន្ធសម សារី យកទៅដាក់គុកភ្លាមៗតែម្ដង។

ក្រុមគ្រួសារសម សារី មានការឈឺចាប់ខ្លាំងណាស់ ព្រោះការចាប់ខ្លួនពួកគាត់នេះ គឺគ្មានភស្តុតាង គ្មានហេតុផលបញ្ជាក់ឲ្យឃើញថា សម សារី ជាអ្នកនៅពីក្រោយការបំផ្ទុះគ្រាប់បែកនោះ បន្តិចទាល់តែសោះ ហើយពួកគាត់ជឿជាក់ថា សម សារី គ្មានគំនិតអ្វី ដើម្បីធ្វើគតសម្ដេចសីហនុ និងព្រះមហាក្សត្រជាព្រះបិតាព្រះមាតារបស់ព្រះអង្គនោះទេ។

សម រង្ស៊ី ជាកូនពៅក្នុងគ្រួសារសម សារី បានរម្លឹកពីអនុស្សាវរីយ៍ឈឺចាប់ នៅពេលម្ដាយគាត់កំពុងជាប់ពន្ធនាគារនោះថា ជារឿងរាល់ល្ងាច ពេលគាត់ត្រលប់មកពីរៀនវិញ គាត់តែងតែដើរកាត់មុខពន្ធនាគារប៉េហ្ស៊ី(PJ) ស្ថិតនៅផ្លូវបាស្ទ័រ។ ពេលមកដល់របងពន្ធនាគារម្ដងៗ គាត់បានព្យាយាមយកដុំថ្មពីរបីដុំ មកដាក់បន្តុបលើគ្នា ដើម្បីឈរចំអើតរកមើលទៅទីឃ្លាំខាងក្នុង ដោយគាត់សង្ឃឹមថា បានឃើញអ្នកទោសជាម្ដាយរបស់គាត់ ជា

# របត់នយោបាយ

ជីតារបស់គាត់ ឬជាឪពុកមារបស់គាត់ពីរបីនាក់ទៀត ដែលពួកឆ្មាំគុកបញ្ចេញពីបន្ទប់ឃុំឃាំង ឱ្យមកធ្វើពលកម្ម នៅទីធ្លាខាងក្នុងនោះ។ ប៉ុន្តែ សេចក្តីសង្ឃឹមនេះ ត្រូវរលាយបាត់អស់ ជំនួសមកវិញនូវទឹកភ្នែកហូរធ្លាក់ដោយមិនដឹងខ្លួន ព្រោះម្តាយគាត់ត្រូវគេយកទៅដាក់ក្នុងគុកងងឹត ដាច់ដោយឡែកពីអ្នកទោសផ្សេងៗទៀត។ តែទោះបីយ៉ាងនេះក្តី គាត់នៅតែស្រមៃឃើញម្តាយចេញមកឱបរឹតគាត់ពេញក្នុងដៃ។ តាមពិត ម្តាយគាត់នៅមិនឆ្ងាយប៉ុន្មានពីគាត់ប្រហែល២០ម៉ែត្រប៉ុណ្ណោះ គ្រាន់តែមានជញ្ជាំង និងលួសបន្លាជាច្រើនជាន់ បាំងជារនាំងឃាំងគាត់ និងម្តាយ មិនឱ្យបានឃើញគ្នា សូម្បីបន្តិចឡើយ។

សម រង្ស៊ី បានរម្លឹកបន្តថា ក្រោយពីម្តាយគាត់ជាប់ពន្ធនាគារ បានរយៈពេល៦ខែ ទើបគេអនុញ្ញាតឱ្យបងប្រុសរបស់គាត់ ឈ្មោះអេម៉ារិទ្ធ ចូលទៅជួប ដើម្បីសួរសុខទុក្ខ។ ពេលត្រលប់មកផ្ទះវិញ បងប្រុសរបស់គាត់បានរៀបរាប់ថា ម្តាយរបស់គាត់ត្រូវបានគេយកទៅដាក់ក្នុងបន្ទប់កខ្វក់គួរឲ្យខ្ពើមតូចមួយ ទំហំ៣ម៉ែត្រក្រឡា និងមានប្រហោងមួយធ្វើជាបង្គន់។ ជារៀងរាល់ថ្ងៃ បើពួកឆ្មាំគុកសប្បាយចិត្ត ពួកគេអនុញ្ញាតឲ្យម្តាយគាត់ដើរចុះឡើងនៅក្នុងទីធ្លាមួយទំហំ១០ម៉ែត្រក្រឡា។ ពេលខ្លះ ពួកគេអនុញ្ញាតឱ្យម្តាយរបស់គាត់ងូតទឹកជម្រះកាយដែរ ពោលគឺអ្វីៗ អាស្រ័យទៅតាមទំនើងចិត្តរបស់ពួកឆ្មាំគុកទាំងអស់នោះ។

ចាប់ពីពេលនោះមក អេម៉ារិទ្ធ ជាបងប្រុសរបស់គាត់ តែងតែជិះកង់យកបាយទឹក និងចំណីអាហារផ្សេងៗទៀតទៅឱ្យម្តាយរបស់គាត់ ពីរដងក្នុងមួយថ្ងៃ។ ប៉ុន្តែ ម្តាយគាត់បានផ្តាំផ្ញើមកបងស្រីរបស់គាត់ ឈ្មោះអេម្ម៉ារ៉ាន ឱ្យយកគ្រឿងអលង្ការនៅសេសសល់ទៅលក់មួយចំនួន ដើម្បីយកលុយទៅទិញម្ហូបឆ្ងាញ់ៗ ដូចជាទាខ្វៃ និងស្រាវីស្គី ជាដើម មកឱ្យគាត់បន្ថែមលើម្ហូបធម្មតា ដែលបងប្រុសរបស់គាត់ជិះកង់យកទៅឱ្យនោះ។ ខណៈជីវភាពពួកគាត់កំពុងជួបការលំបាកខ្វះខាតស្រាប់ហើយនោះ ពួកគាត់ជាកូនៗចេះតែឆ្ងល់ថា តើហេតុដូចម្តេចបានជាម្តាយរបស់ពួកគាត់ ទាមទារឲ្យទិញម្ហូបឆ្ងាញ់ៗ ព្រមទាំងស្រាថ្លៃៗដូច្នេះទៅវិញ? ព្រោះតាំងពីដើមមក ពួកគាត់ដឹងច្បាស់ថា ម្តាយរបស់ពួកគាត់មិនចេះផឹកស្រា សូម្បីមួយតំណក់ឡើយ តើនេះមកពីម្តាយរបស់ពួកគាត់ព្រួយចិត្ត និងអស់សង្ឃឹមក្នុងជីវិតឬ? បានជាផ្លាស់ប្តូរ



**ស្នងការដ្ឋាននប៉ូលិស** (PJ) **សម័យអាណានិគមបារាំង**

គំនិត ទៅជាមនុស្សផ្សេងទៀតដូចនេះ?។

ក្រោយមក ទើបពួកគាត់ដឹងថា ការពិត មូលហេតុ ម្ដាយរបស់គាត់ទាមទារឱ្យទិញម្ហូបឆ្ងាញ់ៗ និងស្រាល្អៗនេះ មិនមែនសម្រាប់ខ្លួនឯងទេ គឺសម្រាប់យកទៅផ្គាប់ផ្គុនពួកមន្ត្រីអនុរក្សពន្ធនាគារ ដើម្បីកុំឱ្យគេធ្វើបាបគាត់តែប៉ុណ្ណោះ។ ប៉ុន្តែ រឿងពួកមន្ត្រីអនុរក្សពន្ធនាគារ ធ្វើទារុណកម្មខាងផ្លូវចិត្ត និងផ្លូវកាយយ៉ាងណានោះ ក៏ម្ដាយរបស់ពួកគាត់មិនដែលនិយាយរៀបរាប់ប្រាប់កូនៗបន្តិចណាឡើយ ហើយពួកគាត់ជាកូនៗ ក៏មិនហ៊ានសួរនាំអ្វីដែរ។ ក្រោយមក អេម៉ារិទ្ធ ជាបងប្រុសរបស់គាត់ បានសរសេរលិខិតមួយថ្វាយទៅសម្ដេចសីហនុ ដើម្បីសុំចូលក្រាបបង្គំសុំអង្វរព្រះអង្គ មេត្តាប្រោសប្រណី លើកលែងទោសឱ្យម្ដាយគាត់ដែរ តែពុំមានការឆ្លើយតបទាល់តែសោះ មិនដឹងមកពីមូលហេតុអ្វី?។ សម រង្ស៊ី បានរម្លឹកបន្តទៀតថា រហូតដល់ចុងឆ្នាំ១៩៦០ គឺក្រោយពេលម្ដាយរបស់គាត់ជាប់ពន្ធនាគារ បានជិតមួយឆ្នាំ ទើបពួកគាត់ជាកូនៗទាំង៥នាក់ ត្រូវបានគេអនុញ្ញាតឱ្យចូលព្រះបរមរាជវាំង ដើម្បីក្រាបបង្គំគាល់សម្ដេចសីហនុ តាមព្រះរាជពិធីការ។

## របត់នយោបាយ

ពេលនោះ សម្តេចសីហនុ ទ្រង់គង់លើកៅអីធំមួយ អេម៉ារិទ្ធ ជាបងប្រុសរបស់គាត់ បានក្រាបបង្គំទូលព្រះអង្គថា ព្រះករុណាជាអម្ចាស់ ទូលបង្គំយើងខ្ញុំទាំងអស់គ្នាជាកូន របស់លោកសម សារី សូមក្រាបថ្វាយបង្គំព្រះករុណាជាអម្ចាស់ សូមព្រះមេត្តាសន្តោសប្រោសប្រណីឱ្យម្តាយទូលបង្គំយើងខ្ញុំទាំងអស់គ្នា បានរួចចេញពីពន្ធនាគារផង។

ភ្លាមនោះ សម្តេចសីហនុ មានព្រះបន្ទូលរបៀបធ្វើជាភ្ញាក់ផ្អើលថា ហេតុដូចម្តេចបានជាគេទៅចាប់លោកស្រីអ៊ិន អេម ជាមនុស្សមានកិត្តិយសខ្ពង់ខ្ពស់ យកទៅដាក់ពន្ធនាគារយ៉ាងដូច្នេះ? តើនរណាមួយបញ្ជាឲ្យធ្វើបែបនេះ ដោយមិនប្រាប់យើងជាមុន។ ដូច្នេះ ត្រូវតែដោះលែងលោកស្រី ឲ្យមកទៅរួមរស់ជាមួយកូនៗរបស់គាត់ វិញភ្លាម។

នៅពេលឮព្រះអង្គមានបន្ទូលដូច្នេះ ធ្វើឱ្យពួកគាត់មានការភ្ញាក់ផ្អើលស្រឡាំងកាំងជាខ្លាំង ព្រោះមិនជឿថា ព្រះអង្គមិនមែន មិនដឹងពីរឿងគេចាប់ម្តាយរបស់ពួកគាត់ យកទៅដាក់ពន្ធនាគារជិត១ឆ្នាំ មកហើយនោះទេ។ លុះពួកគាត់វិលត្រលប់មកដល់ផ្ទះវិញ នៅវេលាម៉ោង១២ថ្ងៃត្រង់ ស្រាប់តែឃើញម្តាយរបស់ពួកគាត់បានចេញពីពន្ធនាគារ មកដល់ផ្ទះមុនជាស្រេចទៅហើយ។

អាថ៌កំបាំងករណីបំផ្ទុះគ្រាប់បែកដៃ ដើម្បីប៉ុនប៉ងធ្វើគតព្រះមហាក្សត្រនរោត្តម សុរាម្រិត និងព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ ព្រមទាំងសម្តេចសីហនុ នៅក្នុងព្រះបរមរាជវាំង នាព្រលប់ថ្ងៃទី៣១ សីហា ឆ្នាំ១៩៥៩នោះ ក្រោយមក មានប្រភពព័ត៌គួរឱ្យជឿជាក់មួយ បានឱ្យដឹងថា គឺ ង៉ូ ឌិញញូ ជាប្អូនប្រុស និងជាទីប្រឹក្សាជាន់ខ្ពស់របស់ប្រធានាធិបតីវៀតណាមខាងត្បូង ង៉ូ ឌិញយៀម ជាអ្នកផ្តើមគំនិតរៀបចំឡើង ដើម្បីជាការសងសឹកចំពោះផែនការសម្ងាត់របស់គាត់បានសហការជាមួយសម សារី ផ្តួលរំលំសម្តេចសីហនុ ដើម្បីដាក់ប្រទេសកម្ពុជា ឱ្យចូលជាសមាជិកអង្គការសេអាតូ(SEATO) ត្រូវបរាជ័យ ហើយជាបឈូន ក៏ត្រូវទាហានរបស់សម្តេចសីហនុ ឱ្យលន់ នល់ ដឹកនាំកងទ័ពទៅបាញ់សម្លាប់ទៀត។

ដើម្បីជាការសងសឹក ង៉ូ ឌិញញូ បានប្រើល្បិចឱ្យភ្នាក់ងារសម្ងាត់របស់គាត់រកវិធីផ្ញើប្រអប់តង្វាយដាក់ក្នុងវ៉ាលិស ២ មកកាន់ព្រះបរមរាជវាំង ដោយក្នុងនោះមួយវ៉ាលិសផ្ញើ

ថ្វាយសម្តេចសីហនុ ពេលនោះព្រះអង្គគង់ជានាយករដ្ឋមន្ត្រី និងមួយទៀតផ្ញើមកថ្វាយព្រះមាតា និងព្រះបិតារបស់ព្រះអង្គ។ តង្វាយ២វ៉ាលិសនេះ ត្រូវបានគេផ្ញើតាមប៉ុស្តិ៍ប្រៃសណីយ៍ពីទីក្រុងហុងកុង មកកាន់ព្រះបរមរាជវាំង នៅទីក្រុងភ្នំពេញ ដោយមានបិទផ្លាកអាសយដ្ឋានអ្នកផ្ញើមកថា ពីវិស្វករជាតិអាមេរិកម្នាក់ ធ្លាប់បានមកធ្វើការនៅប្រទេសកម្ពុជា ពីមុន។ តែក្នុងចំណោមតង្វាយទាំង២វ៉ាលិសនោះ មានតែវ៉ាលិសមួយប៉ុណ្ណោះ មានបង្កប់គ្រាប់បែកមួយ គឺនៅក្នុងវ៉ាលិស ដាក់អក្សរថា ផ្ញើថ្វាយព្រះករុណាសម្តេចសីហនុ ។ ពេលនោះ ទ្រង់វ៉ាគ្រីវណ្ណ នាយកពិធីការបើកវ៉ាលិសទាំងពីរនោះ ស្រាប់តែមានគ្រាប់បែកនៅក្នុងវ៉ាលិសមួយផ្ទុះលាន់ឮកក្រើក បណ្តាលឱ្យទ្រង់សុគតភ្លាមៗតែម្តង ។

# ១២១
# ទំនាក់ទំនងរវាងសហរដ្ឋអាមេរិក និងកម្ពុជា ពីឆ្នាំ១៩៥២ ដល់ឆ្នាំ១៩៥៩



**ឯកអគ្គរដ្ឋទូតអាមេរិក ដូណាល់ ហ៊ីល** (Donald R. Heath)



**ឯកអគ្គរដ្ឋទូត រ៉ូប៊េរ ម៉ាក់គ្លីនតុក** (Robert M. McClintock)

បើតាមឯកសាររបស់ក្រសួងការបរទេសរបស់សហរដ្ឋអាមេរិក បានឱ្យដឹងថា ការិយាល័យតំណាងទូតសហរដ្ឋអាមេរិកប្រចាំប្រទេសកម្ពុជា ត្រូវបានតំឡើងឲ្យទៅជាស្ថានឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៥២ ដោយនៅពេលនោះ អ្នកការទូតសហរដ្ឋអាមេរិក ឈ្មោះដូណាល់ ហ៊ីល( Donald R. Heath ) បានក្លាយទៅជាឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកដំបូង គេនៅព្រះរាជាណាចក្រកម្ពុជា។ ពេលនោះ សហរដ្ឋអាមេរិកបានចុះកិច្ចព្រមព្រៀងផ្តល់ជំនួយយោធា និងសេដ្ឋកិច្ច ដល់ប្រទេសកម្ពុជា គិតជាទឹកប្រាក់ចំនួន ៧,៨លានដុល្លារ ដែលត្រូវផ្តល់ឱ្យក្នុងរយៈពេល៤ឆ្នាំ។

នង គឹមនី ដែលត្រូវបានតែងតាំងជាឯកអគ្គរាជទូតខ្មែរដំបូងបង្អស់ប្រចាំសហរដ្ឋអាមេរិក ក្នុងពេលទៅធ្វើទស្សនកិច្ចនៅសហរដ្ឋអាមេរិក ត្រូវអនុញ្ញាតឱ្យចូលជួបប្រធានាធិបតីទ្រូម៉ាន់ (Truman) ក្នុងនាមប្រទេសកម្ពុជា បានសម្តែងការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ

ជំនួយសហរដ្ឋអាមេរិក បន្ថែមពីលើព្រះរាជសាររបស់ព្រះមហាក្សត្រនរោត្តម សីហនុ។

ពេលនោះដែរ ព្រះមហាក្សត្រនរោត្តម សីហនុ បានផ្ញើជំរឹសដ៏កម្រមួយទៅជូនប្រធានាធិបតីទ្រូម៉ាន់( Truman ) ផងដែរ។

ភារធារីសហរដ្ឋអាមេរិកប្រចាំប្រទេសកម្ពុជា ឈ្មោះដូន វី. កាត្លេត( Don V. Catlett ) ជាអ្នកចាត់ចែងការងារដ៏លំបាកក្នុងការដឹកយកជំរឹសនោះពីប្រទេសកម្ពុជា ទៅកាន់ទីក្រុងវ៉ាស៊ីនតោន។

ក្រោយពីមានកិច្ចព្រមព្រៀងក្រុងហ្សឺណែវឆ្នាំ១៩៥៤ភ្លាមអ្នកការទូតសហរដ្ឋអាមេរិក ឈ្មោះរ៉ូប៊ែរ ម៉ាក់គ្លីនតុក (Robert M. McClintock) ត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំប្រទេសកម្ពុជា ។

ក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះមហាក្សត្រនរោត្តម សីហនុ ប្រទេសកម្ពុជាដែលមានសេរីភាពពេញលេញនោះ បានប្ដេជ្ញាចិត្តយ៉ាងមោះមុតក្នុងការរក្សាអព្យាក្រឹតភាពរបស់ខ្លួន ហើយព្រះអង្គបានផ្សារទំនាក់ទំនងមិត្តភាពទាំងជាមួយបណ្ដាប្រទេសលោកខាងលិចទាំងជាមួយមហាអំណាចកុម្មុយនិស្ត។ ដោយសារមានរបបកុម្មុយនិស្តរបស់ហូជីមិញនៅវៀតណាមខាងជើង និងមានការភ័យខ្លាចថា កងកម្លាំងកម្ពុជា មិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទប់ទល់ការបះបោររបស់ចលនាកុម្មុយនិស្តដែលអាចកើតមានឡើងនោះ សហរដ្ឋអាមេរិក បានបង្កើនជំនួយយោធារបស់សហរដ្ឋអាមេរិក ដល់កម្ពុជា។ ជាមួយកម្មវិធីហ្វឹកហ្វឺនយោធាដល់កងទ័ពកម្ពុជា នោះដែរ ឯកអគ្គរដ្ឋទូត រ៉ូប៊ែរ ម៉ាក់គ្លីនតុក (Robert McClintock) និងឧបការីរដ្ឋមន្ត្រីក្រសួងការបរទេស វ៉លទ័រ រ៉ូប៊ីនសុន (Walter S. Robinson) បានបង្កើតក្រុមផ្ដល់ប្រឹក្សាសម្រាប់ជំនួយយោធា ហៅកាត់ថា ក.ប.ជ.យ. ឬ MAAG) នៅភ្នំពេញ ដើម្បីត្រួតពិនិត្យការបញ្ជូន និងការប្រើប្រាស់ជំនួយទាំងនោះ។

ក្នុងខែកុម្ភៈ ឆ្នាំ១៩៥៥ រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក ចន ហ្វស្ទ័រ ឌុល្លេស (John Foster Dulles) បានអញ្ជើញមកបំពេញទស្សនកិច្ចជាផ្លូវការនៅទីក្រុងភ្នំពេញ ដើម្បីជួបពិភាក្សាស្ដីពីបញ្ហាគោលនយោបាយការបរទេសសហរដ្ឋអាមេរិក ជាមួយសម្ដេច



ហ្វូស្ទ័រ ឌុល្លេស និងសម្តេចសីហនុ

នរោត្តម សីហនុ (ពេលនោះ រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក បញ្ចុះបញ្ចូលសម្តេចសីហនុ ឱ្យងាកទៅរកអង្គការសេ អាតូ(SEATO) តែព្រះអង្គបដិសេធ)។

នៅក្នុងខែឧសភា ឆ្នាំ១៩៥៥ កិច្ចព្រមព្រៀងយោធា ត្រូវបានចុះហត្ថលេខា។ ពេលនោះ ឯកអគ្គរដ្ឋទូត រ៉ូប៊ែរ ម៉ាក់គ្លីនតុក(Robert McClintock) បានយកចិត្តទុកដាក់ក្នុងការជានាឲ្យមានការដកកងទ័ពបារាំង បន្តិចម្តងៗ ចេញពីប្រទេសកម្ពុជា។

ចាប់ពីឆ្នាំ១៩៥៥ សហរដ្ឋអាមេរិក បានផ្តល់ជំនួយមានទឹកប្រាក់ ចំនួន៥០លានដុល្លារអាមេរិក ក្នុងមួយឆ្នាំៗដើម្បីជំរុញដំណើរជឿនលឿនផ្នែកសេដ្ឋកិច្ច និងសង្គម ពង្រឹងឯករាជ្យ កែលម្អ និងពង្រឹងវិស័យអប់រំសិក្សាធិការសាធារណៈដោយមិនយកថ្លៃ ព្រមទាំងបង្កើនគុណភាពនិងបរិមាណផលិតផលកសិកម្ម លើកកម្ពស់សុខភាពសាធារណៈ សន្តិសុខហេដ្ឋារចនាសម្ព័ន្ធ និងធ្វើទំនើបកម្មកងកម្លាំងប្រដាប់អាវុធ ផងដែរ។

កម្មវិធីជំនួយរបស់សហរដ្ឋអាមេរិក មានទំហំធំជាងជំនួយបូករួមចូលគ្នាទាំងអស់ពីបណ្តាប្រទេស និងអង្គការអន្តរជាតិដទៃទៀត ដោយសហរដ្ឋអាមេរិក បានផ្តល់ជំនួយ៤៩៣លានដុល្លារ គិតពីឆ្នាំ១៩៥៥ មកត្រឹមឆ្នាំ១៩៦៣ ដើម្បីជួយបង្កើតសាលាគរុកោសល្យសម្រាប់បណ្តុះបណ្តាលគ្រូបឋមសិក្សា នៅកំពង់កន្ទួត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល និងបំពាក់គ្រឿងសម្ភារៈដល់សាលាឯកទេស សាលាមធ្យមសិក្សា សាលាបឋមសិក្សា ព្រមទាំងសាងសង់អគារសាលាបឋមសិក្សាចំនួន ១៤កន្លែង និងអគារសាលាមធ្យមសិក្សាចំនួន ៥កន្លែងទៀត។

និស្សិតកម្ពុជាមួយចំនួនបានទទួលអាហារូបករណ៍ទៅសិក្សានៅសហរដ្ឋអាមេរិក ផ្នែកកសិកម្ម សុខភាពសាធារណៈ វិស្វកម្ម និងបច្ចេកទេសក្នុងការប្រើប្រាស់ឧបករណ៍និងគ្រឿងម៉ាស៊ីន ។

ជាមួយគ្នានោះដែរ សហរដ្ឋអាមេរិក បានជួយកសាងមណ្ឌលសុខភាព មន្ទីរពេទ្យកុមារ រាជបណ្ឌិត្យសភានគរបាល និងជួយជួសជុលផ្លូវប្រវែង ជាង១២០០គីឡូម៉ែត្រ និងស្ពានចំនួន៤៣កន្លែង ។ ពិសេសបានសាងសង់ផ្លូវជាតិលេខ៤ ដែលមានឈ្មោះថា ផ្លូវមិត្តភាពកម្ពុជា-សហរដ្ឋអាមេរិក មានប្រវែង២៣០គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ ទៅក្រុងព្រះសីហនុ។ ការសាងសង់ផ្លូវនេះបានចំណាយថវិកាអស់ ចំនួន២៥លានដុល្លារ ដោយមានកម្មករជាជនជាតិ អាមេរិក និងកម្មករខ្មែរ ធ្វើការជាមួយគ្នាទៀតផង។

បើតាមឯកសាររបស់ក្រសួងការបរទេសរបស់សហរដ្ឋអាមេរិក ដដែលបានបន្តថា ទន្ទឹមនោះ ផ្នែកនយោបាយរបស់ប្រទេសកម្ពុជា ក៏មានការប្រែប្រួលផងដែរ ដោយនៅក្នុងខែមីនា ឆ្នាំ១៩៥៥ ព្រះមហាក្សត្រនរោត្តម សីហនុ បានប្រកាសដាក់រាជសម្បត្តិ ទៅបង្កើតចលនាសង្គមរាស្ត្រនិយម ចូលរួមក្នុងការបោះឆ្នោតនៅខែកញ្ញា ឆ្នាំ១៩៥៥ ហើយបានឈ្នះឆ្នោត ឡើងកាន់តំណែងជានាយករដ្ឋមន្ត្រី។

អ្នកការទូតសហរដ្ឋអាមេរិក ឈ្មោះខាល ស្ត្រូម (Carl W. Strom) ដែលត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក នៅកម្ពុជា ចាប់ពីថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៥៦ មកនោះ បានជួយការពារអធិបតេយ្យភាពរបស់កម្ពុជានៅចំពោះមុខការឈ្លានពានកាន់តែច្រើនឡើងៗពីសំណាក់កងទ័ពថៃ និងវៀតណាមខាងត្បូង ដែលមានប្រវត្តិជម្លោះទឹកដីជាមួយប្រទេសកម្ពុជា ជាយូរមកហើយ។ ទោះបីជាទំនាក់ទំនងរវាងប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក ត្រូវបានពង្រឹងយ៉ាងណាក្តី តែគោលជំហររបស់សម្តេចសីហនុ ក្នុងការប្រកាន់យកអព្យាក្រឹតភាព បានចាប់ផ្តើមធ្វើឱ្យទំនាក់ទំនងការទូតមានបញ្ហាស្មុគស្មាញ។

សម្តេចសីហនុ ម្តងហើយម្តងទៀតបានទោរទន់ទៅរកសាធារណរដ្ឋប្រជាមានិតចិន ដោយនៅក្នុងឆ្នាំ១៩៥៧ ព្រះអង្គបានទៅធ្វើទស្សនកិច្ចនៅប្រទេសចិន និងប្រទេសកុម្មុយ

និស្តដទៃទៀត ហើយពេលនោះព្រះអង្គបានទទួលជំនួយសេដ្ឋកិច្ចពីសាធារណរដ្ឋប្រជាមានិតចិន ទៀតផង។ កាន់តែអាក្រក់ជាងនេះទៅទៀត នៅក្នុងពេលកំពុងមានភាពតានតឹងខ្លាំងឡើងៗ ជាមួយរាជរដ្ឋាភិបាលប្រទេសថៃ និងវៀតណាមខាងត្បូង ដែលមានទំនោរទៅរកលោកខាងលិច បើទោះបីមានការប្រឆាំងពីសំណាក់សហរដ្ឋអាមេរិកយ៉ាងណាក្តី ក៏សម្តេចសីហនុ បានប្រកាសទទួលស្គាល់សាធារណរដ្ឋប្រជាមានិតចិន នៅក្នុងខែកក្កដា ឆ្នាំ១៩៥៨។ ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ខាល ស្រ្តូម (Carl W. Strom) ត្រូវបានហៅឲ្យត្រលប់ទៅសហរដ្ឋអាមេរិកវិញជាបណ្តោះអាសន្ន។

ដោយប្រឈមនឹងបរិយាកាសកាន់តែបាត់បង់ស្ថិរភាពឡើងនៅក្នុងប្រទេស សម្តេចសីហនុ ខិតខំស្តារទំនាក់ទំនងឡើងវិញ ដោយព្រះអង្គបានយាងឲ្យទៅបំពេញព្រះរាជទស្សនកិច្ចនៅសហរដ្ឋអាមេរិក ក្នុងខែកញ្ញា ឆ្នាំ១៩៥៨។ ព្រះអង្គបានឈប់សំចតនៅទីក្រុងវ៉ាស៊ីនតោន ទីក្រុងញូវយ៉ក ទីក្រុងដីទ្រ័ត(Detroit) ទីក្រុង ស៊ីកាហ្គោ(Chicago) និងទីក្រុងឡូស អេនចឺឡេស(Los Angeles)។ ពេលទៅដល់អាកាសយានដ្ឋានអន្តរជាតិនៅទីក្រុងឡូស អេនចឺឡេស(Los Angeles) សម្តេចសីហនុ បានថ្លែងប្រាប់ក្រុមអ្នកសារព័ត៌មានថា យើងមិនបានបំភ្លេចទេថា សហរដ្ឋអាមេរិក ស្ថិតក្នុងចំណោមប្រទេសដំបូងគេដែលបានទទួលស្គាល់ប្រទេសរបស់យើង ហើយបានផ្តល់ការគាំទ្រ និងជំនួយដល់ប្រទេសកម្ពុជាចាប់តាំងពីជំហានដំបូងរបស់យើង ។ ក្នុងការទទួលបានឯករាជ្យ យើងបានបោះជំហានសំខាន់ៗខ្លះ ក្នុងដំណើរជឿនលឿនទៅមុខនេះ ត្រូវបានសម្រួលដោយមិត្តភាព និងជំនួយសម្បុរសធម៌ជាប្រចាំរបស់សហរដ្ឋអាមេរិក។ កម្ពុជាអាចជំនះបានលើការលំបាកដ៏ធំធេងដែលបានជះស្រមោលទៅលើការចាប់កំណើតឡើងវិញនៃឯករាជ្យរបស់កម្ពុជា មួយចំណែកធំ គឺដោយសារសហរដ្ឋអាមេរិក។ ប្រជារាស្ត្រខ្មែរបានដឹងពីរឿងនេះ ហើយនឹងមិនអាចភ្លេចបានទេ។

ព្រះរាជទស្សនកិច្ចរបស់សម្តេចសីហនុ នៅពេលនោះ នាំឲ្យមជ្ឈដ្ឋានអ្នកការទូតបណ្តាប្រទេសនានាមានការចាប់អារម្មណ៍យ៉ាងខ្លាំង ពិសេសបន្ទាប់ពីពិធីជប់លៀងតាមបែប



**សម្តេចសីហនុ ប្រគល់ចម្លាក់បដិមាសម័យអង្គរជូនប្រធានាធិបតីអាមេរិក**

ប្រទេសកម្ពុជា ដែលព្រះអង្គបានរៀបចំឡើងនៅទីក្រុងញូវយ៉ក និងទីក្រុងវ៉ាស៊ីនតោន ព្រះអង្គបានរៀបចំមានរបាំខ្មែរបុរាណ សម្តែងដោយបុត្រីបុត្រារបស់ព្រះអង្គ គឺម្ចាស់ក្សត្រីបុប្ផាទេវី និងព្រះអង្គម្ចាស់ចក្រពង្ស ព្រមទាំងអ្នករាំរបាំក្នុងក្រុមរបាំព្រះរាជទ្រព្យផ្សេងៗជាច្រើនទៀត។

កាសែតវ៉ាស៊ីនតោនប៉ុស្តិ៍ និងកាសែតថែម៍ ហេរ៉លដ៍ (Time Herald) បានហៅព្រះអង្គថា ជាអ្នករៀបចំពិធីជប់លៀងដ៏ល្អបំផុតពេលនោះ បានបន្ថែមថាភ្ញៀវបានសរសើរយ៉ាងខ្លាំងចំពោះការតុបតែង និងសម្លៀកបំពាក់ដ៏ចាំងចែងរបស់អ្នករាំរបាំនោះ។

នៅទីក្រុងវ៉ាស៊ីនតោន សម្តេចសីហនុ បានប្រគល់ជូនប្រធានាធិបតីឌ្វៃត៍ ឌី. អែសិនហាវើរ (Dwight D. Eisenhower) នូវចម្លាក់បដិមាសម័យអង្គរក្នុងសតវត្សរ៍ទី១២ ធ្វើពីថ្មក្រានីដតាន់ ដោយព្រះអង្គមានបន្ទូលថា ដើម្បីជាការដឹងគុណចំពោះជំនួយដែលប្រទេសរបស់លោកបានផ្តល់ឱ្យប្រទេសខ្ញុំ។ រូបចម្លាក់បដិមានេះត្រូវបានដាក់តាំងនៅក្នុងវិចិត្រសាលជាតិ (National Gallery)។

## របត់នយោបាយ

ពេលបំពេញព្រះរាជទស្សនកិច្ចនោះ រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក ហ្វូស្ទ័រ ឌុល្លេស (John Foster Dulles) ក៏បានជួបសំណេះសំណាលជាមួយព្រះអង្គផងដែរ ដោយព្រះអង្គបានបញ្ជាក់សាជាថ្មីដល់រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិករូបនេះ ពីការប្ដេជ្ញាចិត្តរបស់ព្រះអង្គក្នុងការថែរក្សាគោលនយោបាយអព្យាក្រឹតភាព នៃប្រទេសកម្ពុជា ហើយរដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក បានបញ្ជាក់សាជាថ្មីនូវការប្ដេជ្ញាចិត្តគោរព ចំពោះឯករាជ្យភាពទាំងស្រុងនៃប្រទេសកម្ពុជា វិញដែរ។

ព្រះរាជដំណើរនៃទស្សនកិច្ចនោះគឺជាចំណុចខ្ពស់បំផុតក្នុងទំនាក់ទំនងទ្វេភាគីក្នុងទសវត្សរ៍ឆ្នាំ១៩៥០ ដោយឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកខាល ស្ត្រូម (Carl W. Strom) បានមានប្រសាសន៍ថា៖ ខ្ញុំសប្បាយចិត្តណាស់ នៅពេលបានដឹងថា សម្ដេចបានធ្វើដំណើរមកបំពេញព្រះរាជទស្សនកិច្ចនៅសហរដ្ឋអាមេរិក ដើម្បីបានដឹងពីសហរដ្ឋអាមេរិក និងពលរដ្ឋអាមេរិក ឲ្យកាន់តែច្បាស់។ ខ្ញុំដឹងថា ជំនួបរបស់សម្ដេចជាមួយប្រធានាធិបតី ដ្វៃត៍ ឌី. អែសិនហាវរើ (Dwight D. Eisenhower) និងរដ្ឋមន្ត្រីការបរទេស ហ្វូស្ទ័រ ឌុល្លេស (John Foster Dulles) មានផ្លែផ្កាច្រើន ខ្ញុំសង្ឃឹមថាវានឹងធ្វើឱ្យប្រជាជាតិខ្មែរការយល់ដឹងកាន់តែច្បាស់ពីសហរដ្ឋអាមេរិក។ ខ្ញុំប្រាកដក្នុងចិត្តថា ការយល់គ្នាទៅវិញទៅមកបានល្អ ពិតជាធានាដល់ទំនាក់ទំនងមិត្តភាពរបស់យើង។ នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៥៩ ឯកអគ្គរដ្ឋទូតថ្មីរបស់សហរដ្ឋអាមេរិក ឈ្មោះវីល្លៀម ទ្រីមប៊ិល (William C. Trimble) បានថ្វាយសារតាំងសម្ដេចនរោត្តម សីហនុ ។ ឯកអគ្គរដ្ឋទូតអាមេរិកម្នាក់នេះបានចាត់ចែងសាងសង់អគារស្ថានទូតជាផ្លូវការឡើង។

ឯកអគ្គរដ្ឋទូតវីល្លៀម ទ្រីមប៊ិល នៅក្នុងខែកក្កដា ឆ្នាំ១៩៥៩ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃរបស់សហរដ្ឋអាមេរិក ឈ្មោះ ហ្វ្រេត អេ ស៊ីតុន (Fred A. Seaton) បានធ្វើដំណើរមកប្រទេសកម្ពុជា ដើម្បីចូលរួមជាអធិបតីក្នុងពិធីសម្ពោធផ្លូវមិត្តភាពកម្ពុជា-អាមេរិក (ផ្លូវជាតិលេខ៤) ទើបតែសាងសង់ហើយថ្មីៗនាពេលនោះ។ ផ្លូវនោះ ត្រូវបានចាត់ទុកថាជានិមិត្តរូបនៃចំណងមិត្តភាពរវាងរដ្ឋាភិបាលអាមេរិក និងរាជរដ្ឋាភិបាលកម្ពុជា ដោយមានផ្លាកសម្គាល់នៅចុង

ទាំងសងខាងនៃផ្លូវនោះ មានចារឹតព្រះបន្ទូលរបស់សម្ដេចសីហនុ ថា៖ ផ្លូវនេះ ជាផ្លូវមិត្តភាពដែលត្រូវបានកសាងឡើងតាមរយៈការខិតខំសហប្រតិបត្តិការគ្នារវាងអាមេរិក និងកម្ពុជា ក្នុងស្មារតីសេរីភាពនិងភាតរភាព ដើម្បីសម្រេចបំណងឯករាជ្យសេដ្ឋកិច្ចនៃប្រទេសកម្ពុជា និងប្រសាសន៍របស់





**ទូតអាមេរិក វីល្លៀម ទ្រីមប៊ុល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ហ្វ្រេត អេ ស៊ីតុន និងសម្ដេចសីហនុ**

ប្រធានាធិបតី ដ្វៃត៍ ឌី. អែសិនហាវវើរ (Dwight D. Eisenhower) ថា៖ ផ្លូវនេះកសាងឡើងដោយការខិតខំរួមគ្នារបស់ប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក គឺជានិមិត្តរូបនៃមិត្តភាពរបស់ប្រជាពលរដ្ឋនៃប្រទេសយើងទាំងពីរក្នុងបំណងប្រាថ្នារួមគ្នារបស់យើងដែលចង់ឲ្យប្រទេសកម្ពុជា ក្លាយជាប្រទេសមានសេរីភាព ឯករាជ្យ និងវិបុលភាព។



ឯកអគ្គរដ្ឋទូតឌុដសាន់ ស្ព្រូស ថ្វាយសារតាំង

នៅថ្ងៃទី២២ ខែកក្កដា១៩៥៩ ផ្លូវជាតិលេខ៤ ជាជំនួយរបស់សហរដ្ឋអាមេរិក ត្រូវបានធ្វើពិធីសម្ពោធឱ្យប្រើប្រាស់ជាផ្លូវការ និងដាក់ឈ្មោះថា ផ្លូវមិត្តភាពខ្មែរ-អាមេរិក។

នៅក្នុងឆ្នាំ១៩៦១ សហរដ្ឋអាមេរិកបានផ្តល់អាហារូបករណ៍ដល់មន្ត្រីរាជការសាស្ត្រាចារ្យនិស្សិតខ្មែរ ចំនួន៣៦នាក់ ឱ្យទៅបន្តការសិក្សានៅសហរដ្ឋអាមេរិក។ ក្នុងនោះ មានអ្នកខ្លះត្រូវសិក្សារយៈពេល៣ខែ ខ្លះត្រូវសិក្សារយៈពេល១ឆ្នាំ និងខ្លះទៀតត្រូវសិក្សារយៈពេល៤ឆ្នាំ អាស្រ័យតាមមុខជំនាញនីមួយៗ។ គិតមកដល់ខែកញ្ញា ឆ្នាំ១៩៦១ សហរដ្ឋអាមេរិកបានផ្តល់អាហារូបករណ៍ដល់មន្ត្រីរាជការសាស្ត្រាចារ្យនិស្សិតខ្មែរជាង១០០នាក់ ឲ្យទៅបន្តការ-សិក្សានៅប្រទេសរបស់ខ្លួន។

នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៦២ វីល្លៀម ទ្រីមប៊ល (William C. Trimble) បានបញ្ចប់តួនាទីជាឯកអគ្គរដ្ឋទូតរបស់សហរដ្ឋអាមេរិក នៅប្រទេសកម្ពុជា ។ នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៦២ ឌុដសាន់ ស្ព្រូស (Dodson Sprouse) ត្រូវបានរដ្ឋាភិបាលសហរដ្ឋអាមេរិក តែងតាំងជាឯកអគ្គរដ្ឋទូតរបស់សហរដ្ឋអាមេរិក នៅប្រទេសកម្ពុជា។ ប៉ុន្តែរហូតដល់ថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៦២ ទើបគាត់មកថ្វាយសារតាំងចំពោះសម្តេចសីហនុ ជាព្រះប្រមុខរដ្ឋ ជាផ្លូវការ។



និស្សិតខ្មែរថតនៅទីក្រុងវ៉ាស៊ីងតោន



និស្សិតខ្មែរនៅសាកលវិទ្យាល័យ អារីហ្សូណា

# ១២២
# សម្តេចសីហនុ រៀបរាប់ពីអំពើក្បត់របស់ សម សារី និងសឹង ង៉ុកថាញ់

ក្រោយពីរត់គេចខ្លួនទៅដល់ប្រទេសវៀតណាមខាងត្បូង សម សារី ត្រូវភ្នាក់ងារ សេអ៊ីអា និងមេដឹកនាំវៀតណាមខាងត្បូង បញ្ជូនឲ្យទៅជួបពិភាក្សា និងសហការជាមួយ សឹង ង៉ុកថាញ់។ បន្ទាប់មក ដោយមានការឯកភាពពីសឹង ង៉ុកថាញ់ ផងដែរ សម សារី ត្រូវបានគេបញ្ជូនឱ្យទៅដឹកនាំកម្លាំងតស៊ូខ្មែរសេរី ជាមួយឡឹក សំអឿន នៅរណសិរ្សភ្នំដងរែក ជាប់ព្រំដែនថៃ ដោយមានទីប្រឹក្សាជាជនជាតិយួនម្នាក់ទៅជាមួយផង។ ក្នុងខែតុលា ឆ្នាំ ១៩៥៩ ដោយមានការគាំទ្រពីសហរដ្ឋអាមេរិក វៀតណាមខាងត្បូង និងថៃ សមាសភាព មេដឹកនាំចលនាខ្មែរសេរី ត្រូវបានប្រកាសឡើងជាផ្លូវការ ដោយមានមេដឹកនាំកំពូល៣នាក់ គឺ ទី១. សឹង ង៉ុកថាញ់, ទី២, សម សារី និងទី៣. ឡឹក សំអឿន ហៅផ្កាយព្រឹក។

ចំណែក នៅទីក្រុងភ្នំពេញ ឯណោះវិញ សម្តេចសីហនុ ក៏បានប្រកាសតាមវិទ្យុជាតិ បាចខិតប័ណ្ណ និងបិទប្រកាសតាមទីសាធារណៈនានា តាមទីប្រជុំជន នៅទូទាំងប្រទេស ព្រមទាំងតែងបទចម្រៀង ពាក្យកាព្យ មានទាំងរូបថត រូបតុ្លក ដោយប្រើពាក្យអសុរោះ ដេរ ប្រមាថតិះដៀលសម សារី ថា ជាជនក្បត់ជាតិ។

ក្រោយមកទៀត ព្រះអង្គក៏បានប្រកាសជាសាធារណៈថា បើជនណាកាត់ក្បាលសឹង ង៉ុកថាញ់បាន ហើយយកមកប្រគល់ឲ្យអាជ្ញាធររបស់ព្រះអង្គ នឹងទទួលប្រាក់រង្វាន់ ចំនួន៣ លានរៀល, បើកាត់ក្បាល សម សារី បាន នឹងទទួលប្រាក់រង្វាន់ ចំនួន២លានរៀល បើកាត់ ក្បាលឡឹក សំអឿន ហៅ ផ្កាយព្រឹក បាន នឹងទទួលរង្វាន់ ចំនួន១លានរៀល។ ចំណែក សឹង ង៉ុកថាញ់ និងសម សារី ក៏បានធ្វើសេចក្តីថ្លែងតាមវិទ្យុខ្មែរសេរី ពីក្រៅប្រទេស និងបាន ឱ្យភ្នាក់ងារសម្ងាត់លួចចូលមកបាចខិតប័ណ្ណនៅក្នុងផ្ទៃប្រទេស វាយប្រហារ ដើម្បីតិះដៀល រិះគន់ព្រះអង្គវិញដែរ ។

ពេលខ្លះ សម សារី បានសរសេរអត្ថបទជាសារនយោបាយ រួចឱ្យសឹង ង៉ុកថាញ់ ចុះហត្ថលេខា និងអានផ្សាយតាមវិទ្យុខ្មែរសេរី ថា ប្រទេសកម្ពុជា ដែលមានឈ្មោះសីហនុ និងចលនាសង្គមរាស្ត្រនិយមជាអ្នកដឹកនាំ ត្រូវផ្លាស់ប្តូរនយោបាយអព្យាក្រឹតរបស់ខ្លួនចោល ហើយដាក់ប្រទេសឱ្យចូលជាសមាជិកអង្គការសេអាតូ (SEATO)វិញ។

ចំពោះការវាយប្រហារ តិះដៀលរិះគន់របស់មេដឹកនាំចលនាខ្មែរសេរី ទាំង២នាក់នេះ សម្តេចសីហនុ បាននិពន្ធអត្ថបទមួយយ៉ាងវែង ស្តីពីអំពើក្បត់របស់សម សារី និងសឹង ង៉ុកថាញ់ យកទៅចុះផ្សាយនៅក្នុងទស្សនាវដ្តីអ្នកជាតិនិយម ជាការតបតទៅវិញដែរ។ នៅក្នុងទស្សនាវដ្តីអ្នកជាតិនិយម ច្បាប់ចេញផ្សាយ ចាប់ពីលេខ១ ដល់លេខ៣ នៅដើមទសវត្សរ៍ ឆ្នាំ១៩៦០ សម្តេចសីហនុ បានដាក់ជាសំណួរថា តើប្រទេសកម្ពុជាយើង ត្រូវផ្លាស់ប្តូរនយោបាយអព្យាក្រឹតរបស់ខ្លួនឬទេ? បន្ទាប់មកព្រះអង្គបានធ្វើការពន្យល់ និងបកស្រាយថា សម សារី និងសឹង ង៉ុកថាញ់ បានចោទប្រកាន់ថា៖

ទី១. សីហនុ បានឱ្យពួកកុម្មុនិស្តជ្រៀតជ្រែកចូលក្នុងផ្ទៃប្រទេស ធ្វើសកម្មភាពជាន់ពន្លិចឯករាជ្យ និងសន្តិភាពរបស់ខ្មែរ ហើយព្រះអង្គដឹកនាំជាតិ ឱ្យមានសត្រូវជុំទិស ព្រមទាំងធ្វើឲ្យប្រទេសជិតខាង ដូចជាថៃ និងវៀតណាមខាងត្បូង ត្រូវរងគ្រោះយ៉ាងធំ ដោយសារតែសីហនុ និងពួកកុម្មុយនិស្តនេះឯង។

ទី២.នយោបាយអព្យាក្រឹតរបស់សីហនុ នាំឲ្យប្រទេសជាតិ មានអសន្តិសុខ បែកបាក់សាមគ្គីរវាងគ្នានឹងគ្នា ព្រមទាំងនាំទៅរកគ្រោះមហន្តរាយរហូតដល់ស្លាប់បាន ដោយការដឹកនាំប្រទេស នៅចំកណ្តាលភ្នក់ភ្លើងបរមាណូទាំងពីរ គឺម្ខាងជារបស់កុម្មុយនិស្ត និងម្ខាងទៀតជារបស់លោកសេរី ម្ល៉ោះហើយ មហាអំណាចទាំង២នេះ គេអាចកម្ទេចប្រទេសយើង បានដោយងាយ។

ទី៣. នយោបាយចលនាសង្គមរាស្ត្រនិយម និងសីហនុ ជានយោបាយប្រឆាំងនឹងលទ្ធិប្រជាធិបតេយ្យ ប្រឆាំងឧត្តមគតិសេរីភាព និងយុត្តិធម៌ ដែលធម៌ព្រះពុទ្ធហៅថា សម្មាទិដ្ឋិ។

## របត់នយោបាយ

ចំពោះពាក្យចោទប្រកាន់ខាងលើនេះ សម្តេចសីហនុ សូមឱ្យប្រជាជាតិខ្មែរជួយវិនិច្ឆ័យ រកខុសរកត្រូវដូចតទៅនេះ ៖

ទី១. អំពីរឿងបញ្ចូលពួកកុម្មុយនិស្តមកក្នុងប្រទេសខ្មែរ ព្រះអង្គសូមរម្លឹកថា សម សារី និងសឺង ង៉ុកថាញ់ តែងតែប្រើពាក្យថា ខ្លួនជាអ្នកស្រលាញ់ជាតិ អាណិតអាសូរដល់ជាតិ ជាអ្នកស្នេហាជាតិ ជាអ្នកជាតិនិយម ជាអ្នកការពារឯករាជ្យ និងសន្តិភាពជាតិនោះ គឺពាក្យទាំងអស់នេះ ដូចនឹងពាក្យរបស់ពួកពាលដែរ ហើយអត្ថបទ និងសេចក្តីថ្លែងការណ៍ទាំងអស់របស់ពួកគេ ក៏មិនខុសគ្នានឹងអត្ថបទចុះផ្សាយ ដោយពួកកាសែតកាន់ជើងអង្គការសេអាតូ(SEATO) ដូចជាកាសែតឡឺហ្វីការ៉ូ របស់បារាំង, ទស្សនាវដ្តីអាមេរិក ថៃម៍ (Time), កាសែតនូស៍វីក (news week), កាសែតថៃ និងកាសែតវៀតណាមខាងត្បូង ។ល។

សម្តេចសីហនុ បានសរសេរបន្តថា សម សារី និងសឺង ង៉ុកថាញ់ បានស្រែកឃោសនាថា ពួកឥស្សរៈបានដេញពួកកុម្មុយនិស្តវៀតមិញ ចេញពីប្រទេសកម្ពុជា អស់ទៅហើយ បែរជាសីហនុ ដើរទៅទាក់ទងប្រទេសរុស្ស៊ី និងចិនប្រជាមានិត ព្រមទាំងតាំងខ្លួនជាមិត្តភក្តិជាមួយយួនខាងជើង នាំពួកកុម្មុយនិស្តទាំងអស់នេះ ចូលមកធ្វើសកម្មភាពពាសពេញផ្ទៃប្រទេស និងបានទទួលជំនួយសេដ្ឋកិច្ច ព្រមទាំងទាក់ទងខាងពាណិជ្ជកម្ម ជាមួយពួកនេះទៀតផង។

សម្តេចសីហនុ បានបកស្រាយថា ការដែលសឺង ង៉ុកថាញ់ អួតអាងថា កាលខ្លួនធ្វើឥស្សរៈនៅក្នុងព្រៃ ពួកគេបានដេញពួកកុម្មុយនិស្តវៀតមិញ ឲ្យចេញពីប្រទេសអស់ហើយនោះ គឺជាការភូតភរទាំងស្រុង ហើយក៏ជាការប្រមាថមើលងាយដល់ជនរួមជាតិរបស់ខ្លួនឯងជ្រុលពេក ព្រមទាំងជាការប្រមាថដល់ប្រវត្តិសាស្ត្រខ្មែរផងដែរ ព្រោះអ្នកផងទាំងពួងដឹងច្បាស់ថា ក្នុងគ្រាអសន្តិសុខពីមុននោះ ពួកឥស្សរៈបានបើកទ្វារកម្ពុជា ឱ្យកងទ័ពយួនវៀតមិញចូលមកយាយីប្រទេសយើង ប្រជារាស្ត្រយើង អស់ជាច្រើនឆ្នាំ។

ក្នុងពេលកងទ័ពវៀតមិញ ចូលមកលុកលុយដណ្តើមយកខេត្តក្រចេះ និងស្ទឹងត្រែងនៅក្នុងខែមេសា ឆ្នាំ១៩៥៤ ពួកឥស្សរៈសឺង ង៉ុកថាញ់ មានឈ្មោះអៀ ស៊ីចូវ ជាទីប្រឹក្សា



**សម្តេចសីហនុ ដឹកនាំកងទ័ពដេញពួកវៀតមិញ ឆ្នាំ១៩៥៤**

នយោបាយ និងជាពួកកុម្មុយនិស្ត ផងដែរ បាននាំកងទ័ពរបស់ខ្លួន មកត្រៀមនៅក្នុងខេត្ត កំពង់ធំ រង់ចាំជួយពួកវៀតមិញ ដើម្បីវាយកងទ័ពជាតិ មានព្រះអង្គជាអគ្គបញ្ជាការ។ តែគាប់ជួនពេលនោះ សន្និសីទក្រុងហ្សឺណែវ មកដល់ ក៏ត្រូវឈប់ច្បាំងគ្នា ចាប់ពីពេលនោះមក។

នៅក្នុងសន្និសីទក្រុងហ្សឺណែវ ពួកសឺង ង៉ុកថាញ់ និងពួកសឺង ង៉ុកមិញ បានខិតខំបញ្ចុះបញ្ចូលឱ្យមហាប្រទេសកុម្មុយនិស្ត ជួយខ្លួន គឺជួយតវ៉ាទាមទារយកទឹកដីកម្ពុជា មួយភាគ ឲ្យពួកខ្លួនត្រួតត្រា ដូចពួកប៉ាថេតឡាវ ទាមទារបានខេត្តសាំនឿ និង ខេត្តផុង សាលី យកមកត្រួតត្រានៅប្រទេសឡាវ ។

ពួកឥស្សរៈនេះ មិនបានគិតគូរដល់បូរណភាព ឯករាជ្យភាពរបស់ជាតិ និងមិនបានគិតគូរពីរឿងឱ្យកងទ័ពវៀតមិញ ចេញឱ្យអស់ពីដែនដីមាតុភូមិទេ គឺគិតតែប្រយោជន៍ផ្ទាល់ខ្លួន លាភសក្ការៈ និងមហិច្ឆតារបស់ពួកខ្លួនតែប៉ុណ្ណោះ។

ផ្ទុយទៅវិញ គឺមានតែគណៈប្រតិភូតំណាងរាជរដ្ឋាភិបាលយើងទេ បានតស៊ូដដែក

តវ៉ាជាមួយមហាអំណាចសហភាពសូវៀត និងចិនប្រជាមានិត រហូតពួកនេះ សុខចិត្តបង្គាប់ឱ្យកងទ័ពវៀតមិញ ចាកចេញពីដែនដីខ្មែរយើង និងបង្គាប់ឱ្យពួកឥស្សរៈទាំងអស់ដាក់អាវុធចុះ ហើយសុខចិត្តឱ្យប្រទេសខ្មែរ នៅគង់វង្សទាំងមូល ក្រោមម្លប់រាជបល្លង្ករបស់ជាតិ ដោយពុំមានការបែងចែកទឹកដីជាពីរភាគ ដូចនៅវៀតណាម និងប្រទេសឡាវ ឡើយ។ ជ័យជម្នះរបស់ខ្មែរយើង នៅសន្និសីទក្រុងហ្សឺណែវនោះ បានមកដោយសារយើងលើកហេតុផលជាក់ស្តែងថា ពួកអ្នកជាតិនិយមពិតប្រាកដ គ្មានបែកបាក់សាមគ្គីគ្នាទេ គឺប្រជារាស្ត្រខ្មែរទាំង ៤លាន ២សែននាក់ កំពុងរស់នៅជុំវិញរាជបល្ល័ង្ក បានកសាងឯករាជ្យជាតិ ដោយខ្លួនឯងពិតប្រាកដ ដោយគ្មានពឹងពាក់កងទ័ពបរទេសវៀតមិញ និងពួកឧទ្ទាមនោះទេ។

ឯករាជ្យនេះទៀតសោត ក៏កើតមានជាក់ស្តែង ដោយសារបារាំង បានផ្ទេរកេតនភណ្ឌសឹក ទាហាន ប៉ូលិស តុលាការ និងកិច្ចការទូត មកជូនរាជរដ្ឋាភិបាលស្រេចបាច់អស់ហើយតាំងពីមុនពេលមានកិច្ចព្រមព្រៀងនៅហ្សឺណែវ មកម្ល៉េះ។ ដោយហេតុនេះហើយ បានជានៅប្រទេសកម្ពុជា មានសន្ធិសញ្ញាបញ្ឈប់ចម្បាំងជាមួយមេទ័ពវៀតមិញ ដោយមាន ញឹក ជូឡុង ជាអ្នកចុះហត្ថលេខាផ្ទាល់ ។ ឯសន្ធិសញ្ញាបញ្ឈប់ចម្បាំង នៅប្រទេសឡាវ និងវៀតណាម វិញ គឺឧត្តមសេនីយ៍បារាំង ឈ្មោះដែលតី( Delteil ) ជាអ្នកចុះហត្ថលេខា ជាមួយកងទ័ពវៀតមិញ ជំនួសប្រទេសឡាវ និងវៀតណាម។

នៅក្នុងគណៈប្រតិភូខ្មែរយើង មាន ទេព ផន រដ្ឋមន្ត្រីក្រសួងការបរទេស ជាប្រធានផ្នែកស៊ីវិល និងញឹក ជូឡុង មេបញ្ជាការកងខេមរភូមិន្ទ ជាប្រធានផ្នែកយោធា ក្នុងនោះ ក៏មានឈ្មោះសម សារី ជាសមាជិកម្នាក់ដែរ ប៉ុន្តែឈ្មោះនេះមិនមែនជួយជាតិតែម្នាក់ឯងទេ គឺមានវីរជនឯទៀតជាច្រើន គេខិតខំធ្វើការដូចខ្លួនដែរ។

នៅក្នុងសន្និសីទក្រុងហ្សឺណែវ សម សារី មានឈ្មោះល្បីជាងគេ គឺដោយសារមានកាសែតអាមេរិកាំង ជួយឃោសនាលើកតម្កើង ព្រោះពួកអាមេរិក មានការពេញចិត្តខ្លាំងណាស់ចំពោះសម សារី ព្រោះហ៊ានដេរប្រមាថកាតទានទាំងទទឹងទិស ទៅលើ ម៉ូឡូតូវ ( Molotov ) ជាមេដឹកនាំគណៈប្រតិភូសហភាពសូវៀត។




**សម សារី និង ស៊ីន សាន ពេលសម្តេចសីហនុ បញ្ជូនឱ្យទៅតវ៉ាទាមទារឯករាជ្យពីបារាំង នៅសន្និសីទក្រុងហ្សឺណែវ** (រូបថត Getty)

សម្តេចសីហនុ បានសរសេរបញ្ជាក់ថា សម សារី ត្រូវជើងជាមួយពួកលោកសេរី តាំងពីពេលបានទៅចូលប្រជុំនៅសន្និសីទក្រុងហ្សឺណែវ នោះមក ចាត់ទុកខ្លួនឯងថា ជារដ្ឋបុរសមានសមត្ថភាពខ្លាំងជាងគេ នៅក្នុងប្រទេសកម្ពុជា ទៀតផង។

ពេលនោះ ស៊ឹង ង៉ុកថាញ់ ពុំទាន់ចូលដៃចូលជើងជាមួយពួកលោកសេរី បានចាត់ឲ្យបក្ខពួកខ្លួនម្នាក់ ឈ្មោះអៀ ស៊ីចូវ ធ្វើដំណើរទៅទាក់ទងមេដឹកនាំចិនប្រជាមានិត ដើម្បីសុំឱ្យជួយខ្លួន ក្នុងការប្រឆាំងនឹងសីហនុ។ តែរដ្ឋាភិបាលចិន មិនព្រមជួយទេ គឺចិន បែរជាមកសុំចងស្ពានមេត្រីភាពជាមួយរាជរដ្ឋាភិបាលរបស់ព្រះអង្គទៅវិញ។ រឿងនេះ សម្តេចប៉ែន នុត ជ្រាបច្បាស់ជាងគេ។

ពេលនោះ ស៊ឹង ង៉ុកថាញ់ អស់ផ្លូវដើរ ក៏បានទៅទាក់ទងមេដឹកនាំក្រុងបាងកក ដើម្បីលក់ខ្លួនឱ្យពួកសេរី វិញ។

# ១២៣
# សម សារី និងសឹង ង៉ុកថាញ់ ថា
# នយោបាយអព្យាក្រឹត ជានយោបាយទាល់ច្រក



**សម្តេចសីហនុ**

នៅក្នុងទស្សនាវដ្តីអ្នកជាតិនិយម ដដែលនោះ សម្តេចសីហនុ បានសរសេរបន្តថា ឥឡូវ សឹង ង៉ុកថាញ់ និងសម សារី បានរួមគ្នាកាន់ជើងលោកសេរី ដើម្បីជាន់ពន្លិចព្រះអង្គ ដោយសម សារី បានលើកឡើងថា កាលនៅក្នុងសន្និសីទក្រុងហ្សឺណែវ រូបគេបានបណ្តេញពួកកុម្មុយនិស្តឲ្យចេញពីប្រទេសកម្ពុជា អស់ហើយ តែ សីហនុ បែរជាបញ្ចូលពួកកុម្មុយនិស្តឱ្យចូលមកជិះជាន់ប្រទេសជាតិមាតុភូមិបន្តទៀតទៅវិញ។

ព្រះអង្គសូមរម្លឹកថា នៅក្នុងសន្និសីទក្រុងហ្សឺណែវ គណៈប្រតិភូរាជរដ្ឋាភិបាលយើងទេ ជាអ្នកស្នើសុំឲ្យកងទ័ពវៀតមិញ ចាកចេញពីទឹកដីយើងជាដាច់ខាត។ រហូតដល់សព្វថ្ងៃនេះ កងទ័ពវៀតមិញ ក៏ពុំបានវិលចូលមកក្នុងប្រទេសជាតិយើងវិញដែរ ហើយពុំអាចនឹងលបលួចចូលមកដោយសម្ងាត់បានដែរ ព្រោះនៅក្នុងប្រទេសយើងមានគណៈកម្មការត្រួតពិនិត្យអន្តរជាតិ(ICC) ដែលសន្និសីទក្រុងហ្សឺណែវ ឲ្យមកឃ្លាំមើល កុំឲ្យមានការលួចបញ្ចូល

កងទ័ព និងគ្រឿងសស្ត្រាវុធមកពីបរទេស ដូចមុនទៀត។ សម សារី និងសឺង ង៉ុកថាញ់ ចោទព្រះអង្គដូចពួកកាសែតខាងលោកសេរីបានចោទព្រះអង្គដែរថា ព្រះអង្គបានបង្កើតឲ្យមានសកម្មភាពកុម្មុយនិស្តឡើងវិញ ដោយព្រះអង្គបានបញ្ចូលពួកអ្នកការទូត, ពួកកាសែត, ពួកបច្ចេកទេសរុស្ស៊ី និងចិន មកក្នុងប្រទេសកម្ពុជា យ៉ាងច្រើនសន្ធឹកសន្ធាប់។

សម្តេចសីហនុ បានបញ្ជាក់ថា ជនរួមជាតិរបស់យើង បានជ្រាបស្រាប់ហើយថា សន្និសីទក្រុងហ្សឺណែវ បានជួយដោះស្រាយតែបញ្ហាដកកងទ័ពវៀតមិញ ឱ្យចេញពីប្រទេសជាតិយើងប៉ុណ្ណោះ។ រីឯបញ្ហាពួកខ្មែរឥស្សរៈឱ្យឈ្មោះខ្លួនឯងថា ពួកប្រជាជន ហើយយួនកុម្មុយនិស្តបានអប់រំពួកគេឱ្យទៅជាជនកុម្មុយនិស្តក្បត់ជាតិឯង រាប់ពាន់នាក់នោះ សន្និសីទក្រុងហ្សឺណែវ បានសម្រេចឲ្យរាជរដ្ឋាភិបាលយើង លើកទោសពៃរ៍ដល់ពួកគេទាំងអស់។

មិនតែប៉ុណ្ណោះ សន្និសីទនេះបានសម្រេចឲ្យរាជរដ្ឋាភិបាលយើង ទទួលយកពួកប្រជាជនទាំងអស់នោះ មករួមរស់ក្នុងសង្គមជាតិវិញ ដោយត្រូវផ្តល់សិទ្ធិឱ្យពួកគេរស់នៅជាពលរដ្ឋពេញលក្ខណៈច្បាប់ ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះ ពួកកុម្មុយនិស្តខ្មែរនេះ ក៏មានសេរីភាពក្នុងការបន្តធ្វើសកម្មភាពបម្រើឱ្យវៀតមិញពេញទីតាំងពីឆ្នាំ១៩៥៤មក ហើយរាជរដ្ឋាភិបាលយើងត្រូវតែគោរពតាម ដោយមិនហ៊ានបំពានទៅលើកិច្ចព្រមព្រៀង នៅក្រុងហ្សឺណែវ ដូចរដ្ឋាភិបាលរបស់ប្រទេសខ្លះ នោះទេ។

ដោយសារកិច្ចព្រមព្រៀង នៅក្រុងហ្សឺណែវនេះ ពួកខ្មែរឥស្សរៈឱ្យឈ្មោះខ្លួនឯងថា ពួកប្រជាជន ជាកូនជឹងរបស់ពួកវៀតមិញ និងជាទាសកររបស់ពួកកុម្មុយនិស្តអន្តរជាតិ ក៏មានសិទ្ធិឃោសនា, មានសិទ្ធិសរសេរកាសែត និងមានសិទ្ធិបើកការប្រជុំ ដើម្បីជួយចៅហ្វាយ និងលទ្ធិកុម្មុយនិស្តរបស់គេ បានដោយសេរី ហើយបើពួកនេះមិនប្រឆាំងរបបរាជានិយម ដោយចេញមុខទេ រាជរដ្ឋាភិបាលយើង ក៏គ្មានសិទ្ធិអំណាចអ្វី ទៅបង្ក្រាបពួកគេបានដែរ។ សិទ្ធិអំណាចយើងក្នុងការទប់ទល់ ជាមួយពួក គេមានតែម្យ៉ាង គឺបើគេធ្វើសកម្មភាពប្រឆាំងនឹងយើង តាមរយៈទំព័រកាសែត ឬការថ្លែងសុន្ទរកថាណាមួយ យើងត្រូវតែឆ្លើយតបទៅវិញ តាមរយៈទំព័រកាសែត ឬតាមការថ្លែងសុន្ទរកថា ដូចដែលព្រះអង្គបានធ្វើ នាពេលសព្វថ្ងៃ

នេះស្រាប់។ សម្តេចសីហនុ បានវាយតម្លៃថា បើសម សារី និងសឺង ង៉ុកថាញ់ បានឡើងធ្វើជាមេដឹកនាំកំពូលរបស់ប្រទេស យើងជឿថា ពួកគេអាចបង្ក្រាបពួកកុម្មុយនិស្តបានដោយជោគជ័យ ព្រោះពួកគេអាចយកទ្រឹស្តីរបស់ចៅហ្វាយគេ គឺទ្រឹស្តីកុម្មុយនិស្ត មកប្រើ។

បើយើងក្រឡេកមើលទៅបណ្តាប្រទេសមួយចំនួន នៅលើពិភពលោក យើងអាចឃើញជាក់ស្តែងថា ស្ថានភាពរបស់ប្រទេសទាំងនោះ មានការដុនដាបតោកយ៉ាក ជាងប្រទេសយើងឆ្ងាយខ្លាំងណាស់។

សព្វថ្ងៃ ប្រទេសយើងមានសុខសន្តិភាពត្រជាក់ត្រជុំ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍នេះក៏ដោយសារយើងបានប្រកាន់គោលនយោបាយអព្យាក្រឹត និងគោលការណ៍បញ្ចសិលា ដ៏បរិសុទ្ធ គ្មានលម្អៀង ហើយបានយកធម៌សាមគ្គីមកប្រើផងដែរ។ តែប្រទេសយើងមានការលំបាកខ្លះ គឺដោយសារតែពួកសម សារី និងសឺង ង៉ុកថាញ់ បានប្រាក់កាសពីចៅហ្វាយរបស់ពួកវា ឱ្យមកសម្រាប់ធ្វើបាបជាតិ ធ្វើបាបប្រទេស ធ្វើបាបរាជបល្ល័ង្ក ធ្វើគតរាជវង្សនិងធ្វើគតព្រះអង្គផ្ទាល់ ព្រោះតែពួកវាច្រណែនឈ្នានីស ព្រោះតែប្រជារាស្ត្រខ្មែរពុំសុខចិត្តឲ្យពួកវាមកឡើងសោយរាជ្យ មកដឹកនាំរាជរដ្ឋាភិបាល ដូចព្រះអង្គនោះឯង។

ដោយសារការប្រកាន់យកអព្យាក្រឹតភាពដ៏បរិសុទ្ធនេះ ទើបប្រទេសយើងបានសុខ-សប្បាយជាងប្រទេសជិតខាងយើង តែសម សារី និងសឺង ង៉ុកថាញ់ ហ៊ានចោទប្រកាន់ថានយោបាយអព្យាក្រឹតភាពរបស់សីហនុ នាំឲ្យកម្ពុជាទទួលទុក្ខវេទនា ព្រោះត្រូវលោករលួយខ្លួន នៅក្នុងភ្នក់ភ្លើងពីរ គឺក្នុងភ្នក់ភ្លើងរបស់លោកសេរីមួយ និងក្នុងភ្នក់ភ្លើងរបស់លោកកុម្មុយ-និស្តមួយ។

បើតាមព្រះអង្គឈ្វេងយល់ ទ្រឹស្តីនយោបាយរបស់សម សារី និងសឺង ង៉ុកថាញ់ ដែលឲ្យឈ្មោះថា សម្មាទិដ្ឋិ ស្អីគេនោះ មានន័យថា ប្រទេសជាតិយើងត្រូវបោះបង់ចោលអព្យាក្រឹតភាពលុបចោល ហើយចូលទៅនៅខាងលោកសេរី ឱ្យស៊ប់ទៅ ដើម្បីកម្ទាត់ពួកកុម្មុយនិស្តចោល ហើយបើត្រូវប្រយុទ្ធជាមួយពួកកុម្មុយនិស្ត គឺយើងរងគ្រោះ ដោយសារតែគ្រាប់បែកបរមាណូរបស់កុម្មុយនិស្តមួយប៉ុណ្ណោះ តែយើងអាចចៀសផុតពីការរងគ្រោះ ដោយសារ

តែគ្រាប់បរមាណូរបស់លោកសេរី។

សម្តេចសីហនុ បានធ្វើការបកស្រាយទៅវិញថា ប្រជារាស្ត្របានបោះឆ្នោតជាឯកច្ឆន្ទ ដើម្បីឱ្យព្រះអង្គដឹកនាំប្រទេសនេះ ព្រះអង្គមិនអាចយកប្រទេសជាតិ ទៅឲ្យរងគ្រោះដោយសារ តែគ្រាប់បែកបរមាណូរបស់ប្លុក ឬបក្ខពួកណាមួយនោះបានឡើយ គឺព្រះអង្គត្រូវតែប្រកាន់ យកគោលនយោបាយអព្យាក្រឹត មកដឹកនាំប្រទេស ដើម្បីចៀសវាងឱ្យផុតពីការរងគ្រោះ ដោយសារតែគ្រាប់បែកបរមាណូ ទាំងរបស់ពួកកុម្មុយនិស្ត ទាំងគ្រាប់បែកបរមាណូរបស់លោក សេរី។ តែសម សារី និងសឺង ង៉ុកថាញ់ បែរជាហ៊ានប្រមាថព្រះអង្គថា នយោបាយអព្យាក្រឹត នេះ ជានយោបាយទាល់ច្រក ឬជានយោបាយអត្តឃាតទៅវិញ។

ព្រះអង្គយល់ថា ដោយសារខ្មែរយើងងាកទៅខាងលិច ក៏ឃើញយក្ស ឃើញគ្រាប់បែក បរមាណូរបស់លោកសេរី ហើយងាកទៅខាងកើត ក៏ឃើញយក្ស ឃើញបរមាណូរបស់ពួក កុម្មុយនិស្ត កាន់តែគួរឲ្យខ្លាចទៅទៀត ដូច្នេះហើយ ទើបព្រះអង្គមិនហ៊ានងាកទៅខាងកើត ឬងាកទៅខាងលិច គឺមានតែសុំនៅផ្លូវកណ្តាល គឺផ្លូវអព្យាក្រឹត ហើយការសុំនៅតែក្នុងផ្លូវ កណ្តាល ផ្លូវអព្យាក្រឹតនេះ គឺពុំមែនជានយោបាយទាល់ច្រក ឬជានយោបាយអត្តឃាតកម្ម ដូចសម សារី និងសឺង ង៉ុកថាញ់ បានប្រមាថនោះទេ តែជាផ្លូវនាំមកនូវទំនាក់ទំនងមិត្តភាព រាប់អាន ជាមួយពួកខាងលិច និងពួកខាងកើត ស្មើគ្នា ហើយក៏មិនចូលដៃចូលជើងជាមួយ ម្ខាង ដើម្បីទៅរករឿង ឬទៅប្រឆាំងជាមួយម្ខាងទៀត នោះដែរ។

# ១២៤
# សម្តេចសីហនុ ផ្តាំទៅសម សារី ថា កុំខ្លាចកុម្មុយនិស្តជាងព្រះអង្គដែលជាស្តេច




**សម្តេចសីហនុ និងប្រធានម៉ៅ** (រូបថត Getty images)

សម សារី និងសឺង ង៉ុកថាញ់ បានលើកឡើងថា ការដែលសីហនុ ភ្ជាប់ទំនាក់ទំនងការទូតជាមួយវៀតណាមខាងត្បូង និងថៃ គឺជាភស្តុតាងបញ្ជាក់យ៉ាងច្បាស់ថា សីហនុ បានដឹងខ្លួន និងបានសារភាពថា ការប្រកាន់យកនយោបាយអព្យាក្រឹតនេះ ជាកំហុសដ៏ធ្ងន់ក្រៃលែងមួយ ដូច្នេះសីហនុ ចង់ផ្លាស់ប្តូរនយោបាយនេះចោល ទើបព្យាយាមអែបអម

ទាក់ទងជាមួយថៃ និងវៀតណាមខាងត្បូង វិញ។

សម សារី និងសឺង ង៉ុកថាញ់ លើកឡើងបែបនេះ គឺជាការថោកទាបបំផុត ដោយពួកគេសុខចិត្តមួលបង្កាច់បង្ខូចកិត្តិយសជាតិឯង ដើម្បីឃោសនាឲ្យបរទេស ដែលជាចៅហ្វាយព្រោះជនរួមជាតិទាំងអស់ ក៏បានជ្រាបច្បាស់ទៅហើយថា ការដែលប្រទេសយើងមានជម្លោះជាមួយប្រទេសថៃ និងយួនខាងត្បូង នោះ ពុំមែនជាកំហុសរបស់រាជរដ្ឋា ភិបាលយើងទេហើយព្រះអង្គក៏ពុំត្រូវឱនក្បាលជាមួយប្រទេសណាមួយដែរ តែដូចព្រះអង្គបានប្រកាសក្នុងពេលប្រទេសកំពុងមានជម្លោះជាមួយប្រទេសថៃ និងយួនខាងត្បូង នោះហើយថា ប្រទេសយើងជាប្រទេសកាន់អព្យាក្រឹត ហើយជាប្រទេសតូច និងស្រលាញ់សុខសន្តិភាព មានបំណងតែម្យ៉ាង គឺចង់ធ្វើមិត្តជាមួយពួកគេ ពុំមែនចង់ធ្វើសត្រូវនោះទេ យើងសុំតែកុំឱ្យគេមករករឿងនិងជ្រៀតជ្រែកដល់កិច្ចការផ្ទៃរបស់យើងបានហើយ។

សម្តេចសីហនុ បានសរសេរបន្តថា សម សារី និងសឺង ង៉ុកថាញ់ ពុំបានធ្វើអត្ថាធិប្បាយពន្យល់ពីខ្លឹមសារនៃនយោបាយសម្មាទិដ្ឋិរបស់ខ្លួនទេ នៅក្នុងខិតប័ណ្ណរបស់ពួកគេនោះទេ។ តែ បើតាមការឈ្វេងយល់របស់ព្រះអង្គ នយោបាយសម្មាទិដ្ឋិរបស់សម សារី និងសឺង ង៉ុកថាញ់នេះ គឺតម្រូវឱ្យយើងលះបង់ចោលនូវចំណងមិត្តភាពជាមួយប្រទេសសង្គមនិយមរួមមាន សហភាពសូវៀត និងចិនប្រជាមានិត ជាដើម ព្រមទាំងឈប់ទទួលជំនួយរបស់ប្រទេសមហាអំណាចទាំងពីរនេះ ផងដែរ។

ចំណែកព្រះរាជាណាចក្រឡាវ ជាបងប្អូននៃព្រះរាជាណាចក្រខ្មែរយើង បានប្រកាន់យកនយោបាយសម្មាទិដ្ឋិ ដូចគំនិតរបស់សម សារី និងសឺង ង៉ុកថាញ់ នោះ គឺប្រទេសមួយនេះមិនមានទំនាក់ទំនងការទូតជាមួយប្រទេសសង្គមនិយម ដូចជា សហភាពសូវៀត និងចិនប្រជាមានិត ហើយមិនព្រមទទួលជំនួយសេដ្ឋកិច្ចរបស់ប្រទេសមហាអំណាចទាំងពីរនេះទៀតផង។

លើសពីនេះទៅទៀត ព្រះរាជាណាចក្រឡាវ បានស្នើសុំឱ្យបញ្ចប់បេសកកម្មរបស់គណៈកម្មការអន្តរជាតិ (ICC) មកពីប្រទេសប៉ូឡូញ ជាប្រទេសកុម្មុយនិស្ត ឱ្យចាកចេញពី

ទឹកដីរបស់គេទៀតផង ហើយខិតខំបោសសម្អាតពួកកុម្មុយនិស្តយ៉ាងណាក្តី ក៏ប្រទេសឡាវ មិនអាចចៀសផុតពីការបែកបាក់សាមគ្គីជាតិ និងមិនអាចចៀសផុតពីសង្គ្រាមបង្ហូរឈាមគ្នា ឯងបានដែរ ហើយរហូតដល់សព្វថ្ងៃនេះ អង្គការសេអាតូ(SEATO)ក្តី ឬអង្គការសហ-ប្រជាជាតិក្តី ពុំទាន់ដឹងថា ត្រូវជួយសង្គ្រោះប្រទេសឡាវ យ៉ាងដូចម្តេចផង?។

រាជរដ្ឋាភិបាលឡាវ បានស្នើសុំជាផ្លូវការឲ្យរាជរដ្ឋាភិបាលខ្មែរយើង ជួយការពារគោលជំហររបស់ខ្លួន ហើយរាជរដ្ឋាភិបាលខ្មែរយើង ក៏រកមធ្យោបាយដើម្បីជួយប្រទេសជាបងប្អូនមួយនេះដែរ តែករណីនេះ មានភាពលំបាកពន់ពេកណាស់ ព្រោះជំងឺនេះ អាចព្យាបាលឱ្យជាសះស្បើយបាន លុះត្រាតែរកឫសគល់(បុព្វហេតុ)វា ឲ្យឃើញច្បាស់លាស់សិន គឺពុំមែនគ្រាន់តែយកថ្នាំកងទ័ព និងអាវុធមកដាក់ ក៏ជាសះស្បើយបាននោះទេ។

ដោយសារតែ សម សារី និងសឺង ង៉ុកថាញ់ លែងមានចិត្តគំនិតជាខ្មែរហើយនោះ កាលណា ប្រទេសជិតខាងយើងមានវិបត្តិនយោបាយអ្វីមួយ ពួកគេស្រែកតាមវិទ្យុរបស់ពួកគេភ្លាមថា នេះជាកំហុសរបស់រាជរដ្ឋាភិបាលខ្មែរ ទៅវិញ គឺពួកគេកាន់ជើងយួន និងថៃ ពេញទី ដូចមានភស្តុតាងក្នុងខិតប័ណ្ណ ដែលរាជការយើងចាប់បានស្រាប់។ ពេលនេះ ព្រះរាជា-ណាចក្រឡាវ កំពុងរងគ្រោះ ដោយសារមានសង្គ្រាមឆាបឆេះពេញបន្ទុក យើងសូមសួរទៅ សម សារី និងសឺង ង៉ុកថាញ់ វិញថា តើនេះ មកពីព្រះរាជាណាចក្រឡាវ មានទំនាក់ទំនងមិត្តភាពជាមួយប្រទេសជាមហាអំណាចកុម្មុយនិស្ត និងទទួលជំនួយពីប្រទេសជាមហាអំណាចនេះ ដូចព្រះរាជាណាចក្រកម្ពុជា ដែរឬទេ?។

ការពិត ការផ្សារទំនាក់ទំនងការទូតជាមួយប្រទេសកុម្មុយនិស្ត វាមិនមែនមានតែប្រទេសកម្ពុជា ប្រកាន់យកគោលនយោបាយអព្យាក្រឹតនោះទេ សូម្បីតែប្រទេសលោកសេរី និងប្រទេសជាសមាជិកអង្គការសេអាតូ(SEATO) ក៏គេផ្សារទំនាក់ទំនងការទូតជាមួយប្រទេសកុម្មុយនិស្ត ដែរ ឧទាហរណ៍ប្រទេសថៃ ជាសមាជិកអង្គការសេអាតូ ផង តែគេបានផ្សារទំនាក់ទំនងការទូតជាមួយសហភាពសូវៀត ដោយបានបង្កើតឱ្យមានស្ថានឯកអគ្គរដ្ឋទូតមួយយ៉ាងធំ នៅរាជធានីបាងកក ។

ចំណែកសហរដ្ឋអាមេរិក ក៏បានទទួលស្គាល់ជាផ្លូវការ និងមានទំនាក់ទំនងជាអចិន្ត្រៃយ៍ជាមួយប្រទេសកុម្មុយនិស្ត ដូចជា សហភាពសូវៀត និងប្រទេសប៉ូឡូញ ដែលថ្មីៗនេះ អនុប្រធានាធិបតី និចសុន ទើបនឹងទៅបំពេញទស្សនកិច្ច ដើម្បីរឹតចំណងមិត្តភាព ផងដែរ។ ជាមួយគ្នានេះ ប្រទេសជាសមាជិកអង្គការសេអាតូ(SEATO)ដូចជា ប្រទេសប៉ាគីស្ថាន មិនត្រឹមតែបានផ្សារទំនាក់ទំនងការទូតជាមួយសហភាពសូវៀត ប៉ុណ្ណោះទេ គឺថែមទាំងបានផ្សារទំនាក់ទំនងការទូតយ៉ាងជិតស្និទ្ធបំផុត ជាមួយចិនប្រជាមានិត ជាជិតខាងគ្នានោះ ហេតុអ្វី សម សារី និងសឹង ង៉ុកថាញ់ មិនហ៊ានរិះគន់ទិតៀនប្រទេសជាសមាជិកអង្គការសេអាតូ (SEATO) នេះផង ម៉េចក៏ហ៊ានប្រឆាំងតែជាមួយចលនាសង្គមរាស្ត្រនិយម ពិសេសគឺប្រឆាំងនឹងជាតិឯង?។ ជនរួមជាតិបានជ្រាបគ្រប់គ្នាស្រាប់ហើយថា ចលនាសង្គមរាស្ត្រនិយមប្រកាន់យកនយោបាយអព្យាក្រឹត និងគោលការណ៍បញ្ចសិលា គឺពុំមែនជាឧត្តមគតិរបស់ព្រះអង្គតែម្នាក់ឯងនោះទេ គឺកើតឡើងពីឧត្តមគតិរបស់ព្រះសង្ឃ របស់ទាហាន របស់ប្រជារាស្ត្រខ្មែរ ក្មេងចាស់ប្រុសស្រី ពោលគឺកើតឡើងពីឧត្តមគតិរបស់ជាតិយើងទាំងមូល។

ចំណែក បញ្ហាជំនួយប្រទេសសង្គមនិយម បានផ្តល់មកឱ្យ គឺជាតិយើងទាំងមូលចង់បាន ហើយយើងទទួលយកដោយអំណរ និងកតញ្ញូ ដូចការទទួលជំនួយពីប្រទេសលោកសេរី មានសហរដ្ឋអាមេរិក និងបារាំង ដែរ។

ប្រទេសជាតិយើងនៅខ្សត់ខ្សោយ បើឱ្យជំនួយជាផ្ទះពេទ្យ៥០០គ្រែ អាចធ្វើឱ្យជាតិយើងមានសុខភាពល្អប្រសើរជាងមុន ហើយបើគេឲ្យជំនួយជារោងចក្រយ៉ាងធំសម្បើម អាចធ្វើឱ្យសេដ្ឋកិច្ចជាតិយើងលូតលាស់ទាន់សម័យ តើមានច្បាប់អ្វី ដែលហាមឃាត់ព្រះអង្គមិនឱ្យទទួលយកនោះ? ហើយហេតុអ្វី បានជាសម សារី និងសឹង ង៉ុកថាញ់ ចេះតែរិះគន់ថា ការទទួលជំនួយពីប្រទេសសង្គមនិយម ដូចនាំពួកកុម្មុយនិស្តមកឱ្យនៅក្នុងប្រទេសកាន់តែមានច្រើនថែមទៀត? ហើយថា ការទទួលជំនួយពីប្រទេសកុម្មុយនិស្ត ធ្វើឲ្យប្រទេសជាតិមានអំពើពុករលួយកាន់តែច្រើន ទៅវិញ?។

ព្រះអង្គបានផ្តាំទៅសម សារី និងសឹង ង៉ុកថាញ់ ថា មិនគួរភ័យខ្លាចចំពោះពួកកុម្មុយ

និស្តនេះ ជាងព្រះអង្គជាពូជពង្សមហាក្សត្រនោះទេ ព្រោះនរណាក៏ដឹងថា ពួកកុម្មុយនិស្ត បានចាត់ទុកពូជពង្សមហាក្សត្រជាសត្រូវទី១ របស់ពួកគេ ហើយដំបូងបង្អស់ ពួកគេត្រូវតែ បំបាត់ស្តេចចោល។ ទ្រឹស្តីនយោបាយរបស់ពួកកុម្មុយនិស្តនេះ ព្រះអង្គដឹងច្បាស់ណាស់ មិនចាំបាច់កាសែតពួកលោកសេរី ឬសម សារី និងសឺង ង៉ុកថាញ់ មកប្រដៅព្រះអង្គទេ។ តែមូលហេតុ ព្រះអង្គសុខចិត្តទាក់ទងមហាអំណាចកុម្មុយនិស្តនេះ គឺដោយសារព្រះអង្គ គិតពីឧត្តមប្រយោជន៍របស់ជាតិ និងប្រជារាស្ត្រជាជនរួមជាតិរបស់ព្រះអង្គ តែប៉ុណ្ណោះ។

ដោយឡែកបញ្ហាអនាគត បញ្ហាជីវិត បញ្ហាបុណ្យស័ក្តិរបស់ព្រះអង្គផ្ទាល់ ព្រះអង្គពុំ រវល់នឹកគិតដល់ទេ ព្រោះព្រះអង្គពុំមែនជាមនុស្សអត់ពូជ ដូចសម សារី និងសឺង ង៉ុកថាញ់ មិនទាន់ស្គាល់រសជាតិបុណ្យស័ក្តិ ជាមេដឹកនាំកំពូលរបស់ជាតិម្តងណា នោះឡើយ។ ដូច្នេះ ដើម្បីតបស្នងសងគុណប្រជាជាតិ ប្រជារាស្ត្រខ្មែរធ្លាប់តែស្រលាញ់ និងជឿទុកចិត្តព្រះអង្គ ព្រមទាំងជឿទុកចិត្តព្រះមហាក្សត្រ ជាព្រះបិតាមាតារបស់ព្រះអង្គ ផងដែរនោះ ព្រះអង្គត្រូវ តែបំពេញពលីកម្ម ដើម្បីរកជំនួយឲ្យជាតិ រកមិត្តភាព រកសេចក្តីសុខ រកការរីកចម្រើនឱ្យ ជាតិបន្តទៀត ហើយប្រសិនបើពិភពលោកទាំងមូលប្រែក្លាយជាមានរឿងអសន្តិសុខវឹកវរ យ៉ាងណានោះ ក៏ព្រះអង្គត្រូវតែធ្វើយ៉ាងណា ដើម្បីឱ្យប្រទេសជាតិបានសុខ ។ តែបើចៀស មិនផុតទេ ព្រះអង្គធ្វើយ៉ាងណា កាត់បន្ថយរឿងអសន្តិសុខវឹកវរនោះឱ្យនៅតូចជាងប្រទេស គេផ្សេងៗទៀតដែរ ពោលគឺព្រះអង្គពុំមែនដាច់ចិត្ត ធ្វើដូចសម សារី និងសឺង ង៉ុកថាញ់ នៅពេលប្រទេសជាតិមាតុភូមិ កំពុងមានសន្តិភាពសុខសប្បាយ និងកំពុងរួបរួមមូលគ្នា កសាងជាតិ កើតជាផ្លែផ្កាទៅហើយ ពួកគេទាំងពីរនាក់ បែរជាបង្កឱ្យមានអសន្តិសុខដល់ ប្រទេសជាតិខ្លួនឯង ដើម្បីបំពេញចិត្តពួកបរទេស ឱ្យជួយខ្លួនឱ្យបានឡើងអង្គុយលើរាជ បល្ល័ង្ក ជំនួសស្តេចរបស់ខ្លួន ទៅវិញនោះទេ។

សម សារី និងសឺង ង៉ុកថាញ់ ប្រឹងឃោសនាថា ព្រះអង្គជាមនុស្សល្ងង់ ងងឹតងងុល ខ្វះបទពិសោធ បានជាមិនស្គាល់គ្រោះថ្នាក់ កើតឡើងដោយសារពួកកុម្មុយនិស្ត ហើយថា មានតែពួកបរទេសជាចៅហ្វាយពួកគេទេ ទើបមានបទពិសោធគ្រប់គ្រាន់ពីបញ្ហាពួកកុម្មុយ

និស្ដនេះ។ តែទោះបីយ៉ាងនេះក្ដី ក៏ប្រទេសជាមហាអំណាចសេរី មិនអាចធ្វើឲ្យប្រជាជាតិតូចៗ មួយចំនួន ដែលគ្នាពឹងផ្អែកលើខ្លួន ជឿពាក្យសម្ដីនេះ បានដែរ ព្រោះថា ទោះបីប្រជាជាតិតូចៗ មួយចំនួននោះ នាំគ្នាប្រយុទ្ធប្រឆាំងនឹងពួកកុម្មុយនិស្ដប្ដូរផ្ដាច់យ៉ាងណា ក៏មិនបានសេចក្ដីសុខ ដូចប្រទេសខ្មែរយើងដែរ។ ហេតុនេះ សូមជនរួមជាតិយើងទាំងអស់មេត្តាពិចារណាផងទៅចុះ។

# ១២៥
# សម សារី ថា៖ សីហនុ ជាជនផ្តាច់ការ បំបាត់លទ្ធិប្រជាធិបតេយ្យ



សម្តេចសីហនុ ជាមួយប្រជារាស្ត្រ

ចំពោះការឃោសនារបស់សម សារី និងសឹង ង៉ុកថាញ់ ជាមួយបងប្អូនខ្មែរ នៅកម្ពុជាក្រោម ឱ្យជឿថា ៖

ទី១. សីហនុ ជាអ្នកបំបាត់លទ្ធិប្រជាធិបតេយ្យ ដើម្បីតាំងខ្លួនជាស្តេចត្រាញ់។

ទី២. សីហនុ ជាមនុស្សអយុត្តិធម៌ និងទី៣.សីហនុ ជាអ្នកប្រឆាំងនឹងសាមគ្គីភាពរបស់ជាតិ គឺបំបែកបំបាក់ខ្មែរ ឱ្យបែកបាក់ធ្វើជាសត្រូវនឹងគ្នានោះ សម្តេចសីហនុ សូមឱ្យជនរួមជាតិ ជាអ្នកអានទស្សនាវដ្តីអ្នកជាតិនិយម ធ្វើការពិចារណា និងវិនិច្ឆ័យដូចខាង ក្រោមនេះ ៖ ទី១.បើព្រះអង្គតាំងខ្លួនជាស្តេចត្រាញ់ជិះជាន់សង្កត់សង្កិនជនរួមជាតិពិតមែន ម្ល៉េះ

ព្រះសង្ឃក្តី ប្រជារាស្ត្រទូទៅក្តី ពុំអាចស៊ូទ្រាំនឹងជិះជាន់របស់ព្រះអង្គ រហូតដល់ទៅ១៨ឆ្នាំ គឺចាប់ពីឆ្នាំ១៩៤១ មកទល់នឹងឆ្នាំ១៩៥៩នេះ បានទេ។ ការពិត ជនរួមជាតិរមែងចាត់ទុកព្រះអង្គជាព្រះបិតារបស់ខ្លួន និងជាអគ្គមគ្គទេសក៍របស់មាតុប្រទេសជាតិ។ ពីឆ្នាំ១៩៤៥ មកដល់ឆ្នាំ១៩៥៤ បើពិតជាមាននឹមជិះជាន់របស់ព្រះអង្គ មែននោះ ជនរួមជាតិរបស់ព្រះអង្គមានឱកាសច្រើនណាស់ ដើម្បីរំដោះខ្លួនចេញពីនឹមជិះជាន់របស់ព្រះអង្គ ព្រោះនៅក្នុងឆ្នាំ១៩៤៥ កងទ័ពមហាអំណាចជប៉ុន បានជួយពួកសាធារណរដ្ឋនិយម សឺង ង៉ុកថាញ់ និងប៉ាច ឈឺន ឱ្យធ្វើរដ្ឋប្រហារ នៅថ្ងៃទី៩ ខែសីហា ម្តងទៅហើយ។

ក្នុងឱកាសនោះដែរ ពួកសឺង ង៉ុកថាញ់ និងប៉ាច ឈឺន បានដើរបាចខិតប័ណ្ណបំបះបំបោរប្រជារាស្ត្រយើង ឲ្យទម្លាក់ព្រះអង្គចេញពីរាជបល្ល័ង្ក តែគ្មានប្រជារាស្ត្រណាជឿតាមការបំបះបំបោររបស់ពួកគេឡើយ។ ពីឆ្នាំ១៩៤៧ ដល់ឆ្នាំ១៩៥៤ ពួកខ្មែរឥស្សរៈ និងពួកយួនវៀតមិញ បានព្យាយាមធ្វើការឃោសនាផង គំរាមកំហែងព្រះសង្ឃ និងប្រជារាស្ត្រផង កាប់សម្លាប់ប្រជារាស្ត្រស្លូតត្រង់ផង ដើម្បីឲ្យបោះបង់គំនិតរាជានិយម និងបំបះបំបោរឱ្យប្រឆាំងនឹងព្រះអង្គ តែប្រជារាស្ត្រសុខចិត្តលះបង់ជីវិត ដើម្បីការពារព្រះអង្គជាមហាក្សត្រ។ ក្រោយពេលព្រះអង្គបានសុំបារាំង ឲ្យលើកលែងទោសដល់សឺង ង៉ុកថាញ់ ឲ្យបានវិលត្រលប់មកមាតុប្រទេសវិញ ក្នុងឆ្នាំ១៩៥១ សឺង ង៉ុកថាញ់ បានធ្វើសកម្មភាពញុះញង់អស់រយៈពេល៤ឆ្នាំ ដើម្បីឱ្យប្រជាជាតិខ្មែរលុបបំបាត់ស្តេច គឺរូបព្រះអង្គនេះចោល ដោយគេចោទថាព្រះអង្គក្បត់ជាតិ ក្បត់លទ្ធិប្រជាធិបតេយ្យ។ ពេលនោះ ក៏មានកូនសិស្សមធ្យមសិក្សា និងនិស្សិត នៅប្រទេសបារាំងខ្លះ បានដើរតាមសឺង ង៉ុកថាញ់ ប្រឆាំងនឹងព្រះអង្គដែរ តែមានព្រះសង្ឃ ៩០ភាគរយ ទាហាន ១០០ភាគរយ ឥស្សរជន ៩០ភាគរយ និងប្រជារាស្ត្រ ៩០ភាគរយ បាននាំគ្នាការពារព្រះអង្គ ហើយពួកខ្មែរឥស្សរៈ ៨០ភាគរយ ក៏បានចុះចូលថ្វាយខ្លួនជាមួយព្រះអង្គ ដែរ។

ជនរួមជាតិនៅក្នុងប្រទេស ជាសាក្សីស្រាប់ អាចយល់បានដោយងាយថា សេចក្តីស្នេហារបស់ជនរួមជាតិ ៩០ភាគរយ ចំពោះព្រះអង្គនេះ ពុំអាចកើតមានបានទេ ប្រសិនបើព្រះអង្គ

គ្រប់គ្រងប្រទេស ដូចស្ដេចត្រាញ់ មែននោះ ។ មុនពេល បើកសមាជជាតិលើកទី៨ មួយឬពីរសប្ដាហ៍ វិទ្យុរបស់សម សារី និងសឺង ង៉ុកថាញ់ បានស្រែកថ្លែងការណ៍ក្ដែងៗ ឲ្យលោកសេរី មានសហរដ្ឋអាមេរិក ជាដើម កត់សម្គាល់ថា សីហនុ ជាមនុស្សតែលតោល និងមិនរឹងមាំក្នុងការកាន់អំណាចទេ ព្រោះព្រះសង្ឃមិនគាំទ្រ ដោយសារសីហនុ ជាមនុស្សជិះជាន់សង្កត់សង្កិនសាសនា និងព្រះសង្ឃ។ លុះសម្ដេចព្រះសង្ឃនាយកទាំងពីរគណៈ បានជ្រាបនូវពាក្យមួលបង្កាច់នេះ ក៏បានសរសេរលិខិតមួយ ទៅកាន់សមាជជាតិភ្លាមថា សេចក្ដីថ្លែងការណ៍របស់វិទ្យុសម សារី និងសឺង ង៉ុកថាញ់ នេះ ជាសេចក្ដីថ្លែងការណ៍ប្រកបដោយមោហៈទោសៈ មុសា ពេញទី ហើយជនទាំងពីរនាក់នេះ មិនត្រឹមតែក្បត់នឹងរាជបល្ល័ង្កទេ គឺថែមទាំងក្បត់សាសនាទៀតផង។ ចំពោះលទ្ធិប្រជាធិបតេយ្យវិញ ព្រះអង្គពុំមានគំនិតដកហូតសិទ្ធិពីប្រជារាស្ត្រជាទីស្នេហា ស្មើនឹងឪពុកម្ដាយ ឬស្មើនឹងកូនបង្កើតរបស់ព្រះអង្គ ម្ដងណាទេ។ តែអ្វីដែលព្រះអង្គមានការខ្វែងយោបល់គ្នា ជាមួយរដ្ឋសភាខ្លះៗនោះ គឺដោយសារតែព្រះអង្គមិនអាចបណ្ដោយឲ្យពួកអ្នកនយោបាយ និងតំណាងរាស្ត្រខ្លះ ក្បត់ប្រយោជន៍ធំរបស់ជាតិតែប៉ុណ្ណោះ។ ឧទាហរណ៍ ប្រជារាស្ត្រចង់បានសុខសន្តិភាព មានពួកអ្នកនយោបាយ និងតំណាងរាស្ត្រខ្លះ បែរជារករឿងហេតុបង្កបង្កើតឱ្យមានអសន្តិសុខ ដល់ប្រជារាស្ត្រទៅវិញ។

ពួកអ្នកនយោបាយ និងតំណាងរាស្ត្រខ្លះ បានចូលដៃចូលជើងជាមួយពួកឥស្សរៈក្លាហានតែខាងដុតផ្ទះរាស្ត្រ លួចប្លន់រាស្ត្រ កាប់សម្លាប់រាស្ត្រ តែមិនក្លាហាន ហ៊ានចេញមកច្បាំងនឹងបារាំងទេ គឺក្លាហានតែខាងធ្វើឱ្យប្រជារាស្ត្រ និងប្រទេសខ្លួនឯងអន្តរាយគ្រប់បែបយ៉ាង។ ដោយឡែក ចំពោះតំណាងរាស្ត្រជាសមាជិកចលនាសង្គមរាស្ត្រនិយម ជាកូនចៅបង្កើតរបស់ព្រះអង្គ វិញ បើនរណាម្នាក់ហ៊ានធ្វើឲ្យខូចផលប្រយោជន៍ប្រទេសជាតិ ព្រះអង្គមិនត្រាប្រណីឡើយ។ ហេតុនេះហើយ បានជាក្នុងឆ្នាំ១៩៥៨ ព្រះអង្គ និងរាជរដ្ឋាភិបាលមាន ស៊ឹម វ៉ា ជានាយករដ្ឋមន្ត្រី បានស្នើសុំឲ្យព្រះមហាក្សត្ររំលាយសភាអាណត្តិទី១ របស់ចលនាសង្គមរាស្ត្រនិយមចោលវិញ និងរៀបចំការបោះឆ្នោតឡើងវិញ។

ចំពោះករណី សម សារី និងសឺង ង៉ុកថាញ់ ឃោសនាវាយប្រហារថា ប្រទេសយើង




**ទិដ្ឋភាពបោះឆ្នោតឆ្នាំ១៩៥៥ នៅខេត្តកណ្តាល**

គ្មានលទ្ធិប្រជាធិបតេយ្យទេ ព្រោះសីហនុ ជាប្រធានចលនាសង្គមរាស្ត្រនិយម មិនមែនជាពូជពង្សរាស្ត្រ គឺជាពូជពង្សក្សត្រ ហើយនៅក្នុងរដ្ឋសភាមានតែគណបក្សសង្គមរាស្ត្រនិយមមួយគត់( សភាឯកបក្ស )ទៀតផង។ ករណីនេះ សម្តេចសីហនុ បានបំភ្លឺថា ព្រះអង្គជាស្តេចមែន តែប្រជារាស្ត្រជនរួមជាតិ បានបោះឆ្នោតថ្វាយព្រះអង្គឱ្យឡើងកាន់អំណាច ដឹកនាំប្រទេសពេញលក្ខណៈច្បាប់ ដោយគ្មានការបំភិតបំភ័យ គំរាមកំហែងអ្វីឡើយ ហើយគណៈកម្មាធិការត្រួតពិនិត្យអន្តរជាតិ( ICC ) ក៏ប្រកាសទទួលស្គាល់លទ្ធផលបោះឆ្នោតនោះដែរ។ មេដឹកនាំគណបក្សនយោបាយខ្មែរមុនៗ ក៏សុទ្ធតែជាពូជពង្សស្តេចដែរ ព្រោះប្រជារាស្ត្រយើងស្រលាញ់ស្តេចរបស់ជាតិខ្លួន ហើយរាជបល្ល័ង្ក និងរាជវង្សានុវង្ស ធ្លាប់តែជាម្លប់ជាទីពឹងពាក់របស់ប្រជារាស្ត្រ និងជាអ្នកការពារប្រទេសប្រជាជាតិ ផងដែរ។

កាលព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស មេដឹកនាំគណបក្សប្រជាធិបតេយ្យ ឈ្នះឆ្នោតបានឡើងកាន់តំណែងជានាយករដ្ឋមន្ត្រី ដឹកនាំប្រទេស ពេលនោះ ពុំមាននរណាម្នាក់ចោទ

ប្រកាន់ថា ប្រទេសខ្មែរយើង គ្មានប្រជាធិបតេយ្យ ដោយសារតែពូជពង្សក្សត្រ ឡើងកាន់អំណាចនោះទេ កម្មអ្វី តែព្រះអង្គ ប៉ុន្មានឆ្នាំនេះ ត្រូវពួកសឹង ង៉ុកថាញ់ តាមព្យាបាទមួលបង្កាច់ចោទប្រកាន់មិនចេះចប់។ ដូចព្រះអង្គបានប្រកាសប្រគេនព្រះសង្ឃ និងជូនទៅបងប្អូនកូនចៅជាជនរួមជាតិ ច្រើនលើកច្រើនសាហើយថា ព្រះអង្គមិនមែនចង់តោងកៅអីនាយករដ្ឋមន្ត្រីនេះទេ បើបងប្អូនកូនចៅជនរួមជាតិ មេត្តាអនុញ្ញាតឲ្យព្រះអង្គចាកចេញផុតពីជីវភាពនយោបាយ ព្រះអង្គនឹងមានសេចក្តីសប្បាយរីករាយ ដោយមិនពិបាកព្រួយពីរឿងគូសត្រូវ ដែលវាទទួលប្រាក់ពីបរទេស សម្រាប់យកមកតាមព្យាបាទធ្វើគតព្រះអង្គ និងរាជវង្សព្រះអង្គ ផងដែរ។ ប៉ុន្តែល្តឹកណា បងប្អូនកូនចៅជនរួមជាតិ នៅតែត្រូវការព្រះអង្គដើម្បីបម្រើ និងការពារប្រទេសជាតិ ទោះបីត្រូវស្លាប់ ព្រះអង្គត្រូវតែបំពេញបេសកកម្មនេះបន្តទៀត។ សម្តេចសីហនុ បានរម្លឹកថា នៅក្នុងការបោះឆ្នោតឆ្នាំ១៩៥៥ គណបក្សប្រជាធិប-តេយ្យ ទទួលបានការគាំទ្រពីប្រជារាស្ត្រខ្មែរទូទៅ បាន១៣ភាគរយដែរ តែបេក្ខជនរបស់គណបក្សនេះ ចាញ់ឆ្នោតបេក្ខជនរបស់ចលនាសង្គមរាស្ត្រនិយម គ្រប់មណ្ឌល។

ចំណែកពួកកុម្មុយនិស្តខ្មែរ ឲ្យឈ្មោះខ្លួនឯងថា ពួកប្រជាជន មានសិទ្ធិសេរីភាពចូលប្រកួតប្រជែងនៅក្នុងការបោះឆ្នោតនោះដែរ ទទួលបានសំឡេងគាំទ្រ តែ៣ភាគរយ។ លុះដល់បោះឆ្នោតឆ្នាំ១៩៥៨ ទទួលបានការគាំទ្រតែ១ភាគរយប៉ុណ្ណោះ។ តែពួកគេបានចោទប្រកាន់ថា មូលហេតុ ពួកគេចាញ់ឆ្នោតនេះ ព្រោះចលនាសង្គមរាស្ត្រនិយម មានទាហានប៉ូលិសដើរសម្លុត គំរាមកំហែងប្រជារាស្ត្រ ទៅវិញ។ យើងចង់សួរថា ការបោះឆ្នោតនៅកណ្តាលរាជធានីភ្នំពេញ មានមនុស្សច្រើនកុះករ ទាហានប៉ូលិសរបស់ចលនាសង្គមរាស្ត្រនិយម មិនអាចដើរសម្លុត គំរាមកំហែងប្រជារាស្ត្រជាអ្នកបោះឆ្នោតបាន និងមានអ្នកសង្កេតការណ៍បរទេសមកពីប្រទេសជាច្រើន ពិសេស នៅក្នុងគណៈកម្មការត្រួតពិនិត្យអន្តរជាតិ(ICC) ក៏មានតំណាងប្រទេសប៉ូឡូញ ជាប្រទេសកុម្មុយនិស្ត ចាំជួយការពារគណបក្សប្រជាជន ជាសម្ព័ន្ធមិត្តរបស់គេផងដែរនោះ តើហេតុអ្វី គណបក្សប្រជាធិបតេយ្យ និងគណបក្សប្រជាជននៅចាញ់ឆ្នោតចលនាសង្គមរាស្ត្រនិយម?។

សម សារី និងសឺង ង៉ុកថាញ់ កាលពីកាន់តំណែងជាន់ខ្ពស់នៅក្នុងប្រទេស ពួកគេប្រើអំណាចដូចស្ដេចត្រាញ់។ កាលជប៉ុនលើកបន្ទុប សឺង ង៉ុកថាញ់ ជាបរិវារឱ្យឡើងធ្វើជានាយករដ្ឋមន្ត្រី (ឆ្នាំ១៩៤៥) គេបានធ្វើរដ្ឋប្រហារ ចាប់រដ្ឋមន្ត្រីរបស់ព្រះអង្គយកទៅដាក់គុក និងបានបាញ់នង គឹមនី ឱ្យរងរបួសទៀតផង ពិសេស បានយកកាំភ្លើងមកភ្ជង់គំរាមព្រះអង្គជាព្រះមហាក្សត្រ ឱ្យប្រគល់អំណាចដល់រាជរដ្ឋាភិបាលរបស់គេឱ្យបានច្រើនជាអតិបរិមា។ លុះដល់ចៅហ្វាយជប៉ុន របស់គេត្រូវបរាជ័យ ចាញ់សង្គ្រាម ដោយសារតែចង់ឲ្យបារាំង និងសម្ព័ន្ធមិត្ត ទុកខ្លួនជានាយករដ្ឋមន្ត្រីតទៅទៀត សឺងង៉ុកថាញ់ ក៏បង្គាប់ឲ្យធ្វើប្រជាមតិតាមរយៈការបោះឆ្នោត ដោយនៅលើសន្លឹកឆ្នោតនីមួយៗ គាត់កំណត់ឱ្យពលរដ្ឋម្នាក់ៗ ជាអ្នកបោះឆ្នោតសរសេរពីមុខងារ និងអាសយដ្ឋាន គឺទីលំនៅ នៅភូមិ ឃុំ ស្រុកណា? ព្រមទាំងសរសេរឈ្មោះ និងចុះហត្ថលេខា ទៀតតផង បើនរណាហ៊ានជំទាស់ គាត់នឹងបញ្ជូនឱ្យទៅស្លាប់ក្នុងព្រៃនៅជ្រោះភ្នំពេជ្រនិល ។

# ១២៦
# សម្តេចសីហនុ មានបន្ទូលពីរឿងអាស្រូវរបស់សម សារី



**សម្តេចសីហនុ**

អត្ថបទរបស់សម្តេចសីហនុ ចុះផ្សាយនៅក្នុងទស្សនាវដ្តីអ្នកជាតិនិយម បានបន្តថា ចំណែកសម សារី ព្រះអង្គមិនបាច់និយាយវែងឆ្ងាយទេ មនុស្សនេះ ពេលបានធ្វើធំ រួមទាំងប្រពន្ធផង ចូលចិត្តជិះជាន់ធ្វើបាបជេរប្រមាថកាតទានអ្នកតូចតាចយ៉ាងណាខ្លះ អស់លោកអ្នកជារាជការ ប្រាកដជាជ្រាបស្រាប់ហើយ។ អ្នករងគ្រោះដោយអំពើអយុត្តិធម៌ និងអំពើកំណាចឃោរឃៅរបស់សម សារី មានច្រើនរាប់មិនអស់ទេ ហើយក៏មានសាក្សីច្រើនណាស់ធ្លាប់និយាយគ្រប់ៗគ្នាថា សម សារី និងប្រពន្ធនេះ តែងតែធ្វើបាបអ្នកតូចតាចឃោរឃៅជាងស្តេចកាចសាហាវជាទីបំផុតទៅទៀត ហើយព្រះអង្គ ក៏មិនដែលដឹងថា មានស្តេចអង្គណាមួយ ប្រើអំណាចផ្តាច់ការសាហាវឃោរឃៅ ដូចជនអត់ពូជ លុបចោលជាតិវច្ឆានសុទ្ធ-សាជម្នាក់នេះ ផងដែរ។

ជាមួយគ្នានេះ សូម្បីតែក្មេងស្រីៗជាសិស្សវិទ្យាល័យ ឬសិស្សអនុវិទ្យាល័យ ក៏ពុំទាន់ភ្លេចនូវពាក្យសម្តីចម្អេះចំអាស និងការវាយធ្វើបាបរបស់ប្រពន្ធសម សារី ដែរ ខណៈសូម្បីព្រះមហាក្សត្រិយានី ក៏ពុំដែលហ៊ានប៉ះពាល់ប្រជារាស្ត្រជាកូនចៅ យ៉ាងនេះដែរ។ ដូច្នេះព្រះអង្គសុំឱ្យប្រជារាស្ត្រជាកូនចៅ ជួយរកយុត្តិធម៌ឱ្យព្រះអង្គផងថា តើព្រះអង្គ ឬសម សារី និងសឺង ង៉ុកថាញ់ ជាអ្នកក្បត់លទ្ធិប្រជាធិបតេយ្យនោះ?។ម្យ៉ាងទៀត អ្វីដែលធ្វើឲ្យព្រះអង្គហួសចិត្តនោះ គឺសម សារី និងសឺង ង៉ុកថាញ់ ហ៊ានរិះគន់ថា លទ្ធិប្រជាធិបតេយ្យជាតិយើងថា មិនល្អផូរផង់ ដូចលទ្ធិប្រជាធិបតេយ្យលោកសេរី ដែលពួកគេជាខ្ញុំកញ្ជះនោះទេ។ ជាការពិតហើយ សហរដ្ឋអាមេរិក និងចក្រភពអង់គ្លេស ជាប្រទេសកាន់លទ្ធិប្រជាធិបតេយ្យ តែប្រធានាធិបតីអាមេរិក មានអំណាចច្រើនជាងព្រះមហាក្សត្រខ្មែរយើង ទ្វេមួយជាដប់ ហើយបើទោះបី សម សារី និងសឺង ង៉ុកថាញ់ ពុំមែនរស់នៅក្នុងមហាប្រទេសមួយនេះ ក៏ពិតមែន ក៏ពួកគេអាចដឹងច្បាស់ថា មានប្រទេសសេរីច្រើនណាស់ ដែលប្រធានាធិបតី ឬរដ្ឋាភិបាល មិនបានឡើងអំណាច ដោយប្រជារាស្ត្របោះឆ្នោតឱ្យនោះ គឺច្រើនតែឡើងកាន់អំណាចដោយសារការធ្វើរដ្ឋប្រហារ និងដោយសារមានកម្លាំងបរទេសជួយធ្វើអន្តរាគមន៍ ឬដោយសារការបំបិទសិទ្ធិ មិនឲ្យគណបក្សប្រឆាំង(ពិសេសបក្សកុម្មុយនិស្ត) ចូលរួមប្រកួតប្រជែង ក្នុងការបោះឆ្នោត។ ដោយឡែក នៅប្រទេសយើងវិញ អ្នកសង្កេតការណ៍បរទេសឃើញស្រាប់ហើយថា ចលនាសង្គមរាស្ត្រនិយមស្រលាញ់របបរាជានិយម ហ៊ានបើក សិទ្ធិឲ្យពួកកុម្មុយនិស្ត ជាសត្រូវនឹងរបបរាជានិយម ឱ្យធ្វើសកម្មភាពប្រឆាំងជំទាស់តាមរយៈការចេញផ្សាយកាសែត តាមរយៈការឃោសនា និងបើកសិទ្ធិឱ្យចូលរួមប្រកួតប្រជែងប្រជែង ក្នុងការបោះឆ្នោតបោះឆ្នោត ដោយសេរី។

សម សារី និងសឺង ង៉ុកថាញ់ ក្អេងក្អាងដូចក្អាត់ក្នុងក្អម ជួយឃោសនាឲ្យចៅហ្វាយបរទេសរបស់ខ្លួន ជួយស្រែកច្រៀងដោយខំដំឡើងសំឡេងខ្លាំងៗថា ប្រទេសខ្មែរពុករលួយដោយសារមានពួកកុម្មុយនិស្តច្រើន។ ដើម្បីឲ្យដឹងច្បាស់ថា រវាងយើងជាប្រទេសអព្យាក្រឹត និងប្រទេសសេរីខ្លះ (វៀតណាម ឡាវ) ជាប្រទេសប្រឆាំងយ៉ាងប្តូរផ្តាច់ចំពោះលទ្ធិកុម្មុយនិស្ត

## របត់នយោបាយ

តើប្រទេសណាមួយ មានអំពើពុករលួយ ដោយសារមានពួកកុម្មុយនិស្ត ច្រើននោះ? ព្រះអង្គសូមឲ្យយោបល់ថា គួរបើកឱ្យមានការប្រកួតគ្នា ដូចការប្រកួតកីឡា ទើបជាការប្រសើរ គឺសូមបើកសិទ្ធិឲ្យពួកកុម្មុយនិស្ត នៅក្នុងប្រទេសនីមួយៗ ចេញមុខមកប្រកួតប្រជែងក្នុងការបោះឆ្នោត ដោយស្មើភាពគ្នា ហើយដល់ពេលបោះឆ្នោតរួច ចូរយើងប្រៀបធ្ធឹមលទ្ធផលរៀងៗខ្លួនថា តើប្រទេសខ្មែរ ជាប្រទេសអព្យាក្រឹត ឬមួយប្រទេសលោកសេរី(វៀតណាមឡាវ) មានភាគរយ នៃវត្តមានពួកកុម្មុយនិស្ត ច្រើនជាងគេ។

ព្រះអង្គសូមឲ្យជនរួមជាតិជួយវិនិច្ឆ័យ ដោយយុត្តិធម៌ ចំពោះការឃោសនាចោទប្រកាន់របស់សម សារី និងសឺង ង៉ុកថាញ់ ជាសត្រូវរបស់ព្រះអង្គ ឲ្យបងប្អូនខ្មែរនៅកម្ពុជាក្រោមជឿថា សង្គមរាស្ត្រនិយមរបស់ព្រះអង្គជាសង្គមអយុត្តិធម៌ និងពុករលួយ។ សម្ដេចសីហនុបានសរសេរបន្តទៀតថា សម សារី បានតាក់តែងអត្ថបទមួយថា ព្រះអង្គជាប្រធានចលនាសង្គមរាស្ត្រនិយម ចូលចិត្តប្រើប្រាស់តែមនុស្សគ្មានចំណេះវិជ្ជា ពុករលួយ មិនចេះការពារផលប្រយោជន៍ជាតិ និងមនុស្សអែបអប បញ្ជោរបញ្ជើច លើកជើង តែប៉ុណ្ណោះ។

ជាមួយគ្នានេះ គេហ៊ានភូតកុហកជនរួមជាតិ រស់នៅក្នុងប្រទេសជិតខាងថា ស្ដេចខ្មែរមើលងាយរាស្ត្ររបស់ខ្លួនណាស់ ដោយឲ្យឯកសិទ្ធិ បុណ្យស័ក្តិ តួនាទីទៅតែរាជវង្សានុវង្សតែប៉ុណ្ណោះ។ សម សារី វាហ៊ាននិយាយប្រាប់និស្សិត និងជនរួមជាតិនៅឯបរទេសថា បានជាព្រះអង្គ មិនឲ្យគេធ្វើនាយករដ្ឋមន្ត្រី ដូច ប៉ែន នុត ដូច សាន យន់ ដោយសារម្យ៉ាងព្រះអង្គប្រណែននិន្ទានឹងគេ មានចំណេះវិជ្ជាខ្ពង់ខ្ពស់ជាង ឆ្ងាយដូចមេឃនិងដី ម្យ៉ាងទៀតដោយសារតែគេចង់ការពាររាស្ត្រតូចតាច ការពារមនុស្សមិនចេះអែបអបឡេមឡឺម មិនចេះពុករលួយ ការពារលទ្ធិប្រជាធិបតេយ្យ និងមិនចង់ឲ្យព្រះអង្គប្រើអំណាច ដូចស្ដេចត្រាញ់តទៅទៀត។ សម្ដេចសីហនុ បានធ្វើការបកស្រាយថា អ្វីដែលសម សារី និយាយថា ព្រះអង្គមានចិត្តប្រណែននិន្ទាចំពោះចំណេះវិជ្ជាគេនោះ គឺមិនពិតទេ ព្រោះចំណេះវិជ្ជាគេនោះ មានតែទាបជាងរបស់សហជីវិនជាសហការីរបស់ព្រះអង្គ ដូចជា ហ៊ូ យន់ និងទ្រឿង កាង ក្នុងពេលបច្ចុប្បន្ននេះ ទៀតផង។



**សម្តេចសីហនុ និងគ្រូស្ឆេវ មេដឹកនាំសហភាពសូវៀត**

សម សារី ហ៊ានឃោសនាភូតភរខ្មែរនៅក្រៅប្រទេស ដូចជានៅអឺរ៉ុប នៅថៃ និង វៀតណាមខាងត្បូង ថា ស្តេចងរង៉ក់សីហនុ មិនគាប់ព្រះទ័យនឹងខ្លួន ដោយសារតែខ្លួនជា មនុស្សស្អាតស្អំ មិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន គិតតែការពារប្រយោជន៍រាស្ត្រតូចតាច ការពារ ឧត្តមប្រយោជន៍ជាតិ ការពារលទ្ធិប្រជាធិបតេយ្យ ជាដើម។ ការឃោសនាភូតភរនេះ ខ្មែរ មិនធ្លាប់រស់នៅក្នុងមាតុប្រទេសខ្លួន តាំងពីកំណើតមក អាចជឿបានខ្លះ តែចំពោះខ្មែរ មាន ដើមកំណើតនៅក្នុងប្រទេស ដូចជាពួកនិស្សិតបានចាកចេញពីប្រទេស ទៅរៀនសូត្រនៅ បរទេស សុទ្ធសឹងបានដឹងគ្រប់គ្នាថាៈ

១.សម សារី ជាមនុស្សពុករលួយៈ ធ្លាប់ពាក់ព័ន្ធក្នុងរឿងរថយន្តកាំមីញ៉ុង ១៩គ្រឿង, រឿងរត់ពន្ធគយម្រេច ប្រែក្លាយទៅជាគ្រាប់គ, រឿងគាំទ្រអំពើក្បត់លួចថវិកាជាតិ របស់មន្ត្រី ឈ្មោះអ៊ូច សមសែម, រឿងខ្សែសូត្រប្រែក្លាយទៅជាផ្ងៀតត្រីយៀហ៊ឺ (មឹក)...។ល។

២.សម សារី ជាមនុស្សអយុត្តិធម៌ៈ សូមអ្នកអានទស្សនាវដ្តីជាតិនិយម របស់ព្រះអង្គ មេត្តាសាកសួរមន្ត្រីធ្លាប់ធ្វើការនៅក្រោមបង្គាប់សម សារី ទៅ ច្បាស់ជាដឹងថា ជននេះជា មនុស្សពុករលួយ។ បើមន្ត្រីនៅក្រោមបង្គាប់ខ្លួនណា សូកលុយកាក់ ខ្លួនតម្លើងបុណ្យស័ក្តិ ឱ្យភ្លាម។ តែបើមន្ត្រីណាមិនសូកប៉ាន់ទេ បើទោះបីខិតខំធ្វើការបម្រើរាជការ ដោយសមត្ថភាព

បរិបូណ៌ និងស្អាតស្អំយ៉ាងណា ក៏សម សារី ធ្វើបាប មួលបង្កាច់ជិះជាន់ សង្កិតសង្កន់ ឱ្យគ្នាវិនាសដែរ ហើយអ្នករាជការតូចតាចណា ចេះតែធ្វើការជូនជាតិ មិនព្រមដាក់ខ្លួន ធ្វើដូចជាខ្ញុំបម្រើរបស់គេ និងលោកជំទាវជាប្រពន្ធ នៅឯផ្ទះ និងមិនចេះរកផលប្រយោជន៍ឱ្យគ្រួសារវាទេ អ្នកនោះត្រូវជួបបញ្ហាធ្ងន់ជាមិនខាន។ រឿងហេតុអយុត្តិធម៌អស់ទាំងនេះ មន្ត្រីធ្លាប់បានរងគ្រោះ ដោយអំពើអយុត្តិធម៌របស់សម សារី អាចធ្វើអត្ថាធិប្បាយជម្រាបលោកអ្នកបានក្បោះក្បាយជាងព្រះអង្គ។

៣. សម សារី ជាមនុស្សផ្តាច់ការ៖ សម សារី ក៏ដូចជា សឹង ង៉ុកថាញ់ ដែរ មិនដែលសាងអំពើអ្វីមួយបង្ហាញឱ្យឃើញថា ខ្លួនជាអ្នកទ្រទ្រង់លទ្ធិប្រជាធិបតេយ្យម្តងណាទាល់តែសោះ។ រឿងនេះ សូមលោកអ្នកអានអត្ថបទរបស់ព្រះអង្គបានសរសេរ ចុះផ្សាយនៅក្នុងទស្សនាវដ្តីអ្នកជាតិនិយម លេខ២ ប្រាកដជាជ្រាបច្បាស់ហើយ។

៤. សម សារី ជាមនុស្សក្បត់ឧត្តមប្រយោជន៍ជាតិ បម្រើប្រយោជន៍បរទេស៖ ពេលនេះព្រះអង្គសូមបង្ហាញភ័ស្តុតាងនៃអំពើក្បត់ជាតិមាតុភូមិរបស់សម សារី សូម្បីតែចៅហ្វាយបរទេសរបស់វា ក៏ស្អប់ខ្ពើមដែរនោះ ជូនដល់ប្រជាជាតិខ្មែរបានជ្រាប ដូចខាងក្រោមនេះ៖ សម សារី បានបម្រើប្រយោជន៍ពួកបរទេស ជាយូរឆ្នាំមកហើយ គឺចាប់តាំងពីពេលវាបានធ្វើជាទីប្រឹក្សារាជរដ្ឋាភិបាលមកនោះ។ រឿងនេះ សូមអស់លោកអ្នកមេត្តានឹកទៅដល់សុន្ទរកថារបស់ព្រះអង្គបានថ្លែងនៅខេត្តកំពង់ចាម កាលពីដើមឆ្នាំ១៩៥៩ កន្លងទៅនេះ ប្រាកដជាបានជ្រាបហើយ។

នៅក្នុងឆ្នាំ១៩៥៦ សម សារី បានធ្វើដំណើរទៅប្រទេសបារាំង ដើម្បីព្យាបាលខ្នង់ច្រមុះបាក់។ ក្រោយពេលព្យាបាលរួច សម សារី ក៏បានមកជួបព្រះអង្គក្នុងឱកាសយន្តហោះដឹកព្រះអង្គ ទៅបំពេញព្រះរាជទស្សនកិច្ចនៅសហភាពសូវៀត ត្រូវឈប់សំចតនៅក្រុងប៉ារីស។

ពេលនោះ សម សារី ក៏សុំព្រះអង្គទៅទស្សនកិច្ចនៅសហភាពសូវៀត ដែរ ព្រះអង្គក៏ព្រមឱ្យទៅជាមួយ។ លុះពេលទៅដល់សហភាពសូវៀត សម សារី បែរជានិយាយនៅចំពោះមុខមេដឹកនាំប្រទេសកុម្មុយនិស្ត មួយនេះ ដោយបរិហារិះគន់លទ្ធិកុម្មុយនិស្តយ៉ាងធ្ងន់ក្រៃ

លែង ហើយលើកសរសើរពីលទ្ធិលោកសេរី ថែមទៀតផង។

ឮដូច្នេះ ព្រះអង្គ និងឧត្តមសេនីយ៍ ង៉ោ ហ៊ូ ព្រមទាំងស្តេចក្រុមហ្លួងស៊ីសុវត្ថិ មុនីពង្ស មានការភ្ញាក់ផ្អើលស្រឡាំងកាំងជាខ្លាំង ដោយមិននឹកស្មានថា សម សារី ហ៊ានប្រើពាក្យសម្តីរិះគន់ ធ្វើឲ្យប៉ះពាល់ដល់មិត្តភាពខ្មែរ ជាមួយប្រទេសជាមហាអំណាចកុម្មុយនិស្ត នៅកណ្តាលក្រុងមូស្គូបែបនេះសោះ។ ស្តេចក្រុមហ្លួងស៊ីសុវត្ថិ មុនីពង្ស សុគតនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៥៦ គឺ៦ថ្ងៃក្រោយបុណ្យចម្រើនព្រះជន្មរបស់ព្រះអង្គក្នុងជន្មាយុ៥៤ព្រះវស្សា ដោយរោគគាំងព្រះហឫទ័យ(គាំងបេះដូង)នៅទីក្រុងប៉ារីស។ សម្តេចសីហនុ បានបកស្រាយបញ្ជាក់ថា ពេលនោះ ព្រះអង្គបាននាំគ្នាប្រដៅផង ហាមប្រាមផង អង្វរផង ឱ្យសម សារី ឈប់ប្រើពាក្យសម្តីបែបនេះទៀត តែសម សារី បែរជាឆ្លើយមកព្រះអង្គវិញថា ខ្លួនមិនមែនរិះគន់ទិតៀនអីទេ គឺគ្រាន់តែជាការសង្កេតឃើញរបស់គេ និងជាការជួយបំភ្លឺប្រជាជនសូវៀតឲ្យបានដឹងពីកំហុសរបស់មេដឹកនាំខ្លួន និងដើម្បីឱ្យមេដឹកនាំសហភាពសូវៀត កែកុនលទ្ធិកុម្មុយនិស្តរបស់ខ្លួន ឱ្យបានល្អឡើងវិញ តែប៉ុណ្ណោះ។

រឿងនេះ បើអស់លោកអ្នកអានទស្សនាវដ្តីអ្នកជាតិនិយមមិនជឿទេ សូមសួរវស្សរជនទាំងឡាយបានហែហមព្រះអង្គ ពេលទៅយាងបំពេញព្រះរាជទស្សនកិច្ចនៅសហភាពសូវៀតកាលក្នុងឆ្នាំ១៩៥៦នោះ ដូចជា អ៊ុម ឈាងស៊ុន, ឃឹម ទិត និងទ្រង់ស៊ីសុវត្ថិ មេថាវី ក៏មិនទាន់ភ្លេចនូវអំពើផ្តាំផ្តងរបស់សម សារី នេះ នៅក្នុងស្ថានីយរថភ្លើងលេនីនក្រាដ នៅទីក្រុងមូស្គូ នៅឡើយដែរ។

សូមជនរួមជាតិវិនិច្ឆ័យចុះ បើព្រះអង្គ និងព្រះមហាក្សត្រ ជាអ្នកធ្វើឱ្យសង្គមជាតិក្លាយជាសង្គមអយុត្តិធម៌ សង្គមល្ងិតល្ងង់ និងសង្គមពុករលួយមែននោះ សង្គមយើងពុំមានការរីកចម្រើន និងពុំអាចបង្រួបបង្រួមជាតិអ្នកនយោបាយ រួមមាន ពួកគណបក្សប្រជាធិបតេយ្យ និងពួកបញ្ញវន្ត ជាអតីតនិស្សិតមានសញ្ញាបត្រខ្ពង់ខ្ពស់ ជាដើម មកក្នុងសង្គមជាតិបានទេ។

# ១២៧
# សម សារី និងសឺង ង៉ុកថាញ់ ថាៈ សីហនុ ដឹកនាំប្រទេសលម្អៀងទៅរកកុម្មុយនិស្ត



**សម្តេចសីហនុ ជាមួយ ជូ អេនឡាយ**

អត្ថបទដែលសម្តេចសីហនុ ចុះផ្សាយនៅក្នុងទស្សនាវដ្តីអ្នកជាតិនិយម បានបញ្ជាក់ថាៈ ជ័យជម្នះរបស់ព្រះមហាក្សត្រ និងចលនាសង្គមរាស្ត្រនិយម កើតឡើងដោយសារមានឧត្តមគតិយុត្តិធម៌ ចំពោះជនរួមជាតិទូទៅ ដោយពុំរើសមុខៈ

១. យុត្តិធម៌ក្នុងការជ្រើសរើសឥស្សរជនឱ្យកាន់តំណែងទទួលខុសត្រូវកិច្ចការរដ្ឋធំៗ ដើម្បីបម្រើជាតិសាសនាព្រះមហាក្សត្រ។ ក្នុងការជ្រើសរើសឱ្យកាន់តំណែងទទួលខុសត្រូវកិច្ចការរដ្ឋធំៗ នេះ ពុំមែនសំដៅយកតែរាជវង្សានុវង្ស ឬមន្ត្រីចាស់ៗជំនាន់មុនៗ ដូចសម សារី ចោទប្រកាន់នោះទេ សូម្បីតែឥស្សរជនក្មេង ឬចាស់ធ្លាប់ប្រឆាំងនឹងព្រះមហាក្សត្រ ឬ

ប្រឆាំងចលនាសង្គមរាស្ត្រនិយម យ៉ាងណាក្តី បើពិនិត្យទៅឃើញថា គេមានចំណេះដឹងខ្ពស់ មានសមត្ថភាព មានចរិយាសម្បត្តិស្អាតស្អំនោះ ព្រះមហាក្សត្រ និងចលនាសង្គមរាស្ត្រនិយម ត្រូវតែតែងតាំងពួកគេឱ្យកាន់មុខតំណែងធំៗរបស់រដ្ឋ។ សូមអស់លោកមេត្តាពិនិត្យមើលសមាសភាពនៅក្នុងជួររាជរដ្ឋាភិបាល រដ្ឋសភា និងឧត្តមក្រុមប្រឹក្សាព្រះរាជាណាចក្រយើង សព្វថ្ងៃនេះ ក៏អាចដឹងដែរ។

២. យុត្តិធម៌ក្នុងការបោសសម្អាត ៖ ឥស្សរជនណាជាអ្នកជិតស្និទ្ធ ជាមួយព្រះមហាក្សត្រ ឬសហជីវិនចាស់ៗរបស់ព្រះអង្គ ឬជាសមាជិករបស់ចលនាសង្គមរាស្ត្រនិយម ក៏ពុំត្រូវទទួលបាននូវឯកសិទ្ធិខុសពីគេដទៃដែរ គឺពួកគេរមែងតែងតែទទួលទោសតាមច្បាប់នៅពេលណា ពួកគេបានប្រព្រឹត្តខុសឆ្គងអ្វីមួយ ចំពោះប្រទេសជាតិ។ អស់លោកជាអ្នកសង្កេតការណ៍ជ្រាបស្រាប់ហើយថា ព្រះអង្គពុំកាន់ជើងសហជីវិនចាស់ ឬសេនាបរិពាររបស់ព្រះអង្គម្តងណាទេ ទោះបីអ្នកនោះជាមនុស្សជិតស្និទ្ធជាមួយព្រះអង្គយ៉ាងណាក៏ដោយ បើមានគេប្តឹងហើយ ព្រះអង្គតែងតែដកចេញពីមុខតំណែងភ្លាមៗ ដើម្បីឲ្យតុលាការ ឬក្រសួងបោសសម្អាត ផ្តន្ទាទោស ឬជំនុំជម្រះតាមច្បាប់។

ដូច្នេះ សហជីវិនជាកូនចៅជិតស្និទ្ធជាមួយព្រះអង្គមួយចំនួន គ្នាបានទទួលរងគ្រោះដោយសារតែមានគេសរសេរសំបុត្រអនាមិកមកប្តឹងដោយគ្មានឲ្យភស្តុតាងបន្តិចសោះនោះ ក៏ព្រះអង្គឱ្យដកពួកគេចេញពីតំណែង ដើម្បីឱ្យតុលាការជំនុំជម្រះដែរ ធ្វើឱ្យសហជីវិនទាំងអស់នោះតូចចិត្តនឹងព្រះអង្គខ្លាំងណាស់ដែរ។

ជាមួយគ្នានេះ សូម្បីញាតិសន្តានមីងមាបង្កើតរបស់ព្រះអង្គ ក៏ព្រះអង្គពុំដែលកាន់ជើងដែរ។ បើព្រះអង្គ ការពារ និងតែងតាំងតែមនុស្សល្ងិតល្ងង់ មនុស្សពុករលួយ មនុស្សអែបអបទ្បេមឡឺម ឱ្យធ្វើធំមែននោះ ពួកមន្ត្រីរបស់បក្សប្រជាធិបតេយ្យ គេមិនចាកចេញ ឬពួកគេមិនរំលាយគណបក្សធំរបស់គេ មកចុះចូលជាសមាជិករបស់ចលនាសង្គមរាស្ត្រនិយមរបស់ព្រះអង្គដែរ។ នៅក្នុងរដ្ឋសភា និងនៅក្នុងរាជរដ្ឋាភិបាលសព្វថ្ងៃ បើរាប់សហជីវិនចាស់ៗជិតស្និទ្ធនឹងព្រះអង្គ មានយ៉ាងច្រើន បួនដប់នាក់ប៉ុណ្ណោះ ហើយក្នុងចំណោមបួនដប់

នាក់នេះទៀតសោត សុទ្ធសឹងតែប្រកបដោយសមត្ថភាពបរិបូណ៌ និងមានចរិយាសម្បត្តិល្អ ត្រឹមត្រូវ ទៀតផង។

ចំណែកសហជីវិន ៨ភាគ១០ទៀត ព្រះអង្គបានប្រគល់តំណែងនៅក្នុងរដ្ឋសភា និងនៅក្នុងជួររាជរដ្ឋាភិបាល សុទ្ធតែជាមនុស្សពុំមែនជាមិត្តភក្តិរបស់ព្រះអង្គ ឬជាមនុស្សព្រះអង្គពុំធ្លាប់បានស្គាល់ពីមុនមក គឺព្រះអង្គតែងតាំង ដោយសារតែឃើញចំណេះវិជ្ជា និងចរិយាសម្បត្តិរបស់ពួកគេ តែប៉ុណ្ណោះ។

៣.យុត្តិធម៌ សច្ចធម៌ក្នុងការបម្រើជាតិ៖ រឿងនេះ សូមអស់លោកអ្នកវិនិច្ឆ័យទៅចុះថា តើសម សារី និងសឹង ង៉ុកថាញ់ វាជាមនុស្សមានយុត្តិធម៌ដែរឬទេ?៖

១.ប្រទេសជាតិរបស់វាកំពុងតែមានសន្តិភាព មានភាពសុខសាន្តត្រាណ វាទាំងពីរនាក់ បែរជាបញ្ចូលកងទ័ពក្បត់ជាតិរបស់ពួកវា និងពួកទាហានយួនខាងត្បូង ឲ្យមកបង្កអសន្តិសុខ នៅក្នុងព្រះរាជាណាចក្រទាំងមូល ដោយចាប់ផ្តើមពីខេត្តកំពត តាកែវ ស្វាយរៀង និងស្ទឹងត្រែង ជាដើម។

២.ជាតិយើងកំពុងតែស្រុះស្រួលរួបរួមគ្នា កសាងប្រទេសឱ្យរីកចម្រើនគ្រប់ទិសទី ពួកវាទាំងពីរនាក់នេះ បែរជាធ្វើសកម្មភាពឃោសនាចង់បំបែកបំបាក់កម្លាំងសាមគ្គីជាតិទៅវិញ។

៣. ប្រទេសយើងប្រកាន់យកគោលនយោបាយអព្យាក្រឹត ទទួលបាននូវការរាប់រកដ៏ពិសេសពិសាលពីប្រទេសទាំងឡាយ នៅលើពិភពលោក រួមទាំងពួកប្រទេសលោកសេរី ទាំងពួកប្រទេសកុម្មុយនិស្ត និងពួកប្រទេសលោកកណ្តាល អព្យាក្រឹត បែរជាសម សារី និងសឹង ង៉ុកថាញ់ ដើរញុះញង់ពួកប្រទេសលោកសេរី ឱ្យប្រើវា ដើម្បីមកបំផ្លាញគោលនយោបាយអព្យាក្រឹតភាព ឯករាជ្យរបស់ជាតិ ដោយវាឃោសនាថា ការប្រកាន់យកគោលនយោបាយអព្យាក្រឹតនេះ នឹងបង្កឱ្យមានគ្រោះថ្នាក់ដោយសារពួកកុម្មុយនិស្តទៅវិញ។ប្រទេសជាតិយើងកំពុងរីកចម្រើន ថ្កុំថ្កើង រុងរឿង សុខសប្បាយ កំពុងមូលពូជពង្សវង្សត្រកូល រួចផុតពីគ្រោះថ្នាក់កុម្មុយនិស្ត សម សារី និងសឹង ង៉ុកថាញ់ ហ៊ានប្រកាសប្រាប់លោកសេរី

ថា ប្រទេសខ្មែរ កំពុងជួបគ្រោះមហន្តរាយ ដោយសារសីហនុ ដាក់ប្រទេសឲ្យនៅក្រោមពួកកុម្មុយនិស្ត ។

ពេលនេះ ប្រទេសខ្មែរយើងមានស្ថានភាពល្អប្រសើរជាងបណ្តាប្រទេសជិតខាង សម សារី និងសឺង ង៉ុកថាញ់ បែរជាខំឃោសនាថា បណ្តាប្រទេសជិតខាងជាបក្ខពួកលោកសេរីនោះ រីកចម្រើន ថ្កុំថ្កើង រុងរឿង សុខសប្បាយ ជាងប្រទេសខ្មែរ ទៅវិញ?។ ចលនាសង្គមរាស្ត្រនិយមបង្កើតឱ្យមានសមាជជាតិ ផ្តល់សិទ្ធិសេរីភាព ផ្តល់លទ្ធិប្រជាធិតេយ្យឲ្យជនរួមជាតិយើង ច្រើនជាងនៅបណ្តាប្រទេសនានា សម សារី និងសឺង ង៉ុកថាញ់ ហ៊ាននិយាយសំអុយថា ប្រទេសខ្មែរយើង មិនមានលទ្ធិប្រជាធិបតេយ្យបរិសុទ្ធ ដូចប្រទេសទាំងអស់នោះ ទៅវិញ ដោយសម សារី យកការរលាយរបស់គណបក្សបង្រួបបង្រួមខ្មែរអ្នកប្រជាធិបតេយ្យ វាបានបង្កើតឡើងនោះជា ឧទាហរណ៍នៃលទ្ធិផ្តាច់ការរបស់សីហនុ។

ព្រះអង្គសូមបញ្ជាក់ថា រាជរដ្ឋាភិបាលពុំបានរំលាយគណបក្សរបស់សម សារី នោះទេ។ ប្រសិនបើរាជរដ្ឋាភិបាលបំបិទសិទ្ធិ មិនឱ្យមានគណបក្សនយោបាយផ្សេងទៀត ក្រៅពីចលនាសង្គមរាស្ត្រនិយមដូចសម សារីបានចោទប្រកាន់មែននោះម្ល៉េះសមគណបក្សប្រជាជនជាបក្សកុម្មុយនិស្ត ត្រូវរលាយមុនគណបក្សបង្រួបបង្រួមខ្មែរអ្នកប្រជាធិបតេយ្យ របស់សម សារី ជាយូរឆ្នាំមកហើយ។ ការពិត គណបក្សបង្រួបបង្រួមខ្មែរអ្នកប្រជាធិបតេយ្យ នេះ គ្មានប្រជារាស្ត្រណាចូលរួមជាសមាជិក ក្រៅតែអតីតមន្ត្រីខិលខូច ជាកូនចៅរបស់សម សារី ដែលរាជការបានបណ្តេញចេញពីការងារ ដោយសារប្រព្រឹត្តអំពើពុករលួយ ស៊ីសំណូក លួចប្រាក់រាជការ ដូចសម សារី នោះឡើយ។ គណបក្សបង្រួបបង្រួមខ្មែរអ្នកប្រជាធិបតេយ្យ ត្រូវរលាយទៅវិញ ដោយសារតែសម សារីរួមគំនិតជាមួយបរទេស ក្បត់ជាតិឯងតែប៉ុណ្ណោះ ក្នុងនោះ រាជការចាប់បានភស្តុតាងនៅជាប់នឹងខ្លួនកូនចៅរបស់សម សារី ម្នាក់ឈ្មោះស៊ី វុធថៃ និងនៅក្នុងផ្ទះរបស់សម សារី និងដាប ឈួន ជាច្រើន ផងដែរ។

សរុបសេចក្តីទៅ គណបក្សបង្រួបបង្រួមខ្មែរអ្នកប្រជាធិបតេយ្យ រលាយទៅវិញនោះ គឺដោយសារបទឧក្រិដ្ឋក្បត់ជាតិ របស់សម សារី រាជការចាប់បានទាំងភ័ស្តុតាង ពុំមែន

រលាយដោយសារធ្វើសកម្មភាពប្រឆាំង ស្របតាមលទ្ធិប្រជាធិបតេយ្យ នោះឡើយ។

សម សារី ចោទព្រះមហាក្សត្រថា ខ្លួនវាអស់បុណ្យស័ក្តិ ដោយសារវាមានកំហុសតូចមួយ គឺវាបានវាយស្រីបម្រើម្នាក់ ហើយការវាយនោះទៀតសោត គឺវាធ្វើឡើង ដោយសារតែការស្រលាញ់ស្រីបម្រើម្នាក់នោះតែប៉ុណ្ណោះ។ រឿងអាស្រូវរបស់សម សារី នៅក្រុងឡុងដ៍ ប្រទេសអង់គ្លេស បានធ្វើឲ្យស្អុយដល់កិត្តិយសកេរ្តិ៍ឈ្មោះប្រទេសជាតិទាំងមូលនៅពាសពេញសាកលលោក។ អស់លោកអ្នក ប្រាកដជាបានជ្រាបច្បាស់រឿងនេះហើយ និងអាចវិនិច្ឆ័យថ្វាយព្រះមហាក្សត្រ និងឲ្យរាជរដ្ឋាភិបាលយើងបាន។ ជាទីអវសាននេះ ព្រះអង្គសួរទៅសម សារី ថា ការដែលវាធ្វើកញ្ចប់គ្រាប់បែកមកសម្លាប់មាតាព្រះអង្គ សម្តេចព្រះមហាក្សត្រិយានី ជាស្ត្រីភេទទន់ខ្សោយនោះ តើនោះជាអំពើធ្វើដោយគោរព និងដោយស្រលាញ់ចំពោះព្រះអង្គ ដូចវាបានអះអាងនោះឬទេ?។

# ១២៨
# សឺង ង៉ុកថាញ់ ជាអ្នកស្នេហាជាតិ ឬជាអ្នកបំផ្លាញជាតិ ?



**សម សារី**



**សឺង ង៉ុកថាញ់**

ជាមួយនឹងការចុះផ្សាយអត្ថបទ ជាព្រះរាជនិពន្ធផ្ទាល់ របស់សម្តេចសីហនុ នោះដែរ ទស្សនាវដ្តីអ្នកជាតិនិយម ក៏បានចុះផ្សាយពីប្រវត្តិ និងអំពើក្បត់របស់សម សារី និងសឺង ង៉ុកថាញ់ មានខ្លឹមសារទាំងស្រុង ដូចខាងក្រោម៖

សម សារី និងសឺង ង៉ុកថាញ់ ដែលលោកអ្នកស្គាល់ថា ជាមនុស្សក្បត់ជាតិឯង បាននាំគ្នាទៅជ្រកពួននៅក្នុងប្រទេសជិតខាងនោះ ក្នុងពេលថ្មីៗនេះ វាខំប្រឹងស្រែកលូ ដូចឆ្កែព្រៃប្លែកខុសពីធម្មតា ហើយនៅពេលនេះ យើងសូមដកស្រង់ខ្លឹមសារសម្រែកវាខំប្រឹងស្រែកលូនោះ មកចុះផ្សាយជូនជនរួមជាតិឲ្យបានជ្រាប និងដើម្បីជួយវិនិច្ឆ័យថា តើសម សារី និងសឺង ង៉ុកថាញ់ ភូតភរ និងមើលងាយប្រជារាស្ត្រខ្មែរ យ៉ាងណាខ្លះ? ពួកក្បត់នេះ ប្រហែលជាវានឹកគិតថា ប្រជារាស្ត្រខ្មែរទូទាំងប្រទេស គ្មានចំណេះប្រាជ្ញាដូចវានោះ មុខតែជឿតាមការស្រែកលូរបស់វាថា វាកំពុងតស៊ូដោយពេញទំហឹង, វាជាមនុស្សសេរី, ប្រទេសខ្មែរ មិន

ត្រូវកាន់នយោបាយអព្យាក្រឹតទេ, នៅកម្ពុជា មានពួកកុម្មុយនិស្តពាសពេញផ្ទៃប្រទេស ហើយសីហនុ បានបញ្ចេញពួកកុម្មុយនិស្ត ឲ្យទៅធ្វើបាបវៀតណាម និងថៃ ទៀតផង។

យើងសូមឆ្លើយតបនឹងសម្រែកស្រែកលូរបស់ពួកក្បត់សម សារី និងសឺង ង៉ុកថាញ់ ដូចខាងក្រោមនេះ តែមុននឹងឆ្លើយតប យើងសូមជូនប្រវត្តិខ្លីៗរបស់សឺង ង៉ុកថាញ់ និងសម សារី ដើម្បីឱ្យជនរួមជាតិបានជ្រាបថា តើជនក្បត់ទាំងពីរនាក់នេះ មុននឹងក្លាយជាក្រពើវង្វេងបឹង រត់ទៅជ្រកក្រោមនឹមបរទេស វាបានធ្វើអ្វីខ្លះជាប្រយោជន៍ជូនចំពោះប្រជាជាតិខ្មែរ?។

ការពិត សឺង ង៉ុកថាញ់ ពុំមែនជាអ្នកស្នេហាជាតិស្អីនោះទេ ព្រោះឱ្យតែពេលណាវាមានរឿងអាសន្នម្តងៗ វាមិនគិតដល់ជាតិទេ គឺវារត់យករស់តែម្នាក់វាប៉ុណ្ណោះ។ ឧទាហរណ៍ កាលពីឆ្នាំ១៩៤២ មានការបង្ក្រាបចលនាបះបោរប្រឆាំងនឹងបារាំង នៅក្រុងភ្នំពេញ សឺង ង៉ុកថាញ់ បានរត់គេចខ្លួនទៅជ្រកកោននៅប្រទេសជប៉ុន ឯណោះធ្វើព្រងើយ ដោយមិនគិតគូរដល់ជាតិសោះឡើយ។

ដល់ពេលកងទ័ពជប៉ុន ដណ្តើមអំណាចត្រួតត្រាពីបារាំង(ឆ្នាំ១៩៤១) កងទ័ពជប៉ុនក៏បានលើកបន្តុបឲ្យវាធ្វើនាយករដ្ឋមន្ត្រី តែសឺង ង៉ុកថាញ់ គ្មានអំណាចអ្វីឡើយ ហើយកិច្ចការអ្វីៗ គឺស្រេចតែលើកងទ័ពជប៉ុន ទាំងអស់ សឺង ង៉ុកថាញ់ គ្រាន់តែមានឈ្មោះជានាយករដ្ឋមន្ត្រី ដូចទីងមោងប៉ុណ្ណោះ។ ដោយសារធ្វើជានាយករដ្ឋមន្ត្រី គ្មានការងារអ្វីធ្វើ វាក៏បើកការប្រជុំទាំងយប់ទាំងថ្ងៃនៅផ្ទះវា ហើយចាត់កសិករជាអ្នកស្រែចម្ការ ពុំបានដឹងច្បាស់ពីកិច្ចការនយោបាយរបស់ប្រទេសជាតិពិតប្រាកដមួយចំនួន និងអ្នកគ្មានការងារធ្វើមួយចំនួនទៀត ឱ្យដើរឃោសនាគ្រប់ច្រកល្ហកថា ខ្លួនវានេះជាអ្នកស្នេហាជាតិ។ លុះជប៉ុនចាញ់សង្គ្រាមលោកលើកទី២ ពេលកងទ័ពបារាំង វិលមកត្រួតត្រាប្រទេសខ្មែរ វិញ ក៏ចាប់សឺង ង៉ុកថាញ់ ទៅដាក់គុកប្រវាក់ ហើយនិរទេសឱ្យទៅនៅស្រុកបារាំង បាត់ទៅ។

ក្រោយមក ដោយសារព្រះករុណា ព្រះនរោត្តម សីហនុ តែងតែមានព្រះទ័យអាណិតអាសូរដល់ប្រជារាស្ត្រឥតរើសមុខនោះ ព្រះអង្គបានតវ៉ា សុំឱ្យបារាំង ដោះលែងសឺង ង៉ុក

ថាញ់ ឱ្យរួចខ្លួន និងបានវិលត្រលប់មកជួបប្រពន្ធកូនវិញ ហើយសឺង ង៉ុកថាញ់ ក៏បានសន្យាជាមួយព្រះអង្គថា វានឹងលែងធ្វើនយោបាយផ្តេសផ្តាស ឲ្យព្រះអង្គពិបាកព្រះទ័យទៀតហើយ។ ឯការដែលវាធ្វើនយោបាយនេះ ក៏ដើម្បីជាប្រយោជន៍ដល់ព្រះមហាក្សត្រ ដែរតែឥឡូវ បើព្រះមហាក្សត្រទាមទារឯករាជ្យបានហើយនោះ វាសប្បាយចិត្តណាស់ ហើយវាសុំរស់នៅជាប្រជារាស្ត្រសាមញ្ញវិញ។ តែក្រោយពេលបានមកដល់មាតុប្រទេសវិញ សឺង ង៉ុកថាញ់ ក៏មានចិត្តក្បត់ ហើយប្រមែប្រមូលកូនសិស្សដែលគ្នាកំពុងរៀនសូត្រ និងបានបញ្ចុះបញ្ចូលនាយទាហានមួយចំនួន ឲ្យធ្វើជាឈ្នាន់នយោបាយរបស់វា ដូចជាស័ក្តិ២ ឈ្មោះដួងចន្ទ សារ៉ាត់ សព្វថ្ងៃនេះកំពុងជាប់គុកនៅឡើយ ឱ្យចូលរួមក្នុងអំពើក្បត់ជាតិ ជាមួយវាដែរ។

នៅពេលនោះដែរ សឺង ង៉ុកថាញ់ បានសរសេរសំបុត្រសូមឲ្យរាជការបើកប្រាក់បៀវត្សរម្លឹក(ប្រាក់ខែរ៉ាប់ប៉ែល) ឲ្យវា ដោយគិតតាំងពីពេលវាទៅជាប់គុកនៅប្រទេសបារាំង នោះផងដែរ។ ពេលនោះព្រះករុណាសីហនុ កំពុងគង់សោយរាជ្យនៅឡើយ ព្រះអង្គក៏បានអនុគ្រោះបញ្ជាឱ្យរាជការបើកប្រាក់បៀវត្សរម្លឹក(ប្រាក់ខែរ៉ាប់ប៉ែល)នោះ តាមសំណូមពរវា។

លុះបើកប្រាក់ខែនោះ បានច្រើនកាលណា សឺង ង៉ុកថាញ់ ដើរបញ្ឆោតកូនសិស្សឱ្យរត់ចូលព្រៃ ថា តស៊ូដើម្បីវាយបារាំង ដណ្តើមឯករាជ្យមកវិញ ប៉ុន្តែវាមិនបានវាយបារាំងទេ គឺវារត់ចូលទៅជ្រកនៅក្នុងខេត្តសៀមរាប ជាខេត្តព្រះករុណាសីហនុ ទាមទារស្វ័យភាពបានពីបារាំង នោះទៅវិញ។ នៅពេលព្រះករុណាសីហនុ កំពុងទាមទារឯករាជ្យ(ឆ្នាំ១៩៥៣) នោះ សឺង ង៉ុកថាញ់ មិនជួយទាមទារទេ គឺវាគិតតែពីស្រែកជេរព្រះអង្គថា ព្រះអង្គចូលដៃនឹងបារាំង ទៅវិញ។ ពេលនោះដែរ សឺង ង៉ុកថាញ់ ក៏ប្រាកដជាដឹងខ្លួនថា ប្រជាជាតិខ្មែរទាំងមូល គេស្គាល់ច្បាស់នូវគំនិតក្បត់ជាតិរបស់វារួច ហើយដែរ។ នៅក្នុងព្រៃតស៊ូនោះ សឺង ង៉ុកថាញ់ គ្មានបានធ្វើអ្វី ក្រៅតែពីបង្កើតឱ្យមានចោរកម្ម លួចប្លន់ នៅខេត្តសៀមរាប ខេត្តកំពង់ធំ និងខេត្តបាត់ដំបង ហើយរាលដាលពាសពេញផ្ទៃប្រទេស បង្កឱ្យមានអសន្តិសុខ និងបន្ទុចបង្អាក់ រំខានពេលវេលាដល់ប្រជារាស្ត្រខ្មែរទូទាំងប្រទេស កំពុងរួបរួមគ្នាជុំវិញ

ព្រះមហាក្សត្រ ដើម្បីទាមទារឯករាជ្យពីបារាំង នោះទៀតផង។

មិនតែប៉ុណ្ណោះ សេដ្ឋកិច្ចជាតិក៏ធ្លាក់ដុនដាប ដោយសារសឺង ង៉ុកថាញ់ និងកូនចោររបស់វា ដើររាតត្បាត ធ្វើឲ្យអ្នកស្រុកអ្នកភូមិភិតភ័យ លែងហ៊ានចេញទៅប្រកបការងាររកស៊ី ដូចសព្វដង។ ទាំងនេះ សបញ្ជាក់ឱ្យឃើញច្បាស់ថា សឺង ង៉ុកថាញ់ គ្មានបានធ្វើអ្វីជាផលប្រយោជន៍ ឲ្យប្រទេសជាតិមាតុភូមិយើងទេ វាគ្រាន់តែស្រែកឡូៗ ឲ្យគេកោតសសើរថា វាជាអ្នកស្នេហាជាតិប៉ុណ្ណោះ។ តាមការពិត ប្រជាពលរដ្ឋខ្មែរនៅទីក្រុង និងខេត្តនានា បានដឹងច្បាស់ថា សឺង ង៉ុកថាញ់ ជាមនុស្សស្នេហាតែអំណាច តួនាទី និងបុណ្យស័ក្តិប៉ុណ្ណោះ។ ជាក់ស្តែង កាលវារួចពីគុក នៅប្រទេសបារាំង ចូលមកប្រទេសវិញ វាទទូចចង់បានតំណែងជានាយករដ្ឋមន្ត្រី តែមិនបានដូចបំណង វាបោករាជការបានប្រាក់គ្រប់គ្រាន់ក៏រត់ទៅដេកស៊ីសប្បាយនៅក្រុងបាងកក ប្រទេសថៃ ធ្វើព្រងើយ ហើយរង់ចាំតែពេលណាប្រទេសខ្លួនឯង មានជម្លោះជាមួយជាតិសាសន៍ជិតខាង វានឹងចេញមុខមកជួយជាតិសាសន៍ជិតខាង ជាសត្រូវនឹងខ្មែរ នោះភ្លាម។ សូមជនរួមជាតិពិចារណាមើលចុះថា តើសឺង ង៉ុកថាញ់នេះ ជាអ្នកស្នហាជាតិ ឬជាអ្នកបំផ្លាញជាតិ ?។

ការពិតសឺង ង៉ុកថាញ់ ជាអ្នកបំផ្លាញជាតិយ៉ាងជាក់ស្តែងបំផុត ហើយអ្វីដែលវាលក់ខ្លួនឱ្យបរទេសនេះ គឺវាគិតតែផលប្រយោជន៍ផ្ទាល់ខ្លួនវា តែប៉ុណ្ណោះ។ សព្វថ្ងៃ វារស់បានដោយសារប្រាក់បរទេស ជួលឲ្យវារករឿងខ្មែរគ្នាឯង ដើម្បីបរទេសងាយបំផ្លិចបំផ្លាញប្រទេសជាតិយើង កុំឲ្យងើបមុខរួច។ ឧទាហរណ៍មួយទៀត កាលវាធ្វើជានាយករដ្ឋមន្ត្រី វាបានទៅអង្វរសំពះបាតជើងជប៉ុន ដើម្បីសុំឱ្យមានអំណាចពេញដៃ ដើម្បីដឹកនាំប្រទេស តែជប៉ុន ពុំព្រម គឺវាធ្វើជានាយករដ្ឋមន្ត្រីទីងមោងដដែល។ បើវាពូកែ ហេតុអ្វី ក៏ទាមទារអំណាចពីជប៉ុនយកមកដឹកនាំប្រទេស មិនបាន ?។ នៅពេលកាន់តំណែងជានាយករដ្ឋមន្ត្រីនោះដែរ មានរឿងមួយទៀត គឺសឺង ង៉ុកថាញ់ ជ្រើសរើសទាហានស្ម័គ្រចិត្តបានមួយកងវរសេនាតូច យកទៅឲ្យកងទ័ពជប៉ុន ជួយបង្ហាត់បង្រៀន។ តែពុំមែនទុកទាហានស្ម័គ្រចិត្តនោះ សម្រាប់ការពារប្រទេសជាតិទេ គឺទុកសម្រាប់ការពារខ្លួនឯង នៅពេលកងទ័ពបារាំង ត្រលប់មកត្រួតត្រា

ប្រទេសខ្មែរយើង វិញប៉ុណ្ណោះ។

លុះកងទ័ពបារាំង ត្រលប់មកត្រួតត្រាប្រទេសខ្មែរយើងវិញ ហើយចាប់សឺង ង៉ុកថាញ់ យកទៅបាត់ ទើបពួកទាហានស្ម័គ្រចិត្តទាំងអស់នោះ ដឹងខ្លួនថា ចំនួនទាហានមួយកងវរ-សេនាតូច មានគ្នាប្រហែល៧០០នាក់នេះ តើទៅការពារជាតិទាំងមូល ឯណាបាន?។ សូមជនរួមជាតិមេត្តាវិនិច្ឆ័យមើលចុះថា តើសឺង ង៉ុកថាញ់ បង្កើតទាហានស្មគ្រចិត្ត មួយកងវរសេនាតូចនេះ សម្រាប់ការពារជាតិ ឬសម្រាប់ការពារខ្លួនឯង? ហើយពួកទាហានស្មគ្រចិត្តទាំងអស់នោះ ក៏រត់ចោលវាអស់ដែរ ក្រោយពេលដឹងខ្លួនថា ពួកគេមិនមែនជាទាហានបម្រើប្រទេសជាតិ ពិតប្រាកដនោះ។ ករណីទាហានសឺង ង៉ុកថាញ់នេះ ក៏ដូចទាហានដាប ឈួន ដែរ ពួកគេលែងស្តាប់តាមបញ្ជាដោយដឹងថាចៅហ្វាយនាយរបស់ពួកគេ ក្បត់រាជបល្ល័ង្ក ហើយពួកគេបែរទៅប្រឆាំងនឹងដាប ឈួន វិញ។ ត្រង់នេះ សឲ្យឃើញថា ទាហានជាតិយើង ពិតជាស្រលាញ់ជាតិសាសនា និងព្រះមហាក្សត្ររបស់ខ្លួនប្រាកដមែន ពួកគេមិនព្រមចូលដៃជាមួយពួកក្បត់ ជាដាច់ខាត។ អ្វីដែលសឺង ង៉ុកថាញ់ អួតអាងថា ខ្លួនជាអ្នកស្នេហាជាតិនោះ កុំថាឡើយ យកទៅប្រៀបផ្ទឹមឥស្សរជនណាម្នាក់របស់ចលនាសង្គមរាស្ត្រនិយម មានសម្តេចព្រះបិតាឯករាជ្យជាតិជាប្រធាន សូម្បីតែយកទៅប្រៀបផ្ទឹមជាមួយពលទាហានរបស់ជាតិម្នាក់ក៏មិនអាចបានផង។

សឺង ង៉ុកថាញ់ អួតខ្លួនឯងថា ពូកែធ្វើនយោបាយខ្លាំងណាស់។ ដូច្នេះ បើសិនខ្លួនពូកែធ្វើនយោបាយមែន ម្ល៉េះមិនត្រូវបារាំង មកចាប់ឃ្លុំមាត់ច្រមុះ ដូចគេឃ្លុំគោក្របី យកទៅដាក់គុក នៅប្រទេសបារាំង នោះទេ។ បើសិនសឺង ង៉ុកថាញ់ ចង់ជួយកសាងប្រទេសជាតិមែន ម៉េចក៏មិនចូលមកក្នុងមហាសង្គមជាតិ? ម្តេចក៏បានតែព្រុសឡូឡាពីខាងក្រៅព្រំដែនមកវិញ? មាននរណាហាមឃាត់ មិនឲ្យខ្លួនចូលមកជួយកសាងប្រទេសជាតិ?។

កាលពីឆ្នាំ១៩៥៣ សម្តេចព្រះបិតាឯករាជ្យជាតិ បានហៅសឺង ង៉ុកថាញ់ ឱ្យមករួមជាកម្លាំង ដើម្បីទាមទារឯករាជ្យដែរ ខ្លួនបែរជាឆ្លើយថា ឱ្យព្រះអង្គទាមទារឯករាជ្យពីបារាំងបានសិន ទើបខ្លួនចូលមកក្នុងមហាសង្គមជាតិវិញ។ ប៉ុន្តែបើខ្លួនចូលមក ខ្លួនសុំព្រះអង្គនៅ

ឱ្យស្មៀម ទុកឲ្យខ្លួនធ្វើជាមេដឹកនាំប្រជារាស្ត្រ ដើម្បីទាមទារឯករាជ្យពីបារាំងនោះវិញ។ និយាយបែបនេះ តើសឹង ង៉ុកថាញ់ មានបំណងយ៉ាងណា?។

ពេលនេះ ប្រទេសខ្មែរយើងបានឯករាជ្យហើយ ខ្លួនក៏បានដឹងបានឮដែរថា រាជការត្រូវការអ្នកចេះដឹង ឲ្យជួយធ្វើការបម្រើជាតិ បើខ្លួនពូកែចូលមក កុំលក់ខ្លួនឱ្យបរទេសហើយអួតថា ខ្លួនគ្រាន់បើនោះ។ ខ្មែរស្គាល់ក្រយៅខ្លួនអស់ហើយ។ អួតខ្លួនឯងថា មានចំណេះវិជ្ជាខ្ពស់ តែបើខ្លួនមិនយកចំណេះវិជ្ជានោះ មកបម្រើរាស្ត្រ បម្រើជាតិមាតុភូមិទេ តើឲ្យគេចាត់ទុកថា ខ្លួនមានចំណេះវិជ្ជាខ្ពស់បានឬទេ?។

# ១២៩
# សម សារី មិនចង់ធ្វើទីប្រឹក្សារាជរដ្ឋាភិបាល ព្រោះមិនមានអំណាចដូចនាយករដ្ឋមន្ត្រី



**សម្តេចសីហនុ, ទ្រង់មុនីរ៉េត, ទ្រង់មុនីពង្ស, ប៉ែន នុត, ឡេង ង៉ែត និងសម សារី**

ទស្សនាវដ្តីអ្នកជាតិនិយម បានសរសេរបន្តថា ចំណែក សម សារី កាលដើមឡើយ ដោយសារចង់បានបុណ្យស័ក្តិពីសម្តេចព្រះឧបយុវរាជ ខ្លួនក៏បានទទួលស្គាល់នយោបាយអព្យាក្រឹតរបស់ព្រះអង្គដែរ តែសម សារី នេះជាមន្ត្រីពុករលួយសម្បើមណាស់ ប្រជាជាតិខ្មែរបានដឹងបានឮ បានស្គាល់ច្បាស់រហូតដល់ក្រយៅទៀតផង។ សម សារី ជាមនុស្សល្មោភប្រាក់ ទៅធ្វើការនៅកន្លែងណា ស្អុយឈ្មោះដូចលាមក ដោយសារប្រព្រឹត្តអំពើពុករលួយនៅកន្លែងនោះ។ កាលវាធ្វើការនៅសាលាក្រុង ល្បីឈ្មោះខាងបន្លំបំបាត់ប្រាក់រាជការ និងពុករលួយស៊ីសំណូកពីចិនយួន និងខ្មែរ បើជនណាទៅជួបវានិយាយដោះស្រាយពីការងារអ្វីមួយ ត្រូវយកស្រោមសំបុត្រពណ៌ក្រហមមានប្រាក់នៅក្នុងនោះផង ទើបនិយាយការងារនោះបានសម្រេច។ នៅសាលាក្រុងអ្នករាជការណា ក៏បានដឹងរឿងនេះដែរ។ កាល សម សារី ទៅធ្វើការនៅខេត្តកំពង់ចាម ប្រជារាស្ត្រអ្នកក្រីក្រអ្នកជំនួញចង់នាំគ្នាបះបោរវាយសំពងក្បាល

សម្លាប់វាចោលម្តងទៅហើយ ទើបរាជការផ្លាស់ឲ្យមកភ្នំពេញ ធ្វើការនៅក្រសួងវិញ។ មិនយូរប៉ុន្មាន វាបានបន្លំបំភាន់រាជការ ដោយដឹកគ្រាប់ម្រេចទៅក្រៅប្រទេស វាបន្លំបំភាន់ឯកសារថា ដឹកគ្រាប់គទៅវិញ ធ្វើឲ្យខាតប្រាក់ជាតិរាប់លានរៀល។

ពេលទៅរៀន នៅប្រទេសបារាំង ចន្លោះពីឆ្នាំ១៩៤៩ ដល់ឆ្នាំ១៩៥០ សម សារី បានញុះញង់ឱ្យនិស្សិតខ្មែរបែកបាក់សាមគ្គីគ្នា បង្កជាបក្ខជាពួក។ ពេលនោះដែរ វាបានរៀបចំធ្វើពិធីបុណ្យចូលឆ្នាំខ្មែរមួយ នៅក្នុងអគារស្នាក់នៅរបស់និស្សិតមកពីឥណ្ឌូចិន នៃសាកលវិទ្យាល័យប៉ារីស ដោយបានអញ្ជើញលោកហ្សង់ ឡឺទូណូ រដ្ឋមន្ត្រីទទួលបន្ទុកទឹកដីបារាំងនៅឯនាយសមុទ្រ(ប្រទេសស្ថិតនៅក្រោមអាណានិគមបារាំង)មកជាអធិបតី។ តែនេះជាឧបាយកលរបស់សម សារី សង្ឃឹមទុកថា ដល់ពេលវារៀនចប់ វិលត្រលប់មកដល់ប្រទេសខ្មែរវិញ រដ្ឋមន្ត្រីទទួលបន្ទុកទឹកដីបារាំង នៅឯនាយសមុទ្រ ស្គាល់វាច្បាស់ហើយនោះ នឹងជួយវាឱ្យឡើងធ្វើជាអ្នកធំ នៅប្រទេសខ្មែរ ជាមិនខាន។ នៅពេលនោះនិស្សិតខ្មែរជាច្រើនបាននាំគ្នាប្រឆាំងចំពោះល្បិចកលនេះដែរ តែមាននិស្សិតខ្លះ មិនបានដឹងល្បិចកលនេះ ក៏ចាញ់ បោកវាទៅ។

លុះត្រលប់មកដល់មាតុប្រទេសវិញ សម សារី ត្រូវបានតែងតាំងជាទីប្រឹក្សាព្រះរាជរដ្ឋាភិបាល (មានឋានៈស្មើនាយករដ្ឋមន្ត្រី) តែវាមិនចង់ទទួលយកឋានៈនេះទេ ព្រោះតំណែងជាទីប្រឹក្សានេះមិនមានអំណាចដូចនាយករដ្ឋមន្ត្រី ម្ល៉ោះហើយ វាក៏មានពុតត្បុតអាក្រក់ឆ្លៀតឱ្យបក្ខពួកដៃជើងវាទៅជ្រៀតជ្រែកកិច្ចការ នៅតាមក្រសួងនានា ដើម្បីរកផលប្រយោជន៍ផ្ទាល់ខ្លួន ធ្វើឱ្យរដ្ឋមន្ត្រីនៅតាមបណ្តាក្រសួងជាច្រើន នាំគ្នារអ៊ូរទាំគ្រប់ៗគ្នា។ ពេលធ្វើជាទីប្រឹក្សារាជរដ្ឋាភិបាលនោះដែរ សម សារី ក៏បានគប់គិតគ្នាជាមួយពួកបរទេស នាំចូលខ្សែភាពយន្តទំហំ៣៥មិល្លីម៉ែត្រ ដោយវានិយាយទូរសព្ទទៅបញ្ជាឱ្យទឹម ដុង ជារដ្ឋលេខាធិការក្រសួងឃោសនាការ កុំឱ្យយកពន្ធនាំចូលខ្សែភាពយន្តនោះ តែ ទឹម ដុង មិនព្រម ព្រោះបាត់ចំណូលថវិកាជាតិ ស្រាប់តែវានិយាយគំរាមថា បើវាប្រាប់ធ្វើអ្វី ត្រូវធ្វើតាមវាទៅ! តែទឹម ដុង ក៏ឆ្លើយតបទៅវិញថា ខ្ញុំទឹម ដុង គ្មានអ្វីត្រូវធ្វើតាមសម សារី ឯងទេ ហើយគ្មានអ្វី

ត្រូវស្តាប់បង្គាប់សម សារី ឯងដែរ។ សម សារី ខឹងណាស់ ក៏ទម្លាក់ទូរសព្ទឮសូរ ប្រ៉ាវ!។ មានថ្ងៃមួយ សម សារី បាន បានហៅមន្ត្រីជាន់ខ្ពស់ចំនួន៨នាក់ ទៅប្រជុំសម្ងាត់នៅជាន់លើរបស់ផ្ទះវា ដោយវាជឿក្នុងចិត្តថា វាអាចបោកប្រាស់ឱ្យវង្វេងទៅតាមវាបាន។ ក្រោយពីនិយាយបែកពពុះមាត់មក វាចាត់ឲ្យមន្ត្រីជាន់ខ្ពស់ខ្លះឱ្យទៅទូលសម្តេចសីហនុ ថា រដ្ឋមន្ត្រីមួយចំនួន សុំលាលែងពីតំណែង ដោយសារពួកគេចង់បានវាធ្វើនាយករដ្ឋមន្ត្រី។ តែគ្មាននរណាទៅធ្វើតាមអណ្តាតឆ្កែរបស់វាទេ ហើយគ្រោងការគាត់ក៏ត្រូវរលាយសូន្យទៅ។

ត្រង់នេះសបញ្ជាក់ឲ្យឃើញថា សម សារី មិនចង់ធ្វើជាទីប្រឹក្សារាជរដ្ឋាភិបាលទេ ព្រោះមិនមានអំណាចផ្ទាល់ដើម្បីរកប្រយោជន៍ផ្ទាល់ខ្លួន គឺវាចង់ធ្វើនាយករដ្ឋមន្ត្រី ដូចសឺង ង៉ុកថាញ់ លក់ប្រទេសខ្មែរឱ្យបរទេស ដើម្បីបានប្រយោជន៍ផ្ទាល់ខ្លួន។ ពេលព្រះមហាក្សត្រតែងតាំងវាឱ្យទៅធ្វើឯកអគ្គរាជទូតនៅប្រទេសអង់គ្លេស វាគិតតែដើរលេងហ៊ឺហា ចូលក្លឹបកំសាន្តរាត្រី ហើយពួកនាងៗនៅក្លឹបកំសាន្តរាត្រីនោះ តែងហៅវាថា ព្រះករុណាសម ( សម សារី) ព្រោះឃើញវាចាយប្រាក់ដូចចាយសម្បកលៀស គ្មានមន្ត្រីទូតប្រទេសណាធ្វើដូចវាបានឡើយ។ លុះដល់ពេលបែកធ្លាយរឿងអាស្រូវ រាជការឱ្យឆែកឆេរថវិការដ្ឋ នៅស្ថានទូតឃើញថា វាចាយវាយខ្ជះខ្ជាយ គ្មានបញ្ជីស្នាមថា ត្រូវចាយវាយទៅលើអ្វីឱ្យច្បាស់លាស់នោះទេ។ ក្រោយមកទៀត វាបានវាយស្ត្រីខ្មែរម្នាក់ឈ្មោះអ៊ីវ អេងសេង ដែលវាចាត់ទុកថាជាស្រីបម្រើធ្វើការនៅផ្ទះវាផង និងជាប្រពន្ធចុងវាផង។ តាំងពីដើមមក ស្ត្រីៗជាអ្នកបម្រើនៅផ្ទះសម សារី ទាំងប៉ុន្មាន តែងត្រូវវាជេរបញ្ឆោរគ្រប់គ្នា ដោយគ្មាននរណាហ៊ានប្រកែកតវ៉ាមួយម៉ាត់ឡើយ បើមិនដូច្នេះទេ ច្បាស់ជាត្រូវវាទះកំផ្លៀងឬត្រូវវាយទាត់ជាក់ជាមិនខាន។

ក្រោយពីវាយជំនាងអ៊ីវ អេងសេង រួច វាបានបណ្តេញនាងនោះឱ្យចេញពីផ្ទះ ហើយវាប្រកាសប្រាប់អ្នកកាសែតនៅក្រុងឡុងដ៍ ថា ស្រុកខ្មែរគេតែងអប់រំស្រីបម្រើបែបនេះ។សូមជនរួមជាតិជួយពិចារណាចុះ សម សារី ត្រូវបានព្រះករុណាព្រះមហាក្សត្រ តែងតាំងឱ្យទៅធ្វើជាព្រះរាជតំណាងរបស់ព្រះអង្គ និងជាតំណាងប្រជាជាតិខ្មែរទាំងមូល នៅប្រទេសអង់គ្លេសមិនគួរមានចិត្តគំនិតដូចតិរច្ឆានយ៉ាងនេះ តើឲ្យរាជរដ្ឋាភិបាលទុកឲ្យវាធ្វើជាឯកអគ្គរដ្ឋទូត

នៅប្រទេសអង់គ្លេសនោះ តទៅទៀតបានដែរឬទេ? ឃើញថា ទុកមិនបានទេ។

ពេលនោះ រាជរដ្ឋាភិបាលក៏បានជួយបិទបាំងរឿងស្អុយរលួយនេះ ដោយមិនឲ្យឮសុសសាយទៀតផង តែផ្ទុយទៅវិញ នៅពេលវាមកមាតុប្រទេសវិញ វាគាស់កកាយប្រមាថមើលងាយសម្តេចព្រះបិតាឯករាជ្យ ដោយតាំងខ្លួនវាហាក់ដូចជាអ្នកដឹកនាំកំពូលលើប្រជា-រាស្ត្រខ្មែរទាំង៥លាននាក់ ទៅវិញ។ ជាមួយគ្នានោះ វាបានសរសេរសំបុត្រទៅជេរជៀលច្បាប់រដ្ឋធម្មនុញ្ញរបស់ប្រទេសអង់គ្លេស ថែមទៀតផង ហើយត្រូវបុគ្គលិកធ្វើការនៅស្ថានទូតអង់គ្លេស ប្រចាំប្រទេសខ្មែរ លួចយកឲ្យដំណឹងនេះមកថ្វាយសម្តេចព្រះបិតាឯករាជ្យផងដែរ។

ដូច្នេះឃើញថា សម សារី ជាមនុស្សអកតញ្ញូ ជាមនុស្សគ្មានសីលធម៌ក្នុងខ្លួន ដូចជាសត្វគ្មានដឹងដប់ម្តៃ។ ដោយសារមោរយាទយ៉ាងនេះហើយ បានជារាជរដ្ឋាភិបាល មិនឱ្យវាធ្វើការអ្វីតទៅទៀត។ តាំងពីពេលនោះមក វាក៏ដើរប្រមូលបក្ខ ពួកជាកូនសិស្ស ជាជនអកុសលជាពួកអស់ផ្លូវដើរ និងជាពួកមានរឿងជាប់ចោទពីបទល្មើសផ្សេងៗ ដើម្បីធ្វើសកម្មភាពប្រឆាំង នឹងរាជរដ្ឋាភិបាល ប្រឆាំងនឹងរាជបល្ល័ង្ក ក្នុងបំណងលក់ប្រទេសជាតិឲ្យបរទេស។

ចំណែកពួកបរទេសវិញ ពេលគេឃើញខ្មែរណា បង្ករឿងជាមួយខ្មែរគ្នាឯង គេក៏យកខ្មែរនោះទៅចិញ្ចឹមឲ្យប្រាក់ខែ ដើម្បីឲ្យខ្មែរនោះធ្វើការឲ្យគេ ដើម្បីប្រឆាំងនឹងខ្មែរគ្នាឯង។ ឥឡូវនេះ សម សារី បានរត់គេចខ្លួនចេញពីប្រទេស ទៅលក់ខ្លួនឱ្យបរទេស ហើយប្រកាសថា ខ្លួនជាខ្មែរសេរី ទៀតផង។

# ១៣០
# សម្តេចសីហនុ ថា៖ សម សារី និងសឹង ង៉ុកថាញ់ ជាជនក្បត់ជាតិ




**សម្តេចសីហនុ** (រូបថត Getty images)

ទស្សនាវដ្តីអ្នកជាតិនិយម បានបន្តទៀតថា យើងសូមឆ្លើយតបទៅជនក្បត់ជាតិ សម សារី និងសឹង ង៉ុកថាញ់ ដូចទៅ៖

១. តើពួកក្បត់សម សារី និងសឹង ង៉ុកថាញ់ ខំតស៊ូរកអ្វីទៀត បើប្រទេសខ្មែរបាន

ឯករាជ្យហើយ គ្មាននៅក្រោមនឹមអាណានិគមបរទេសណាមួយទៀតទេនោះ?។ ចំណែក ប្រជាជាតិខ្មែរទាំងអស់ ក៏គ្មានរឿងអ្វីដែលត្រូវទៅចូលរួមតស៊ូអ្វីជាមួយសម សារី និងសឹង ង៉ុកថាញ់ នោះដែរ ព្រោះខ្មែរទូទាំងប្រទេសបានដឹងច្បាស់ណាស់ហើយថា ការខំតស៊ូរបស់ពួកក្បត់ទាំង២នាក់នេះ គ្មានអ្វីក្រៅពីដើម្បីយកប្រទេសជាតិទៅលក់ឲ្យនៅជាខ្ញុំកញ្ជះបរទេស នោះឡើយ ហើយពេលមានជ័យជម្នះ សម សារី និងសឹង ង៉ុកថាញ់ នឹងចែកកៅអីលឿងគ្នាអង្គុយ និងមានឱកាសធ្វើបាបរាស្ត្រទៅតាមអំពើចិត្តរបស់ខ្លួនឬ? ខ្មែរទូទាំងប្រទេសបានដឹងពីប្រវត្តិ និងចំណុចខ្សោយរបស់ខ្លួនអស់ហើយ ដឹងទាំងសម សារី ប្រើឈ្មោះជាយួនថា ង្វៀង យ៉ាំងសាំ ទៀតផង។

យើងសូមផ្តាំទៅសម សារី និងសឹង ង៉ុកថាញ់ ថា បើល្មមឈប់បាន ក៏ឈប់ទៅ ការដែលខ្លួនប្រឹងប្រែងឃោសនាបោកបញ្ឆោតខ្មែរ គឺការឥតប្រយោជន៍ទេ ទាំងបរទេសដែលគេជាអ្នកទិញខ្លួន ជួយឧបត្ថម្ភគាំទ្រខ្លួន ក៏គេពុំទុកចិត្តថាខ្លួនថា ធ្វើការបានសម្រេចឲ្យគេនោះដែរ ហើយខ្លួនឯងក៏ដឹងស្រាប់ហើយថា សព្វថ្ងៃនេះ គេបានទាំងកាត់បន្ថយជំនួយមកលើខ្លួនទៀតផង ដូច្នេះកុំបំប៉ោងខ្លួនដូចហ៊ឹង ក្រែងស្លាប់ខ្លួន។ តើតស៊ូរកអ្វី ? មានតែតស៊ូរកកៅអីដែលគេទម្លាក់ខ្លួនដោយប្រព្រឹត្តអំពើពុករលួយនោះឯង។

២. សម សារី និងសឹង ង៉ុកថាញ់ អួតថា ខ្លួនគេជាខ្មែរសេរី គឺជាការភាន់ច្រឡំទាំងស្រុង ព្រោះខ្មែរសេរី គឺជាខ្មែរដែលមិនក្បត់ជាតិសាសនា និងព្រះមហាក្សត្រ រស់នៅដោយសេរីលើផ្ទៃប្រទេសកម្ពុជាឯករាជ្យ។ ពួកខ្លួនមិនមែនខ្មែរសេរីទេ តែថាជាពួកខ្មែរព្រៃ ខ្មែរគ្មានសេរី ទើបសមជាង ព្រោះខ្លួនជាខ្មែរក្បត់ជាតិ ខ្មែរប្រឆាំងនឹងរាជការជាតិ និងរាជបល្ល័ង្ក រត់ចូលព្រៃទៅជ្រកនៅបរទេសផ្លាស់ឈ្មោះជាបរទេស លក់ខ្លួនជាខ្ញុំកញ្ជះបរទេស ធ្វើការឲ្យបរទេស តើសេរីស្ថិតនៅលើមនុស្សបែបហ្នឹងដូចម្តេចកើត?។

ពួកក្បត់ទាំងនេះពិតជាគ្មានសេរីអ្វីបន្តិចទាល់តែសោះ ដូច្នេះល្មមលែងច្រៀងចម្រៀងបែបនេះទៀតទៅ ឥតប្រយោជន៍ទេ។ មួយចំណែកទៀត ទោសនៃអំពើក្បត់នេះ ពន្ធនាគារបានរៀបបម្រុងកន្លែងទុកសម្រាប់ពួកខ្លួនជាស្រេចហើយ ហើយប្រជាជាតិខ្មែរទូទាំងប្រទេស

មិនអនុញ្ញាតឲ្យរួចខ្លួនទេ ឧទាហរណ៍ដូចជាជនក្បត់ជាតិ ដាប ឈួន ជាមិត្តភក្តិខ្លួនស្រាប់ត្រូវរាស្ត្រវិនិច្ឆ័យ ដោយមិនចាំបាច់រាជការឡើយ។ តែសម សារី ដែលមានពួកបរទេសជាអ្នក ជួយបិទបាំងនិងជម្លៀសចេញទៅក្រៅប្រទេសនោះ បើត្រលប់ចូលស្រុកវិញ មុខជាទទួលបានសំណាងដូចដាប ឈួន ជាមិនខាន។

៣. ពួកគេបានលើកឡើងថា ខ្មែរមិនត្រូវប្រកាន់នយោបាយអព្យាក្រឹតទេ។ ចំពោះសម្តីនេះប្រជាជាតិយើងទូទាំងប្រទេសដែលស្រលាញ់អព្យាក្រឹតភាព ពេញចិត្តចំពោះនយោ-បាយអព្យាក្រឹតនេះខ្លាំងណាស់ និងសូមឱ្យសម្តេចព្រះបិតាឯករាជ្យជាតិ រក្សាមាគ៌ានយោបាយនេះបន្តទៅទៀត ដើម្បីអភិវឌ្ឍប្រទេសជាតិឱ្យបានរីកចម្រើន ដែលផ្ទុយស្រឡះពីសឺង ង៉ុកថាញ់ និងសម សារី ពុំមែនជាអ្នកស្រលាញ់អព្យាក្រឹត ដូចប្រជាជាតិខ្មែរទូទាំងប្រទេសនោះឡើយ។ សឺង ង៉ុកថាញ់ និងសម សារី គឺជាជនក្បត់ជាតិ ព្រោះប្រឆាំងនឹងឆន្ទៈរបស់ប្រជារាស្ត្ររាប់លាននាក់។ ក្បត់ព្រះរាជបល្លង្ក ព្រោះប្រឆាំងព្រះមហាក្សត្រនឹងសម្តេចព្រះបិតាឯករាជ្យជាតិ ដែលព្រះអង្គបានប្រកាន់មាគ៌ានយោបាយអព្យាក្រឹត ដើម្បីរក្សាការពារប្រជារាស្ត្រ ការពារប្រទេសដ៏តូចរបស់យើងឲ្យគេចផុតពីភ្លើងសង្គ្រាម ឲ្យបានសុខសន្តិភាពដល់ប្រជារាស្ត្រទូទៅ។

សរុបសេចក្តីមក សឺង ង៉ុកថាញ់ និងសម សារី ជាជនក្បត់ជាតិយ៉ាងជាក់ស្តែងដោយបានលក់ខ្លួនឱ្យបរទេស ដើម្បីប្រឆាំងបំផ្លិចបំផ្លាញអព្យាក្រឹត្យភាពរបស់ខ្មែរយ៉ាងពិតប្រាកដ។

៤. ពួកគេលើកឡើងថា សម្តេចព្រះបិតាឯករាជ្យជាតិបានឱ្យពួកកុម្មុយនិស្តចូលមកត្រួតត្រានៅពាសពេញប្រទេស ហើយបានបញ្ចេញឲ្យពួកកុម្មុយនិស្តនេះទៅធ្វើបាបប្រជារាស្ត្រវៀតណាម និងថៃ ទៀតផង។ ចំពោះពាក្យចោទប្រកាន់របស់សឺង ង៉ុកថាញ់ និងសម សារី ដូចខាងលើនេះ គឺពុំពិតទាល់តែសោះ ព្រោះពួកកុម្មុយនិស្តមាននៅឯប្រទេសវៀតណាមខាងជើង និងប្រទេសចិន ឯណោះ ហើយខ្មែរយើងមិនមានព្រំប្រទល់ជាប់ជាមួយប្រទេសទាំងពីរនោះផង គឺជាប់តែជាមួយប្រទេសវៀតណាមខាងត្បូង ប៉ុណ្ណោះ។

# របត់នយោបាយ

ប្រសិនបើពួកកុម្មុយនិស្តចូលមកកាន់កាប់ប្រទេសខ្មែរមែន មុខជាពួកនេះនឹងដើរកាត់តាមដែនដីប្រទេសវៀតណាមខាងត្បូង ពុំខាន ហើយប្រទេសវៀតណាមខាងត្បូង មុខជាដឹងយ៉ាងពិតប្រាកដ ដោយសារគេមានទាហានច្រើន អាចវាយធ្វើជារបងពេញទឹកដីគេ ចុះហេតុអ្វី ក៏វៀតណាមខាងត្បូង ពុំមានការតវ៉ាចំពោះរឿងនេះ?។ នេះជាភ័ស្តុតាងមួយបញ្ជាក់ឲ្យឃើញថា ពាក្យចោទប្រកាន់របស់ជនក្បត់ទាំង២នាក់នេះពុំសមហេតុផលទេ។ តែការពិតគឺសឹង ង៉ុកថាញ់ និងសម សារី នេះឈឺចិត្តជួសយួន និងថៃ ហើយបានបង្កើតកងទ័ពនៅបរទេស ឱ្យចូលមករួមជាមួយកម្លាំងដាប ឈួន ដើម្បីវាយប្រទេសខ្មែរយកឲ្យទៅយួន និងសៀម ជាចៅហ្វាយរបស់ខ្លួនតែប៉ុណ្ណោះ។

រឿងនេះពិតណាស់ ព្រោះដាប ឈួន បានសង់បន្ទាយបាន៣កន្លែង ដើម្បីចាំទទួលកងទ័ពសឹង ង៉ុកថាញ់ និងសម សារី តែត្រូវកងទ័ពជាតិយើងទៅដុតបំផ្លាញអស់ ព្រមទាំងសម្លាប់ដាប ឈួន ឲ្យងាប់ដូចខ្មោចឆ្កែទៀតផង។ រឿងសឹង ង៉ុកថាញ់ និងសម សារី ក្បត់ជាតិ និងព្រះរាជបល្ល័ង្កនេះ មានកងទ័ពជាតិយើងជាសាក្សីស្រាប់ ដូច្នេះ សូមជនរួមជាតិមេត្តាវិនិច្ឆ័យចុះ។ ម្យ៉ាងទៀតក្នុងឋានៈជាប្រទេសអព្យាក្រឹត យើងត្រូវតែទទួលស្គាល់គ្រប់ប្រទេសតូចធំ គ្រប់ពណ៌នយោបាយ ទោះបីលោកសេរីក្តី លោកកុម្មុយនិស្តក្តី ឬលោកអព្យាក្រឹតដូចគ្នាក្តី គឺដើម្បីរក្សានូវខឿនឯករាជ្យអព្យាក្រឹតរបស់ប្រទេសតែប៉ុណ្ណោះ។

ដូច្នេះហើយបានជាយើងមានស្ថានទូតមកពីប្រទេសតូចធំនានា គ្រប់ពណ៌នយោបាយនៅក្នុងប្រទេសយើង ជាភ័ស្តុតាងមួយបញ្ជាក់ឲ្យឃើញថា ខ្មែរពិតជាកាន់នយោបាយអព្យាក្រឹតយ៉ាងបរិសុទ្ធ គ្មានពួកកុម្មុយនិស្តនៅពាសពេញប្រទេស ដូចពាក្យចោទប្រកាន់របស់ជនក្បត់នោះទេ។

សឹង ង៉ុកថាញ់ និងសម សារី មិនខ្មាសពួកបរទេសទៅក្នុងពិភពលោកនេះទេ ឬព្រោះខ្លួនឯងជាខ្មែរ មិនគួរអ្វីចង់លើកទ័ពមកវាយប្រទេសខ្មែរ យកទៅឱ្យយួន និងសៀម ដោយយកលោកសេរី មកបាំងមុខធ្វើជាខែលដូច្នេះសោះ។ ចំណែកលោកសេរី មានអាមេរិកាំង ជាមិត្តនឹងប្រទេសយើងស្រាប់ ព្រោះយើងជាប្រទេសកាន់អព្យាក្រឹតពិតប្រាកដ ខណៈពួក

ក្បត់ទាំងពីរនាក់នេះគ្រាន់តែជាខ្ញុំកញ្ជះបរទេសតែប៉ុណ្ណោះ កុំអួតថា ខ្លួនជាអ្នកដឹកនាំជាតិឲ្យចូលលោកសេរីនោះ គឺមានតែពួកបរទេសមួយចំនួនដែលមិនបានដឹងពីគំនិតអាក្រក់របស់សឺង ង៉ុកថាញ់ និងសម សារី អាចនឹងជឿពួកខ្លួនខ្លះៗដែរ តែចំពោះយើងដែលជាតិខ្មែរបានដឹងច្បាស់ពីសកម្មភាពជនក្បត់ទាំង២នាក់នេះ ហើយថែមទាំងមានភ័ស្តុតាងសព្វគ្រប់ទៀតផងនោះ គឺមិនជឿជាដាច់ខាត។

សូមពួកបរទេសជាមិត្តទាំងឡាយ កុំជឿការបោកប្រាស់របស់ខ្មែរក្បត់ជាតិទាំងពីរនាក់នេះពេក ក្រែងឃ្លាតចាកពីមិត្តជាមួយប្រជារាស្ត្រខ្មែរ នាំឲ្យពិបាកទាំងអស់គ្នា ដូចជាយើងដែលជាប្រជារាស្ត្រខ្មែររងទុក្ខលំបាកវេទនាអស់រយៈពេលចំនួន៧ឆ្នាំគត់ ទើបដឹងខ្លួនថាចាញ់បោកបញ្ឆោតនយោបាយវាទាំង២នាក់នេះ។ ឥឡូវនេះអាចង្រៃពីរនាក់នេះ វាគិតតែលើកទ័ពមកវាយខ្មែរនៅក្នុងពេលដែលស្រុកខ្មែរកំពុងសុខសាន្តត្រាណ ក្នុងពេលដែលខ្មែរយើងទាំងប្រុសទាំងស្រីទាំងក្មេងទាំងចាស់នាំគ្នាប្រកបការងារសព្វគ្រប់យ៉ាង ដើម្បីកសាងប្រទេសឱ្យជឿនលឿនទាន់សម័យនិយម។ ប្រជាជាតិខ្មែរទូទាំងប្រទេសដែលស្គាល់ប្រវត្តិសាស្ត្រ និងស្គាល់គំនិតដ៏លាមកអាក្រក់របស់សឺង ង៉ុកថាញ់ និងសម សារី យ៉ាងច្បាស់ក្រឡែតនោះ ទោះបីពួកវាខំឃោសនាដោយមធ្យោបាយយ៉ាងក៏ដោយ ក៏ប្រជាជាតិខ្មែរទាំងអស់មិនស្តាប់ហើយប្រឆាំងចំពោះពួកអាក្បត់ទាំង២នេះជាដាច់ខាត។ បើដឹងដូច្នេះ ពួកអាក្បត់ទាំង២នេះគួរតែវិលក្បាលទៅប្រឆាំងនឹងពួកបរទេសដែលអ្នកទិញក្បាលខ្លួននោះម្តងវិញ បើខ្លួនចំណាប់ខាងខូចខាងខិល ដើម្បីឲ្យបានជាប្រយោជន៍មកដល់ប្រទេសជាតិមាតុភូមិខ្លះផង កុំចំណាប់ខាងខូចខាងខិលធ្វើឱ្យរលាយប្រទេសជាតិនោះ។

ទន្ទឹមនឹងអត្ថបទអត្ថាធិប្បាយនយោបាយរបស់សម្តេចសីហនុ វាយបកទៅលើសឺង ង៉ុកថាញ់ និងសម សារី នៅលើទំព័រទស្សនាវដ្តីអ្នកជាតិនិយមរបស់ព្រះអង្គដូចខាងលើនេះដែរ នៅតាមសាលាបឋមសិក្សានានាគេបានបំផុសឱ្យកូនសិស្សនាំគ្នាសូត្រមេសូត្រត់មាត់ដែលគេនិពន្ធបំភ្លែថា៖ សារីឆ្កែខ្ញុំ មិនតូចមិនធំ រាងទ្រើសជាងឆ្មា ត្រចៀកកញ្ជ្រឹប មិនមូលដូចខ្លា ស៊ីឆ្អែតកាលណា បែរខាំម្ចាស់វិញ...។ នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៥៩ សម្តេច

សីហនុ ក៏បានស្នើសុំការយល់ព្រមពីរដ្ឋសភារៀបចំការបោះឆ្នោតធ្វើប្រជាមតិមួយ ដើម្បីឱ្យប្រជារាស្ត្រខ្មែរទូទាំងប្រទេសបោះឆ្នោតសម្តែងឆន្ទៈថា រវាងនយោបាយអព្យាក្រឹតរបស់ព្រះអង្គ និងពួកមេដឹកនាំចលនាខ្មែរសេរី សឺង ង៉ុកថាញ់ និងសម សារី ដែលលម្អៀងទៅសហរដ្ឋអាមេរិក ព្រមទាំងពួកកុម្មុយនិស្តផងដែរ តើប្រជារាស្ត្រខ្មែរជ្រើសរើសយកមួយណា?។

លទ្ធផលនៃការបោះឆ្នោតនោះ សម្តេចសីហនុ បានទទួលការគាំទ្រចំនួន២០២០៥៤៩ សំឡេង, ពួកខ្មែរសេរី សឺង ង៉ុកថាញ់ និងសម សារី បានទទួលការគាំទ្រត្រឹមតែ១៣៣ សំឡេង។ ចំណែកពួកកុម្មុយនិស្តនិយម បានទទួលការគាំទ្រត្រឹមតែ១៣៣ដូចគ្នា។

# ១៣១
# ខៀវ សំផន កំពុងជិះកង់តាមផ្លូវ ត្រូវគេស្ទាក់វាយ សម្រាតខោអាវ



**ខៀវ សំផន**

នៅពាក់កណ្ដាលខែកញ្ញា ឆ្នាំ១៩៥៩ ក្រោយទទួលបានសញ្ញាបត្របណ្ឌិតសេដ្ឋកិច្ច នៅប្រទេសបារាំង ខៀវ សំផន បានវិលត្រលប់មកមាតុប្រទេសវិញ និងបម្រើការងារជាសាស្ត្រាចារ្យនៅមហាវិទ្យាល័យសេដ្ឋកិច្ច និងនីតិសាស្ត្រ នៅក្រុងភ្នំពេញ ហើយឆ្លៀតទៅបង្រៀនភាសាបារាំង នៅវិទ្យាល័យឯកជនចម្រើនវិជ្ជា និងវិទ្យាល័យឯកជនកម្ពុជបុត្រ ដែលជាសម្បុកពួកកុម្មុយនិស្ត ជាមួយអៀង ធីរិទ្ធ (ប្រពន្ធ អៀង សារី)ផងដែរ។ បន្ទាប់មក គាត់បានបង្កើតកាសែតជាភាសាបារាំងមួយឈ្មោះអ្នកសង្កេតការណ៍ (Observateur) ទៀតផងដែរ។

ក្នុងឆ្នាំ១៩៥៩នោះដែរ ស៊ីវ ហេង អស់ទឹកចិត្តតស៊ូ ដោយឃើញប្រទេសជាតិមាន

ឯករាជ្យ និងស្ថិរភាព ហើយចលនាតស៊ូរបស់គាត់ក៏គ្មានអ្វីរឹងមាំគួរឱ្យសង្ឃឹមដែរ។ ក្រោយពីគាត់រស់នៅផ្ទះមួយក្បែរផ្ទះទូ សាមុត ក្នុងទីក្រុងភ្នំពេញមួយរយៈខ្លី គាត់ក៏សម្រេចចិត្តចុះចូលជាមួយសម្ដេចសីហនុ ត្រលប់ទៅជួបប្រពន្ធកូននៅឯខេត្តបាត់ដំបង ប្រកបមុខរបរធ្វើស្រែចម្ការ វិញ។ ប៉ុន្តែមិត្តរួមការតស៊ូរបស់គាត់បានធ្វើការចោទប្រកាន់ថា គាត់បោះបង់បដិវត្តន៍សុខចិត្តដើរតាមវណ្ណៈសក្តិភូមិជាអ្នកកាន់អំណាច ដែលមានសម្ដេចសីហនុ ជាអ្នកដឹកនាំ ហើយគាត់បានរាយការណ៍ពីកម្លាំងតស៊ូសម្ងាត់ឱ្យអាជ្ញាធរសម្ដេចសីហនុ ដើម្បីចាប់ខ្លួនទៀតផង។

ចំណែក ចាន់ តារា អតីតមេខ្មែរឥស្សរៈដែលបោះបង់ចោលការតស៊ូ មករស់នៅជួបជុំប្រពន្ធកូន ធ្វើស្រែនៅក្នុងខេត្តកំពង់ឆ្នាំង តាំងពីឆ្នាំ១៩៥២ និងអតីតសកម្មជនគណបក្សប្រជាធិបតេយ្យ ព្រមទាំងបក្ខពួកដាប ឈួន មួយចំនួនទៀត ក៏ត្រូវអាជ្ញាធរចាប់យកទៅដាក់ពន្ធនាគារម្នាក់ៗរយៈពេល៣ឆ្នាំ។ ក្រោយពីស៊ីវ ហេង បានទៅចុះចូលជាមួយសម្ដេចសីហនុ មក ទូ សាមុត ជាលេខាគណៈកម្មាធិការបក្សទីក្រុងភ្នំពេញ ត្រូវបានតែងតាំងជាលេខាគណៈកម្មាធិការបក្សទទួលខុសត្រូវទូទាំងប្រទេស ហើយមានគម្រោងបើកមហាសន្និបាតបក្សលើកទី២ នៅក្នុងឆ្នាំ១៩៥៩ នោះផងដែរ ប៉ុន្តែគម្រោងបើកមហាសន្និបាតរៀបចំបក្សឡើងវិញនោះ ត្រូវពន្យារពេលរហូតដល់ខែកញ្ញា ឆ្នាំ១៩៦០។

នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៥៩ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ពាក្យបណ្ដឹងទៅតុលាការអន្តរជាតិទីក្រុងឡាអេ ប្រទេសស្វីស ដើម្បីទាមទារប្រាសាទព្រះវិហារ ដែលកងទ័ពថៃ ចូលមកដណ្ដើមកាន់កាប់យ៉ាងព្រហើនកោងកាចបំផុត។

នៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៥៨ ណុប បូផាន់ និពន្ធនាយកកាសែតប្រជាជន ត្រូវឃាតករមិនស្គាល់មុខ បាញ់សម្លាប់នៅខាងមុខការិយាល័យរបស់គាត់ផ្ទាល់តែម្ដង។ នៅថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៥៩ សម្ដេចសីហនុ បានប្រកាសថ្កោលទោសជាសាធារណៈចំពោះអំពើឃាតកម្មដ៏ព្រៃផ្សៃនេះដែរ។ ប៉ុន្តែ ឡុង បូរ៉េត ពេលនោះជារដ្ឋលេខាធិការក្រសួងឃោសនាការ បានឆ្លៀតឱកាសធ្វើការរិះគន់ចំពោះបណ្ដាកាសែតមួយដែលមាននិន្នាការ

ឆ្វេងនិយម ដោយមិនបានបញ្ចេញឈ្មោះកាសែតទាំងនោះថា បានយកបញ្ហាឃាតកម្មនេះ ដើម្បីទម្លាក់កំហុសមកលើរាជរដ្ឋាភិបាលទៅវិញ។

មជ្ឈដ្ឋានខ្លះបានដាក់ការសង្ស័យថា អ្នកបញ្ជាឱ្យបាញ់សម្លាប់ណុប បូផាន់ និពន្ធនាយកកាសែតប្រជាជននោះ គឺលន់ នល់ ជារដ្ឋមន្ត្រីការពារប្រទេស ព្រោះអំពើឃាតកម្មនេះ បានកើតឡើងក្រោយពេលដែលសម្ដេចសីហនុ បានមានបន្ទូលប្រាប់ លន់ នល់ ថា កាសែតប្រជាជននេះ បង្កឱ្យមានការលំបាកដល់ប្រទេសជាតិ និងព្រះអង្គច្រើនណាស់។ ចំណែកកាសែតជាភាសាបារាំង អ្នកសង្កេតការណ៍ (Observateur) ត្រូវបាន ឡុង បូរ៉េត រដ្ឋលេខាធិការក្រសួងឃោសនាការ ធ្វើការកត់សម្គាល់ថា ខៀវ សំផន ជាអ្នកសរសេរអត្ថបទសំខាន់ៗនៅក្នុងកាសែតនោះ តែមិនហ៊ានដាក់ឈ្មោះខ្លួនឯង។

អត្ថបទទាំងឡាយដែលខៀវ សំផន សរសេរចុះផ្សាយលើទំព័រកាសែតអ្នកសង្កេត-ការណ៍ (Observateur) ត្រូវបានអ្នកនិយមអាន និងនិយាយភាសាបារាំង ពិសេសគឺពួកឥស្សរជន មន្ត្រីរាជការ សិស្សនិស្សិត មានការជក់ចិត្តយ៉ាងខ្លាំង ព្រោះគាត់សរសេរតាមទម្រង់ជាកាសែតបែបទាន់សម័យ ដោយឆ្លុះបញ្ចាំងឱ្យឃើញពីគំនិតថ្មីៗ មិនដូចកាសែត ជាច្រើនទៀតដែលសរសេរអត្ថបទគ្រាន់តែដើម្បីលើកបញ្ជោរសម្ដេចសីហនុ តែប៉ុណ្ណោះ។

ខៀវ សំផន បានសរសេរអត្ថបទតាមបែបសង្គមសាស្ត្រ ដោយបានលាតត្រដាងឱ្យឃើញពីជីវិតពិតរបស់អ្នកដែលអត់ការងារធ្វើ ពីពួកអ្នកញៀនស្រា និងពីការលក់ពលកម្មរបស់ក្មេងៗ មិនទាន់គ្រប់អាយុធ្វើការ នៅក្នុងទីក្រុងភ្នំពេញ។ តែគាត់មិនបានសរសេរអត្ថបទរិះគន់ ឬវាយប្រហារឱ្យខ្លាំងក្លារទៅលើសម្ដេចសីហនុ ម្ដងណាទេ ព្រោះគាត់ខ្លាចគេចាប់ខ្លួនបញ្ជូនទៅឱ្យតុលាការកាត់ទោសដាក់ពន្ធនាគារ។ តែទោះបីយ៉ាងនេះក៏ដោយ ក៏សម្ដេចសីហនុ បានហៅគាត់ និងសហការីគាត់ថា ជាជនដែលលម្អៀងទៅខាងកុម្មុយនិស្តដែរ។

អៀង ធីរិទ្ធ បានជួយផ្ដល់ប្រាក់កាសមួយភាគដែលបានមកពីការបង្រៀននៅវិទ្យាល័យឯកជនកម្ពុជបុត្រ ដើម្បីជួយបោះពុម្ពកាសែតអ្នកសង្កេតការណ៍(Observateur)ជាភាសា

បារាំង ដែលមានខៀវ សំផន ជាចាងហ្វាងនោះបានចេញផ្សាយជាប់ជាប្រចាំដែរ។ អៀង ធីរិទ្ធ បានរម្លឹកឱ្យដឹងថា កាលសម័យនោះ គាត់អាចបង្រៀនម៉ោងបន្ថែមបានច្រើនម៉ោង ហើយប្រាក់កម្រៃដែលបានមកពីការបង្រៀននោះ គាត់អាចយកទៅសង់វីឡា ឬក៏ទិញរថយន្តជិះបានដោយងាយបំផុត តែគាត់ត្រូវយកលុយដែលបានមកពីការបង្រៀននោះ ទៅជួយទ្រទ្រង់កាសែតរបស់ពួកគាត់វិញ។ ជាមួយគ្នានោះ សម្តេចសីហនុ ក៏មានព្រះទ័យចង់រាប់អានអៀង ធីរិទ្ធ និងក្រុមគ្រួសារ ហើយក៏ចង់ឱ្យគាត់កាន់តំណែងណាមួយក្នុងរាជរដ្ឋាភិបាលទៀតផង តែគាត់មិនអាចទទួលយកបានទេ ព្រោះបក្សរបស់គាត់មិនអនុញ្ញាត។

ពេលនោះដែរ អៀង ធីរិទ្ធ យល់ថា មេដឹកនាំចិនដែលកំពុងមានការជិតស្និទ្ធជាមួយសម្តេចសីហនុ បានបោះបង់ចោលពួកគាត់ទៅហើយ គាត់បានសាកល្បងសុំខ្ចីលុយចំនួនមួយម៉ឺនរៀល ពីឯកអគ្គរដ្ឋទូតសហភាពសូវៀត ជាប្រទេសមហាអំណាចកុម្មុយនិស្តមួយដែរ ប្រចាំនៅទីក្រុងភ្នំពេញ ប៉ុន្តែ ត្រូវបានឯកអគ្គរដ្ឋទូតនោះបដិសេធ។ នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៦០ សម្តេចសីហនុ ក៏បានលើកសរសើរពីកាសែតអ្នកសង្កេតការណ៍ (Observateur) របស់ខៀវ សំផន ថា សរសេរបានសមរម្យ ហើយបានទទួលស្គាល់ពីការរីកចម្រើនរបស់ប្រទេសជាតិក្រោមការដឹករបស់ចលនាសង្គមរាស្ត្រនិយមរបស់ព្រះអង្គ។ ប៉ុន្តែ នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៦០ ខៀវ សំផន ត្រូវពួកប៉ូលិសរបស់គូ រុន ទេសរដ្ឋមន្ត្រីទទួលភារៈខាងក្រសួងសន្តិសុខជាតិ និងការពារផ្ទៃប្រទេស ស្លៀកពាក់ស៊ីវិល នាំគ្នាស្ទាក់វាយសម្រាតខោអាវ នៅពេលកំពុងជិះកង់តាមផ្លូវសាធារណៈ។ នៅក្នុងខែសីហា ពួកឆ្វេងនិយម (កុម្មុយនិស្ត) ចំនួន៣០នាក់ ត្រូវកម្លាំងប៉ូលិសចាប់យកទៅសួរចម្លើយនៅស្នងការដ្ឋានភ្នំពេញ ក្នុងនោះមាន១៨នាក់ ត្រូវឃុំខ្លួន ដោយរួមទាំង ខៀវ សំផន, នង សួន, ជូ ជេត ជានិពន្ធនាយកកាសែតប្រជាជន បន្តពីណុប បូផាន់ និងបុគ្គលិករបស់កាសែតប្រជាជន កាសែតមិត្តភាព និងកាសែតឯកភាព ចេញផ្សាយជាភាសាខ្មែរផងដែរ។

កាសែតប្រជាជន បានសរសេរប្រឆាំងនឹងផែនការរបស់សម្តេចសីហនុ ដែលឱ្យបង្រៀនភាសាបារាំង នៅតាមសាលាបឋមសិក្សា។ នង សួន ត្រូវគេវាយដំធ្វើទារុណកម្ម

យ៉ាងវេទនាឈឺចាប់បំផុតនៅក្នុងពេលឃុំខ្លួននោះ ព្រោះគេចាត់ទុកគាត់ថា ជាមេខ្លោង ហើយកាសែតប្រឆាំងទាំងអស់ ត្រូវបិទ លែងឱ្យចេញផ្សាយ។

សម្តេចសីហនុ បានចោទប្រកាន់ថា កាសែតទាំងនោះ បានចុះផ្សាយនូវអត្ថបទជាលក្ខណៈញុះញង់ ហើយព្រះអង្គបានឱ្យគេប្រមូលអត្ថបទទាំងអស់នោះ ចងក្រងជាសៀវភៅមួយ ដើម្បីប្តឹងកាសែតទាំងនោះ ឱ្យឃើញស-ខ្មៅម្តង។ ប៉ុន្តែក្រោយមក មិនដឹងមូលហេតុអ្វី ព្រះអង្គ មិនបានប្តឹងផ្តល់អ្វីទេ ហើយនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៦០ ព្រះអង្គ ក៏បានឱ្យគេដោះលែង នង សួន, ខៀវ សំផន, ជូ ជេត និងសហការី ទាំង១៨ នាក់នោះវិញ។ ក្រោយពីព្រះអង្គឱ្យគេដោះលែងវិញ ពួកអ្នកនយោបាយឆ្វេងនិយម ក៏បានចេញសេចក្តីប្រកាសមួយមានខ្លឹមសារជាអាទិ៍ថា៖ ពេលនេះប្រទេសជិតខាងកំពុងឈ្លានពានប្រទេសកម្ពុជា ចំណែកពួកក្បត់កំពុងប្រឆាំងនឹងឯករាជ្យ អព្យាក្រឹត និងសន្តិភាពរបស់ប្រទេសជាតិ។ ពួកចក្រពត្តិនិយមកំពុងព្យាយាមផ្តួលរំលំសម្តេចព្រះប្រមុខរដ្ឋ តាមគ្រប់មធ្យោបាយ។ ពួកវាព្យាយាមបំបែកបំបាក់ឯកភាពជាតិខ្មែរ។

សេចក្តីប្រកាសនោះ ក៏បានអំពាវនាវថា ក្នុងកាលៈទេសៈដ៏ធ្ងន់ក្រៃលែងនេះ ក្រុមប្រជាជន (គណបក្សប្រជាជន) សូមឱ្យសមាជិកទាំងអស់ និងប្រជារាស្ត្រខ្មែរទាំងមូល ជឿតាមព្រះឱង្ការរបស់សម្តេចឧបយុវរាជ (សម្តេចសីហនុ) និងមិនត្រូវភ័យខ្លាចការគំរាមផ្តាច់ជំនួយ ឬការហ៊ុមព័ទ្ធសេដ្ឋកិច្ចរបស់ពួកចក្រពត្តិអាមេរិកទេ។ ពេលនោះ អៀង ធីរិទ្ធ បានបង្កើតសាលាបង្រៀនភាសាអង់គ្លេសឯកជនមួយ ដោយទាក់ទងប្រពន្ធសាស្ត្រាចារ្យ ទីវ អុល ដែលជាពួកកុម្មុយនិស្តនិយម ឈ្មោះ ឡេង ស៊ឹមហាក់ (មិត្តសី) ឱ្យមកជួយបង្រៀននៅទីនោះដែរ។

នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៦០ រដ្ឋាភិបាលវៀតណាមខាងត្បូង បានចូលឈ្លានពានរំលោភដណ្តើមយកកោះថ្មី កោះសេះ កោះទន្សាយ កោះតាគៀវ និងកោះពោធិ៍ នៅតាមឆ្នេរសមុទ្ររបស់កម្ពុជា។

# ១៣២
# អាកប្បកិរិយា និងអត្តចរិតរបស់សម សារី



**សម សារី**

សម សារី ជាបញ្ញវន្ត មានការចេះដឹងជ្រៅជ្រះ តែគាត់មានចរិតឆេវឆាវ សូម្បីតែពេលបាយខ្លះគាត់តែងតែឈ្លោះប្រកែកគ្នាជាមួយប្រពន្ធបោកចានបាយជាញឹកញាប់។ បរិយាកាសនៃអំពើហិង្សានេះបានជះឥទ្ធិពលអាក្រក់មកលើកូនៗរបស់គាត់យ៉ាងខ្លាំង

ពិសេស សម រង្ស៊ី ជាកូនពៅបានតាំងចិត្តតាំងពីវ័យកុមារមកថា គាត់នឹងមិនប្រកាន់យកអាកប្បកិរិយា និងអត្តចរិតដូចឪពុកគាត់ជាដាច់ខាត។

សម រង្ស៊ី បានរម្លឹកថា បរិយាកាសដ៏អាប់អួរមួយបានដក់ជាប់នៅក្នុងសតិអារម្មណ៍គាត់ខ្លាំងជាងគេ គឺពេលមួយ ឪពុកម្តាយគាត់កំពុងមានរឿងឈ្លោះប្រកែកគ្នាយ៉ាងខ្លាំងនៅក្នុងផ្ទះ បងប្រុសនោះក៏រត់ទៅពួនសំងំក្នុងកន្លៀតទូមួយ។ លុះពេលឪពុកម្តាយគាត់ឈប់ឈ្លោះគ្នា ហើយចេញទៅធ្វើការអស់ បងប្រុសគាត់ខំរើខ្លួនចេញពីកន្លៀតទូនោះ តែមិនរួចទោះបីពួកគាត់ខំជួយទាញយ៉ាងណាក៏ដោយ។ សម រង្ស៊ី គិតថា នេះប្រហែលជាមកពីបងប្រុសភ័យខ្លាចខ្លាំងពេករហូតដងខ្លួនត្រូវរួញតូចអាចចូលក្នុងកន្លៀតទូដ៏តូចចង្អៀតនេះបាន។ តែពេលចេញមកវិញចេញមិនរួច។ ដោយឡែកគាត់ជាកូនពៅមិនសូវទទួលរងនូវការវាយតប់ពីឪពុកទេ។ ប៉ុន្តែទោះបីជាយ៉ាងនេះក៏ដោយ ក៏គាត់នៅតែមានអារម្មណ៍ភ័យខ្លាចដែរ។

មានរឿងមួយទៀតដែលសម រង្ស៊ី នៅតែនឹកឃើញនោះ គឺជារៀងរាល់ចុងសប្តាហ៍ឪពុកម្តាយគាត់តែងនាំពួកគាត់ជាកូនៗទៅសម្រាកកាយនៅមាត់សមុទ្រក្រុងកែប។ ប៉ុន្តែចុងសប្តាហ៍ខ្លះ បរិយាកាសសប្បាយរីករាយនៅមាត់សមុទ្រនោះត្រូវបាត់បង់មួយរំពេច ដោយសារអំពើហិង្សារបស់ឪពុកគាត់។ ពេលមួយមានពួកភ្ញៀវមានឋានៈខ្ពង់ខ្ពស់នៅក្រោមឱវាទមកលេងផ្ទះ ឪពុកគាត់ចង់ឲ្យពួកភ្ញៀវទាំងនោះឃើញថាកូនៗគាត់ចេះច្រៀងបទចម្រៀងបារាំងពីរោះៗ ឪពុកគាត់ឱ្យពួកគាត់ឡើងច្រៀងម្នាក់ម្តងៗ។ លុះបងៗគាត់ច្រៀងចប់ ដល់វេនគាត់ជាកូនពៅ ពេលនោះមិនដឹងជាយ៉ាងម៉េចគាត់ច្រៀងចម្រៀងជាភាសាបារាំងមានចំណងជើងថាក្រោមពន្លឺព្រះចន្ទ នោះ តែមិនឮសំឡេងដូចរាល់ដង គឺប្រៀបដូចជាមនុស្សគធ្វើឱ្យឪពុកគាត់ខឹងច្រឡោត ហើយស្ទុះមកទះតប់គាត់យ៉ាងខ្លាំងរហូតដល់ដួលដាំមុខមាត់អស់ ដោយមិនខ្វល់ដល់ពេលចាំឲ្យភ្ញៀវចេញផុតពីផ្ទះសិនឡើយ។ ឯពួកភ្ញៀវសុទ្ធតែជាមន្ត្រីធំៗដែរនោះ ក៏មិនហ៊ាននិយាយស្តីអ្វីទាំងអស់ចំពោះអំពើហិង្សានេះ ព្រោះពេលនោះឪពុកគាត់ឡើងឋានៈដល់កំពូលទៅហើយ។ ប៉ុន្តែករណីអំពើហិង្សានេះគាត់យល់ថា នៅក្នុង

## របត់នយោបាយ

សង្គមខ្មែរយើងកាលជំនាន់ទសវត្សរ៍ឆ្នាំ១៩៥០នោះ ការវាយតប់កូនចៅជារឿងមួយធម្មតា គ្មានអ្វីចម្លែកទេ។ និយាយដូច្នេះ មិនមែនបានន័យថាគាត់ចង់សម្រាលទោសឱ្យឪពុកគាត់ ដែលតែងតែប្រើអំពើហិង្សានោះទេ។ គាត់ស្អប់ខ្ពើមអំពើហិង្សា គឺដោយសារអំពើហិង្សានេះ ឯងដែលបានបំផ្លាញក្រុមគ្រួសារគាត់ទាំងមូល។ ប៉ុន្តែយ៉ាងណា គាត់មិនស្អប់ខ្ពើមឪពុកម្តាយ គាត់ទេ ព្រោះឪពុកម្តាយគាត់ទទួលឥទ្ធិពលពីសង្គមជំនាន់នោះ។

ជំនាន់នោះឪពុកម្តាយគាត់ឈ្លោះគ្នាដូចក្នុងគ្រួសារឯទៀតៗដែរ។ ប៉ុន្តែឪពុកគាត់ ជាមនុស្សចូលចិត្តប្រើអំណាច មួម៉ៅក្តៅក្រហាយឆាប់ខឹងជាងគេ។ សូម្បីកាលឪពុកគាត់ ធ្វើការនៅខេត្តកំពង់ចាម ដោយសារទប់កំហឹងមិនបាន ឪពុកគាត់រហូតយកត្រាទៅគប់ក្បាល ចៅហ្វាយជាជនជាតិបារាំង ទៀតផង។

សម រង្ស៊ី បានរម្លឹកបន្តថា ចំណែករឿងស្រីញីវិញក្នុងសង្គមខ្មែរយើងជំនាន់នោះ ពួក អ្នកធំៗអ្នកមានបុណ្យស័ក្តិតែងតែមានប្រពន្ធផង មានស្រីកំណាន់ច្រើន និងមានប្រពន្ធ ច្រើន គឺជារឿងធម្មតា។ គាត់និយាយនេះ មិនមែនចង់ការពារទម្លាប់ចាស់គំរឹលបែបនេះទេ ប៉ុន្តែគាត់ចង់បង្ហាញឱ្យឃើញនូវអ្វីៗ ដែលជារឿងហួសសម័យសម្រាប់ក្មេងៗជំនាន់ក្រោយ។ ឪពុកគាត់ចូលចិត្តដើរលេងផ្តេសផ្តាសមានស្រីញី មានស្រីកំណាន់ច្រើន និងមានកូនក្រៅ ខោមិនដឹងជាប៉ុន្មាននាក់? អ្នកផងទាំងពួងក៏បានដឹងឮរឿងនេះស្ទើរគ្រប់ៗគ្នាដែរ។ ម្តាយ គាត់តែងតែបន្ទោសឪពុកគាត់ពីរឿងផ្តេសផ្តាសនេះ។ យប់ខ្លះដោយមិនឃើញឪពុកមកផ្ទះ ម្តាយគាត់បានឱ្យបងប្រុសគាត់ឈ្មោះ អេម៉ារិទ្ធ ទៅតាមរកឪពុកគាត់ដល់ផ្ទះស្រីកំណាន់ម្នាក់ ក្នុងចំណោមស្រីកំណាន់ដ៏ច្រើនរបស់ឪពុកគាត់។ បងប្រុសគាត់ឈ្មោះអេម៉ារិទ្ធ មានចរិត ឆេវឆាវបន្តិចដែរ។ ដោយសារតែមានចិត្តអាណិតស្រលាញ់ម្តាយគាត់ខ្លាំងពេកមានថ្ងៃមួយ បងប្រុសគាត់ម្នាក់នេះ បានលួចនោមដាក់ក្នុងដបទឹកអប់របស់ស្រីកំណាន់ (ប្រពន្ធចុង) របស់ឪពុកគាត់ម្នាក់ដែលឪពុកគាត់យកមករស់នៅក្នុងផ្ទះជាមួយពួកគាត់។

សម រង្ស៊ី យល់ឃើញថា រហូតដល់ចុងទសវត្សរ៍ឆ្នាំ១៩៥០ ស្ត្រីខ្មែរយើងមានទម្លាប់ មួយ គឺស្តាប់បង្គាប់ប្តី មិនរឹងរូសទេ។ តែម្តាយគាត់មិនមានចរិតបែបនេះឡើយ ម្តាយគាត់

ប្រលងជាប់បាក់ឌុបមុនគេទាំងអស់ នៅក្នុងប្រទេសខ្មែរយើង គាត់មានគំនិតលើកតម្កើងឋានៈស្ត្រីមុនគេបង្អស់ គឺតាំងតែពីអង្គការចលនាស្ត្រីពិភពលោកមិនទាន់ត្រូវបានបង្កើតឡើងមកម្ល៉េះ។ ម្តាយគាត់មិនអាចស៊ូទ្រាំស្ងាត់ស្ងៀមមិនហ៊ានតវ៉ាជាមួយប្តីឬទាមទារអ្វីៗ ដើម្បីផលប្រយោជន៍សង្គម ដូចស្ត្រីខ្មែរឯទៀតៗទេ។ ម្តាយគាត់បានចូលប្រលូកយ៉ាងសកម្មក្នុងការទាមទារឲ្យស្ត្រីមានសិទ្ធិបោះឆ្នោត ហើយឱ្យស្ត្រី និងបុរសមានសិទ្ធិស្មើគ្នាក្នុងគ្រួសារផងដែរ។ កាលនោះម្តាយគាត់បានទាំងនាំគាត់ទៅប្រទេសនូវែលហ្សេឡង់ ដើម្បីចូលរួមសន្និសីទមួយស្តីពីសិទ្ធិស្ត្រីក្នុងពិភពលោកទៀតផង។

# ១៣៣
# មូលហេតុព្រះមហាក្សត្រនរោត្តម សុរាម្រិត ចូលទិវង្គត



ក្រោយពីប្រារព្ធពិធីសម្ពោធដាក់ឱ្យប្រើប្រាស់កំពង់ផែក្រុងព្រះសីហនុ ជាជំនួយរបស់បារាំង បានមួយថ្ងៃ នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ១៩៦០ ព្រះមហាក្សត្រនរោត្តម សុរាម្រិត ចូលទិវង្គត។

ប្រជារាស្ត្រខ្មែរ ក៏ដូចជាជនបរទេសជាមិត្តភក្តិរបស់ព្រះអង្គជាច្រើន ចាត់ទុកព្រះអង្គថា ជាព្រះមហាក្សត្រមួយអង្គប្រកបដោយសមត្ថភាព និងមានព្រហ្មវិហារធម៌ដ៏ខ្ពង់ខ្ពស់បំផុត។

មិនខុសពីមហេសីព្រះអង្គ គឺម្ចាស់ក្សត្រិយានីស៊ីសុវត្ថិ កុសុមៈ ប៉ុន្មានទេ ព្រះមហាក្សក្រនរោត្តម សុរាម្រិត តែងតែចូលចិត្តទាក់ទងប្រជារាស្ត្ររបស់ព្រះអង្គក្នុងលក្ខណៈជាព្រះមហាក្សត្រដ៏សាមញ្ញ ហើយប្រជារាស្ត្រក៏នាំគ្នាគោរពស្រលាញ់ព្រះអង្គវិញដោយស្វាមីភក្តិដែរ។

ព្រះអង្គតែងមានព្រះទ័យសន្ដោសប្រោសប្រណីដល់ជនគ្រប់រូប សូម្បីជនទាំងឡាយណាដែលប្រមាថមកលើ ព្រះអង្គក៏ដោយ ក៏ព្រះអង្គមិនយកទោសពៃរ៍ដែរ។ សូម្បីសឹង ង៉ុក

ថាញ់ ជាមិត្តភក្តិជិតស្និទ្ធរបស់ព្រះអង្គតាំងពីដើមមករត់ទៅបង្កើតចលនាប្រឆាំងព្រះអង្គនៅភាគខាងលិចប្រទេស ក៏ព្រះអង្គមិនមានប្រតិកម្មក្រេវក្រោធណាមួយគួរឱ្យកត់សម្គាល់ឡើយ។

ជាមួយគ្នានោះ ព្រះអង្គក៏មានព្រះទ័យសន្តោសប្រណីដល់ពួកមេដឹកនាំគណបក្សប្រជាធិបតេយ្យដែលចេញមុខប្រឆាំងនឹងសម្តេចសីហនុ ជាបុត្រាព្រះអង្គផងដែរ។

ក្រោយពីបានឡើងសោយរាជ្យ ព្រះមហាក្សត្រសុរាម្រិត មិនសូវហ៊ានសម្រេចដោះស្រាយលើកិច្ចការនយោបាយសំខាន់ៗរបស់ប្រទេសជាតិទេ គឺភាគច្រើនព្រះអង្គធ្វើការពិគ្រោះយោបល់ជាមួយព្រះរាជបុត្រនរោត្តម សីហនុ ដែលជាប្រធានចលនាសង្គមរាស្ត្រនិយម ហើយពេលខ្លះព្រះអង្គត្រូវសួរយោបល់មហាក្សត្រិយានី កុសុមៈជាមហេសី ដែលមានប្រាជ្ញាឈ្លាសវៃ និងតែងតែដឹងពីព័ត៌មានសំខាន់ៗរបស់ប្រទេសជាតិច្បាស់លាស់ជាងព្រះអង្គផងដែរ។

ដោយសារព្រះអង្គមានព្រះទ័យនឹងធឹង សន្តោសប្រណី សូម្បីពួកអ្នកនយោបាយប្រឆាំង ក៏មិនដែលធ្វើការរិះគន់ទិតៀនព្រះអង្គម្តងណាឡើយ។

ជាមួយគ្នានោះ ព្រះអង្គក៏ជាព្រះមហាក្សត្រមិនសូវចេះកើតទុក្ខផងនោះដែរ ព្រះអង្គបានបង្កើតពាក្យស្លោកមួយឃ្លាថា៖ "អ្វីៗងាយសោះ ហេតុអ្វីក៏ធ្វើឱ្យស្មុគស្មាញ" ។ ខ្លឹមសារពាក្យស្លោកនេះត្រូវបានគេយកទៅសរសេរដាក់ព្យួរនៅតាមជញ្ជាំងការិយាល័យនៃរដ្ឋសភា និងនៅតាមក្រសួងស្ថាប័ននានា ព្រមទាំងនៅតាមជញ្ជាំងគេហដ្ឋានរបស់ប្រជារាស្ត្រមួយចំនួនទុកគ្រាន់ពិចារណា ហើយប្រជារាស្ត្រភាគច្រើន បានចាត់ទុកថា ព្រះអង្គគឺជាព្រះមហាក្សត្រស៊ីសុវត្ថិទី២ ទៀតផង ។

ចំណែកក្នុងជីវិតឯកជនរបស់ព្រះអង្គវិញ ក្រៅពីមានស្នំឯកម្នាក់ឈ្មោះឃុន យ៉ាប ដែលព្រះអង្គគាប់ព្រះទ័យបំផុតនោះ ព្រះអង្គក៏បានធ្វើការផ្សេងព្រេងលេងសើចជាមួយស្រីក្រៅផ្សេងទៀត មានទាំងស្រីខ្មែរ និងស្រីបរទេសម្តងម្កាលដែរ ប៉ុន្តែជាមួយស្រីៗទាំងឡាយដែលស្ថិតនៅក្នុងព្រះបរមរាជវាំង ព្រះអង្គមិនដែលប្រព្រឹត្តអំពើផ្តេសផ្តាសម្តងណាទេ។

ពេលមហាក្សត្រិយានីកុសុមៈ រអ៊ូរទាំស្តីបន្ទោសពីរឿងខិលខូចស្រីញីនេះដែរថា កាលពីនៅយុវវ័យ ព្រះអង្គអាចលុបលាងការប្រព្រឹត្តអំពើខិលខូច ប្រាសចាកពីសីលធម៌ (មាន



ស្រីផ្សេង ) ដោយយកលេសថា នេះជាកំសួលស្រើបស្រាលនៃធម្មជាតិជាយុវភាព ហើយពេលព្រះអង្គមានព្រះជន្មកាន់តែច្រើន ព្រះអង្គក៏កាន់តែផ្សងព្រេងក្នុងរឿងស្នេហា ដូចកាលព្រះអង្គនៅព្រះជន្ម ២០វស្សាដដែល។

តើពេលណាទៅ ទើបព្រះអង្គលះបង់អំពើខិលខូចនេះចោល មកប្រព្រឹត្តអំពើត្រឹមត្រូវវិញ ? គ្មានផ្លូវដែលធ្វើឱ្យព្រះអង្គអាចកែប្រែព្រះទ័យខិលខូចនេះបានទេ។

ពេលឮមហេសី មានបន្ទូលរបៀបស្ដីបន្ទោសដូច្នេះ ព្រះមហាក្សត្រសុរាម្រិត មានបន្ទូលលួងលោមមហេសីព្រះអង្គថា អូនអើយ! បងកាន់តែមានវ័យចាស់ហើយ និងមានជំងឺទឹកនោមផ្អែមនៅជាប់នឹងខ្លួនទៀតផង។ ដូច្នេះបងរស់មិនបានយូរប៉ុន្មានតទៅទៀតទេ។ ប៉ុន្តែ មុននឹងសោយទិវង្គតទៅ អូនត្រូវផ្ដល់ឱកាសឱ្យបងបានសប្បាយខ្លះៗទៅ តែក្នុងបេះដូងបង គឺមានតែអូនជាមហេសីមួយអង្គប៉ុណ្ណោះ។

សម្ដេចព្រះនរោត្ដម សីហនុ បានមានបន្ទូលបញ្ជាក់ពីប្រវត្តិជំងឺទឹកនោមផ្អែមរបស់ព្រះបិតាព្រះអង្គថា នៅក្នុងឆ្នាំ១៩៥៧ វេជ្ជបណ្ឌិត អារម៉ង់ រីស្វ ជាគ្រូពេទ្យប្រចាំរាជវង្សានុវង្សបានឱ្យដឹងថា ព្រះមហាក្សត្រជាបិតាព្រះអង្គនឹងត្រូវសោយទិវង្គត ដោយសារជំងឺទឹកនោមផ្អែម ក្នុងរយៈពេល៣ឆ្នាំទៀតយ៉ាងយូរ ប្រសិនបើព្រះអង្គមិនព្រមបញ្ឈប់ការសោយអាហារឆ្ងាញ់ៗ ពិសេសគឺការ៉េម និងស្ករនោះទេ។ តែបើព្រះអង្គអនុវត្តតាមការណែនាំរបស់វេជ្ជបណ្ឌិត

ក្នុងការតមអាហារមានជាតិផ្អែមឱ្យបានត្រឹមត្រូវ ព្រះអង្គអាចមានព្រះជន្មរស់នៅបានពី៧ ទៅ ៨ឆ្នាំបន្តទៅមុខទៀត ឬអាចថាមានព្រះជន្មរស់នៅ រហូតដល់១០ឆ្នាំទៀតផង។

ប៉ុន្តែ ពេលវេជ្ជបណ្ឌិតអារម៉ង់ រីស្វ ណែនាំព្រះអង្គឱ្យតមអាហារមួយចំនួននោះ ព្រះអង្គបានវាយបកស៊កសៀតទៅវិញថា៖ ការពន្យារជីវិតដោយតម្រូវឱ្យតមនូវអ្វីៗទាំងឡាយ ដែលខ្ញុំចូលចិត្តបំផុតនោះ តើខ្ញុំរស់មានន័យអ្វីទៅ? តើឱ្យខ្ញុំស៊ូទ្រាំមិនសោយអាហារគ្មានជាតិផ្អែម គ្មានបីរ ឬក៏គ្មានទឹកជ្រលក់ រហូតដល់៧ ទៅ ៨ឆ្នាំ ឬ១០ឆ្នាំបានទេ? ខ្ញុំមិនអាចកែប្រែទម្លាប់ទាំងអស់នេះបានឡើយ។

វេជ្ជបណ្ឌិត អារម៉ង់ រីស្វ ពិតជាធ្វើការវាយតម្លៃទៅលើស្ថានភាពជំងឺទឹកនោមផ្អែមរបស់ព្រះមហាក្សត្រនរោត្តម សុរាម្រិត ពិតជាត្រូវមែន ព្រោះ៣ឆ្នាំក្រោយពីការសន្និដ្ឋាននោះមក នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ១៩៦០ ព្រះអង្គក៏សោយទិវង្គតប្រាកដមែន ដោយពេលដំបូង ព្រះអង្គត្រូវសន្លប់អស់មួយសប្តាហ៍ ទោះបីត្រូវគ្រូពេទ្យយកម្ជុលចាក់សរសៃ ដើម្បីព្យូរសេរ៉ូម ក៏ព្រះអង្គមិនដឹងខ្លួនបន្តិចដែរ។ ប៉ុន្តែ ពេលដឹងខ្លួនឡើង សម្តេចនរោត្តម សីហនុ ជាបុត្របានចូលសួរព្រះអង្គថា តើព្រះបិតាចង់ជួបអ្នកស្រី យុន យ៉ាប ដែលជាស្នំឯក និងបុត្រាបុត្រីរបស់ព្រះអង្គ គឺនរោត្តម សេរីរ៉ុឌ្ឍ, នរោត្តម វិជ្ជរ៉ា និងនរោត្តម ស្រីយ៉ាសូផុន ឬទេ? ពេលនោះ ព្រះមហាក្សត្រនរោត្តម សុរាម្រិត ចាប់ដៃព្រះរាជបុត្រ (សីហនុ) ហើយមានបន្ទូលតិចៗថា បិតាបានប្រព្រឹត្តកំហុសធ្ងន់ណាស់ចំពោះមាតាបុត្រ។ ពេលនេះ បិតាត្រូវការតែមាតាបុត្រ និងបុត្រនៅក្បែរបិតាប៉ុណ្ណោះ។

នៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៦០ ព្រះកោដ្ឋបរមសព នរោត្តម សុរាម្រិត ត្រូវហែចេញពី រាជវាំងឆ្លងកាត់មហាវិថីធំៗ កាត់ទៅវត្តភ្នំ។ ចុងក្រោយ ព្រះបរមសពហែមកតម្កល់នៅលើមហាបញ្ជា៩ជាន់ នៅក្នុងរោងពិធីដោយសាងសង់នៅវាលមេរុ ដោយតម្កល់រយៈពេល ៥ថ្ងៃ មុននឹងថ្វាយព្រះភ្លើង។

ក្រោយពិធីថ្វាយព្រះភ្លើងហើយ នៅមានធ្វើពិធីសាសនាផ្សេងៗទៀត រហូតដល់ចប់សពគ្រប់ ដោយចំណាយពេលជាង ១០ថ្ងៃ។

# ១៣៤
# សម្ដេចសីហនុ ក្លាយជាព្រះប្រមុខរដ្ឋ មានឋានៈស្មើព្រះមហាក្សត្រ



**សម្ដេចព្រះប្រមុខរដ្ឋ**

ក្រោយពីព្រះមហាក្សត្រសុរាម្រិត សោយទិវង្គតទៅ មេដឹកនាំបណ្ដាប្រទេសជាមិត្ត ជាច្រើនបានអញ្ជើញមកគោរពព្រះវិញ្ញាណក្ខន្ធព្រះអង្គ និងចូលរួមរំលែកទុក្ខចំពោះសម្ដេច សីហនុ ជាបុត្រ។ ពិសេសគឺមេដឹកនាំចិនកុម្មុយនិស្ដជួ អេនឡាយ ជានាយករដ្ឋមន្ត្រី និង ចេន យី ជារដ្ឋមន្ត្រីក្រសួងការបរទេស ក៏បានមកដាក់កម្រងផ្កានៅចុងជើងរបស់ព្រះបរម



**ចេន យី សម្តេចសីហនុ និងជូ អេនឡាយ**

សពដែរ។

ឆ្លៀតឱកាសមកចូលរួមក្នុងពិធីដ៏ក្រៀមក្រំនោះ មេដឹកនាំចិនទាំងពីរ ក៏ត្រូវសម្តេចសីហនុ អមដំណើរដោយជិះនាវាចម្បាំងធុនធំមួយគ្រឿង នៅតាមឆ្នេរសមុទ្រខ្មែរនៅក្រុងកែបក្នុងខេត្តកំពត។

សម្តេចសីហនុ បានរៀបរាប់ពីដំណើរទេស្សនកិច្ចនោះថា ពេលនាវាបើកនៅក្បែរកោះដ៏ធំមួយ គឺកោះភូកុក ដែលខ្មែរយើងហៅថា កោះត្រល់ ពេលនោះ មេដឹកនាំប្រទេសចិនទាំង២នាក់ បានពោលថា៖ "កោះនេះជារបស់ប្រទេសកម្ពុជា មិនអាចប្រកែកបានឡើយ ពីព្រោះវាស្ថិតនៅក្នុងដែនសមុទ្ររបស់កម្ពុជា ហើយមេដឹកនាំចិន ក៏បានបន្ថែមទៀតថា ពួកអាណានិគមបារាំង មិនគួរណាប្រគល់កោះនេះ ទៅឱ្យប្រទេសវៀតណាម ដូចនេះសោះ។

តាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ក្រោយព្រះមហាក្សត្រសោយទិវង្គត រយៈពេល៣ថ្ងៃយ៉ាងយូរ ក្រុមប្រឹក្សារាជបល្លង្ក ត្រូវតែងតាំងព្រះមហាក្សត្រថ្មី ឱ្យឡើងសោយរាជ្យបន្តទៀត។ ពេលនោះ ព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉េត ជាប្រធានក្រុមប្រឹក្សារាជបល្ល័ង្កមានបំណងតែងតាំងព្រះមហាក្សត្រិយានីជាព្រះមាតាព្រះអង្គឱ្យឡើងសោយរាជ្យបន្តដែរ តែសម្តេចសីហនុ

ឈ្វេងយល់ថា នេះអាចជាបន្ទុកធ្ងន់ណាស់ចំពោះព្រះមាតារបស់ព្រះអង្គ។ ក្រោយពីព្រះ-មហាក្សត្រសុរាម្រិត សោយទិវង្គតអស់រយៈពេល៣ថ្ងៃទៅហើយ ក៏នៅតែមិនអាចរកអ្នកស្នងរាជសម្បត្តិបន្តទៀតបាន ប្រទេសជាតិ ក៏ត្រូវជួបវិបត្តិរឿងរាជបល្ល័ង្កនេះ។ ដូច្នេះ ព្រះអង្គបានបង្កើតស្ថាប័នថ្មីមួយទៀត គឺក្រុមប្រឹក្សារាជានុសិទ្ធិ ដើម្បីបំពេញតួនាទីជំនួសស្ថាប័នព្រះមហាក្សត្រជាបណ្តោះអាសន្ន។

នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ១៩៦០ ព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉េត ត្រូវបានក្រុមប្រឹក្សារាជបល្ល័ង្កតែងតាំងជាប្រធានក្រុមប្រឹក្សារាជានុសិទ្ធិ, ផូ ព្រឿង និង ទ្រឿង កាង ជាសមាជិក។ ក្រុមប្រឹក្សារាជានុសិទ្ធិនេះ មានសមាជិកបម្រុង២នាក់ទៀត គឺ ទេព ផន និង ពីទូ ដឺម៉ុងតេរ៉ូ។

នៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៦០ សម្តេចសីហនុ ដែលបានកាន់តំណែងនាយករដ្ឋមន្ត្រីជាប់ៗគ្នា៣អាណត្តិរាជរដ្ឋាភិបាល ចាប់ពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៥៨ រហូតដល់ព្រះមហាក្សត្រសុរាម្រិត ជាព្រះបិតាសោយទិវង្គតនៅថ្ងៃទី០៣ ខែមេសា ឆ្នាំ១៩៦០ នេះព្រះអង្គ និងគណៈរដ្ឋមន្ត្រីទាំងមូល បានប្រកាសលាលែងពីតំណែង ធ្វើឱ្យប្រទេសជាតិជួបវិបត្តិរាជរដ្ឋាភិបាល និងវិបត្តិរដ្ឋធម្មនុញ្ញបន្ថែមទៀត។

ដើម្បីកុំឱ្យប្រទេសជាតិជួបវិបត្តិកាន់តែធ្ងន់ថែមទៀតផង នៅថ្ងៃទី១៩ មេសា ឆ្នាំ១៩៦០ ផូ ព្រឿង ក៏បានលាឈប់ពីតំណែងសមាជិកក្រុមប្រឹក្សារាជានុសិទ្ធិមក រៀបចំសមាសភាពគណៈរដ្ឋមន្ត្រីថ្មីមួយ ដោយមានរូបគាត់ជានាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីមហាផ្ទៃ និងរដ្ឋមន្ត្រីធម្មការ, ញឹក ជូឡុង ជាឧបនាយករដ្ឋមន្ត្រីទី១ និងជារដ្ឋមន្ត្រីក្រសួងផែនការ ទេសចរណ៍ ផលិតកម្ម និងទូរគមនាគមន៍, ទេព ផន (សមាជិកបម្រុងក្រុមប្រឹក្សារាជានុសិទ្ធិ) ជាឧបនាយករដ្ឋមន្ត្រីទី២ និងជារដ្ឋមន្ត្រីការបរទេស ,ជា ជិនកុក ទេសរដ្ឋមន្ត្រី ប្រតិភូអមនាយករដ្ឋមន្ត្រីទទួលបន្ទុកអប់រំជាតិ , លន់ នល់ ទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងការពារប្រទេស, គូ រុន ទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងសន្តិសុខជាតិ និងការពារលើផ្ទៃប្រទេស, លឹម គ្រី ជារដ្ឋមន្ត្រីយុត្តិធម៌ និងបោសសម្អាតទូទៅ, ទូច គីម ជារដ្ឋមន្ត្រីសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ចៅ សេង

ជារដ្ឋមន្ត្រីឃោសនាការ សុខាភិបាល, យឹម ឌិត ជារដ្ឋមន្ត្រីសាធារណសុខាភិបាល, ព្រំ ថុស ជារដ្ឋលេខាធិការមហាផ្ទៃ, ចេង ហេង (ប្រមុខរដ្ឋខ្មែរក្រោយថ្ងៃរដ្ឋប្រហារ១៨ មីនា ១៩៧០) ជារដ្ឋមន្ត្រីកសិកម្ម, ពុង ប៉េងចេង (ឪពុករបស់អ្នកស្រី ពុង ឈីវហ្គិច) ជារដ្ឋលេខាធិការការងារ និងសង្គមកិច្ច, កេនថាវ ដឺម៉ុងតេរ៉ូ ជារដ្ឋលេខាធិការអប់រំជាតិ ,អ៊ឹង ក្រពុំផ្កា ជារដ្ឋលេខាធិការសាធារណការ និងទូរគមនាគមន៍, ឌី បែលឡុង ជាអនុរដ្ឋលេខាធិការផែនការ, ឡេង សារ៉ែង ជាអនុរដ្ឋលេខាបោសសម្អាតទូទៅ, សូ ខាំខូយ ជាអនុរដ្ឋលេខាធិការ និងទំនាក់ទំនងសភា និងអ៊ាប គីមជន ជាអនុរដ្ឋលេខាធិការហិរញ្ញវត្ថុ។

ក្រុមប្រឹក្សារាជានុសិទ្ធិ មានបំណងឱ្យសម្តេចសីហនុ មានគោរមងារជាសម្តេចឧបយុវរាជ ឡើងគ្រងរាជ្យជាព្រះមហាក្សត្របន្តពីព្រះបិតាដែរ ប៉ុន្តែព្រះអង្គបដិសេធ ព្រោះកាលពីដាក់រាជ្យសម្បត្តិថ្វាយព្រះបិតាសុរាម្រិត ដើម្បីចូលប្រឡូកក្នុងឆាកនយោបាយកាលពីឆ្នាំ១៩៥៥ ព្រះអង្គបានសន្យាហើយថា ព្រះអង្គនឹងមិនឡើងសោយរាជសម្បត្តិវិញទេ ។

នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៦០ សម្តេចសីហនុ បានថ្លែងការណ៍ទៅកាន់ប្រជារាស្ត្រឱ្យបានដឹងថា បញ្ហាជម្លោះក្នុងរាជវង្សដោយសារមានការប្រណែននិន្ទាដណ្តើមរាជបល្ល័ង្គគ្នា ជាប្រពៃណីរបស់រាជវង្សខ្មែរតាំងពីសម័យពាក់កណ្តាលសតវត្សរ៍ទី១៩មកនោះ ពេលនេះលែងមានបញ្ហាទៀតហើយ។ តែនៅក្នុងសេចក្តីថ្លែងការណ៍នោះ ព្រះអង្គមិនបានបង្ហាញឱ្យប្រជារាស្ត្រដឹងថា តើបុត្រាអង្គណាមួយដែលត្រូវឡើងគ្រងរាជ្យសម្បត្តិបន្តនោះទេ។ ព្រះអង្គគ្រាន់តែថ្លែងបញ្ជាក់ថា បុត្រារបស់ព្រះអង្គទាំងអស់សុទ្ធតែនៅមានវ័យក្មេងៗនៅឡើយ ហើយគ្មានបទពិសោធអ្វីទេ។ មិនតែប៉ុណ្ណោះព្រះអង្គបានមានបន្ទូលពីគុណវិបត្តិរបស់បុត្រារបស់ព្រះអង្គថា ពិសេស បុត្រានរោត្តម រណឫទ្ធិ មិនចេះធ្វើអ្វី ក្រៅតែពីចេះបើករថយន្តលឿនៗ និងធ្វើឫកក្រអឺតក្រទមដាក់ពួកប៉ូលិសតែប៉ុណ្ណោះ។

នៅដើមខែមិថុនា ឆ្នាំ១៩៦០ ពេលសម្តេចសីហនុ យាងទៅបំពេញព្រះរាជទស្សនកិច្ចនៅទីក្រុងកែប ព្រះអង្គបានថ្លែងសង្កថាទៅជនរួមជាតិរបស់ព្រះអង្គថា ប្រសិនបើមានការស្នើសុំពីជនរួមជាតិ ព្រះអង្គនឹងយល់ព្រមកាន់តំណែងជាប្រមុខរដ្ឋ។




**រដ្ឋសភាសម័យសង្គមរាស្ត្រនិយម**

ក្រោយពីព្រះអង្គសេចក្ដីថ្លែងការណ៍នេះភ្លាម នៅទីក្រុងកែប ក៏ដូចជានៅរាជធានីភ្នំពេញដែរ ក៏មានរៀបចំឱ្យប្រជារាស្ត្រមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នាំគ្នាដង្ហែក្បួនព្យុះហយាត្រាយ៉ាងគគ្រឹកគគ្រេង គាំទ្រនិងស្នើសុំឱ្យព្រះអង្គកាន់តំណែងជាព្រះប្រមុខរដ្ឋ។

នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩៦០ ដើម្បីចង់ដឹងថាតើប្រជារាស្ត្រខ្មែរគាំទ្រព្រះអង្គឱ្យព្រះអង្គកាន់តំណែងជាព្រះប្រមុខរដ្ឋមានចំនួនប៉ុន្មាន? ព្រះអង្គបានឱ្យរៀបចំការបោះឆ្នោតធ្វើប្រជាមតិមួយ។ លទ្ធផលនៃការបោះឆ្នោតធ្វើប្រជាមតិនោះ គឺក្នុងចំណោមអ្នកបោះឆ្នោតជាង២លាននាក់ ព្រះអង្គទទួលបានការគាំទ្រចំនួន៩៩,៩៨ ភាគរយ។តាមរយៈលទ្ធផលនៃការធ្វើប្រជាមតិនេះព្រះអង្គបានបង្កើតស្ថាប័នថ្មីមួយគឺជាស្ថាប័នព្រះប្រមុខរដ្ឋ។ តាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ មាត្រា៣៥ បានចែងថា ព្រះមហាក្សត្រិយ៍ទ្រង់ជាអគ្គប្រមុខនៃរដ្ឋ។ អង្គព្រះមហាក្សត្រិយ៍ជាទីសក្ការៈ នរណានឹងល្មើសពុំបាន។ បន្ទាប់មកនៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៦០ សភាជាតិ និងក្រុមប្រឹក្សារាជានុសិទ្ធិ បានបើកអង្គប្រជុំ ឯកភាពគ្នាស្នើសុំឱ្យព្រះអង្គកាន់តំណែងជាប្រមុខរដ្ឋ និងមានឋានៈស្មើព្រះមហាក្សត្រ។ ចំណែកព្រះមហាក្សត្រិយានីកុសមៈនារីរតន៍ ជាព្រះមាតាគង់ប្រថាប់ជានិមិត្តរូបនៃព្រះរាជបល្ល័ង្ក។

នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ ១៩៦០ សភាជាតិ ក៏បានប្រជុំធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ បន្ថែមជំពូក១២ ស្តីពីបទបញ្ញត្តិពិសេស មាត្រា១២២ ចែងថា៖

ក្នុងករណីដែលកាលៈទេសៈពុំអនុញ្ញាតឱ្យចាត់តាំងទាំងព្រះមហាក្សត្រិយ៍ថ្មី ទាំងក្រុម-ប្រឹក្សារាជានុសិទ្ធិ ដោយអនុលោមទៅតាមបទបញ្ញត្តិមាត្រា៣០ និង៣០ស្ទួននៃរដ្ឋធម្មនុញ្ញនោះ សភាទាំងពីរត្រូវរួមប្រជុំគ្នា ដោយសេចក្តីអញ្ជើញនៃប្រធានរដ្ឋសភា និងក្រោមអធិបតីភាពនៃប្រធាននេះ ដោយអនុលោមទៅតាមឆន្ទៈដែលប្រជារាស្ត្របានសម្តែងហើយសភាទាំងនេះអាចលើកអំណាច និងបុព្វសិទ្ធិទាំងឡាយរបស់ប្រមុខរដ្ឋប្រគល់ទៅជូនឥស្សរជនណាមួយរូបដែលប្រជាពលរដ្ឋស្រលាញ់ទុកចិត្ត ហើយបានបញ្ចេញមតិចង្អុលបង្ហាញយ៉ាងជាក់ច្បាស់។

ប្រសិនបើប្រមុខរដ្ឋ ពុំបានស្ថិតនៅក្នុងកម្ពុជរដ្ឋមួយដងមួយគ្រា ឬពុំអាចទទួលភារៈបានក្នុងមួយដងមួយគ្រាប្រមុខរដ្ឋប្រគល់ភារៈនេះទៅប្រធានរដ្ឋសភា។ ប្រធានរដ្ឋសភាទទួលកាន់កាប់ភារៈទាំងនេះដោយទទួលខុសត្រូវផ្ទាល់ខ្លួន។ បន្ទាប់មក សម្តេចសីហនុ បានឲ្យប្រធានរដ្ឋសភាឈ្មោះជួប ហែល ជាប្រមុខរដ្ឋស្តីទី រៀបចំបោះឆ្នោតធ្វើប្រជាមតិមួយ ដើម្បីបង្ហាញសាធាណមតិជាតិ និងអន្តរជាតិថា តើរវាងព្រះអង្គ ជាមួយពួកខ្មែរក្រហម និងពួកខ្មែរសេរី ប្រជារាស្ត្រខ្មែរនៅទូទាំងប្រទេសស្រលាញ់គាំទ្រនរណាច្រើនជាង ?។

ការបោះឆ្នោតនៅពេលនោះ គេបានរៀបចំឱ្យមានសន្លឹកឆ្នោតជា៤ប្រភេទ គឺទី១ សន្លឹកឆ្នោតមានព្រះឆាយាល័ក្ខណ៍សម្តេចសីហនុ, ទី២ សន្លឹកឆ្នោតមានពណ៌ខៀវតំណាងឲ្យពួកខ្មែរសេរី សឺង ង៉ុកថាញ់, ទី៣ សន្លឹកឆ្នោតមានពណ៌ក្រហមតំណាងឲ្យពួកខ្មែរក្រហម (កុម្មុយនិស្ត) និងទី៤ សន្លឹកឆ្នោតមានរូបសញ្ញាសំណួរ( ? ) ជាសន្លឹកឆ្នោតអនុបវាទ។ លទ្ធផល នៃការបោះឆ្នោតធ្វើប្រជាមតិនោះ សម្តេចសីហនុ បានទទួលការគាំទ្រចំនួន ២.០០០៣៤៩សំឡេង, សន្លឹកឆ្នោតពណ៌ខៀវតំណាងឲ្យពួកខ្មែរសេរី សឺង ង៉ុកថាញ់ បានទទួលការគាំទ្រចំនួន ១៣៣សំឡេង សន្លឹឆ្នោតពណ៌ក្រហម តំណាងឲ្យពួកខ្មែរក្រហម (កុម្មុយនិស្ត) ទទួលការគាំទ្រចំនួន១៣៣សំឡេង និងសន្លឹកឆ្នោតអនុបវាទមានចំនួន ៩៣ សំឡេង។

## របត់នយោបាយ

នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ១៩៦០ សម្តេចសីហនុ បានចូលទៅធ្វើសច្ចាប្រណិធាន ចូលកាន់តំណែងជាព្រះប្រមុខរដ្ឋ ក្នុងទីប្រជុំសភាជាតំណាងប្រជារាស្ត្រខ្មែរថា ព្រះអង្គ ស្មោះត្រង់ជានិច្ច ចំពោះជាតិ សាសនា និងព្រះរាជបល្ល័ង្ក ហើយបន្តប្រពៃណីនៃអំណាច រាជានិយមជារៀងរហូត។ ជាមួយគ្នានោះ ព្រះអង្គក៏បានប្រកាសថា ព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ ជាព្រះមាតារបស់ព្រះអង្គ គឺជានិមិត្តរូបនៃរាជបល្ល័ង្ក និងរាជវង្សានុវង្ស ទាំងមូលផងដែរ។

ចាប់ពីពេលនោះ សម្តេចសីហនុ បានចាកចេញពីព្រះបរមរាជវាំង ទៅគង់នៅឯវិមាន រដ្ឋចំការមន ជាមួយអ្នកម្នាងម៉ូនិក ជាមហេសី ឆ្ងាយដាច់ពីកិច្ចការរាជសម្បត្តិ ហើយក៏មាន ការរិះគន់ថា ព្រះអង្គមិនត្រឹមតែមិនសូវបានមកចូលរួមក្នុងព្រះរាជពិធីផ្សេងៗ ដែលប្រារព្ធ ធ្វើនៅក្នុងព្រះបរមរាជវាំងប៉ុណ្ណោះទេ គឺព្រះអង្គថែមទាំងលែងសូវស្តាប់ព្រះឱវាទរបស់ព្រះ មាតាដូចមុនទៀតផង។

# ១៣៥
# គ្រូស្ចូឆេវ មេដឹកនាំសូវៀត
# មានបំណងចែចង់អ្នកម្នាងម៉ូនិក




**សម្តេចសីហនុ និងមេដឹកនាំសូវៀត គ្រូស្ចូឆេវ** (រូបថតGetty images)

នៅក្នុងខែមីនា ឆ្នាំ១៩៦០ សម្តេចសីហនុ និងបណ្តាមេដឹកនាំប្រទេសមិនចូលបក្សសម្ព័ន្ធទាំងអស់ បានទៅចូលរួមនៅក្នុងមហាសន្និបាតរបស់អង្គការសហប្រជាជាតិ។ អ្វីដែលធ្វើឱ្យព្រះអង្គនៅចងចាំបំផុតនោះ គឺពេលឡើងថ្លែងមតិនៅក្នុងមហាសន្និបាតនោះ នីគីតា គ្រូស្ចូឆេវ (Nikita Khrushchev) ជាអគ្គលេខាបក្សកុម្មុយនិស្តសូវៀត និងជាប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី នៃសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត បានផ្ទុះកំហឹងក្រេវក្រោធមួយរហូតដោះស្បែកជើងរបស់គាត់មកគោះលើតុវេទិកាដែលគាត់កំពុងឡើងមានមតិនោះ បណ្តាគណៈប្រតិភូប្រទេសលោកខាងលិច នាំគ្នាសើចចំអក ហើយអ្នកដែលមានការសោកស្តាយ និងអាម៉ាស់បំផុតចំពោះអំពើដ៏ប្រឡើសបើសកែមិនឡើងរបស់គ្រូស្ចូឆេវ នេះ គឺសមាជិក



**គ្រូស្ចូឆេវ អគ្គលេខាបក្សកុម្មុយនិស្តសូវៀត**

គណៈប្រតិភូសហភាពសូវៀត តែម្តង។

អង្គសន្និបាតទាំងមូលយល់ថា ការដោះស្បែកជើងមកគោះលើតុវេទិការបស់គ្រូស្ចូឆេវ បញ្ជាក់ឱ្យឃើញថា គាត់ជាមនុស្សគ្មានវប្បធម៌ និងសុជីវធម៌អ្វីបន្តិចឡើយ។

បន្ទាប់មកទៀត សម្តេចសីហនុ ក៏បានឃើញនូវអាកប្បកិរិយាច្រឡើសបើសរបស់មេដឹកនាំប្រទេសមហាអំណាចកុម្មុយនីស្តរូប នេះចំពោះព្រះអង្គផ្ទាល់តែម្តង គឺនៅក្នុងពិធីជប់លៀងមួយហៅថាខុកតៃ ផាធី( Cocktail Party ) ដែលរៀបចំដោយអង្គការសហប្រជាជាតិ ដើម្បីទទួលគណៈប្រតិភូទាំងអស់នោះ គ្រូស្ចូឆេវ បានសុំយាងព្រះអង្គឱ្យទៅបំពេញទស្សនកិច្ចនៅសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត។

នៅចំពោះមុខក្រុមអ្នកកាសែតអន្តរជាតិជាច្រើន គ្រូស្ចូឆេវ បានបញ្ជាក់ថា បើព្រះអង្គមិនយកមហេសីដ៏ស្រស់ស្អាតដែលធ្វើឱ្យគាត់រំភើបចិត្តនោះមកជាមួយទេ គាត់ក៏មិនឱ្យព្រះអង្គចូលប្រទេសគាត់ដែរ។

សម្តេចសីហនុ និងមហេសី ក៏បានយល់ព្រមតាមការយាងរបស់គ្រូស្ចូឆេវ ជាមេដឹកនាំកំពូលរបស់សហភាពសូវៀត ដ៏ច្រឡើសបើសរូបនេះ។

នៅក្រុងមូស្គូ ព្រះអង្គបានធ្វើការកត់សម្គាល់ថា គ្រូស្ចូឆេវ បានសម្តែងឱ្យឃើញនូវ

ការយកចិត្តទុកដាក់ផ្គាប់ផ្គុនចំពោះមហេសីរបស់ព្រះអង្គខ្លាំងណាស់ ហើយឡេអូនីដ ប្រេសណេវ (Leonid Brezhnev) ជាមេដឹកនាំលំដាប់ទី២របស់សហភាពសូវៀត ក៏ដូចគ្នាដែរ តែប្រេសណេវ ហាក់ដូចជាមានការញញើតញញើមបន្តិច នៅចំពោះមុខគ្រូស្ចេវ ជាមេកោយរបស់គាត់។



អ្នកម្នាងម៉ូនិក

នៅពេលព្រះអង្គជាប់មាត់សន្ទនាជាមួយគ្រូស្ចេវ នោះ ប្រេសណេវ ក៏បានហុចស្ករគ្រាប់ទៅមហេសីព្រះអង្គ និងបានលើកសរសើរពីរូបសម្រស់របស់មហេសីព្រះអង្គជារបៀបចែចង់ភ្លាមមួយរំពេច។ តែមហេសីព្រះអង្គក៏បានប្រកាន់នូវឥរិយាបថបែបការទូតរួច ជាស្រេចទៅហើយ ដោយមិនទទួលយកស្ករគ្រាប់នោះទេ គឺគ្រាន់តែញញឹមតបទៅប្រេសណេវ វិញតែប៉ុណ្ណោះ។

សម្ដេចសីហនុ ឈ្វេងយល់ថា ក្នុងវិមានក្រឹមឡាំង គ្រូស្ចេវ ហាក់ដូចជាជ្រុលបន្តិចហើយ ព្រោះសូម្បីពេលជួបពិភាក្សាជាមួយគាត់ស្ដីពីជំនួយសាងសង់ទំនប់វារីអគ្គិសនីនៅភ្នំកំចាយ ក្នុងខេត្តកំពត គាត់តម្រូវឱ្យមហេសីព្រះអង្គចូលរួមដែរ។

គាត់បានរៀបចំកៅអីសម្រាប់មហេសីព្រះអង្គនៅជ្រុងតុម្ខាង នៅចំពីមុខគាត់ ដើម្បីងាយស្រួលនឹងបានគយគន់សម្រស់មហេសីព្រះអង្គ។ ព្រះអង្គឈ្វេងយល់ថា នេះជាអាកប្បកិរិយារបស់មនុស្សខូច។

តែក្នុងពេលជួបពិភាក្សាគ្នានោះ រដ្ឋមន្ត្រីការបរទេសអង់ដ្រេ ហ្គ្រោមីកូ (Andrei Gromyko) ដែលជាមនុស្សហ្មត់ចត់ត្រឹមត្រូវ បានពិភាក្សាពីការសាងសង់ទំនប់វារីអគ្គិសនីស្ទឹងភ្នំកំចាយ ក្នុងបរិយាកាសដ៏អស្ចារ្យបំផុត ដែលផលិតអគ្គិសនីបាន១៩៣ម៉េហ្គាវ៉ាត់។



មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត



សាលាបច្ចេកទេសមិត្តភាពខ្មែរ-សូវៀត

ក្រោយការជួបពិភាក្សានោះ ព្រះអង្គបានរៀបចំឱ្យមានការសម្តែងសិល្បៈរបាំព្រះរាជទ្រព្យ ដើម្បីជាកិត្តិយសដល់ មេដឹកនាំសូវៀត ដែលជាម្ចាស់ផ្ទះផងដែរ។ ប៉ុន្តែ នៅពេលសម្តែងរបាំនោះចប់ គ្រូស្តធេវ ក៏បានទៅឆក់ក្បាំងមុខសត្វស្វា.ស ដែលសិល្បករខ្មែរពាក់សម្តែងរឿងរាមកេរ្តិ៍នោះ យកមកពាក់នៅលើមុខរបស់គាត់ រួចបញ្ចេញក្បាច់ត្រាប់តាមការសម្តែងនោះ ធ្វើឱ្យអ្នកទស្សនា និងសិល្បករខ្មែរនៅទីនោះផ្ទុះសំណើចគ្រប់ៗគ្នា។

ក្រៅពីជួយសាងសង់មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ជាមន្ទីរពេទ្យធំជាងគេបង្អស់នៅតំបន់អាស៊ីអាគ្នេយ៍ ដែលសម្តេចសីហនុ បានយាងជាអធិបតីក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៦០ នោះ សហភាពសាធារណរដ្ឋសង្គមនិយមសូវៀត ក៏មានគម្រោងជួយសាងសង់សាលាបច្ចេកទេសមិត្តភាពខ្មែរ-សូវៀត នៅក្រុងភ្នំពេញ និងទំនប់វារីអគ្គិសនីដ៏ទំនើបមួយនៅស្ទឹងកំចាយ ជាប់ជួរភ្នំដំរីនៅខេត្តកំពត ផងដែរ។ ពួកវិស្វករ និងអ្នកបច្ចេកទេសសូវៀតជាច្រើននាក់ បានមកធ្វើការសិក្សាយ៉ាងល្អិតល្អន់ពីគម្រោងនេះដល់កន្លែង និងគ្រោងសាងសង់បុរីមួយកន្លែងសម្រាប់ពួកវិស្វករ និងអ្នកបច្ចេកទេសសូវៀតទៀតផង។ ប៉ុន្តែ នៅទីបំផុត គ្រូស្តធេវ បែរជាប្រាប់ថា ថវិកាជាតិរបស់គាត់កំពុងជួបការខ្វះខាត គម្រោងនោះក៏ត្រូវអាក់ខានទៅវិញ។ ប៉ុន្តែប៉ុន្មានឆ្នាំក្រោយមក ប្រទេសឆេកូស្លូវ៉ាគី និងយូហ្គោស្លាវី ក៏បានជួយសាងសង់ទំនប់វារីអគ្គិសនីមួយនៅគិរីរម្យ ទៅវិញ ដែលផលិតអគ្គិសនី បាន១២មេហ្គាវ៉ាត់ និងសាងសង់ស្ថានីយ៍តម្លើងអគ្គិសនីនៅផ្សារតូចមួយកន្លែងទៀត។

# ១៣៦
# បក្សប្រជាជនបដិវត្តន៍ខ្មែរ
# ដូរឈ្មោះជាបក្សពលករកម្ពុជា វិញ



**សឺង ង៉ុកមិញ មេដឹកនាំបក្សប្រជាជនបដិវត្តន៍ខ្មែរ**

នៅក្នុងមហាសន្និបាតរបស់ខ្លួននាខែមករា និងខែឧសភា ឆ្នាំ១៩៥៩ បក្សពលករវៀតណាម បានសម្រេចប្រែក្លាយចលនាតស៊ូនយោបាយនៅក្នុងប្រទេសវៀតណាមខាងត្បូងឱ្យទៅជាការតស៊ូដោយអាវុធដើម្បីប្រឆាំងនឹងរបបគ្រប់គ្រងង៉ូ ឌិញយៀម ដែលបានបង្ក្រាបចលនាតស៊ូនយោបាយរបស់ពួកគេយ៉ាងសាហាវព្រៃផ្សៃបំផុត នោះ។

មេដឹកនាំវៀតណាមខាងជើង ចាប់ផ្តើមកសាងផ្លូវលំហូជីមិញកាត់ព្រៃភ្នំ និងកាត់ប្រទេសលាវ និងកម្ពុជា ចូលទៅប្រទេសវៀតណាមខាងត្បូង ដើម្បីបញ្ជូនកងទ័ព និងអាវុធយុទ្ធភណ្ឌ មកធ្វើសង្គ្រាមជួយរំដោះប្រទេសវៀតណាមខាងត្បូង។

## របត់នយោបាយ

នៅក្នុងឆ្នាំ១៩៦០ នោះដែរ បក្សប្រជាជនបដិវត្តន៍លាវ ដែលកិច្ចព្រមព្រៀងក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ សម្រេចឱ្យកាន់កាប់ត្រួតត្រាខេត្តពីរ នៅជាប់ព្រំដែនប្រទេសវៀតណាមខាងជើងនោះ ក៏បានរួមចំណែកសំខាន់ក្នុងការការពារផ្លូវលំ ហូជីមិញ នោះដែរ។

ចំណែកចលនាតស៊ូកុម្មុយនិស្តនៅកម្ពុជា មិនទាន់មានលទ្ធភាពធ្វើការតស៊ូដោយអាវុធ ដូចពួកកុម្មុយនិស្តវៀតណាមទេ គឺបានត្រឹមតែតស៊ូនយោបាយប៉ុណ្ណោះ។

ពីថ្ងៃទី២៨ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០ បក្សប្រជាជនបដិវត្តន៍ខ្មែរ បានប្រារព្ធធ្វើមហាសន្និបាតលើកទី២ របស់ខ្លួន ដោយលួចលាក់នៅក្នុងបន្ទប់ការិយាល័យធ្វើការ របស់ ជួន ប្រាសិទ្ធ ជាអតីតនិស្សិតវិស្វករមកពីប្រទេសបារាំង ដោយមានតំណាង១៤រូប មកពីជនបទ និងតំណាង៧រូប មកពីក្រុងភ្នំពេញ។

មហាសន្និបាតបានសម្រេចប្តូរឈ្មោះបក្សប្រជាជនបដិវត្តន៍ខ្មែរ ឱ្យទៅជាបក្សពលករកម្ពុជាវិញ ដូចបក្សពលករវៀតណាម ដែលកំពុងដឹកនាំប្រទេសវៀតណាមខាងជើងផងដែរ។

ទូ សាមុត ត្រូវបានជ្រើសតាំងជាអគ្គលេខាគណៈកម្មាធិការមជ្ឈិមបក្ស និងនួន ជាជាអនុលេខា អៀង សារី, កែវ មាស, សឹង ង៉ុកមិញ (ទាំង៣នាក់អវត្តមាន), សោ ភឹម សមាជិកគណៈកម្មាធិការមជ្ឈិមបក្ស។ ឯជួន ប្រាសិទ្ធិ និងនង សួន ជាសមាជិកបម្រុងនៃគណៈកម្មាធិការមជ្ឈិមបក្ស។ ចំណែក សាឡុត ស ជាជំនួយការរបស់ទូ សាមុត។ ទូ សាមុត សឹង ង៉ុកមិញ, កែវ មាស និងសោ ភឹម សុទ្ធតែជាអតីតសមាជិកបក្សកុម្មុយនិស្តឥណ្ឌូចិន។ ការជ្រើសរើសយកទីតាំងនៅស្ថានីយរថភ្លើង ធ្វើជាកន្លែងប្រារព្ធមហាសន្និបាតនោះ គឺដោយសារ ជួន ប្រាសិទ្ធ កំពុងបម្រើការងារជាមន្ត្រីរាជការម្នាក់នៅទីនោះ។ មហាសន្និបាតបក្សនៅពេលនោះ ក្រៅពីរៀបចំសមាសភាពក្បាលម៉ាស៊ីនដឹកនាំបក្ស ក៏បានអនុម័តពីគោលនយោបាយយុទ្ធសាស្ត្រ និងយុទ្ធវិធីផ្សេងៗរបស់បក្ស និងអនុម័តលក្ខន្តិកៈបក្សផងដែរ។ តែទោះបីយ៉ាងណា បក្សនេះនៅតែមានសម្ព័ន្ធភាពជាមួយបក្សពលករវៀតណាម ដែរ។

ការបញ្ចូលឈ្មោះរបស់សឹង ង៉ុកមិញ ដែលជាអតីតលេខាបក្សប្រជាជនបដិវត្តន៍ខ្មែរ

តាំងពីឆ្នាំ១៩៥១ មកជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្សដែរនោះ គឺគ្រាន់តែជានិមិត្តរូបប៉ុណ្ណោះ ព្រោះគាត់បានទៅរស់នៅវៀតណាមភាគខាងជើង តាំងពីឆ្នាំ១៩៥៤ មកម្ល៉េះ។

មហាសន្និបាតនេះ បានប្រារព្ធធ្វើឡើងពីរសប្តាហ៍ ក្រោយពីមហាសន្និបាតបក្សលើកទី៣ របស់បក្សពលកវៀតណាម(វៀតណាមខាងជើង) បានអនុម័តឱ្យបង្កើតរណសិរ្សរំដោះជាតិវៀតណាមខាងត្បូង ដែលហៅកាត់ថា វៀតកុង (Viêt Công) ដើម្បីធ្វើការតស៊ូរំដោះវៀតណាមខាងត្បូង ឱ្យទៅជាប្រទេសកុម្មុយនិស្ត ដូចវៀតណាមខាងជើងដែរ។

នៅចុងឆ្នាំ១៩៦០ សហរដ្ឋអាមេរិក និងវៀតណាមខាងត្បូង បានប្រកាសថា នៅភាគឦសានប្រទេសកម្ពុជា មានផ្លូវលំហូជីមិញ ខ្វាត់ខ្វែង និងមានកងទ័ពវៀតកុង-វៀតណាមខាងជើង ប្រមាណ៨០០០នាក់ កំពុងបោះទីតាំងនៅតំបន់នោះផងដែរ។

# ១៣៧
# សម្តេចសីហនុ យាងទៅជួបទីតូ និងចន កេណ្ណឺឌី




**សម្តេចសីហនុ នៅទីក្រុងបែលក្រាដ**

នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៦១ រាជរដ្ឋាភិបាលដែលមាន ផូ ព្រឿង ជានាយករដ្ឋមន្រ្តី ត្រូវប្រកាសរំសាយ ហើយសម្តេចសីហនុ បានរៀបចំរាជរដ្ឋាភិបាលថ្មីមួយទៀត ដែលមានព្រះអង្គផ្ទាល់ ជានាយករដ្ឋមន្រ្តី , ប៉ែន នុត ជាឧបនាយករដ្ឋមន្រ្តី- រដ្ឋមន្រ្តីក្រសួងមហាផ្ទៃ និងធម្មការ, ញឹក ជូឡុង ជាទេសរដ្ឋមន្រ្តី ទទួលបន្ទុកការបរទេស និងទេសចរណ៍, សឺន សាន ទេសរដ្ឋមន្រ្តី ទទួលបន្ទុកហិរញ្ញវត្ថុ និងសេដ្ឋកិច្ច, លន់ នល់ ជាទេសរដ្ឋមន្រ្តីទទួលបន្ទុកការពារជាតិ, ទេព ផន ជាទេសរដ្ឋមន្រ្តីទទួលបន្ទុកផែនការ និងជាអភិបាលរាជធានីភ្នំពេញ, ជា ជិនកុក ជារដ្ឋមន្រ្តីព័ត៌មាន និងវិចិត្រសិល្បៈ, ឃួន គីមម៉ន ជារដ្ឋមន្រ្តីយុត្តិធម៌, អ៊ឹង ហុងសាធ ជារដ្ឋមន្រ្តីសាធារណសុខាភិបាល- សង្គមកិច្ច និងការងារ, អ៊ឹង ក្រពុំផ្កា ជារដ្ឋមន្រ្តី

ឧស្សាហកម្ម សាធារណការ និងទូរគមនាគមន៍, ទ្រង់ស៊ីសុវត្ថិ ប៉ូរ៉ាស៊ី ជារដ្ឋលេខាធិការសេដ្ឋកិច្ច ទទួលបន្ទុកកសិកម្ម, ឌី សាត រដ្ឋលេខាធិការមហាផ្ទៃ ទទួលបន្ទុកសន្តិសុខជាតិ (ជាអគ្គនាយកដ្ឋានរាជនគរបាល)និងការពារលើផ្ទៃប្រទេស (សេនាធិការ), ស៊ិន ប៉ូចកោ ជារដ្ឋលេខាធិការធម្មការ និងទំនាក់ទំនងសភា, ព្រុំ ថុស ជារដ្ឋលេខាធិការសេដ្ឋកិច្ចជាតិ ទទួលបន្ទុកពាណិជ្ជកម្ម , គឹម យន ជារដ្ឋលេខាធិការ ហិរញ្ញវត្ថុ ,ទ្រង់នរោត្តម ភូរិស្សារ៉ា ជាអនុរដ្ឋលេខាធិការមហាផ្ទៃ , អ៊ឹង ប៊ុនហោ អនុរដ្ឋលេខាធិការការងារ និងសង្គមកិច្ច, ទុំ គឹមហេង អនុរដ្ឋលេខាធិការឧស្សាហកម្ម, ឌី បែលឡុង ជាអនុរដ្ឋលេខាធិការផែនការ ទទួលបន្ទុកលំនៅឋានជនបទ និងអាណានិគមកម្ម។

នៅក្នុងខែសីហា ឆ្នាំ១៩៦១ ក្នុងនាមជាព្រះប្រមុខរដ្ឋ នៃព្រះរាជាណាចក្រកម្ពុជា សម្តេចសីហនុ បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់មួយក្រុម ទៅចូលរួមប្រជុំសន្និសីទលើកទី១នៃបណ្តាប្រទេសមិនចូលបក្សសម្ព័ន្ធ នៅទីក្រុងបែលហ្រ្គាដ នៃសហព័ន្ធយូហ្គោស្លាវី ពេលនោះ ហ៊ូ នឹម ជាអនុប្រធានរដ្ឋសភា ក៏ជាសមាជិកប្រតិភូនេះដែរ។

នៅក្នុងសន្និសីទនោះ បណ្តាប្រទេសមិនចូលបក្សសម្ព័ន្ធទាំងអស់ បានចេញសេចក្តីថ្លែងការណ៍រួមមួយថា ការបង្កើតនូវអង្គការនេះឡើង ជាសម័យកាលបង្ហាញនូវក្តីសង្ឃឹមនៃយុត្តិធម៌ និងសេរីភាពចំពោះបណ្តាប្រទេសជាច្រើននៅលើសាកលលោក ហើយបើមានប្រទេសណាមួយនៅក្នុងអង្គការនេះងាកវេទៅរកនយោបាយឆ្វេងនិយមនោះ ក៏មិនចាត់ទុកប្រទេសនោះថា ជាអ្នកបង្កើតប្លុកនយោបាយដែរ។ ទន្ទឹមនេះ អង្គការបណ្តាប្រទេសមិនចូលបក្សសម្ព័ន្ធនឹងធ្វើការទប់ទល់ចំពោះការគាបសង្កត់ដ៏ធ្ងន់ក្រៃណាមួយ ពីសំណាក់មហាអំណាចទាំង២ (លោកសេរី និងកុម្មុយនិស្ត) ដែលប្រមាថមើលងាយ ឬរំលោភបំពានដល់អធិបតេយ្យភាព ដើម្បីត្រួតត្រាប្រទេសណាមួយជាសមាជិករបស់ខ្លួន។

ពេលនោះ សម្តេចសីហនុ ក៏បានឡើងប្រកាសទទួលស្គាល់ជាផ្លូវការថា រដ្ឋាភិបាលបណ្តោះអាសន្នរបស់សាធារណរដ្ឋអាល់ហ្សេរី ដែលកំពុងប្រយុទ្ធតស៊ូទាមទារឯករាជ្យពីប្រទេសអាណានិគមបារាំងនោះថា ជារដ្ឋាភិបាលស្របច្បាប់ផងដែរ។

## របត់នយោបាយ

ការប្រកាសទទួលស្គាល់រដ្ឋាភិបាលបណ្ដោះអាសន្ន នៃសាធារណរដ្ឋអាល់ហ្សេរី នេះ ធ្វើឱ្យមានការភ្ញាក់ផ្អើល និងចាប់អារម្មណ៍ពីអ្នកសង្កេតការណ៍អន្តរជាតិជាខ្លាំង ព្រោះការប្រកាសបែបនេះអាចជាគ្រោះថ្នាក់ដល់ស្ថិរភាពនយោបាយរបស់ប្រទេសព្រះអង្គផងដែរ។ ប៉ុន្តែ សម្ដេចសីហនុ បានគិតគូរល្អិតល្អន់ជាមុនរួចទៅហើយ ព្រះអង្គមានវិធីពន្យល់ពីហេតុផលនៃការទទួលស្គាល់រដ្ឋាភិបាលបណ្ដោះអាសន្នរបស់ប្រទេសអាល់ហ្សេរី នេះ ដោយឈរលើគោលជំហរគាំទ្រយុត្តិធម៌ចំពោះប្រជាជាតិមួយ ដែលទាមទារឯករាជ្យរបស់ខ្លួនពីប្រទេសបារាំង ដូចកាលព្រះអង្គទាមទារឯករាជ្យមកឱ្យមាតុប្រទេសរបស់ព្រះអង្គ កាលពីដើមទសវត្សរ៍ឆ្នាំ១៩៥០ ដែរ។

ក្រសួងការបរទេសបារាំង មិនសប្បាយចិត្តចំពោះការប្រកាសទទួលស្គាល់រដ្ឋាភិបាលបណ្ដោះអាសន្នរបស់ប្រទេសអាល់ហ្សេរី របស់ព្រះអង្គនោះឡើយ តែក៏មិនបង្ហាញឱ្យឃើញនូវប្រតិកម្មដ៏ខ្លាំងក្លាណាមួយមកលើព្រះអង្គដែរ។

ប្រទេសអាល់ហ្សេរី ត្រូវបានប្រទេសបារាំងចូលឈ្លានពាន និងធ្វើអាណានិគម តាំងពីឆ្នាំ១៨៣០មកម្ល៉េះ។ នៅក្នុងឆ្នាំ១៩៥៤ រណសិរ្សរំដោះជាតិ (FLN) និងរដ្ឋាភិបាលបណ្ដោះអាសន្នរបស់ប្រទេសអាល់ហ្សេរី ត្រូវបានបង្កើតឡើង ដើម្បីធ្វើការតស៊ូទាមទារឯករាជ្យពីប្រទេសបារាំង មកវិញ។

ក្រោយពីមានកិច្ចព្រមព្រៀងនៅក្រុងអេវីយ៉ង់ (Evian) ខែមីនា ឆ្នាំ១៩៦២ ប្រទេសអាល់ហ្សេរី ក៏បានទទួលឯករាជ្យពេញលេញ។

លោកប៊ីន ខេដដា (Ben khedda) ជាមេដឹកនាំលំដាប់ទី៣ នៃរដ្ឋាភិបាលបណ្ដោះអាសន្ន និងរណសិរ្សរំដោះជាតិ(FLN)អាល់ហ្សេរី ក៏បានសុំចូលគាល់ព្រះអង្គនៅកន្លែងព្រះអង្គគង់ក្នុងសណ្ឋាគារមួយ ខណៈដែលព្រះអង្គចូលរួមសន្និសីទនោះ ដោយទទូចសុំឱ្យព្រះអង្គមេត្តាជួយអូសទាញបញ្ចុះបញ្ចូលឱ្យមេដឹកនាំប្រទេសផ្សេងៗទៀត ឱ្យទទួលស្គាល់រដ្ឋាភិបាលបណ្ដោះអាសន្នរបស់លោក ដូចជាព្រះអង្គដែរ។

គណៈប្រតិភូរបស់ប្រទេសអារ៉ាប់ បានទះដៃអបអរសាទរយ៉ាងខ្លាំង ចំពោះការប្រកាស




**សម្តេចសីហនុ និងមហេសី ជូនដំណើរសេនាប្រមុខទីតូ និងភរិយា ទៅទស្សនាប្រាសាទអង្គរ**

គាំទ្ររដ្ឋាភិបាលបណ្តោះអាសន្ននៃប្រទេសអាល់ហ្សេរី របស់សម្តេចសីហនុ នេះ។ បន្ទាប់មក សេនាប្រមុខទីតូ ក៏បានប្រកាសថា ប្រទេសយូហ្គោស្លាវី ក៏ទទួលស្គាល់រដ្ឋាភិបាលបណ្តោះអាសន្នអាល់ហ្សេរី (GPRA) ដូចសម្តេចសីហនុ ដែរ។

ចុងបញ្ចប់នៃសន្និសីទបណ្តាប្រទេសមិនចូលបក្សសម្ព័ន្ធ មានភាពតានតឹងបន្តិចពីបញ្ហាតាក់តែងសេចក្តីប្រកាសរួម ដោយសារតែការប៉ះទង្គិចពាក្យសម្តីគ្នារវាងមេដឹកនាំបណ្តាប្រទេស ដែលប្រឆាំងនឹងពួកចក្រពត្តិនិយម(ប្រទេសកុម្មុយនិស្ត) ជាមួយបណ្តាប្រទេសដែលស្និទ្ធនឹងលោកខាងលិច។

ការជជែកគ្នានៅក្នុងការតាក់តែងសេចក្តីថ្លែងការណ៍រួមនេះ ត្រូវបានជជែកគ្នាយ៉ាងស្វិតស្វាញ រហូតដល់ពាក់កណ្តាលអធ្រាត្រ ព្រះមហាក្សត្រនៃប្រទេសនេប៉ាល់ មិនសព្វព្រះទ័យចំពោះការជជែកគ្នាល្អិតល្អន់ពេក គ្មានបានផលប្រយោជន៍នោះ ព្រះអង្គបានយាង



**សម្តេចសីហនុ និងប្រធានាធិបតី ចន កេណ្ណឌី**

ចេញពីអង្គប្រជុំ ដោយមានបន្ទូលថា ព្រះអង្គយាងទៅសម្រាកហើយ ព្រោះព្រឹកស្អែកត្រូវភ្ញាក់ពីព្រលឹម។

នៅក្នុងឱកាសធ្វើសន្និសីទនោះដែរ បណ្តាប្រទេសជាសមាជិកអង្គការបណ្តាប្រទេសមិនចូលបក្សសម្ព័ន្ធទាំងអស់ ក៏មានការរៀបចំតាំងពិព័រណ៍អន្តរជាតិមួយ ដោយដាក់តាំងបង្ហាញពីសមិទ្ធផល និងវប្បធម៌នៅតាមប្រទេសនីមួយៗ។ ពេលនោះប្រទេសកម្ពុជា ទទួលបាននូវការកោតសរសើរ ពីការដាក់តាំងនូវរូបចម្លាក់បដិមាតូចៗ និងរូបចម្លាក់ផ្សេងៗទៀតតាមរចនាប័ទ្មអង្គរ ព្រមទាំងសាច់សំពត់ធ្វើពីអំបោះសូត្រដ៏ប្រណីតផងដែរ។

សម្តេចសីហនុ បានប្រគល់ជូននូវរូបបដិមាព្រះកេសព្រះរាជាខ្មែរពីសម័យអង្គរមួយ



**សម្តេចសីហនុ និងប្រធានាធិបតី ចន កេណ្ណឌី**

អង្គ ចំពោះសេនាប្រមុខទីតូ មេដឹកនាំប្រទេសយូហ្គោស្លាវី ធ្វើឱ្យលោកមានក្តីរំភើបរីករាយបំផុត។

ក្រោយពីបញ្ចប់កិច្ចប្រជុំសន្និសីទ នៅក្រុងបែលហ្ក្រាដនោះ សម្តេចសីហនុ បានបន្តព្រះរាជដំណើរទៅកាន់សហរដ្ឋអាមេរិក ជាថ្មីម្តងទៀត។

នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៦១ ព្រះអង្គបានជួបសម្តែងការគួរសមជាមួយលោកប្រធានាធិបតី ចន កេណ្ណឌី(John Kennedy) និងមន្ត្រីជាន់ខ្ពស់សហរដ្ឋអាមេរិកជាច្រើនរូបទៀត នៅសណ្ឋាគារ Carlyle នៅក្នុងទីក្រុងញូវយ៉ក ដោយមានវត្តមានឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ប្រចាំអង្គការសហប្រជាជាតិ អាដឡាយ ស្ទេវិនសុន (Adlai Stevenson), ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា វីល្លៀម ទ្រីមប៊ល (William Trimble) និងឧបការីរងរដ្ឋលេខាធិការក្រសួងការបរទេសសហរដ្ឋអាមេរិក ទទួលបន្ទុកកិច្ចការចុងបូព៌ា ចន ស្ទីវេស (John Steeves) ចូលរួមផងដែរ។ ឯខាងកម្ពុជា មាន ញឹក ជូឡុង ជារដ្ឋមន្ត្រីក្រសួងការបរទេស និងនង គីមនី ជាឯកអគ្គរាជទូតកម្ពុជា ប្រចាំសហរដ្ឋអាមេរិក។

# ១៣៨
# តុលាការក្រុងឡាអេ ៖ ប្រាសាទព្រះវិហារជារបស់ខ្មែរ



**ប្រាសាទព្រះវិហារ កាលក្នុងអំឡុងឆ្នាំ១៩៣០**

តាមពិតទៅ ប្រទេសថៃ បានចូលដណ្ដើមកាន់កាប់ប្រាសាទព្រះវិហារ ដោយខុសច្បាប់តាំងពីឆ្នាំ១៩៤០មកម្ល៉េះ ហើយបានដាក់បញ្ចូលប្រាសាទព្រះវិហារនេះទៅក្នុងបញ្ជីបេតិកភណ្ឌរបស់ថៃ នៅឆ្នាំ១៩៤០នោះដែរ។ នៅឆ្នាំ១៩៤១ ប្រទេសថៃ បានដាក់ឆ្មាំការពាររបស់ខ្លួននៅក្នុងប្រាសាទព្រះវិហារនេះ។

ដោយមានប្រទេសជប៉ុន គាំទ្រប្រទេសថៃផងនោះ នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៤១ អនុសញ្ញាបារាំងសៀមមួយ ត្រូវបានចុះហត្ថលេខា នៅទីក្រុងតូក្យូ។ តាមអនុសញ្ញានេះ ទឹកដីខេត្តបាត់ដំបង, ខេត្តកំពង់ធំមួយភាគ និងខេត្តសៀមរាប មួយភាគរបស់កម្ពុជា ត្រូវកាត់ទៅឲ្យប្រទេសថៃ។ ប៉ុន្តែ៥ឆ្នាំក្រោយមក បន្ទាប់ពីប្រទេសជប៉ុន ចាញ់សង្គ្រាមលោកលើកទី២ គឺនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤៦ នៅទីក្រុងវ៉ាស៊ីនតោន មានកិច្ចព្រមព្រៀង

បារាំង-សៀម ត្រូវបានរំលាយចោលនូវ អនុសញ្ញាចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៤១ នោះវិញ។ ដូច្នេះថៃ ត្រូវប្រគល់ទឹកដីខេត្តបាត់ដំបង, ខេត្តកំពង់ធំមួយភាគ និងខេត្តសៀមរាបមួយភាគ របស់កម្ពុជា ដែលខ្លួនបានកាន់កាប់ចាប់ពីឆ្នាំ១៩៤១ នោះ មកឱ្យខ្មែរវិញ។ ពេលនោះ ប្រទេសថៃ បានប្រគល់ប្រាសាទវត្តភូ ឱ្យទៅប្រទេសឡាវ វិញដែរ ប៉ុន្តែប្រទេសថៃ មិនព្រមប្រគល់ប្រាសាទព្រះវិហារ មកឱ្យកម្ពុជាវិញឡើយ។



ថាណាត់ ខូម៉ាន់ រដ្ឋមន្ត្រីការបរទេសថៃ

លុះដល់អំឡុងទទួលបានឯករាជ្យពីបារាំង នាថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ រដ្ឋាភិបាលកម្ពុជា ក៏បានទាមទារប្រាសាទព្រះវិហារ បានមកវិញ ហើយបានចាត់តាំងជនជាតិខ្មែរបីនាក់ ឱ្យទៅធ្វើជាឆ្មាំថែរក្សាប្រាសាទនោះ។ ប៉ុន្តែជនជាតិខ្មែរទាំងបីនាក់នោះត្រូវអាជ្ញាធរថៃ ដេញឲ្យចាកចេញពីប្រាសាទព្រះវិហារ នោះវិញ។ នៅឆ្នាំ១៩៥៤ រដ្ឋាភិបាលកម្ពុជា បានព្រមានទៅរដ្ឋាភិបាលក្រុងបាងកក ថា នឹងបញ្ជូនកងទ័ពឲ្យទៅការពារប្រាសាទព្រះវិហារ ជំនួសឆ្មាំកម្ពុជា ដែលត្រូវអាជ្ញាធរថៃ ដេញឲ្យចាកចេញពីប្រាសាទព្រះវិហារ នោះ។ ប៉ុន្តែមុនពេលអនុវត្តគម្រោងនៃការព្រមាននេះ រដ្ឋាភិបាលក្រុងបាងកក បានបញ្ជូនកងទ័ពរបស់ខ្លួនឲ្យមកឈរជើងនៅប្រាសាទព្រះវិហារនេះ ដោយខុសច្បាប់ជាមុនស្រេចទៅហើយ។

ក្រោយពីរដ្ឋមន្ត្រីការបរទេសថៃ ថាណាត់ ខូម៉ាន់ ( Thanat Koman ) មកទស្សនកិច្ចជាផ្លូវការនៅកម្ពុជា ក្នុងខែមិថុនា ឆ្នាំ១៩៥៩ មក រដ្ឋាភិបាលកម្ពុជា បានដាក់សំណើថ្មីសម្រាប់ឱ្យមេដឹកនាំថៃ ជ្រើសរើស។ សំណើនោះគឺ ការគ្រប់គ្រងប្រាសាទរួមគ្នា ដោយប្រទេសកម្ពុជា រក្សានូវសិទ្ធិអធិបតេយ្យភាពរបស់ខ្លួន។ បើសិនមិនយល់ព្រមតាមនោះទេ ប្រទេស



**តុលាការក្រុងឡាអេ បើកសវនាការពីបញ្ហាប្រាសាទព្រះវិហារ**

កម្ពុជា នឹងដាក់ពាក្យបណ្ដឹងទៅតុលាការយុត្តិធម៌អន្តរជាតិ (ICJ) នៅក្រុងឡាអេ។ ក្រោយពីទទួលបរាជ័យតាមដំណោះស្រាយផ្លូវទូតមក កម្ពុជា ក៏បានងាកទៅរកយន្តការតុលាការវិញម្ដង តាមរយៈការដាក់ពាក្យបណ្ដឹងទៅតុលាការយុត្តិធម៌អន្តរជាតិ (ICJ) ក្រុងឡាអេ ប្រទេសហូឡង់ នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៥៩ ដើម្បីទាមទារឱ្យថៃ ដកកងកម្លាំងប្រដាប់អាវុធទាំងអស់ចេញពីប្រាសាទ និងប្រគល់ប្រាសាទព្រះវិហារមកឱ្យកម្ពុជា វិញ។

នៅថ្ងៃទី០៨ ធ្នូ ឆ្នាំ១៩៥៩ តុលាការបានចេញដីកាបង្គាប់កំណត់កាលបរិច្ឆេទដែលកម្ពុជា និងថៃ ត្រូវបញ្ជូនសារណាតបទៅតុលាការ។ សារណារបស់កម្ពុជា ត្រូវបានបញ្ជូនទៅដល់ដៃតុលាការតាមពេលកំណត់។ ចំណែកថៃ វិញ ដល់ពេលកំណត់ត្រូវបញ្ជូនសារណានោះ ថៃ បែរជាបានបញ្ជូនពាក្យបណ្ដឹងជំទាស់មួយថា ការជំនុំជម្រះពាក្យបណ្ដឹងរបស់កម្ពុជា មិនស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការអន្តរជាតិមួយនេះ ទៅវិញ។ ការបើកសវនាការសាធារណៈ ដើម្បីជំនុំជម្រះលើបណ្ដឹងជំទាស់របស់ថៃ ត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី១០ រហូតដល់ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៦០។ ពេលនោះ រដ្ឋាភិបាលកម្ពុជា បានបញ្ជូនលោក

ទៀង កាង ជាសមាជិកឧត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក និងមេធាវីបរទេសបីរូប គឺ៖

១.លោក ឌីន អាចេសុន (Dean Acheson) ជាសមាជិកស្មាក្តី នៃតុលាការកំពូលសហរដ្ឋអាមេរិច។

២.លោក រ៉ូហ្សេ ពិនតូ (Roger Pinto) ជាសាស្ត្រាចារ្យមហាវិទ្យាល័យនីតិសាស្ត្រក្រុងប៉ារីស។ ៣.លោក ប៉ូល រ៉ឺទ័រ (Paul Reuter) ជាសាស្ត្រាចារ្យមហាវិទ្យាល័យនីតិសាស្ត្រក្រុងប៉ារីស។ ចំណែកខាងភាគីថៃ ដឹកនាំដោយព្រះអង្គម្ចាស់ វង់សាម៉ាហ៊ីប ចាយ៉ាន់គូរ៉ា (Vongsamahip Jayankura) ជាឯកអគ្គរាជទូតថៃ ប្រចាំប្រទេសហូឡង់។ នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៦១ តុលាការក្រុងឡាអេ បានចេញសេចក្តីសម្រេចច្រានចោលបណ្តឹងជំទាស់របស់ថៃ ហើយប្រកាសថា តុលាការយុត្តិធម៌អន្តរជាតិ(ICJ)មានសមត្ថកិច្ចពេញលេញក្នុងការជំនុំជម្រះលើបណ្តឹងរបស់កម្ពុជា។

នៅក្នុងសារណាជាលាយលក្ខណ៍អក្សរ ព្រមទាំងនៅក្នុងអំឡុងសវនាការផ្ទាល់មាត់ជាបន្តបន្ទាប់ កម្ពុជាបានលើកយក "ផែនទីភ្នំដងរែក" (ផែនទីឧបសម្ព័ន្ធទី១) ដែលជាផែនទីភ្ជាប់ជាមួយនឹងសន្ធិសញ្ញាបារាំង-សៀម ឆ្នាំ១៩០៤ មកធ្វើជាមូលដ្ឋានច្បាប់។ តាមរយៈខ្សែបន្ទាត់ព្រំដែននៅក្នុងផែនទីឧបសម្ព័ន្ធទី១នេះ បង្ហាញថា ប្រាសាទព្រះវិហារស្ថិតនៅក្នុងទឹកដីរបស់កម្ពុជាយ៉ាងពិតប្រាកដ។ ក៏ប៉ុន្តែភាគីថៃ បានលើកឡើងថា នៅក្នុងពាក្យបណ្តឹងដំបូង កម្ពុជាទាមទារតែរឿងប្រាសាទព្រះវិហារប៉ុណ្ណោះ មិនបាននិយាយអំពីបញ្ហាព្រំដែននោះទេ។ ដូច្នេះតុលាការមិនអាចសម្រេចសេចក្តីទាក់ទងនឹងបញ្ហាព្រំដែនកម្ពុជា និងថៃ បានទេ។

ក្រោយបើកសវនាការសាធារណៈ រយៈពេល២ឆ្នាំ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២ តុលាការយុត្តិធម៌អន្តរជាតិ (ICJ) នៅទីក្រុងឡាអេ បានចេញសាលក្រមសម្រេចឱ្យភាគីកម្ពុជា ឈ្នះក្តីលើប្រាសាទព្រះវិហារនេះ។

សាលក្រមរបស់តុលាការយុត្តិធម៌អន្តរជាតិ (ICJ) ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២ បានសម្រេចចេញសាលក្រមថា ៖ ដើម្បីទាមទារអធិបតេយ្យលើ ប្រាសាទព្រះវិហារ ទាំង

## របត់នយោបាយ

ភាគីកម្ពុជា និងភាគីថៃ សុទ្ធតែបានអះអាងរៀងៗខ្លួនថា ប្រាសាទព្រះវិហារស្ថិតនៅក្នុងទឹកដីរបស់ខ្លួន។ ដូច្នេះជាតុពិតនៃជម្លោះរវាងកម្ពុជា និងថៃ ដែលនាំឱ្យមានការប្តឹងផ្តល់មកដល់តុលាការនេះ គឺជាជម្លោះស្តីពីអធិបតេយ្យដែនដី ដូច្នេះដើម្បីកាត់សេចក្តីទៅលើអធិប-តេយ្យដែនដីនៅក្នុងតំបន់ប្រាសាទព្រះវិហារ តុលាការចាំបាច់ត្រូវតែកំណត់អំពីព្រំដែនរវាងកម្ពុជា និងថៃ នៅក្នុងតំបន់ប្រាសាទនេះ ឱ្យបានត្រឹមត្រូវផងដែរ។ ដោយយោងទៅលើខ្សែបន្ទាត់ព្រំដែននេះ តុលាការយុត្តិធម៌អន្តរជាតិក្រុងឡាអេ បានសម្រេចសេចក្តីថា ៖

-ប្រាសាទព្រះវិហារ ស្ថិតនៅក្នុងទឹកដី ក្រោមអធិបតេយ្យរបស់កម្ពុជា(អនុម័តដោយ ៩សំឡេង ទល់នឹង៣)។

-ថៃ ត្រូវតែដកកងទ័ព ប៉ូលិស ឬឆ្មាំផ្សេងៗទៀតដែលឈរជើងនៅក្នុងប្រាសាទ និងនៅជុំវិញប្រាសាទ ក្នុងដែនរបស់កម្ពុជា(៩សំឡេង ទល់នឹង៣)។

-ថៃ ត្រូវប្រគល់នូវរាល់វត្ថុបុរាណ ដូចជារូបចម្លាក់ សិលាចារឹក គ្រឿងចានឆ្នាំងធ្វើអំពីដីដុត ជាដើម ដែលខ្លួនបានយកចេញពីប្រាសាទព្រះវិហារ ឬពីតំបន់ប្រាសាទ ក្នុងអំឡុងពេលដែលថៃកាន់កាប់ប្រាសាទនេះ ចាប់តាំងពីឆ្នាំ១៩៥៤ ត្រលប់មកឱ្យកម្ពុជាវិញ (៧សំឡេងទល់ នឹង៥)។

គួររម្លឹកឡើងវិញដែរថា តាមសន្ធិសញ្ញាបារាំង-សៀម ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩០៤ សៀមត្រូវប្រគល់ខេត្តម្លូព្រៃ និងទន្លេរពៅ ដែលស្ថិតនៅត្រើយខាងលិច នៃទន្លេមេគង្គ មកឱ្យកម្ពុជាវិញ។ នៅក្នុងឆ្នាំ១៩០៤ នោះផងដែរ សៀម ត្រូវប្រគល់ខេត្តត្រាត ដែលជាខេត្តខ្មែរនៅតំបន់ឆ្នេរសមុទ្រ មកកម្ពុជាវិញ។

សន្ធិសញ្ញាបារាំង-សៀម ថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩០៧ តម្រូវឱ្យសៀម ប្រគល់មកឱ្យកម្ពុជា នូវទឹកដីខេត្តបាត់ដំបង សៀមរាប និងសិរីសោភ័ណ។ បន្ទាប់មក ខេត្តបាត់ដំបង សៀមរាប និងសិរីសោភ័ណ នេះ ត្រូវអគ្គទេសាភិបាលបារាំងប្រចាំឥណ្ឌូចិន ចេញអនុក្រឹត្យចុះថ្ងៃទី២៣ ធ្នូ ១៩០៧ ថ្វាយព្រះមហាក្សត្រស៊ីសុវត្ថិ ជាផ្លូវការ។

តាមពិត សៀមបានដកខ្លួនចេញពីទឹកដីខ្មែរ នៅភាគខាងជើង និងភាគពាយ័ព្យ ជា



**សម្តេចសីហនុ យាងទៅប្រាសាទព្រះវិហារ ចុងឆ្នាំ១៩៦២**

៤ ដំណាក់កាលគឺ ៖

-នៅឆ្នាំ១៨៩០ : ដកពីធ្លូងលើ

-នៅឆ្នាំ១៨៩៣ : ដកពីខេត្តស្ទឹងត្រែង

-នៅឆ្នាំ១៩០៤ : ដកពីខេត្តម្លូព្រៃ និងទន្លេរពៅ

របត់នយោបាយ

-នៅឆ្នាំ១៩០៧ : ដកពីខេត្តបាត់ដំបង សៀមរាប និងសិរីសោភ័ណ។

ក្នុងសង្គ្រាមលោកលើកទី២ (១៩៣៩-១៩៤៥) ឆ្លៀតឱកាសដែលប្រទេសបារាំងចុះខ្សោយ ប្រទេសថៃបានទាមទារទឹកដីរបស់ខ្មែរជាថ្មីម្តងទៀត។

នៅក្នុងខែឧសភា ១៩៤១ ដោយមានអន្តរាគមន៍ពីជប៉ុន បារាំងយល់ព្រមប្រគល់ទឹកដីខេត្តបាត់ដំបង ខេត្តកំពង់ធំ មួយភាគ ខេត្តសៀមរាប និងខេត្តស្ទឹងត្រែង ទៅឱ្យថៃវិញ។

រហូតទាល់តែជប៉ុន ចាញ់សង្គ្រាមលោកលើកទីពីរ ទើបមានកិច្ចព្រមព្រៀងបារាំង-សៀម ថ្ងៃទី១៧ វិច្ឆិកា ១៩៤៦ នៅទីក្រុងវ៉ាស៊ីនតោន ដោយចាត់ទុកអនុសញ្ញាបារាំង-ថៃ ឆ្នាំ១៩៤១ ជាមោឃៈ និងតម្រូវឱ្យរក្សាស្ថានភាពព្រំដែនដូចមុនឆ្នាំ១៩៤១។ ដូច្នេះថៃត្រូវប្រគល់ទឹកដីខ្មែរ ដែលបានកាន់កាប់ចាប់ពីឆ្នាំ១៩៤១ ដល់ឆ្នាំ១៩៤៦ នោះ មកឱ្យខ្មែរវិញ។

ប៉ុន្តែប្រទេសថៃ មិនអនុវត្តតាមកិច្ចព្រមព្រៀងក្រុងវ៉ាស៊ីនតោន នៅឆ្នាំ១៩៤៦ នោះទេ គឺបានឱ្យកងទ័ពខ្លួនចូលមកកាន់កាប់ប្រាសាទព្រះវិហារ ចាប់ពីឆ្នាំ១៩៥៨ មក រហូតដល់មានការប្ដឹងផ្ដល់គ្នានៅតុលាការយុត្តិធម៌អន្តរជាតិ នៅក្រុងឡាអេ នោះ។

ចាប់ពីថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៦៣ ប្រទេសកម្ពុជា បានចូលទៅកាន់កាប់ប្រាសាទព្រះវិហារ វិញជាផ្លូវការ។

ក្រោយពេលតុលាការក្រុងឡាអេ សម្រេចប្រគល់ប្រាសាទព្រះវិហារ និងតំបន់ជុំវិញនោះ មកឱ្យប្រទេសខ្មែរវិញ ពួកថៃនាំគ្នាធ្វើបាតុកម្ម នៅទីក្រុងបាងកក ប្រឆាំងនឹងសាលក្រមរបស់តុលាការនោះ។ មិនតែប៉ុណ្ណោះ នៅថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៦២ តំណាងប្រទេសថៃប្រចាំនៅអង្គការសហប្រជាជាតិ បានទាមទារទាំងងងឹតងងល់យកខេត្តបាត់ដំបង កំពង់ធំ និងសៀមរាប ដែលផ្ទុយទាំងស្រុងពីកិច្ចព្រមព្រៀងបារាំង-សៀម ឆ្នាំ១៩០៤ និង១៩០៧។

ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៨ អង្គការយូនីស្កូ បានសម្រេចដាក់ប្រាសាទព្រះវិហាររបស់កម្ពុជា ចូលទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ក្នុងសម័យប្រជុំលើកទី៣២ នៅទីក្រុងកេប៊ិច ប្រទេសកាណាដា។

# ១៣៩
# ឡឹក សំអឿន លែងហ៊ានបង្រៀនសិស្សថៃ



**ប្រាសាទព្រះវិហារ**

បន្ទាប់ពីផ្តាច់ចំណងការទូតរវាងប្រទេសថៃ និងកម្ពុជា ដោយសារបញ្ហាជម្លោះប្រាសាទព្រះវិហារមក ថ្ងៃមួយពួកសិស្សថៃ នៅក្នុងថ្នាក់ដែលឡឹក សំអឿន បង្រៀននោះបានចោទសួរគាត់ថា តើប្រាសាទព្រះវិហារជាសម្បត្តិរបស់ថៃ ឬរបស់ខ្មែរ? ដោយសារដឹងថាពួកសិស្សថៃនោះចង់បង្ករឿង គាត់ក៏ឆ្លើយតបទៅសិស្សថៃទាំងនោះវិញថា តាមសន្ធិសញ្ញាបារាំង-សៀម ការចែកខ្សែបន្ទាត់ព្រំដែនខ្មែរ-ថៃ បានបញ្ជាក់ថា នៅលើភ្នំដងរែកទីដីដែលមានទឹកហូរធ្លាក់ទៅខាងត្បូង ជាដែនដីរបស់ខ្មែរ ឯទីដីដែលមានទឹកហូរធ្លាក់ទៅខាងជើង ជាទឹកដីរបស់ថៃ ហើយព្រំប្រទល់នៃប្រទេសទាំងពីរនេះ មានដាក់បង្គោលសីមានៅលើជួរភ្នំដងរែកទៀតផង ដូច្នេះប្រសាទព្រះវិហារស្ថិតនៅត្រង់កន្លែងដែលទឹកហូរធ្លាក់ទៅទិសខាងត្បូង។ តែគាត់មិនហ៊ានបញ្ជាក់ឱ្យច្បាស់ថា ប្រាសាទព្រះវិហារជារបស់ប្រទេសខ្មែរទេ។ តាំងពីនោះមក សិស្សថៃទាំងអស់នោះក៏ចេះតែសម្តែងអាកប្បកិរិយាជាមួយគាត់ជាបន្តបន្ទាប់។

## របត់នយោបាយ

ឃើញស្ថានភាពមិនគួរគប្បីដូច្នេះ ឡឹក សំអឿន ក៏បានទៅជួបមេតម្រួតថៃ ធណៈ សមុទ្ទផាណិជ ដែលពេលនោះបានឡើងឋានន្តរស័ក្តិជាឧត្តមសេនីយ៍ត្រី មានមុខដំណែងជានាយការិយាល័យព័ត៌មាននៅទីស្តីការនាយករដ្ឋមន្ត្រី ដើម្បីសុំឲ្យជួយឲ្យគាត់បានលាឈប់ពីមុខការជាគ្រូបង្រៀនសិស្សថៃនោះផង និងសុំឲ្យគាត់ជួយសម្រួលការធ្វើដំណើរគាត់ទៅក្រុងវៀងចន្ទ ប្រទេសឡាវ ផង។ មួយសប្តាហ៍ក្រោយមកឧត្តមសេនីយ៍ធណៈ សមុទ្ទផាណិជ ក៏បានជួយជូនដំណើរគាត់រហូតទៅដល់ក្រុងណងខាយ នៅក្បែរព្រំដែនឡាវ។

នៅក្រុងណងខាយ ឧត្តមសេនីយ៍ធណៈ បានណែនាំគាត់ឱ្យស្គាល់អភិបាលក្រុង ដែលជាមិត្តភក្តិរបស់លោក និងប្រធានអន្តោប្រវេសន៍នៅទីក្រុងនោះ ផងដែរ។ ឧត្តមសេនីយ៍ធណៈ បានស្នាក់នៅជាមួយឡឹក សំអឿន នៅក្រុងណងខាយ អស់រយៈពេល២ថ្ងៃ ទើបគាត់លាវិលត្រលប់ទៅក្រុងបាងកកវិញ ហើយឡឹក សំអឿន ក៏បន្តដំណើរទៅទីក្រុងវៀងចន្ទបន្តទៀត។ តែមុនពេលបែកគ្នាឧត្តមសេនីយ៍ធណៈ បានប្រគល់លិខិតមួយច្បាប់ឲ្យឡឹក សំអឿន យកទៅជូនឯកអគ្គរដ្ឋទូតថៃ ប្រចាំប្រទេសឡាវ ផងដែរ។

ជាមួយគ្នានោះ គាត់ក៏បានសរសេរលិខិតមួយបញ្ជាក់ថាឡឹក សំអឿន ជាភ្នាក់ងារយកការសម្ងាត់នៅទីស្តីការនាយករដ្ឋមន្ត្រីថៃ ដើម្បីឱ្យឡឹក សំអឿន ជិះរថភ្លើងដោយមិនបាច់បង់ថ្លៃមួយច្បាប់ទៀតផង។ ពេលទៅដល់ទីក្រុងវៀងចន្ទ ក្រោយពីប្រគល់លិខិតរបស់ឧត្តម-សេនីយ៍ធណៈមក ឯកអគ្គរាជរាជទូតថៃបានទៅរកជួលផ្ទះមួយល្វែងនៅជិតស្ថានទូតរបស់ខ្លួន និងនៅជិតស្ថានទូតខ្មែរផងដែរ ឱ្យឡឹក សំអឿន ស្នាក់នៅ។ ពេលនោះឯកអគ្គរាជទូតខ្មែរនៅប្រទេសឡាវ ឈ្មោះកែវ គឹមសាន។ តែ ឡឹក សំអឿន បានជម្រាបលោកឯកអគ្គរាជរាជទូតថៃថា គាត់មានកន្លែងស្នាក់អាស្រ័យហើយ គឺគាត់ទៅស្នាក់នៅផ្ទះមិត្តភក្តិ ឈ្មោះ អ៊ុក ម៉ិល នោះឯង។

ពីរបីថ្ងៃក្រោយមក អ៊ុក ម៉ិល ក៏បាននាំគាត់ឱ្យទៅធ្វើការនៅក្រុមហ៊ុនមួយឈ្មោះក្រុមហ៊ុនដឹកជញ្ជូនអាមេរិកាំងត្រង់ស្ពាក (American Transpack )និងបានទទួលតួនាទីជានាយកដឹកនាំទំនិញចេញចូលប្រទេសថៃ ហើយបានប្រាក់បៀវត្សប្រចាំខែ ចំនួន១៥០០០

គីប មានទាំងរថយន្តតូចមួយគ្រឿងសម្រាប់ជិះបម្រើការងារ ព្រមទាំងមានសិទ្ធិចាយវាយក្នុងកិច្ចការផ្សេងៗទៀត ដោយគ្រាន់តែមានវិក្កយបត្រទុកជាឯកសារឱ្យក្រុមហ៊ុនតែប៉ុណ្ណោះ។ ភារកិច្ចរបស់ឡឹក សំអឿន គឺទាក់ទងជារៀងរាល់ថ្ងៃជាមួយអាជ្ញាធរគយឡាវ និងថៃ ដើម្បីដឹកទំនិញចេញចូលប្រទេសទាំងពីរនេះ។ ពេលខ្លះ គាត់ត្រូវធ្វើដំណើរទៅក្រុងបាងកក ដើម្បីទាក់ទងផ្ទាល់ជាមួយអាជ្ញាធរកំពង់ផែក្រុងបាងកក។

បន្ទាប់មក គាត់ក៏បានចាប់ផ្តើមទាក់ទងទៅសឺង ង៉ុកថាញ់ នៅរណសិរ្សវាលភក់នៅវៀតណាមខាងត្បូង ហើយដឹងថា ខាងរណសិរ្សវាលភក់នោះ បានបញ្ជាប់ឱ្យធ្វើសកម្មភាពហើយដែរ។ តែបន្ទាប់ពីបានរំសាយកម្លាំងរួច សឺង ង៉ុកថាញ់ បានងាកទៅដោះស្រាយបញ្ហាបងប្អូនខ្មែរកម្ពុជាក្រោមវិញ ដោយបានបង្កើតជាសហជីពកម្មករកសិករខ្មែរ នៅក្នុងសម្ព័ន្ធសហជីពកសិករកម្មករវៀតណាម និងបានចងស្ពានមេត្រីជាមួយនិកាយពុទ្ធសាសនាផ្សេងៗ ព្រមទាំងបានចូលជាសមាជិកនៃគណកម្មការនិកាយពុទ្ធសាសនាចម្រុះផងដែរ ដើម្បីជាវិធានការប្រុងប្រៀបជើងព្រួលទុកជាមុន សម្រាប់ការពារខ្លួនទៅអនាគត។

# ១៤០
# ជីវិតប្រពន្ធ និងកូនៗ
# ក្រោយពេលសម សារី រត់គេចខ្លួនទៅក្រៅប្រទេស




**សម សារី ជាមួយប្រពន្ធ និងកូនៗទាំង៥នាក់ កាលដើមទសវត្សរ៍ឆ្នាំ១៩៥០** (រូបថត សម រង្ស៊ី)

ក្រោយពេលសម សារី បាត់ខ្លួនពីទីក្រុងភ្នំពេញទៅ ក្រុមគ្រួសាររបស់គាត់គ្មានដំណឹងទាល់តែសោះ។ ពេលខ្លះ ប្រពន្ធកូនថា ប្ដី និងឪពុកពួកគាត់ពិតជាស្លាប់ហើយ។ ប៉ុន្តែ នៅពេលឮថា កម្លាំងសមត្ថកិច្ចនៅតែតាមរកចាប់ ធ្វើឲ្យពួកគាត់គិតថា ប្ដី និងឪពុកពួកគាត់ប្រហែលជានៅរស់នៅឡើយ។

សម រង្ស៊ី ជាកូនពៅរបស់សម សារី បានរម្លឹកថា តាមរលកអាកាសវិទ្យុជាតិនៅភ្នំពេញ បានយកព្រះរាជសង្កថាយ៉ាងវែងមួយ របស់សម្ដេចសីហនុ មកចាក់ផ្សាយជាច្រើនលើកច្រើនសាក្នុងមួយថ្ងៃៗ។ ព្រះអង្គចោទប្រកាន់ឪពុកគាត់ថា ជាជនក្បត់ជាតិ ថាជាសត្វឆ្កែជាដើម។ ជាមួយគ្នានេះដែរ មានរថយន្តបំពាក់គ្រឿងបំពងសំឡេងជាច្រើនគ្រឿងបើកខ្វាត់ខ្វែងក្នុងទីក្រុងភ្នំពេញ ស្រែកប្រកាសតែពាក្យដដែលៗថា សម សារី ជាជនក្បត់ជាតិ ៗៗៗ។

មិនតែប៉ុណ្ណោះគេបានបិទផ្ទាំងក្រដាសគំនូរធំៗ ដែលមានក្បាលឪពុកគាត់ (សម សារី) ត្រឹម.ក ប៉ុន្តែដងខ្លួនជារូបសត្វឆ្កែ នៅពាសពេញក្នុងទីក្រុងភ្នំពេញ។ សិស្សមួយចំនួនដែលរៀនថ្នាក់ជាមួយគាត់បានស្រែកតិះដៀលគាត់ថា៖ ឪពុកឯង គឺជាសត្វឆ្កែ។

រៀងរាល់ថ្ងៃ ពួកគាត់តែងតែព្រួយបារម្ភខ្លាចកម្លាំងសមត្ថកិច្ចមកចាប់ចងពួកគេ ពិសេសម្តាយគាត់ចេះតែភ័យខ្លាចគេមកចាប់គាត់យកទៅបាញ់ចោលដោយត្រង់តែម្តង។ សម រង្ស៊ី បានរម្លឹកបន្តថា ក្រោយពេលសមត្ថកិច្ចដោះលែងពីពន្ធនាគារ ម្តាយគាត់បានសុំរាជានុញ្ញាតចូលគាល់ព្រះមហាក្សត្រិយានីកុសមៈ នៅក្នុងព្រះបរមរាជវាំង ។ ពេលនោះ ម្តាយបានយករូបគាត់ម្នាក់ទៅជាមួយដែរ ដោយរៀបចំស្លៀកពាក់ឱ្យគាត់យ៉ាងសមរម្យបំផុត។ ពេលពួកគាត់ពីនាក់ម្តាយកូនចូលថ្វាយបង្គំ ព្រះមហាក្សត្រិយានីកំពុងគង់សោយព្រះក្រយាតែអង្គឯង នៅតុមូលមួយ ដោយមានពួកស្នំបម្រើជាច្រើននាក់ និងអង្គរក្សនៅការពារជុំវិញព្រះអង្គ។

នៅក្បែរព្រះបាទាព្រះអង្គ ម្តាយគាត់បានទូលរៀបរាប់អំពីស្ថានភាពជីវភាពរស់នៅលំបាកវេទនារបស់គ្រួសារពួកគាត់។ តែព្រះអង្គមិនមានបន្ទូលអ្វីតបវិញនោះទេ។ រហូតដល់ពេលព្រះអង្គកាន់ផ្លែក្រូចមួយផ្លែបម្រុងយកមកសោយ ទើបព្រះអង្គមានបន្ទូលថា ៖ អ្នកឯងមើលផ្លែក្រូចនេះ មើលទៅវាដូចជាផ្អែមគួរឱ្យចង់សោយណាស់។ ប៉ុន្តែយើងមិនអាចសោយវាភ្លាមៗបានទេ។

តើអ្នកឯងដឹងទេ ព្រោះហេតុអ្វី? ពីព្រោះវាអាចមានគ្រឿងពុលនៅខាងក្នុង ដូច្នេះមុននឹងសោយវា យើងត្រូវយកជីវិតអ្នកភ្លក់ម្នាក់មកប្តូរជាមុនសិន។ តែគាត់ និងម្តាយមិនដឹងថា ព្រះសុវណ្ណីរបស់ព្រះមហាក្សត្រិយានីកុសមៈ នេះ មានបង្កប់អត្ថន័យអ្វីទៅ?

សម រង្ស៊ី បានរម្លឹកបន្តថា ថ្ងៃមួយ ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសន្តិសុខជាតិ និងការពារលើផ្ទៃប្រទេស បានកោះហៅម្តាយគាត់ទៅព្រមានថា បើពួកខ្មែរសេរីចូលមកប្រឆាំងក្នុងដែនដីខ្មែរ គាត់នឹងបញ្ជាឲ្យគេបាញ់សម្លាប់ម្តាយគាត់ភ្លាមៗ សូម្បីតែកូនៗ ក៏មិនទុកឲ្យមានជីវិតដែរ។ នៅចំពោះមុខស្ថានភាពដ៏ខ្មៅងងឹតបែបនេះ ដើម្បីជួយស្រោចស្រង់អាយុជីវិតកូនៗ ម្តាយគាត់បានសម្រេចចិត្តធ្វើតាមការណែនាំពីអ្នកធំៗ ដែលនៅរាប់អាន

ម្តាយគាត់ ឱ្យម្តាយគាត់ធ្វើដំណើរទៅក្រសួងសមត្ថកិច្ចសុំលែងលះជាមួយនឹងសម សារី ជាប្តី ហើយឈ្មោះអ្នកស្រីសម សារី ជាឈ្មោះដែលម្តាយគាត់ប្រើក្រោយពេលរៀបការជាមួយឪពុកគាត់នោះ ម្តាយគាត់ក៏បានសុំដូរយកឈ្មោះកាលពីនៅក្រមុំ គឺឈ្មោះអ៊ិន អេម មកប្រើវិញដែរ។ មិនតែប៉ុណ្ណោះ គេឲ្យម្តាយគាត់បានប្រកាសជាសាធារណៈថា គាត់លែងមានការទាក់ទងជាមួយសម សារី ទៀតហើយ។ ម្តាយគាត់ក៏សុខចិត្តធ្វើតាមគេគ្រប់បែបយ៉ាង ទោះបីជាដឹងថា ការធ្វើបែបនេះប្រហែលជាគ្មានប្រសិទ្ធភាពក៏ដោយ។ ក្រោយមក ម្តាយគាត់ត្រូវគេឱ្យចូលទៅស្ថានីយវិទ្យុជាតិ ដើម្បីអានលិខិតមួយដែលគេសរសេរទុកឱ្យជាមុន ដើម្បីថតសំឡេងយកទៅចាក់ផ្សាយតាមវិទ្យុជាតិ ដោយក្នុងលិខិតនោះ គេបានសរសេរប្រមាថតិះដៀលថា សម សារី គឺជាជនក្បត់ជាតិ។

ពេលអានលិខិតនោះ ម្តាយគាត់ភ័យញ័រដៃញ័រជើង ភ្នែកស្រវាំងមើលអក្សរច្រឡំបន្ទាត់ជាច្រើនដង។ ប៉ុន្តែម្តាយគាត់ចាំបាច់ត្រូវតែធ្វើអំពើដ៏ថោកទាបនេះ ដោយតាំងចិត្តអានលិខិតនោះរហូតចប់។ ចំណែកបងប្រុសគាត់ ឈ្មោះអេម៉្មារ៉ា ដែលបានស្រលាញ់គ្នាជាមួយនារីម្នាក់ជាប់ជាបងប្អូនសាច់ឆ្ងាយ កាលគ្រួសារគាត់មានឋានៈខ្ពង់ខ្ពស់មានមុខមាត់ក្នុងសង្គម ក្រុមគ្រួសារខាងស្រីជាគ្រួសារមានទ្រព្យសម្បត្តិគួរសមនឹងគេដែរ មានការពេញចិត្តបងប្រុសគាត់ខ្លាំងណាស់ និងចង់ឱ្យកូនក្រមុំគេក្លាយជាគូស្វាមីភរិយានឹងគ្នាទៀតផង។ ប៉ុន្តែ នៅពេលឪពុកគាត់ត្រូវគេចោទថា ជាជនក្បត់ជាតិ ហើយរត់គេចខ្លួនចេញពីប្រទេសបាត់ទៅ ឪពុកម្តាយខាងស្រី ក៏ឈប់លែងរវីរវល់ជាមួយនឹងគ្រួសារគាត់ដូចពេលមុនទៀត។ ចំណែកកូនស្រីនោះ ដែលបានរៀនសូត្រចេះដឹងជ្រៅជ្រះដែរនោះ នាងរកវិធីផ្តាច់ចំណងស្នេហា ពីបងប្រុសរបស់គាត់ដោយវិធីត្រជាក់បំផុត។

ក្នុងអំឡុងពេលនោះដែរ ទោះបីគាត់ ទើបមានអាយុជាង១០ឆ្នាំ ក៏ពិតមែន តែគាត់ក៏មានការភ័យខ្លាច និងមានការប្រុងប្រយ័ត្នជានិច្ច។ ពេលស្ងាត់នៅក្នុងផ្ទះម្នាក់ឯង ឮសំឡេងបិទបើកទ្វារ ឬឮសំឡេងឆ្កែព្រុសម្តងៗអារម្មណ៍របស់គាត់តែងតែភ្ញាក់ផ្អើល ហើយសម្លឹងរកច្រករត់គេចខ្លួន។ គាត់បានរៀបចំទុកជាស្រេចនូវកន្លែងឡើងលោតផ្លោះរបង ដើម្បីរត់



**វិទ្យាល័យបារាំងដេកាត** ( Français René Descartes ) **សម័យទសវត្សរ៍ឆ្នាំ១៩៥០**

សំដៅទៅរកស្ថានទូតបារាំង ភ្លាមៗតែម្តង។

គាត់នៅតែស្រមៃឃើញជានិច្ច ពេលកម្លាំងសមត្ថកិច្ចប្រដាប់អាវុធប្រងែងប្រងាង ចូលឆែកឆេរផ្ទះរបស់គាត់នៅផ្លូវត្រសក់ផ្អែម ដើម្បីចាប់ឪពុកគាត់ កាលពីមុននោះ។ គាត់ជឿជាក់ថា ថ្ងៃនោះ បើឪពុកគាត់នៅផ្ទះ ប្រហែលជាត្រូវគេបាញ់សម្លាប់ភ្លាមៗ នៅចំពោះមុខគាត់ជាមិនខាន។

សម រង្ស៊ី បានរម្លឹកពីការសិក្សារបស់គាត់ថា ទោះបីស្ថិតនៅក្នុងការគំរាមកំហែង និងភ័យខ្លាចយ៉ាងណាក៏ដោយ ពេលសិក្សាថ្នាក់ទី៤ នៅវិទ្យាល័យបារាំង ឈ្មោះដេកាដ ក៏គាត់នៅតែជាសិស្សពូកែម្នាក់ដដែល។ គាត់រៀនបានចំណាត់ថ្នាក់លេខ១ប្រចាំថ្នាក់ ហើយពិន្ទុរបស់គាត់ទទួលបានលើសគេក្នុងចំណោមសិស្សថ្នាក់ទី៤ទាំងអស់នៅវិទ្យាល័យនោះ។

ជាគោលការណ៍របស់វិទ្យាល័យ គាត់ត្រូវឡើងទទួលរង្វាន់លេខ១។ ប៉ុន្តែពិធីចែករង្វាន់ត្រូវធ្វើឡើងនៅក្រោមព្រះរាជាធិបតីភាពរបស់សម្តេចសីហនុ ពួកអ្នកការទូតបារាំង និង

## របត់នយោបាយ

អ្នកគ្រប់គ្រងវិទ្យាល័យ មិនចង់ឱ្យមានបញ្ហាដល់ពួកគេ ដូច្នេះពួកគេបានសម្រេចដកឈ្មោះគាត់ចេញ ហើយយកសិស្សជាប់ចំណាត់ថ្នាក់លេខ២ ឱ្យឡើងទទួលរង្វាន់ជំនួសគាត់វិញ។

គាត់មានការតូចចិត្តខ្លះៗដែរ គាត់មិនយល់ថា ហេតុអ្វី បានជាគេហ៊ានផ្លាស់ប្តូររូបគាត់ត្រូវឡើងទទួលរង្វាន់លេខ១ ទៅឱ្យសិស្សជាប់ចំណាត់ថ្នាក់លេខ២ យ៉ាងអយុត្តិធម៌យ៉ាងដូច្នេះ? ប៉ុន្តែគាត់គិតថា នេះវាជារឿងមួយតូចតាច មិនមានសារៈសំខាន់អ្វីទេ បើប្រៀបធៀបទៅនឹងទុក្ខលំបាកចំពោះការធ្វើទុក្ខបុកម្នេញទៅលើរូបឪពុកម្តាយ និងបងៗ របស់គាត់។ តែយ៉ាងណា ដោយសាររឿងរើសអើងនេះ គាត់បានសម្រេចចិត្តឈប់រៀននៅវិទ្យាល័យដេកាដ នោះ ទៅចូលរៀននៅវិទ្យាល័យឯកជនមួយ ឈ្មោះវិទ្យាល័យតារាវស្មី វិញ ម្យ៉ាងកម្មវិធីសិក្សានៅវិទ្យាល័យឯកជនមួយនេះ ក៏មិនសូវតឹងរ៉ឹងប៉ុន្មានដែរ។

ពេលចូលរៀនថ្នាក់ទី៤ មួយអាទិត្យដំបូង គាត់មានការលំបាកច្រើនក្នុងការសរសេរអក្សរខ្មែរ ព្រោះកាលរៀននៅវិទ្យាល័យដេកាដ គាត់មិនសូវបានរៀនមុខវិជ្ជាភាសាខ្មែរទេ ប៉ុន្តែក្រោយមកគាត់អាចសរសេរអក្សរខ្មែរ ទាន់ដូចគេដូចឯងដែរ។

សម រង្ស៊ី នៅចងចាំថា ពេលនោះមានសាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរម្នាក់ បានយកអត្ថបទមួយដែលជីតាគាត់ (សម ញាណ) សរសេរស្តីពីកម្លាំងខាងផ្លូវចិត្ត កាលពីប៉ុន្មានឆ្នាំមុនមកអាន និងពន្យល់បកស្រាយឱ្យសិស្សក្នុងថ្នាក់បានយល់ដឹងពីកម្លាំងខាងផ្លូវចិត្តរបស់មនុស្សម្នាក់ៗ ធ្វើឱ្យសិស្សក្នុងថ្នាក់របស់គាត់មានការភ្ញាក់ផ្អើលគ្រប់គ្នា។ ចាប់ពីពេលនោះមក សិស្សរួមថ្នាក់គាត់ភាគច្រើនលែងចាត់ទុករូបគាត់ជាកូនជនក្បត់ជាតិដូចមុនទៀត ហើយអ្នកខ្លះចាត់ទុកគាត់ជាចៅរបស់ព្រឹទ្ធាចារ្យម្នាក់ទៅវិញ។

ចំណែកគាត់វិញ ហាក់ដូចជារំភើបក្នុងចិត្តយ៉ាងខ្លាំង និងមានកម្លាំងចិត្តដ៏ចម្លែកអស្ចារ្យមួយ ដោយឃើញសាស្ត្រាចារ្យម្នាក់នោះមានចិត្តក្លាហាន ហ៊ានលើកយកអត្ថបទសរសេរដោយឪពុកអ្នកនយោបាយប្រឆាំងម្នាក់ត្រូវបានគេចោទថា ជនក្បត់ជាតិ មកអាន និងពន្យល់បកស្រាយឱ្យសិស្សក្នុងថ្នាក់របស់គាត់បានយល់បែបនេះ។

កម្លាំងចិត្តដ៏ចម្លែកអស្ចារ្យមួយនេះហើយ ធ្វើឱ្យគាត់ខិតខំរៀនយ៉ាងខ្លាំងពេញមួយ

រដូវប្រាំង រួចសុំអ្នកគ្រប់គ្រងវិទ្យាល័យតាពរស្មី ផ្លោះទៅរៀនថ្នាក់ទី៣ តែម្តង ដោយមិនចាំបាច់រៀនចប់ថ្នាក់ទី៤ នោះឡើយ។

រយៈពេល១ខែដំបូងគាត់មានការលំបាកខ្លះៗ ប៉ុន្តែគាត់ខំប្រឹងរហូត ប្រលងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ( ឌីប្លូម ) នៅចុងឆ្នាំសិក្សា។

ក្រោយពេលប្រលងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ( ឌីប្លូម )មក គាត់បានដាក់ពាក្យសុំចូលរៀនថ្នាក់ទី២ នៅវិទ្យាល័យព្រះស៊ីសុវត្ថិ វិញ ហើយពេលកំពុងរៀនថ្នាក់ទី២នោះ គាត់ក៏ឆ្លៀតពេលល្ងាចៗទៅរៀនបំប៉នបន្ថែម ថ្នាក់ទី១ នៅវិទ្យាល័យតាពរស្មី ថែមទៀត ដើម្បីត្រៀមប្រលងផ្លោះយកសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិភាគ១( បាក់អង )បន្តទៀត។ ក្រោយពីប្រលងផ្លោះសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិភាគ១ ( បាក់អង ) ជាប់ដូចបំណងមក គាត់បានដាក់ពាក្យសុំចូលរៀនថ្នាក់ទីបញ្ចប់នៅវិទ្យាល័យដេកាដ វិញ ដោយគាត់រៀនលើសមិត្តភក្តិចាស់ៗ ដែលរៀនជាមួយគ្នានៅវិទ្យាល័យនោះពីមុន ដល់ទៅពីរថ្នាក់។

សម រង្ស៊ី បានរម្លឹកបន្តថា គាត់ខិតខំរៀនសូត្រក្នុងជីវភាពលំបាកតោកយ៉ាកទាំងផ្លូវចិត្តទាំងផ្លូវសម្ភារៈ រស់នៅខាងក្រោមផ្ទះឪពុកមាម្តាយមីង ព្រមទាំងមានសិស្សមួយចំនួនក្នុងវិទ្យាល័យជាមួយគ្នាជេរប្រមាថឪពុកគាត់មិនឈប់ឈរ។ តែគាត់យល់ស្របតាមទស្សនៈរបស់ខុង ជឺ អ្នកប្រាជ្ញចិនដែលថា ៖ មានតែការរៀនសូត្រ និងការងារប៉ុណ្ណោះ ជាផ្លូវនាំយើងទៅរកភាពថ្កុំថ្កើងក្នុងជីវិតបាន ហើយធ្វើឱ្យគាត់កាន់តែចងចាំជឿជាក់លើការអប់រំដាស់តឿនរបស់ឪពុកម្តាយចំពោះរូបគាត់ និងបងៗថា ពួកឯងត្រូវរៀនសូត្រឲ្យបានចេះដឹងជ្រៅជ្រះទើបទទួលបានអត្ថប្រយោជន៍ទាំងខាងផ្លូវចិត្ត ទាំងខាងផ្លូវសម្ភារៈ...។

# ១៤១
# នរណាជាអ្នកសម្លាប់ទូ សាមុត ?



**ទូ សាមុត**

ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៦២ ទូ សាមុត លេខាបក្សពលករកម្ពុជា ត្រូវបាត់ខ្លួន។ ប្រភពព័ត៌មានមួយ បានអះអាងថា ទូ សាមុត ត្រូវប៉ូលិសរាជរដ្ឋាភិបាលចាប់ខ្លួនបាន ហើយយកទៅចងសណ្ដូនជាមួយដុំថ្មធំៗ យកទៅទម្លាក់ចោលនៅក្នុងទឹកទន្លេមេកុង។

តែពេលនោះ កម្លាំងសមត្ថកិច្ចប៉ូលិសរបស់សម្ដេចសីហនុ មិនបានធ្វើការស្រាវជ្រាវពីរឿងបាត់ខ្លួន ទូ សាមុត ទេ។ ប៉ុន្តែក្រោយថ្ងៃ៧ ខែមករា ឆ្នាំ១៩៧៩ មេដឹកនាំវៀតណាមកុម្មុយនិស្ត ដែលលើកទ័ពចូលមកផ្ដួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ បានអះអាងនៅក្នុងវគ្គរៀនសូត្រនយោបាយឱ្យដល់ពួកកម្មាភិបាលនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ថា សាឡុត ស ហៅប៉ុល ពត ជាអ្នកបញ្ជាឱ្យសម្លាប់ទូ សាមុត ដើម្បីខ្លួនគាត់មានឱកាសបានឡើងកាន់តំណែងជាលេខាបក្សពលករកម្ពុជា។

ជាង៥០ឆ្នាំក្រោយមក នួន ជា ជាអនុលេខាបក្សពលករកម្ពុជា តាំងពីឆ្នាំ១៩៦០ នោះ បានបញ្ជាក់នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពីបញ្ហានៃការបាត់ខ្លួនរបស់ទូ សាមុត ថា មុនពេលកើតហេតុ ទូ សាមុត រស់នៅជាមួយប្រពន្ធ និងកូនតូចម្នាក់នៅម្តុំក្បែរផ្សារទួលទំពូង ពេលនោះគាត់បានទៅសួរប្រពន្ធទូ សាមុត ដើម្បីសួររកទូ សាមុត។

ប្រពន្ធទូ សាមុត ប្រាប់គាត់ថា ប្តីគាត់ទៅផ្សារទួលទំពូងយូរហើយ តែមិនឃើញត្រលប់មកវិញសោះ។ មុនដំបូង នួន ជា នឹកថា ទូ សាមុត អាចមានគ្រោះថ្នាក់ចរាចរណ៍ក៏មិនដឹង ? តែដល់ពេលបាត់ទូ សាមុត យូរពេក គាត់សង្ស័យថាសមត្ថកិច្ចចាប់ខ្លួន។ ក្រោយទូ សាមុត បាត់ខ្លួនជាច្រើនថ្ងៃមក នួន ជា បានទទួលដំណឹងពីនាយទាហានជាន់ខ្ពស់ម្នាក់ដែលស្គាល់រាប់អានគ្នា បានលួចខ្សឹបប្រាប់គាត់ថា លន់ នល់ បានបញ្ជាឱ្យកូនទាហានគាត់ចាប់ទូ សាមុត យកទៅបាញ់សម្លាប់នៅក្បែរវត្តចង្ក្រានតាព្រហ្មមានជ័យ(វត្តស្ទឹងមានជ័យ) បាត់ទៅហើយ។

# ១៤២
# ចៅសែន កុសលឈុំ ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រី



**ចៅសែន កុសលឈុំ កាលនៅវ័យក្មេង**

ក្រោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៦២ សម្តេច សីហនុ បានចេញព្រះរាជក្រឹត្យមួយ ប្រកាសតែងតាំងសមាសភាពរាជរដ្ឋាភិបាលថ្មីមួយ នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៦២ ដោយបានតែងតាំងចៅសែន កុសលឈុំ ជានាយករដ្ឋមន្ត្រី, លន់ នល់ ជាទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងការពារជាតិ, យ៉ែម សំបូរ ជារដ្ឋលេខាធិការក្រសួងកសិកម្ម, ផ្លែក ភីន ជារដ្ឋលេខាធិការក្រសួងសាធារណការ និងទូរគមនាគមន៍, ហួត សម្បត្តិ ជារដ្ឋលេខាធិការក្រសួងការបរទេស និងទេសចរណ៍, អ៊ឹង ហុងសាធ ជារដ្ឋលេខាធិការក្រសួងសាធារណសុខាភិបាល,ទ្រិញ វ៉ាញ ជារដ្ឋលេខាធិការក្រសួងឃោសនាការ, សឹង គៀកថ ជារដ្ឋលេខាធិការក្រសួងផែនការ, ហ៊ូ យន់ ជារដ្ឋលេខាធិការក្រសួងហិរញ្ញវត្ថុ, ហ៊ូ នឹម ជារដ្ឋលេខាធិការក្រសួងយុត្តិធម៌, ឧប គីមអាង ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ, ម៉ែន ឈុំ ជារដ្ឋលេខាធិការក្រសួងអប់រំជាតិ-យុវជន និងវិចិត្រសិល្បៈ, យុង យុន ជារដ្ឋ

លេខាធិការក្រសួងឧស្សាហកម្ម, ហ៊ែល ស៊ុំផា ជារដ្ឋលេខាធិការក្រសួងសង្គមកិច្ច និងការងារ, គុយ ពៅ ជារដ្ឋលេខាធិការក្រសួងធម្មការ និងទំនាក់ទំនងសភា, សាក់ ស៊ុតសាខន ជាអនុរដ្ឋលេខាធិការអមទីស្ដីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកសន្តិសុខជាតិ និងការពារលើផ្ទៃប្រទេស។ នៅក្នុងការរៀបចំរាជរដ្ឋាភិបាលនេះ គេសង្កេតឃើញថា ក្រៅពីតំណែងនាយករដ្ឋមន្ត្រី គឺមានតែតំណែងទេសរដ្ឋមន្ត្រីមួយប៉ុណ្ណោះ ហើយគ្មានតំណែងថ្នាក់រដ្ឋមន្ត្រីទេ។ អ្នកដឹកនាំតាមក្រសួងនីមួយៗ មានឋានៈត្រឹមថ្នាក់រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការប៉ុណ្ណោះ។

ចៅសែន កុសលឈុំ កើតនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩០៥ នៅខេត្តមាត់ជ្រូក (ខេត្តចូវដុក) កម្ពុជាក្រោម។

ឪពុកឈ្មោះ យុន គីម ជាចៅហ្វាយខេត្តកណ្ដាល។ យុន គីម នេះ ត្រូវជាប្អូនប្រុសរបស់ ប៉ាន់ យ៉ុង (១៨៨០-១៩៥៤) ជាមន្ត្រីជាន់ខ្ពស់ក្នុងរដ្ឋបាលខ្មែរ និងជាសមាជិកគណៈកម្មាធិការសហភាពបារាំង ផងដែរ។

ចៅសែន កុសលឈុំ បានសិក្សានៅអនុវិទ្យាល័យព្រះស៊ីសុវត្ថិ និងបន្តទៅសិក្សានៅវិទ្យាល័យហ្សាសសឺលូ ឡូបា (Chasseloup Laubat) នៅទីក្រុងព្រៃនគរបន្តទៀត នៅក្នុងឆ្នាំ១៩២៦។ ពេលមានអាយុ២១ឆ្នាំ គាត់បានប្រលងសញ្ញាបត្របាក់ឌុប ផ្នែកទស្សនវិជ្ជា និងជាជនជាតិខ្មែរទី១ ដែលទទួលសញ្ញាបត្របាក់ឌុប នេះផងដែរ? ក្រោយពីទទួលសញ្ញាបត្របាក់ឌុបនេះមក គាត់បានចូលបម្រើការងារជាមន្ត្រីរដ្ឋាភិបាលនៅទីក្រុងភ្នំពេញ។

នៅឆ្នាំ១៩២៨ គាត់ត្រូវបានទទួលតំណែងជាអភិបាលរងខេត្តតាកែវ បានរយៈពេលតែមួយឆ្នាំ ក៏សម្រេចចិត្តបោះបង់តំណែងនេះចោល ហើយទៅបន្តការសិក្សានៅមហាវិទ្យាល័យវេជ្ជសាស្ត្រ នៅទីក្រុងហាណូយ។ ប៉ុន្តែ ក្រោយពីមានទំនាក់ទំនងជាមួយពួកអ្នកជាតិនិយមវៀតណាម នៅក្រុងហាណូយនោះមក នៅក្នុងឆ្នាំ១៩៣១ គាត់សម្រេចចិត្តបោះបង់ការសិក្សាផ្នែកវេជ្ជសាស្ត្រនោះ ហើយវិលត្រលប់មកមាតុប្រទេសវិញ ធ្វើជាអភិបាលស្រុកកំពង់ត្រាច ខេត្តកំពត។ នៅក្នុងឆ្នាំ១៩៣៥ គាត់ផ្លាស់ទៅបម្រើការងារជាអភិបាលស្រុក



ចៅសែន កុសលឈុំ ពេលវ័យចាស់ជរា

ត្បូងឃ្មុំ ខេត្តកំពង់ចាម។ បន្ទាប់មកទៀត គាត់ត្រូវបានតែងតាំងជាអភិបាលខេត្តពោធិ៍សាត់ និងនៅឆ្នាំ១៩៣៨ ជាអភិ-បាលខេត្តស្វាយរៀង។

គាត់បានរៀបការជាមួយក្រមុំម្នាក់ ឈ្មោះ វ៉ាន់ ធីហាយ (ខ្មែរកម្ពុជាក្រោម) នៅថ្ងៃទី ០២ ខែមេសា ឆ្នាំ១៩៤០ និងមានកូន៧នាក់ ឈ្មោះ គីម ធូ, គីម វ៉ាន់, គីម សេដ្ឋា, គីម ដារី, គីម តន្ត្រី, គីម កុសលសង្ហារ និងគីម កុសលព្រីដា។

នៅក្នុងឆ្នាំ១៩៤០ ដល់១៩៤៥ ចៅសែន កុសលឈុំ បានទទួលតំណែងជាអភិបាលខេត្តកំពង់ចាម។ ក្រោយ ពេលសឺង ង៉ុកថាញ់ ត្រូវបានជប៉ុន នាំពីទីក្រុងតូក្យូ មកឱ្យកាន់តំណែងជានាយករដ្ឋមន្ត្រី ពីខែសីហា ដល់ខែតុលា ឆ្នាំ១៩៤៥ មក គាត់មានជំនឿលើមេដឹកនាំប្រឆាំងនឹងបារាំងរូបនេះកាន់តែខ្លាំងឡើងៗ។ ប៉ុន្តែក្រោយបារាំង ត្រលប់មកត្រួតត្រា ប្រទេសកម្ពុជា ដូចមុនវិញ ហើយចាប់សឺង ង៉ុកថាញ់ ថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៤៥ យកទៅដាក់ពន្ធធានាគារមក គាត់ និងចៅហ្វាយស្រុក៧នាក់ទៀត ក្នុងខេត្តកំពង់ចាម ក៏បាននាំគ្នារត់ភៀសខ្លួនទៅចូលរួមជាមួយពួកខ្មែរឥស្សរៈ ដែលគាំទ្រដោយពួកវៀតមិញ។ ប៉ុន្តែនៅក្នុងខែកុម្ភៈ ឆ្នាំ១៩៤៦ គាត់បានសម្រេចចិត្តមកសុំចូលជាមួយព្រះមហាក្សត្រសីហនុ និងពួកបារាំងវិញ ដោយបានទទួលតំណែងជាអភិបាល ខេត្តកំពត។

នៅក្នុងឆ្នាំ១៩៤៨ គាត់ទទួលតំណែងជា អភិបាលខេត្តកណ្តាល រហូតដល់ឆ្នាំ១៩៥១ គាត់ក៏ត្រូវបានតែងតាំងជាឯកអគ្គរាជទូតកម្ពុជា ប្រចាំនៅប្រទេសថៃ។

នៅក្នុងឆ្នាំ១៩៥២ ដោយមានការសង្ស័យថា គាត់បានទាក់ទងជាមួយចលនាតស៊ូសឺង ង៉ុកថាញ់ នៅភាគខាងលិចប្រទេស គាត់ត្រូវបានសម្តេចសីហនុ ដកតំណែងឯកអគ្គរាជទូត និងបញ្ជាឱ្យវិលត្រលប់មកមាតុប្រទេសវិញ។

នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៥៥ គាត់បានសម្រេចចិត្តចូលរួមក្នុងចលនាសង្គមរាស្ត្រនិយម ដែលបង្កើតឡើងដោយ សម្តេចសីហនុ។

នៅក្នុងឆ្នាំ១៩៥៦ គាត់បានក្លាយទៅជាអគ្គនាយកធនាគារខ្មែរ។ នៅឆ្នាំ១៩៥៨ គាត់បានជាប់ឆ្នោតជាតំណាងរាស្ត្ររបស់ចលនាសង្គមរាស្ត្រនិយម នៅមណ្ឌលខេត្តកំពង់ចាម និងបានក្លាយជាប្រធានរដ្ឋសភា។ ឆ្នាំ១៩៦២ ពីខែសីហា ដល់ខែតុលា ជានាយករដ្ឋមន្ត្រី។ ពីចុងឆ្នាំ១៩៦២ ដល់ឆ្នាំ១៩៦៨ ជាប្រធានរដ្ឋសភា។ ឆ្នាំ១៩៦៩ គាត់បានចូលនិវត្តន៍ពីជីវភាពមន្ត្រីរាជការ។ មុនទីក្រុងភ្នំពេញ ធ្លាក់ទៅក្នុងកណ្តាប់ដៃមេដឹកនាំខ្មែរក្រហម ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គាត់ និងក្រុមគ្រួសារបានទៅទស្សនកិច្ចនៅក្រុងព្រៃនគរ (សៃហ្គន) ប្រទេសវៀតណាមខាងត្បូង។ ក្រោយពេលកងទ័ពវៀតកុង-វៀតណាមខាងជើងវាយដណ្តើមបានទីក្រុងព្រៃនគរ ថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៥ គាត់ត្រូវពួកកុម្មុយនិស្តវៀតណាម ចាប់យកទៅដាក់គុករយៈពេល១៧ខែ ដោយចោទប្រកាន់ពីបទមានជាប់ពាក់ព័ន្ធជាមួយពួកសេ.អ៊ី.អា របស់អាមេរិក។

ក្រោយចេញពីពន្ធនាគារវិញ ចៅសែន កុសលឈុំ ត្រូវគេឃុំឱ្យនៅតែក្នុងផ្ទះអស់រយៈពេល២ឆ្នាំទៀត ទើបអាចទាក់ទងមន្ត្រីការទូតបារាំង នាំក្រុមគ្រួសារចេញពីទីក្រុងព្រៃនគរទៅរស់នៅទីក្រុងប៉ារីស។

នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៣ សម្តេចសីហនុ ដែលបានឡើងសោយរាជសម្បត្តិជាថ្មីម្តងទៀត នៅថ្ងៃទី២៤ ខែតុលា នោះ បានតែងតាំង ចៅសែន កុសលឈុំ ជាឧត្តមទីប្រឹក្សាព្រះមហាក្សត្រ។ បន្ទាប់មក នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៣ គាត់ត្រូវបានតែងតាំងជាប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ដែលទើបបង្កើតថ្មី។

នៅក្នុងឆ្នាំ២០០៧ គាត់បានបញ្ចប់ពីអាជីពជាជាអ្នកនយោបាយ។

លោកចៅសែន កុសលឈុំ បានទទួលមរណភាពនៅក្នុងទីក្រុងភ្នំពេញ នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០៩ ក្នុងជន្មាយុ១០៣ឆ្នាំ ដោយជរាពាធ។

# ១៤៣
# ខៀវ សំផន ត្រូវបានតែងតាំងរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម



ខៀវ សំផន

នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៦២ កងទ័ពជើងទឹកវៀតណាមខាងត្បូង បានចូលឈ្លានពានលើកោះសេះ និងកោះអង្រ្គង ដែលស្ថិតនៅខាងមុខទីក្រុងកែប។

នៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៦២ សម្តេចសីហនុ បានផ្ញើសារលិខិតទៅជូនមេដឹកនាំនៅលើពិភពលោកចំនួន១២ប្រទេស ដើម្បីសុំឱ្យជួយធានាការពារគោលនយោបាយអព្យាក្រឹត និងបូរណភាពទឹកដីកម្ពុជា។ ភ្លាមៗនោះ មេដឹកនាំប្រទេសចិន សហភាពសូវៀត និង

វៀតណាមខាងជើង ដែលជាពួកកុម្មុយនិស្ត ព្រមទាំងប្រទេសបារាំងផងដែរ បានឆ្លើយតបជាវិជ្ជមាន។

នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៦២ យន្តហោះរបស់កងទ័ពជើងអាកាសវៀតណាមខាងត្បូង បានហោះមកទម្លាក់គ្រាប់បែកមកលើ ភូមិខ្មែរជាច្រើន ដែលនៅក្បែរព្រំដែន។

នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៦២ សម្តេចសីហនុ សម្រេចរំលាយរាជរដ្ឋាភិបាលដែលមាន ចៅសែន កុសលឈុំ ចោល ហើយរៀបចំសមាសភាពរាជរដ្ឋាភិបាលមួយទៀតដែលមានព្រះអង្គម្ចាស់ នរោត្តម កន្តុល ជានាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ, លន់ នល់ ជាទេសរដ្ឋមន្ត្រីការពារប្រទេស និងកីឡា, ឡុង បូរ៉េត ជារដ្ឋលេខាធិការក្រសួងហិរញ្ញវត្ថុ, ចៅ សេង ជារដ្ឋលេខាធិការក្រសួងកសិកម្ម, សាក់ ស៊ុតសាខន ជារដ្ឋលេខាធិការអមទីស្តីការនាយករដ្ឋមន្ត្រី ទទួលបន្ទុកសន្តិសុខជាតិ និងការពារលើផ្ទៃប្រទេស, ហួត សម្បត្តិ ជារដ្ឋលេខាធិការក្រសួងការបរទេស, ហ៊ូ យន់ ជារដ្ឋលេខាធិការក្រសួងផែនការ, ទឹម ដុង ជារដ្ឋលេខាធិការក្រសួងឃោសនាការ និងទេសចរណ៍ ,ព្រះអង្គម្ចាស់នរោត្តម ភូរិស្សារ៉ា ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងធម្មការ, ភី ធៀនឡាយ ជារដ្ឋលេខាធិការក្រសួងយុត្តិធម៌, ថោ ប៉េងចុង ជារដ្ឋលេខាធិការសាធារណសុខាភិបាល ,វណ្ណ ម៉ូលីវណ្ណ ជារដ្ឋលេខាធិការក្រសួងសាធារណការ និងគមនាគមន៍, ខៀវ សំផន ជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម, ភូ ស៊ីអ៊ុយ ជារដ្ឋលេខាធិការក្រសួងអប់រំជាតិ និងវិចិត្រសិល្បៈ, អ៊ឹង គៀត ជារដ្ឋលេខាធិការក្រសួងសង្គមកិច្ច និងការងារ ,ឈុត ឈឿ ជារដ្ឋលេខាធិការក្រសួងឧស្សាហកម្ម, អ៊ឹង ក្រពុំផ្កា ជាអនុរដ្ឋលេខាធិការសាធារណការ និងទូរគមនាគមន៍ ទទួលបន្ទុកប្រៃសណីយ៍ និងដឹកជញ្ជូន, ម៉ែន ឈុំ ជាអនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកធម្មការ និងទំនាក់ទំនងសភា និងចៅ សៅ ជាអនុរដ្ឋលេខាធិការ ក្រសួងហិរញ្ញវត្ថុ ទទួលបន្ទុកថវិកា។

នៅក្នុងឱកាសប្រកាសតែងតាំងសមាសភាពគណៈរដ្ឋមន្ត្រីថ្មីនេះ សម្តេចសីហនុ បានលើកឡើងពីទិសដៅធំៗ ដែលជាយុទ្ធសាស្ត្រ ធ្វើការកែទម្រង់សេដ្ឋកិច្ចដូចគ្នា នឹងអ្វីៗដែល ខៀវ សំផន បានសរសេរនៅក្នុងនិក្ខេបបទថ្នាក់ បណ្ឌិតរបស់គាត់ដែរ ហើយព្រះអង្គបាន

សាកល្បងធ្វើតាមការស្នើសុំរបស់ពួកឆ្វេងនិយមផងដែរ តែព្រះអង្គបានព្រមានទុកជាមុនថា ព្រះអង្គនឹងមិនអត់ឱនចំពោះការប្រឆាំងណាមួយរបស់ពួកឆ្វេងនិយម ដែលធ្វើឱ្យប៉ះពាល់ដល់ឯករាជ្យរបស់ប្រទេសនោះឡើយ។

ព្រះអង្គម្ចាស់ នរោត្តម កន្តុល ជានាយករដ្ឋមន្ត្រី បានថ្លែងសុន្ទរកថានៅពេលចូលកាន់តំណែង ដោយលើកឡើងពីយុទ្ធសាស្ត្រនៃការកែទម្រង់សេដ្ឋកិច្ចរបស់ប្រទេសជាតិ តាមទស្សនៈរបស់ ខៀវ សំផន ដែលបានសរសេរនៅក្នុងនិក្ខេបបទថ្នាក់បណ្ឌិតសេដ្ឋកិច្ចរបស់គាត់ កាលនៅប្រទេសបារាំង ដែលមានចំណងជើងថា ការអភិវឌ្ឍសេដ្ឋកិច្ច និងឧស្សាហកម្មនៅកម្ពុជា។

នេះជាយុទ្ធសាស្ត្រងាកចេញពីបែបផែនសេដ្ឋកិច្ចទោល គួរឱ្យភ្ញាក់ផ្អើលរបស់រាជរដ្ឋាភិបាលព្រះអង្គម្ចាស់ នរោត្តម កន្តុល តម្រង់ទៅរកបែបផែនសេដ្ឋកិច្ចថ្មីមួយ។

ក្រោយពីទទួលបានការតែងតាំងជាលេខាធិការក្រសួងពាណិជ្ជកម្ម មក ខៀវ សំផន ក៏បានរៀបចំគម្រោងពិស្តារមួយ ដើម្បីដោះស្រាយវិបត្តិសេដ្ឋកិច្ចរបស់ប្រទេសជាតិ ហើយសម្តេច សីហនុ ក៏បានគាំទ្រគម្រោងនេះ ផងដែរ។

នៅដើមខែមករា ឆ្នាំ១៩៦៣ សម្តេចសីហនុ បានថ្លែងថា ព្រះអង្គបានប្រគល់សិទ្ធិឱ្យរាជរដ្ឋាភិបាលធ្វើអ្វីៗបានតាមបំណងប្រាថ្នា តែត្រូវធ្វើអ្វីៗត្រូវឱ្យមានទំនុកចិត្តពីប្រជារាស្ត្រផង។ តែព្រះអង្គបានរិះគន់ដែរថា គោលការណ៍របស់រាជរដ្ឋាភិបាលនេះ មានទ្រឹស្តីច្រើនពេក។

ក្នុងនាមជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ខៀវ សំផន បានរិះរកគ្រប់វិធី ដើម្បីធ្វើការឱ្យសេដ្ឋកិច្ចរបស់ប្រទេសជាតិ មានភាពល្អប្រសើរ។

គាត់បានចាប់ផ្តើមប្រឆាំងនឹងការផ្តល់សាច់ប្រាក់បន្ថែម ដើម្បីបំពេញការចំណាយទៅលើសេវាសាធារណៈផ្សេងៗរបស់រដ្ឋ។ ដោយសារថវិការដ្ឋមានការចំណាយច្រើនជាងចំណូលនោះ ខៀវ សំផន បានប្រកាសថា បញ្ហានេះនឹងនាំឱ្យមានអតិផរណាកាន់តែខ្លាំងឡើងៗ ជាមិនខាន តែគាត់ក៏បានអួតអាងពីការបង្កើតសហគ្រាសផលិតកម្មនានា របស់រាជរដ្ឋាភិបាលទៅវិញ។

ជាមួយគ្នានេះ គាត់បានស្នើសុំឱ្យមានការរឹតត្បិតក្នុងការចំណាយថវិការដ្ឋ គួបផ្សំ

នឹងការបង្កើនតម្លៃពន្ធទៅលើការនាំចូលផលិតផលប្រណីតៗ និងការធ្វើកំណែទម្រង់មួយចំនួនទៀត ដើម្បីកាត់បន្ថយផលប៉ះពាល់ផ្សេងៗមកលើប្រជារាស្ត្រដែលមានជីវភាពក្រីក្រ។ បញ្ហានេះក៏ធ្វើឱ្យមន្ត្រីធំៗ និងពួកពាណិជ្ជករមួយចំនួននាំគ្នាប្រឆាំងជំទាស់ចំពោះការបង្កើនតម្លៃពន្ធរបស់គាត់ដែរ។

ទោះបីយ៉ាងណាក៏ដោយ ក៏ខៀវ សំផន កាន់តែមានប្រជាប្រិយភាពខ្លាំងឡើងៗ ដោយសារតែពេលកាន់តំណែងជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មនោះ គាត់រក្សាបាននូវភាពស្អាតស្អំ មិនប្រព្រឹត្តអំពើពុករលួយ សូម្បីបន្តិចក៏គ្មានដែរ។

ពេលនោះ កាសែតអព្យាក្រឹត ក៏បានចេញផ្សាយជំនួសកាសែតដំណឹងថ្មី ហើយកាសែតយុវមិត្ត ត្រូវជំនួសដោយទិន្នានុប្បវត្តិ(ទស្សនាវដ្តី) សហមិត្ត ដែលមានអតីតនិស្សិតនៅប្រទេសបារាំងម្នាក់ឈ្មោះឱក សាគុណ ជានិពន្ធនាយក។

ចំណែកកាសែតមាតុភូមិរបស់សឺង គៀកថ ដែលធ្លាប់ធ្វើជារដ្ឋលេខាធិការជាច្រើនក្រសួង កាលពីមុនឆ្នាំ១៩៥៧នោះ ជាកាសែតចេញផ្សាយប្រចាំថ្ងៃ បោះពុម្ពមួយលេខៗមានចំនួន៣៦០០ច្បាប់។ ឯចៅ សេង ដែលពេលនោះ កំពុងកាន់តំណែងជារដ្ឋលេខាធិការក្រសួងកសិកម្ម ក៏មានកាសែតជាភាសាខ្មែរ និងបារាំង មួយឈ្មោះឡា ដេប៉េស្ហ (La Dépêche) ដែរ។

ក្នុងឆ្នាំ១៩៦៣ នោះដែរ សម្តេចសីហនុ ក៏បានសម្រេចបន្ធូរបន្ថយទោស នង សួន និងបក្ខពួកគាត់១៤នាក់ទៀត ពីការកាត់ទោសប្រហារជីវិត មកត្រឹមដាក់ពន្ធនាគារអស់មួយជីវិតវិញ ហើយជូ ជេត និពន្ធនាយកកាសែតប្រជាជន និងសហការី ក៏ត្រូវដោះលែងឱ្យមានសេរីភាពវិញដែរ។

ទាក់ទងដល់ករណី នង សួន និងបក្ខពួកគាត់១៤នាក់ទៀត ត្រូវបានសម្តេចសីហនុបន្ធូរបន្ថយទោស មកត្រឹមដាក់ពន្ធនាគារអស់មួយជីវិតនេះ ក្នុងចម្លើយសារភាពរបស់ឈ្មោះ ឈូ ប៊ុនលាត ជាអនុប្រធានកងវរសេនាធំលេខ ៣៣ នៃកងពលលេខ ៧០៣ ដែលត្រូវមេដឹកនាំខ្មែរក្រហមប៉ុល ពត ចាប់យកមកឃុំឃាំងនិងធ្វើទារុណកម្មនៅមន្ទីរសន្តិសុខ ស-២១

# របត់នយោបាយ

(គុកទួលស្លែង)បានឱ្យដឹងថា ក្រុមគ្រួសារគាត់មានទីលំនៅនៅភូមិព្រៃកតាវ៉ា ឃុំទឹកវិល ស្រុកស្អាង ខេត្តកណ្ដាល។ ក្រោយពីឪពុកឈ្មោះឈូ ហ៊ី ស្លាប់ទៅ គាត់និងបងប្អូន ៤នាក់ទៀត(ស្រី៣ ប្រុស១) ម្ដាយគាត់ជួបបញ្ហាជីវភាពលំបាកខ្លាំង។

ក្រោយមក គាត់ត្រូវបានព្រះសង្ឃមួយអង្គព្រះនាមម៉ាក (ជាបណ្ដាញមេខ្មែរក្រហម) បានជួយឧបត្ថម្ភឲ្យបានរៀនសូត្រអស់រយៈពេលជាច្រើនឆ្នាំ។ ក្នុងឆ្នាំ១៩៦២ នោះ គាត់មានអាយុ២៣ឆ្នាំ បានរៀបការជាមួយនារីម្នាក់ឈ្មោះស៊ូ កិ ស្រុកកំណើតនៅភូមិត្រពាំងស្គុក ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ។ បន្ទាប់មកលោកគ្រូម៉ាក បានទាក់ទងឱ្យគាត់ទៅធ្វើការនៅពន្ធនាគារព្រៃស មានតួនាទីជាអ្នកយាម និងជាអ្នកបណ្ដើរអ្នកទោសពីកន្លែងមួយទៅកន្លែងមួយទៀត ក្នុងបំណងដើម្បីធ្វើជាខ្សែរយៈរនុកក្នុង និងជាអ្នក នាំសំបុត្រពីលោកគ្រូម៉ាក ទៅឲ្យនង សួន និងពួកមេខ្មែរក្រហមផ្សេងៗទៀត ដែលជាប់ពន្ធនាគារព្រៃស នោះ។

ឈូ ប៊ុនលាត បានបន្តថា ក្រោយរដ្ឋប្រហារថ្ងៃ១៨ ខែមីនា ឆ្នាំ១៩៧០ នង សួន និងមេដឹកនាំខ្មែរក្រហមផ្សេងៗទៀត ត្រូវបានគេដោះលែងពីពន្ធនាគារព្រៃសវិញ។ ចំណែកគាត់ក៏បានបោះបង់ការងារនៅពន្ធនាគារព្រៃស ហើយរត់ទៅចូលបម្រើការងារជាយោធាខ្មែរក្រហមនៅ តំបន់២៥ ដឹកនាំដោយ នង សួន ហៅជ័យ សួន ឬតាជ័យ។

ក្នុងឆ្នាំ១៩៧២ គាត់ត្រូវបាន នង សួន គណៈតំបន់ ចាត់តាំងឱ្យឡើងតួនាទីជាអនុប្រធានកងវរសេនាធំលេខ ៣៣ នៃកងពលលេខ ៧០៣ ដែលមានឈ្មោះ ប៉ុល ខាត់ ជាប្រធានកងវរសេនាធំ។

ក្នុងឆ្នាំ១៩៧៦ ឈូ ប៊ុនលាត ត្រូវមេដឹកនាំខ្មែរក្រហមប៉ុល ពត ចាប់យកមកឃុំឃាំងធ្វើទារុណកម្មនៅមន្ទីរសន្តិសុខ ស-២១ (គុកទួលស្លែង) និងសម្លាប់ចោល។

# ១៤៤
# នរណាសម្លាប់សម សម សារី ?

នៅដើមឆ្នាំ១៩៦៣ នៅក្នុងប្រទេស មានលេចឮពាក្យចចាមអារ៉ាមថា សឺង ង៉ុកថាញ់ ជាអ្នកបាញ់សម្លាប់ សម សារី ព្រោះតែរឿងដណ្ដើមតួនាទីគ្នា។ មជ្ឈដ្ឋានខ្លះខ្សឹបខ្សៀវគ្នាថា សម សារី ត្រូវបានកម្លាំងប៉ូលិសសម្ងាត់របស់សម្ដេចសីហនុ ទៅតាមបាញ់សម្លាប់។

ចំណែក ប្រភពព័ត៌មានមួយបានផ្សព្វផ្សាយថា ពេលនោះ សម សារី បានលួចផ្ញើសំបុត្រថ្វាយដំណឹងមកសម្ដចសីហនុ ជាសម្ងាត់ ដើម្បីឱ្យក្រុមប៉ូលិសសម្ងាត់របស់ព្រះអង្គត្រៀមរៀបចំ ផែនការពួនស្ទាក់បាញ់សម្លាប់សឺង ង៉ុកថាញ់ ឱ្យបាន ពេលឆ្លងដែនពីប្រទេសថៃ ចូលដល់ក្នុងដីខ្មែរកណ្ដាល ដើម្បីទៅកម្ពុជាក្រោម ។ តែសំណាងល្អ សំបុត្រនោះបានធ្លាក់ចូលទៅក្នុងដៃរបស់ថាច់ ត្រឹង ជាអង្គរក្សផ្ទាល់របស់សឺង ង៉ុកថាញ់ គាត់ក៏បាញ់សម្លាប់សម សារី ចោលទៅ ពីព្រោះដឹងច្បាស់ថា លោក សម សារី ជាចារកម្មរបស់សម្ដេច សីហនុចូលមកដើម្បីបំផ្លាញចលនាខ្មែរសេរី ហើយលាបពណ៌ចលនាខ្មែរសេរីថា ជាពួកកុម្មុយនិស្តធ្វើឱ្យប្រទេស សៀមលែងឱ្យដីចលនាខ្មែរសេរី ជ្រកកោនទៀត។ មិនតែប៉ុណ្ណោះ សម សារីបានរៀបចំផែនការសម្លាប់សឺង ង៉ុកថាញ់ ផងដែរ។ ពេលថាច់ ត្រឹង សម្លាប់សម សារី នោះអត់មានសុំបញ្ជាពីសឺង ង៉ុកថាញ់ទេ ពោលគឺសម្លាប់រួចហើយ ទើបរាយការណ៍ និងបង្ហាញឯកសារតឹកតាងទៅសឺង ង៉ុកថាញ់ តាមក្រោយ។

ប្រភពព័ត៌មានដដែលនោះ បានអះអាងថា មុនពេលបាញ់ស្លាប់ សម សារី បានប្រកែកតវ៉ាជាមួយថាច់ ត្រឹង ឡើងតឹងសរសៃក តែវាសនាចារកិច្ចជនរូបនេះ មិនអាចគេចផុតពីគ្រាប់កាំភ្លើងរបស់អ្នកស្នេហាជាតិខ្មែរក្រោម ឈ្មោះថាច់ ត្រឹង នោះបានទេ។

ប្រភពព័ត៌មានខាងលើនេះហាក់ដូចជាមិនត្រឹមត្រូវទេ ព្រោះសឺង ង៉ុកថាញ់ បានចាកចេញពីប្រទេសថៃទៅរស់នៅស្រុកកំណើតរបស់គាត់ឯកម្ពុជាក្រោម តាំងពីឆ្នាំ១៩៥៧មកម្ល៉េះ ហើយគាត់រស់នៅ និងបង្កើតចលនាខ្មែរសេរី ចាប់ពី ឆ្នាំ១៩៥៨ នៅប្រទេសយួនខាងត្បូង រហូតដល់សម សារី ស្លាប់ក្នុងឆ្នាំ១៩៦៣ ក៏គាត់នៅតែរស់ក្នុងប្រទេសយួនខាង

ត្បូង នោះដែរ។  ដូច្នេះប្រភពព័ត៌មានដែលថា សម សារី បានលួចផ្ញើសំបុត្រថ្វាយដំណឹងមកសម្តេចសីហនុ ជាសម្ងាត់ ដើម្បីឱ្យក្រុមប៉ូលិសសម្ងាត់របស់ព្រះអង្គត្រៀមរៀបចំផែនការពួនស្ទាក់បាញ់សម្លាប់សឺង ង៉ុកថាញ់ ឱ្យបាន ពេលឆ្លងដែនពីប្រទេសថៃ ចូលដល់ក្នុងដីខ្មែរកណ្តាល ដើម្បីទៅកម្ពុជាក្រោមនោះ ដូចជាមិនសមហេតុផលទេ។

ប្រភពព័ត៌មានមួយផ្សេងទៀត បានអះអាងថា ក្រោយពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃថៃ ប្រ៉ះផាត ចារុសៈធៀន ( Praphat Charusathian ) ស្នើសុំឱ្យបញ្ឈប់សកម្មភាពរបស់ចលនាតស៊ូខ្មែរសេរីមក សម សារី អស់សង្ឃឹម គាត់មានបំណងសុំសិទ្ធិជ្រកកោនខាងនយោបាយនៅប្រទេសបារាំង តែមិនបានដូចបំណង គាត់ក៏ចង់សុំការលើកលែងទោសពីសម្តេចសីហនុ ដើម្បីបានវិញត្រលប់មកមាតុប្រទេសវិញ។ ក្នុងអំឡុងឆ្នាំ១៩៦២ គាត់បានយកឯកសារសម្ងាត់របស់ចលនាតស៊ូខ្មែរសេរី ឱ្យអ្នកបើកបររថយន្តជនជាតិថៃម្នាក់ យកទៅដាក់នៅប៉ុស្តិ៍ប្រៃសណីយ៍ ដោយផ្ញើបង្វែងដានទៅមិត្តភក្តិជិតស្និទ្ធរបស់គាត់ ជាជនជាតិអង់គ្លេសរស់នៅទីក្រុងឡុងដ៍ ដើម្បីឱ្យផ្ញើបន្តទៅថ្វាយសម្តេចសីហនុ ជាបន្តបន្ទាប់ ដើម្បីយកគុណសម្បត្តិ ជាថ្នូរនឹងការលុបលាងកំហុស និងសុំចុះចូលជាមួយព្រះអង្គវិញ ។ តែបញ្ញើឯកសារសម្ងាត់នោះ ត្រូវគេចាប់បានទាំងអស់។ នៅទីបំផុត ក្នុងឆ្នាំ១៩៦៣ ពួកសេ.អ៊ី.អា( CIA ) អាមេរិក និងប៉ូលិសថៃ ដែលជាអ្នកទទួលខុសត្រូវលើចលនាខ្មែរសេរី ក៏បានប្រើល្បិចនាំសម សារី ទៅមើលទីតាំងតស៊ូដែលត្រូវបង្កើតថ្មី នៅក្បែរព្រំដែនលាវ និងកម្ពុជា រួចហើយក៏បានសម្លាប់គាត់ នៅទីនោះតែម្តងទៅ។

បើតាមបុរសវ័យចំណាស់ម្នាក់ ឈ្មោះចាន់ សាម៉ន រស់នៅប្រទេសបារាំង មានឪពុកឈ្មោះចាន់ រស់ ធ្លាប់ចូលរួមចលនាខ្មែរសេរីនៅតាមព្រំដែនខ្មែរ.ថៃ នៅចុងឆ្នាំ១៩៥៩ បានអះអាងថា សម សារី មានគំនិតក្បត់សឺង ង៉ុកថាញ់ ដោយលួចសរសេរសំបុត្រទៅសុំចុះចូលនឹងសម្តេចសីហនុ វិញ ហើយសំបុត្រនោះត្រូវបានបែកការណ៍។ ចុងបញ្ចប់ នៅក្នុងឆ្នាំ១៩៦៣ សម សារី ត្រូវបានទាហានថៃ យកទៅសម្លាប់ចោលនៅទល់ដែនខ្មែរ.លាវ ដោយកុហកគាត់ថា នាំទៅមើលទីតាំងតស៊ូដែលត្រូវបង្កើតថ្មីទៀត។

ប្រហាក់ប្រហែលគ្នានឹងព័ត៌មានខាងលើនេះដែរ តាម ឡឹក សំអឿន ហៅផ្កាយព្រឹក ជាអតីតមេដឹកនាំទី៣ របស់ពួកខ្មែរសេរី ដែលបានភៀសខ្លួនទៅរស់នៅសហរដ្ឋអាមេរិក ក្រោយពេលពួកមេដឹកនាំខ្មែរក្រហមឡើងកាន់អំណាចឆ្នាំ១៩៧៥ បានបញ្ជាក់ថា សម សារី បានលួចសរសេរសំបុត្រជាបន្តបន្ទាប់ ដើម្បីត្រលប់មកសុំចុះចូលជាមួយសម្តេចសីហនុ វិញ ដោយឱ្យអ្នកបើកបររថយន្តជាជនជាតិថៃម្នាក់ យកសំបុត្រនោះទៅផ្ញើនៅប៉ុស្តិ៍ប្រៃសណីយ៍។ តែអ្នកបើកបររថយន្តជាជនជាតិថៃនោះ បែរជាយកសំបុត្រទាំងអស់នោះទៅប្រគល់ឱ្យពួកមន្ត្រីអាមេរិក នៅក្នុងក្រុងបាងកក ទៅវិញ។ ពេលនោះពួកសេអ៊ីអា(CIA)ដឹងថា សម សារី មានចិត្តមិនស្មោះត្រង់ចង់ទៅចុះចូលជាមួយសម្តេចសីហនុ វិញ ក៏ឱ្យពួកថៃ ប្រើល្បិចនាំទៅក្បែរព្រំដែនប្រទេសឡាវ រួចសម្លាប់ចោលនៅទីនោះតែម្តងទៅ។

ក្នុងឆ្នាំ១៩៦៣ មជ្ឈដ្ឋានខ្លះនៅក្រុងភ្នំពេញ បានបំផុសពាក្យចចាមអារ៉ាមថា សឺង ង៉ុកថាញ់ ជាអ្នកបាញ់សម្លាប់ សម សារី ព្រោះតែរឿងដណ្តើមតួនាទីគ្នា។

ប៉ុន្តែបើតាម ឡឹក សំអឿន ហៅផ្កាយព្រឹក ជាអតីតមេដឹកនាំលំដាប់ទី៣ របស់ពួកខ្មែរសេរីដែលបានភៀសខ្លួនទៅរស់នៅសហរដ្ឋអាមេរិក ក្រោយពេលពួកមេដឹកនាំខ្មែរក្រហមឡើងកាន់អំណាចឆ្នាំ១៩៧៥ បានអះអាងថា នៅពេលកំពុងដឹកនាំចលនាតស៊ូខ្មែរសេរី នៅប្រទេសថៃ ក្នុងឆ្នាំ១៩៦២-៦៣ សម សារី បានឱ្យអ្នកបើកបររថយន្តជនជាតិថៃ យកលិខិតដែលគាត់សរសេរពីការសម្ងាត់របស់ចលនាតស៊ូខ្មែរសេរី ជាបន្តបន្ទាប់ ទៅដាក់នៅប៉ុស្តិ៍ប្រៃ-សណីយ៍ ដើម្បីផ្ញើថ្វាយសម្តេចសីហនុ ដើម្បីយកគុណសម្បត្តិជាថ្នូរនឹងការសុំចុះ ចូលជាមួយព្រះអង្គវិញ។

ក្រោយពីដឹងថា សម សារី មិនស្មោះត្រង់ជាមួយពួកខ្មែរសេរី និងចង់ងាកត្រលប់រកសម្តេចសីហនុ វិញនោះ មេសេ.អ៊ី.អា(CIA) អាមេរិក រួមគ្នាជាមួយមេប៉ូលិសថៃ ដែលជាអ្នកទទួលខុសត្រូវលើចលនាខ្មែរសេរី ក៏បានប្រើល្បិចកល នាំសម សារី ទៅខេត្តចំប៉ាសាក់ ជាប់ព្រំដែនថៃ លាវ និងកម្ពុជា រួចហើយ ក៏បានសម្លាប់នៅទីនោះតែម្តងទៅ។

ឡឹក សំអឿន ហៅផ្កាយព្រឹក មេដឹកនាំលំដាប់ទី៣ របស់ចលនាតស៊ូខ្មែរសេរី ក្រោយ

## របត់នយោបាយ

ព្រឹត្តិការណ៍រដ្ឋប្រហារ ឆ្នាំ១៩៧០ នៅក្នុងរបបសាធារណរដ្ឋខ្មែរ(ឆ្នាំ១៩៧០-៧៥)ជាមេបញ្ជាការរងយោធភូមិភាគទី៤ និងជាមេបញ្ជាការកងពលតូចលេខ២៥ ប្រចាំការនៅខេត្តសៀមរាប។ ក្រោយពួកខ្មែរក្រហមវាយដណ្ដើមបានទីក្រុងភ្នំពេញ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គាត់បានភៀសខ្លួនទៅរស់នៅសហរដ្ឋអាមេរិក គាត់បានទទួលមរណភាពនៅថ្ងៃចន្ទទី១៧ ខែធ្នូ ឆ្នាំ២០១២ នៅក្នុងមន្ទីរពេទ្យបូស្តុន (Boston) រដ្ឋម៉ាស្សាជូសេត សហរដ្ឋអាមេរិក ក្នុងជន្មាយុ ៨៤ ឆ្នាំ។

បើយោងតាមសៀវភៅប្រវត្តិរូបសង្ខេបនៃសមាជិកគណៈកម្មាធិការកណ្ដាលរបស់គណបក្សសង្គមរាស្ត្រនិយម សម សារី កើតនៅថ្ងៃទី០៦ ខែមីនា ឆ្នាំ១៩១៧ នៅឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។ គាត់កូនទី២ ក្នុងចំណោមកូនទាំងអស់ចំនួន៧នាក់។

ក្រោយរៀនចប់សាលាបឋមសិក្សា គាត់បានមកបន្តការសិក្សានៅអនុវិទ្យាល័យព្រះស៊ីសុវត្ថិ រហូតប្រលងជាប់មធ្យមសិក្សាបត្រផ្នែកទស្សនវិជ្ជា ហើយបានទទួលអាហារូបករណ៍ត្រូវមកសិក្សានៅប្រទេសបារាំង ក្នុងឆ្នាំសិក្សា១៩៣៩។ តែគាត់ត្រូវរង់ចាំអស់រយៈពេលដល់ទៅ៧ឆ្នាំទៀត ទើបបានទៅបន្តការសិក្សានោះ។ នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៣៩ ក្នុងវ័យ២២ឆ្នាំ សម សារី បានរៀបអាពាហ៍ពិពាហ៍ជាមួយកញ្ញាអ៊ិន អេម ជាស្ត្រីខ្មែរទី១ ដែលទទួលបានសញ្ញាបត្រមធ្យមសិក្សាបត្រ នៅវិទ្យាល័យហ្សាស់សឺលូ ឡូបា ទីក្រុងព្រៃនគរ ។ ក្នុងឆ្នាំ១៩៤០ គាត់បានចូលបម្រើការងារជាសុភាចារ្យបុរសកម្មសិក្សាការីនៅក្នុងតុលាការខេត្តបាត់ដំបង រហូតដល់ឆ្នាំ១៩៤៤ គាត់បានផ្លាស់មកបម្រើការងារនៅសាលាឧទ្ធរណ៍នៅរាជធានីភ្នំពេញ វិញ។

នៅក្នុងឆ្នាំ១៩៤៥ ពេលជប៉ុន ដណ្ដើមបារាំងកាន់កាប់ប្រទេសខ្មែរ គាត់បម្រើការងារជាមេប៉ូលិសនយោបាយ។ ក្រោយពេលព្រះចៅអធិរាជប្រទេសជប៉ុន ប្រកាសចុះចាញ់សង្គ្រាមលោកលើកទី២ ក្នុងកញ្ញា ឆ្នាំ១៩៤៥ ហើយបារាំង វិលមកត្រួតត្រាប្រទេសកម្ពុជាវិញ គាត់បានឡើងតំណែងជាស្នងការប៉ូលិសរាជធានីភ្នំពេញ នៅដើមឆ្នាំ១៩៤៦។ តែប៉ុន្មានខែក្រោយមក គាត់បានដាក់ពាក្យសុំព្យួរមុខតំណែងនេះ ដើម្បីទៅបន្តការសិក្សានៅ

ប្រទេសបារាំង។ នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ១៩៤៩ សម សារី ទទួលបានសញ្ញាបត្រផ្នែកសេវាសាធារណៈ នៅវិទ្យាស្ថានសិក្សានយោបាយ និងសញ្ញាបត្រច្បាប់នៅមហាវិទ្យាល័យច្បាប់ នាទីក្រុងប៉ារីស។

ក្រោយពីបញ្ចប់ការសិក្សានៅប្រទេសបារាំង វិញមក នៅដើមឆ្នាំ១៩៥០ គាត់បានវិលត្រលប់ មកមាតុប្រទេសវិញ ហើយត្រូវបាន ប៉ែន នុត នាំចូលគាល់ព្រះមហាក្សត្រ នរោត្តម សីហនុ ស្របពេលព្រះអង្គកំពុងរកអ្នកមានចំណេះវិជ្ជាខ្ពង់ខ្ពស់ ប្រាជ្ញាឈ្លាសវៃ ដើម្បីជួយព្រះអង្គក្នុងព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យពីបារាំង រហូតបានជោគជ័យនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣។

នៅក្នុងឆ្នាំ១៩៥៤ គណៈប្រតិភូនៃរាជរដ្ឋាភិបាលកម្ពុជា ដឹកនាំដោយរដ្ឋមន្ត្រីការបរទេស ទេព ផន, នង គីមនី, សម សារី, សឺន សាន ទៅចូលរួមក្នុងសន្និសីទក្រុងហ្សឺណែវ។

នៅថ្ងៃទី០២ ខែមីនា ឆ្នាំ១៩៥៥ សម សារី រួមទាំង ប៉ែន នុត និងយឹម ទិត ផងដែរត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សារាជបល្ល័ង្ក។ ដោយឡែក សម សារី ក៏មានតួនាទីជាអ្នកនិពន្ធព្រះរាជជីវប្រវត្តិរបស់សម្ដេចសីហនុ ផងដែរ។

នៅក្នុងចលនាសង្គមរាស្ត្រនិយម ដែលសម្ដេចសីហនុ ប្រកាសបង្កើតជាផ្លូវការនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៥៥ សម សារី ជាអគ្គលេខាធិការចលនានេះ និងជាសហការីដ៏ជំនិតបំផុតរបស់ព្រះអង្គដែរនោះ បានរិះរកគ្រប់វិធី ធ្វើយ៉ាងណាឱ្យចលនានោះទទួលបានជ័យជម្នះ ដ៏ត្រចះត្រចង់នៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៥៥។

ក្រោយលទ្ធផលនៃការបោះឆ្នោត ដែល ចលនាសង្គមរាស្ត្រនិយម ឈ្នះក្លូកទឹកក្លូកដីនោះមក នៅថ្ងៃទី០៣ ខែតុលា សម្ដេចសីហនុ ជាប្រធានចលនាសង្គមរាស្ត្រនិយម បានឡើងជានាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេស ព្រះអង្គបានតែងតាំង សម សារី ឱ្យឡើងជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីសេដ្ឋកិច្ចជាតិ ហិរញ្ញវត្ថុ ផែនការ និងអប់រំជាតិ ផងដែរ។

នៅក្នុងឆ្នាំ១៩៥៥ នោះដែរ មានកម្មវិធីប្រលងបវរកញ្ញាមួយឱ្យឈ្មោះថា ទេវីសោភា



**បវរកញ្ញា ទេព កិន្នរី** (រូបកណ្ដាលគេ)

ក្រុងភ្នំពេញ ខណៈនោះបេក្ខនារីឈ្មោះ ទេព កិន្នរី ជាប់ចំណាត់ថ្នាក់ជាបវរកញ្ញាទេវីសោភា លេខ១។ បេក្ខនារីជាគ្រូបង្រៀនឈ្មោះ ហុក ស៊ុនលី ជាប់ចំណាត់ថ្នាក់ជាបវរកញ្ញាកិត្តិយស លេខ២ និងបេក្ខនារីឈ្មោះហែម ចំរើន ជាប់ចំណាត់ថ្នាក់ជាបវរកញ្ញាកិត្តិយសលេខ២។

ពេលនោះ សម សារី បានយកស្រីដ៏ស្រស់ស្អាតម្នាក់ ដែលទើបនឹងប្រលងជាប់ ជាបវរកញ្ញា ឈ្មោះ ទេព កិន្នរី ធ្វើជាប្រពន្ធចុង ហើយថែមទាំងយកមករស់នៅផ្ទះជាមួយប្រពន្ធដើមទៀតផង។ ក្រោយមក គាត់ក៏បានយកបេក្ខនារីដែលប្រលងបវរកញ្ញាឈ្មោះ អ៊ីវ អេងសេង មកធ្វើជាប្រពន្ធថែមម្នាក់ទៀត។

ចំណែកបេក្ខនារីជាគ្រូបង្រៀនឈ្មោះ ហុក ស៊ុនលី ជាប់ចំណាត់ថ្នាក់លេខ២ បានរៀបការជាមួយកំលោះ ពីង គឹមសួ ជាសស្ត្រាចារ្យនៅវិទ្យាល័យព្រះស៊ីសុវត្ថិ។ សម សារី និងអ៊ិន អេម មានកូនចំនួន៥នាក់ គឺ ១-សម អេម៉ារ៉ា ភេទប្រុស កើតក្នុងឆ្នាំ១៩៤០, ២-សម អេម៉ារ៉ាន ភេទស្រី កើតក្នុងឆ្នាំ១៩៤១, ៣-សម អេម៉ារិទ្ធ ភេទប្រុស កើតក្នុងឆ្នាំ១៩៤៥, ទី៤-សម មិទ្ធារី ភេទប្រុស កើតក្នុងឆ្នាំ១៩៤៦ និងសម រង្ស៊ី ភេទប្រុស កើតនៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៤៩។

# ១៤៥
# បាតុកម្មនៅខេត្តសៀមរាប សិស្សម្នាក់ស្លាប់នៅក្នុងប៉ុស្តិ៍ប៉ូលិស សម្តេចសីហនុ បន្ទោសកេង វ៉ាន់សាក់ និងសុន សេន




**សុន សេន** (**ពាក់អាវធំពណ៌ខ្មៅ**) **កេង វ៉ាន់សាក់**(**ពាក់អាវស**)

នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៦៣ ក្រោយពីយាងទៅបំពេញទស្សនកិច្ចនៅប្រទេសឥណ្ឌា និងប្រទេសចិនមក សម្តេចសីហនុ ក៏បានណែនាំឱ្យរាជរដ្ឋាភិបាលដែលមានទ្រង់នរោត្តម កន្តុល ជានាយករដ្ឋមន្ត្រី ធ្វើយ៉ាងណាកុំឱ្យទំនិញឡើងថ្លៃ និងបញ្ឈប់ការចាយវាយថវិការដ្ឋខ្ជះខ្ជាយ ពិសេស គឺលុបបំបាត់ពួកឈ្មួញកណ្តាល។

ពេលព្រះអង្គកំពុងបំពេញទស្សនកិច្ចនៅប្រទេសទាំង២នោះ នៅក្រុងសៀមរាប ក៏

# របត់នយោបាយ

មានសិស្សវិទ្យាល័យនាំគ្នាធ្វើបាតុកម្មវាយកម្ទេចប៉ុស្តិ៍ប៉ូលិសមួយកន្លែង។

ដើមហេតុនៃការធ្វើបាតុកម្មនោះ ត្រូវបានគេដឹងថា នៅក្នុងក្រុងសៀមរាបនោះ មាននាយប៉ូលិសកំណាចម្នាក់ ដែលគេសង្ស័យថា ជាអ្នករកស៊ីរត់ពន្ធផងដែរ តែងតែធ្វើបាបសិស្សវិទ្យាល័យណាដែលជិះកង់តាមផ្លូវនានានៅពេលយប់ស្ងាត់។ គាត់យល់ថា ពួកសិស្សដែលជិះកង់ដើរលេងយប់ទាំងនោះជាពួកមនុស្សខិលខូច គាត់ក៏ចាប់វាយ ឬធ្វើទារុណកម្មដើម្បីឱ្យរាងចាល កុំឱ្យដើរលេងផ្តេសផ្តាសពេលយប់អធ្រាត្រទៀត ។

ពិសេស គាត់ក៏បានវាយដំទៅលើក្មួយប្រុសរបស់គាត់ម្នាក់ដែលមិនព្រមស្តាប់តាមការទូន្មានរបស់គាត់ គឺនៅតែចចេសលួចជិះកង់ដើរលេងនៅពេលយប់ផងដែរ។

ប៉ុន្មានថ្ងៃក្រោយមក គេឃើញសាកសពសិស្សម្នាក់ស្លាប់នៅក្នុងប៉ុស្តិ៍ប៉ូលិស ដោយមានស្នាមវាយដំជាច្រើនកន្លែង។ ពេលនោះ សិស្សវិទ្យាល័យជាច្រើនបានចោទប្រកាន់គាត់ថា ជាអ្នកវាយសម្លាប់មិត្តរួមវិទ្យាល័យរបស់ពួកគេ។ ប៉ុន្តែ ដោយសារអាជ្ញាធរខេត្តសៀមរាបមិនបានចាត់ការអ្វីទៅលើនាយប៉ូលិសរូបនោះ ទើបបណ្តាលឱ្យពួកសិស្សវិទ្យាល័យមានការខឹងសម្បាកាន់តែខ្លាំងឡើងៗ ក៏បាននាំគ្នាធ្វើបាតុកម្មឡោមព័ទ្ធប៉ុស្តិ៍ប៉ូលិសនោះ ដោយមានលើកបដាសរសេរអក្សរថា សង្គមពុករលួយ! សង្គមអយុត្តិធម៌! បរាជ័យសង្គមរាស្ត្រនិយម! ជាដើម និងបាននាំគ្នាចូលទៅវាយកម្ទេចតុកៅអី និងសម្ភារៈការិយាល័យ ព្រមទាំងឯកសារផ្សេងៗ ក្នុងប៉ុស្តិ៍ប៉ូលិសនោះខ្ទេចខ្ទីអស់ ហើយថែមទាំងដោះយកព្រះឆាយាលក្ខណ៍សម្តេចសីហនុ ជាព្រះប្រមុខរដ្ឋគ្រវែងចេញមកក្រៅ ហើយប៉ូលិសម្នាក់ ក៏ត្រូវពួកបាតុករវាយសម្លាប់នៅពេលនោះផងដែរ។

តាមរបាយការណ៍របស់អាជ្ញាធរខេត្ត បានឱ្យដឹងថា បាតុកម្មដ៏ហិង្សានេះពុំមែនកើតឡើងដោយពួកសិស្សវិទ្យាល័យទាំងស្រុងនោះទេ គឺគ្រូៗជាខ្មែរបណ្តាញបង្កប់របស់ពួកកុម្មុយ-និស្តជាអ្នកញុះញង់ពីក្រោយផងដែរ។

សមាជិកគណៈរដ្ឋមន្ត្រី២រូប នៅទីក្រុងភ្នំពេញ និងអភិបាលខេត្តសៀមរាប ព្រមទាំងមន្ត្រីរដ្ឋាភិបាលមួយចំនួនទៀត ក៏បាននាំគ្នាទៅដល់កន្លែងកើតហេតុ ក្នុងគោលបំណងធ្វើការ

សម្របសម្រួលជាមួយបាតុករទាំងនោះដែរ។ តែត្រូវពួកបាតុករដែលមានសុទ្ធតែដុំថ្ម ព្រនង់ និងដំបងគ្រប់ដៃនោះ នាំគ្នាចាប់បង្ខំឱ្យមន្ត្រីរាជរដ្ឋាភិបាលទាំងអស់នោះ ដើរហែក្បួនធ្វើបាតុកម្ម ជាមួយពួកគេជុំវិញក្រុងសៀមរាប ។

ពេលនោះដែរ ពួកបាតុករជាសិស្សនៅក្រុងសៀមរាប ក៏បានអំពាវនាវឱ្យសិស្សនៅទីក្រុងភ្នំពេញ និងនៅតាមខេត្តផ្សេងៗទៀត នាំគ្នាធ្វើបាតុកម្មប្រឆាំងនឹងការសម្លាប់សិស្សនៅក្រុងសៀមរាប នោះផងដែរ។

នៅពេលសម្តេចសីហនុ យាងត្រលប់មកពីបរទេសវិញ ព្រះអង្គបានស្តីបន្ទោស កេង វ៉ាន់សាក់ និងសុន សេន ជានាយកសាលាគរុកោសល្យនៅកំពង់កន្ទួត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលមុនមានបាតុកម្មដ៏ហិង្សានោះ គាត់បានទៅជួបប្រជុំជាមួយសិស្សនៅក្នុងក្រុងសៀមរាបនោះ ដោយបានលើកឡើងពីបញ្ហានយោបាយរបស់ប្រទេសជាតិផងដែរ តែសុន សេន បានបដិសេធនឹងការចោទប្រកាន់នោះ។

ជាមួយគ្នានោះ ព្រះអង្គក៏បានទាមទារឱ្យរាជរដ្ឋាភិបាលព្រះអង្គម្ចាស់នរោត្តម កន្តុល ទាំងមូលលាលែងពីតំណែង។

ក្រោយនោះបន្តិច នៅក្នុងពិធីប្រគល់សញ្ញាបត្រវេជ្ជបណ្ឌិតជំនាន់ទី១ នៃមហាវិទ្យាល័យភូមិន្ទវិជ្ជាទេព្យ សម្តេចសីហនុ បានមានបន្ទូលថា និស្សិតជាច្រើនធ្លាប់ចាញ់បោកការឃោសនានយោបាយនៅបរទេស ដោយបំភ្លេចចោលពីហេតុផលផ្សេងៗ របស់ពួកគេពេលដែលត្រូវបញ្ជូនឱ្យទៅរៀននៅប្រទេសបារាំង ហើយពេលត្រលប់មកវិញពួកគេគ្មានគិតអ្វីក្រៅពីធ្វើឱ្យមានភាពច្របូកច្របល់នៅក្នុងសង្គមជាតិតែប៉ុណ្ណោះ។ ពួកគេក្រពុលមុខលែងដឹងខុសត្រូវអស់ហើយ។

# ១៤៦
# មហាសន្និបាតលើកទី៣ របស់បក្សពលករកម្ពុជា



**សាឡុត ស**

ក្រោយពីបាត់ខ្លួន ទូ សាមុត ជាអគ្គលេខាបក្សពលករកម្ពុជា រយៈពេលកន្លះឆ្នាំ នៅថ្ងៃទី២០ និង២១ ខែកុម្ភៈ ឆ្នាំ១៩៦៣ បក្សពលករកម្ពុជា ក៏បានប្រារព្ធធ្វើមហាសន្និបាតលើកទី៣របស់ខ្លួន ដើម្បីរៀបចំរចនាសម្ព័ន្ធដឹកនាំឡើងវិញ នៅកន្លែងលាក់ការសម្ងាត់មួយក្នុងទីក្រុងភ្នំពេញ។

បើតាមប្រភពពីមេដឹកនាំកុម្មុយនិស្តវៀតណាម បានឱ្យដឹងថា ពេញ ធួក ហៅ វន វ៉េត ពេលនោះមានតួនាទីជាលេខាគណៈកម្មាធិការបក្សទីក្រុងភ្នំពេញ និងជាអ្នកទទូចឱ្យបើកមហាសន្និបាតនេះ ដោយមិនបាច់ឱ្យសមាជិកគណៈកម្មាធិការមជ្ឈិមបក្សផ្សេងៗទៀត ដឹងជាមុនយូរថ្ងៃឡើយ ដូច្នេះហើយ បានជាក្នុងចំណោមសមាជិកបក្ស២០នាក់ ដែលចូលរួមក្នុងមហាសន្និបាតនោះ ភាគច្រើនជាតំណាងបក្សនៅក្នុងទីក្រុងភ្នំពេញ និងខេត្តជិតៗទីក្រុង

ភ្នំពេញនេះ។

សាឡុត ស ត្រូវបានតែងតាំងជាលេខាគណៈកម្មាធិការមជ្ឈិមបក្សពលករកម្ពុជា។ តាមពិតតំណែងនេះត្រូវបានទៅលើនួន ជា ដែលពីមុនជាអនុលេខាគណៈកម្មាធិការមជ្ឈិមបក្ស។ ប៉ុន្តែគាត់បដិសេធមិនទទួល ដោយលើកហេតុផលថា ស៊ីវ ហេង ជាពូថ្លៃរបស់គាត់ក្បត់បក្ស ទៅចុះចូលជាមួយនឹង លន់ នល់ ដូច្នេះ គាត់គិតថា គាត់មិនស័ក្តិសមនឹងទទួលតំណែងកំពូលនេះទេ។

តាមរចនាសម្ព័ន្ធចាត់តាំងរបស់បក្សពលករកម្ពុជានេះ រួមមាន សាឡុត ស លេខាគណៈកម្មាធិការមជ្ឈិមបក្ស, នួន ជា អនុលេខាគណៈកម្មាធិការមជ្ឈិមបក្ស, អៀង សារី, សោ ភឹម, វន វ៉េត, ជួន ប្រាសិទ្ធ, រស់ ញឹម (មូល សម្បត្តិ), តាម៉ុក (ឈិត ជឿន), សុន សេន (ខៀវ)។

ជាមួយគ្នានោះ មាន៥នាក់ជាសមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការមជ្ឈិមបក្ស រួមមាន សាឡុត ស, នួន ជា, អៀង សារី, សោ ភឹម, វន វ៉េត។ ដោយឡែក សោ ភឹម ត្រូវបានតែងតាំងជាលេខាគណៈកម្មាធិការបក្សភូមិភាគបូព៌ា, រស់ ញឹម (មូល សម្បត្តិ) ត្រូវបានតែងតាំងជាគណៈកម្មាធិការបក្សភូមិភាគពាយ័ព្យ និងតាម៉ុក(ឈិត ជឿន) ត្រូវបានតែងតាំងជាគណៈកម្មាធិការបក្សភូមិភាគនិរតី។

សាឡុត ស, នួន ជា, អៀង សារី និងវន វ៉េត ជាអ្នកទទួលខុសត្រូវលើផ្ទៃប្រទេសទាំងមូល។

ចំណែក កែវ មាស ដែលទើបនឹងរត់គេចខ្លួនទៅក្រៅប្រទេស និងនង សួន ដែលត្រូវបន្ធូរបន្ថយពីទោសប្រហារជីវិតឱ្យមកនៅត្រឹមជាប់គុកមួយជីវិតវិញនោះ ពុំមានឈ្មោះក្នុងរចនាសម្ព័ន្ធដឹកនាំថ្មីនោះទេ។

រហូតមកដល់ឆ្នាំ១៩៧៤ គឺពេលកំពុងធ្វើសង្គ្រាមស៊ីសាច់ហុតឈាមគ្នាជាមួយរបបសាធារណរដ្ឋខ្មែររបស់លោកសេនាប្រមុខ លន់ នល់ នោះ អៀង សារី បានធ្វើការបកស្រាយថា មហាសន្និបាត ដែលធ្វើឡើងនៅក្នុងឆ្នាំ១៩៦៣ នោះ គឺជាមហាសន្និបាតបក្សលើកទី២

មិនមែនលើកទី៣ទេ ហើយមហាសន្និបាតនោះ មិនមានអ្វីក្រៅពីការចាត់តាំងរចនាសម្ព័ន្ធដឹកនាំក្នុងជួរបក្សនោះឡើយ។

ការពិត មហាសន្និបាតរបស់បក្សប្រជាជនបដិវត្តន៍ខ្មែរ បង្កើតឡើងនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៥១ ដែលមាន សឺង ង៉ុកមិញ ជាលេខាគណៈកម្មាធិការមជ្ឈិមបក្សនោះ គឺជាមហាសន្និបាតលើកទី១ ពិតមែនហើយ។ ប៉ុន្តែនៅថ្ងៃទី២៨ ដល់៣០ ខែកញ្ញា ឆ្នាំ១៩៦០ បក្សប្រជាជនបដិវត្តន៍ខ្មែរនេះ បានប្រារព្ធធ្វើមហាសន្និបាតលើកទី២របស់ខ្លួន ដោយគ្មានវត្តមានសឺង ង៉ុកមិញ ជាលេខាបក្ស និងបានដូរឈ្មោះមកជាបក្សពលករកម្ពុជា ហើយទូ សាមុត ត្រូវបានតែងតាំងជាលេខាគណៈកម្មាធិការមជ្ឈិមបក្សវិញ។

នេះអាចចាត់ទុកថា ជាមហាសន្និបាតបក្សពលករកម្ពុជាលើកទី១ ដូច្នេះអ្វីដែល អៀង សារី បញ្ជាក់ថា ការបើកមហាសន្និបាត នៅថ្ងៃទី២០ និង២១ ខែកុម្ភៈ ឆ្នាំ១៩៦៣ នោះ ថាជាមហាសន្និបាតបក្សពលករកម្ពុជាលើកទី២ ក៏មិនខុសដែរ។

នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៦៣ គឺក្រោយមហាសន្និបាតបក្សពលករកម្ពុជា ១៤ថ្ងៃ សម្តេចសីហនុ បានប្រកាសឈ្មោះជនទាំងឡាយដែលព្រះអង្គចាត់ទុកថាជា មេខ្លោងធ្វើវិទ្ធង្សនា ចំនួន៣៤នាក់ សុទ្ធសឹងជាបញ្ញវន្ត និងឥស្សរជនឆ្វេងនិយម មានជាអាទិ ខៀវ សំផន (រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម), ហ៊ូ យន់ (រដ្ឋលេខាធិការក្រសួងផែនការ), ចៅ សេង (រដ្ឋលេខាធិការក្រសួងកសិកម្ម), ហ៊ូ នឹម, សាឡុត ស, អៀង សារី, សុន សេន, ជួន ប្រាសិទ្ធ និងឱក សាគុណ ជាដើម ព្រមទាំងមានពួកស្តាំនិយមមួយចំនួនផងដែរ។

តែទោះបីយ៉ាងណា ព្រះអង្គបានបដិសេធចំពោះសំណើរបស់ឧត្តមសេនីយ៍ លន់ នល់ ជាទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារប្រទេស និងកីឡា ដែលបានសុំចាត់វិធានការបង្ក្រាបពួកប្រឆាំងទាំង៣៤នាក់នោះ ដោយសារទី១ ព្រះអង្គចង់រក្សាទុកពួកឆ្វេងនិយមដ៏ទន់ខ្សោយទាំងអស់នេះ ដើម្បីប្រឆាំងទប់ទល់ជាមួយពួកអភិជនមួយចំនួនដែលជាគូប្រជែងរបស់ព្រះអង្គ និងទី២ ព្រះអង្គឈ្វេងយល់ថា ពួកនេះក៏មានគំនិតជឿនលឿន អាចយកមកប្រើជាកូនសោដ៏សំខាន់សម្រាប់ជួយដោះស្រាយបញ្ហាឱនភាពសេដ្ឋកិច្ចរបស់ប្រទេសជាតិ

ផងដែរ។

ព្រះអង្គឈ្វេងយល់ទៀតថា ប្រសិនបើការបះបោរធ្វើបាតុកម្មដ៏ហិង្សានៅក្រុងសៀមរាបនោះកើតឡើង ដោយសារតែប្រជារាស្ត្រគាំទ្រពួកឆ្វេងនិយមមែននោះ ព្រះអង្គសូមឱ្យពួកប្រឆាំងទាំងនោះរៀបចំសមាសភាពគណៈរដ្ឋមន្ត្រីថ្មីមួយ ដើម្បីដឹកនាំប្រទេស។ ប៉ុន្តែក្នុងចំណោមអ្នកប្រឆាំងទាំង៣៤នាក់នោះ គ្មាននរណាម្នាក់ ហ៊ានចេញមុខមករៀបចំគណៈរដ្ឋមន្ត្រីថ្មីមួយ តាមការប្រកាសរបស់ព្រះអង្គឡើយ។ ផ្ទុយទៅវិញ ពួកគេជឿជាក់ថា នេះជាអន្ទាក់របស់សម្តេចសីហនុ និងមេប៉ូលិស មេទាហានរបស់ព្រះអង្គដែលកំពុងតាមស្រាវជ្រាវរកឈ្មោះមេដឹកនាំបក្សពលករកម្ពុជា ដើម្បីយកមកកម្ចាត់ចោលតែប៉ុណ្ណោះ។

# ១៤៧
# សាឡុត ស និងអៀង សារី បាត់ខ្លួនពីក្រុងភ្នំពេញ




ប៉ុល ពត និងអៀង សារី

នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៦៣ លីវ ចាវជី (Liu Shaoqi) ប្រធានាធិបតីសាធារណរដ្ឋប្រជាមានិតចិន មកបំពេញទស្សនកិច្ចនៅកម្ពុជា ដើម្បីរឹតចំណងមិត្តភាព និងសហប្រតិបត្តិការរវាងប្រទេសទាំងពីរឱ្យកាន់តែល្អប្រសើរថែមទៀត។ ព្រះមហាក្សត្រិយានីកុសុមៈ និងសម្តេចសីហនុ ជាព្រះប្រមុខរដ្ឋ បានយាងទៅទទួលស្វាគមន៍ដល់អាកាសយានដ្ឋានពោធិ៍ចិនតុង។

ពេលនោះ ភ្នាក់ងារស៊ើបការណ៍សម្ងាត់របស់ចិន បានរកឃើញគ្រាប់បែកបង្កៃមួយគ្រាប់នៅត្រង់ខ្លោងទ្វារចូលវត្តនាគវ័ន មុនពេលព្រះមហាក្សត្រិយានីកុសុមៈ និងសម្តេចសីហនុ ជូនដំណើរប្រធានាធិបតី លី ចាវជី តាមក្បួនរថយន្តកិត្តិយសតាមបណ្តោយផ្លូវពីអាកាសយានដ្ឋានពោធិ៍ចិនតុង ចូលមកក្រុងភ្នំពេញ។ ភ្នាក់ងារស៊ើបការណ៍សម្ងាត់របស់ចិន បាន

រាយការណ៍ឱ្យសមត្ថកិច្ចកម្ពុជា ទៅដោះគ្រាប់បែបនោះចេញវិញ។ ក្នុងពេលបំពេញ ទស្សន-កិច្ចនោះ មេដឹកនាំប្រទេសទាំងពីរបានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍រួមមួយ ជាមូលដ្ឋានគ្រឹះដើម្បីកិច្ចសហប្រតិបត្តិការ និងរឹតចំណងមិត្តភាពរវាងសាធារណរដ្ឋប្រជាមានិតចិន និងព្រះរាជាណាចក្រកម្ពុជា ឱ្យកាន់តែរឹងមាំថិតថេរយូរអង្វែងថែមទៀត។

ជាមួយគ្នានោះ មេដឹកនាំកុម្មុយនិស្តវៀតណាម ក៏បានប្រកាសទទួលស្គាល់កោះទាំងឡាយរបស់ខ្មែរ ដែលស្ថិតនៅក្នុងឈូងសមុទ្រថៃ ថាជារបស់កម្ពុជា ខណៈដែលប្រទេសវៀតណាមខាងត្បូង ដែលមានសហរដ្ឋអាមេរិកជាខ្នងបង្អែកកំពុងធ្វើសកម្មភាពរំលោភបំពានចង់បានទៅធ្វើជារបស់ខ្លួន។

ទាំងមេដឹកនាំចិន ទាំងមេដឹកនាំវៀតណាមកុម្មុយនិស្ត បានបង្កើនការយកចិត្តទុកដាក់ផ្គាប់ផ្គុនសម្តេចសីហនុ យ៉ាងអស់ពីចិត្តពីថ្លើម ក្នុងបំណងឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង បានបោះទីតាំងក្នុងទឹកដីកម្ពុជា ដើម្បីធ្វើសង្គ្រាមបណ្តេញពួកចក្រពត្តិអាមេរិក និងផ្តួលរំលំរបបរដ្ឋការក្រុងព្រៃនគរ ព្រមទាំងរំដោះប្រទេសវៀតណាមខាងត្បូង ឱ្យទៅជាប្រទេសកុម្មុយនិស្តតែមួយ។

ចិន និងវៀតណាមកុម្មុយនិស្ត បានសម្រេចចិត្តរឹតចំណងមិត្តភាពជាមួយសម្តេចសីហនុ ឱ្យបានរឹងមាំសិន ប្រសើរជាងជួយឧបត្ថម្ភគាំទ្រដល់ចលនាតស៊ូរបស់ពួកកុម្មុយនិស្តកម្ពុជា។

ពេលនោះ ភ្នាក់ងារប៉ូលិសរបស់សម្តេចសីហនុ បានធ្វើការតាមដានសកម្មភាព សាឡុត ស ដែរ តែពួកគេមិនច្បាស់ថា សាឡុត ស ជានរណាឱ្យពិតប្រាកដទេ ហើយសាធារណជនក៏មិនសូវស្គាល់គាត់ប៉ុន្មានដែរ ព្រោះគាត់ចេះតែលាក់ការណ៍ មិនឱ្យនរណាដឹងថាគាត់ជាមេដឹកនាំកំពូលរបស់ពួកកុម្មុយនិស្តនោះឡើយ។

ចំណែក ខៀវ ប៉ុណ្ណារី ជាប្រពន្ធរបស់គាត់មានតួនាទីសម្ងាត់ជាប្រធានអង្គការនារីរបស់ពួកកុម្មុយនិស្តនោះ បានឆ្លៀតឱកាសជួយសរសេរទស្សនាវដ្តីកាំប៊ូហ្សា (Kambuja) របស់សម្តេចសីហនុ ផងដែរ។ ឯ ហ៊ូ នឹម ក៏បានធ្វើជានិពន្ធនាយករងទស្សនាវដ្តីអ្នកជាតិ

និយមរបស់សម្តេចសីហនុ តាំងពីឆ្នាំ១៩៦២ មកដែរ។

នៅក្នុងឆ្នាំ១៩៦៣ ហ៊ូ នឹម រួមជាមួយសមាជិកគណៈប្រតិភូមួយចំនួនទៀតរបស់អ្នកកាសែតកម្ពុជា បានធ្វើដំណើរទៅបំពេញទស្សនកិច្ចនៅប្រទេសចិន ប្រទេសកូរ៉េខាងជើង និងវៀតណាមខាងជើង។

នៅទីក្រុងហាណូយ ហូជី មិញ និងផាំ វ៉ាន់ដុង បានអះអាងនៅចំពោះមុខ ហ៊ូ នឹម ថា ប្រសិនបើនៅកម្ពុជាមានជួបបញ្ហាពិបាក មិនអាចនៅបាន សូមឱ្យគាត់(ហ៊ូនឹម)មករស់នៅវៀតណាមខាងជើងចុះ ពួកគេនឹងទទួលដោយរីករាយ។ ទោះបី សាឡុត ស មិនសូវមានសាធារណជនស្គាល់ប៉ុន្មានក៏ដោយ ប៉ុន្តែភ្នាក់ងារសេមត្ថកិច្ចបានតាមដានគាត់គ្រប់ជំហាន ដូច្នេះគាត់មិនអាចរស់នៅក្នុងក្រុងភ្នំពេញ បានទៀតទេ។

នៅក្នុងខែឧសភា ឆ្នាំ១៩៦៣ សាឡុត ស និងអៀង សារី បាត់ខ្លួនពីក្រុងភ្នំពេញ ទៅរស់នៅលាក់ខ្លួននៅក្នុងព្រៃមួយនៃទឹកដីខេត្តកំពង់ចាម ជាប់នឹងព្រំប្រទល់ប្រទេសវៀតណាម។ បន្ទាប់មកទៀត នៅក្នុងខែកញ្ញា ឆ្នាំ១៩៦៥ នៃ សារ៉ាន់ ហៅយ៉ា ក៏រត់ទៅចូលព្រៃតស៊ូជាមួយ សាឡុត ស និងអៀង សារី បន្តទៀត។ មួយឆ្នាំក្រោយមក សុន សេន ក៏រត់ទៅដែរ។

ក្រោយពីបាត់ខ្លួន សុន សេន និងនៃ សារ៉ាន់ មក ក៏លេចឮពាក្យចចាមអារ៉ាមថា អ្នកទាំង២នេះ ត្រូវពួក ប៉ូលិសចាប់យកទៅសម្លាប់ស្ងាត់ៗ បាត់អស់ហើយ។

ពេលនោះ សមាជិកគណៈកម្មាការមជ្ឈិមបក្ស ស្ទើរតែទាំងអស់ ត្រូវបង្ខំចិត្តនាំគ្នារត់ចូលព្រៃ ដើម្បីធ្វើការតស៊ូនៅភាគខាងកើតប្រទេស ព្រោះទីនោះមានការងាយស្រួលធ្វើទំនាក់ទំនង និងសហប្រតិបត្តិការជាមួយពួកវៀតកុង-វៀតណាមខាងជើង (អតីតពួកវៀតមិញ) ដែលជាសម្ព័ន្ធមិត្តតាំងពីទសវត្សរ៍ឆ្នាំ១៩៤០មកនោះ។

យុវជនក្មេងៗ ជាច្រើនរយនាក់ ក៏បានស្ម័គ្រចិត្តរត់ចូលព្រៃ ដើម្បីចូលរួមចំណែកក្នុងចលនាតស៊ូនោះដែរ ហើយយុវជនខ្លះ ត្រូវបានគេបញ្ចូលជាសមាជិកសម្ព័ន្ធយុវកក (**យុវកក** ជាពាក្យកាត់។ ពាក្យពេញគឺ យុវជនកុម្មុយនិស្តកម្ពុជា) យុវជនខ្លះទៀតបានក្លាយទៅជាបក្ខជន(ជនរបស់បក្ស)។

យុវជនមួយចំនួនទទួលបានការហ្វឹកហ្វឺនក្បួនយុទ្ធសាស្ត្រយោធារយៈពេលខ្លី ហើយដើម្បីពង្រឹងស្មារតីប្រយុទ្ធតស៊ូ ពួកគេត្រូវមេដឹកនាំឱ្យសាកល្បងដើរកាត់តាមផ្លូវលំដែលនៅក្បែរៗ ទីតាំងឈរជើងរបស់ទាហាន និងប៉ូលិសរបស់រាជរដ្ឋាភិបាលនៅពេលយប់ស្ងាត់ ដោយមិនឱ្យពួកទាហាន និងប៉ូលិសរបស់រាជរដ្ឋាភិបាលទាំងនោះដឹងសូម្បីបន្តិចឡើយ ហើយក៏មានការបង្ហាត់បង្រៀនឱ្យពួកគេស៊ូទ្រាំនឹងការលំបាកគ្រប់បែបយ៉ាងដើម្បីលត់ដំខ្លួនឱ្យទៅជាជនបដិវត្តផងដែរ។ នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៦៣ រដ្ឋសភាបានសម្រេចដក ហ៊ូ យន់ ចេញពីតំណែងរដ្ឋមន្ត្រីក្រសួងផែនការ ហើយ ខៀវ សំផន ត្រូវបានសមាជសង្គមរាស្ត្រនិយមដែលប្រារព្ធធ្វើឡើងនៅពាក់កណ្តាលឆ្នាំ១៩៦៣នោះ ទាមទារឱ្យចុះចេញពីតំណែងរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ដោយសារបញ្ហាសាច់គោឡើងថ្លៃ។

នៅចុងឆ្នាំ១៩៦៣ រដ្ឋសភាបានបើកសម័យប្រជុំវិសាមញ្ញ សម្រេចដកតំណែងរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ពី ខៀវ សំផន។ ប៉ុន្តែយ៉ាងណា ហ៊ូ យន់ និងខៀវ សំផន នៅតែជាតំណាងរាស្ត្រដដែល។

---

# ១៤៨
# ង៉ូ ឌិញយៀម កាន់សាសនាកាតូលិក ជាន់ឈ្លីសាសនាព្រះពុទ្ធ




ង៉ូ ឌិញយៀម និងសាសនារ៉ូម៉ាំងកាតូលិក

ដើមឆ្នាំ១៩៦៣ ប្រធានាធិបតី ង៉ូ ឌិញយៀម ជាអ្នកកាន់សាសនារ៉ូម៉ាំងកាតូលិក និងមានចរិតរើសអើងសាសនាព្រះពុទ្ធផងដែរនោះ កាន់តែបង្កើនសម្ពាធគាបសង្កត់អ្នកកាន់ព្រះពុទ្ធសាសនា ដោយឱ្យកម្លាំងសមត្ថកិច្ចអនុវត្តអនុក្រឹត្យលេខ១០ ដែលហាមឃាត់ការលើកឬបង្ហូតទង់សាសនានៅទីសាធារណៈ។ អនុក្រឹត្យលេខ១០នេះ ត្រូវបានប្រធានាធិបតី ង៉ូ ឌិញយៀម សម្រេចឱ្យអនុវត្តតាំងពីឆ្នាំ១៩៥៨ មកម្ល៉េះ តែតាំងពីពេលនោះមក ការអនុវត្តអនុក្រឹត្យនេះ មិនមានប្រសិទ្ធភាពឡើយ។

ការហាមឃាត់នេះបានធ្វើឡើងនៅថ្ងៃបុណ្យវិសាខបូជា ជាថ្ងៃកំណើតរបស់ព្រះសម្មាសម្ពុទ្ធតែម្តង ខណៈកាលពីសប្តាហ៍មុន បុព្វជិតកាតូលិកជាន់ខ្ពស់បំផុតនៅក្នុងប្រទេសវៀតណាម ឈ្មោះ ង៉ូ ឌិញធុក (Ngô Đình Thục) ជាបងប្រុសរបស់ប្រធានាធិបតី ង៉ូ ឌិញ-យៀម មានសិទ្ធិលើក និងបង្ហូតទង់សាសនាកាតូលិក នៅឯពិធីបុណ្យមួយឧបត្ថម្ភដោយរដ្ឋា-ភិបាល។ ការអនុវត្តច្បាប់មិនស្មើភាពគ្នានេះ បានបង្កឱ្យពុទ្ធសាសនិកជនមានការ ខឹងសម្បាយ៉ាងខ្លាំងនៅថ្ងៃរៀបចំបុណ្យវិសាខបូជាដែលជាបុណ្យសំខាន់បំផុតសម្រាប់ព្រះពុទ្ធសាសនា។

ថ្ងៃទី៨ ខែឧសភា ឆ្នាំ១៩៦៣ កម្មវិធីបុណ្យវិសាខបូជាដែលបានគ្រោងទុក គឺពេលព្រលប់ ព្រះតេជគុណ ធិច ទីញខៀត ( thích tịnh khiết ) ប្រធានសមាគមសហពុទ្ធបរិស័ទវៀតណាម ត្រូវនិមន្តទៅថ្លែងអនុមោទនាកថានៅស្ថានីយវិទ្យុក្រុងវ៉េ ដើម្បីផ្សព្វផ្សាយដល់ពុទ្ធបរិស័ទទាំងអស់ នៅវៀតណាមខាងត្បូង ឱ្យយល់ដឹងពីខ្លឹមសារនៃបុណ្យវិសាខបូជា។ នៅវេលាម៉ោង១០ព្រឹក កម្មវិធីបុណ្យវិសាខបូជានៅក្រុងវ៉េ( Huế ) ដែលពុទ្ធសាសនិកប្រមាណ ១០,០០០នាក់ ចូលរួមនោះ បាននាំគ្នាស្រែកតវ៉ាពីបញ្ហាហាមលើកទង់ពុទ្ធសាសនានេះ។

ព្រះភិក្ខុមួយអង្គ បានសម្តែងអនុមោទនាកថាទៅកាន់ពុទ្ធបរិស័ទក្នុងពិធីថា ការតវ៉ារបស់ព្រះសង្ឃ និងពុទ្ធបរិស័ទយើងទាំងអស់គ្នាពីបញ្ហានេះ មិនមែនដើម្បីប្រឆាំងនឹងរដ្ឋាភិបាលទេ ប៉ុន្តែក៏ពួកយើងមិនអាចស៊ូទ្រាំបានចំពោះសម្មភាពគាបសង្កត់បំបាត់សេរីភាពមកលើពុទ្ធសាសនាតទៅទៀត។ ព្រះអង្គបានសូមឲ្យរដ្ឋាភិបាល ផ្តល់សេរីភាពបរិបូណ៌មកឱ្យខាងពុទ្ធសាសនា ដូចសាសនាផ្សេងៗដែរ។ បន្ទាប់មក ព្រះភិក្ខុមួយអង្គទៀត ក៏បានស្រែកតវ៉ាចំពោះការគាបសង្កត់បំបាត់សេរីភាពមកលើពុទ្ធសាសនារបស់រដ្ឋការ ង៉ូ ឌិញយៀម ដោយស្រែកជាពាក្យស្លោកថា៖ "ជយោ! សេរីភាពខាងសាសនា, អ្នកប្រឆាំងពុទ្ធសាសនា នឹងត្រូវតែវិនាស, ព្រះពុទ្ធសាសនា នឹងឋិតនៅជានិរន្តរ៍"។

ក្រោយពីមានហេតុការណ៍នេះ រដ្ឋការង៉ូ ឌិញយៀម ក៏បានបញ្ជាឲ្យលុបកម្មវិធីដែលព្រះតេជគុណ ធិច ទីញខៀត ( thích tịnh khiết ) ប្រមុខសង្ឃពុទ្ធសាសានាមហាយានវៀតណាម ត្រូវនិមន្តមកថ្លែងអនុមោទនាកថានៅស្ថានីយវិទ្យុក្រុងវ៉េ នៅពេលព្រលប់ នោះចោលវិញ ហើយយកកម្មវិធីសាសនាផ្សេងជំនួសវិញ ។

ក្រោយពីទទួលដំណឹងនេះភ្លាម នៅវេលាល្ងាច មានប្រជាជនជាពុទ្ធបរិស័ទប្រមាណ ៣,០០០នាក់ បានមកដើរហែក្បួនមកជួបជុំគ្នា ដើម្បីប្រឆាំងតវ៉ាដោយសន្តិវិធីនៅមុខស្ថានីយវិទ្យុក្រុងវ៉េ។ លុះដល់វេលាម៉ោង១០យប់ រដ្ឋការ ង៉ូ ឌិញយៀម បានបញ្ជាឱ្យកងប៉ូលិស និងកងទ័ពមានរថពាសដែកផង មកបង្ក្រាបប្រជាជនជាពុទ្ធបរិស័ទយ៉ាងសាហាវឃោរឃៅព្រៃផ្សៃបំផុត បណ្តាលឱ្យមានមនុស្សស្លាប់៩នាក់ ក្នុងចំនួននោះមានកុមារ៦នាក់។ ក្នុងការ

## របត់នយោបាយ

បង្ក្រាបដ៏សាហាវឃោរឃៅព្រៃផ្សៃនេះ មានវេជ្ជបណ្ឌិតអាល្លឺម៉ង់ម្នាក់ឈ្មោះវ៉ុលក៍ និងគ្រូពេទ្យអាល្លឺម៉ង់ម្នាក់ទៀត ថតបានរូបភាពអ្នកស្លាប់ទាំង៩នាក់ ដោយសារគ្រាប់កាំភ្លើងខ្លះ និងដោយសាររថក្រោះកៀរខ្លះ ទុកភ័ស្តុតាងផងដែរ។

ក្រោយហេតុការណ៍បង្ក្រាបនោះមួយសប្តាហ៍ នៅថ្ងៃទី១៥ ខែឧសភា មេដឹកនាំដោយព្រះតេជគុណធិច ទ្រីក្វាង ( Thích Trí Quang )តំណាងព្រះសង្ឃ និងពុទ្ធបរិស័ទជាអ្នកតវ៉ាបានធ្វើសំណូមពរទៅប្រធានាធិបតី ង៉ូ ឌិនយៀម ៥ចំណុចគឺ៖

១.សូមឲ្យដកចេញបទបញ្ជារបស់ប្រធានាធិបតី ដែលហាមមិនឲ្យបង្ហូតទង់ និងដំឡើងទង់ជានិមិត្តសញ្ញារបស់ព្រះពុទ្ធសាសនា។

២.សូមឲ្យពុទ្ធសាសនិក និងកាតូលិកសាសនិក មានភាពស្មើគ្នាចំពោះមុខច្បាប់។

៣. សូមឲ្យឈប់ចាប់ចងពុទ្ធសាសនិកតាមអំពើចិត្តបន្តទៀត។

៤.សូមឲ្យមានសេរីភាពក្នុងការគោរពបដិបត្តិ និងផ្សព្វផ្សាយធម៌ព្រះពុទ្ធ ដូចសាសនាផ្សេងៗទៀតដែរ។

៥.សូមឲ្យសងជំងឺចិត្តចំពោះគ្រួសារពុទ្ធសាសនិកដែលបានបាត់បង់ជីវិតក្នុងការបង្ក្រាបក្នុងថ្ងៃទី ៨ឧសភានោះ និងសូមឲ្យយកពួកកងទ័ពជាអ្នកដៃដល់ក្នុងការបាញ់សម្លាប់អ្នកតវ៉ាទាំង៩នាក់នោះ យកទៅកាត់ទោស តាមច្បាប់។

តែប្រធានាធិបតីង៉ូ ឌិញយៀម បានបដិសេធ និងមិនទទួលខុសត្រូវចំពោះឧប្បត្តិហេតុបណ្តាលឱ្យស្លាប់អ្នកតវ៉ាទាំង៩នាក់ ដូចការចោទប្រកាន់នោះទេ។ ផ្ទុយទៅវិញ គាត់បានទម្លាក់កំហុសទៅលើពួកវៀតកុងទៅវិញ។ ង្វៀង ឌិញធួន( Nguyễn Đình Thuận ) រដ្ឋមន្ត្រីក្រសួងសន្តិសុខរបស់ង៉ូ ឌិញយៀម បានថ្លែងបំផ្លើសថា ពួកវៀតកុង បានបន្លំចូលទៅបោកគ្រាប់បែកទៅលើហ្វូងបាតុករបណ្តាលឱ្យស្លាប់៩នាក់នោះ ហើយបានប្រកាសថាប្រធានាធិបតីង៉ូ ឌិញយៀម មិនអាចធ្វើសម្បទានឱ្យមានការតវ៉ាបន្តទៀតទេ។ កាសែតវៀតណាមប្រេស្ស ( Vietnam Press ) ដែលជាកាសែតគាំទ្ររដ្ឋាភិបាលង៉ូ ឌិញយៀម បានចុះផ្សាយបទអត្ថាធិប្បាយថា អត្ថិភាពនៃសេរីភាពសាសនាមិនមែនរឿងលើកទង់សាសនាជារឿងសំខាន់ទេ

គឺការលើកទង់ជាតិរបស់ប្រទេសជារឿងចាំបាច់។

ក្នុងកិច្ចប្រជុំមួយជាមួយមន្ត្រីរបស់គាត់ ង៉ូ ឌិញយៀម បានចាត់ទុកថា ពួកពុទ្ធសាសនិក ជាមនុស្សល្ងង់ ព្រោះមុននឹងពួកគេទាមទាររឿងអ្វីមួយ ពួកគេមិនបានគិតថារឿងនោះគាត់មិនចូលចិត្តរួចហើយ។ តែយ៉ាងណា នៅថ្ងៃទី១៨ ខែឧសភា ប្រធានាធិបតីង៉ូ ឌិញយៀម បានយល់ព្រមសងសំណងសរុបចំនួន៧០០០ដុល្លារអាមេរិក សម្រាប់គ្រួសារជនរងគ្រោះដោយការបាញ់ប្រហារនៅក្រុងវ៉េ ក្នុងថ្ងៃទី ៨ឧសភានោះ ។

ជាមួយគ្នានោះ ប្រធានាធិបតី ង៉ូ ឌិញយៀម បានប្រកាសដកតំណែងអភិបាលខេត្ត អភិបាលខេត្តរង និងប្រតិភូរដ្ឋាភិបាលប្រចាំភូមិភាគកណ្តាលនៃប្រទេសវៀតណាម ផងដែរ។ តែការដកតំណែងនេះមិនមែនដោយសារជាប់ពាក់ព័ន្ធក្នុងបាញ់សម្លាប់អ្នកតវ៉ា៩នាក់នៅក្រុងវ៉េនោះទេ គឺមូលហេតុដោយសារពួកគេមិនបានរក្សាសន្តិសុខសណ្តាប់ធ្នាប់ឱ្យបានល្អ បណ្តាលឱ្យពួកវៀតកុងឆ្លៀតឱកាសបន្លំចូលមកគប់គ្រាប់បែកក្នុងហ្វូងអ្នកតវ៉ាបណ្តាលឱ្យស្លាប់អស់៩នាក់នោះទៅវិញ។

អំឡុងពេលនោះដែរ ប្រធានាធិបតីង៉ូ ឌិញយៀម បានទៅចូលរួមជាអធិបតីក្នុងពិធីសម្ពោធវត្តរបស់ពុទ្ធសាសនាចម្លែកមួយ ក្នុងទីរដ្ឋធានីសៃហ្គន នោះដែរ គឺព្រះសង្ឃក្នុងពុទ្ធសាសនានិកាយចម្លែកនេះអាចរៀបការមានគ្រួសារប្រពន្ធកូនបានដូចគ្រហស្ថដែរ។ ដូច្នេះហើយ បានជាព្រះតេជគុណធិច ទីញខៀត (Thích Tịnh Khiết) ប្រធានសមាគមសហពុទ្ធបរិស័ទវៀតណាម មិនទទួលស្គាល់ពុទ្ធសាសនាចម្លែកនេះទេ។

មិនតែប៉ុណ្ណោះ ង៉ូ ឌិញយៀម មានបំណងដកព្រះតេជគុណធិច ទីញខៀត (Thích Tịnh Khiết) មិនឱ្យធ្វើជាតំណាងពុទ្ធសាសនិកវៀតណាម ហើយលើកបន្តុបមេដឹកនាំពុទ្ធសាសនានិកាយចម្លែកនោះ ឱ្យធ្វើជាតំណាងទៅចូលរួមប្រជុំនៅក្នុងអង្គការពុទ្ធសាសនិកសម្ព័ន្ធពិភពលោកជំនួសវិញ។ ផែនការនេះជាយុទ្ធវិធីរបស់ង៉ូ ឌិញយៀម ក្នុងគោលដៅធ្វើឲ្យពុទ្ធសាសនិកវៀតណាម មានជម្លោះបែកបាក់ផ្ទៃក្នុង និងលែងគោរពពុទ្ធសាសនាទៀត។

# ១៤៩
# ព្រះសង្ឃស្រោចប្រេងសាំងបូជាកាយ ដើម្បីសេរីភាពពុទ្ធសាសនា



**ព្រះសង្ឃធិច ក្វាងឌឹក ស្រោចប្រេងសាំងបូជាកាយ**

នៅថ្ងៃទី៣០ខែឧសភា ព្រះសង្ឃ និងដូនជី ប្រមាណ៥០០អង្គ/ រូប បាននាំធ្វើកូដកម្មដោយអត់អាហារនៅមុខអគាររដ្ឋសភាក្នុងរដ្ឋធានីសៃហ្គន។ នេះជាលើកទីមួយហើយដែលការតវ៉ាប្រឆាំងនឹងប្រធានាធិបតី ង៉ូ ឌិញយៀម ដែលដឹកនាំប្រទេសវៀតណាមខាងត្បូងអស់រយៈពេល៨ឆ្នាំមកហើយនោះ ត្រូវបានធ្វើជាសាធារណៈនៅចំកណ្ដាលរដ្ឋធានីមួយនេះ។ ក្រុមបាតុករដឹកនាំដោយបុព្វបុរសពុទ្ធសាសនា ធិច ទីញខៀត (Thích Tịnh Khiết) នាំគ្នាលើកបដា និងអង្គុយសមាធិ៤ម៉ោង រួចប្រកាសឱ្យពុទ្ធសាសនិកទូទាំងប្រទេសធ្វើកូដកម្មអត់អាហាររយៈពេល៤៨ម៉ោង។

នៅថ្ងៃទី៣ ខែមិថុនា នៅក្នុងរដ្ឋធានីសៃហ្គន និងទីក្រុងផ្សេងៗទៀត ពុទ្ធសាសនិក



**ព្រះសង្ឃខ្មែរ និងវៀតណាមធ្វើកូដកម្ម**

នាំគ្នាងើបឡើងបះបោរយ៉ាងគគ្រឹកគគ្រេង។ សភាពការណ៍កាន់តែធ្ងន់ធ្ងរទៅៗ នៅខាងក្រៅវត្តទឺដាម(Từ Đàm) ក្នុងក្រុងវ៉េ កម្លាំងប៉ូលិស និងកងទ័ពរដ្ឋការង៉ូ ឌិញយៀម បានធ្វើការបង្ក្រាបដោយបាញ់សារធាតុគីមីទៅលើពុទ្ធសាសនិកជាអ្នកតវ៉ា បណ្តាលឱ្យមនុស្ស ៦៧នាក់ត្រូវបញ្ជូនទៅមន្ទីរពេទ្យ ហើយបាតុករ៣៨នាក់ទៀតត្រូវចាប់ខ្លួន។

ដោយសារ សហរដ្ឋអាមេរិក គំរាមដកជំនួយព្រោះតែបញ្ហាប្រើសារធាតុគីមីបង្ក្រាបពុទ្ធសាសនិកជាអ្នកតវ៉ានេះ នៅថ្ងៃទី៥ ខែមិថុនា ប្រធានាធិបតី ង៉ូ ឌិញយៀម ក៏យល់ព្រមបើកការចរចាជាផ្លូវការ ហើយគាត់បានតែងតាំងគណៈកម្មាធិការមួយដែលមានអនុប្រធានាធិបតី ង្វៀន ង៉ុកបឺ ជាប្រធាន ឱ្យទៅចូលរួមចរចាជាលើកដំបូងជាមួយមេដឹកនាំពុទ្ធសាសនិកស្តីពីការប្រឈមមុខដាក់គ្នារវាងក្រុមអ្នកតវ៉ាជាមួយកម្លាំងប៉ូលិស និងកងទ័ពនៅក្នុងទីក្រុងវ៉េ ។

មេដឹកនាំព្រះពុទ្ធសាសនាបញ្ជាក់នៅក្នុងអង្គប្រជុំថា ប្រសិនបើសេរីភាព និងសមភាពរបស់សាសនាទាំងអស់ ត្រូវបានអនុវត្តដោយស្មើភាពគ្នានោះ ខាងពុទ្ធសាសនិក ក៏បញ្ឈប់ការតវ៉ារបស់ខ្លួនដែរ។ តែការចចារនេះមិនបានទទួលលទ្ធផលអ្វីផង ស្រាប់តែប្រធានាធិបតីង៉ូ ឌិញយៀម ប្រកាសហាមធ្វើបាតុកម្ម ហាមចេញពីផ្ទះ និងបញ្ជូនកងទ័ពយ៉ាងច្រើនចូល



**ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ហ្វ្រីដរិក នុលទីង**
**ជាមិត្តជិតស្និទ្ធង៉ូ ឌិញយៀម**

ទៅក្នុងក្រុងវ៉េ ឡោមព័ទ្ធវត្តទីដាម ជាវត្តធំ និងសំខាន់ជាងគេនៅក្រុងនោះ ហើយវាយលួសបន្លាព័ទ្ធជុំវិញ ផ្តាច់ទឹក ផ្តាច់ភ្លើង និងត្រួតពិនិត្យមនុស្សចេញចូល ព្រមទាំងបិទពាក្យផ្លាកថា ពួកវៀតកុង ជាអ្នកបង្កអំពើចលាចលក្នុងក្រុងវ៉េ នោះទៀតផង។

បន្ទាប់មក រដ្ឋការ ង៉ូ ឌិញយៀម បានចែកខិត្តប័ណ្ណថ្កោលទោសព្រះតេជគុណនាយកសមាគមពុទ្ធសាសនិកនៅវៀតណាមភាគកណ្តាល ដោយចោទប្រកាន់ថា ព្រះអង្គប្រើឧបាយកលបោកប្រាស់ប្រកូកប្រកាសប្រាប់ប្រជាពុទ្ធបរិស័ទថា ឱ្យនាំគ្នាមកធ្វើបុណ្យសូត្រមន្តតែព្រះអង្គបែរជាដឹកនាំពុទ្ធបរិស័ទទាំងអស់នោះឱ្យដើរដង្ហែក្បួនធ្វើបាតុកម្មទៅវិញ។

លុះមកដល់ថ្ងៃទី៨ ខែមិថុនា ម៉ាដាមញូ(អ្នកស្រីញូ)ជាប្រពន្ធរបស់ ង៉ូ ឌិញញូ និងជាប្អូនថ្លៃរបស់ប្រធានាធិបតី ង៉ូ ឌិញយៀម ក៏បានចាប់ផ្តើមចេញមុខថ្លែងការណ៍ថ្កោលទោសពុទ្ធសាសនិកថា ជាពួកទុទិដ្ឋិនិយម ជាពួកសម្ងំសុខ មិនខ្វល់ខ្វាយប្រឆាំងនឹងពួកកុម្មុយនិស្តជាសត្រូវរបស់ប្រទេសជាតិទេ បែរជានាំគ្នាធ្វើឧបករណ៍នយោបាយឱ្យពួកកុម្មុយនិស្តវៀតកុងទៅ វិញ។

ពេលនោះ មន្ត្រីស្ថានទូតសហរដ្ឋអាមេរិក រដ្ឋធានីសៃហ្គន បានព្យាយាមបញ្ចុះបញ្ចូល

ឲ្យប្រធានាធិបតីង៉ូ ឌិញយៀម រិះរកមធ្យោយសម្របសម្រួលជាមួយពុទ្ធសាសនិកដោយសន្តិវិធីផង និងបានព្រមានថា ប្រសិនបើរដ្ឋាភិបាលមិនបញ្ឈប់ការធ្វើទុក្ខបុកម្នេញទៅលើអ្នកកាន់ពុទ្ធសាសនាទេ សហរដ្ឋអាមេរិក ចាំបាច់ត្រូវតែប្រកាសឲ្យប្រជាពលរដ្ឋវៀតណាមដឹងថា សហរដ្ឋអាមេរិក មិនយល់ស្របជាមួយនយោបាយរដ្ឋាភិបាលគាត់ដែរ។ ប៉ុន្តែ ប្រធានាធិបតី ង៉ូ ឌិញយៀម នៅតែមានះចចេស ចង់យកឈ្នះដដែល។

ថ្ងៃទី៨ ខែមិថុនា នោះដែរ ង៉ូ ឌិញយៀម បានទទួលដំណឹងជាមុនថា នឹងមានព្រះសង្ឃពុទ្ធសាសនាមួយអង្គដុតព្រះកាយនៅទីសាធារណៈ ដើម្បីទាមទារឱ្យមានសេរីភាព និងសមភាព ក្នុងការប្រតិបត្តិពុទ្ធសាសនា និងសាសនាផ្សេងៗទៀត ពិសេសគ្រិស្តសាសនា។ ប៉ុន្តែ ង៉ូ ឌិញយៀម យល់ថា នេះគ្រាន់តែជាការគំរាមរបស់ព្រះសង្ឃពុទ្ធសាសនាប៉ុណ្ណោះ។

លុះមកដល់ព្រឹកថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៦៣ នៅក្នុងទីក្រុងសៃហ្គន មានព្រះសង្ឃនិងដូនជីប្រមាណ១០០០អង្គ/រូប បានប្រារព្ធពិធីសូត្រមន្តបង្សុកូលឧទ្ទិសកុសលដល់អ្នកដែលបាត់បង់ជីវិតក្នុងថ្ងៃបុណ្យវិសាខបូជាកាលពីថ្ងៃ៨ខែឧសភានោះ។ បន្ទាប់មក ក៏បាននាំគ្នាហែក្បួនទៅឈប់នៅមុខស្ថានទូតព្រះរាជណាចក្រកម្ពុជា ហើយព្រះសង្ឃមួយអង្គព្រះនាម ធិច ក្វាងឌឹក (Thích Quảng Đức) បានរៀបចំពិធីស្រោចប្រេងសាំងដុតខ្លួនឯងដើម្បីសម្តែងការទាមទារឱ្យមានសេរីភាព និងសមភាពក្នុងការប្រតិបត្តិសាសនា ដូចដែលប្រធានាធិបតី ង៉ូ ឌិញយៀម បានទទួលដំណឹងកាលពី៣ថ្ងៃមុននោះមែន។

ព្រះតេជគុណបានសរសេរលិខិតបណ្តាំមួយថា ព្រះតេជគុណបូជាព្រះកាយដើម្បីព្រះពុទ្ធសាសនា និងដាក់សម្ពាធទៅលើប្រធានាធិបតី ង៉ូ ឌិញយៀម ឱ្យមានការអត់ឱនមកលើព្រះពុទ្ធសាសនា ។

នៅកណ្តាលផ្លូវបំបែកជាបួននោះ ព្រះតេជគុណ ធិច ក្វាងឌឹក (Thích Quảng Đức) បានចុះពីលើរថយន្តដោយមានការអមដំណើរព្រះសង្ឃពីរអង្គទៀត។ ព្រះសង្ឃមួយអង្គបានរៀបចំដាក់កម្រាលខ្នើយមួយជាទ្រនាប់នៅលើទ្រូងផ្លូវ ដើម្បីឲ្យព្រះតេជគុណគង់ពែនភ្នែន ហើយព្រះសង្ឃមួយអង្គទៀតបានយកសាំងមួយប៊ីដុងជ័រ ចាក់ស្រោចលើស្បង់ចីវរ។




ព្រះសង្ឃខ្មែរចូលរួមធ្វើបាតុកម្ម នោះដែរ

ក្រោយពីព្រះតេជគុណចាប់ផ្តើមធ្វើសមាធិដើម្បីរំងាប់ចិត្តមួយស្របក់មក ព្រះសង្ឃមួយអង្គទៀតបានយកឈើគូសមកគូសហើយឈួលក្បែរនោះ បណ្តាលឱ្យអណ្តាតភ្លើងឆាបឆេះនៅលើព្រះកាយរបស់ព្រះតេជគុណមួយរំពេច។ ពេលនោះមានព្រះសង្ឃខ្លះបានស្រែកតវ៉ា និងព្រះសង្ឃខ្លះទៀតបាននាំគ្នាលុតជង្គង់ថ្វាយបង្គំស្រែកទ្រហោយំនៅជុំវិញអណ្តាតភ្លើងកំពុងឆាបឆេះព្រះកាយព្រះតេជគុណយ៉ាងសន្ធោសន្ធៅនោះ។ បន្ទាប់ពីភ្លើងឆាបឆេះអស់រយៈពេលប្រហែល១០នាទីមក ព្រះកាយព្រះតេជគុណបានរលំដួលសុគតមកលើកម្រាលថ្នល់។

ព្រះសពរបស់ព្រះអង្គត្រូវបានព្រះសង្ឃ និងពុទ្ធសាសនិកដង្ហែយកទៅតម្កល់ធ្វើបុណ្យនៅវត្តសាឡឿយ (Xá Lợi) នៅក្នុងក្រុងសៃហ្គននោះ។ ពេលនោះដែរ នៅតាមបណ្តាវត្តផ្សេងៗទៀតនៅទូទាំងប្រទេស ក៏បានបង្ហូតទង់សាសនាចុះមកត្រឹមពាក់កណ្តាលដង ជាការសម្តែងនូវការកាន់ទុក្ខ និងគោរពដល់វិញ្ញាណក្ខន្ធរបស់ព្រះតេជគុណ។ ដោយឡែក ខាងរដ្ឋាភិបាល ក៏បានបញ្ជូនកម្លាំងប៉ូលិស និងទាហាន មកហ៊ុមព័ទ្ធវត្តសាឡឿយ (Xá Lợi) នោះទៀតផង។

ព្រះតេជគុណធិច ក្វាងឌឹក(Thích Quảng Đức)កើតនៅក្នុងឆ្នាំ១៨៩៧ នៅភូមិហូយ ខាញ់ (Hội Khánh )ស្រុកវ៉ាន់ នីញ ខេត្តខាញ់ ហ័រ(Khánh Hòa) នៅអណ្តាមភាគកណ្តាលប្រទេសវៀតណាម។ ព្រះតេជគុណមានឈ្មោះកំណើតថា ឡឹម វ៉ាន់ទុក (Lâm Văn Túc) មានបងប្អូន៧នាក់។ ពេលមានវ័យ៧វស្សា ព្រះតេជគុណបានចាកចេញពីម្តាយឪពុកទៅស្នាក់នៅជាមួយព្រះសង្ឃមួយអង្គព្រះនាមធិច ហ័ងថឹម (Thích Hoằng Thâm) ដែលត្រូវជាឪពុកមានៅក្នុងវត្ត ដើម្បីសិក្សាធម៌ព្រះពុទ្ធសាសនា។ លុះដល់អាយុ១៥ឆ្នាំ បានបួសជាសាមណេរ រហូតដល់ព្រះជន្ម២០វស្សា បានក្លាយជាភិក្ខុ និងបានដូរព្រះនាមថា ធិច ក្វាងឌឹក វិញ។

នៅឆ្នាំ១៩៣២ ព្រះតេជគុណត្រូវបានតែងតាំងជាអធិការនៃសមាគមពុទ្ធសាសនា និងជាអធិការសង្ឃនៅក្នុងខេត្តខាញ់ហ័រ (Khánh Hòa) ព្រមទាំងទទួលខុសត្រូវលើការ



**ព្រះសង្ឃធិច ក្វាងឌឹក**

សាងសង់ ព្រះវិហារចំនួន១៤នៅវៀតណាម ភាគកណ្ដាលផងដែរ។ នៅឆ្នាំ១៩៣៤ ព្រះអង្គបានផ្លាស់ ទៅនៅទឹកដីកម្ពុជាក្រោម ហើយបានបង្រៀនចំណេះដឹងខាងព្រះពុទ្ធសាសនាតាមបណ្ដាខេត្តនានា ជាបន្តបន្ទាប់។ ព្រះតេជគុណក៏បានចំណាយពេលពីរឆ្នាំ មកគង់នៅក្នុងប្រទេសកម្ពុជា ដើម្បីសិក្សាអំពីព្រះពុទ្ធសាសនាថេរវាទ ផងដែរ។

ក្រោយពេលត្រលប់ពីកម្ពុជា ទៅទឹកដីកម្ពុជាក្រោម វិញ ព្រះអង្គត្រូវបានតែងតាំងឲ្យមើលការខុសត្រូវលើការសាងសង់ព្រះវិហារថ្មី ចំនួន១៧ទៀត។ ព្រះតេជគុណត្រូវបានតែងតាំងជាប្រធានគណៈកម្មាធិការប្រជុំសង្ឃវៀតណាម នៅវត្តភុក ហ័រ (Phuoc Hoa) ដែលជាទីតាំងស្នាក់ការដំបូងរបស់សមាគមសម្រាប់ការសិក្សាព្រះពុទ្ធសាសនាវៀតណាម (ABSV)។ ប៉ុន្តែ ក្រោយពីស្នាក់ការសមាគម(ABSV)នេះ ត្រូវផ្លាស់ប្ដូរទីតាំងទៅវត្តសាឡឺយ (Xá Lợi) ដែលជាវត្តធំ និងសំខាន់ជាងគេនៅរដ្ឋធានីសៃហ្គន។ ភិក្ខុ ធិច ក្វាងឌឹក ក៏បានលាលែងពីតំណែង ក្នុងឆ្នាំ ១៩៧៥។ ផ្លូវដែលនៅមុខវត្តនោះ ត្រូវបានប្ដូរឈ្មោះជាផ្លូវ ក្វាងឌឹក (Quang Đức)វិញ។

# ១៥០
# ប្រពន្ធង៉ូ ឌិញញូ និយាយបញ្ឈឺថា ៖ បើសង្ឃណាចង់ដុតខ្លួនទៀត គាត់នឹងជួយផ្ដល់ប្រេងសាំង



**អ្នកស្រីញូ ប្រពន្ធ ង៉ូ ឌិញញូ**

ក្រោយដុតព្រឹត្តិការណ៍ស្រោចប្រេងសាំងដុតបូជាព្រះកាយដើម្បីសេរីភាពពុទ្ធសាសនានេះមក អ្នកស្រីញូ ឈ្មោះដើមត្រាន់ ឡេ ស៊ន់ (Tran Le Xuân) ជាប្រពន្ធ ង៉ូ ឌិញញូ និងជាប្អូនថ្លៃរបស់ប្រធានាធិបតីង៉ូ ឌិញយៀម បាននិយាយបញ្ឈឺថា សូមទះដៃអបអរសាទរចំពោះការបង្ហាញឆាកឈុតដុតសាច់បាប៊ីឃ្យូ (BBQ show)នេះ។ ស្រីកំណាចនេះ បានបន្តទៀតថា បើព្រះសង្ឃពុទ្ធសាសនាណាចង់ដុតខ្លួនទៀត គាត់នឹងជួយផ្ដល់ប្រេងសាំងជូន...។ តែឯកអគ្គរដ្ឋទូតស្ដីទីរបស់សហរដ្ឋអាមេរិក ប្រចាំសាធារណរដ្ឋវៀតណាមខាងត្បូង វីល្លៀម ទ្រូហាត(William Trueheart)បានព្រមានថា ប្រសិនបើគ្មានការធ្វើសម្បទានណាមួយដល់អ្នកតវ៉ាជាពុទ្ធសាសនិកទេនោះ សហរដ្ឋអាមេរិក នឹងលែងគាំទ្ររបបគ្រប់គ្រង

របស់ប្រធានាធិបតី ង៉ូ ឌិញយៀម ទៀតហើយ ។

ប្រធានាធិបតី ង៉ូ ឌិញយៀម មិនត្រឹមតែជាមេដឹកនាំផ្តាច់ការ ជិះជាន់ សង្កត់សង្កិនប្រជាពលរដ្ឋខ្លួនឯង ព្រមទាំងប្រព្រឹត្តអំពើពុករលួយ និងគ្រួសារនិយមបក្ខពួកនិយមប៉ុណ្ណោះទេ គឺអំណាចដឹកនាំប្រទេសមួយចំណែកធំគាត់ បានប្រគល់ឲ្យ ង៉ូ ឌិញញូ ជាប្អូនប្រុសរបស់គាត់ដែលមានតួនាទីជាទីប្រឹក្សារបស់គាត់។ ពិសេសជាងនេះទៅទៀត គឺប្រពន្ធ ង៉ូ ឌិញញូ ដែលភាគច្រើនគេហៅគាត់ថា ម៉ាដាមញូ(អ្នកស្រីញូ)នោះ ជាអ្នកចាត់ចែងក្នុងការតែងតាំង មុខតំណែងមន្ត្រីគ្រប់លំដាប់ថ្នាក់ក្នុងជួររដ្ឋាភិបាលទៀតផង។

បើតាមប្រភពពីកាសែតបរទេស បានឱ្យដឹងថា មន្ត្រីរដ្ឋាភិបាលទាំងឡាយដែលចង់ផ្លាស់ប្តូរតំណែងទៅកន្លែងខ្លាញ់ធ្លាញ់មាត់ តំណែងរដ្ឋមន្ត្រី, ចៅហ្វាយស្រុក, ចៅហ្វាយខេត្ត និងនៅតាមក្រសួងសំខាន់ៗ ឱ្យចេះតែសូកប៉ាន់អ្នកស្រីញូនេះ ពិតជាបានសម្រេច ដូចបំណងប្រាថ្នាជាមិនខាន។

ទន្ទឹមនឹងនោះប្រធានាធិបតី ង៉ូ ឌិញយៀម ក៏បានតែងតាំងបងប្អូនក្រុមគ្រួសារ និងបក្ខពួកខ្លួន ឱ្យកាន់តំណែងខ្ពស់ៗ និងសំខាន់ៗផ្សេងៗផងដែរ។

ការប្រព្រឹត្តទង្វើបែបនេះ ធ្វើឱ្យសហរដ្ឋអាមេរិក ដែលជាម្ចាស់ជំនួយ និងជាអ្នកមានបំណងចង់ឱ្យរបបសាធារណរដ្ឋវៀតណាមខាងត្បូង មានលទ្ធិប្រជាធិបតេយ្យពិតប្រាកដនោះ មានការខកចិត្តយ៉ាងខ្លាំង។ ប៉ុន្តែក៏មានមន្ត្រីយោធា និងស៊ីវិលភាគច្រើនក្នុងរបបនេះមិនពេញចិត្តចំពោះទង្វើរបស់ ង៉ូ ឌិញ យៀម នេះដែរ។

នៅថ្ងៃទី១២ មិថុនា រដ្ឋសភានៃសាធារណរដ្ឋវៀតណាមខាងត្បូង បានប្រកាសបង្កើតគណៈកម្មាធិការអន្តរក្រសួងមួយ ដើម្បីដោះស្រាយបញ្ហាតវ៉ារបស់ព្រះសង្ឃ និងពុទ្ធបរិស័ទ។ ២ថ្ងៃក្រោយមក នៅថ្ងៃទី ១៤ ខែមិថុនា គណៈកម្មាធិការនោះបានជួបចរចាជាមួយតំណាងពួកអ្នកតវ៉ាជាពុទ្ធសាសនិក។ ក្នុងពេលការចរចា ព្រះតេជគុណ ធិច ទីញខៀត ( Thích Tịnh Khiết ) តំណាងពួកអ្នកតវ៉ា បានចេញសេចក្តីប្រកាសអង្វរឱ្យពុទ្ធសាសនិកទូទាំងប្រទេសមេត្តាកុំនាំគ្នាធ្វើសកម្មភាពណាមួយដែលអាចបង្កឲ្យបញ្ហាដល់កិច្ចចរចានោះ។ ចំណែក

ប្រធានាធិបតី ង៉ូ ឌិញយៀម ក៏បានបញ្ជាឱ្យកងកម្លាំងប៉ូលិស និងកងទ័ពរុះរើរបាំងដែលហ៊ុមព័ទ្ធជុំវិញវត្តចេញទាំងអស់ដែរ។ ជាមួយគ្នានោះ គណៈកម្មាធិការអន្តរក្រសួងបាននិយាយបញ្ចុះបញ្ចូលឱ្យប្រធានាធិបតី ង៉ូ ឌិញយៀម ធ្វើកែសម្រួលអនុក្រឹត្យលេខ១០នោះជាបន្ទាន់ផងដែរ។

អាមេរិក វីល្លៀម ទ្រូហាត(William Trueheart) គិតថា ប្រសិន បើប្រធានាធិបតី ង៉ូ ឌិញយៀម មិនធ្វើតាមកិច្ចព្រមព្រៀងនោះទេ សហរដ្ឋអាមេរិក គួរតែជ្រើសរើសរកមេដឹកនាំថ្មីមកជំនួស។

នៅថ្ងៃទី១៤ ខែមិថុនា កាសែតញូវយ៉កថាមស៍ (The New York Times) បានចេញ ផ្សាយនៅទំព័រមុខ ស្តីពីព័ត៌មានបែកធ្លាយរបស់រដ្ឋាភិបាលអាមេរិកថា ឧត្តមសេនីយ ប៉ូល ហាគិន (Paul Harkins) ជាប្រធានបេសកកម្មទីប្រឹក្សាសហរដ្ឋអាមេរិក នៅវៀតណាមខាងត្បូង បានបញ្ជាទៅសហការីនៅក្រោមឱវាទរបស់គាត់ទាំងអស់ កុំឱ្យជាប់ពាក់ព័ន្ធជាមួយអង្គភាពកងកម្លាំងប៉ូលិស និងកងទ័ពវៀតណាមខាងត្បូង ដែលកំពុងធ្វើសកម្មភាពបង្រ្កាបពួកអ្នកតវ៉ាជាពុទ្ធសាសនិក យ៉ាងសាហាវឃោរឃៅនោះឱ្យសោះ។

ពេលនោះ សហរដ្ឋអាមេរិក បានពិចារណាក្នុងការគាំទ្រអនុប្រធានាធិបតីង្វៀង ង៉ុកថឺឱ្យឡើងជាប្រធានាធិបតីជំនួស ង៉ូ ឌិញយៀម ផងដែរ គឺដំណាលគ្នានឹងការលេចឮពាក្យចចាមអារ៉ាមថា ឧត្តមសេនីយ ប៉ូល ហាគិន( Paul Harkins ) បានចាប់ផ្តើមស្ទាបស្ទង់ការគាំទ្រក្នុងចំណោមសហការីរបស់គាត់ ដើម្បីឱ្យវរសេនីយ៍ទោ ដូ ខាក់ម៉ៃ(Đỗ Khắc Mai)នាយសេនាធិការកងទ័ពអាកាសនៃសាធារណរដ្ឋវៀតណាម ធ្វើរដ្ឋប្រហារទម្លាក់ ង៉ូ ឌិញយៀម។ នៅថ្ងៃទី១៦ ខែមិថុនា តំណាងពុទ្ធសាសនិក និងរដ្ឋាភិបាល បានឈានដល់ការព្រមព្រៀងគ្នាថា ទង់ពុទ្ធសាសនាក៏ដូចទង់សាសនាផ្សេងៗទៀតដែរ ត្រូវបានគោរពជានិច្ច ហើយអាចលើកបាននៅកន្លែងសមរម្យណាមួយ។

ជាមួយគ្នានោះ រដ្ឋសភានឹងលើកយកបញ្ហាអនុក្រឹត្យលេខ១០ មកធ្វើការពិគ្រោះយោបល់គ្នា ដើម្បីបង្កើតគោលការណ៍ណែនាំថ្មីដែលសមស្របទៅនឹងសកម្មភាពរបស់ពុទ្ធ-

សាសនា។ ទន្ទឹមនឹងនោះ ភាគីទាំងពីរបានយល់ព្រមគ្នាបង្កើតគណៈកម្មការស៊ើបអង្កេតមួយ ដើម្បីពិនិត្យឡើងវិញពីករណីបាញ់សម្លាប់អ្នកតវ៉ា៩នាក់នៅក្រុងវ៉េកន្លងទៅ ហើយប្រធានាធិបតី ង៉ូ ឌិញយៀម យល់ព្រមលើកលែងទោស និងដោះលែងអ្នកតវ៉ាជាពុទ្ធសាសនិកទាំងអស់វិញដែរ។

កិច្ចព្រមព្រៀងបានចែងបន្តថា រាល់សកម្មភាពសាសនាធម្មតា និងសុទ្ធសាធនៅក្នុងវត្ត ឬនៅទីស្នាក់ការកណ្តាលនៃសមាគមពុទ្ធសាសនិកទូទៅ អាចដំណើរការបាន ដោយមិនចាំបាច់មានការអនុញ្ញាតពីអាជ្ញាធរ។

ព្រះតេជគុណ ធិច ទីញខៀត (Thích Tịnh Khiết) បានថ្លែងអំណរគុណប្រធានាធិបតីង៉ូ ឌិញយៀម ដោយជឿជាក់ថា ក្រោយពីមានកិច្ចព្រមព្រៀងនេះទៅ អាជ្ញាធរនឹងគ្មានសម្ពាធអ្វីមកលើសហគមន៍ពុទ្ធសាសនិកទៀតទេ ហើយព្រះអង្គបានអំពាវនាវឱ្យសហគមន៍ពុទ្ធសាសនិករក្សាភាពស្ងប់ស្ងាត់ វិលទៅរកជីវភាពធម្មតាវិញ និងបួងសួងសុំឱ្យកិច្ចព្រមព្រៀងនេះអនុវត្តដោយជោគជ័យទៀតផង។ តែទោះជាយ៉ាងណាក៏ដោយ ក៏ព្រះសង្ឃវ័យក្មេងៗមួយចំនួន ដូចជា ធិច ទ្រីក្វាង (Thich Trí Quang) គ្មានជំនឿទៅលើការចរចានោះឡើយ ព្រោះគិតថាប្រធានាធិបតី ង៉ូ ឌិញយៀម នឹងមិនគោរពតាមកិច្ចព្រមព្រៀងនោះឡើយ។

ថ្ងៃបន្ទាប់ ទោះបីជាមានការព្រមព្រៀងគ្នាក៏ដោយ ក៏នៅខាងក្រៅរបងវត្តសាឡើយ (Xá Lợi) មានហ្វូងបាតុករជាពុទ្ធសាសនិកប្រមាណ២០០០នាក់កំពុងប្រឈមមុខជាមួយកម្លាំងប៉ូលិស និងកងទ័ពដែរ។ នៅទីបំផុត សកម្មភាពកុបកម្មមួយបានផ្ទុះឡើង កម្លាំងប៉ូលិស និងកងទ័ពបានវាយប្រហារទៅលើហ្វូងបាតុករដោយឧស្ម័នបង្ហូរទឹកភ្នែក បំពង់ ពន្លត់អគ្គីភ័យ និងការបាញ់កាំភ្លើង បណ្តាលឱ្យបាតុករម្នាក់ត្រូវបាត់បង់ជីវិត និងច្រើននាក់ទៀតរងរបួស។ រដ្ឋការង៉ូ ឌិញយៀម បានស្តីបន្ទោសព្រឹត្តិការណ៍នេះថា "អំពីកុបកម្មនេះ គឺពួកពុទ្ធសាសនិកជ្រុលនិយម ជាអ្នកបង្កឡើង" ។

ចំណែកសារព័ត៌មានAP (Associated Press) បានចុះផ្សាយថា បើទោះបីមានកិច្ចព្រមព្រៀងហើយក៏ដោយ អំពីកុបកម្មប្រឆាំងរដ្ឋាភិបាល និងការបង្ក្រាបដ៏ឃោរឃៅបំផុត



**សង្ឃធិច ទ្រីក្វាង**

នៅក្នុងប្រទេសវៀតណាមខាងត្បូង នៅតែកើតមានបន្តទៀត ហើយអ្នកតវ៉ាជាច្រើននាក់នៅតែជាប់ពន្ធនាគារដដែល។ ដោយសារតែការបរាជ័យក្នុងការអនុវត្តកិច្ចព្រមព្រៀងនោះ ព្រះសង្ឃវ័យក្មេង ធិច ទ្រីក្វាង (Thich Trí Quang) ដែលកាន់តែលេចធ្លោនៅក្នុងសហគមន៍ពុទ្ធសាសនិកនោះ បានចេញមុខដឹកនាំធ្វើបាតុកម្មយ៉ាងគគ្រឹកគគ្រេង ដោយបន្ទោសប្រធានាធិបតី ង៉ូ ឌិញយៀម ថា ជាអ្នកធ្វើឱ្យជាប់គាំងការអនុវត្តកិច្ចព្រមព្រៀងនោះ និងទាមទារឱ្យមានការផ្លាស់ប្តូររដ្ឋាភិបាល ង៉ូ ឌិញយៀម ចេញទៀតផង។

បន្ទាប់ពីធ្វើពិធីបុណ្យសពព្រះតេជគុណ ធិច ក្វាងឌឹក (Thích Quảng Đức) រួចមក ព្រះតេជគុណ ធិច ទីញខៀត (Thích Tịnh Khiết) តំណាងសហគមន៍ពុទ្ធសាសនិកទូទាំងប្រទេស បានចោទប្រកាន់រដ្ឋាភិបាលមិនគោរពតាមកិច្ចព្រមព្រៀងនេះ ទើបធ្វើឲ្យពុទ្ធសាសនិកនៅវៀតណាមខាងត្បូង កាន់តែរងទុក្ខទៅៗ។ តែអនុប្រធានាធិបតី ង្វៀន ង៉ុកថឺ បានបដិសេធការចោទប្រកាន់នេះ ហើយថា ពួកវៀតកុងបានជ្រៀតចូលក្នុងចលនាបះបោររបស់

ពុទ្ធសាសនិក ហើយបានបំប្លែងពុទ្ធសាសនិកឲ្យទៅជាអង្គការនយោបាយទៅវិញ។

ចំណែកប្រធានាធិបតី ង៉ូ ឌិញយៀម បានថ្លែងប្រាប់ក្រុមអ្នកកាសែតថា គឺពួកគេវាំជាពុទ្ធសាសនិកទេ ដែលមិនគោរពតាមកិច្ចព្រមព្រៀងនោះ។ ជាមួយគ្នានោះ អង្គការយុវជនសាធារណរដ្ឋដែលគាត់ជាបង្កើតឡើងនោះ បានប្រកាសអំពាវនាវ ឲ្យប្រជាជនវៀតណាមទាំងអស់ក្រោកឡើងទប់ទល់នឹងពួកពុទ្ធសាសនិកដែលពួកគេចាត់ទុកថាជាពួកជ្រុលនិយមបម្រើនយោបាយឱ្យកុម្មុយនិស្ត និងអំពាវនាវឱ្យរដ្ឋាភិបាលបដិសេធកិច្ចព្រមព្រៀងនោះចោលវិញ ព្រមទាំងហៅពុទ្ធសាសនិកថា ជាពួកឧទ្ទាមកុម្មុយនិស្តទៀតផង។ មិនតែប៉ុណ្ណោះ នៅដំណាច់ខែមិថុនានោះដែរ រដ្ឋាភិបាល ង៉ូ ឌិញយៀម ថែមទាំងប្រកាសថា មុនពេលធ្វើអត្តឃាតដុតបូជាព្រះកាយនោះ ព្រះតេជគុណ ធិច ក្វាងឌឹក( Thích Quảng Đức )ត្រូវបានគេដាក់ថ្នាំសណ្តំរួចទៅហើយ។ តែយ៉ាងណា របាយការណ៍របស់ក្រសួងការបរទេសសហរដ្ឋអាមេរិកបានសន្និដ្ឋានថា ការរំជើបរំជួលខាងសាសនានៅប្រទេសវៀតណាមខាងត្បូងនេះ មិនមែនបង្កឡើង ដោយពួកកុម្មុយនិស្តនោះទេ។

សូមរង់ចាំអានភាគ៤ បន្តទៀត
សូមអរគុណ

# ឯកសារយោង ៖


1. Le Cambodge de Sihanouk Espoir, Désillusions et Amertume. par Richard Sola .
2. Le mal Cambodge Histoire D´une société traditionnelle Face à ses Leaders Politiques 1946 – 1987. par Marie Alexandrine Martin .
3. Pol Pot Frère Numéro Un. par Davidp – Chandler.
4. Le Cambodge dans la tourmente: Le troisième conflit indochinois, 1978-1991. par Nicolus Regaud .
5. Cambodge : Rêves et Réalités. par Vandy Kaonn.
6. Histoire du Cambodge 1863 – 1992. par Vandy Kaonn .
7. Cambodia: Year Zero by Francois Ponchaud
8. Hun Sen strongman of Cambodia. by Harrish C. Metha Julie B. metha.
9. When the War Was Over by Elizabeth Becker
10. How Pol Pot to come Power. By Ben Kiernan .
11. Wikipedia The free encyclopedia .
12. Wikipedia Org. wiki.
13. DP. Pedia org. page.
14. Wikiwand.
15. U.S. Embassy in Cambodia document.
16. Cold war international history Project.
17. The New York Times newspaper.
18. Times Magazine.
19. The Far Eastern Economic Review Magazine.
20. Le Figaro newspaper.

21. Le Monde newspaper.

22. Les Echos newspaper.

23. Le Parisien newspaper.

24. L´ humanite newspaper.

25. Liberation newspaper.

26. Washington Post newspaper.

27. Pol Pot by Philip Short.

28. The Gate by Francois Bizot.

29. Haing Ngor: A Cambodian Odyssey by Haing S. Ngor with Roger Warner.

30. My War With the CIA by Norodom Sihanouk .

31. War and Hope: The Case for Cambodia by Norodom Sihanouk .

32. Flying Tigers Over Cambodia by Larry Partridge.

33. The United States and Cambodia, 1870-1969 By Kenton Clymer.

34 .L´histoire terrible mais inachevée de Norodom Sihanouk, roi du Cambodge (THEATRE) (French Edition).

35. Souvenir doux et amers  par Norodom Sihanouk.

36. គុកនយោបាយ  ដោយ ប៊ុណ្ណ ចន្ទម៉ុល.

37. ឧត្តមគតិ លោកអៀវ កើស ដោយ ង៉ែត ហៀង.

38. លោកព្រឹទ្ធាចារ្យ បណ្ឌិតជួន មុម្ម ដោយបណ្ឌិតពុទ្រី ទត់.

39. ជីវប្រវត្តិសង្ខេប ប៉ែន សុវណ្ណ និងបុព្វហេតុជាតិមាតុភូមិកម្ពុជា ដោយប៉ែន សុវណ្ណ និងនាង សារ៉ុន.

40. Des racines dans la pierre par Sam raingsy

# ជីវប្រវត្តិសង្ខេបរបស់អ្នកសិក្សាស្រាវជ្រាវ



**រូបថត ឆ្នាំ១៩៨៥**



**រូបថត បច្ចុប្បន្ន**

ឈ្មោះ **ឈឹម សេរីឆ្លួន** កើតថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៥៤ ។ ឪពុកឈ្មោះ **ឈឹម ប៉ាវ** មានស្រុកកំណើតនៅខេត្តព្រៃវែង មុខរបរជាអ្នកថែសួននៅមន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត។ ម្តាយឈ្មោះ **ទេព ឌុន** មានស្រុកកំណើតនៅខេត្តស្វាយរៀង មុខរបរជាមេផ្ទះ។ មានបង៣នាក់(ស្រី១ប្រុស២) និងប្អូន៣នាក់(ស្រី២ប្រុស១)។

ឆ្នាំ១៩៦២ - ៦៣ ចូលរៀនថ្នាក់ទី១២ សាលាបឋមសិក្សាឯកជនសង្គមមានជ័យ នៅម្តុំខាងក្រោយ សាលាបច្ចេកទេសថៃទាំវេជ្ជសាស្ត្រសព្វថ្ងៃ ។

ឆ្នាំ១៩៦៣ - ៦៩ រៀននៅសាលាបឋមសិក្សាចង្ក្រានតាព្រហ្មមានជ័យ (វត្តចង្ក្រានតាព្រហ្មស្ទឹងមានជ័យ)

ឆ្នាំ១៩៦៩ - ៧៤ រៀននៅវិទ្យាល័យឥន្ទ្រទេវី (វិទ្យាល័យទួលគោក)

ឆ្នាំ១៩៧៤ - ៧៥ រៀនថ្នាក់ទីបញ្ចប់ផ្នែកទស្សនវិជ្ជា នៅវិទ្យាល័យកែវ សង់គីម (វិទ្យាល័យ១៨មីនា ១៩៧០ ឬវិទ្យាល័យព្រះយុគន្ធរ)។

ក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ត្រូវជម្លៀសជាមួយក្រុមគ្រួសារទៅរស់នៅក្នុង

សង្កាត់ព្រៃរំដេង ស្រុកមេសាងតំបន់២០ ភូមិភាគបូព៌ា។

ដើមឆ្នាំ១៩៧៦ ត្រូវជម្លៀសបន្តតែម្នាក់ឯង ទៅរស់នៅក្នុងសង្កាត់តាប្រ៉ុក ស្រុកចម្ការលើ តំបន់៤២ ភូមិភាគឧត្តរ (ក្រោយមក នៅឆ្នាំ ១៩៧៧ ដូរឈ្មោះជាភូមិភាគកណ្តាល) ហើយត្រូវពួកខ្មែរក្រហមបញ្ចូលជាកងចល័តតំបន់៤២ រហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។

ឪពុកម្តាយ និងបងប្អូនបង្កើតទាំង៦នាក់ ព្រមទាំងក្មួយៗប្រមាណ១០នាក់ទៀត ត្រូវពួកខ្មែរក្រហមប៉ុល ពត សម្លាប់ចោលទាំងអស់ កាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

**ពីឆ្នាំ១៩៧៩ ដល់ដើម១៩៩៣ ៖**

-បម្រើការងារជា ជាបុគ្គលិករដ្ឋ នៅស្រុកមេសាង ខេត្តព្រៃវែង។

-ឆ្នាំ១៩៩៣ ជាជំនួយការមន្ត្រីរៀបចំការបោះឆ្នោតអ៊ុនតាក់(UNTAC)ប្រចាំស្រុកមេសាង ខេត្តព្រៃវែង។

-ឆ្នាំ១៩៩៤ ជាមន្ត្រីនគរបាលនៅនាយកដ្ឋានជនបរទេស អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ។

**ពីឆ្នាំ១៩៩៥ ដល់ឆ្នាំ២០២១៖**

-ជាអ្នកនិពន្ធអត្ថបទវិភាគនយោបាយឱ្យកាសែតចក្រវាឡ កាសែតអរិយធម៌ កាសែតសំឡេងនិស្សិត ទស្សនាវដ្តីកងរាជអាវុធហត្ថរាជធានីភ្នំពេញ។

-ជានិពន្ធនាយកទស្សនាវដ្តីអង្គរធំ, ជានិពន្ធនាយកទស្សនាវដ្តីខេមរា, ជានិពន្ធនាយកទស្សនាវដ្តីសោភ័ណ, ជានិពន្ធនាយករងទស្សនាវដ្តីរថយន្ត, ជាទីប្រឹក្សាកាសែតនគរធំ, ជានិពន្ធនាយកគេហទំព័រTVFB, ជានិពន្ធនាយកគេហទំព័រKBN និងជាប្រធានផ្នែកព័ត៌មាន SBM News ។

**UNITED NATIONS**
**UNITED NATIONS TRANSITIONAL AUTHORITY IN CAMBODIA (UNTAC)**

**NATIONS UNIES**
**AUTORITE PROVISOIRE DES NATIONS UNIES AU CAMBODGE (APRONUC)**

# CERTIFICATE OF OUTSTANDING SERVICE

This certifies that Mr. Chhim Sery Phuon worked with UNTAC Electoral Component at the District of Mesang for more than eight months at different capacities. Initially, he was recruited as a Registration Team Leader (RTL) for four months. As he extraordinarily completed his contract as RTL, his contract was extended for two more months as Senior Election Assistant (SEA). Finally, after the completion of his contract as SEA, he was re-employed as a Presiding Officer for UNTAC Election in May 1993 in Combodia.

As a RTL, Mr. Chhim worked out Training Manual in Khemer, Trained the Local Staff about Registration Process and was a Team Leader of Eight other Registration Teams. I was really impressed with Mr. Chhim's training capabilities. Because of his fine training skill, we had no complains from the higher authorities regarding registration, despite complex and long procedures. His profound ability to teach others was also reflected during civic education campaign. He trained all the assistants for civic education regarding Paris Peace Agreement, UNTAC Electoral Law, Human Rights etc. so well that 99.3 % people turned over to express their opinion during the Election. He was the best PO in respect of due completion of all the technicalities during the election.

I am very much impressed of his originality, managerial skill and sincerity at work. In brief, he is a multidimensional personality with whom every one would love to work. I give him my highest regards and wish every success in his future assignments.

Sincerely,

H. Prasad

Hari Prasad, DES
Mesang, Prey Veng
COMBODIA

June 7, '93



# លិខិតថ្លែងអំណរគុណ

ឯកសារប្រវត្តិសាស្ត្រមានចំណងជើងថា **របត់នយោបាយ** ( **សីហនុ - លន់ នល់ - ប៉ុល ពត - ហ៊ុន សែន**) តាំងពីភាគ១ រហូតដល់ភាគ៣នេះ ត្រូវបានបោះពុម្ពជាសៀវភៅ ក្រោមការជួយឧបត្ថម្ភគាំទ្រដ៏ថ្លៃថ្លាពីសំណាក់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។**

អ្វីដែលធ្វើខ្ញុំបាទ ជាអ្នកសិក្សាស្រាវជ្រាវឯកសារប្រវត្តិសាស្ត្រនេះ មានការរំភើបរីករាយ និងមានកិត្តិយសបំផុតនោះ គឺនៅក្នុងលិខិតដាក់ជូនសុំអនុសាសន៍ស្តីពីជម្រើសនៃការបោះពុម្ព **សម្តេចក្រឡាហោម** បានចារបញ្ជាក់មកវិញ ប្រកបដោយគតិបណ្ឌិត និងមនសិការប្រវត្តិសាស្ត្រជាតិ គួរឱ្យគោរពបំផុត ថា៖ ...ជម្រើសណាក៏បាន សំខាន់ចង់បានសៀវភៅប្រវត្តិសាស្ត្រមួយនេះ ទុកឲ្យកូនចៅរៀនសូត្រ ។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណដ៏ជ្រាលជ្រៅ និងសូមប្រសិទ្ធិពរជ័យជូន **សម្តេចក្រឡាហោម** សូមប្រកបដោយពលានុភាពខ្លាំងក្លា បញ្ញាញាណភ្លឺថ្លា សុខភាពល្អបរិបូរណ៍ អាយុយឺនយូរ និងទទួលបានជោគជ័យគ្រប់ភារកិច្ចដឹកនាំប្រទេសជាតិ។

ដោយក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុត

ពីខ្ញុំបាទ **ឈឹម សេរីត្នូន**

9 789924 969808 >